c. khñom mɨn daɛl tɨw srok siem tee (look) — look kɔɔ mɨn daɛl tɨw srok siem daɛ

d. pəpún khñom mɨn coŋ məəl kon nih daɛ (pəpún look) — pəpún look kɔɔ mɨn coŋ məəl kon nih daɛ

e. look mɨn coŋ khcɛy luy khñom tee (pəpún look) — pəpún look kɔɔ mɨn coŋ khcɛy luy khñom daɛ

f. look mian laan ɔŋglee muoy (khñom) — khñom kɔɔ mian laan ɔŋglee muoy daɛ

DRILL TEN: Transformation

MODEL: T: pəpún khñom mɨn coŋ tɨw leeŋ phtéh look tee

S: pəpún khñom koo mɨn coŋ tɨw, khñom koo mɨn coŋ tɨw

T: My wife doesn't want to go visit your house.

S: My wife doesn't want to go; I don't want to go either.

| | | |
|---|---|---|
| a. | look pərien l?ɔɔ nah | look pərien koo l?ɔɔ, khñom pərien koo l?ɔɔ |
| b. | look kruu pəñap tɨw phtéh | look kruu koo pəñap tɨw, khñom koo pəñap tɨw |
| c. | look mɨn móo rien | look koo mɨn móo rien, khñom koo mɨn móo rien |
| d. | pəpún khñom coul cət baay cən nah | pəpún khñom koo coul cət, khñom koo coul cət |
| e. | look tɨw məəl kón | look koo tɨw məəl, khñom koo tɨw məəl |
| f. | niaŋ daə tɨw phtéh | niaŋ koo daə, khñom koo daə |

DRILL ELEVEN: Response

MODEL: **T: ŋay naa khlah look mɨn tɨw thəə kaa? (ŋay saw nɨŋ ŋay aatɨt) [Saturday] [Sunday]

S: ŋay saw nɨŋ ŋay aatɨt khñom mɨn tɨw thəə kaa tee

T: What days don't you go to work?

S: I don't go to work on Saturday and Sunday.

| | | | |
|---|---|---|---|
| *a. | s?aɛk cia ŋay ɛy? | (ŋay ŋkia) [Tuesday] | s?aɛk cia ŋay ŋkia |
| *b. | look coŋ chup thəə kaa pii ŋay naa tɨw? | (ŋay pəhoh) [Thursday] | khñom coŋ chup thəə kaa pii ŋay pəhoh tɨw |
| *c. | look tɨw nuu yɔɔk pii ŋkaal? | (ŋay can mun) [Monday] | khñom tɨw nuu yɔɔk ŋay can mun |
| **d. | look pərien taɛ ŋay naa khlah? | (ŋay put nɨŋ ŋay sok) [Wednesday] [Friday] | khñom pərien taɛ ŋay put nɨŋ ŋay sok |
| e. | look trəw tɨw pɛɛt ŋkaal? | (ŋay sok prɨk) | khñom trəw tɨw pɛɛt ŋay sok prɨk |
| f. | ŋay naa look mɨn coul cət móo rien? | (ŋay can) | ŋay can khñom mɨn coul cət móo rien |

DRILL TWELVE: Response

MODEL: ** T: ŋkaal look kaa pəpún? (khaɛ meesaa rɨɨ ohsəphia)
[April] [May]

S: khñom kaa pəpún nɨw khaɛ meesaa rɨɨ ohsəphia

T: When will you get married?

S: I'll get married in April or May.

a. ŋkaal look rien cɔp? (sɛyhaa) [August] khñom rien cɔp nɨw khaɛ sɛyhaa

b. ŋkaal look dəŋ thaa pəpún look móo leeŋ look? (pəhaɛl khaɛ tu?laa) [October] khñom dəŋ thaa pəpún khñom móo leeŋ khñom pəhaɛl khaɛ tu?laa

c. look tiñ laan look pii khaɛ naa? (komphé?) [February] khñom tiñ laan khñom pii khaɛ komphé?

d. kaññaa móo rien khmaɛ pii khaɛ naa? (viccəkaa) [November] khñom móo rien khmaɛ pii khaɛ viccəkaa

e. look rien khmaɛ pii khaɛ naa tɨw khaɛ naa? (khaɛ thnuu tɨw khaɛ mi?thu?naa) [December] [June] khñom rien khmaɛ pii khaɛ thnuu tɨw khaɛ mi?thu?naa

f. knoŋ khaɛ naa look chup rien mə aatɨt? (ka?kədaa) [July] knoŋ khaɛ ka?kədaa khñom chup rien mə aatɨt

Reading Passage

សុខគិតនឹងធ្វើ

កាលសុខនៅក្មេង វានៅជាមួយលោកចៅហ្វាយខេត្តម្នាក់នៅខេត្តតាកែវ។ កាលនោះសុខមិនសូវធ្វើការច្រើនទេ គ្រាន់តែជួយលើកម្ហូបទៅជូនលោកចៅហ្វាយខេត្តនៅពេលបាយ ហើយឈរនៅជិតគាត់ ដើម្បីមើលក្រែងគាត់ត្រូវការអ្វីៗ។

លោកចៅហ្វាយខេត្តមានអ្នកបម្រើច្រើនដែរ តែគាត់នៅតែខ្វះអ្នកធ្វើការឲ្យគាត់។ គាត់មានការច្រើនណាស់ ច្រើនដល់ទៅសុខទៅជាជិតដូចអ្នកបម្រើដែរ។

តាមសុខឃើញ លោកចៅហ្វាយខេត្តនិងគ្រួសារគាត់ស្រួលណាស់។ ម្នាក់ៗគ្មានធ្វើអ្វីទេ សូម្បីតែទៅយកទឹកនៅចម្ងាយប្រហែល ១ម៉ែត្រពីខ្លួនមកញ៉ាំខ្លួនឯង ក៏មិនទៅយកខ្លួនឯងដែរ។ ហើយគេមានអំណាចណាស់ដែរ។

ដូច្នេះរឿងទាំងប៉ុន្មាននោះ ធ្វើឲ្យសុខគិតច្រើនណាស់។ ហើយកាលនោះវាយល់ថា ធ្វើចៅហ្វាយខេត្តស្រួល ហើយមានអំណាចណាស់ ហើយនឹងសប្បាយណាស់ដែរ។ យល់ដូច្នេះហើយ វាសម្រេចចិត្តថា វានឹងខំរៀនក្រែងបានធ្វើចៅហ្វាយខេត្ត។

តាំងពីពេលនោះមក សុខខំរៀនណាស់ គឺវាមិនដែលភ្លេចថាវាបានសម្រេចចិត្តថាវាត្រូវខំរៀនទេ។ តែរឿងធ្វើចៅហ្វាយខេត្តវាដូចជាមិនសូវគិតទេ ព្រោះវាយល់ថាធ្វើចៅហ្វាយខេត្តត្រូវចេះអំពីនយោបាយ។ តែសុខមិនចូលចិត្តនយោបាយទេ ហើយវាមិនសូវយល់អំពីនោះថែមទៀតផង។ ម្យ៉ាងទៀត វាយល់ថាធ្វើចៅហ្វាយខេត្តមិនសូវសំខាន់ទេ បើធ្វើគ្រូបង្រៀនវិញ ដូចជាសំខាន់ជាង។

## VOCABULARY

| | | |
|---|---|---|
| coul leeŋ | ចូលលេង | to drop in, to pay a visit |
| dɔl tɨw | ដល់ទៅ | to the point that (R) |
| kaa | ការ | to marry, to get married |
| kaa pdɛy | ការប្ដី | to get married |
| kaa pəpùn | ការប្រពន្ធ | to get married |
| ləək | លើក | to carry, to lift (R) |
| look mənéʔ | លោកម្នាក់ | a man, a gentleman (L) |
| mɛɛn-əh | មែនឬ | is that right?, that's right |
| mənéʔ mənéʔ | ម្នាក់ៗ | every one of them (R) |
| məyaaŋ tiet | ម្យ៉ាងទៀត | furthermore (R) |
| muk cia | មុខជា | certainly, definitely; will |
| ŋay saw kraoy | ថ្ងៃសៅរ៍ក្រោយ | next Saturday |
| néʔ bɔmrae | អ្នកបំរើ | servant (R) |
| neyoobaay | នយោបាយ | politics (R) |
| pəkɔt | ប្រាកដ | certain |
| pəñap | ប្រញាប់ | to be in a hurry |
| prap | ប្រាប់ | to tell |
| səbaay cət | សប្បាយចិត្ត | to be happy (L) |
| səmrac cət | សម្រេចចិត្ត | to decide (R) |
| som tooh | សុំទោស | excuse me |
| soumbɛy...kɔɔ | សូម្បី... ក៏ | even... (R) |
| téŋ pəmaan | ទាំងប៉ុន្មាន | all (of them) (R) |
| tɨw tiet | ទៅទៀត | even more (L) |

| DAYS OF WEEK | | | | NAMES OF MONTHS | |
|---|---|---|---|---|---|
| ŋay aatɨt | ថ្ងៃអាទិត្យ | Sunday | (ខែ) មករា | (khaɛ) méʔkəraa | January |
| ŋay can | ថ្ងៃច័ន្ទ | Monday | (ខែ) កុម្ភៈ | (khaɛ) komphéʔ | February |
| ŋay ŋkia | ថ្ងៃអង្គារ | Tuesday | (ខែ) មិនា | (khaɛ) miinaa | March |
| ŋay put | ថ្ងៃពុធ | Wednesday | (ខែ) មេសា | (khaɛ) meesaa | April |
| ŋay pəhoh | ថ្ងៃព្រហស្បតិ៍ | Thursday | (ខែ) ឧសភា | (khaɛ) ohsəphia | May |
| ŋay sok | ថ្ងៃសុក្រ | Friday | (ខែ) មិថុនា | (khaɛ) miʔthuʔnaa | June |
| ŋay saw | ថ្ងៃសៅរ៍ | Saturday | (ខែ) កក្កដា | (khaɛ) kaʔkədaa | July |
| | | | (ខែ) សីហា | (khaɛ) sɛyhaa | August |
| | | | (ខែ) កញ្ញា | (khaɛ) kaññaa | September |
| | | | (ខែ) តុលា | (khaɛ) tulaa | October |
| | | | (ខែ) វិច្ឆិកា | (khaɛ) viccəkaa | November |
| | | | (ខែ) ធ្នូ | (khaɛ) thnuu | December |

## LESSON THIRTY-ONE

## DIALOGUE

| | | | |
|---|---|---|---|
| | | ក្រូច | orange, citrus fruit |
| | | ឡូ | dozen |
| ១. | គុម | ក្រូចហ្នឹងមួយឡូថ្លៃប៉ុន្មាន? | How much does a dozen of these oranges cost? |
| | | ដែល | which, that (relative pronoun) |
| | | បៃតង | green |
| ២. | សិន | អាហ្នឹងលក់តាមគីឡូ តែ អាបៃតងទេ ដែលខ្ញុំលក់ តាមឡូ។ | Those are sold by the kilo; it's only the green ones that I sell by the dozen. |
| ៣. | គុម | មួយគីឡូថ្លៃប៉ុន្មាន? | How much do they cost a kilo? |
| ៤. | សិន | បាទ មួយគីឡូថ្លៃសែសិប | Forty (riels) a kilo. |
| | | ថ្លឹង | to weigh(transitive) |
| | | រើស | to choose |
| | | ផ្អែម | sweet |
| | | ស្រស់ | fresh |
| ៥. | គុម | ថ្លឹងឲ្យខ្ញុំពីរគីឡូមក រើសអាណាផ្អែមៗ ហើយ ស្រស់ផង។ | Weigh me out 2 kilos. Select the sweet ones and (make them) fresh, too. |
| | | ផ្លែឈើ | fruit |
| | | ព្រួយ | to worry |
| | | សុទ្ធតែ | all, exclusively |
| | | ជានិច្ច | always |
| ៦. | សិន | បាទ សូមកុំព្រួយ ផ្លែឈើខ្ញុំ សុទ្ធតែស្រស់ជានិច្ច។ លោកចង់ទិញអីទៀតទេ? | Don't worry. All of my fruit is always fresh. Do you want to buy anything else? |
| | | ក្រូចឃ្វិច | tangerine |
| ៧. | គុម | លោកដឹងកន្លែងណាដែល គេលក់ក្រូចឃ្វិចទេ? | Do you know any place that sells tangerines? |
| ៨. | សិន | បាទ មានច្រើនណាស់នៅ ក្នុងផ្សារហ្នឹង។ | Yes, there are many in this market. |

DIALOGUE:

1. tom - krouc nɨŋ mə lou thlay pəmaan?

2. sin - aa nɨŋ lúʔ taam kəlou taɛ aa baytɔɔŋ tee daɛl khñom lúʔ taam lou

3. tom - mə kəlou thlay pəmaan?

4. sin - baat, mə kəlou thlay saɛ səp

5. tom - thləŋ aoy khñom pii kəlou mɔ́o. rəəh aa naa phʔaɛm phʔaɛm haəy nɨŋ srɔh phɔɔŋ

6. sin - baat, som kom pruoy. phlaɛ chəə khñom sot taɛ srɔh cia nic. look cɔŋ tiñ ɛy tiet tee?

7. tom - look dəŋ kəlaɛŋ naa daɛl kee lúʔ krouc khvic tee?

8. sin - baat, mian craən nah nɨw knoŋ phsaa nɨŋ

NOTES

DIALOGUE

SENTENCE NO.

2. តាម /taam/ is 'to follow,' but as a phrase relator it means 'according to.' It is used in this sentence as 'according to weight, by the kilo' or in the sense of 'according to (my) opinion,' e.g.

តាមខ្ញុំយើងត្រូវបត់ឆ្វេង។
taam khñom yəəŋ trəw bɔt chveeŋ
According to me, we should have turned left.

2. You have already seen that a clause can be attributive to a noun without a word corresponding to 'which, that' between the noun and the clause, e.g.

នេះជាហាងយើងរក។
nih cia haaŋ yəəŋ rɔ́o
This is the store we're looking for.

Frequently, however, the word ដែល /daɛl/ 'which, that' introduces the clause. The above example could also be:

នេះជាហាងដែលយើងរក។
nih cia haaŋ daɛl yəəŋ rɔ́o
This is the store that we're looking for.

Note in sentence 7 that ដែល /daɛl/, unlike formal English 'that, which,' need not be subject or object of the following relative clause: literally sentence 7 is 'Do you know of any place which (such that) they sell tangerines?'

5. The final មក /mɔ́o/ is a mild imperative indicating that the direction of the action is towards the speaker. If direction is away from the speaker, the word ទៅ /tɨw/ occurs in the sentence instead of មក /mɔ́o/. Cf. also Drill 4

## DRILLS

DRILL NO.

7. លើកលែងតែ /lǝǝk lɛɛŋ taɛ/ means 'except.'

9. ជានិច្ច /cia nic/ and តែង (តែ) /taɛŋ (taɛ)/ both mean 'always.' However, ជានិច្ច /cia nic/ follows the verb phrase it modifies, while តែង (តែ) /taɛŋ (taɛ)/ is always preverbal and is not used in future contexts.

10. Note the new use of indefinites in the students' sentences of this drill. In this type of sentence, the construction indefinite ដែល /daɛl/ means 'anywhere, wherever; anyone, whoever; any, whichever,' etc., e.g.

    អ្នកណាដែលគ្មានលុយត្រូវខ្ចីពីគេ ។

    né?naa daɛl kmian luy trǝw khcɛy pii kee

    Whoever has no money must borrow.

## DRILLS

DRILL ONE: Response

MODEL: T: លោកលក់ក្រូចហ្នឹងយ៉ាងម៉េច? (គីឡូ)

S: ក្រូចហ្នឹងលក់តាមគីឡូ ។

T: How do you sell these oranges? (kilogram)

S: These oranges are sold by the kilo.

ក. លោកលក់ផ្លែឈើហ្នឹងយ៉ាងម៉េច? (ឡូ) ផ្លែឈើហ្នឹងលក់តាមឡូ ។

ខ. លោកលក់ផ្លែទំពាំងបាយជូរហ្នឹងយ៉ាងម៉េច? (គីឡូ) ទំពាំងបាយជូហ្នឹងលក់តាមគីឡូ ។

គ. លោកលក់ស្វាយហ្នឹងយ៉ាងម៉េច? (ឡូ) ស្វាយហ្នឹងលក់តាមឡូ ។

ឃ. លោកលក់ប៉ោមហ្នឹងយ៉ាងម៉េច? (គីឡូ) ប៉ោមហ្នឹងលក់តាមគីឡូ ។

ង. លោកលក់ក្រូចឆ្មាហ្នឹងយ៉ាងម៉េច? (ឡូ) ក្រូចឆ្មាហ្នឹងលក់តាមឡូ ។

ច. លោកលក់ផ្លែស៊ើរីហ្នឹងយ៉ាងម៉េច? (គីឡូ) ផ្លែស៊ើរីហ្នឹងលក់តាមគីឡូ ។

DRILL TWO: Response

MODEL: T: ក្រូចហ្នឹងមួយឡូថ្លៃប៉ុន្មាន? (នោះ)

S: តែក្រូចនោះទេដែលខ្ញុំលក់តាមឡូ ។

T: How much do these oranges cost a dozen? (those)

S: It's only those oranges that I sell by the dozen.

ក. ផ្លែឈើនោះមួយឡូថ្លៃប៉ុន្មាន? (ក្បែរលោក)
តែផ្លែឈើក្បែរលោកទេដែលខ្ញុំលក់តាមឡូ ។

ខ. ទំពាំងបាយជូនេះមួយគីឡូថ្លៃប៉ុន្មាន? (ស)
តែទំពាំងបាយជូរសទេ ដែលខ្ញុំលក់តាមគីឡូ ។

គ. ស្វាយហ្នឹងមួយឡូថ្លៃប៉ុន្មាន? (ទុំសែន)
តែស្វាយទុំសែនទេដែលខ្ញុំលក់តាមឡូ ។

ឃ. ប៉ោមសមួយគីឡូថ្លៃប៉ុន្មាន? (ក្រហម)
តែប៉ោមក្រហមទេដែលខ្ញុំលក់តាមគីឡូ។
ង. ក្រូចឆ្មាហ្នឹងមួយឡូថ្លៃប៉ុន្មាន? (លឿង)
តែក្រូចឆ្មាលឿងទេដែលខ្ញុំលក់តាមឡូ។
ច. ផ្លែស៊ើរីហ្នឹងមួយគីឡូថ្លៃប៉ុន្មាន? (ជិតលោក)
តែផ្លែស៊ើរីជិតលោកទេដែលខ្ញុំលក់តាមគីឡូ។

DRILL THREE: Transformation

MODEL: T: ក្រូចនេះផ្អែមណាស់ (ទិញ)
S: ក្រូចដែលខ្ញុំទិញផ្អែមណាស់។
T: These oranges are very sweet. (buy)
S: The oranges that I buy are very sweet.

ក. សាលាខ្ញុំឆ្ងាយណាស់ (ទៅ) សាលាដែលខ្ញុំទៅឆ្ងាយណាស់។
ខ. កុននោះល្អណាស់ (មើល) កុនដែលខ្ញុំមើលល្អណាស់។
គ. ឡានហ្នឹងថ្លៃណាស់ (ទិញ) ឡានដែលខ្ញុំទិញថ្លៃណាស់។
ឃ. ផ្លែស៊ើរីនោះជោកណាស់ (ឃើញ) ផ្លែស៊ើរីដែលខ្ញុំឃើញជោកណាស់។
ង. ស្វាយនេះជូរណាស់ (ទិញ) ស្វាយដែលខ្ញុំទិញជូរណាស់។
ច. ចំណោទនេះពិបាកណាស់ (ធ្វើ) ចំណោទដែលខ្ញុំធ្វើពិបាកណាស់។

DRILL FOUR: Transformation

MODEL: T: ខ្ញុំយកទំពាំងបាយជូរមួយគីឡូ (ថ្លឹង)
S: ថ្លឹងទំពាំងបាយជូរឲ្យខ្ញុំមួយគីឡូមក។
T: I'll take a kilo of grapes. (weigh out)
S: Weigh out one kilo of grapes for me.

ក. ខ្ញុំយកអាវមួយ (លក់) លក់អាវឲ្យខ្ញុំមួយមក។
ខ. ខ្ញុំត្រូវការតែមប្រាំ (ដូរ) ដូរតែមឲ្យខ្ញុំប្រាំមក។
គ. ខ្ញុំចង់បានស៊ើរីមួយគីឡូ (ថែម) ថែមស៊ើរីឲ្យខ្ញុំមួយគីឡូមក។
ឃ. ខ្ញុំខ្វះសំបុត្រពីរ (សរសេរ) សរសេរសំបុត្រឲ្យខ្ញុំពីរមក។
ង. ខ្ញុំទិញក្រូចមួយឡូ (រើស) រើសក្រូចឲ្យខ្ញុំមួយឡូមក។
ច. ខ្ញុំញ៉ាំស្រាមួយកែវ (ចាក់) ចាក់ស្រាឲ្យខ្ញុំមួយកែវមក។

DRILL FIVE: Extension

MODEL: T: ខ្ញុំយកទំពាំងបាយជូរមួយគីឡូ (ផ្អែមៗ/ស្រស់)
S: រើសទំពាំងបាយជូរផ្អែមៗ ហើយនឹងស្រស់ផង។
T: I'll take a kilo of grapes. (sweet/fresh)
S: Choose the sweet grapes and fresh ones, too.

ក. ខ្ញុំយកអាវមួយ (ស / ដៃវែង)
រើសអាវសហើយនិងដៃវែងផង ។
ខ. ខ្ញុំត្រូវការតែមប្រាំ (ប្រាំមួយសេន / ទើបនឹងចេញ)
រើសតែមប្រាំមួយសេនហើយនិងទើបនឹងចេញផង ។
គ. ខ្ញុំចង់បានស៊ើរីមួយគីឡូ (ជោកៗ / ផ្អែម)
រើសស៊ើរីជោកៗហើយផ្អែម ។
ឃ. ខ្ញុំចង់ទិញស្រាមួយដប (ជោក / ខ្លាំង)
រើសស្រាជោកហើយខ្លាំងផង ។
ង. ខ្ញុំត្រូវការក្រដាសមួយសន្លឹក (ធំ / ស្តើង)
រើសក្រដាសធំហើយនិងស្តើងផង ។
ច. ខ្ញុំយកក្តាមួយសន្លឹក (តូច / ក្រាស់)
រើសក្តាតូចហើយនិងក្រាស់ផង ។

DRILL SIX: Response

MODEL: T: ក្រូចនេះផ្អែមទេ?
S: ក្រូចខ្ញុំសុទ្ធតែផ្អែមទាំងអស់ ។
T: Is this orange sweet?
S: All of my oranges are sweet.

ក. ស្វាយនេះជូរទេ? ស្វាយខ្ញុំសុទ្ធតែជូរទាំងអស់ ។
ខ. តែមនេះចេញថ្មី? តែមខ្ញុំសុទ្ធតែចេញថ្មីទាំងអស់ ។
គ. ក្តានេះស្តើងទេ? ក្តាខ្ញុំសុទ្ធតែស្តើងទាំងអស់ ។
ឃ. អាវនេះសទេ? អាវខ្ញុំសុទ្ធតែសទាំងអស់ ។
ង. កូននេះស្អាតទេ? កូនខ្ញុំសុទ្ធតែស្អាតទាំងអស់ ។
ច. កូនសិស្សនេះពូកែទេ? កូនសិស្សខ្ញុំសុទ្ធតែពូកែទាំងអស់ ។

DRILL SEVEN: Transformation

MODEL: T: ក្រូចខ្ញុំផ្អែមទាំងអស់ (អាមួយជិតលោក)
S: ក្រូចខ្ញុំសុទ្ធតែផ្អែមទាំងអស់ លើកលែងតែអាមួយជិតលោក ។
T: All my oranges are sweet. (the one near you)
S: All of my oranges are sweet, except the one near you.

ក. អាវខ្ញុំសទាំងអស់ (អាមួយខ្ញុំពាក់នេះ)
អាវខ្ញុំសុទ្ធតែសទាំងអស់ លើកលែងតែអាមួយខ្ញុំពាក់នេះ ។
ខ. ក្តាខ្ញុំក្រាស់ទាំងអស់ (មួយសន្លឹកលោកទិញ)
ក្តាខ្ញុំសុទ្ធតែក្រាស់ទាំងអស់ លើកលែងតែមួយសន្លឹកលោកទិញ ។
គ. ទំពាំងបាយជូរខ្ញុំជូរទាំងអស់ (អាមួយនេះ)
ទំពាំងបាយជូរខ្ញុំសុទ្ធតែជូរទាំងអស់ លើកលែងតែអាមួយនេះ ។

ឃ. បងប្អូនខ្ញុំស្រីទាំងអស់ ( ខ្ញុំ )
បងប្អូនខ្ញុំសុទ្ធតែស្រីទាំងអស់ លើកលែងតែខ្ញុំ។
ង. បងប្អូនខ្ញុំនៅស្រុកខ្មែរទាំងអស់ ( ខ្ញុំ )
បងប្អូនខ្ញុំសុទ្ធតែនៅស្រុកខ្មែរទាំងអស់ លើកលែងតែខ្ញុំ។
ច. ឡាននេះថ្មីទាំងអស់ (អាមួយនៅជិតផ្លូវ)
ឡាននេះសុទ្ធតែថ្មីទាំងអស់ លើកលែងតែអាមួយនៅជិតផ្លូវ។

DRILL EIGHT: Response

MODEL: T: ក្រូចនេះផ្អែមណាស់ (ស្រស់)
S: ក្រូចផ្អែមៗសុទ្ធតែស្រស់ជានិច្ច។
T: This orange is very sweet. (fresh)
S: All the sweet oranges are always fresh.

ក. ឡានលោកល្អណាស់ (ថ្លៃ) ឡានល្អៗសុទ្ធតែថ្លៃជានិច្ច។
ខ. ស្វាយនេះជូរណាស់ (បៃតង) ស្វាយជូរៗសុទ្ធតែបៃតងជានិច្ច។
គ. សាលានេះល្អណាស់ (ថ្លៃ) សាលាល្អៗសុទ្ធតែថ្លៃជានិច្ច។
ឃ. អាវកញ្ញាថ្លៃណាស់ (ល្អ) អាវថ្លៃៗសុទ្ធតែល្អជានិច្ច។
ង. ឡាននេះលឿនណាស់ (ស៊ីសាំងច្រើន)
ឡានលឿនៗសុទ្ធតែស៊ីសាំងច្រើនជានិច្ច។
ច. ផ្លែឈើលោកថ្លៃណាស់ (ស្រស់) ផ្លែឈើថ្លៃៗសុទ្ធតែស្រស់ជានិច្ច។

DRILL NINE: Transformation

MODEL: T: ផ្លែឈើខ្ញុំនៅស្រស់ជានិច្ច។
S: ផ្លែឈើខ្ញុំតែងតែនៅស្រស់។
T: My fruit always stays fresh.
S: My fruit always stays fresh.

ក. ខ្ញុំទៅរៀនអង់គ្លេសជានិច្ច។ ខ្ញុំតែងតែទៅរៀនអង់គ្លេស។
ខ. មុនទៅដេកខ្ញុំផឹកទឹកជានិច្ច។ មុនទៅដេកខ្ញុំតែងតែផឹកទឹក។
គ. ខ្ញុំញ៉ាំបាយព្រឹកជានិច្ច។ ខ្ញុំតែងតែញ៉ាំបាយព្រឹក។
ឃ. ខ្ញុំមើលសៀវភៅនៅពេលព្រឹកជានិច្ច។ ខ្ញុំតែងតែមើលសៀវភៅនៅពេលព្រឹក។
ង. រាល់ល្ងាចខ្ញុំដើរលេងជានិច្ច។ រាល់ល្ងាចខ្ញុំតែងតែដើរលេង។
ច. កាលណាញ៉ាំបាយរួចខ្ញុំមើលកូនជានិច្ច។ កាលណាញ៉ាំរួចខ្ញុំតែងតែមើលកូន។

DRILL TEN: Response

MODEL: T: លោកទិញក្រូចកន្លែងណា? (គេលក់ក្រូចឃ្វិច)
S: ខ្ញុំទិញក្រូចកន្លែងណាដែលគេលក់ក្រូចឃ្វិច។

T: Where do you buy oranges? (they sell tangerines)
S: I buy oranges anywhere they sell tangerines.

ក. យើងទៅញ៉ាំបាយនៅហាងណា? (នៅជិតនេះ)
យើងទៅញ៉ាំបាយនៅហាងណាដែលនៅជិតនេះ។

ខ. យើងទៅលេងនៅកន្លែងណា? (គេមិនទៅ)
យើងទៅលេងកន្លែងណាដែលគេមិនទៅ។

គ. លោកទៅរៀនអង់គ្លេសនៅសាលាណា? (មានកូនសិស្សស្រីច្រើន)
ខ្ញុំទៅរៀនអង់គ្លេសនៅសាលាណាដែលមានកូនសិស្សស្រីច្រើន។

ឃ. លោកចង់ញ៉ាំផ្លែឈើណា? (ខ្ញុំចូលចិត្ត)
ខ្ញុំចង់ញ៉ាំផ្លែឈើណាដែលខ្ញុំចូលចិត្ត។

ង. លោកត្រូវការខ្ទីអាមួយណា? (លោកមិនមើល)
ខ្ញុំត្រូវការខ្ទីអាមួយណាដែលលោកមិនមើល។

ច. លោកចង់ញ៉ាំបារីមួយណា? (ខ្សោយជាងគេ)
ខ្ញុំចង់ញ៉ាំបារីណាដែលខ្សោយជាងគេ។

Reading Passage

ផ្លែឈើស្រុកខ្មែរ

នៅស្រុកខ្មែរយើងមានផ្លែឈើច្រើនដែរ។ ហើយផ្លែឈើជិតទាំងអស់សុទ្ធតែបេះនៅក្នុងស្រុក លើកលែងតែផ្លែឈើខ្លះដូចជាប៉ោម ស៊ើរី និងទំពាំងបាយជូរជាដើម មកពីស្រុកគេឯទៀត។

ផ្លែឈើដែលមកពីស្រុកគេឯទៀតនោះមានលក់នៅផ្សាររាល់រដូវ តែគ្រាន់តែរដូវខ្លះថ្លៃ រដូវខ្លះថោក។

ឯផ្លែឈើដែលមកពីចំការនៅស្រុកយើងវិញមានរាល់រដូវដែរ តែមិនទាំងអស់ទេ គឺផ្លែឈើខ្លះមានតាមរដូវដូចជាស្វាយជាដើម។ ឯផ្លែឈើមានលក់នៅផ្សាររាល់ពេលនោះគឺចេក ក្រូច និងផ្លែឈើច្រើនទៀត។

ធម្មតាផ្លែឈើដែលបេះនៅស្រុកយើងសុទ្ធតែស្រស់ជានិច្ច ហើយផ្អែមផង ព្រោះចំការនឹងផ្សារនៅមិនឆ្ងាយពីគ្នាទេ រួចផ្លែឈើនោះបេះនៅពេលល្មមបរិភោគបានដែរផង។

ប៉ុន្តែមានផ្លែឈើខ្លះដែលមានពណ៌បៃតងជានិច្ចជូរណាស់។ ផ្លែឈើនោះមិនសម្រាប់បរិភោគស្រស់ទេ គឺសម្រាប់ធ្វើម្ហូប។ ហើយផ្លែឈើនេះយើងមិនហៅថាផ្លែឈើទេ តែយើងហៅថាម្ជូរវិញទេ។

ក្រៅពីម្ជូរដែលជាផ្លែឈើពណ៌បៃតងជានិច្ចនោះ មានផ្លែឈើខ្លះទៀតមានពណ៌បៃតងដែរ តែផ្អែមណាស់ដែរ ដូចជាចេក ក្រូចខ្លះ និងស្វាយមួយយ៉ាងនោះជាដើម។

## VOCABULARY

| | | |
|---|---|---|
| ក្រាស់ | krah | thick |
| ក្រូច | krouc | citrus fruit; orange |
| ក្រូចឆ្មា | krouc chmaa | lime, lemon |
| ក្រូចខ្វិច | krouc khvic | tangerine |
| ខុសពី | khoh pii | different from (L)[1] |
| ជានិច្ច | cia nɨc | always |
| ជូរ | cuu | sour |
| ដោយ | daoy | according to, by (L) |
| តែងតែ | taɛŋ taɛ | always |
| ថ្លឹង | thləŋ | to weigh out |
| ទូទៅ | tuu tɨw | (in) general, generally (L) |
| ទំពាំងបាយជូរ | təpéŋ baay cuu | grape |
| បៃតង | baytɔɔŋ | green |
| ប៉ោម | paom | apple |
| បេះ | bɛh | to pick, to pluck (R) |
| ផ្លែ | phlaɛ | fruit |
| ផ្លែឈើ | phlaɛ chəə | fruit |
| ផ្អែម | phˀaɛm | sweet |
| ពុំសែន | pum saɛn | a kind of fragrant tree; a kind of large mango |
| ព្រួយ | pruoy | to worry, to be sad |
| ម្ជូរ | mcuu | sour substance |
| រាប់ | róp | to count |
| លើកលែងតែ | ləək lɛɛŋ taɛ | except |
| សញ្ញា | saññaa | sign (L) |
| ស្តើង | sdaəŋ | thin |
| ស្វាយ | svaay | mango |
| ស៊ីសាំង | sii saŋ | to consume gas |
| សុទ្ធតែ | sot taɛ | all, exclusively |
| សេន | seen | cent |
| ស៊េរី | seerii | cherry |
| ស្តើង | sdaəŋ | thin |
| សំគាល់ | səmkól | to recognize (L) |
| ស្រស់ | sroh | fresh; pretty |
| ឡូ | lou | dozen |

## ADDITIONAL FOOD VOCABULARY

| | | |
|---|---|---|
| ចេក | ceek | banana |
| ដូង | douŋ | coconut |
| ដំឡូង | təlouŋ | potato, tuber |
| ម្នាស់ | mnóh | pineapple |



Streetside market, Phnom Penh

## LESSON THIRTY-TWO

## DIALOGUE

| | | | |
|---|---|---|---|
| ១ | សុខ | ថម មើចង់ញ៉ាំមហូបអី រើសខ្លួនឯងទៅ ។ | Tom, whatever you want to eat, choose yourself. |
| | | ស្រេចតែ | it's up to..., it depends on... |
| ២. | ថម | ទេ ខ្ញុំមិនចេះរើសទេ ស្រេចតែសុខឯងទេ ។ | No, I don't know how to choose, it's up to you. |
| ៣. | សុខ | អញ្ចឹងក៏បាន តែខ្ញុំប្រាប់ ឲ្យហើយ ..... | That's fine, but I'm telling you once and for all... |
| ៤. | ថម | ប្រាប់អី ? | Telling what? |
| | | ហៅ | to call, to order, to invite (non-formal) |
| | | ឆប់ស៊ុយ | chop suey |
| | | ចាវមេង | chow mein |
| ៥. | សុខ | ថាខ្ញុំមិនហៅឆប់ស៊ុយឬ ចាវមេងទេណា ។ | That I will not order chop suey or chow mein. |
| | | ឆ្ងាញ់ | delicious, good-tasting |
| ៦. | ថម | យី អាហ្នឹងហើយឆ្ងាញ់ នោះ ។ | Gee! (but) those are delicious! |
| | | ម្យ៉ាងទៀត ម្យ៉ាងទៀត | another thing, furthermore, in addition, on the other hand |
| | | ស្គាល់ | to know, be acquainted with |
| ៧. | សុខ | បាទ អាមេរិកាំងញ៉ាំតែ អាហ្នឹង ហើយម្យ៉ាងទៀត នៅស្រុកខ្មែរគ្មានឆប់ស៊ុយ ទេ ។ | (But) Americans eat only those, and another thing, in Cambodia there is no chop suey. |

DIALOGUE:

1. sok - tom, mɛc cɔŋ ñam məhoup ɛy rəəh khluon aɛŋ teh
2. tom - eeh, khñom mɨn cɛh rəəh eh, srac taɛ sok aɛŋ teh
3. sok - əñcəŋ kɔɔ baan, taɛ khñom prap aoy haəy...
4. tom - prap ɛy?
5. sok - thaa khñom mɨn haw chop suuy rɨɨ chaaw mɛɛŋ tee naa
6. tom - yii aa nɨŋ haəy chŋañ nuh
7. sok - baat, aamerɨkaŋ ñam taɛ aa nɨŋ, haəy mə yaaŋ tiet nɨw srok khmaɛ kmian chɔɔp suuy tee

## NOTES

## DIALOGUE

SENTENCE NO.

1. The word បាយ /baay/ means 'cooked rice.' As you have seen, it also can be used to mean 'meal' or 'food' in certain contexts. Ordinarily, however, the word that refers to food which is not rice is ម្ហូប /məhoup/. The word ម្ហូប /məhoup/ refers to meat, fish, vegetables, fruits, sweets, and cooked dishes of every sort.

5. The word ហៅ /haw/ means 'to call' in the sense of shouting to someone, of telephoning someone, or of naming someone. It is also the non-formal counterpart of អញ្ជើញ /əñcəəñ/ 'to invite.' (Cf. Drill 6 below and Lesson 29.) It also means 'to order food or drink.'

5. The final particle ណា៎ /naa/ or /nɛɛ/ is an emphatic meaning 'I want to make it perfectly clear' or 'you hear?!' It is extremely common in non-formal, especially intimate, speech. You will hear this particle very frequently when Cambodians talk to their siblings, children, or close friends; it will not often be used with you unless you come to know Cambodians well.

6. Note the use of ហើយ /haəy/ to isolate the nominal that comes before as a clause separate from what follows. ហើយ /haəy/ in this construction is very frequently followed by ដែល /daɛl/ 'which, that,' e.g.,

    សៀវភៅនឹងហើយ(ដែល) យើងត្រូវការឥឡូវ។

    səphɨw nɨŋ haəy (daɛl) yəəŋ trəw kaa ɛyləw

    It's that book that we need now.

   The preceding nominal is translated as 'it's...that...,' the clause following ហើយ(ដែល)/haəy (daɛl)/ is a relative clause attributive to the nominal.

   Notice that ហើយ /haəy/ can be omitted if ដែល /daɛl/ is present, e.g.,

    សៀវភៅនឹងដែលយើងត្រូវការឥឡូវ។

    səphɨw nɨŋ daɛl yəəŋ trəw kaa ɛyləw

    It's that book that we need now.

7. មយ៉ាងទៀត /mə yaaŋ tiet/ means 'furthermore, in addition, another thing.' It also is sometimes used to mean 'on the other hand.'

7. You have already studied two words for 'know': ដឹង /dəŋ/ 'to know (a fact)' and ចេះ /cɛh/ 'to know (how to).' In this lesson is a third word for 'know' ស្គាល់ /skóal/ 'to be acquainted with, to recognize.' When you say 'I know the mayor,' you must use the word ស្គាល់ /skóal/, e.g:

ខ្ញុំស្គាល់មេឃុំ
khñom skɔ́l mee khum
I know (am acquainted with) the mayor.

7. The three main types of cuisine available in Cambodia are French, Chinese, and Cambodian. French cuisine is found only in major urban centers and is too expensive for most Cambodians. Cambodian cooking is found in small roadside eateries, in sidewalk vending establishments, and, of course, in Cambodian homes. There are also two or three restaurants in Phnom Penh that serve Cambodian specialties. However, the great majority of eating places, ranging from sidewalk noodle stands to large, well-known restaurants, offer Chinese food. The Chinese food of Cambodia as well as that of most of Southeast Asia is from the south of China. It is, however, different from the Chinese food with which most Americans are familiar. For one thing, as the dialogue points out, Cambodian Chinese food has no such thing as chop suey. Meat-filled or sweet bean-paste-filled pastries are common, but most common of all are the various kinds of noodle.

The most frequent noodles are long, thin noodles made of flour called គុយទាវ /kuy tiev/, which are normally eaten in a soup with beef, chicken, or pork and garnished with raw bean sprouts. This is one of the most frequent breakfast dishes for Cambodians of every social class and is also a favorite snack eaten at any time of day. Egg noodles are called មី /mii/ and are also a popular snack in soup. Rice flour noodles are called នំបញ្ចុក /num bɔñcok/. They are often served with curries or spiced stews. The last major type of noodle is មីសួ /miisuo/ which are transparent noodles made from mung beans and used as an ingredient in sautés and stews.

## DRILLS

DRILL NO.

3. Note that in this drill ដឹង /dəŋ/ is used for 'to know (a place).' In this case ស្គាល់ /skɔ́l/ 'to be familiar with' could also have been used. However, in most cases ដឹង /dəŋ/ and ស្គាល់ /skɔ́l/ are not interchangeable; in Drill 2 ដឹង /dəŋ/ could not have been used instead of ស្គាល់ /skɔ́l/.

## DRILLS

DRILL ONE: Response

MODEL: T: ខ្ញុំទៅញ៉ាំបាយចិន។ (រើសម្ហូប)

S: លោកចេះរើសម្ហូបចិនទេ?

T: I'm going to eat Chinese food. (select food)

S: Do you know how to select Chinese food?

ក. ខ្ញុំចង់ទៅស្រុកបារាំង (និយាយ) លោកចេះនិយាយបារាំងទេ?

ខ. ខ្ញុំត្រូវទៅមើលឡានខ្ញុំ (ជិះ) លោកចេះជិះឡានទេ?

គ. ល្ងាចនេះខ្ញុំទៅយកឡាន (បើក) លោកចេះបើកឡានទេ?

ឃ. ខ្ញុំទទួលសំបុត្រអង់គ្លេសមួយ (ប្រែភាសា) លោកចេះប្រែភាសាអង់គ្លេសទេ?

ង. ខ្ញុំទើបនឹងទិញសៀវភៅយួនមួយ (មើលភាសា) លោកចេះមើលភាសាយួនទេ?

ច. ខ្ញុំត្រូវទៅរៀនខ្មែរថ្ងៃនេះ (មេរៀន) លោកចេះមេរៀនខ្មែរទេ?

DRILL TWO: Transformation

MODEL: T: ហាងបាយនេះឈ្មោះអង្គរ។

S: លោកស្គាល់ហាងបាយនេះទេ ឈ្មោះអង្គរ?

T: This restaurant is named Angkor.

S: Do you know this restaurant? It's named Angkor.

ក. ខ្ញុំមានពួកម៉ាកម្នាក់ឈ្មោះសុផាត។
លោកស្គាល់ពួកម៉ាកខ្ញុំម្នាក់ទេ ឈ្មោះសុផាត?

ខ. ហាងនេះមានម្ហូបស៊ុបស្ងួយឆ្ងាញ់ណាស់។
លោកស្គាល់ហាងនេះទេ មានម្ហូបស៊ុបស្ងួយឆ្ងាញ់ណាស់?

គ. លោកកនទៅស្រុកបារាំងម្តង។
លោកស្គាល់លោកកនទេ ទៅស្រុកបារាំងម្តង?

ឃ. គាត់នៅផ្លូវនរោត្តម។
លោកស្គាល់គាត់ទេ នៅផ្លូវនរោត្តម?

ង. លោកស៊ុខបង្រៀនខ្មែរនៅសាលាអង្គរ។
លោកស្គាល់លោកស៊ុខទេ បង្រៀនខ្មែរនៅសាលាអង្គរ?

ច. វាមិនចូលចិត្តផ្លែស្វាយនោះ។
លោកស្គាល់វាទេ មិនចូលចិត្តស្វាយនោះ?

DRILL THREE: Transformation

MODEL: T: នៅស្រុកខ្មែរមានកន្លែងដើរលេងច្រើនណាស់ (កន្លែងដើរលេងច្រើន)

S: លោកដឹងកន្លែងដើរលេងច្រើនទេ នៅស្រុកខ្មែរ?

T: In Cambodia, there are many places to stroll around. (many places to stroll around)

S: In Cambodia, do you know many places to stroll around?

ក. ផ្លូវទៅសៀមរាបរកក្រណាស់។ (ផ្លូវស្រួល)
លោកដឹងផ្លូវស្រួលទៅសៀមរាបទេ?
ខ. ខ្ញុំជិះឡានទៅសៀមរាប។ (ឡានណា)
លោកដឹងឡានណាទៅសៀមរាបទេ?
គ. នៅស្រុកខ្មែរអ្នកតែលជោគណាស់។ (អ្នកតែលណាជោគ)
លោកដឹងអ្នកតែលណាជោគទេនៅស្រុកខ្មែរ?
ឃ. ហាងបាយនេះធ្វើម្ហូបឆ្ងាញ់ណាស់។ (ហាងបាយណា)
លោកដឹងហាងបាយណាធ្វើម្ហូបឆ្ងាញ់ទេ?
ង. ហាងនេះលក់សៀវភៅច្រើន។ (ហាងណា)
លោកដឹងហាងណាលក់សៀវភៅច្រើនទេ?
ច. ខ្ញុំចង់ទិញឡាននេះ។ (អ្នកណា)
លោកដឹងអ្នកណាចង់ទិញឡាននេះទេ?

DRILL FOUR: Transformation

MODEL: T: ប្រពន្ធខ្ញុំបង្រៀនខ្មែរនៅសាលាអង្គរ។
S: លោកដឹងថាប្រពន្ធខ្ញុំបង្រៀនខ្មែរនៅសាលាអង្គរទេ?
T: My wife is teaching Cambodian at the Angkor School.
S: Do you know that my wife is teaching Cambodian at the Angkor School?

| | |
|---|---|
| ក. ខ្ញុំត្រូវទៅស្រុកខ្មែរ។ | លោកដឹងថាខ្ញុំត្រូវទៅស្រុកខ្មែរទេ? |
| ខ. លោកស្មិសចេះភាសាច្រើនណាស់។ | លោកដឹងថាលោកស្មិសចេះភាសាច្រើនណាស់ទេ? |
| គ. ខ្ញុំស្គាល់កញ្ញាណាង់ស៊ី។ | លោកដឹងថាខ្ញុំស្គាល់កញ្ញាណាង់ស៊ីទេ? |
| ឃ. មួយថ្ងៃយើងត្រូវរៀនមេរៀនមួយ។ | លោកដឹងថាមួយថ្ងៃយើងត្រូវរៀនមេរៀនមួយទេ? |
| ង. លោកសុខបង្រៀនខ្មែរល្អណាស់។ | លោកដឹងថាលោកសុខបង្រៀនខ្មែរល្អណាស់ទេ? |
| ច. ខ្ញុំទើបនឹងទិញឡានមួយ។ | លោកដឹងថាខ្ញុំទើបនឹងទិញឡានមួយទេ? |
| ឆ. យើងចូលចិត្តញ៉ាំគុយទាវ។ | លោកដឹងថាយើងចូលចិត្តញ៉ាំគុយទាវទេ? |

DRILL FIVE: Response

MODEL: T: លោកចង់ញ៉ាំម្ហូបអ្វីខ្លះ?
S: ស្រេចតែលោកទេ ញ៉ាំម្ហូបអីក៏បានដែរ។
T: What food do you want to eat?
S: It's up to you; any kind of food is fine.

| | |
|---|---|
| ក. លោកចង់មើលកុនអី? | ស្រេចតែលោកទេ មើលកុនអីក៏បានដែរ។ |
| ខ. កញ្ញាចង់ទៅញ៉ាំហាងបាយណា? | ស្រេចតែលោកទេ ញ៉ាំហាងបាយណាក៏បានដែរ។ |

គ. លោកស្រីចង់មើលសៀវភៅណា? — ស្រេចតែលោកទេ មើលសៀវភៅណាក៏បានដែរ។

ឃ. លោកចង់ទៅរង៉ាស់? — ស្រេចតែលោកទេ ទៅរង៉ាស់ក៏បានដែរ។

ង. លោកចង់ឲ្យខ្ញុំបង្រៀនអី? — ស្រេចតែលោកទេ បង្រៀនអីក៏បានដែរ។

ច. យើងចង់ទៅលេងកន្លែងណា? — ស្រេចតែលោកទេ ទៅលេងកន្លែងណាក៏បានដែរ។

DRILL SIX: Substitution

MODEL: T: លោកគ្រូ ខ្ញុំចង់អញ្ជើញសុខឯងទៅញ៉ាំបាយថ្ងៃនេះ (ម៉ៅ)

S: ម៉ៅ ខ្ញុំចង់ហៅម៉ៅឯងទៅញ៉ាំបាយថ្ងៃនេះ។

T: Sok, I want to invite you to go eat today. (Maw)

S: Maw, I want to invite you to go eat today.

ក. ម៉ៅ ខ្ញុំចង់ហៅម៉ៅឯងទៅញ៉ាំបាយថ្ងៃនេះ។ (ម៉ានយាន)

ខ. ម៉ានយាន ខ្ញុំចង់ហៅម៉ានយានឯងទៅញ៉ាំបាយថ្ងៃនេះ។ (សួន)

គ. សួន ខ្ញុំចង់ហៅសួនឯងទៅញ៉ាំបាយថ្ងៃនេះ។ (លោកសំណាង)

ឃ. លោកសំណាង ខ្ញុំចង់ហៅលោកសំណាងទៅញ៉ាំបាយថ្ងៃនេះ។ (សៅ)

ង. សៅ ខ្ញុំចង់ហៅសៅឯងទៅញ៉ាំបាយថ្ងៃនេះ។ (លោកសុខ)

ច. លោកសុខ ខ្ញុំចង់ហៅលោកសុខទៅញ៉ាំបាយថ្ងៃនេះ។

DRILL SEVEN: Transformation

MODEL: T: ខ្ញុំញ៉ាំតែឆុបស្វយទេ (វាឆ្ងាញ់ហើយថោកផង)

S: ខ្ញុំញ៉ាំតែឆុបស្វយទេ ហើយម្យ៉ាងទៀតវាឆ្ងាញ់ហើយថោកផង។

T: I eat only chop suey. (it's tasty and cheap, too)

S: I eat only chop suey; furthermore it's delicious and cheap, too.

ក. ខ្ញុំចូលចិត្តហាងបាយនេះណាស់។ (វានៅជិតផ្ទះខ្ញុំផង)
ខ្ញុំចូលចិត្តហាងបាយនេះណាស់ ហើយម្យ៉ាងទៀតវានៅជិតផ្ទះខ្ញុំផង។

ខ. ខ្ញុំចង់រៀនខ្មែរណាស់។ (ខ្ញុំចង់ទៅស្រុកខ្មែរផង)
ខ្ញុំចង់រៀនខ្មែរណាស់ ហើយម្យ៉ាងទៀតខ្ញុំចង់ទៅស្រុកខ្មែរផង។

គ. ប្រើឡានខ្ញុំប្រយ័ត្នបន្តិច។ (ចាក់សាំងឲ្យខ្ញុំផង)
ប្រើឡានខ្ញុំប្រយ័ត្នបន្តិច ហើយម្យ៉ាងទៀតចាក់សាំងឲ្យខ្ញុំផង។

ឃ. លោកទៅញ៉ាំបាយជាមួយខ្ញុំ។ (ចេញលុយពាក់កណ្ដាលផង)
លោកទៅញ៉ាំបាយជាមួយខ្ញុំ ហើយម្យ៉ាងទៀតចេញលុយពាក់កណ្ដាល។

ង. ខ្ញុំមិនទៅរៀនទេ។ (ខ្ញុំត្រូវទៅទទួលប្រពន្ធខ្ញុំផង)
ខ្ញុំមិនទៅរៀនទេ ហើយម្យ៉ាងទៀតខ្ញុំត្រូវទៅទទួលប្រពន្ធខ្ញុំផង។

ច. យើងទៅញ៉ាំបាយហាង។ (យើងទៅមើលកុនផង)
យើងទៅញ៉ាំបាយហាង ហើយម្យ៉ាងទៀតយើងទៅមើលកុនផង។

DRILL EIGHT: Response

MODEL: T: ខ្ញុំត្រូវចេញលុយទាំងអស់ ។
S: លោកត្រូវចេញលុយពាក់កណ្ដាលបានហើយ ។
T: I have to pay (the whole) check.
S: It's O.K. if you (have to) pay half of the check.

ក. ខ្ញុំត្រូវញ៉ាំស្រាទាំងអស់ ។ — លោកត្រូវញ៉ាំពាក់កណ្ដាលបានហើយ ។
ខ. ខ្ញុំត្រូវរៀនមេរៀនទាំងអស់ ។ — លោកត្រូវរៀនមេរៀនពាក់កណ្ដាលបានហើយ ។
គ. ខ្ញុំយកទាំងអស់ ។ — លោកយកពាក់កណ្ដាលបានហើយ ។
ឃ. ខ្ញុំខ្ចីលុយលោកទាំងអស់ ។ — លោកខ្ចីលុយខ្ញុំពាក់កណ្ដាលបានហើយ ។
ង. ខ្ញុំមើលមេរៀននេះទាំងអស់ ។ — លោកមើលមេរៀននេះពាក់កណ្ដាលបានហើយ ។
ច. ខ្ញុំឲ្យលោកទាំងអស់ ។ — លោកឲ្យខ្ញុំពាក់កណ្ដាលបានហើយ ។

DRILL NINE: Response

MODEL: T: ឡានលោកខូចឯណា? (ផ្លូវ)
S: ឡានខ្ញុំខូចកណ្ដាលផ្លូវ ។
T: Where did your car break down? (street)
S: My car broke down in the middle of the street.

ក. លោកដាក់សៀវភៅឯណា? (តុ) ខ្ញុំដាក់សៀវភៅកណ្ដាលតុ ។
ខ. លោកឈឺអី? (ក្បាល) ខ្ញុំឈឺកណ្ដាលក្បាល ។
គ. លោកឃើញកប៉ាល់ហោះឯណា? (មេឃ) ខ្ញុំឃើញកប៉ាល់កណ្ដាលមេឃ ។
ឃ. លោកអង្គុយម្នាក់ឯងឯណា? (បន្ទប់) ខ្ញុំអង្គុយម្នាក់ឯងកណ្ដាលបន្ទប់ ។
ង. ខ្ញុំដាក់ទឹកនេះឯណា? (ផ្ទះ) លោកដាក់ទឹកនេះកណ្ដាលផ្ទះ ។
ច. លោកទុកលុយឯណា? (តុ) ខ្ញុំទុកលុយកណ្ដាលតុ ។

DRILL TEN:

MODEL: T: លោកទៅធ្វើការម៉ោងប៉ុន្មាន? (ប្រាំបី)
S: ខ្ញុំទៅធ្វើការម៉ោងប្រាំបីកន្លះ ។
T: What time do you go to work? (eight)
S: I go to work at eight-thirty.

ក. លោកនិយាយប៉ុន្មានម៉ោង? (ម៉ោង) ខ្ញុំនិយាយកន្លះម៉ោង ។
ខ. ថ្ងៃនេះកូនសិស្សឈប់ប៉ុន្មាននាក់? (ថ្នាក់) ថ្ងៃនេះកូនសិស្សឈប់កន្លះថ្នាក់ ។
គ. ពីសាលាទៅផ្ទះលោកចម្ងាយប៉ុន្មាន? (គីឡូ) ពីសាលាទៅផ្ទះខ្ញុំចម្ងាយកន្លះគីឡូ ។
ឃ. លោកចង់ទិញទំពាំងបាយជូរប៉ុន្មានគីឡូ? (ពីរគីឡូ)
ខ្ញុំចង់ទិញទំពាំងបាយជូរពីរគីឡូ ។

ង. យប់មិញលោកញ៉ាំស្រាប៉ុន្មានដប? (ដប) យប់មិញខ្ញុំញ៉ាំស្រាកន្លះដប។
ច. លោកចង់ខ្ចីឡានខ្ញុំប៉ុន្មានថ្ងៃ? (ពីរថ្ងៃ) ខ្ញុំចង់ខ្ចីឡានលោកពីរថ្ងៃ។

Reading Passage

## ការទុកម្ហូបអាហារស្រស់

ដោយសារប្រទេសខ្មែរមិនសូវមានទូទឹកកក ហើយបើមានវិញក៏វាថ្លៃៗទៀត ដូច្នេះហើយបានជាគ្រួសារខ្មែរមានការពិបាកក្នុងការទុកម្ហូបឲ្យបានយូរថ្ងៃ។ ស្រីមេផ្ទះត្រូវទៅផ្សារទិញម្ហូបមួយថ្ងៃពីរដងឬបួនកាលតែម្តង។ នៅពេលព្រឹកប្រហែលម៉ោងប្រាំបួន គេទៅផ្សារដើម្បីនឹងទិញសាច់ បន្លែនឹងផ្លែឈើល្មមតែនឹងធ្វើម្ហូបសំរាប់គ្រួសារក្នុងពេលបាយថ្ងៃត្រង់។ នៅពេលថ្ងៃរសៀល ម៉ោងបីឬម៉ោងបួន គេត្រូវទៅផ្សារម្តងទៀត។ តែគ្រួសារខ្លះស្រីមេផ្ទះបានធ្វើម្ហូបទុកសំរាប់ពេលល្ងាចដែរ ដូច្នេះគេគ្រាន់តែកំដៅម្ហូបចាស់ៗនោះ ហើយគេក៏ញ៉ាំទៅ។ ការធ្វើដំណើរទៅផ្សារមួយឬពីរដងយ៉ាងនេះ ហើយនឹងការខ្វះទូទឹកកកធ្វើឲ្យគេមានការពិបាកច្រើន តែផ្ទុយទៅវិញគ្រួសាររបស់គេសប្បាយណាស់ ពីព្រោះគេញ៉ាំម្ហូបអាហារផ្លែឈើសុទ្ធតែស្រស់ទាំងអស់។ សាច់ដូចជាសាច់គោ សាច់ជ្រូកនៅថ្មីៗ បន្លែវិញគេទើបនឹងយកមកពីចំការ ត្រីទើបនឹងចាប់បានហើយនៅរស់ទៀតផង។

VOCABULARY

| | | |
|---|---|---|
| ការ | kaa | the fact that; makes a noun (R) |
| កំដៅ | kəmdaw | to heat something (R) |
| ចាប់ | cap | to catch, to capture (R) |
| ចេញលុយ | cɛñ luy | to pay |
| ឆ្ងាញ់ | chŋañ | delicious |
| ឆាវមេង | chaaw mɛɛn | chow mein |
| ឆុបស៊ុយ | chop suuy | chop suey |
| ជាមិនខាន | cia mɨn khaan | without fail, definitely (L) |
| ឈ្មោះ | chmúh | name |
| តែផ្ទុយទៅវិញ | taɛ phtuy tɨw viñ | on the contrary (R) |
| ទូទឹកកក | tuu tɨk kɔɔˀ | refrigerator (R) |
| ទើប | təəp | to have just + verb (R) |
| ធ្វើដំណើរ | thəə tənaə | to take a trip, to travel (R) |
| បញ្ហា | paññəhaa | problem (L) |
| បញ្ជីមុខម្ហូប | bɔñcii muk məhoup | menu (L) |
| ប្រើ | praə | to use |
| ពាក់កណ្តាល | péˀ kədaal | middle, half |
| ពេញចិត្ត | piñ cət | to be pleased, to be satisfied (L) |
| មួយយ៉ាងទៀត (ម្យ៉ាងទៀត) | mə yaaŋ tiet | another thing, furthermore |
| មេឃ | meek | sky |

| | | |
|---|---|---|
| មេរៀន | meerien | lesson |
| រឹតតែ | rɨt taɛ | increasingly (L) |
| ស្គាល់ | skól | to know, to be acquainted with |
| ស្រីមេផ្ទះ | srɛy mee phtéh | housewife (R) |
| ស្រេចតែ | srac taɛ | it's up to... |
| ហៅ | haw | to call, to order |
| អាហារ | aahaa | food (R) |

## ADDITIONAL FOOD VOCABULARY

| | | |
|---|---|---|
| កាំបិត | kambət | knife |
| ចាន | caan | dish, plate, bowl |
| ចង្កឹះ | cəkəh | chopsticks |
| ឆ្នាំង | chnaŋ | pot, pan, kettle |
| ទឹក | tɨk | water, liquid |
| ទឹកដោះគោ | tɨk dəh koo | milk |
| បាយលីង | baay liiŋ | fried rice |
| សម | sɔɔm | fork |
| ស្ករ | skɔɔ | sugar |
| ស្លាបព្រា | slaap pria | spoon |
| ស្ពៃ | spɨy | any cabbage-like vegetable |
| ស្ពៃក្តោប | spɨy kdaop | cabbage |



Sidewalk cooked meat vendor, Phnom Penh

## LESSON THIRTY-THREE

### DIALOGUE

| | | | |
|---|---|---|---|
| ១. | ថុម | កុំនិយាយច្រើនពេក ឥឡូវញ៉ាំអីខ្លះ ? | Don't talk too much. Now, what do you want to eat? |
| | | ឆា | sauté, stir-fry |
| | | សាច់ | meat |
| | | សាច់គោ | beef |
| | | សណ្ដែក | bean |
| ២. | សុខ | យើងយកឆាសាច់គោសណ្ដែកមួយ ។ | We'll take one order of beef sautéed with beans. |
| | | ស៊ុប | soup |
| ៣. | ថុម | ចុះស៊ុប ? ហើយស្រា ? | What about soup? and liquor? |
| | | បង្កង | lobster |
| | | ចាន | plate, dish, bowl |
| | | ទា | duck |
| | | ខ្វៃ | to roast on a spit |
| ៤. | សុខ | បាទ ហើយឆាបង្កងមួយចាននឹងទាខ្វៃមួយ ។ | Yes, and one dish of sautéed lobster and a roast duck. |
| | | មុខ | face (here, dish - pertaining to a variety of food) |
| ៥. | ថុម | យី ដូចជាច្រើនពេកហើយ យកតែពីរមុខបានហើយ ។ | Gee! it seems like too much already. Take only two kinds (dishes); that'll be fine. |
| ៦. | សុខ | អញ្ចឹងយើងហៅស៊ុបមួយវិញ កុំយកទាខ្វៃអី ។ | So we'll order one (kind of) soup instead. Don't take the roast duck. |
| ៧. | ថុម | ហើយខ្ញុំញ៉ាំវិស្គីមួយកែវ អូ! កុំភ្លេចយកបាយខ្លះផង ។ | And I'll have a whisky. Oh! don't forget some rice, too. |

DIALOGUE:

1. tom - kom niyiey craən peek. ɛyləw ñam ɛy khlah?
2. sok - yəəŋ yóo chaa sac koo sədaɛk muoy
3. tom - coh sup? haəy sraa?
4. sok - baat, haəy chaa pəkooŋ mə caan nɨŋ tia khvay muoy
5. tom - yii douc cia craən peek haəy. yóo taɛ pii muk baan əh
6. sok - əñcəŋ yəəŋ haw sup muoy viñ. kom yóo tia khvay ɛy
7. tom - haəy khñom ñam viiskii mə kaɛv. oh! kom phlic yóo baay khlah phooŋ

## NOTES

## DIALOGUE

2. The main ways of cooking are

ឆា /chaa/ 'to sauté, stir-fry Chinese style'

បំពង /bɔmpóoŋ/ 'to deep fry'

ចៀន /cien/ 'to fry in shallow fat'

អាំង /aŋ/ 'to roast, to broil'

ខ្វៃ /khvay/ 'to roast (on a spit)'

ស្ងោរ /sŋao/ 'to boil, to make into soup, a soup containing boiled meat

ស្ល /slɔɔ/ 'to stew'

សម្ល /sɔmlɔɔ/ 'a stew'

ចំហុយ /cɔmhoy/ 'to steam'

Cambodian food tends to use a lot of fish since it is very plentiful there. Much of the fish is fresh-water fish from the Tonlé Sap, which produces so many fish that Cambodia has been able to export fish in quantity and still have plenty to use at home. When a dish includes a large chunk of meat, it is usually fish which is smoked, steamed, broiled, or stewed. Other types of meat are usually chopped up into small pieces and a little meat is cooked with a lot of vegetable and served with much rice. Beef, chicken, and pork are all common, lamb and mutton are almost never used. Shellfish are eaten on the coast and in Phnom Penh. The more well-to-do the family, the greater the number and quantity of non-rice dishes, and the more meat they contain. Very poor families may have to be content with rice and some preserved fish paste, called ប្រហុក /prɔhok/.

Fresh fruit is plentiful and cheap; it is the usual sweet. In the towns a kind of pudding called សង់ខ្យា /sɔŋkhyaa/, sweetened agar-agar, or candy made of sugar and duck-egg yolk, among others, are also available. Iced tea is very popular in Phnom Penh.

In addition to គុយទាវ /kuy tiev/ 'Chinese noodles' for breakfast or snacks (cf. Lesson 32) Cambodians also like a kind of rice gruel called បបរ /bɔɔbɔɔ/. This rice gruel is sometimes eaten plain but usually spiced and flavored with pieces of meat, especially from the internal organs of pigs. Rice gruel is considered good for infants, invalids, and people with stomach trouble.

In most households cooking is done over wood or charcoal; ovens are not used, and there is no refrigeration so marketing must be done daily. This and the

absence of other kitchen appliances means that feeding a family three times daily is usually almost a full-time job for one member of the household. This is not necessarily the wife; servants are common for the well-to-do, and the less wealthy often have members of their extensive families who help out with household chores, including marketing and cooking.

5. The word មុខ /muk/ means 'face, kind, type.' When it refers to food, it means 'dish' in the sense of a type of prepared food, not a plate or bowl.

DRILLS

DRILL NO.

3. Both ... ជាងគេ /...ciaŋ kee/ and ... ជាងគេបង្អស់ /...ciaŋ kee bɔŋʔɔh/ mean 'the...-est, the most...' However, ជាងគេបង្អស់ /ciaŋ kee bɔŋʔɔh/ is all-inclusive, while ជាងគេ /ciaŋ kee/ can be limited to a small, immediate set of things or people to which one is referring.

4. (Sentence e) In this sentence ចូល /coul/ 'to enter' is used as a resultative verb with a sense of 'to go in.' It can occur with main verbs other than រៀន /rien/ 'study,' e.g. ញ៉ាំចូល /ɲam coul/ 'to be able to eat.'

5. In this lesson you have two contrasting preverbals: ចាប់ /cap/ 'to begin' and ឈប់ /chup/ 'to stop.' Both contrast with the resultative verb ចប់ /cɔp/ which means 'to finish, to complete.' Drills 5 - 11 give you practise in using these important words.

8. រួច /ruoc/ and ចប់ /cɔp/ are both translated 'to finish;' however, there are differences between them. រួច /ruoc/ is 'to be finished doing something,' but it does not indicate that the job itself is completed. ចប់ /cɔp/, on the other hand, means that the task is completed, that there is nothing further left to do on it.

11. Note the use of ហើយ /haəy/ with a time expression to mean 'ago,' e.g.

គេមកស្រុកនេះពីរខែហើយ។
kee mɔ́ɔ srok nih pii khaɛ haəy
They came to this country two months ago.

## DRILLS

DRILL ONE: Substitution

MODEL: T: កុំនិយាយច្រើនពេក។ (ញ៉ាំ)

S: កុំញ៉ាំច្រើនពេក។

T: Don't talk too much. (eat)

S: Don't eat too much.

ក. កុំញ៉ាំច្រើនពេក។ (យក)
ខ. កុំយកច្រើនពេក។ (ហៅ)
គ. កុំហៅច្រើនពេក។ (ទិញ)
ឃ. កុំទិញច្រើនពេក។ (រៀន)
ង. កុំរៀនច្រើនពេក។ (បង្រៀន)
ច. កុំបង្រៀនច្រើនពេក។ (សរសេរ)
ឆ. កុំសរសេរច្រើនពេក។ (ដើរ)
ជ. កុំដើរច្រើនពេក។

DRILL TWO: Extension

MODEL: T: លោកយកម្ហូបច្រើនណាស់។ (ខ្ញុំមិនសូវឃ្លានទេ)

S: កុំយកច្រើនពេកព្រោះខ្ញុំមិនសូវឃ្លានទេ។

T: You're bringing a lot of food. (I'm not very hungry)

S: Don't bring too much food because I'm not really hungry.

ក. លោកហៅមនុស្សច្រើនណាស់។ (ខ្ញុំគ្មានលុយទេ)
កុំហៅច្រើនពេកព្រោះខ្ញុំគ្មានលុយទេ។

ខ. លោកបើកឡានលឿនណាស់។ (ខ្ញុំមិនស្រួលខ្លួន)
កុំបើកលឿនពេកព្រោះខ្ញុំមិនស្រួលខ្លួន។

គ. លោកញ៉ាំច្រើនណាស់។ (ខ្ញុំចង់ទុកសម្រាប់ពួកម៉ាកលោកផង)
កុំញ៉ាំច្រើនពេកព្រោះខ្ញុំចង់ទុកសម្រាប់ពួកម៉ាកលោកផង។

ឃ. លោកនិយាយច្រើនណាស់។ (ខ្ញុំធ្វើការមិនបានទេ)
កុំនិយាយច្រើនពេកព្រោះខ្ញុំធ្វើការមិនបានទេ។

ង. លោកទៅឆ្ងាយណាស់។ (ខ្ញុំអស់កម្លាំងណាស់)
កុំទៅឆ្ងាយពេកព្រោះខ្ញុំអស់កម្លាំងណាស់។

ច. លោកប្រើឡានខ្ញុំច្រើនណាស់។ (ជិតអស់សាំងហើយ)
កុំប្រើឡានខ្ញុំច្រើនពេកព្រោះជិតអស់សាំងហើយ។

DRILL THREE: Response

MODEL: T: ខ្ញុំយកសាច់គោឬទាខ្វៃ ( ទាខ្វៃ / ឆ្ងាញ់ )
S: យកទាខ្វៃវិញ ព្រោះវាឆ្ងាញ់ជាងគេបង្អស់។
T: Should I take beef or roast duck? (roast duck/tasty)
S: Take the roast duck, because it's the most delicious.

ក. យើងទៅហាងបាយចិនឬហាងបាយបារាំង ( ចិន / ថោក )
ទៅហាងបាយចិនវិញ ព្រោះវាថោកជាងគេបង្អស់។
ខ. យើងទៅមើលរោងបាយ័នឬរោងលុច ( បាយ័ន / ជិត )
ទៅមើលរោងបាយ័នវិញ ព្រោះវាជិតជាងគេបង្អស់។
គ. យើងដើរទៅសាលាឬជិះឡានឈ្នួល ( ដើរ / ស្រួល )
ដើរទៅសាលាវិញ ព្រោះវាស្រួលជាងគេបង្អស់។
ឃ. ខ្ញុំយកសៀវភៅសឿងឬសៀវភៅស ( សឿង / ថ្លៃ )
យកសៀវភៅសឿងវិញ ព្រោះវាថ្លៃជាងគេបង្អស់។
ង. នាងចូលចិត្តឡានហ្វ័រឬមែរស៊ីដេស ( មែរស៊ីដេស / ល្អ )
ចូលចិត្តឡានមែរស៊ីដេសវិញ ព្រោះវាល្អជាងគេបង្អស់។
ច. លោករៀនភាសាចិនឬភាសាយួន ( យួន / ស្រួលរៀន )
រៀនភាសាយួនវិញ ព្រោះវាស្រួលរៀនជាងគេបង្អស់។

DRILL FOUR: Response

MODEL: T: លោកញុំាអីទៀតទេ? ( ឆ្អែតហើយ )
S: ស្រេចតែលោកទេ តែខ្ញុំឆ្អែតហើយ។
T: Are you going to eat anything else? (already full)
S: It's up to you, but I'm already full.

ក. កញ្ញាចង់ទៅមើលកុនទេ? ( អស់កម្លាំងណាស់ )
ស្រេចតែលោកទេ តែខ្ញុំអស់កម្លាំងណាស់។
ខ. លោកចង់ធ្វើអីយប់នេះ? ( រវល់ណាស់ )
ស្រេចតែលោកទេ តែខ្ញុំរវល់ណាស់។
គ. នាងចង់ទៅញុំាបាយទេ? ( គ្មានលុយទេ )
ស្រេចតែលោកទេ តែខ្ញុំគ្មានលុយទេ។
ឃ. លោកបង្រៀនអីថ្ងៃនេះ? ( ទៅផ្ទះតស្លូវ )
ស្រេចតែលោកទេ តែខ្ញុំទៅផ្ទះតស្លូវ។
ង. នាងចង់រៀនអី? ( រៀនមិនចូលទេ )
ស្រេចតែលោកទេ តែខ្ញុំរៀនមិនចូលទេ។
ច. លោកចង់ទៅណាទៀត? ( ជិតអស់សាំងហើយ )
ស្រេចតែលោកទេ តែខ្ញុំជិតអស់សាំងហើយ។
ឆ. នាងចង់ញុំាអីទៀត? ( ឆ្អែតហើយ )
ស្រេចតែលោកទេ តែខ្ញុំឆ្អែតហើយ។

DRILL FIVE: Response

MODEL: T: ខ្ញុំហៅម្ហូបបីមុខ ។
S: លោកចាប់ហៅម្ហូបអង្កាល់ ?
T: I'm going to order three kinds of food.
S: When will you start ordering?

ក. ខ្ញុំបង្រៀននៅសាលាអង្គរ ។
លោកចាប់បង្រៀននៅសាលាអង្គរអង្កាល់ ?

ខ. ខ្ញុំធ្វើបាយញ៉ាំនៅផ្ទះ ។
លោកចាប់ធ្វើបាយញ៉ាំនៅផ្ទះអង្កាល់ ?

គ. ខ្ញុំរៀនធ្វើឡានខ្លួនឯង ។
លោកចាប់រៀនធ្វើឡានខ្លួនឯងអង្កាល់ ?

ឃ. ខ្ញុំរៀនបើកឡាន ។
លោកចាប់រៀនបើកឡានអង្កាល់ ?

ង. ខ្ញុំធ្វើការយប់នៅវីអូអេ ។
លោកចាប់ធ្វើការយប់នៅវីអូអេអង្កាល់ ?

ច. ខ្ញុំបង្រៀនខ្មែរតែយប់ទេ ?
លោកចាប់បង្រៀនខ្មែរតែយប់អង្កាល់ ?

DRILL SIX: Response

MODEL: T: ខ្ញុំចាប់ហៅម្ហូប ។
S: លោកចាប់ហៅម្ហូបពីអង្កាល់ ?
T: I started ordering the food.
S: When did you start ordering the food?

ក. ខ្ញុំចាប់បង្រៀននៅសាលាអង្គរ ។
លោកចាប់បង្រៀននៅសាលាអង្គរពីអង្កាល់ ?

ខ. ខ្ញុំចាប់ធ្វើបាយញ៉ាំនៅផ្ទះ ។
លោកចាប់ធ្វើបាយនៅផ្ទះពីអង្កាល់ ?

គ. ខ្ញុំចាប់រៀនធ្វើឡានខ្លួនឯង ។
លោកចាប់រៀនធ្វើឡានខ្លួនឯងពីអង្កាល់ ?

ឃ. ខ្ញុំចាប់រៀនបើកឡាន ។
លោកចាប់រៀនបើកឡានពីអង្កាល់ ?

ង. ខ្ញុំចាប់ធ្វើយប់នៅសម្លេងសហរដ្ឋអាមេរិក ។
លោកចាប់ធ្វើការយប់នៅសម្លេងសហរដ្ឋអាមេរិកពីអង្កាល់ ?

ច. ខ្ញុំចាប់បង្រៀនខ្មែរតែយប់ទេ ។
លោកចាប់បង្រៀនខ្មែរតែយប់ពីអង្កាល់ ?

DRILL SEVEN: Transformation

MODEL: T: ខ្ញុំចាប់រៀនខ្មែរនៅសាលាអង្គរ។
S: លោកឈប់រៀនខ្មែរនៅសាលាអង្គរអង្កាល់?
T: I'll begin to study Cambodian at the Angkor school.
S: When will you stop studying Cambodian at the Angkor school?

ក. ខ្ញុំចាប់បង្រៀនខ្មែរតែយប់ទេ។
លោកឈប់បង្រៀនខ្មែរតែយប់អង្កាល់?
ខ. ខ្ញុំចាប់ធ្វើការយប់នៅសម្លេងសហរដ្ឋអាមេរិក។
លោកឈប់ធ្វើការយប់នៅសម្លេងសហរដ្ឋអាមេរិកអង្កាល់?
គ. ខ្ញុំចាប់រៀនបើកឡាន។
លោកឈប់រៀនបើកឡានអង្កាល់?
ឃ. ខ្ញុំចាប់រៀនធ្វើឡានខ្លួនឯង។
លោកឈប់រៀនធ្វើឡានខ្លួនឯងអង្កាល់?
ង. ខ្ញុំចាប់ធ្វើបាយញុំាំនៅផ្ទះ។
លោកឈប់ធ្វើបាយញុំាំនៅផ្ទះអង្កាល់?
ច. ខ្ញុំចាប់ញុំាំបារី។
លោកឈប់ញុំាំបារីអង្កាល់?

DRILL EIGHT: Response

MODEL: T: ខ្ញុំរៀនខ្មែររួចហើយ។
S: លោករៀនខ្មែរចប់ពីអង្កាល់?
T: I already studied Cambodian.
S: When did you finish studying Cambodian?

ក. ខ្ញុំចម្លងចំណោទនេះរួចហើយ។
លោកចម្លងចំណោទនេះចប់ពីអង្កាល់?
ខ. ខ្ញុំធ្វើចំណោទលោករួចហើយ។
លោកធ្វើចំណោទខ្ញុំចប់ពីអង្កាល់?
គ. ខ្ញុំសរសេររួចហើយ។
លោកសរសេរចប់ពីអង្កាល់?
ឃ. ខ្ញុំបង្រៀនសរសេររួចហើយ។
លោកបង្រៀនសរសេរចប់ពីអង្កាល់?
ង. ខ្ញុំមើលសៀវភៅនេះរួចហើយ។
លោកមើលសៀវភៅនេះចប់ពីអង្កាល់?
ច. ខ្ញុំនិយាយរួចហើយ។
លោកនិយាយចប់ពីអង្កាល់?

DRILL NINE: Response

MODEL: T: លោករៀនខ្មែរចប់អង្កាល់?
S: ខ្ញុំឈប់រៀនខ្មែរហើយ។
T: When will you finish studying Cambodian?
S: I've already stopped studying Cambodian.

ក. លោកធ្វើស្ពានលោកចប់អង្កាល់?
ខ្ញុំឈប់ធ្វើស្ពានខ្ញុំហើយ។
ខ. លោកបង្រៀនភាសាចប់អង្កាល់?
ខ្ញុំឈប់បង្រៀនភាសាហើយ។
គ. ប្រពន្ធខ្ញុំធ្វើការចប់អង្កាល់?
ប្រពន្ធខ្ញុំឈប់ធ្វើការហើយ។
ឃ. កូនលោករៀនពេទ្យចប់អង្កាល់?
កូនខ្ញុំឈប់រៀនពេទ្យហើយ។
ង. លោកសរសេរសៀវភៅនោះចប់អង្កាល់?
ខ្ញុំឈប់សរសេរសៀវភៅនោះហើយ។
ច. លោកមើលសៀវភៅនេះចប់អង្កាល់?
ខ្ញុំឈប់មើលសៀវភៅនេះហើយ។

DRILL TEN: Response

MODEL: T: អង្កាល់លោករៀនខ្មែរចប់? (ដប់អាទិត្យ)
S: ដប់អាទិត្យខ្ញុំរៀនខ្មែរចប់ហើយ។
T: When do you finish studying Cambodian? (ten weeks)
S: In ten more weeks I'll have finished studying Cambodian.

ក. អង្កាល់លោកចម្លងចំលោទ្យនេះចប់? (កន្លះម៉ោង)
កន្លះម៉ោងទៀតខ្ញុំចម្លងចំលោទ្យនេះចប់ហើយ។
ខ. អង្កាល់លោកសរសេរសំបុត្រនេះចប់? (មួយម៉ោង)
មួយម៉ោងទៀតខ្ញុំសរសេរសំបុត្រនេះចប់ហើយ។
គ. អង្កាល់លោកបង្រៀនសរសេរចប់? (ប្រាំអាទិត្យ)
ប្រាំអាទិត្យទៀតខ្ញុំបង្រៀនសរសេរចប់ហើយ។
ឃ. អង្កាល់លោកមើលសៀវភៅនេះចប់? (ពីរថ្ងៃ)
ពីរថ្ងៃទៀតខ្ញុំមើលសៀវភៅនេះចប់ហើយ។
ង. អង្កាល់លោករៀនពេទ្យចប់? (បីឆ្នាំ)
បីឆ្នាំទៀតខ្ញុំរៀនពេទ្យចប់ហើយ។
ច. អង្កាល់លោកនិយាយចប់? (បន្តិច)
បន្តិចទៀតខ្ញុំនិយាយចប់ហើយ។

DRILL ELEVEN: Response

MODEL: T: លោករៀនខ្មែរចប់ពីអង្កាល់? (ដប់អាទិត្យ)
S: ខ្ញុំរៀនខ្មែរចប់ដប់អាទិត្យហើយ។
T: When did you finish studying Cambodian? (ten weeks)
S: I finished studying Cambodian ten weeks ago.

ក. លោកចម្លងចំណោទនេះចប់ពីអង្កាល់? (កន្លះម៉ោង)
ខ្ញុំចម្លងចំណោទនេះចប់កន្លះម៉ោងហើយ។
ខ. លោកសរសេរសំបុត្រនេះចប់ពីអង្កាល់? (មួយម៉ោង)
ខ្ញុំសរសេរសំបុត្រនេះចប់មួយម៉ោងហើយ។
គ. លោកបង្រៀនសរសេរចប់ពីអង្កាល់? (ប្រាំអាទិត្យ)
ខ្ញុំបង្រៀនសរសេរចប់ប្រាំអាទិត្យហើយ។
ឃ. លោកមើលសៀវភៅនេះចប់ពីអង្កាល់? (ពីរថ្ងៃ)
ខ្ញុំមើលសៀវភៅនេះចប់ពីរថ្ងៃហើយ។
ង. លោករៀនពាទ្យចប់ពីអង្កាល់? (បីឆ្នាំ)
ខ្ញុំរៀនពាទ្យចប់បីឆ្នាំហើយ។
ច. លោកនិយាយចប់ពីអង្កាល់? (ពីរមីនុត)
ខ្ញុំនិយាយចប់ពីរមីនុតហើយ។

## Reading Passage

### ខ្មែរញ៉ាំបាយ

ធម្មតាខ្មែរមិនប្រើតុកៅអីដើម្បីនឹងអង្គុយញ៉ាំបាយទេ គេអង្គុយនៅលើកន្ទេលជុំវិញស្លឹកម្ហូបអាហារ។ នៅក្រោយចំអិនម្ហូបអាហារ គេដួសដាក់ចានធំតូចតាមមុខម្ហូបហើយយកទៅដាក់លើស្លឹកមួយ។ ឆ្នាំងបាយ គេដាក់នៅជិតកន្លែងញ៉ាំបាយ។ គ្រួសារទាំងអស់អង្គុយជុំវិញស្លឹក។ ម្នាក់ៗមានចានបាយនៅមុខគេ។ គេប្រើស្លាបព្រា ឬចង្កឹះ តាមចានបាយធំឬតូច តែគេមិនប្រើកាំបិតទេ ព្រោះសាច់ទាំងអស់គេកាប់តូចៗហើយ។ គេចែកសម្លគ្នាញ៉ាំ ឬជួនកាលគេមានចានសម្លម្នាក់មួយៗ តែគេមិនដួសសម្លដាក់ចានគេទេ។ ខ្មែរញ៉ាំបាយច្រើនណាស់ ជួនកាលម្នាក់ៗញ៉ាំបី បួនចាន។ នៅពេលក្រោយញ៉ាំបាយ ម្នាក់ត្រូវលាងចានទាំងអស់ ឬម្នាក់ៗត្រូវលាងចានខ្លួនឯងលើកលែងតែពុកម្ដាយទេ។ ម្ហូបឬបាយដែលនៅសល់គេទុកសម្រាប់ញ៉ាំនៅពេលបាយក្រោយទៀត។ ជួនកាលគេធ្វើម្ហូបអាហារនៅពេលថ្ងៃឲ្យច្រើនទុកសម្រាប់ញ៉ាំនៅពេលល្ងាចដែរ។

## VOCABULARY

| | | |
|---|---|---|
| កម្លាំង | kəlaŋ | strength, force, power |
| កន្ទេល | kəteel | mat (R) |
| កាប់ | kap | to chop (L) |
| ខ្វៃ | khvay | roast (on a spit) |
| គោក | kook | dry (food), without liquid (L) |
| ឃ្លាន | khlian | to be hungry |

| | | |
|---|---|---|
| ចំអិន | cəmʔən | to cook (R) |
| ឆា | chaa | sauté |
| ឆ្អែត | chʔaɛt | to be full (of food) |
| ជាងគេបង្អស់ | ciaŋ kee bɔŋʔɔh | superlative marker |
| ដួស | duoh | to serve food (R) |
| ដោយឡែក | daoy laɛk | separately (L) |
| ទា | tia | duck |
| មនុស្ស | mənuh | people |
| មុខ | muk | face, kind |
| លាយ | liey | to mix (L) |
| សល់ | sɔl | to remain (R) |
| សណ្ដែក | sədaɛk | bean |
| សមុទ្រ | səmot | sea (L) |
| សម្លេង | səmleeŋ | voice |
| សម្លេងសហរដ្ឋអាមេរិក | səmleeŋ sahaʔrót aameerɨk | Voice of America |
| សហរដ្ឋ | sahaʔrót | United States |
| សាច់ | sac | meat |
| សាច់គោ | sac koo | beef |
| សាប | saap | bland, not salty or spicy, fresh (water) (L) |
| ស៊ុប | sup | soup |
| ស្ពក | spóok | tray (R) |
| ហាន់ | han | to cut in strips, to slice (L) |
| អស់កម្លាំង | ɔh kəlaŋ | to be tired |

ADDITIONAL FOOD VOCABULARY

| | | |
|---|---|---|
| ចៀន | cien | to fry in shallow fat |
| ចំហុយ | cəmhoy | to steam |
| ឆា | chaa | sauté, stir-fry Chinese style |
| ជ្រូក | cruuk | pig, hog |
| បបរ | bɔɔbɔɔ | rice gruel |
| ប៉េងប៉ោះ | peeŋ pɔh | tomatoes |
| បំពង | bɔmpɔŋ | to deep-fry |
| ប្រហុក | prɔhok | preserved fish paste |

| | | |
|---|---|---|
| ពង | póoŋ | egg |
| លីង | liiŋ | to fry rice |
| សង់ខ្យា | sɔŋkhyaa | pudding |
| សណ្ដែកបណ្ដុះ | sədaek bɔndɔh | bean sprouts |
| សម្ល | səmlɔɔ | a stew |
| សាច់ជ្រូក | sac cruuk | pork |
| សាឡាត | saalaat | lettuce; salad |
| ស្ល | slɔɔ | to stew |
| ស្ងោរ | sŋao | to boil, to make into soup; a soup containing boiled meat |
| អាំង | aŋ | to roast, to broil |

| | | STATEMENT | | QUESTION | |
|---|---|---|---|---|---|
| | | PAST | NON-PAST | PAST | NON-PAST |
| កាល | kaal | X | | | |
| កាលណា | kaalnaa | | X | | X |
| កាលពី | kaal pii | X | | | |
| អង្កាល់ | ŋkaal | X | | | X |
| ពីអង្កាល់ | pii ŋkaal | X | | X | |
| នៅពេលដែល | nɨw peel daεl | X | X | | |
| ដល់ | dɔl | X | X | | |
| លុះ | luh | X | X | | |

## LESSON THIRTY-FOUR

### DIALOGUE

| | | | |
|---|---|---|---|
| ១. | សុខ | ម៉េចយើងត្រូវការអីខ្លះទៀត ? | Well! What else do we need? |
| | | បន្លែ | vegetable |
| ២ | សៅ | ទៅមើលបន្លែមុន ។ | Let's go look at the vegetables first. |
| ៣. | សុខ | ចុះទឹកដោះគោ ? ប៊ីយែ ? | What about milk? beer? |
| | | អ៊ែ | aah |
| | | ចៀម | sheep |
| | | សាច់ចៀម | lamb meat |
| ៤. | សៅ | ទិញតែទឹកដោះគោបាន ហើយ ។ អ៊ែសុខ ឯងសាកញ៉ាំសាច់ ចៀមម្ដងទេ ? | Buy only the milk. Aah Sok, would you like to try lamb meat (for a change)? |
| | | ខ្ញុំឮគេថា | I've heard that |
| | | ក្លិន | odor, smell |
| | | ធុំក្លិន | to smell, to have an odor |
| ៥. | សុខ | ខ្ញុំឮគេថាវាធុំក្លិនណាស់ ។ | I've heard that it smells a lot. |
| ៦. | សៅ | ទេ ចាំខ្ញុំធ្វើឲ្យញ៉ាំ ។ | No, I'll cook it for you (and you'll see). |
| | | មាន់ | chicken |
| | | សាច់មាន់ | chicken (meat) |
| ៧. | សុខ | អញ្ចឹងទិញក៏ទិញទៅ ទិញ សាច់គោនិងសាច់មាន់ខ្លះផង ។ | In that case go ahead and buy it. Buy some beef and some chicken, too. |
| | | អង្ករ | rice (polished but uncooked) |
| ៨. | សៅ | ចុះអង្ករ ? | And rice? |
| | | កញ្ចប់ | bag, packet |
| | | រក | to look for, to find |
| | | នំ | cake, pastry |
| | | នំបុ័ង | bread |
| | | កាន់តែ | increasingly |
| ៩. | សុខ | យកពីរកញ្ចប់តូចទៅ ហើយខ្ញុំទៅរកនំបុ័ង ព្រោះ អង្ករកាន់តែថ្លៃឡើងៗ ។ | Get two small bags, and I'll go look for some bread, since rice is getting more and more expensive. |

DIALOGUE:

1. sok - mɛcɫ yəəŋ trəw kaa ɛy khlah tiet?

2. saw - tɨw məəl pəlaɛ mun

3. sok - coh tɨk dɔh koo? biyɛɛ?

4. saw - tiñ taɛ tɨk dɔh koo baan haəy. naɛ, sok aɛŋ saaˀ ñam sac ciem mə dɔɔŋ-eh?

5. sok - khñom lɨɨ kee thaa via thum khlən-ah.

6. saw - teeɫ cam khñom thəə aoy ñam

7. sok - əñcəŋ tiñ kɔɔ tiñ təh. tiñ sac koo nɨŋ sac món khlah phɔɔŋ

8. saw - coh ŋkɔɔ

9. sok - yóo pii kəcɔp touc təh, haəy khñom tɨw róo numpaŋ, prúh ŋkɔɔ kan taɛ thlay laəŋ thlay laəŋ

NOTES

DIALOGUE

SENTENCE NO.

4. ណែ /naɛ/ is a hesitation particle usually used before a clause or verb phrase. (Cf. A.4.1 in the grammatical sketch.)

7. The formula verb + ក៏ /kɔɔ/ + verb indicates that the speaker is going along with something that the addressee wants to do, that he won't oppose it. It differs from verb + ចុះ /coh/ in that ចុះ /coh/ not only indicates agreement, but it also has a slight imperative flavor. Verb + ចុះ + verb is not imperative.

8. There is no single word for rice in Cambodian. You must specify whether rice is cooked or uncooked and if uncooked whether milled or not. Rice on the plant or harvested but not yet polished in a rice mill is called ស្រូវ /srəw/. This is also the word for the rice plant. Rice which is processed but not yet cooked is called អង្ករ /ŋkɔɔ/; it is this type of rice that you buy in a store. And as you already know, cooked rice is បាយ /baay/.

9. The formula កាន់តែ /kan taɛ/ + adjective + ឡើង /laəŋ/ means 'increasingly (adjective), ...-er and ...-er.' Thus we can say

   មាន់កាន់តែច្រើនឡើងនៅនេះ
   món kan taɛ craən laəŋ nɨw nih
   There are more and more chickens here.

   More often the adjective + ឡើង /laəŋ/ phrase is repeated, so the above example would usually be

មាន់កាន់តែច្រើនឡើងៗនៅនេះ។

mɔ́n kan taɛ craən laəŋ craən laəŋ nɨw nih

There are more and more chickens here.

Instead of កាន់តែ /kan taɛ/ the adverb រឹតតែ /rɨt taɛ/ can be used. Cf. also Drills 1 and 2.

DRILLS

DRILL NO.

3. Note in the formula verb + ឲ្យ /aoy/ + adjective the phrase ឲ្យ + adjective has a slight imperative force, e.g.

លោកត្រូវធ្វើឲ្យល្អ។

look trəw thəə aoy lʔɔɔ

You have to do it well.

6. The word លែង /lɛɛŋ/ as a preverbal means 'to cease, to quit, to give up, to no longer (do).' Thus 'I've quit smoking' is ខ្ញុំលែងញ៉ាំបារីហើយ។ /khñom lɛɛŋ ñam baarɛy haəy/.

9. The word ធុំ /thum/ means 'to smell' in the sense of 'to give off an odor,' while ហិត /hət/ is a transitive verb meaning 'to smell (something).

10. The causative ធ្វើឲ្យ /thəə aoy/ 'to cause, to make' differs from the simple ឲ្យ /aoy/ 'to cause, to have (done)' in that it does not mean 'to let.' It always indicates that the subject of ធ្វើឲ្យ /thəə aoy/ has actually done something to bring about the effect described in the following clause. If the subject of ធ្វើឲ្យ /thəə aoy/ is human, it indicates that he has taken some sort of action to bring about the effect.

DRILLS

DRILL ONE: Transformation

MODEL: T: សាច់គោថ្លៃណាស់។

S: ឥឡូវសាច់គោកាន់តែថ្លៃឡើងៗ។

T: Beef is expensive.

S: Now beef is more and more expensive.

| | |
|---|---|
| ក. បន្លែថោកណាស់។ | ឥឡូវបន្លែកាន់តែថោកឡើងៗ។ |
| ខ. កប៉ាល់ហោះលឿនណាស់។ | ឥឡូវកប៉ាល់ហោះកាន់តែលឿនឡើងៗ។ |
| គ. លោកមានណាស់។ | ឥឡូវលោកកាន់តែមានឡើងៗ។ |
| ឃ. នាងល្អណាស់។ | ឥឡូវនាងកាន់តែល្អឡើងៗ។ |
| ង. ឡានលោកអាក្រក់ណាស់។ | ឥឡូវឡានលោកកាន់តែអាក្រក់ឡើងៗ។ |
| ច. ចំណោទ នេះពិបាកណាស់។ | ឥឡូវចំណោទ នេះកាន់តែពិបាកឡើងៗ។ |

DRILL TWO: Transformation

MODEL: T: សាច់គោថ្លៃជាងមុន។

S: ខ្ញុំឮគេថាសាច់គោរឹតតែថ្លៃឡើង។

T: Beef is more expensive than before.

S: I've heard that beef is more and more expensive.

ក. បន្លែថោកជាងមុន។ — ខ្ញុំឮគេថាបន្លែរឹតតែថោកឡើង។

ខ. កប៉ាល់ហោះលឿនជាងមុន។ — ខ្ញុំឮគេថាកប៉ាល់ហោះរឹតតែលឿនឡើង។

គ. លោកមានជាងមុន។ — ខ្ញុំឮគេថាលោករឹតតែមានឡើង។

ឃ. កូនលោកល្អជាងមុន។ — ខ្ញុំឮគេថាកូនលោករឹតតែល្អឡើង។

ង. ឡានលោកអាក្រក់ជាងមុន។ — ខ្ញុំឮគេថាឡានលោករឹតតែអាក្រក់ឡើង។

ច. លោកឱ្យចំណោទ ពិបាកជាងមុន។ — ខ្ញុំឮគេថាលោកឱ្យចំណោទ រឹតតែពិបាកឡើង។

DRILL THREE: Substitution

MODEL: T: លោកត្រូវញ៉ាំបន្លែឱ្យច្រើន។ (ម្ហូប)

S: លោកត្រូវញ៉ាំម្ហូបឱ្យច្រើន។

T: You have to eat a lot of vegetables. (food)

S: You have to eat a lot of food.

ក. លោកត្រូវញ៉ាំម្ហូបឱ្យច្រើន។ (សាច់)

ខ. លោកត្រូវញ៉ាំសាច់ឱ្យច្រើន។ (សាឡាត់)

គ. លោកត្រូវញ៉ាំសាឡាត់ឱ្យច្រើន។ (បាយ)

ឃ. លោកត្រូវញ៉ាំបាយឱ្យច្រើន។ (ស៊ុប)

ង. លោកត្រូវញ៉ាំស៊ុបឱ្យច្រើន។ (ទឹកដោះគោ)

ច. លោកត្រូវញ៉ាំទឹកដោះគោឱ្យច្រើន។

DRILL FOUR: Response

MODEL: T: ខ្ញុំធ្វើបាយញ៉ាំយប់នេះ។ (ឆ្ងាញ់)

S: បើលោកធ្វើបាយញ៉ាំ ត្រូវធ្វើឱ្យឆ្ងាញ់។

T: Tonight I'll cook. (delicious)

S: If you cook, you'll have to cook so it will taste good.

ក. ខ្ញុំធ្វើឡានលោក។ (ល្អ) បើលោកធ្វើឡានខ្ញុំ ត្រូវធ្វើឱ្យល្អ។

ខ. ខ្ញុំចង់បើកឡាន។ (យឺត) បើលោកចង់បើកឡាន ត្រូវបើកឱ្យយឺត

គ. ខ្ញុំឱ្យលុយលោក។ (ច្រើន) បើលោកចង់ឱ្យលុយខ្ញុំ ត្រូវឱ្យៗច្រើន។

ឃ. ខ្ញុំចង់បើកឡាន។ (ប្រយ័ត្ន) បើលោកចង់បើកឡាន ត្រូវបើកឱ្យប្រយ័ត្ន។

ង. ខ្ញុំមើលផ្គង់។ (ខ្លាំង) បើលោកចង់មើលផ្គង់ ត្រូវមើលឱ្យខ្លាំង។

ច. ខ្ញុំញ៉ាំស្រា។ (ស្រវឹង) បើលោកចង់ញ៉ាំស្រា ត្រូវញ៉ាំឱ្យស្រវឹង។

DRILL FIVE: Response

MODEL: T: លោកទិញទឹកដោះទេ?
S: ទិញក៏ទិញទៅ។
T: Will you buy milk?
S: Go ahead and buy it.

| | |
|---|---|
| ក. លោកទៅសាលាទេ? | ទៅក៏ទៅៗ។ |
| ខ. លោកយកលុយទេ? | យកក៏យកទៅ។ |
| គ. លោកញ៉ាំទេ? | ញ៉ាំក៏ញ៉ាំទៅ។ |
| ឃ. លោកមើលសៀវភៅទេ? | មើលក៏មើលទៅ។ |
| ង. លោករៀនទេ? | រៀនក៏រៀនទៅ។ |
| ច. លោកបង្រៀនទេ? | បង្រៀនក៏បង្រៀនទៅ។ |

DRILL SIX: Response

MODEL: T: នាងញ៉ាំទឹកដោះគោទេ?
S: ខ្ញុំលែងញ៉ាំទឹកដោះគោហើយ។
T: Miss, do you drink milk?
S: I've quit drinking milk.

| | |
|---|---|
| ក. លោកញ៉ាំស្រាទេ? | ខ្ញុំលែងញ៉ាំស្រាហើយ។ |
| ខ. លោកញ៉ាំបារីទេ? | ខ្ញុំលែងញ៉ាំបារីហើយ។ |
| គ. លោករៀនខ្មែរទេ? | ខ្ញុំលែងរៀនខ្មែរហើយ។ |
| ឃ. លោកធ្វើបាយញ៉ាំនៅផ្ទះទេ? | ខ្ញុំលែងធ្វើបាយញ៉ាំនៅផ្ទះហើយ។ |
| ង. លោកបង្រៀនខ្មែរទេ? | ខ្ញុំលែងបង្រៀនខ្មែរហើយ។ |
| ច. លោកលេងបៀទេ? | ខ្ញុំលែងលេងបៀហើយ។ |

DRILL SEVEN: Transformation

MODEL: T: ខ្ញុំសាកញ៉ាំសាច់ចៀមម្ដង។ (ធុំ)
S: កុំញ៉ាំសាច់ចៀមព្រោះវាធុំណាស់។
T: I tried to eat lamb once.
S: Don't eat lamb because it smells a lot.

| | | |
|---|---|---|
| ក. ខ្ញុំរៀនភាសាចិន។ | (ពិបាក) | កុំរៀនភាសាចិនព្រោះវាពិបាកណាស់ |
| ខ. កុំញ៉ាំផ្លែស្វាយនេះ។ | (ជូរ) | កុំញ៉ាំផ្លែស្វាយនេះព្រោះវាជូរណាស់ |
| គ. កុំឲ្យគេធ្វើឡានខ្ញុំ។ | (ថ្លៃ) | កុំឲ្យគេធ្វើឡានខ្ញុំព្រោះវាថ្លៃណាស់។ |
| ឃ. ខ្ញុំទៅរៀនសាលានោះ។ | (ឆ្ងាយ) | កុំទៅរៀនសាលានោះព្រោះវាឆ្ងាយណាស់។ |
| ង. ខ្ញុំទិញសាច់គោ។ | (ថ្លៃ) | កុំទិញសាច់គោព្រោះវាថ្លៃណាស់ |
| ច. កុំយកឡានហ្នឹង។ | (តូច) | កុំយកឡានហ្នឹងព្រោះវាតូចណាស់ |

DRILL EIGHT: Transformation

MODEL: T: ម្ហូបនេះឆ្ងាញ់ណាស់។
S: ម្ហូបនេះធុំឆ្ងាញ់ណាស់។
T: This food is delicious.
S: This food smells very delicious.

| | | |
|---|---|---|
| ក. | កន្លែងនេះអាក្រក់ណាស់។ | កន្លែងនេះធុំអាក្រក់ណាស់។ |
| ខ. | បន្ទប់ទឹកនេះល្អណាស់។ | បន្ទប់ទឹកនេះធុំល្អណាស់។ |
| គ. | ត្រីនេះឆ្អាបណាស់។ | ត្រីនេះធុំឆ្អាបណាស់។ |
| ឃ. | កន្លែងនេះស្អុយណាស់។ | កន្លែងនេះធុំស្អុយណាស់។ |
| ង. | បន្ទប់កញ្ញាក្រអូបណាស់។ | បន្ទប់កញ្ញាធុំក្រអូបណាស់។ |
| ច. | ម្ហូបនេះឈ្ងុយណាស់។ | ម្ហូបនេះធុំឈ្ងុយណាស់។ |

DRILL NINE: Transformation

MODEL: T: ម្ហូបនេះធុំឆ្ងាញ់ណាស់។
S: ខ្ញុំហិតម្ហូបនេះ។
T: This food smells very delicious.
S: I've smelled this food.

| | | |
|---|---|---|
| ក. | កន្លែងនេះធុំអាក្រក់ណាស់។ | ខ្ញុំហិតកន្លែងនេះ។ |
| ខ. | បន្ទប់នេះធុំល្អណាស់។ | ខ្ញុំហិតបន្ទប់នេះ។ |
| គ. | ត្រីនេះធុំឆ្អាបណាស់។ | ខ្ញុំហិតត្រីនេះ។ |
| ឃ. | កន្លែងនេះធុំស្អុយណាស់។ | ខ្ញុំហិតកន្លែងនេះ។ |
| ង. | បន្ទប់កញ្ញាធុំក្រអូបណាស់។ | ខ្ញុំហិតបន្ទប់កញ្ញា។ |
| ច. | ម្ហូបនេះធុំឈ្ងុយណាស់។ | ខ្ញុំហិតម្ហូបនេះ។ |

DRILL TEN: Response

MODEL: T: ម្ហូបនេះឈ្ងុយណាស់។ (ញ៉ាំ)
S: ឈ្ងុយណាស់ធ្វើឲ្យខ្ញុំចង់ញ៉ាំ។
T: This food smells good.
S: It smells very good; it makes me want to eat it.

| | | | |
|---|---|---|---|
| ក. | កន្លែងនោះល្អណាស់។ | (ទៅ) | ល្អណាស់ធ្វើឲ្យខ្ញុំចង់ទៅ។ |
| ខ. | កន្លែងនោះស្អុយណាស់។ | (ក្អក) | ស្អុយណាស់ធ្វើឲ្យខ្ញុំចង់ក្អក។ |
| គ. | បន្ទប់កញ្ញាក្រអូបណាស់។ | (ហិត) | ក្រអូបណាស់ធ្វើឲ្យខ្ញុំចង់ហិត។ |
| ឃ. | សាលានេះពិបាកណាស់។ | (ឈប់រៀន) | ពិបាកណាស់ធ្វើឲ្យខ្ញុំចង់ឈប់រៀន។ |
| ង. | ឡាននេះថោកណាស់។ | (ទិញ) | ថោកណាស់ធ្វើឲ្យខ្ញុំចង់ទិញ។ |
| ច. | កូននោះល្អមើលណាស់។ | (ទៅមើល) | ល្អមើលណាស់ធ្វើឲ្យខ្ញុំចង់ទៅមើល។ |

## Reading Passage

### ផ្សារលក់ម្ហូបអាហារ

នៅទីក្រុងណាក៏ដូចទីក្រុងណាដែរនៅស្រុកខ្មែរ គេមានផ្សារតែមួយទេដែលលក់ម្ហូបអាហារ។ នៅក្នុងកន្លែងនេះ គេចែកជាផ្នែកៗសម្រាប់លក់ឥវ៉ាន់តាមមុខដោយឡែកៗ។ មានកន្លែងលក់នំបុ័ងក្តៅៗ ដែលទើបនឹងយកចេញពីចង្ក្រានហើយមានក្លិនគួរឱ្យឃ្លាន។ កន្លែងលក់ត្រីជាកន្លែងក្លិនខ្លាំងជាងគេ មានត្រីងាប់ត្រីរស់។ គេធ្វើអាងមួយសម្រាប់ត្រីដែលនៅរស់។ បើមានអ្នកណាទិញ អ្នកលក់នឹងសម្លាប់ត្រីនោះនៅមុខគេ។ សាច់គោសាច់ជ្រូកលក់នៅកន្លែងមួយទៀត។ គេកាត់សាច់លក់តាមអ្នកទិញបង្គាប់ឱ្យគេកាត់ តាមទម្ងន់ដែលគេចង់បាន។ មាន់ទាក៏គេលក់នៅកន្លែងដោយឡែកៗដែរ ខ្លះគេសម្លាប់ធ្វើស្អាតហើយ ខ្លះនៅរស់នៅឡើយ។ បើអ្នកទិញៗអាណានៅរស់ អ្នកលក់មិនអាចសម្លាប់ឱ្យដូចគេលក់ត្រីទេតែគេលក់ថោកជាងអាងាប់។ ឯនៅកន្លែងលក់អង្ករវិញ យើងឃើញមានអង្ករគ្រប់មុខ។ គេមានអង្ករក្រហម អង្ករស ហើយអង្ករខ្លះមានគ្រាប់វែងខ្លះគ្រាប់ខ្លី។ នៅស្រុកយើងអង្ករសគ្រាប់វែងថ្លៃជាងអង្ករសគ្រាប់ខ្លី ហើយអង្ករក្រហមថោកជាងគេទាំងអស់។

ចម្ងាយកន្លែងលក់បន្លែនិងកន្លែងលក់ផ្លែឈើនៅមិនឆ្ងាយពីគ្នាទេ។ បើយើងគិតពីម្ហូប យើងឃើញថាបន្លែថោកជាងម្ហូបឯទៀត ព្រោះបន្លែលក់ដោយអ្នកស្រែឬអ្នកចំការ ហើយបន្លែខ្លះមិនបាច់ដាំផងគឺគេបេះវានៅក្នុងព្រៃ។

នៅកន្លែងលក់ផ្លែឈើ យើងឃើញផ្លែឈើច្រើនមុខណាស់។ ផ្លែឈើទាំងនោះសុទ្ធតែបេះនៅស្រុកយើង លើកលែងតែប៉ោម ស៊ីរី និងទំពាំងបាយជូរ។ ផ្លែឈើដែលបេះនៅស្រុកយើងក៏ថោកណាស់ដែរ ព្រោះខ្លះលក់ដោយអ្នកស្រែចំការនិងខ្លះទៀតមិនបេះនៅចំការទេគឺបេះនៅក្នុងព្រៃ។

បើយើងគិតតាមរឿងដែលយើងនិយាយមកនេះ យើងឃើញថាផ្សារលក់ម្ហូបនៅស្រុកយើងធំណាស់ ហើយមានឥវ៉ាន់និងអ្នកលក់ច្រើនផង។ តាមពិត យើងគិតនោះត្រូវ។

## VOCABULARY

| | | |
|---|---|---|
| កាន់តែ ... ឡើង ( ... ឡើង ) | kan taɛ...laəŋ (...laəŋ) | more and more |
| ក្លិន | khlén | odor, smell |
| ក្អួត | kʔuot | to vomit |
| កញ្ចប់ | kəcɔp | bag, pack, packet |
| ក្រអូប | kʔoup | fragrant, pleasant, nice smelling (perfume, flower) |
| ខ្ញុំឮគេថា | khñom lii kee thaa | I've heard that |
| ងាប់ | ŋóp | to die (very informal; used of animals and plants also)(R) |
| ចៀម | ciem | sheep |
| ចង្ក្រាន | cəkraan | kitchen, stove, oven (R) |
| ឆ្អាប | chʔaap | fishy (smell) |
| ឈ្ងុយ | chŋuy | good smelling (food) |

| | | |
|---|---|---|
| ដាំ | dam | to plant, to grow (something)(R) |
| ណែ | naɛ | aah, well, uh... (R) |
| តាមពិត | taam pɨt | actually, in fact, truly (R) |
| ត្រី | trɛy | fish |
| ទម្ងន់ | təŋún | weight (R) |
| ធុំ | thum | to smell |
| ធុំក្លិន | thum khlən | to smell, to have an odor |
| នំប៉័ង | numpaŋ | bread |
| បង្គាប់ | bɔŋkóp | to order, to command (R) |
| បន្លែ | pəlaɛ | vegetable |
| ផ្នែក | phnaɛk | part, section, portion (R) |
| ព្រៃ | prɨy | forest, jungle (R) |
| មាន់ | món | chicken |
| រក | róo | to look for |
| រឹតតែ... ឡើង (... ឡើង) | rɨt taɛ... laəŋ (...laəŋ) | more and more |
| លែង | lɛɛŋ | to quit; no longer + verb |
| សាឡាត់ | səlat | salad |
| សាច់ចៀម | sac ciem | lamb meat |
| សាច់មាន់ | sac món | chicken meat |
| ស្រវឹង | səvəŋ | to be drunk |
| ស្អុយ | sʔuy | pungent, bad smelling |
| ហិត | hət | to smell something |
| អាង | aaŋ | a very large vessel, often rectangular, frequently used in the market place (R) |
| អង្ករ | ŋkɔɔ | rice (polished and uncooked) |

ADDITIONAL FOOD VOCABULARY

| | | |
|---|---|---|
| ក្ដាម | kdaam | crab |
| កំពិស | kəpɨh | fresh water shrimp |
| ខ្ទឹមបារាំង | khtɨm baraŋ | onion (round) |
| ខ្ទឹមស | khtɨm sɔɔ | garlic |
| បង្គា | pəkia | salt-water shrimp |
| ស្រូវ | srəw | raw, unpolished rice; the rice plant |

## LESSON THIRTY-FIVE

| | | | |
|---|---|---|---|
| | | រត់ | to run |
| ១. | ធុម | ឡានថ្មីលោករត់ស្រួលទេ ? | How is your new car running? |
| ២. | សុខ | បាទ ប៉ុន្មានថ្ងៃហ្នឹងដូចជារត់មិនសូវស្រួលសោះ ។ | In the last few days, it hasn't been running smoothly at all. |
| ៣. | ធុម | វាកើតអី ? | What's wrong with it? |
| | | បញ្ឆេះ | to start (an engine) |
| | | ព្រម | to agree, to be willing |
| ៤. | សុខ | ព្រឹកមិញ ខ្ញុំបញ្ឆេះអស់ជិតដប់មីនុត មិនព្រមឆេះ ។ | This morning, I tried to start it for almost ten minutes, but it wouldn't start. |
| | | ឧស្សាហ៍ | often; to be diligent |
| | | ឆែក | to check |
| | | អាគុយ | battery |
| ៥. | ធុម | ខែត្រជាក់ លោកត្រូវឧស្សាហ៍ឆែកមើលអាគុយ ។ | In the cold months, you have to check the battery often. |
| | | ឥតខាន, គ្មាន | without |
| | | ប្រហែស | negligence, to neglect |
| | | ផ្សេងៗ | different, various |
| ៦. | សុខ | ខ្ញុំឆែកឥតខានប្រហែសទេ តែប្រហែលខូចស្អីផ្សេងៗទៀត ទេក៏មិនដឹង ។ | I always check, without fail! But probably there's something else wrong. |
| | | ស្ដាយ | to regret, to be too bad |
| ៧. | ធុម | ស្ដាយណាស់ បើខ្ញុំនៅជិត ខ្ញុំនឹងមើលតើវាខូចអី ។ | That's too bad. If I live near (you), I'll take a look and see what's wrong with it. |
| | | បង្ហូត | directly; indefinitely, all the way |
| | | តែម្ដង | directly, immediately |
| ៨. | សុខ | អញ្ចឹង ចេញពីធ្វើការ បង្ហូតទៅផ្ទះខ្ញុំតែម្ដងទៅ ។ | Then after work go straight to my house. |
| ៩. | ធុម | អញ្ចឹង ចាំល្ងាចហ្នឹងខ្ញុំទៅមើល ។ | In that case, wait until this evening and I'll come take a look. |

DIALOGUE:

1. tom - laan thmɛy look rút sruol eh?

2. sok - baat, pəmaan ŋay nɨŋ douc cə rút mɨn səw sruol soh

3. tom - via kaət ɛy?

4. sok - prɨk mɛñ, khñom pəchɛh ɔh cit dɔp mənut, mɨn próom chɛh

5. tom - khaɛ təcéʔ, look trəw əhsaa chaɛk məəl aʔkuy

6. sok - khñom chaɛk ət mian pəhɛh tee taɛ pəhaɛl khouc sʔɛy phseeŋ phseeŋ tiet tee kɔɔ mɨn dəŋ

7. tom - sdaay nah, baə khñom nɨw cit, khñom nɨŋ məəl, taə via khouc ɛy

8. sok - əñcəŋ. cɛñ pii thəə kaa pəhout tɨw phtéh khñom taɛ mə dɔɔŋ tɨw

9. tom - əñcəŋ cam lŋiac nɨŋ khñom tɨw məəl

NOTES

DIALOGUE

SENTENCE NO.

4. The word ព្រម /próom/ means 'to be willing, to agree to.' Note that it may be used with an inanimate subject to indicate that the thing can't be made to function.

5. ឧស្សាហ៍/əhsaa/ as an adjective means 'to be diligent, industrious.' As a preverbal it means 'often; to be diligent at.'

6. So far you have made negatives with មិន /mɨn/. In speech there is another negator អត់, អិត /ɔt, ət/ which can be used instead of មិន /mɨn/. អត់ /ɔt/ is much rarer in writing than មិន /mɨn/, however.

អិតមាន /ət mian/ can be used instead of គ្មាន /kmian/ 'there isn't, doesn't have.' អិតមាន /ət mian/, គ្មាន /kmian/, and អិត /ət/ can all be used as relators meaning 'without.' (Cf. Drills 7 and 8.)

DRILLS

DRILL NO.

4. រាល់តែ /ról taɛ/ and តែរាល់ /taɛ ról/ mean the same as រាល់ /ról/ 'every, each.' They are used with time words like រាល់ /ról/ 'every.'

## DRILLS

DRILL ONE: Transformation

MODEL: T: ខ្ញុំបញ្ឆេះឡានខ្ញុំដប់មីនុត។

S: ខ្ញុំបញ្ឆេះឡានខ្ញុំអស់ជិតដប់មីនុត។

T: I tried to start my car for ten minutes.

S: I tried to start my car for almost ten minutes.

ក. ខ្ញុំទិញសាច់ម្ភៃដុល្លា។ ខ្ញុំទិញសាច់អស់ជិតម្ភៃដុល្លា។
ខ. ខ្ញុំជិះឡានលោកមួយម៉ោង។ ខ្ញុំជិះឡានលោកអស់ជិតមួយម៉ោង។
គ. ខ្ញុំដើរលេងបីម៉ោង។ ខ្ញុំដើរលេងអស់ជិតបីម៉ោង។
ឃ. ខ្ញុំដូរប្រេងដប់លីត្រ។ ខ្ញុំដូរប្រេងអស់ជិតដប់លីត្រ។
ង. ខ្ញុំដើរដប់គីឡូ។ ខ្ញុំដើរអស់ជិតដប់គីឡូ។
ច. ខ្ញុំត្រូវបង់លុយមួយរយដុល្លា។ ខ្ញុំត្រូវបង់លុយអស់ជិតមួយរយដុល្លា។

DRILL TWO: Transformation

MODEL: T: ខ្ញុំបញ្ឆេះអស់ជិតដប់មីនុត។ (ឆេះ)

S: ខ្ញុំបញ្ឆេះអស់ជិតដប់មីនុត មិនព្រមឆេះ។

T: I tried to start it for almost ten minutes. (start)

S: I tried to start it for almost ten minutes, (but) it won't start.

ក. ខ្ញុំនិយាយជាមួយគាត់អស់ជិតមួយម៉ោង។ (ស្តាប់)
ខ្ញុំនិយាយជាមួយគាត់អស់ជិតមួយម៉ោង មិនព្រមស្តាប់។

ខ. ខ្ញុំឲ្យគាត់ដប់ដុល្លា។ (លក់)
ខ្ញុំឲ្យគាត់ដប់ដុល្លា មិនព្រមលក់។

គ. ខ្ញុំបង្រៀនគាត់មួយម៉ោង។ (យល់)
ខ្ញុំបង្រៀនគាត់មួយម៉ោង មិនព្រមយល់។

ឃ. ខ្ញុំពន្យល់គាត់កន្លះម៉ោង។ (ទិញ)
ខ្ញុំពន្យល់គាត់កន្លះម៉ោង មិនព្រមទិញ។

ង. ខ្ញុំចាំគាត់បីថ្ងៃ។ (មក)
ខ្ញុំចាំគាត់បីថ្ងៃ មិនព្រមមក។

ច. ខ្ញុំអញ្ជើញគាត់បួនដង។ (ចូល)
ខ្ញុំអញ្ជើញគាត់បួនដង មិនព្រមចូល។

DRILL THREE: Transformation

MODEL: T: ខែត្រជាក់ លោកត្រូវឆែកមើលអាគុយ។

S: ខែត្រជាក់ លោកត្រូវឧស្សាហ៍ឆែកមើលអាគុយ។

T: In the cold months, you have to check the battery.

S: In the cold months, you have to check the battery often.

ក. ខ្ញុំសរសេរសំបុត្រទៅឪពុកម្ដាយខ្ញុំ។
ខ្ញុំឧស្សាហ៍សរសេរសំបុត្រទៅឪពុកម្ដាយខ្ញុំ។
ខ. លោកដើរលេងជាមួយពួកម៉ាកស្រីលោក។
លោកឧស្សាហ៍ដើរលេងជាមួយពួកម៉ាកស្រីលោក។
គ. បើលោកមិនយល់លោកត្រូវសួរខ្ញុំ។
បើលោកមិនយល់លោកត្រូវឧស្សាហ៍សួរខ្ញុំ។
ឃ. លោកត្រូវរៀនសរសេរខ្មែរ។
លោកត្រូវឧស្សាហ៍រៀនសរសេរខ្មែរ។
ង. ខ្ញុំធ្វើបាយខ្មែរញ៉ាំ។
ខ្ញុំឧស្សាហ៍ធ្វើបាយខ្មែរញ៉ាំ។
ច. គ្រួសារខ្ញុំទៅមើលកុន។
គ្រួសារខ្ញុំឧស្សាហ៍ទៅមើលកុន។

DRILL FOUR: Transformation

MODEL: T: ឡានខ្ញុំខូចរាល់ថ្ងៃ។
S: ឡានខ្ញុំឧស្សាហ៍ខូចណាស់។
T: My car breaks down every day.
S: My car breaks down very often.

ក. ប្រពន្ធខ្ញុំឈឺរាល់ថ្ងៃ — ប្រពន្ធខ្ញុំឧស្សាហ៍ឈឺណាស់។
ខ. លោកលេងបៀរាល់អាទិត្យ។ — លោកឧស្សាហ៍លេងបៀណាស់។
គ. បងខ្ញុំឱ្យលុយខ្ញុំរាល់ថ្ងៃ។ — បងខ្ញុំឧស្សាហ៍ឱ្យលុយខ្ញុំណាស់។
ឃ. លោកទៅបន្ទប់ទឹករាល់ម៉ោង។ — លោកឧស្សាហ៍ទៅបន្ទប់ទឹកណាស់។
ង. ប្រពន្ធខ្ញុំសរសេរសំបុត្រមកខ្ញុំរាល់អាទិត្យ។ — ប្រពន្ធខ្ញុំឧស្សាហ៍សរសេរសំបុត្រមកខ្ញុំណាស់។
ច. លោកសរសេរខុសរាល់តែពេល។ — លោកឧស្សាហ៍សរសេរខុសណាស់។

DRILL FIVE: Transformation

MODEL: T: លោកចេះធ្វើឡានទេ?
S: ខ្ញុំចង់ដឹងតើលោកចេះធ្វើឡានទេ។
T: Do you know how to fix cars?
S: I want to know whether you know how to fix cars or not.

ក. នាងចង់ទៅញ៉ាំបាយចិនទេ?
ខ្ញុំចង់ដឹងតើនាងចង់ទៅញ៉ាំបាយចិនទេ។
ខ. លោកគ្រូបង្រៀនភាសាបារាំងបានទេ?
ខ្ញុំចង់ដឹងតើលោកគ្រូបង្រៀនភាសាបារាំងបានទេ។
គ. យើងមានកូនសិស្សខ្មែរទេ?
ខ្ញុំចង់ដឹងតើយើងមានកូនសិស្សខ្មែរទេ។

ឃ. លោករៀនខ្មែរនៅផ្ទះរាល់ថ្ងៃទេ?
ខ្ញុំចង់ដឹងតើលោករៀនខ្មែរនៅផ្ទះរាល់ថ្ងៃទេ។
ង. លោកទៅជាមួយខ្ញុំទេ?
ខ្ញុំចង់ដឹងតើលោកទៅជាមួយខ្ញុំទេ។
ច. លោកចិត្តរៀនភាសាខ្មែរទេ?
ខ្ញុំចង់ដឹងតើលោកចូលចិត្តរៀនភាសាខ្មែរទេ។

DRILL SIX. Transformation

MODEL: T: លោកចេះជួសឡានអី?
S: ខ្ញុំចង់ដឹងតើលោកចេះជួសឡានអី។
T: What kind of cars do you know how to fix?
S: I want to know what kind of cars you know how to fix.

ក. នាងចង់ញ៉ាំបាយអី?
ខ្ញុំចង់ដឹងតើនាងចង់ញ៉ាំបាយអី។
ខ. លោកគ្រូបង្រៀនភាសាអី?
ខ្ញុំចង់ដឹងតើលោកគ្រូបង្រៀនភាសាអី។
គ. យើងមានកូនសិស្សខ្មែរប៉ុន្មាននាក់?
ខ្ញុំចង់ដឹងតើយើងមានកូនសិស្សខ្មែរប៉ុន្មាននាក់។
ឃ. លោករៀនខ្មែររាល់ថ្ងៃ?
ខ្ញុំចង់ដឹងតើលោករៀនខ្មែររាល់ថ្ងៃ។
ង. លោកទៅទិញអី?
ខ្ញុំចង់ដឹងតើលោកទៅទិញអី។
ច. លោកចូលចិត្តភាសាអី?
ខ្ញុំចង់ដឹងតើលោកចូលចិត្តភាសាអី។

DRILL SEVEN: Transformation

MODEL: T: ខ្ញុំរៀននិយាយបារាំង។ (គ្រូ)
S: ខ្ញុំរៀននិយាយបារាំងឥតមានគ្រូ។
T: I learned to speak French.
S: I learned to speak French without a teacher.

ក. ខ្ញុំបង្រៀនកូនសិស្ស។ (សៀវភៅ) ខ្ញុំបង្រៀនកូនសិស្សឥតមានសៀវភៅ។
ខ. ខ្ញុំទិញឡានមួយ។ (លុយ) ខ្ញុំទិញឡានមួយឥតមានលុយ។
គ. ខ្ញុំបើកឡាន។ (ប្រេង) ខ្ញុំបើកឡានឥតមានប្រេង។
ឃ. កញ្ញាមករៀន។ (សៀវភៅ) កញ្ញាមករៀនឥតមានសៀវភៅ។
ង. ខ្ញុំជិះឡានឈ្នួល។ (សំបុត្រ) ខ្ញុំជិះឡានឈ្នួលឥតមានសំបុត្រ។
ច. ខ្ញុំញ៉ាំបាយ។ (ត្រី) ខ្ញុំញ៉ាំបាយឥតមានត្រី។

DRILL EIGHT: Extension

MODEL:
T: ខ្ញុំទិញឡានថ្មីមួយ។ (ខ្ចីលុយអ្នកណា)
S: ខ្ញុំទិញឡានថ្មីមួយ ឥតខ្ចីលុយអ្នកណាទេ។
T: I bought a new car.
S: I bought a new car without borrowing money from anyone.

ក. ខ្ញុំធ្វើដំណោទនេះខ្លួនឯង។ (អ្នកណាពន្យល់ខ្ញុំ)
ខ្ញុំធ្វើដំណោទនេះខ្លួនឯងឥតមានអ្នកណាពន្យល់ខ្ញុំទេ។
ខ. ខ្ញុំរៀនបើកឡាន។ (អ្នកណាបង្រៀនខ្ញុំ)
ខ្ញុំរៀនបើកឡានឥតមានអ្នកណាបង្រៀនខ្ញុំទេ។
គ. កូនខ្ញុំទៅដេក។ (អ្នកណាប្រាប់)
កូនខ្ញុំទៅដេកឥតមានអ្នកណាប្រាប់ទេ។
ឃ. ខ្ញុំរុញឡានម្នាក់ឯង។ (អ្នកណាជួយខ្ញុំ)
ខ្ញុំរុញឡានម្នាក់ឯងឥតមានអ្នកណាជួយខ្ញុំទេ។
ង. បងខ្ញុំរៀនធ្វើឡានខ្លួនគាត់។ (អ្នកណាបង្រៀនគាត់)
បងខ្ញុំរៀនធ្វើឡានខ្លួនគាត់ឥតមានអ្នកណាបង្រៀនគាត់ទេ។
ច. ខ្ញុំទិញឡានមួយ។ (អ្នកណាឲ្យខ្ញុំខ្ចីលុយ)
ខ្ញុំទិញឡានមួយឥតមានអ្នកណាឲ្យខ្ញុំខ្ចីលុយទេ។

DRILL NINE: Transformation

MODEL:
T: គេលក់ឡានច្រើនណាស់នៅកន្លែងនោះ។
S: គេលក់ឡានផ្សេងៗនៅកន្លែងនោះ។
T: They sell a lot of cars in that place.
S: They sell various cars in that place.

| | | |
|---|---|---|
| ក. | សាលារដ្ឋការបង្រៀនភាសាច្រើន។ | សាលារដ្ឋការបង្រៀនភាសាផ្សេងៗ។ |
| ខ. | លោកទទួលដំណឹងច្រើន។ | លោកទទួលដំណឹងផ្សេងៗ។ |
| គ. | ខ្ញុំចូលចិត្តអាវច្រើនពណ៌។ | ខ្ញុំចូលចិត្តអាវពណ៌ផ្សេងៗ។ |
| ឃ. | ហាងសៀវភៅនេះលក់សៀវភៅច្រើនភាសា។ | ហាងសៀវភៅនេះលក់សៀវភៅភាសាផ្សេងៗ។ |
| ង. | ខ្ញុំសរសេរច្រើនរបៀប។ | ខ្ញុំសរសេររបៀបផ្សេងៗ។ |
| ច. | ខ្ញុំចូលចិត្តបារីច្រើន។ | ខ្ញុំចូលចិត្តបារីផ្សេងៗ។ |

DRILL TEN: Response

MODEL:
T: លោកចង់ទិញឡានថ្ងៃនេះ។
S: ខ្ញុំដូចមិនចង់ទិញឡានថ្ងៃនេះទេក៏មិនដឹង។
T: I want to buy a car today.
S: I don't know! I don't seem to want to buy a car today.

ក. លោកទៅរៀនថ្ងៃនេះ? — ខ្ញុំដូចមិនទៅរៀនទេក៏មិនដឹង។
ខ. កូនលោកចេះបើកឡានទេ? — កូនខ្ញុំដូចមិនចេះបើកឡានទេក៏មិនដឹង។
គ លោកមើលស្ទូរដាច់ទេ? — ខ្ញុំដូចមើលស្ទូរមិនដាច់ទេក៏មិនដឹង។
ឃ. លោកត្រូវការលុយទេថ្ងៃនេះ? — ខ្ញុំដូចមិនត្រូវការលុយទេក៏មិនដឹង។
ង. ឪពុកម្ដាយលោកប្រញាប់ទៅផ្ទះវិញទេ? — ឪពុកម្ដាយខ្ញុំដូចមិនប្រញាប់ទៅផ្ទះវិញក៏មិនដឹង។
ច. លោកចង់ទៅមើលកុនយប់នេះ? — ខ្ញុំដូចមិនចង់ទៅមើលកុនទេក៏មិនដឹង។

DRILL ELEVEN: Transformation

MODEL:
T: ខ្ញុំចេញពីធ្វើការទៅផ្ទះលោក។
S: ខ្ញុំចេញពីធ្វើការបង្ហួតទៅផ្ទះលោក។
T: After work I'll go to your house.
S: After work I'll go straight to your house.

ក. ខ្ញុំចេញពីធ្វើការទៅញូវយ៉ក។ — ខ្ញុំចេញពីធ្វើការបង្ហួតទៅញូវយ៉ក។
ខ. ខ្ញុំទៅផ្សារទៅមើលកុន។ — ខ្ញុំទៅផ្សារបង្ហួតទៅមើលកុន។
គ. ខ្ញុំចេញពីរៀនទៅផ្ទះម្ដាយខ្ញុំ។ — ខ្ញុំចេញពីរៀនបង្ហួតទៅផ្ទះម្ដាយខ្ញុំ។
ឃ. យើងចេញពីធ្វើការទៅញ៉ាំស្រា។ — យើងចេញពីធ្វើការបង្ហួតទៅញ៉ាំស្រា។
ង. នាងចេញពីធ្វើការមកផ្ទះខ្ញុំ។ — នាងចេញពីធ្វើការបង្ហួតមកផ្ទះខ្ញុំ។
ច. ញ៉ាំបាយរួចទៅសំរាក។ — ញ៉ាំបាយរួចបង្ហួតទៅសំរាក។

## Reading Passage

### ការធ្វើដំណើរនៅភ្នំពេញ

នៅភ្នំពេញ ការធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយនឹងថាពិបាកក៏មិនបានដែរ ព្រោះភ្នំពេញមិនធំប៉ុន្មានទេហើយមិនសូវមានមនុស្សច្រើនផង។ អ្នកធ្វើដំណើរអាចដើរ ជិះកង់ ជិះស៊ីក្លូ ជិះឡានឈ្នួលឬជិះឡានរបស់ខ្លួនឯងក៏បានដែរ។

ការធ្វើដំណើរដោយដើរមិនពិបាកទេ បើពេលណាគ្មានភ្លៀង។ ឯនៅពេលយប់វិញក៏ដូចនៅពេលថ្ងៃដែរ យើងអាចដើរតាមយើងចង់។ នៅភ្នំពេញមានអ្នកដើរច្រើនដែរ។ ភាគច្រើនៗតែកូនសិស្ស ហើយអ្នកដើរជិតទាំងអស់មិនមែនដើរដោយគេចង់ឬចូលចិត្តទេ គេដើរព្រោះគេមិនសូវមានលុយ។

បើយើងមានលុយបន្តិចហើយយើងអាចទិញកង់ដើម្បីជិះបាន យើងឃើញថាស្រួលណាស់ព្រោះផ្លូវភាគច្រើនធំៗហើយត្រង់ៗផង។ ហើយម្យ៉ាងទៀតនៅតាមផ្លូវទាំងនោះមិនសូវមានឡានច្រើនដែរ។ ដូច្នេះអ្នកជិះកង់ស្រួលណាស់ហើយសប្បាយណាស់ដែរ។

ការធ្វើដំណើរតាមស៊ីក្លូស្រួលម្យ៉ាងដែរ។ ពេលខ្លះមានភ្លៀងឬក្ដៅពេកគេចូលចិត្តជិះស៊ីក្លូបើគេគ្មានឡាន។ ជិះស៊ីក្លូមិនអាក្រក់ជាងជិះឡានប៉ុន្មានទេ តែគ្រាន់តែយឺតជាងបន្តិច។ មានអ្នកមានឡានខ្លះ ជួនថ្ងៃណាគេមិនចង់បើកឡានគេទៅ

ធ្វើការ គេជិះស៊ីក្លូ។ តាមធម្មតា មនុស្សធម្មតាមិនសូវហ៊ានជិះស៊ីក្លូទេ ព្រោះថ្លៃបន្តិច។ ប៉ុន្តែ ជួនកាល បើយើងមានលុយបន្តិច នឹងមានពេលទំនេរល្មម ការជិះស៊ីក្លូនៅក្រុងសប្បាយណាស់។

ឯឡានឈ្នួលវិញ យើងមិនទាន់មានល្មមទេ។ ដូច្នេះការធ្វើដំណើរតាមឡានឈ្នួលដូចជាពិបាកបន្តិច។ ឯរឿងពិបាកនេះមិនមែនគ្រាន់តែពិបាកព្រោះយើងមានឡានឈ្នួលតិចទេ គឺពិបាកព្រោះឡានយើងមិនសូវស្អាត ហើយគេដាក់មនុស្សច្រើនពេកនៅក្នុងឡានផង។ ប៉ុន្តែតាមពិត ជិះឡានឈ្នួលថោកជាងជិះស៊ីក្លូ។

បើយើងគិតឲ្យបានឆ្ងាយទៅ នៅភ្នំពេញ រដ្ឋមន្ត្រីនិងទាហានធ្វើការភាគច្រើនមិនត្រូវការឡានទេ ព្រោះពីផ្ទះគេទៅកន្លែងធ្វើការមិនឆ្ងាយប៉ុន្មានទេ បើគេដើរប្រហែលអស់ដប់មិនុតយ៉ាងយូរ។ ប៉ុន្តែបើគេត្រូវការបើកឡានវិញ គេបើកពេលណាក៏បានដែរ។

ដូច្នេះនៅភ្នំពេញ ការធ្វើដំណើរមិនទាន់ពិបាកទេ។

## VOCABULARY

| | | |
|---|---|---|
| កាណូត | kaanout | boat (L) |
| គិតឲ្យមែនទែនទៅ | kɨt aoy mɛɛn tɛɛn tɨw | actually (L) |
| ឆែក | chaɛk | to check |
| ជួនថ្ងៃណា | cuon thŋay naa | some days, sometimes |
| ដឹកនាំ | dək nóm | to transport; to lead (L) |
| តែម្ដង | taɛ mə dɔɔŋ | directly, immediately |
| ទន្លេ | túnlee | river |
| ទំនេរ | tənee | free, not busy (L) |
| ធាក់ | thé? | to kick, to ride a bicycle |
| នឹងថា | nɨŋ thaa | if one were to say (R) |
| បហូត | pəhout` | directly, throughout |
| បញ្ឆេះ | pəchɛh | to start (an engine), to ignite |
| ប្រដូច | pədouc | to compare (L) |
| ប្រហែស | pəhɛh | to neglect |
| ផ្ទាល់ខ្លួន | phtól khluon | personal; selfish |
| ផ្សេងៗ | phseeŋ phseeŋ | different, various |
| ព្រម | próom | to be willing, to agree |
| រត់ | rút | to run, to work, to function |
| រដ្ឋការ | rottəkaa | government, civil service |
| រុញ | ruñ | to push |
| លីត្រ | liit | liter |
| សាធារណរដ្ឋ | saathiarəna?rót | republic (L) |
| សំរាក | səmé? | to relax |
| ស្ដាយ | sdaay | to regret, to be sorry; to be too bad |
| អនុញ្ញាត | anuññat | to give permission; permission (L) |

| | | |
|---|---|---|
| អាគុយ | a?kuy | battery |
| ឧបសគ្គ | opəsa? | obstacle, challenge (L) |
| ឧស្សាហ៍ | əhsaa | often, to be diligent |
| ឥតមាន | ət mian | without |



Sidewalk noodle vendor, Phnom Penh

PASSAGE A



# អណ្ដាតនឹងបេះដូង

មានមួយថ្ងៃបុរសម្នាក់បង្គាប់ទៅបាវថា ចូរឯងចាប់ជ្រូកមួយនៅក្នុងទ្រុងយកទៅសម្លាប់ រួចឯងយកអ្វីដែលល្អជាងគេក្នុងខ្លួនជ្រូកនោះមកឲ្យអញ ។

បាវក៏ចាប់ជ្រូកមួយយកទៅសម្លាប់ ហើយយកបេះដូង នឹង អណ្ដាត មកជូនចៅហ្វាយ ។

ក្រោយនោះបួន-ប្រាំថ្ងៃ ចៅហ្វាយបង្គាប់ទៅបាវដដែល ឲ្យចាប់ជ្រូកមួយទៀតយកទៅសម្លាប់ ហើយឲ្យយកអ្វី ដែលជាអាក្រក់បំផុតវិញមកឲ្យ ។

បាវក៏យកបេះដូងនិងអណ្ដាតមកជូនចៅហ្វាយ ដូចកាលមុនទៀត ។ ចៅហ្វាយក៏សួរទៅបាវថា ហេតុដូចម្ដេច បានជាឯងនៅតែយកបេះដូងនិងអណ្ដាតមកឲ្យអញ ។

បាវឆ្លើយថា សូមលោកជ្រាបថា ល្អនឹងអាក្រក់មកតែពីសំដីនិងចិត្ត ។

| | | |
|---|---|---|
| បេះដូង | bɛh douŋ | heart |
| បុរស | pəroh | a male person (the word ប្រុស /proh/'male'is a derivative of បុរស ) |
| បង្គាប់ | pəkóp | to give an order |
| បាវ | baav | a servant (rare) |
| ចូរ | cou | please, I urge you to..., I want you to... |
| ឯង | aɛŋ | you (non-formal) |
| ទ្រុង | truŋ | cage, pen |
| សំឡាប់ | səlap | to kill |
| អញ | añ | I (non-formal) |
| បំផុត | pəphot | most of all,...est |
| ជ្រាប | criap | to know (formal , to be informed |
| សំដី | səmdɛy | speech, utterance |



Jackfruit

## LESSON THIRTY-SIX

### DIALOGUE

| | | | |
|---|---|---|---|
| | | ចលាចល | disturbance, uprising |
| ១. | សុខ | លោកចាំទេកាលមានចលាចលឆ្នាំទៅ? | Do you remember the riot last year? |
| | | ជាប់ឃុំ | to be in custody |
| ២. | តុម | បាទ ខ្ញុំមិនភ្លេចទេព្រោះខ្ញុំជាប់ឃុំអស់ជិតពីរម៉ោង ។ | Yes, I'll never forget, because I was in custody for almost 2 hours. |
| ៣. | សុខ | ម៉េចបានជាលោកត្រូវគេចាប់? | Why were you arrested? |
| | | រំលោភ (លើ) | to violate |
| | | បំរាមគោចរ | curfew |
| ៤. | តុម | គេថាខ្ញុំរំលោភលើបំរាមគោចរ ។ | They said that I violated the curfew. |
| | | ជាប់ | to be adjacent to, next to |
| | | ជាប់គ្នា | consecutive |
| ៥. | សុខ | គេមិនឲ្យយើងចេញដើរលេងយប់ប្រាំយប់ជាប់គ្នាមែនទេ? | They didn't allow us to go out for five consecutive nights, did they? |
| | | ដើម្បីឲ្យ | so that |
| | | ដើម្បីកុំឲ្យ | so that...not |
| | | គ្រោះថ្នាក់ | accident, danger |
| ៦. | តុម | បាទ ដើម្បីកុំឲ្យយើងមានគ្រោះថ្នាក់ ។ | Yes, so we wouldn't have any accidents. |
| | | បំផុត | (superlative) |
| | | ក្មេងៗ | youths |
| | | ដុត | to burn |
| | | លួច | to steal |
| ៧. | សុខ | ចំបំផុតដើម្បីកុំឲ្យក្មេងៗដុតផ្ទះនិងលួចឥវ៉ាន់ ។ | Especially so that the youths wouldn't burn down houses and loot. |
| | | ទាហាន | soldier, military |
| | | ស្ទើរតែ | almost |
| | | ស្ទើរតែ ... មិន | hardly, almost...not |
| | | ការពារ | to defend, to prevent |
| | | ឈ្នះ | to win, to overcome |
| ៨. | តុម | បាទ ពេលនោះប៉ូលិសនិងទាហានស្ទើរតែការពារមិនឈ្នះ ។ | Yes, that time police and soldiers could hardly stop them. |

DIALOGUE:

1. sok - look cam eh kaal mian cəlaacɔl chnam tɨw?

2. tom - baat, khñom mɨn phlic eeh, pruh khñom cóp khum ɔh cit pii maoŋ

3. sok - mɛc baan cia look trəw kee cap?

4. tom - kee thaa khñom rəmloop ləə pəraam koocɔɔ

5. sok - kee mɨn aoy yəəŋ cɛñ daə leeŋ yup pram yup cóp knia, mɛɛn tee?

6. tom - baat, daəmbɛy kom aoy yəəŋ mian krúh thna?

7. sok - thom mphot daəmbɛy kom aoy kmeeŋ kmeeŋ dot phtéh nɨŋ luoc ɛyvan

8. tom - baat, peel nuh pəlih nɨŋ təhian stəə taɛ kaapia mɨn chnéh

NOTES

DIALOGUE

SENTENCE NO.

3. In Lesson 16 you learned that Cambodian has no passive construction, but it has various ways of translating English passives. In this lesson occurs one of these ways of expressing passive ideas: the verb ត្រូវ /trəw/, which means 'to have an experience, to undergo.' A construction consisting of a subject plus ត្រូវ /trəw/ plus a following noun or clause is most economically analyzed as an active construction, not passive. Thus, for instance,

   យើងត្រូវគេចាប់។
   yəəŋ trəw kee cap
   We were arrested (by them).

   is simply យើងត្រូវ /yəəŋ trəw/ 'we underwent (something)' plus គេចាប់(យើង) /kee cap (yəəŋ)/ 'they arrested (us).' That is 'we underwent something, namely, they arrested us.' Note that when ត្រូវ /trəw/ is followed by an entire clause there is no change of word order in the clause.

   can also be used with certain nouns, e.g.

   យើងត្រូវភ្លៀង។
   yəəŋ trəw phlieŋ
   We were caught in the rain.

6. Remember that the clause relators ដើម្បី /daəmbɛy/ 'in order to' and ដើម្បីឲ្យ /daəmbɛy aoy/ 'so that' have similar meanings, but ដើម្បី /daəmbɛy/ is used when the first and second clauses have the same subject, while ដើម្បីឲ្យ /daəmbɛy aoy/ is used when the first clause has a different subject from that of the second clause (Lesson 22). However, this distinction does not apply when ដើម្បីកុំឲ្យ /daəmbɛy kom aoy/

'so that...not' is used. ដើម្បីកុំឲ្យ /daəmbɛy kom aoy/ is used whether the subjects of the two clauses it relates are the same or different. For example: គាត់លេបថ្នាំដើម្បីកុំឲ្យ(គាត់)ឈឺទៀត។

kót leep thnam daəmbɛy kom aoy (kót) chɨɨ tiet

He took a pill so that he would not be sick again.

វានិយាយតិចៗដើម្បីកុំឲ្យឪពុកវាឮ។

via niyiey tec tec daəmbɛy kom aoy əwpuk via lɨɨ

He speaks softly so that his father won't hear (him).

Note that while in English the clause that follows 'so that' is negated, in Cambodian the corresponding clause is not negated. This is because the negator is contained in the relator in the word កុំ /kom/.

7. Another form of the superlative is adjective plus មផុត /mphot/ (or បំផុត /bɔmphot/), e.g.

អានេះជាផ្ទះថ្លៃមផុត។

aanih cia phtéh thlay mphot

This is the most expensive house.

The construction adjective plus មផុត /mphot/ is similar in meaning to ជាងគេបំផុត /ciaŋ kee bɔmphot/ 'the -est.' Note here that ធំបំផុត /thom bɔmphot/ is used to mean 'especially,' though literally it means 'the biggest.'

7. You now have studied two words for 'burn.' The word ដុត /dot/ means 'to set on fire, to burn something.' ឆេះ /chɛh/, on the other hand, means 'to catch on fire, to be burning, to be burned.'

8. The adverb ស្ទើរតែ /stəə taɛ/ means 'almost,' as in

ខ្ញុំស្គាល់គេស្ទើរតែទាំងអស់។

khñom skól kee stəə taɛ téŋ ɔh

I know almost all of them.

When ស្ទើរតែ /stəə taɛ/ precedes a negated verb, it means 'almost...not' or 'hardly,' e.g.

ខ្ញុំស្តាប់ស្ទើរតែមិនឮទេ។

khñom sdap stəə taɛ mɨn lɨɨ eh

I can hardly hear (I just manage to hear).

Contrasting with ស្ទើរតែមិន /stəə taɛ mɨn/ 'almost...not, to succeed by only a little' is វិះ(តែ) /vih (taɛ)/ 'to just miss, not quite, to fail by only a little.'

ខ្ញុំស្ដាប់វិះតែឮ។

khñom sdap vih taɛ lɨɨ

I can't quite hear (I just miss hearing).

វិះ(តែ) /vih (taɛ)/ is introduced in Drill 10 and វិះ(តែ) /vih (taɛ)/ and ស្ទើរតែ /stəə taɛ/ are contrasted in Drill 11. Note that when they are used with a resultative verb, both can come either before the main verb or before the resultative verb:

ខ្ញុំស្ទើរតែស្ដាប់មិនឮទេ។

khñom stəə taɛ sdap mɨn lɨɨ eh

I can hardly hear.

ខ្ញុំវិះតែស្ដាប់មិនឮទេ។

khñom vih taɛ sdap mɨn lɨɨ eh

I can't quite hear.

DRILLS

DRILL NO.

4. Note the various causative uses of ឲ្យ /aoy/ in this drill. In none of these sentences does ឲ្យ /aoy/ mean 'let, permit.'

DRILLS

DRILL ONE: Transformation

MODEL: T: ប៉ូលិសចាប់ខ្ញុំឃុំ។

S: ខ្ញុំត្រូវប៉ូលិសចាប់ឃុំ។

T: The police arrested me and put me in custody.

S: I was arrested and put in custody by the police.

| | | |
|---|---|---|
| ក. | ឪពុកខ្ញុំមិនឲ្យខ្ញុំញ៉ាំបាយ។ | ខ្ញុំត្រូវឪពុកខ្ញុំមិនឲ្យញ៉ាំបាយ។ |
| ខ. | គ្រូបង្រៀនដាក់ទោសកូនសិស្ស។ | កូនសិស្សត្រូវគ្រូបង្រៀនដាក់ទោស។ |
| គ. | ប៉ូលិសឃុំកូនសិស្សបីថ្ងៃ។ | កូនសិស្សត្រូវប៉ូលិសឃុំបីថ្ងៃ។ |
| ឃ. | គេវាយកូនខ្ញុំបែកក្បាល។ | កូនខ្ញុំត្រូវគេវាយបែកក្បាល។ |
| ង. | ម្ដាយខ្ញុំវាយខ្ញុំច្រើនដងណាស់។ | ខ្ញុំត្រូវម្ដាយខ្ញុំវាយច្រើនដងណាស់។ |
| ច. | ឪពុកម្ដាយខ្ញុំដាក់ទោសខ្ញុំមិនឲ្យដើរលេង។ | ខ្ញុំត្រូវឪពុកម្ដាយខ្ញុំដាក់ទោសមិនឲ្យដើរលេង។ |

DRILL TWO: Transformation

MODEL: T: ខ្ញុំត្រូវប៉ូលីសចាប់ឃុំ។
S: ខ្ញុំត្រូវចាប់ប៉ូលីសឃុំ។
T: I was arrested and put in custody by the police.
S: I have to arrest the police and put them in custody.

| | | |
|---|---|---|
| ក. | ខ្ញុំត្រូវឪពុកខ្ញុំមិនឲ្យញ៉ាំបាយ។ | ខ្ញុំត្រូវមិនឲ្យឪពុកខ្ញុំញ៉ាំបាយ។ |
| ខ. | កូនសិស្សត្រូវគ្រូបង្រៀនដាក់ទោស។ | កូនសិស្សត្រូវដាក់ទោសគ្រូបង្រៀន។ |
| គ. | កូនសិស្សត្រូវប៉ូលីសឃុំបីថ្ងៃ។ | កូនសិស្សត្រូវឃុំប៉ូលីសបីថ្ងៃ។ |
| ឃ. | កូនខ្ញុំត្រូវគេវាយបែកក្បាល។ | កូនខ្ញុំត្រូវវាយគេបែកក្បាល។ |
| ង. | ខ្ញុំត្រូវម្ដាយខ្ញុំវាយច្រើនដងណាស់។ | ខ្ញុំត្រូវវាយម្ដាយខ្ញុំច្រើនដងណាស់។ |
| ច. | ខ្ញុំត្រូវឪពុកម្ដាយខ្ញុំដាក់ទោសមិនឲ្យដើរលេង។ | ខ្ញុំត្រូវដាក់ទោសឪពុកម្ដាយខ្ញុំមិនឲ្យដើរលេង។ |

DRILL THREE: Transformation

MODEL: T: យើងចេញដើរលេងយប់ប្រាំយប់។ (គេ)
S: គេមិនឲ្យយើងចេញដើរលេងយប់ប្រាំយប់។
T: We went out five nights. (they)
S: They didn't allow us to go out at night for five nights.

| | | | |
|---|---|---|---|
| ក. | ខ្ញុំញ៉ាំបាយ។ | (ឪពុកខ្ញុំ) | ឪពុកខ្ញុំមិនឲ្យខ្ញុំញ៉ាំបាយ។ |
| ខ. | កូនសិស្សចេញទៅផ្ទះម៉ោងប្រាំ។ | (លោកគ្រូ) | លោកគ្រូមិនឲ្យកូនសិស្សចេញទៅផ្ទះម៉ោងប្រាំ។ |
| គ. | លោកនិយាយអង់គ្លេសក្នុងថ្នាក់។ | (ខ្ញុំ) | ខ្ញុំមិនឲ្យលោកនិយាយអង់គ្លេសក្នុងថ្នាក់។ |
| ឃ. | ទាហានការពារផ្ទះខ្ញុំ។ | (ខ្ញុំ) | ខ្ញុំមិនឲ្យទាហានការពារផ្ទះខ្ញុំ។ |
| ង. | ខ្ញុំរំលោភលើបំរាមគោចរ។ | (គេ) | គេមិនឲ្យខ្ញុំរំលោភលើបំរាមគោចរ។ |
| ច. | ប៉ូលីសចាប់ខ្ញុំ។ | (ឪពុកម្ដាយខ្ញុំ) | ឪពុកម្ដាយខ្ញុំមិនឲ្យប៉ូលីសចាប់ខ្ញុំ។ |

DRILL FOUR: Transformation

MODEL: T: ឪពុកខ្ញុំប្រាប់ខ្ញុំឲ្យដើរលេងយប់។
S: ឪពុកខ្ញុំប្រាប់ខ្ញុំមិនឲ្យដើរលេងយប់ទេ។
T: My father told me to go out at night.
S: My father told me not to go out at night.

ក. លោកគ្រូបង្រៀនខ្ញុំឲ្យនិយាយអង់គ្លេស។
លោកគ្រូបង្រៀនខ្ញុំមិនឲ្យនិយាយអង់គ្លេសទេ។

ខ. ខ្ញុំប្រើឡានលោកឲ្យខូច។
ខ្ញុំប្រើឡានលោកមិនឲ្យខូចទេ។

គ. គាត់លាងកែវលោកឲ្យបែក ។
   គាត់លាងកែវលោកមិនឲ្យបែកទេ ។
ឃ. ខ្ញុំពន្យល់ប្រពន្ធខ្ញុំឲ្យស្ដាប់ម្ដាយគាត់ ។
   ខ្ញុំពន្យល់ប្រពន្ធខ្ញុំមិនឲ្យស្ដាប់ម្ដាយគាត់ទេ ។
ង. ខ្ញុំប្រាប់ប៉ូលិសឲ្យការពារផ្ទះឪពុកខ្ញុំ ។
   ខ្ញុំប្រាប់ប៉ូលិសមិនឲ្យការពារផ្ទះឪពុកខ្ញុំទេ ។
ច. គាត់បង្រៀនខ្ញុំធ្វើឡានឲ្យល្អ ។
   គាត់បង្រៀនខ្ញុំធ្វើឡានមិនឲ្យល្អទេ ។

DRILL FIVE: Transformation

MODEL: T: គេមិនឲ្យយើងចេញដើរលេងប្រាំយប់ ។
S: គេមិនឲ្យយើងចេញដើរលេងប្រាំយប់ជាប់គ្នា ។
T: They didn't allow us to go out for five nights.
S: They didn't allow us to go out for five consecutive nights.

ក. លោកឈប់រៀនប្រាំថ្ងៃ ។ — លោកឈប់រៀនប្រាំថ្ងៃជាប់គ្នា ។
ខ. ខ្ញុំបង្រៀនបីម៉ោង ។ — ខ្ញុំបង្រៀនបីម៉ោងជាប់គ្នា ។
គ. ខ្ញុំឲ្យកូនសិស្សបីនាក់អង្គុយ ។ — ខ្ញុំឲ្យកូនសិស្សបីនាក់អង្គុយជាប់គ្នា ។
ឃ. កូនខ្ញុំនឹងខ្ញុំដើរ ។ — កូនខ្ញុំ នឹងខ្ញុំដើរជាប់គ្នា ។
ង. លោកសរសេរអក្សរខ្មែរ ។ — លោកសរសេរអក្សរខ្មែរជាប់គ្នា ។
ច. ខ្ញុំវាយគាត់បួនដង ។ — ខ្ញុំវាយគាត់បួនដងជាប់គ្នា ។

DRILL SIX: Extension

MODEL: T: គេមិនឲ្យយើងចេញដើរលេងយប់ ។ (មានគ្រោះថ្នាក់)
S: ដើម្បីកុំឲ្យយើងមានគ្រោះថ្នាក់ ។
T: They didn't allow us to go out at night. (have an accident)
S: So that we wouldn't have an accident.

ក. ខ្ញុំយកសៀវភៅពីកូនសិស្ស ។ (មើល) — ដើម្បីកុំឲ្យកូនសិស្សមើល ។
ខ. ខ្ញុំមិនឲ្យលុយកូនខ្ញុំ ។ (បង់ថ្លៃសាលា) — ដើម្បីកុំឲ្យកូនខ្ញុំបង់ថ្លៃសាលា ។
គ. ខ្ញុំដាក់កែវក្នុងទូ ។ (បែក) — ដើម្បីកុំឲ្យកែវបែក ។
ឃ. គេមិនឲ្យក្មេងៗដើរលេងយប់ ។ (លួចឥវ៉ាន់) — ដើម្បីកុំឲ្យក្មេងៗលួចឥវ៉ាន់ ។
ង. ខ្ញុំមិនប្រាប់លោកទេ ។ (ស្ដាយ) — ដើម្បីកុំឲ្យលោកស្ដាយ ។
ច. ប្រពន្ធខ្ញុំមិនប្រើខ្ញុំច្រើនទេ ។ (អស់កម្លាំង) — ដើម្បីកុំឲ្យខ្ញុំអស់កម្លាំង ។
ឆ. ឪពុកវាមិនឲ្យវាលេងបៀ ។ (ចាញ់) — ដើម្បីកុំឲ្យវាចាញ់ ។

DRILL SEVEN: Response

MODEL: T: ខ្ញុំត្រូវយកសៀវភៅណា? (ធំ)
S: លោកត្រូវយកសៀវភៅធំបំផុត។
T: Which book do I have to take? (big)
S: You have to take the biggest book.

ក. ខ្ញុំដើរយ៉ាងមេច? (យឺត) លោកដើរយឺតបំផុត។
ខ. ខ្ញុំសរសេរអក្សរខ្មែរល្អទេ? (អាក្រក់) លោកសរសេរអក្សរខ្មែរអាក្រក់បំផុត។
គ. កូនខ្ញុំឧស្សាហ៍រៀនទេ? (ខ្ជិល) កូនលោកខ្ជិលរៀនបំផុត។
ឃ. លោកសម្រាន្តប៉ុន្មានម៉ោង? (ច្រើន) ខ្ញុំគេងច្រើនបំផុត។
ង. ប្រពន្ធលោកពិសាច្រើនទេ? (តិច) ប្រពន្ធខ្ញុំញ៉ាំតិចបំផុត។
ច. ប្តីលោកស្រីនិយាយទេ? (ច្រើន) ប្តីខ្ញុំនិយាយច្រើនបំផុត។

DRILL EIGHT: Substitution

MODEL: T: ទាហានស្ទើរតែការពារមិនឈ្នះ។ (ខ្ញុំ)
S: ខ្ញុំស្ទើរតែការពារមិនឈ្នះ។
T: The soldier just barely managed to defend (it). (I)
S: I just barely managed to defend (it),

ក. ខ្ញុំស្ទើរតែការពារមិនឈ្នះ។ (បាន)
ខ. ខ្ញុំស្ទើរតែការពារមិនបាន។ (ស្តាប់)
គ. ខ្ញុំស្ទើរតែស្តាប់មិនបាន។ (រៀន)
ឃ. ខ្ញុំស្ទើរតែរៀនមិនបាន។ (ចប់)
ង. ខ្ញុំស្ទើរតែរៀនមិនចប់។ (មើល)
ច. ខ្ញុំស្ទើរតែមើលមិនចប់។

DRILL NINE: Transformation

MODEL: T: ប៉ូលិសនឹងទាហានការពារទីក្រុងឈ្នះ។
S: ប៉ូលិសនឹងទាហានការពារទីក្រុងស្ទើរតែមិនឈ្នះ។
T: Police and soldiers successfully defended the city.
S: Police and soldiers just barely managed to defend the city.

ក. ខ្ញុំទៅសាលារៀនព្រឹកមិញ។ ខ្ញុំស្ទើរតែមិនទៅសាលារៀនព្រឹកមិញ។
ខ. ខ្ញុំស្តាប់ប្រពន្ធខ្ញុំបាន។ ខ្ញុំស្តាប់ប្រពន្ធខ្ញុំស្ទើរតែមិនបាន។
គ. កូនខ្ញុំញ៉ាំបាយអស់។ កូនខ្ញុំញ៉ាំបាយស្ទើរតែមិនអស់។
ឃ. ព្រឹកមិញខ្ញុំទៅសាលាទាន់ម៉ោង។ ព្រឹកមិញខ្ញុំទៅសាលាស្ទើរតែមិនទាន់ម៉ោង។
ង. ខ្ញុំមានលុយបង់ថ្លៃសាលា។ ខ្ញុំស្ទើរតែគ្មានលុយបង់ថ្លៃសាលា។
ច. ខ្ញុំទិញឡានបាន។ ខ្ញុំទិញឡានស្ទើរតែមិនបាន។

DRILL TEN: Response

MODEL: T: បូលីសការពារឈ្នះទេ?

S: បូលីសការពាររះឈ្នះ។

T: Did the police manage to defend (it)?

S: The police just missed defending (it) successfully.

ក. ព្រឹកមិញលោកអញ្ជើញទៅរៀនទាន់ទេ? ព្រឹកមិញខ្ញុំទៅរៀនរះទាន់។

ខ. ឡានលោកខូចទេ? ឡានខ្ញុំរះខូច។

គ. លោកឈឺទេ? ខ្ញុំរះឈឺ។

ឃ. ប្រពន្ធលោកអញ្ជើញមកទាន់លោកទេ? ប្រពន្ធខ្ញុំមករះទាន់ខ្ញុំ។

ង. កែវនោះបែកទេ? កែវនេះរះបែក។

ច. លោកឃើញប្រពន្ធលោកនៅកន្លែងនោះទេ? ខ្ញុំរះឃើញប្រពន្ធខ្ញុំនៅកន្លែងនោះ។

ឆ. ប្រពន្ធខ្ញុំប្រឡងជាប់ទេ? ប្រពន្ធលោកប្រឡងរះជាប់។

DRILL ELEVEN: Response

MODEL$_1$: T: បូលីសការពារឈ្នះទេ? (បាទ)

S: បូលីសការពារស្ទើរតែមិនឈ្នះ។

MODEL$_2$. T: បូលីសការពារឈ្នះទេ? (ទេ)

S: បូលីសការពាររះឈ្នះ។

T: Did the police manage to defend (it)? (yes)

S: The police just managed to defend (it).

T: Did the police manage to defend (it)? (no)

S: The police just missed being able to defend (it).

ក. វាទៅដល់ទេ? (បាទ) វាទៅស្ទើរតែមិនដល់។

ខ. វាមើលខ្ញុំឃើញទេ? (ទេ) វាមើលលោករះឃើញ។

គ. វាមើលសៀវភៅនោះជាប់ទេ? (បាទ) វាមើលសៀវភៅនោះស្ទើរតែមិនជាប់។

ឃ. អ្នកគ្រូឲ្យបងខ្ចីលុយបងទេ? (ទេ) អ្នកគ្រូរះឲ្យបងខ្ចីលុយបង។

ង. ប្រពន្ធលោកឲ្យបងលោកទៅទេ? (ទេ) ប្រពន្ធខ្ញុំរះឲ្យបងខ្ញុំទៅ។

ច. គាត់ទិញឡាននោះទេ? (បាទ) គាត់ស្ទើរតែមិនទិញឡាននោះ។

ឆ. វាទៅទាន់ទេ? (ទេ) វាទៅរះទាន់។

ជ. គាត់ស្លាប់ទេ? (ទេ) គាត់រះស្លាប់។

Reading Passage

កាលខ្ញុំនៅក្មេង

នៅពេលចូលរៀនខ្ញុំទៅរៀនរាល់ថ្ងៃ ដល់ខ្ញុំត្រឡប់មកផ្ទះវិញខ្ញុំត្រូវរៀនខ្លួនឯងថែមទៀត ព្រោះខ្ញុំជាកូនសិស្សល្ងង់ជាងកូនសិស្សឯទៀតដែលរៀនជាមួយខ្ញុំ ។ តែខ្ញុំមិនដែលរៀននៅផ្ទះដល់ខ្ញុំនៅនោះទេ។ ខ្ញុំធ្លាប់តែទៅរៀននៅផ្ទះញាតិម្នាក់ខ្ញុំឬនៅកន្លែងផ្សេងៗឯ

ទៀត។ ខ្ញុំធ្វើយ៉ាងនេះ ព្រោះបើខ្ញុំនៅផ្ទះខ្ញុំត្រូវធ្វើការក្នុងផ្ទះ ដូច្នេះខ្ញុំគិតថាខ្ញុំរៀនមិនបានទេ។

កាលនោះខ្ញុំចង់រៀនណាស់។ ខ្ញុំគិតថាខ្ញុំត្រូវតែរៀនដើម្បីឲ្យបានធ្វើធំ មានឡានជិះ មានផ្ទះនៅនិងមានប្រពន្ធល្អ។ ព្រោះតែហេតុទាំងនោះខ្ញុំរៀនច្រើនណាស់ ហើយតាមពិតខ្ញុំរៀនច្រើនមែន។ តែការរៀនរបស់ខ្ញុំមិនសូវបានចំរើនប៉ុន្មានទេ ខ្ញុំនៅតែជាកូនសិស្សខ្សោយជាងគេដដែល។

ដូច្នេះខ្ញុំពិបាកណាស់។ នៅសាលាគ្រូមិនសូវចូលចិត្ត ឯនៅផ្ទះវិញគេមិនចូលចិត្តខ្ញុំសោះ។ ការដែលមិនចូលចិត្តខ្ញុំសោះនោះ មិនខុសទេ។ ហើយខ្ញុំដឹងថាខ្លួនខ្ញុំខុសជាប្រាកដ។ ខ្ញុំនៅផ្ទះគេ ខ្ញុំគ្មានឲ្យប្រយោជន៍អីទៅគេទេ តែខ្ញុំរកប្រយោជន៍សម្រាប់ខ្លួនខ្ញុំទៅវិញ។ ហើយតាមខ្ញុំដឹង មិនមែនតែពីរឿងប្រយោជន៍នោះទេដែលធ្វើឲ្យគេមិនចូលចិត្តខ្ញុំ មានរឿងច្រើនទៀត។ តែរឿងដែលសំខាន់ជាងគេ គឺមកពីគេមិនដែលឃើញខ្ញុំរៀននៅផ្ទះសោះ ហើយគេគិតថាខ្ញុំគិតតែដើរលេង។ ត្រង់នេះ ខ្ញុំខុសទៀត ព្រោះខ្ញុំមិនដែលប្រាប់គេថាខ្ញុំទៅណាឬមកពីណាទេ។ ហើយតាមពិតគេមិនដឹងថាខ្ញុំទៅណាឬមកពីណាមែន តែគេដឹងយ៉ាងប្រាកដថាខ្ញុំទៅដល់ផ្ទះវិញនៅរាល់ពេលបាយ។

ព្រោះខ្ញុំធ្វើយ៉ាងនោះ ខ្ញុំនៅមួយកន្លែងមិនបានយូរទេ យ៉ាងយូរណាស់មួយឆ្នាំ។ ខ្ញុំទៅពីផ្ទះមួយទៅផ្ទះមួយ គឺពីផ្ទះបងខ្ញុំទៅផ្ទះមាខ្ញុំ រួចទៅផ្ទះពួកម៉ាកខ្ញុំ ហើយរួចហើយត្រឡប់ទៅផ្ទះបងខ្ញុំវិញ។

ពិតមែនតែខ្ញុំដឹងថាបងខ្ញុំ មាខ្ញុំនឹងគេរំលឹលខ្ញុំ នៅជាមួយនោះមិនចូលចិត្តខ្ញុំ ខ្ញុំនៅតែដើរផ្លូវដដែល។ ព្រោះខ្ញុំគិតថាអ្នកណាគិតយ៉ាងម៉េចពីខ្ញុំគិតចុះ បើគេមិនឲ្យខ្ញុំនៅជាមួយគេទៀត ខ្ញុំរកកន្លែងផ្សេងនៅទៀត។

ឯរឿងខ្ញុំមិនរៀននៅផ្ទះនោះ មិនមែនគ្រាន់តែមកពីខ្ញុំគិតថាខ្ញុំរៀនមិនបានទេ តែមកពីខ្ញុំគិតពីរឿងដើរលេងដែរ។ ហើយរឿងដើរលេងនេះខ្ញុំចូលចិត្តណាស់ ខ្ញុំចូលចិត្តដល់ទៅមិនគិតពីកន្លែងនៅទៀតផង។ តែខ្ញុំមិនដើរលេងឲ្យច្រើនជាងក្មេងទូទៅទេ ខ្ញុំគ្រាន់តែដើរលេងដើម្បីឲ្យសប្បាយល្មមទេ។

នេះជារឿងមួយរបស់ខ្ញុំកាលខ្ញុំនៅក្មេង។

VOCABULARY

| | | |
|---|---|---|
| កញ្ឆា | kəchaa | marijuana (L) |
| ការពារ | kaapia | to protect, to defend |
| ក្មេងៗ | khmeeŋ khmeeŋ | youth, children |
| ខឹង | khəŋ | angry (L) |
| ខ្ជិល | khcɨl | lazy |
| ឃុំ | khum | to put in custody |
| ចលាចល | cəlaacɔl | disturbance, riot |
| ចាញ់ | cañ | to lose (a game or competition) |
| ចំរើន | cəraən | increase, profit, advantage, progress (L) |

| | | |
|---|---|---|
| ជាប់ | cóp | to be adjacent to; to pass a test; to go to jail |
| ជាប់គ្នា | cóp knia | consecutive |
| ជាប់ឃុំ | cóp khum | to be in custody |
| ឈ្នះ | chnéh | to win, to overcome |
| ដាក់ទោស | da? tooh | to punish |
| ដុត | dot | to burn |
| ដើម្បីឲ្យ | daəmbεy aoy | so that |
| ដើម្បីកុំឲ្យ | daəmbεy kom aoy | so that...not... |
| ត្រង់នេះ | troŋ nih | in this place, with respect to this point (R) |
| ទទួលទោស | tətuol tooh | to be punished (L) |
| ទាហាន | təhian | soldier |
| ទីក្រុង | tii kroŋ | city |
| ទោស | tooh | guilt, punishment, blame (L) |
| ធ្ងន់ | thŋún | heavy, serious (L) |
| បែក | baεk | to be broken |
| បំផុត | mphot | superlative marker |
| បំរាមគោចរ | pəraam koocɔɔ | curfew |
| ប្រដៅ | pədaw | to give advice, to teach manners (L) |
| ប្រជុំ | pəcum | to meet (group) (L) |
| ពាក្យធំៗ | pia? thom thom | rude words, back talk |
| មានទោស | mian tooh | to be punished (L) |
| រំលោភលើ | rəmloop ləə | to violate |
| លួច | luoc | to steal |
| វាយ | vay | to attack, to hit |
| វិះ | vih | to miss, just missed |
| ស្ទើរតែ | stəə taε | almost |
| ស្ទើរតែ ... មិន | stəə taε...mɨn | hardly, almost...not |

## LESSON THIRTY-SEVEN

## DIALOGUE

| | | | |
|---|---|---|---|
| | | ប្រធានាធិបតី | president of a country |
| | | សម្លាប់ | to kill |
| ១. | សុខ | លោកប្រធានាធិបតីកេណ្ណឌី ត្រូវគេសម្លាប់នៅឆ្នាំណា ? | In what year was President Kennedy killed? |
| ២. | ភុម | នៅឆ្នាំមួយពាន់ប្រាំបួនរយហុកបី ។ | In 1963. |
| | | ធ្វើឃាត | to assassinate, to murder |
| ៣. | សុខ | គេធ្វើឃាតគាត់នៅកន្លែងណា ? | Where did they assassinate him? |
| | | បាញ់ | to shoot |
| | | លួច | to steal |
| | | លួច + V | to do something on the sly; to do surreptitiously |
| | | លួចបាញ់ | to snipe |
| ៤. | ភុម | គេបានលួចបាញ់គាត់នៅទីក្រុងដាឡាស ។ | They shot him in the city of Dallas. |
| | | អ្នក | (personifier) 'the one who' |
| ៥. | សុខ | អ្នកណាជាអ្នកសម្លាប់លោកកេណ្ណឌី ? | Who was Mr. Kennedy's killer? |
| | | គឺ | to be |
| ៦. | ភុម | គឺលោកលីហាវីអូស្វល ។ | It was Lee Harvey Oswald. |
| | | ក្នុងពេលថ្មីៗនេះ | recently, lately |
| | | ឃាតកម្ម | murder, assassination |
| ៧. | សុខ | ក្នុងពេលថ្មីៗនេះ មានឃាតកម្មណាសំខាន់ទៀតទេ ? | Recently have there been any other important assassinations? |
| ៨. | ភុម | បាទ ក្នុងឆ្នាំមួយពាន់ប្រាំបួនរយហុកប្រាំបីមានពីរ ។ | Yes, in 1968 there were two. |
| ៩. | សុខ | អ្នកណាខ្លះត្រូវគេធ្វើឃាត ? | Who got assassinated? |
| ១០. | ភុម | លោក ម. ល. ឃីង ហើយនឹងប្អូនប្រុសលោកកេណ្ណឌី ។ | Mr. Martin Luther King and Mr. Kennedy's brother. |

DIALOGUE:

1. sok - look pəthianiathɨppədɛy Kennedy trəw kee səlap nɨw chnam naa?
2. tom - nɨw chnam mə pón pəmbuon róoy hok bɛy
3. sok - kee thəə khiat kót nɨw kəlaɛŋ naa?
4. tom - kee baan luoc bañ kót nɨw tii krɔŋ Dallas
5. sok - néʔnaa cia néʔ səlap look Kennedy?
6. tom - kɨɨ look Lee Harvey Oswald
7. sok - knoŋ peel thmɛy thmɛy nih mian khiatəkam naa səkhan tiet tee?
8. tom - baat, knoŋ chnam mə pón pəmbuon róoy hok pəmbɛy mian pii
9. sok - néʔnaa khlah trəw kee thəə khiat?
10. tom - look Martin Luther King haəy nɨŋ pʔoun proh look Kennedy

## NOTES

## DIALOGUE

This dialogue is written in a rather elevated style of speech, with features that are more common in writing than in spoken usage. Some of these features are:

1. ត្រូវ /trəw/ with passive meaning (Lesson 36).
2. នៅ /nɨw/ with a time expression.
3. The words ធ្វើឃាត /thəə khiat/ and ឃាតកម្ម/khiatəkam/.
4. បាន /baan/ before a verb indicating past tense (Lesson 21).

SENTENCE NO.

1. Normally time expressions can be used in a sentence without the word នៅ /nɨw/ 'in, at.' If នៅ /nɨw/ is used, it indicates a more formal style level of speech or writing.

2. When a tens number that ends in សិប /-səp/ is followed by another number, it is frequently abbreviated by dropping the សិប /səp/, e.g. សាមបួន /saam buon/ 'thirty-four' for សាមសិបបួន /saam səp buon/. This kind of abbreviation occurs only in speech, never in written style.

4. The word លួច /luoc/ means 'to steal,' but when it is used before another verb it means 'to do on the sly, to do surreptitiously, to do without letting others know, to do sneakily.' For example,

   មាខ្ញុំលួចដើរលេងគ្មានឲ្យមីងខ្ញុំដឹង។
   miá khñom luoc daə leeŋ kmián aoy miiŋ khñom dəŋ
   My uncle sneaks out for a good time without letting my aunt know.

5. Review Lesson 19 for a description of អ្នក /néʔ/ 'the one who...'

6. គឺ /kɨɨ/ is like ជា /cia/ 'is' except that គឺ /kɨɨ/ can mean 'that is to say, that is, namely,' and ជា /cia/ is not used this way. Otherwise ជា /cia/ is used much more often than គឺ /kɨɨ/. គឺ /kɨɨ/ occurs usually when the noun following it refers to a specific individual or set or is a name. See also R.2.1 in the grammatical sketch.

DRILLS

DRILL NO.

7. The phrase ត្រូវជា... នឹង /trəw cia...nɨŋ/ is '...is related as...to,' e.g.

   គ្រូខ្ញុំត្រូវជាមីងនឹងប្រពន្ធខ្ញុំ។
   kruu khñom trəw cia miiŋ nɨŋ propun khñom
   My teacher is my wife's aunt. (My teacher is related as aunt to my wife.)

8. Note the use of the indefinite ប៉ុន្មាន /pəmaan/ 'however many' in the idiom ...ទាំងប៉ុន្មាន... ទាំងអស់/...téŋ pəmaan...téŋ ɔh/ 'however many...all of them.' The portion of the sentence with ទាំងប៉ុន្មាន /téŋ pəmaan/ must precede the portion with ទាំងអស់/téŋ ɔh/.

9. Both ក្នុងពេលថ្មីៗនេះ /knoŋ peel thmɛy thmɛy nih/ and ពេលថ្មីៗនេះ /thmɛy thmɛy nih/ mean 'recently.'

10. Note that មិនតែប៉ុណ្ណោះ... ទៀត /mɨn taɛ pənnoh...tiet/ means 'not only that but...in addition, too.'

DRILLS

DRILL ONE: Transformation

MODEL: T: អ្នកណាសម្លាប់លោកកេណ្ណឌី?
S: លោកកេណ្ណឌីត្រូវអ្នកណាសម្លាប់?
T: Who killed Mr. Kennedy?
S: Mr. Kennedy was killed by whom?

| | |
|---|---|
| ក. អ្នកណាបង្រៀនលោក? | លោកត្រូវអ្នកណាបង្រៀន។ |
| ខ. អ្នកណាទាញលោក? | លោកត្រូវអ្នកណាទាញ។ |
| គ. អ្នកណាវាយកូនលោក? | កូនលោកត្រូវអ្នកណាវាយ។ |
| ឃ. លោកគ្រូណាដាក់ទោសកូនលោក? | កូនលោកត្រូវលោកគ្រូណាដាក់ទោស។ |
| ង. អ្នកណាចាប់ប្រពន្ធលោក? | ប្រពន្ធលោកត្រូវអ្នកណាចាប់។ |
| ច. អ្នកណាដុតផ្ទះលោក? | ផ្ទះលោកត្រូវអ្នកណាដុត។ |

DRILL TWO: Transformation

MODEL: T: លោកកេណ្ណឌីត្រូវគេបាញ់។

S: លោកកេណ្ណឌីត្រូវគេលួចបាញ់។

T: Mr. Kennedy was shot.

S: Mr. Kennedy was (sneakily) shot.

| | | |
|---|---|---|
| ក. | ឡានខ្ញុំត្រូវគេវាយបែកចង្កៀង។ | ឡានខ្ញុំត្រូវគេលួចវាយបែកចង្កៀង។ |
| ខ. | កូនស្រីខ្ញុំត្រូវគេចាប់។ | កូនស្រីខ្ញុំត្រូវគេលួចចាប់។ |
| គ. | ផ្ទះខ្ញុំត្រូវគេចូល។ | ផ្ទះខ្ញុំត្រូវគេលួចចូល។ |
| ឃ. | បងខ្ញុំត្រូវគេសម្លាប់។ | បងខ្ញុំត្រូវគេលួចសម្លាប់។ |
| ង. | ឡានខ្ញុំត្រូវគេដឹក។ | ឡានខ្ញុំត្រូវគេលួចដឹក។ |
| ច. | សៀវភៅខ្ញុំត្រូវគេហែក។ | សៀវភៅខ្ញុំត្រូវគេលួចហែក។ |

DRILL THREE: Transformation

MODEL: T: កូនខ្ញុំទៅមើលកុន។

S: កូនខ្ញុំលួចទៅមើលកុន។

T: My kids went to see a movie.

S: My kids sneaked out to see a movie.

| | | |
|---|---|---|
| ក. | ម៉ិសមិញខ្ញុំមើលនាងពីផ្ទះខ្ញុំ។ | ម៉ិសមិញខ្ញុំលួចមើលនាងពីផ្ទះខ្ញុំ។ |
| ខ. | ខ្ញុំរៀនខ្មែរនៅផ្ទះ។ | ខ្ញុំលួចរៀនខ្មែរនៅផ្ទះ។ |
| គ. | ប្រពន្ធខ្ញុំទិញម្ហូបមួយ។ | ប្រពន្ធខ្ញុំលួចទិញម្ហូបមួយ។ |
| ឃ. | ខ្ញុំលេងបៀនៅផ្ទះ។ | ខ្ញុំលួចលេងបៀនៅផ្ទះ។ |
| ង. | កូនខ្ញុំញ៉ាំស្រា។ | កូនខ្ញុំលួចញ៉ាំស្រា។ |
| ច. | សីអូស្វ័លបាញ់លោកកេណ្ណឌី។ | សីអូស្វ័លលួចបាញ់លោកកេណ្ណឌី។ |

DRILL FOUR: Transformation

MODEL: T: កូនខ្ញុំលួចទៅមើលកុន។ (ខ្ញុំ)

S: កូនខ្ញុំទៅមើលកុនមិនឱ្យខ្ញុំដឹង។

T: My kids sneaked out to see a movie. (me)

S: My kids went to see a movie without letting me know.

ក. ម៉ិសមិញខ្ញុំលួចមើលនាងពីផ្ទះខ្ញុំ។ (ប្រពន្ធខ្ញុំ)
ម៉ិសមិញខ្ញុំមើលនាងពីផ្ទះខ្ញុំមិនឱ្យប្រពន្ធខ្ញុំដឹង។

ខ. លោកលួចរៀនខ្មែរនៅផ្ទះ។ (ពួកម៉ាកលោក)
លោករៀនខ្មែរនៅផ្ទះមិនឱ្យពួកម៉ាកលោកដឹង។

គ. ប្រពន្ធខ្ញុំលួចទិញម្ហូបមួយ។ (ខ្ញុំ)
ប្រពន្ធខ្ញុំទិញម្ហូបមួយមិនឱ្យខ្ញុំដឹង។

ឃ. ខ្ញុំលួចលេងបៀនៅផ្ទះ។ (ប៉ូលីស)
ខ្ញុំលេងបៀនៅផ្ទះមិនឱ្យប៉ូលីសដឹង។

ង. ប្អូនខ្ញុំលួចញ៉ាំស្រា។ (ប្រពន្ធខ្ញុំ)
ប្អូនខ្ញុំញ៉ាំស្រាមិនឲ្យប្រពន្ធខ្ញុំដឹង។
ច. ខ្ញុំលួចចេញពីថ្នាក់។ (អ្នកគ្រូ)
ខ្ញុំចេញពីថ្នាក់មិនឲ្យអ្នកគ្រូដឹង។

DRILL FIVE: Transformation

MODEL: T: លីអូស្វល់ជាអ្នកសម្លាប់លោកកេណ្ណឌី។
S: អ្នកសម្លាប់លោកកេណ្ណឌីគឺលីអូស្វល់។
T: Lee Oswald is Mr. Kennedy's killer.
S: Mr. Kennedy's killer is Lee Oswald.

ក. បារីកប៉ាល់ហោះជាបារីល្អ។ | បារីល្អគឺបារីកប៉ាល់ហោះ។
ខ. លោកសុខជាគ្រូបង្រៀនខ្ញុំ។ | គ្រូបង្រៀនខ្ញុំគឺលោកសុខ។
គ. ខោអាវខៀវជាខោអាវខ្ញុំ។ | ខោអាវខ្ញុំគឺខោអាវខៀវ។
ឃ. លោកស្រីពាក់អាវក្រហមជាប្រពន្ធខ្ញុំ។ | ប្រពន្ធខ្ញុំគឺលោកស្រីពាក់អាវក្រហម។
ង. អាមួយលេងក្បែរតុនោះជាកូនខ្ញុំ។ | កូនខ្ញុំគឺអាមួយលេងក្បែរតុនោះ។
ច. ឡានត្រាយយ៉ុមពណ៌សជាឡានប្រពន្ធខ្ញុំ។ | ឡានប្រពន្ធខ្ញុំគឺឡានត្រាយយ៉ុមពណ៌ស។

DRILL SIX: Transformation

MODEL: T: លីអូស្វល់សម្លាប់លោកកេណ្ណឌី។
S: លីអូស្វល់ជាអ្នកសម្លាប់លោកកេណ្ណឌី។
T: Lee Oswald killed Mr. Kennedy.
S: Lee Oswald is the killer of Mr. Kennedy.

ក. ខ្ញុំបើកឡានឲ្យសាលាអង្គរ។ | ខ្ញុំជាអ្នកបើកឡានឲ្យសាលាអង្គរ។
ខ. ខ្ញុំមើលកូនលោក។ | ខ្ញុំជាអ្នកមើលកូនលោក។
គ. កញ្ញាលក់សៀវភៅនៅហាងនោះ។ | កញ្ញាជាអ្នកលក់សៀវភៅនៅហាងនោះ។
ឃ. ខ្ញុំឆែកសំបុត្រកូន។ | ខ្ញុំជាអ្នកឆែកសំបុត្រកូន។
ង. កូនខ្ញុំហែកសៀវភៅខ្ញុំ។ | កូនខ្ញុំជាអ្នកហែកសៀវភៅខ្ញុំ។
ច. ខ្ញុំប្រើភាសាខ្មែរនៅសាលាអង្គរ។ | ខ្ញុំជាអ្នកប្រើភាសាខ្មែរនៅសាលាអង្គរ។

DRILL SEVEN: Response

MODEL: T: លោករ.កេណ្ណឌីត្រូវជាអីនឹងលោកជ.កេណ្ណឌី? (ប្អូន)
S: លោករ.កេណ្ណឌីត្រូវជាប្អូនលោកជ.កេណ្ណឌី។
T: What relation is Mr. R. Kennedy to Mr. J. Kennedy? (younger sibling)
S: Mr. R. Kennedy is Mr. J. Kennedy's younger brother.

ក. នាងផ្លែកកិរណាត្រូវជាអីនឹងលោក? (ពួកម៉ាក)
នាងផ្លែកកិរណាត្រូវជាពួកម៉ាកខ្ញុំ។

ខ. លោកត្រូវជាអីនឹងលោកស្រីនោះ? (ប្ដី)
ខ្ញុំត្រូវជាប្ដីលោកស្រីនោះ។
គ. លោកសមត្រូវជាអីនឹងលោកប្រធានាធិបតី? (អ្នកបើកឡាន)
លោកសមត្រូវជាអ្នកបើកឡានលោកប្រធានាធិបតី។
ឃ. លោកនួនត្រូវជាអីនឹងលោក? (ឪពុក)
លោកនួនត្រូវជាឪពុកខ្ញុំ។
ង. លោកត្រូវជាអីនឹងលោកស្រីសុខ? (កូន)
ខ្ញុំត្រូវជាកូនលោកស្រីសុខ។
ច. កញ្ញាសុវណ្ណត្រូវជាអីនឹងលោក? (ប្អូនស្រី)
កញ្ញាសុវណ្ណត្រូវជាប្អូនស្រីខ្ញុំ។

DRILL EIGHT: Response

MODEL: T: គេចាប់មនុស្សប៉ុន្មាននាក់? (ក្នុងផ្ទះ)
S: មនុស្សទាំងប៉ុន្មានក្នុងផ្ទះគេចាប់ទាំងអស់។
T: How many persons did they arrest? (in the house)
S: As many people as were in the house, they arrested them all.

ក. លោកទិញអាវប៉ុន្មាន? (លោកមាន)
អាវទាំងប៉ុន្មានលោកមាន ខ្ញុំទិញទាំងអស់។
ខ. គេលួចសៀវភៅលោកប៉ុន្មាន? (ខ្ញុំដាក់លើតុ)
សៀវភៅទាំងប៉ុន្មានខ្ញុំដាក់លើតុ គេលួចទាំងអស់។
គ. កូនសិស្សឈប់ប៉ុន្មាននាក់? (ខ្ញុំបង្រៀន)
កូនសិស្សទាំងប៉ុន្មានខ្ញុំបង្រៀន ឈប់ទាំងអស់។
ឃ. លោកត្រូវការប៉ុន្មាន? (លោកមាន)
ទាំងប៉ុន្មានលោកមានខ្ញុំត្រូវការទាំងអស់។
ង. លោកទិញអាវប៉ុន្មាន? (ដែលលោករក)
អាវទាំងប៉ុន្មានដែលលោករក ខ្ញុំទិញទាំងអស់។
ច. គេបាញ់មនុស្សប៉ុន្មាននាក់? (ដែលជិះក្នុងឡាន)
មនុស្សទាំងប៉ុន្មានដែលជិះក្នុងឡាន គេបាញ់ទាំងអស់។

DRILL NINE: Response

MODEL: T: មានឃាតកម្មណាសំខាន់ទេ?
S: ក្នុងពេលថ្មីៗនេះគ្មានឃាតកម្មសំខាន់ទេ។
T: Have there been any important assassinations?
S: Recently there have been no important assassinations.

ក. លោកមានទិញអីទេ? ក្នុងពេលថ្មីៗនេះខ្ញុំគ្មានទិញអីទេ។
ខ. នាងបានទៅណាទេ? ក្នុងពេលថ្មីៗនេះខ្ញុំគ្មានបានទៅណាទេ។
គ. លោកបានរៀនខ្មែរនៅផ្ទះទេ? ក្នុងពេលថ្មីៗនេះខ្ញុំគ្មានបានរៀនខ្មែរនៅផ្ទះទេ។

ឃ. លោកបានជួបលោកប្រធានាធិបតីទេ? — ក្នុងពេលថ្មីៗនេះខ្ញុំគ្មានបានជួបលោកប្រធានាធិបតីទេ។

ង. លោកសរសេរសំបុត្រទេ? — ក្នុងពេលថ្មីៗនេះខ្ញុំគ្មានសរសេរសំបុត្រទេ។

ច. កញ្ញាបានសំរាកទេ? — ក្នុងពេលថ្មីៗនេះខ្ញុំគ្មានបានគេងទេ។

DRILL TEN: Transformation

MODEL: T: គេសម្លាប់លោកសំកុល។ (យកឡានគាត់)

S: គេសម្លាប់លោកសំកុល មិនតែប៉ុណ្ណោះគេយកឡានគាត់ទៀត។

T: They killed Mr. Samkol. (took his car)

S: They killed Mr. Samkol; not only that, they took his car, too.

ក. ខ្ញុំមិនឲ្យកូនខ្ញុំដើរលេង។ (មិនឲ្យលុយចាយ)
ខ្ញុំមិនឲ្យកូនខ្ញុំដើរលេង មិនតែប៉ុណ្ណោះខ្ញុំមិនឲ្យលុយចាយទៀត។

ខ. លោកសារុនមិនឲ្យពួកម៉ាកស្រីគាត់និយាយជាមួយគេ។ (ឲ្យនៅតែផ្ទះ)
លោកសារុនមិនឲ្យពួកម៉ាកស្រីគាត់និយាយជាមួយគេ មិនតែប៉ុណ្ណោះគាត់ឲ្យនៅតែផ្ទះទៀត។

គ. ខ្ញុំទៅផ្សារ។ (ទៅមើលកុន)
ខ្ញុំទៅផ្សារ មិនតែប៉ុណ្ណោះខ្ញុំទៅមើលកុនទៀត។

ឃ. កូនសិស្សខ្ញុំមិនរៀន។ (ខ្ជិល)
កូនសិស្សខ្ញុំមិនរៀន មិនតែប៉ុណ្ណោះកូនសិស្សខ្ញុំខ្ជិលទៀត។

ង. គាត់មិនចូលចិត្តខ្ញុំ។ (មិននិយាយជាមួយខ្ញុំ)
គាត់មិនចូលចិត្តខ្ញុំ មិនតែប៉ុណ្ណោះគាត់មិននិយាយជាមួយខ្ញុំទៀត។

ច. លោកសារុមមិនចេះមើល។ (និយាយមិនល្អ)
លោកសារុមមិនចេះមើល មិនតែប៉ុណ្ណោះលោកសារុមនិយាយមិនល្អទៀត។

## Reading Passage

### ទីក្រុងធំៗ

នៅស្រុកណាក៏ដូចស្រុកណាដែរ ប៉ុន្មានឆ្នាំនេះទីក្រុងធំៗមិនសូវសប្បាយទៀតទេ។ ហើយយើងទាំងអស់គ្នាដឹងថាហេតុដែលឲ្យទីក្រុងនេះទៅជាកន្លែងយ៉ាងនោះទៅវិញមានច្រើនណាស់ តែយើងមិនដឹងប្រាកដថាមានប៉ុន្មានហើយកើតមកពីណាដែរ។

មានអ្នកខ្លះគិតថាហេតុដែលធំជាងគេគឺមកពីមានមនុស្សច្រើនពេក។ គេនិយាយថាកន្លែងណាមានមនុស្សច្រើនកន្លែងនោះតែងតែមិនសូវស្អាត មានគ្រោះថ្នាក់នឹងមានកើតឡើងគ្រប់យ៉ាង។

មានអ្នកខ្លះទៀតយល់ថាហេតុធំជាងគេដែលធ្វើឲ្យទីក្រុងធំៗមិនសប្បាយមិនមកពីមានមនុស្សច្រើនទេ តែមកពីការរៀបចំទីក្រុងមិនបានល្អ។

នឹងមានអ្នកខ្លះទៀតនិយាយតាមគេគិតឃើញ។ គេថាទីក្រុងធំៗមិនសប្បាយដូចកាលមុនព្រោះមានមនុស្សច្រើនដែលនៅទីក្រុងហើយគ្មានការធ្វើ។ គេចង់និយាយថាមនុស្សទាំងនោះហើយដែលបង្កើតឲ្យមានចលាចលគឺការលួច ការសម្លាប់គ្នាជា

ដើម។

ដូច្នេះបើយើងយករឿងទាំងអស់ដែលគេបាននិយាយមកនេះមកគិតមើលឃើញថារឿងនោះត្រូវម្យ៉ាងដែរ។ រួចយើងឃើញថានៅមានរឿងច្រើនទៀតបើយើងចង់គិតរកទៅទៀត។

VOCABULARY

| | | |
|---|---|---|
| កុំថាឡើយ...សូម្បីតែ | kom thaa laəy...soumbɛy taɛ | not only...but... |
| ក្នុងពេលថ្មីៗនេះ | knoŋ peel thmɛy thmɛy nih | recently, lately |
| ក្បត់ជាតិ | kbɔt ciat | to betray one's country (L) |
| គឺ | kii | to be |
| ឃាតកម្ម | khiatəkam | assassination, murder |
| ចាយ | caay | to spend |
| ចេញមុខ | cɛñ muk | to let oneself be seen (L) |
| ជាពិសេស | cia pisɛh | especially (L) |
| ជាប់គុក | cóp kuk | to go to prison (L) |
| ដាក់គុក | daʔ kuk | to put in prison (L) |
| ដោះលែង | dɔh leeŋ | to release, to let go (L) |
| ត្រូវជា | trəw cia | to be related to, must be |
| ទាំងប៉ុន្មាន | téŋ pəmaan | all, all of them |
| ធ្វើឃាត | thəə khiat | to assassinate, to murder |
| បាញ់ | bañ | to shoot |
| បាត់បង់ជីវិត | bat bɔŋ civit | to die (L) |
| បណ្ដោះអាសន្ន | bɔndɔh aasɔn | temporary, as an emergency measure (L) |
| ប្រធានាធិបតី | pəthianiathippədɛy | president (of a country) |
| មិនតែប៉ុណ្ណោះ | mɨn taɛ pənnoh | not only...in addition |
| លួច | luoc | to steal |
| លួច | luoc + verb | to do something surreptitiously |
| សម្លាប់ | səlap | to kill |
| សូម្បីតែ | soumbɛy taɛ | even (L) |
| ហែក | haɛk | to tear |
| អាវុកា | aavoukaa | lawyer, attorney (L) |
| អ្នក | néʔ | (personifier), -er, the one who... |

## LESSON THIRTY-EIGHT

## DIALOGUE

| | | | |
|---|---|---|---|
| | | កេណ្ឌ | to draft, to mobilize |
| | | លើក | to raise, to build |
| ១. | សៅ | លោកអាចកេណ្ឌអ្នកស្រុកមកជួយលើកផ្លូវមួយបានទេ? | Can you mobilize the villagers to come and help build a road? |
| | | ទាល់តែ | unless, until; only if, provided that |
| ២. | សុខ | បាទ តែទាល់តែលោកប្រាប់ខ្ញុំពីកន្លែងណាទៅកន្លែងណា? | Yes, but only if you tell me from where to where (to build the road). |
| | | ជាដាច់ខាត | definitely, at all costs |
| ៣. | សៅ | យើងត្រូវការផ្លូវមួយទៅផ្សារជាដាច់ខាត ។ | We definitely need a road to town. |
| | | រាជការ | government (in monarchy) |
| | | រដ្ឋការ | government (in republic) |
| ៤. | សុខ | ខ្ញុំបានសុំរដ្ឋការឲ្យធ្វើយូរហើយ ។ | I asked the government to do it a long time ago. |
| ៥. | សៅ | លោកចាំរដ្ឋការមិនកើតទេ ។ មិនដឹងឆ្នាំណាទេ ទើបហើយ ។ | You can't wait for the government. (If you do,) you don't know when the road will be finished. |
| | | ទោះជា ... ក៏ដោយ (ក៏) ... | ...although, even though, even if |
| | | ពឹង | to ask a favor; to depend on |
| ៦. | សុខ | ទោះជាអ្នកស្រុកមកជួយយើងក៏ដោយ ក៏យើងត្រូវពឹងរដ្ឋការដែរ ។ | Even if the villagers come to help us, we have to depend on the government also. |
| | | ដរាបណា ... ដរាប នោះ ... | as long as...then; whenever... then |
| ៧. | សៅ | ដរាបណាលោកចាំរដ្ឋការ ដរាបនោះលោកគ្មានផ្លូវដើរទេ ។ | As long as you wait for the government, you'll not have any roads to walk on. |
| | | មួយវិញទៀត | on the other hand; furthermore |
| | | យ៉ាងណាក៏ដោយ | anyway, nevertheless |
| ៨. | សុខ | បាទ មួយវិញទៀត លោកត្រូវសុំច្បាប់រដ្ឋការយ៉ាងណាក៏ដោយ ។ | On the other hand you have to ask the government's permission anyway. |

DIALOGUE:

1. saw - look aac kaɛn néʔ srok móo cuoy ləək phləw muoy baan eh?

2. sok - baat, taɛ tól taɛ look prap khñom pii kəlaɛŋ naa tɨw kəlaɛŋ naa?

3. saw - yəəŋ trəw kaa phləw muoy tɨw phsaa cia dac khaat

4. sok - khñom baan som róttəkaa aoy thəə yuu haəy

5. saw - look cam róttəkaa mɨn kaət eh. mɨn dəŋ chnam naa tee təróm haəy.

6. sok - túh cia néʔ srok móo cuoy yəəŋ kɔɔ daoy kɔɔ yəəŋ trəw pɨŋ róttəkaa daɛ

7. saw - dɔɔraap naa look cam róttəkaa dɔɔraap nuh look kmian phləw daə tee

8. sok - baat, muoy viñ tiet look trəw som cbap róttəkaa yaaŋ naa kɔɔ daoy

NOTES

DIALOGUE

SENTENCE NO.

1. Note the piled up verbs in this sentence:

    មកជួយលើកផ្លូវ

    móo cuoy ləək phləw

    Come and help build a road.

   Cf. also S.2.2.4 in the grammatical sketch.

2. The relator ទាល់តែ /tól taɛ/ plus a clause sets a condition for another contingent event. If there is no negative in the contingent clause, ទាល់តែ can be translated 'only if, on the condition that,' e.g.

    ខ្ញុំទៅទាល់តែលោកទៅជាមួយ

    khñom tɨw tól taɛ look tɨw cia muoy

    I'll go only if you'll go with (me).

   When there is a negative in the contingent clause, ទាល់តែ /tól taɛ/ is translated 'unless,' e.g.

    ខ្ញុំមិនទៅទាល់តែលោកទៅជាមួយ

    khñom mɨn tɨw tól taɛ look tɨw cia muoy

    I won't go unless you go with (me).

   Note that both sentences are equivalent in meaning to:

    លោកទៅជាមួយបានខ្ញុំទៅ

    look tɨw cia muoy baan khñom tɨw

    I won't go unless you go with (me).

3. The term ផ្សារ /phsaa/ is literally 'market,' but it is also used by country people to refer to a town (where the markets are located). In Phnom Penh the term ផ្សារ /phsaa/ refers to the commercial, downtown area as opposed to the residential areas.

3. ជាដាច់ខាត /cia dac khaat/ is an example of ជា /cia/ used as a marker of phrasal adverbials. See also A.5 in the grammatical sketch.

4. The word 'government' has two meanings: the first is a permanent civil service structure which persists no matter who is in power; the second is the elected head of government and the men he appoints. This is usually called an 'administration' in the United States (e.g. the Eisenhower Administration or the Kennedy Administration) but referred to as a 'government' in other countries (e.g. 'Lon Nol was asked to form a new government.'). The term for 'administration' or 'régime' is រដ្ឋាភិបាល /róttəpəbaal/. There are two words in Cambodian to refer to the permanent civil service structure: រាជការ /riaccəkaa/ is used for the civil service in a monarchy; រដ្ឋការ /róttəkaa/ refers to the permanent governmental structure in other types of state. Since the abolition of the Cambodian monarchy in 1970 រដ្ឋការ /róttəkaa/ is the technically correct term, but in fact both terms appear in everyday usage.

DRILLS

DRILL NO.

3. បាន /baan/ 'can' followed by បាន /baan/ or កើត /kaət/ 'can' means 'have to (because there is no other way),' e.g.

ពូបើកឡានទៅបានកើត។
puu baək laan tɨw baan kaət
You have no choice but to drive there.

DRILLS

DRILL ONE: Transformation

MODEL: T: ខ្ញុំទៅហៅអ្នកស្រុក។ (លោកប្រាប់ខ្ញុំ)
S: ខ្ញុំទៅហៅអ្នកស្រុកទាល់តែលោកប្រាប់ខ្ញុំ។
T: I'll go to call the villagers. (you tell me)
S: I'll go to call the villagers only when you tell me.

ក. ខ្ញុំមិនជើងជូនលោកទេ។ (លោកឱ្យលុយខ្ញុំ)
ខ្ញុំមិនជើងជូនលោកទេ ទាល់តែលោកឱ្យលុយខ្ញុំ។
ខ. ខ្ញុំជំរាបលោក។ (លោកមកផ្ទះខ្ញុំ)
ខ្ញុំជំរាបលោក ទាល់តែលោកមកផ្ទះខ្ញុំ។
គ. ខ្ញុំមិនទៅទេ។ (លោកទៅជាមួយខ្ញុំ)
ខ្ញុំមិនទៅទេ ទាល់តែលោកទៅជាមួយខ្ញុំ។
ឃ. ខ្ញុំមិនដើរទេ។ (លោកទិញឱ្យខ្ញុំ)
ខ្ញុំមិនដូរទេ ទាល់តែលោកទិញឱ្យខ្ញុំ។

ង. ខ្ញុំរៀនមេរៀននោះ ។ (លោកពន្យល់ខ្ញុំ)
ខ្ញុំរៀនមេរៀននោះ ទាល់តែលោកពន្យល់ខ្ញុំ ។
ច. ខ្ញុំរៀនខ្មែរ ។ (ខ្ញុំទៅស្រុកខ្មែរ)
ខ្ញុំរៀនខ្មែរ ទាល់តែខ្ញុំទៅស្រុកខ្មែរ ។

DRILL TWO: Transformation

MODEL: T: យើងត្រូវការផ្លូវមួយទៅផ្សារ ។
S: យើងត្រូវការផ្លូវមួយទៅផ្សារជាដាច់ខាត ។
T: We need a road to town (the market).
S: We definitely need a road to town (the market).

ក. ខ្ញុំត្រូវរៀនភាសាខ្មែរ ។ — ខ្ញុំត្រូវរៀនភាសាខ្មែរជាដាច់ខាត ។
ខ. លោកត្រូវបង្រៀនថ្ងៃក្រោយ ។ — លោកត្រូវបង្រៀនថ្ងៃក្រោយជាដាច់ខាត ។
គ. ខ្ញុំត្រូវខ្ចីលុយលោក ។ — ខ្ញុំត្រូវខ្ចីលុយលោកជាដាច់ខាត ។
ឃ. ខ្ញុំទៅផ្ទះលោកល្ងាចនេះ ។ — ខ្ញុំទៅផ្ទះលោកល្ងាចនេះជាដាច់ខាត ។
ង. យើងមិនត្រូវចាំរាជការ ។ — យើងមិនត្រូវចាំរាជការជាដាច់ខាត ។
ច. ខ្ញុំមិនត្រូវសុំច្បាប់លោក ។ — ខ្ញុំមិនត្រូវសុំច្បាប់លោកជាដាច់ខាត ។

DRILL THREE: Transformation

MODEL: T: លោកចាំរាជការមិនកើតទេ ។
S: លោកចាំរាជការបានកើត ។
T: You can't wait for the government.
S: You have no choice but to wait for the government.

ក. លោកទៅទិញមិនបានទេ ។ — លោកទៅទិញបានៗ ។
ខ. ខ្ញុំទៅមិនកើតទេ ។ — ខ្ញុំទៅបានកើត ។
គ. កញ្ញារមើលមិនកើតទេ ។ — កញ្ញារមើលបានកើត ។
ឃ. ខ្ញុំពឹងលោកមិនបានទេ ។ — ខ្ញុំពឹងលោកបានៗ ។
ង. ខ្ញុំផ្ញើសំបុត្រទៅមិនកើតទេ ។ — ខ្ញុំផ្ញើសំបុត្រទៅបានកើត ។
ច. លោកធ្វើមិនបានទេ ។ — លោកធ្វើបានៗ ។

DRILL FOUR: Transformation

MODEL: T: លោកចាំរដ្ឋការប៉ុន្មានឆ្នាំ ? (ធ្វើ)
S: លោកចាំរដ្ឋការប៉ុន្មានឆ្នាំទៅទំរាំរដ្ឋការចាប់ធ្វើ ។
T: How many years will you wait for the government?
S: How many years will you wait until the government starts doing it?

ក. លោកធ្វើប៉ុន្មានម៉ោង ? (សំរាក)
លោកធ្វើប៉ុន្មានម៉ោងទៅទំរាំលោកចាប់សំរាក ។

ខ. យើងចម្លងប៉ុន្មានមីនុត? (មើល)
យើងចម្លងប៉ុន្មានមីនុតទៅទំរាំយើងចាប់មើល។
គ. លោកពិសាប៉ុន្មានម៉ោង? (រៀន)
លោកពិសាប៉ុន្មានម៉ោងទៅទំរាំលោកចាប់រៀន។
ឃ. លោកសរសេរប៉ុន្មានថ្ងៃ? (ស្ដាប់)
លោកសរសេរប៉ុន្មានថ្ងៃទៅទំរាំលោកចាប់ស្ដាប់។
ង. គេធ្វើប៉ុន្មានឆ្នាំ? (នៅ)
គេធ្វើប៉ុន្មានឆ្នាំទៅទំរាំគេចាប់នៅ។
ច. គេសួរប៉ុន្មានម៉ោង? (សរសេរ)
គេសួរប៉ុន្មានម៉ោងទៅទំរាំគេចាប់សរសេរ។

DRILL FIVE: Transformation

MODEL: T: អ្នកស្រុកមកជួយយើង។ (យើងត្រូវពឹងរដ្ឋការ)
S: ទោះជាអ្នកស្រុកមកជួយយើងក៏ដោយក៏យើងត្រូវពឹងរដ្ឋការដែរ។
T: The villagers come to help us. (we have to depend on the government)
S: Although the villagers come to help us, we still have to depend on the government (anyway).

ក. ខ្ញុំមកញ៉ាំបាយផ្ទះ។ (ខ្ញុំត្រូវមានលុយ)
ទោះជាខ្ញុំមកញ៉ាំបាយផ្ទះក៏ដោយក៏ខ្ញុំត្រូវមានលុយដែរ។
ខ. លោកធ្វើមិនទាន់ហើយ។ (លោកត្រូវឲ្យខ្ញុំ)
ទោះជាលោកធ្វើមិនទាន់ហើយក៏ដោយក៏លោកត្រូវឲ្យខ្ញុំដែរ។
គ. នាងញ៉ាំរួចហើយ។ (នាងត្រូវញ៉ាំបន្តិចទៀត)
ទោះជានាងញ៉ាំរួចហើយក៏ដោយក៏នាងត្រូវញ៉ាំបន្តិចទៀតដែរ។
ឃ. ខ្ញុំមិនត្រូវការលុយ។ (ខ្ញុំត្រូវខ្វះ)
ទោះជាខ្ញុំមិនត្រូវការលុយក៏ដោយក៏ខ្ញុំត្រូវខ្វះដែរ។
ង. លោកមិនទៅស្រុកខ្មែរ។ (លោកត្រូវរៀនខ្មែរ)
ទោះជាលោកមិនទៅស្រុកខ្មែរក៏ដោយក៏លោកត្រូវរៀនខ្មែរដែរ។
ច. ខ្ញុំមានការច្រើន។ (ខ្ញុំមកលេងនឹងលោក)
ទោះជាខ្ញុំមានការច្រើនក៏ដោយក៏ខ្ញុំមកលេងនឹងលោកដែរ។

DRILL SIX: Transformation

MODEL: T: លោកត្រូវចាំរដ្ឋការ។ (លោកគ្មានផ្លូវដើរទេ)
S: ដរាបណាលោកចាំរដ្ឋការដរាបនោះលោកគ្មានផ្លូវដើរទេ។
T: You have to wait for the government. (you'll have no roads to walk on)
S: As long as you wait for the government, you'll have no roads to walk on.

ក. ពូមកញ៉ាំបាយផ្ទះខ្ញុំ។ (ពូត្រូវទិញម្ហូប)
ដរាបណាពូមកញ៉ាំបាយផ្ទះខ្ញុំដរាបនោះពូត្រូវទិញម្ហូប។

ខ. លោកប្រើឡានខ្ញុំ ។ (លោកត្រូវចាក់សាំង)
ដរាបណាលោកប្រើឡានខ្ញុំ ដរាបនោះលោកត្រូវចាក់សាំង ។
គ. កូនខ្ញុំមិនទៅរៀន ។ (ខ្ញុំមិនឱ្យលុយវា)
ដរាបណាកូនខ្ញុំមិនទៅរៀន ដរាបនោះខ្ញុំមិនឱ្យលុយវា ។
ឃ. លោករៀន ។ (ខ្ញុំមិនឱ្យចំណោទពិបាក)
ដរាបណាលោករៀន ដរាបនោះខ្ញុំមិនឱ្យចំណោទពិបាក ។
ង. លោកសប្បាយចិត្ត ។ (ខ្ញុំសប្បាយចិត្ត)
ដរាបណាលោកសប្បាយចិត្ត ដរាបនោះខ្ញុំសប្បាយចិត្ត ។
ច. កញ្ញានៅជាមួយខ្ញុំ ។ (ខ្ញុំមិនអាចរៀន)
ដរាបណាកញ្ញានៅជាមួយខ្ញុំ ដរាបនោះខ្ញុំមិនអាចរៀន ។

DRILL SEVEN: Substitution

MODEL: T: មួយវិញទៀតលោកត្រូវសុំច្បាប់រដ្ឋការ ។ (លោកគ្រូ)
S: មួយវិញទៀតលោកត្រូវសុំច្បាប់លោកគ្រូ ។
T: On the other hand you have to ask the government's permission. (the teacher)
S: On the other hand you have to ask the teacher's permission.

ក. មួយវិញទៀតលោកត្រូវសុំច្បាប់លោកគ្រូ ។ (សួរ)
ខ. មួយវិញទៀតលោកត្រូវសួរលោកគ្រូ ។ (រៀនមេរៀនខ្ញុំ)
គ. មួយវិញទៀតលោកត្រូវរៀនមេរៀនខ្ញុំ ។ (ចម្លង)
ឃ. មួយវិញទៀតលោកត្រូវចម្លងមេរៀនខ្ញុំ ។ (ចំណោទ)
ង. មួយវិញទៀតលោកត្រូវចម្លងចំណោទខ្ញុំ ។ (ធ្វើ)
ច. មួយវិញទៀតលោកត្រូវធ្វើចំណោទខ្ញុំ ។

DRILL EIGHT: Transformation

MODEL: T: មួយវិញទៀតលោកត្រូវសុំច្បាប់រដ្ឋការ ។
S: ផ្ទុយទៅវិញលោកមិនត្រូវសុំច្បាប់រដ្ឋការទេ ។
T: On the other hand you have to ask the government's permission.
S: On the contrary you mustn't ask the government's permission.

ក. មួយវិញទៀតលោកត្រូវសុំច្បាប់គ្រូបង្រៀន ។
ផ្ទុយទៅវិញលោកមិនត្រូវសុំច្បាប់គ្រូបង្រៀនទេ ។
ខ. មួយវិញទៀតលោកត្រូវនៅផ្ទះ ។
ផ្ទុយទៅវិញលោកមិនត្រូវនៅផ្ទះទេ ។
គ. មួយវិញទៀតលោកត្រូវសួរគាត់មុន ។
ផ្ទុយទៅវិញលោកមិនត្រូវសួរគាត់មុនទេ ។
ឃ. មួយវិញទៀតយើងត្រូវទៅរៀនម៉ោងប្រាំពីរ ។
ផ្ទុយទៅវិញយើងមិនត្រូវទៅរៀនម៉ោងប្រាំពីរទេ ។

ង. ម្ដាយវិញទៀតគាត់ត្រូវយកកូនទៅសាលា។
ម្ដាយទៅវិញគាត់មិនត្រូវយកកូនទៅសាលាទេ។

DRILL NINE: Transformation

MODEL: T: ផ្លូវនេះធំ។ (ធ្វើ)

S: គេធ្វើផ្លូវនេះកាន់តែធំឡើង។

T: This road is big. (build)

S: They're building this road bigger and bigger.

ក. ឥវ៉ាន់នេះថ្លៃណាស់។ (លក់) គេលក់ឥវ៉ាន់នេះកាន់តែថ្លៃឡើង។
ខ. ឡាននេះលឿនណាស់។ (ធ្វើ) គេធ្វើឡាននេះកាន់តែលឿនឡើង។
គ. ចំណោទនេះពិបាក។ (ឲ្យ) គេឲ្យចំណោទកាន់តែពិបាកឡើង។
ឃ. មេរៀននេះស្រួល។ (ធ្វើ) គេធ្វើមេរៀនកាន់តែស្រួលឡើង។
ង. យើងដើរយូរណាស់។ (ឲ្យ) គេឲ្យយើងដើរកាន់តែយូរឡើង។
ច. កូនគាត់ញ៉ាំបាយតិច។ (ឲ្យ) គេឲ្យកូនគាត់ញ៉ាំកាន់តែតិចឡើង។

DRILL TEN: Transformation

MODEL: T: យើងត្រូវពឹងរដ្ឋការ។

S: យើងត្រូវជួយរដ្ឋការ។

T: We have to depend on the government.

S: We have to help the government.

ក. ខ្ញុំពឹងលោកឲ្យប្រែអង់គ្លេស។ ខ្ញុំជួយលោកប្រែអង់គ្លេស។
ខ. ខ្ញុំពឹងបងខ្ញុំសរសេរសំបុត្រ។ ខ្ញុំជួយបងខ្ញុំសរសេរសំបុត្រ។
គ. ខ្ញុំពឹងលោក។ ខ្ញុំជួយលោក។
ឃ. ខ្ញុំពឹងលោកបើកឡាន។ ខ្ញុំជួយលោកបើកឡាន។
ង. លោកពឹងខ្ញុំប្រែមេរៀន។ លោកជួយខ្ញុំប្រែមេរៀន។
ច. ខ្ញុំពឹងនាងបង្រៀនកូនខ្ញុំ។ ខ្ញុំជួយនាងបង្រៀនកូនខ្ញុំ។

Reading Passage

ពេលទំនេរ

នៅពេលទំនេរគឺក្រោយពេលធ្វើការឬរៀន ដើម្បីជាការសប្បាយយើងចូលចិត្តជួបជុំគ្នារួចធ្វើអ្វីមួយតាមយើងគិតឃើញ។

បើយើងគ្មានលុយ យើងទៅផ្សារមើលគេមើលឯង មើលហាងលក់ឥវ៉ាន់ ឬទៅកន្លែងឯទៀតដូចជាមាត់ទន្លេជាដើម។ នេះបើយើងមិនចូលចិត្តលេងកីឡា។

បើយើងមានលុយវិញ យើងទៅផ្សារដែរ ឬយើងនៅផ្ទះ។ បើយើងទៅផ្សារ

ជួនកាលយើងមើលកុន ជួនកាលយើងទៅហាងបាយ។ នៅស្រុកយើងមានកុនខ្មែរ អាមេរិកាំង បារាំង សៀម ចិននិងឯទៀត។ កុនចិនច្រើនតែនិយាយភាសាចិន កុនបារាំងនិងកុនអាមេរិកាំងច្រើនតែនិយាយភាសាបារាំង និងកុនឯទៀតនិយាយតែជាភាសាខ្មែរទេ។ ដូច្នេះអ្នកណាដែលចេះនិយាយភាសាបារាំង ច្រើនទៅមើលកុននិយាយជាភាសាបារាំង ព្រោះតាមគេ មានតួឯកនិងអ្នកលេងល្អៗជាងកុនឯទៀត។ កាលណាមើលកុននោះហើយ ខ្លះទៅផ្ទះវិញភ្លាម ខ្លះទៀតទៅផឹកស្រាឬទៅរាំដល់ម៉ោងមួយឬម៉ោងពីរយប់បានត្រឡប់ទៅផ្ទះវិញ។ ឯយើងទៅហាងបាយវិញ យើងចូលចិត្តហាងចិន ព្រោះនៅនោះយើងអាចហៅម្ហូបចិនក៏បាន ម្ហូបបារាំងក៏បានហើយម្ហូបទាំងនោះឆ្ងាញ់ហើយថោកផង។ នៅពេលយើងបាយហើយក៏ដូចនៅពេលយើងមើលកុនចប់ដែរ គឺអ្នកខ្លះត្រឡប់ទៅផ្ទះវិញភ្លាម និងអ្នកខ្លះទៀតទៅកន្លែងឯទៀត។

បើយើងនៅផ្ទះ យើងក៏សប្បាយណាស់ដែរ។ ជួនកាលយើងទិញស្រា ទិញម្ហូបមកធ្វើរួចញ៉ាំនៅផ្ទះ។ នៅពេលនោះជួនកាលយើងរាំ ជួនកាលយើងនិយាយគ្នាលេង។ បើយើងមិនរាំឬធ្វើអីទេ យើងលេងបៀ។ ហើយនៅពេលខ្លះបើគ្មានការជប់លៀងទេ យើងលេងបៀតែឯង។

តាមពិតនេះជាការសប្បាយនៅពេលទំនេររបស់យើងដែលជាអ្នកនៅទីក្រុង។

## VOCABULARY

| | | |
|---|---|---|
| ការងារ | kaa ŋia | labor, work (L) |
| ការជប់លៀង | kaa cup liaŋ | a party (R) |
| កីឡា | kɛy laa | sports (R) |
| កេណ្ឌ | kaɛn | to draft, to mobilize |
| កំឡាំង | kəlaŋ | strength, power (L) |
| ជាដាច់ខាត | cia dac khaat | definitely |
| ជួបជុំគ្នា | cuop cum knia | to meet, to have a meeting (R) |
| ដរាបណា ... ដរាបនោះ | dɔɔraap naa...dɔɔraap nuh | as long as...then...whenever |
| ទាល់តែ | tól taɛ | until, unless, only if, provided that |
| ទោះជា... ក៏ដោយក៏ | túh cia...kɔɔ daoy kɔɔ | although, even though |
| បាន | baan kaət | have to |
| ផឹក | phək | to drink (non-formal) (R) |
| ផ្ទុយទៅវិញ | phtuy tɨw viñ | on the contrary |
| ពឹង | piŋ | to depend on |
| ភ្លាម | phliam | immediately, at once (R) |
| មួយវិញទៀត | muoy viñ tiet | on the other hand |
| រដ្ឋការ | róttəkaa | government, civil service (in a republic) |
| រដ្ឋាភិបាល | róttəpiibaal | government, regime |
| រាជការ | riaccəkaa | government, civil service (in a kingdom) |
| លើក | ləək | to raise, to build |
| សត្រូវ | sətrəw | enemy (L) |
| សប្បាយចិត្ត | səbaay cət | to be happy |

## LESSON THIRTY-NINE

## DIALOGUE

| | | | |
|---|---|---|---|
| | | ជីក | to dig |
| | | អណ្ដូង | well |
| | | ជាចាំបាច់ | necessary |
| | | ផឹក | to drink |
| ១. | សុខ | យើងត្រូវការជីកអណ្ដូងមួយជាចាំបាច់ ព្រោះពិបាករកទឹកផឹកណាស់។ | We need to dig a well because it's very difficult to find water to drink |
| | | បើ ... វិញ | if it were (I)... |
| | | ម៉ាស៊ីនទឹក | water fountain, faucet |
| ២. | សៅ | បើខ្ញុំវិញ ខ្ញុំដាក់ម៉ាស៊ីនទឹកវិញ។ | If it were I, I'd put a fountain in instead. |
| | | ...ជាង...ដង | ...times as... |
| | | ទឹកម៉ាស៊ីន | fountain water, running water |
| ៣. | សុខ | បាទ តែទឹកម៉ាស៊ីនថ្លៃជាងទឹកអណ្ដូងដប់ដង។ | Yes, but running water is 10 times as expensive as a well. |
| ៤. | សៅ | ចុះបើលោកជីក លោកជីកឯណា? | If you were to dig, where would you do it? |
| | | ទុកឲ្យ..... វិញ | leave it to... |
| | | ចំណែក(ឯ) ...វិញ | as for... |
| | | ផ្ដល់ | to supply |
| ៥. | សុខ | ទុកឲ្យខ្ញុំរកកន្លែងវិញ។ ចំណែកឯលោកវិញ លោកត្រូវផ្ដល់កម្លាំងឲ្យខ្ញុំ។ | Leave it to me to find a place. As for you, you'll have to supply power to me. |
| | | ទាល់តែ ... ក៏អី | if it were not for the fact |
| | | ភូមិ | village, hamlet |
| | | មិនរវល់ | don't care, don't give a damn |
| ៦. | សៅ | ទាល់តែខ្ញុំនៅក្នុងភូមិនេះទេ ក៏អីខ្ញុំមិនរវល់ទេ។ | If it weren't that I'm living here, I wouldn't give a damn. |
| | | ប្រដាប់ប្រដា | equipment |
| ៧. | សុខ | ខ្ញុំមានប្រដាប់ប្រដាល្មមហើយ។ លោកគ្រាន់តែទៅពឹងគេជីកបានហើយ។ | I have enough equipment; you just get someone to dig, and that will be enough. |

DIALOGUE:

1. sok - yəəŋ trəw kaa ciik ndouŋ muoy cia cam bac, prúh pəbaaʔ róo tɨk phək nah
2. saw - baə khñom viñ, khñom daʔ məsɨn tɨk viñ
3. sok - baat, taɛ tɨk məsɨn thlay ciaŋ tɨk ndouŋ dɔp dɔɔŋ
4. saw - coh baə look ciik, look ciik aɛnaa?
5. sok - tuk aoy khñom róo kəlaɛŋ viñ. cənaɛk aɛ look viñ, look trəw phdɔl kəlaŋ aoy khñom
6. saw - tóh taɛ khñom nɨw knoŋ phum nih tee kom ɛy khñom mɨn ləvúl tee
7. sok - khñom mian pədap pədaa ləmóom haəy look krón taɛ tɨw pɨŋ kee ciik baan haəy

NOTES

DIALOGUE

SENTENCE NO.

1. The word ផឹក /phək/ means 'to drink,' but it is used only in non-formal contexts. To say 'drink' formally you must use ពិសា /piisaa/ 'eat, drink, smoke.'

2. The word វិញ /viñ/ in បើខ្ញុំវិញ /baə khñom viñ/ 'if it were I' adds a meaning of 'on the other hand.' Thus sentence 2 means something like '(Now) if it were I (on the other hand), I'd put in a fountain instead.' As usual both instances of វិញ /viñ/ in this sentence emphasize the contrast with what precedes or something in the context of the sentence.

3. The formula adjective + ជាង /ciaŋ/ + (noun)...+ number + ដង /dɔɔŋ/ means '(number) times as (adjective) as (noun),' e.g.

   ផ្ទះខ្ញុំល្អជាងផ្ទះលោកបីដង។
   phtéh khñom lʔɔɔ ciaŋ phtéh look bɛy dɔɔŋ
   My house is three times as nice as yours.

5. Note that ផ្តល់ /phdɔl/ 'to supply' is a derivative of ដល់ /dɔl/ 'to arrive.' /ph-/ is one of several prefixes added to a verb which give causative meaning; literally ផ្តល់ /phdɔl/ can be translated 'to cause (supplies) to arrive.' Cf. V.3.2.1.

6. In the idiom ទោះតែ...កុំអី /tóh taɛ...kom ɛy/ 'if it were not for the fact that...,' កុំអី /kom ɛy/ is part of the second clause. It can either precede the subject, as in this sentence, or it can follow the subject, as in the example below: ទោះតែខ្ញុំខ្វះលុយខ្ញុំកុំអីញ៉ាំបាយហាងរាល់ថ្ងៃ។

   tóh taɛ khñom khvah luy khñom kom ɛy ñam baay haaŋ ról ŋay
   If it were not for the fact that I lack money, I'd eat out every day.

## DRILLS

DRILL ONE: Substitution

MODEL: T: យើងត្រូវការអណ្តូងមួយជាចាំបាច់។ (ឡាន)

S: យើងត្រូវការឡានមួយជាចាំបាច់។

T: We need a well. (car)

S: We need a car.

ក. យើងត្រូវការឡានមួយជាចាំបាច់។ (ផ្ទះ)
ខ. យើងត្រូវការផ្ទះមួយជាចាំបាច់។ (បន្ទប់)
គ. យើងត្រូវការបន្ទប់មួយជាចាំបាច់។ (សៀវភៅ)
ឃ. យើងត្រូវការសៀវភៅមួយជាចាំបាច់។ (គូ)
ង. យើងត្រូវការគូមួយជាចាំបាច់។ (គ្រូបង្រៀន)
ច. យើងត្រូវការគ្រូបង្រៀនមួយជាចាំបាច់។

DRILL TWO: Response

MODEL: T: ខ្ញុំចង់ដាក់ម៉ាស៊ីនទឹកមួយ។

S: បើខ្ញុំវិញ ខ្ញុំមិនដាក់ម៉ាស៊ីនទឹកទេ។

T: I want to put in a water fountain.

S: If it were I, I wouldn't put in a water fountain.

ក. ខ្ញុំចង់ទៅរៀននៅស្រុកអាមេរិក។
បើខ្ញុំវិញ ខ្ញុំមិនទៅរៀននៅស្រុកអាមេរិកទេ។
ខ. ខ្ញុំចង់ជួលផ្ទះនៅជិតសាលា។
បើខ្ញុំវិញ ខ្ញុំមិនជួលផ្ទះនៅជិតសាលាទេ។
គ. ខ្ញុំចង់អញ្ជើញគាត់មកញ៉ាំបាយ។
បើខ្ញុំវិញ ខ្ញុំមិនអញ្ជើញគាត់មកញ៉ាំបាយទេ។
ឃ. ខ្ញុំចង់ទៅលេងញាតិយើងជាមួយគាត់។
បើខ្ញុំវិញ ខ្ញុំមិនទៅលេងញាតិយើងជាមួយគាត់ទេ។
ង. ខ្ញុំញ៉ាំស្រានេះ។
បើខ្ញុំវិញ ខ្ញុំមិនញ៉ាំស្រានេះទេ។
ច. ខ្ញុំត្រូវការឡានបើកទៅសាលា។
បើខ្ញុំវិញ ខ្ញុំមិនត្រូវការឡានបើកទៅសាលាទេ។

DRILL THREE: Transformation

MODEL: T: ទឹកម៉ាស៊ីនថ្លៃណាស់។ (ដប់)

S: ទឹកម៉ាស៊ីនថ្លៃជាងដប់ដង។

T: The fountain water is very expensive. (ten)

S: The fountain water is 10 times as expensive.

ក. ឡានលោកលឿនណាស់។ (បី) ឡានលោកលឿនជាងបីដង។

ខ. ផ្ទះខ្ញុំធំណាស់។ (ប្អូន) ផ្ទះខ្ញុំធំជាងប្អូនដែរ។
គ. គុខ្ញុំល្អណាស់។ (ក្រាំ) គុខ្ញុំល្អជាងក្រាំដែរ។
ឃ. សាលាលោកឆ្ងាយណាស់។ (ពីរ) សាលាលោកឆ្ងាយជាងពីរដែរ។
ង. ឪពុកខ្ញុំមានណាស់។ (ដប់) ឪពុកខ្ញុំមានជាងដប់ដែរ។
ច. កញ្ញាល្អណាស់។ (ខ្មែរ) កញ្ញាល្អជាងខ្មែរដែរ។

DRILL FOUR: Extension

MODEL: T: ខ្ញុំរៀន។ (បង្រៀន)
S: ចំណែកឯលោកវិញ លោកត្រូវបង្រៀន។
T: I study. (teach)
S: As for you, you have to teach.

ក. ខ្ញុំជិះឡាន។ (បើក) ចំណែកឯលោកវិញ លោកត្រូវបើក។
ខ. ខ្ញុំទិញ។ (លក់) ចំណែកឯលោកវិញ លោកត្រូវលក់។
គ. ខ្ញុំដើរលេង។ (នៅផ្ទះ) ចំណែកឯលោកវិញ លោកត្រូវនៅផ្ទះ។
ឃ. ខ្ញុំមើលសៀវភៅ។ (ស្ដាប់ភ្លេង) ចំណែកឯលោកវិញ លោកត្រូវស្ដាប់ភ្លេង។
ង. ខ្ញុំសួរ។ (អង្គុយ) ចំណែកឯលោកវិញ លោកត្រូវអង្គុយ។
ច. ខ្ញុំដើរ។ (រត់) ចំណែកឯលោកវិញ លោកត្រូវរត់។

DRILL FIVE: Transformation

MODEL: T: ខ្ញុំផ្ដល់កម្លាំងជូនលោក។
S: ចំណែកឯខ្ញុំវិញ ខ្ញុំផ្ដល់កម្លាំងជូនលោក។
T: I'll supply power to you.
S: As for me, I'll supply power to you.

ក. ខ្ញុំទៅរៀនមិនបានទេ។
ចំណែកឯខ្ញុំវិញ ខ្ញុំទៅរៀនមិនបានទេ។
ខ. ខ្ញុំត្រូវមើលសៀវភៅនោះ។
ចំណែកឯខ្ញុំវិញ ខ្ញុំត្រូវមើលសៀវភៅនោះ។
គ. នាងពាក់អាវល្អណាស់។
ចំណែកឯនាងវិញ នាងពាក់អាវល្អណាស់។
ឃ. កូនសិស្សខ្ញុំខ្ជិលរៀនណាស់។
ចំណែកឯកូនសិស្សខ្ញុំវិញ កូនសិស្សខ្ញុំខ្ជិលរៀនណាស់។
ង. គាត់មិនបានរៀនភាសាទេ។
ចំណែកឯគាត់វិញ គាត់មិនបានរៀនភាសាទេ។
ច. លោកគ្រូបង្រៀនល្អណាស់។
ចំណែកឯលោកគ្រូវិញ លោកគ្រូបង្រៀនល្អណាស់។

DRILL SIX: Response

MODEL: T: លោកហាក់ត្រូវទៅ។ (ខ្ញុំ)

S: ទុកឱ្យខ្ញុំទៅវិញ។

T: Mr. Hak has to go. (me)

S: Let me go instead.

ក. លោកស្រីពិសាស្រានេះទៅ។ (ប្ដីខ្ញុំ) ទុកឱ្យប្ដីខ្ញុំញ៉ាំស្រានេះវិញ។

ខ. ខ្ញុំបង្រៀនភាសាបារាំង។ (កញ្ញាផល្លា) ទុកឱ្យកញ្ញាផល្លាបង្រៀនភាសាបារាំងវិញ។

គ. ខ្ញុំទៅយកក៏បានដែរ។ (លោកសំអុល) ទុកឱ្យលោកសំអុលទៅយកវិញ។

ឃ. លោកត្រូវបើកឡាន។ (ប្រពន្ធខ្ញុំ) ទុកឱ្យប្រពន្ធខ្ញុំបើកឡានវិញ។

ង. លោករកកន្លែង។ (ខ្ញុំ) ទុកឱ្យខ្ញុំរកកន្លែងវិញ។

ច. ខ្ញុំទៅជាមួយនាង។ (លោកសាខន) ទុកឱ្យលោកសាខនទៅជាមួយនាងវិញ។

DRILL SEVEN: Transformation

MODEL: T: ខ្ញុំនៅក្នុងភូមិនេះ។ (ខ្ញុំមិនរវល់ទេ)

S: ទាល់តែខ្ញុំនៅក្នុងភូមិនេះទេ កុំអីខ្ញុំមិនរវល់ទេ។

T: I live in this village. (I wouldn't give a damn)

S: If it weren't that I'm living in this village, I wouldn't give a damn.

ក. ខ្ញុំត្រូវទៅស្រុកខ្មែរ។ (មិនរៀនខ្មែរ)
ទាល់តែខ្ញុំត្រូវទៅស្រុកខ្មែរ កុំអីខ្ញុំមិនរៀនខ្មែរទេ។

ខ. ខ្ញុំអស់លុយ។ (មិនញ៉ាំបាយផ្ទះ)
ទាល់តែខ្ញុំអស់លុយ កុំអីខ្ញុំមិនញ៉ាំបាយផ្ទះទេ។

គ. ខ្ញុំអស់កម្លាំង។ (មិនដេក)
ទាល់តែខ្ញុំអស់កម្លាំង កុំអីខ្ញុំមិនដេកទេ។

ឃ. ខ្ញុំចូលចិត្តគាត់។ (មិនទៅលេងគាត់)
ទាល់តែខ្ញុំចូលចិត្តគាត់ទេ កុំអីខ្ញុំមិនទៅលេងគាត់ទេ។

ង. ខ្ញុំជិះឡានជាមួយគាត់។ (មិនចាំ)
ទាល់តែខ្ញុំជិះឡានជាមួយគាត់ទេ កុំអីខ្ញុំមិនចាំទេ។

ច. ខ្ញុំត្រូវទៅធ្វើការ។ (មិនភ្ញាក់ពីដេក)
ទាល់តែខ្ញុំត្រូវទៅធ្វើការទេ កុំអីខ្ញុំមិនភ្ញាក់ពីដេកទេ។

DRILL EIGHT: Transformation

MODEL: T: ខ្ញុំមិននៅក្នុងភូមិនេះទេ។ (ជួយជីក)

S: ទាល់តែខ្ញុំមិននៅក្នុងភូមិនេះទេ កុំអីខ្ញុំជួយជីកហើយ។

T: I'm not living in this village. (help dig)

S: If it were not for the fact that I'm not living in this village, I would help to dig (it).

ក. ខ្ញុំមិនត្រូវទៅស្រុកខ្មែរទេ។ (រៀនខ្មែរ)
ទាស់តែខ្ញុំមិនត្រូវទៅស្រុកខ្មែរទេ កុំអីខ្ញុំរៀនខ្មែរហើយ។
ខ. ខ្ញុំមានលុយ។ (ញ៉ាំបាយផ្ទះ)
ទាស់តែខ្ញុំមានលុយទេ កុំអីខ្ញុំញ៉ាំបាយផ្ទះហើយ។
គ. ខ្ញុំមិនចូលចិត្តគាត់ទេ។ (ទៅលេងគាត់)
ទាស់តែខ្ញុំមិនចូលចិត្តគាត់ទេ កុំអីខ្ញុំទៅលេងគាត់ហើយ។
ឃ. ខ្ញុំមិនជិះឡានជាមួយគាត់ទេ។ (ចាំគាត់)
ទាស់តែខ្ញុំមិនជិះឡានជាមួយគាត់ទេ កុំអីខ្ញុំចាំគាត់ហើយ។
ង. ខ្ញុំមិនត្រូវទៅធ្វើការទេ។ (ភ្ញាក់ពីដេក)
ទាស់តែខ្ញុំមិនត្រូវទៅធ្វើការទេ កុំអីខ្ញុំភ្ញាក់ពីដេកហើយ។
ច. ខ្ញុំមិនដឹងកន្លែងទេ។ (ទៅរក)
ទាស់តែខ្ញុំមិនដឹងកន្លែងទេ កុំអីខ្ញុំទៅរកហើយ។

DRILL NINE: Response

MODEL: T: បីដុល្លាបានទេ?
S: បីដុល្លាល្មមហើយ។
T: Will three dollars be OK?
S: Three dollars are enough.

ក. ដប់ថ្ងៃបានទេ? — ដប់ថ្ងៃល្មមហើយ។
ខ. ពីរម៉ោងបានទេ? — ពីរម៉ោងល្មមហើយ។
គ. មួយបានទេ? — មួយល្មមហើយ។
ឃ. សៀវភៅបួនបានទេ? — សៀវភៅបួនល្មមហើយ។
ង. ប្រាំលីត្របានទេ? — ប្រាំលីត្រល្មមហើយ។
ច. មួយដងបានទេ? — មួយដងពីល្មមហើយ។

DRILL TEN: Substitution

MODEL: T: លោកគ្រាន់តែពឹងគេជីកបានហើយ។ (សរសេរ)
S: លោកគ្រាន់តែពឹងគេសរសេរបានហើយ។
T: It's enough if you just ask them to dig. (write)
S: It's enough if you just ask them to write.

ក. លោកគ្រាន់តែពឹងគេសរសេរបានហើយ។ (ធ្វើ)
ខ. លោកគ្រាន់តែពឹងគេធ្វើបានហើយ។ (ជួយ)
គ. លោកគ្រាន់តែពឹងគេជួយបានហើយ។ (ចម្លង)
ឃ. លោកគ្រាន់តែពឹងគេចម្លងបានហើយ។ (មើល)
ង. លោកគ្រាន់តែពឹងគេមើលបានហើយ។ (បង្រៀន)
ច. លោកគ្រាន់តែពឹងគេបង្រៀនបានហើយ។

## Reading Passage

### លោកគ្រូថ្មីយើង

ប្រហែលមួយខែហើយ យើងមានគ្រូថ្មីម្នាក់ គាត់ចេះធ្វើឱ្យយើងទាំងអស់គ្នាសប្បាយនិងពេញចិត្តនឹងគាត់ ហើយយើងក៏ចូលចិត្តនឹងរៀនដែរ។

ព្រឹកមិញ លោកគ្រូយើងបង្រៀនអំពីពាក្យថ្មី។ គាត់ឱ្យយើងសរសេរបណ្ដើរ គាត់ដើរនៅក្រោយយើងបណ្ដើរដើម្បីមើលថាតើយើងចេះសរសេរឬមិនចេះ។ ពេលនោះគាត់បានឃើញកូនសិស្សម្នាក់មុខក្រហម គាត់ក៏ឱ្យយើងឈប់សរសេរ ហើយដើរទៅជិតកូនសិស្សនោះ។ ក្រោយពីបានដឹងថាកូនសិស្សនោះមិនស្រួលខ្លួនព្រោះវាគ្រុនបន្តិច គាត់ក៏ប្រាប់វាថាត្រូវឯងត្រឡប់ទៅផ្ទះវិញចុះ។ នៅពេលគាត់កំពុងនិយាយទៅកូនសិស្សឈឺនេះ មានសិស្សម្នាក់នៅក្រោយគាត់ក៏ក្រោកឈរលើកៅអីហើយរាំជាការសប្បាយ។ លោកគ្រូយើងក៏ងាកក្បាលទៅឃើញកូនសិស្សខូចនេះ គាត់ក៏ឈប់និយាយទៅក្មេងឈឺនោះភ្លាម ហើយក៏ដើរទៅតុគាត់។

នៅក្រោយពេលដែលកូនសិស្សឈឺបានចេញពីថ្នាក់ លោកគ្រូយើងក៏ចាប់ឱ្យយើងរៀនសរសេរទៀត។ កាលណាយើងសរសេរចប់ គាត់ក៏អង្គុយតែមិននិយាយអ្វីសោះ។ យើងទាំងអស់គ្នានៅស្ងៀម។ ប្រហែលប៉ុន្មាននាទីក្រោយមក គាត់ក៏និយាយថា៖ "អ្នកទាំងអស់គ្នាត្រូវស្ដាប់ខ្ញុំ អ្នកនិងខ្ញុំបានជួបគ្នាប្រហែលមួយខែហើយ ខ្ញុំចូលចិត្តកូនសិស្សទាំងអស់គ្នាដូចខ្ញុំស្រឡាញ់ចូលចិត្តកូនខ្ញុំដែរ ហើយជាពិសេសខ្ញុំមិនដែលហើយមិនចង់ធ្វើទោសអ្នកណាសោះទេ ដូច្នេះត្រូវអ្នកទាំងអស់ខំរៀន កុំលេងច្រើនពេក។ ខ្ញុំមិនចាំបាច់ឱ្យអ្នកធ្វើបីមកខ្ញុំទេ ពីព្រោះខ្ញុំជឿថាអ្នកនឹងស្ដាប់ខ្ញុំហើយនឹងយល់តាមខ្ញុំហើយ។"

ដល់គាត់និយាយចប់ គាត់ក៏ប្រាប់ឱ្យយើងចេញ។ យើងទាំងអស់គ្នាសប្បាយណាស់ ព្រោះយើងមានគ្រូល្អ។

## VOCABULARY

| | | |
|---|---|---|
| ក្បាលម៉ាស៊ីន | kbaal məsin | faucet (L) |
| ក្របី | kəbεy | water buffalo (L) |
| ក្រោក | kraok | to arise, to get up (R) |
| ងាក | ŋiaʔ | to turn (R) |
| ចំណែកឯ...វិញ | cənaεk aε...viñ | as for |
| ជាចាំបាច់ | cia cam bac | necessary (see note) |
| ...ជាង...ដង | ...ciaŋ...dɔɔŋ | times as...as... |
| ជីក | ciik | to dig |
| ជឿ | cɨə | to believe (R) |
| ថ្លា | thlaa | clear (L) |
| ទាល់តែ...កុំអី | tóh taε...kom εy | if it weren't for the fact that... |
| ទាស់អី | tóh εy | what's wrong? |
| ទឹកម៉ាស៊ីន | tik məsin | if it weren't that fountain water |
| ទុកឱ្យ...វិញ | tuk aoy...viñ | leave it to... |

| | | |
|---|---|---|
| បង្ហូរ | pəhou | to cause to flow (L) |
| បណ្ដើរ ... បណ្ដើរ | pədaə...pədaə | to both...and to... (R) |
| បើ ... វិញ | baə...viñ | if it were... |
| ប្រដាប់ប្រដា | pədap pədaa | equipment |
| ផ្ដល់ | phdɔl | to supply |
| ភូមិ | phum | small village, hamlet |
| ម៉ាស៊ីនទឹក | məsin tik | water fountain |
| លូ | luu | sewer, large pipe (L) |
| ស្ងៀម | sŋiem | quiet, still (R) |
| ហូរ | hou | to flow (L) |
| ហូរកាត់ | hou kat | to flow across (L) |
| អណ្ដូង | ndouŋ | well |
| អ្នក | néʔ | you (R) |



Irrigation pond, near Phnom Penh

# LESSON FORTY

## DIALOGUE

| | | | |
|---|---|---|---|
| | | ស៊ឹងតែ | almost |
| | | ស៊ឹងតែ...មិន | hardly, almost...not |
| ១. | សុខ | ម្សិលមិញខ្ញុំស៊ឹងតែរកពេល ញ៉ាំបាយមិនបាន ! | Yesterday I almost couldn't find time to eat. |
| | | មេ៉ចបានតែ | why |
| | | បង្ខំ | to force, to rush |
| ២. | សៅ | មេ៉ចបានតែលោកបង្ខំម្លេះ ? | Why do you rush so much? |
| | | ធ្វើមេ៉ចក៏ត្រូវ | what can (I) do! |
| | | បំណាច់នឹង | since |
| ៣. | សុខ | ធ្វើមេ៉ចក៏ត្រូវបំណាច់នឹង យើងធ្វើការឲ្យគេហើយ។ | What can we do, since we're working for those people. |
| | | គួរ | should |
| | | ...ផង...ផង | both...and... |
| ៤. | សៅ | បាទ តែលោកមិនគួរធ្វើ ការផងហើយញ៉ាំបាយផងទេ។ | Yes, but you shouldn't work and eat at the same time. |
| | | សង្ឃឹមថា | to hope (that) |
| ៥. | សុខ | ខ្ញុំសង្ឃឹមថាប្រហែលស្អែក រួចហើយមើលទៅ។ | I hope that tomorrow I'll finish it. |
| | | ចុងអាទិត្យ | weekend |
| ៦. | សៅ | រួចចុងអាទិត្យហ្នឹងទៅណាទេ? | And this weekend, are you going anywhere? |
| | | បែប | kind, type; perhaps, maybe |
| | | ណាមួយ...ណាមួយ... | on the one hand...and on the other |
| ៧. | សុខ | ទេ ខ្ញុំបែបមកធ្វើការទៀត។ ទៅណា ? ណាមួយខ្ញុំគ្មានលុយ ណាមួយខ្ញុំជំពាក់គេ ។ | No, perhaps I'll go to work. Where can I go? On the one hand I don't have money, and on the other I'm in debt. |
| | | ស្រាប់តែ | suddenly |
| ៨. | សៅ | យី ស្រាប់តែធ្វើការសម្លាប់ ខ្លួនឯងតែម្តង ។ | Gee! Suddenly you're working towards your own funeral. |
| | | ស៊ូ...ជាជាង... | rather...than... |
| | | ឥតប្រយោជន៍ | useless |
| ៩. | សុខ | ខ្ញុំស៊ូធ្វើការជាជាងដើរលេង ឥតប្រយោជន៍ ។ | I'd rather work than go out for nothing. |

DIALOGUE:

1. sok - məsəl mɛñ khñom səŋ taɛ rɔ́o peel ñam baay mɨn baan!

2. saw - mɛc baan tə look pəkhom mɛh?

3. sok - thəə mɛc aaləw ɔmnaac nɨŋ yəəŋ thəə kaa aoy kee haəy

4. saw - baat, taɛ look mɨn kuo thəə kaa phɔɔŋ ñam baay phɔɔŋ tee

5. sok - khñom səkhim thaa pəhaɛl sʔaɛk ruoc haəy məəl təh

6. saw - ruoc cɔŋ aatɨt nɨŋ tɨw naa tee?

7. sok - tee, khñom baɛp mɔ́o thəə kaa tiet. tɨw naa? naa muoy khñom kmian luy, naa muoy khñom cəpéʔ kee

8. saw - yii, srap taɛ thəə kaa səlap khluon aɛŋ taɛ mə dɔɔŋ

9. sok - khñom suu thəə kaa cia ciaŋ daə leeŋ ət pəyaoc

NOTES

DIALOGUE

This lesson has several useful structures:

SENTENCE NO.

3. អំណាចនឹង /mnaac nɨŋ/ 'since, given the fact that.'

4. . . . ផង...ផង /...phɔɔŋ...phɔɔŋ/ 'to both....and...'

7. ណាមួយ...ណាមួយ /naa muoy...naa muoy/ 'on the one hand..., and on the other hand...'

9. សូវ...ជាជាង... /suu...cia ciaŋ.../ '(I'd) rather...than...'

Correct use of this type of structure goes a long way toward making the Cambodian you speak sound more natural and idiomatic.

2. បង្ខំ /pəkhom/ 'to force' is another causative derivative, this time with the common prefix បង់ /bɔŋ-/ and the root verb ខំ /khom/ 'to try, to make an effort.' Cf. V.3.2.1 in the grammatical sketch.

DRILLS

DRILL ONE: Substitution

MODEL: T: ខ្ញុំសឹងតែរកពេលញ៉ាំបាយមិនបាន។ (ដើរលេង)

S: ខ្ញុំសឹងតែរកពេលដើរលេងមិនបាន។

T: I could hardly find time to eat. (go out)

S: I could hardly find time to go out.

ក. ខ្ញុំស្ទើរតែរកពេលដើរលេងមិនបាន។ (បង្រៀន)
ខ. ខ្ញុំស្ទើរតែរកពេលបង្រៀនមិនបាន។ (រៀន)
គ. ខ្ញុំស្ទើរតែរកពេលរៀនមិនបាន។ (ទៅលេងលោក)
ឃ. ខ្ញុំស្ទើរតែរកពេលទៅលេងលោកមិនបាន។ (សំរាក)
ង. ខ្ញុំស្ទើរតែរកពេលសំរាកមិនបាន។ (អង្គុយ)
ច. ខ្ញុំស្ទើរតែរកពេលអង្គុយមិនបាន។

DRILL TWO: Transformation

MODEL: T: ខ្ញុំស្ទើរតែរកពេលញ៉ាំបាយមិនបាន។
S: ខ្ញុំរកពេលញ៉ាំបាយស្ទើរតែមិនបាន។
T: I almost didn't have time to eat.
S: I almost didn't have time to eat.

ក. ខ្ញុំស្ទើរតែរកពេលបង្រៀនមិនបាន។ ខ្ញុំរកពេលបង្រៀនស្ទើរតែមិនបាន។
ខ. ខ្ញុំស្ទើរតែរកពេលរៀនមិនបាន។ ខ្ញុំរកពេលរៀនស្ទើរតែមិនបាន។
គ. ខ្ញុំស្ទើរតែរកពេលអង្គុយមិនបាន។ ខ្ញុំរកពេលអង្គុយស្ទើរតែមិនបាន។
ឃ. ខ្ញុំស្ទើរតែរកពេលសំរាកមិនបាន។ ខ្ញុំរកពេលសំរាកស្ទើរតែមិនបាន។
ង. ខ្ញុំស្ទើរតែរកពេលដើរលេងមិនបាន។ ខ្ញុំរកពេលដើរលេងស្ទើរតែមិនបាន។
ច. ខ្ញុំស្ទើរតែរកពេលទៅលេងលោកមិនបាន។ ខ្ញុំរកពេលទៅលេងលោកស្ទើរតែមិនបាន។

DRILL THREE: Response

MODEL: T: ម៉េចបានតែលោកប្រញាប់ម្ល៉េះ? (ទៅរៀន)
S: ខ្ញុំប្រញាប់ព្រោះខ្ញុំត្រូវទៅរៀន។
T: Why do you have to rush so? (go to school)
S: I have to rush because I have to go to school.

ក. ម៉េចបានតែលោកប្រញាប់ម្ល៉េះ? (ចូលម៉ោងប្រាំបី)
ខ្ញុំប្រញាប់ព្រោះខ្ញុំត្រូវចូលម៉ោងប្រាំបី។
ខ. ម៉េចបានតែលោកប្រញាប់ម្ល៉េះ? (ញ៉ាំបាយ)
ខ្ញុំប្រញាប់ព្រោះខ្ញុំត្រូវញ៉ាំបាយ។
គ. ម៉េចបានតែលោកប្រញាប់ម្ល៉េះ? (ទៅមើលកុន)
ខ្ញុំប្រញាប់ព្រោះខ្ញុំត្រូវទៅមើលកុន។
ឃ. ម៉េចបានតែលោកប្រញាប់ម្ល៉េះ? (ទៅទទួលប្រពន្ធខ្ញុំ)
ខ្ញុំប្រញាប់ព្រោះខ្ញុំត្រូវទៅទទួលប្រពន្ធខ្ញុំ។
ង. ម៉េចបានតែលោកប្រញាប់ម្ល៉េះ? (ជួបគ្រូពេទ្យ)
ខ្ញុំប្រញាប់ព្រោះខ្ញុំត្រូវជួបគ្រូពេទ្យ។
ច. ម៉េចបានតែលោកប្រញាប់ម្ល៉េះ? (ទៅឲ្យទាន់ម៉ោង)
ខ្ញុំប្រញាប់ព្រោះខ្ញុំត្រូវទៅឲ្យទាន់ម៉ោង។

DRILL FOUR: Transformation

MODEL: T: យើងធ្វើការឲ្យគេ។ (បង្ខំ)

S: យើងត្រូវតែបង្ខំបំណាច់នឹងយើងធ្វើការឲ្យគេ។

T: We're working for those people. ( force, rush )

S: We have to rush since we're working for those people.

ក. ខ្ញុំទៅផ្សារ។ (ទិញត្រី)
ខ្ញុំត្រូវតែទិញត្រីបំណាច់នឹងខ្ញុំទៅផ្សារ។

ខ. ខ្ញុំទៅសាលា។ (យកសៀវភៅជូនលោក)
ខ្ញុំត្រូវតែយកសៀវភៅជូនលោកបំណាច់នឹងខ្ញុំទៅសាលា។

គ. ខ្ញុំទៅញូវយ៉ក។ (ចូលលេងលោក)
ខ្ញុំត្រូវតែចូលលេងលោកបំណាច់នឹងខ្ញុំទៅញូវយ៉ក។

ឃ. ខ្ញុំទៅផ្ទះ។ (ធ្វើបាយញ៉ាំ)
ខ្ញុំត្រូវតែធ្វើបាយញ៉ាំបំណាច់នឹងខ្ញុំទៅផ្ទះ។

ង. ខ្ញុំមកថ្នាក់លោក។ (និយាយ)
ខ្ញុំត្រូវតែនិយាយបំណាច់នឹងខ្ញុំមកថ្នាក់លោក។

ច. ខ្ញុំទៅប៉ុស។ (ទិញតែម)
ខ្ញុំត្រូវតែទិញតែមបំណាច់នឹងខ្ញុំទៅប៉ុស។

DRILL FIVE: Transformation

MODEL: T: ខ្ញុំធ្វើការនៅសាលា។ (ផ្ទះ)

S: ខ្ញុំគួរធ្វើការនៅផ្ទះដែរ។

T: I'm working at school.

S: I should work at home, too.

| | | |
|---|---|---|
| ក. ខ្ញុំរៀនភាសាបារាំង។ | (អង់គ្លេស) | ខ្ញុំគួររៀនភាសាអង់គ្លេសដែរ។ |
| ខ. លោកទៅលេងស្រុកជប៉ុន។ | (ស្រុកសៀម) | លោកគួរទៅលេងស្រុកសៀមដែរ។ |
| គ. ខ្ញុំបង្រៀនលោក។ | (នាង) | ខ្ញុំគួរបង្រៀននាងដែរ។ |
| ឃ. នាងដើរលេងជាមួយខ្ញុំ។ | (គាត់) | នាងគួរដើរលេងជាមួយគាត់ដែរ។ |
| ង. យើងទៅលេងអ្នកគ្រូ។ | (លោកគ្រូ) | យើងគួរទៅលេងលោកគ្រូដែរ។ |
| ច. ខ្ញុំញ៉ាំត្រីនៅផ្ទះ។ | (ញ៉ាំបាយ) | ខ្ញុំគួរញ៉ាំបាយនៅផ្ទះដែរ។ |

DRILL SIX: Transformation

MODEL: T: ខ្ញុំធ្វើការ។ (ញ៉ាំបាយ)

S: ខ្ញុំធ្វើការផងខ្ញុំញ៉ាំបាយផង។

T: I work. (eat)

S: I work and eat at the same time.

ក. ខ្ញុំញ៉ាំកាហ្វេ។ (មើលកាសែត) ខ្ញុំញ៉ាំកាហ្វេផងខ្ញុំមើលកាសែតផង។
ខ. ខ្ញុំដើរ។ (មើលសៀវភៅ) ខ្ញុំដើរផងខ្ញុំមើលសៀវភៅផង។
គ. ខ្ញុំបង្រៀន។ (រៀន) ខ្ញុំបង្រៀនផងខ្ញុំរៀនផង។
ឃ. ខ្ញុំធ្វើការ។ (លេង) ខ្ញុំធ្វើការផងខ្ញុំលេងផង។
ង. ខ្ញុំទៅធ្វើការ។ (មើលកូន) ខ្ញុំទៅធ្វើការផងខ្ញុំមើលកូនផង។
ច. ខ្ញុំរៀនមេរៀន។ (ធ្វើចំណោទ្យ) ខ្ញុំរៀនមេរៀនផងខ្ញុំធ្វើចំណោទ្យផង។

DRILL SEVEN: Substitution

MODEL: T: ខ្ញុំសង្ឃឹមថាប្រហែលស្អែករួចហើយ។ (ដឹង)
S: ខ្ញុំដឹងថាប្រហែលស្អែករួចហើយ។
T: I hope that tomorrow I'll finish it. (know)
S: I know that tomorrow I'll finish it.

ក. ខ្ញុំដឹងថាប្រហែលស្អែករួចហើយ។ (ស្មាន)
ខ. ខ្ញុំស្មានថាប្រហែលស្អែករួចហើយ។ (គិត)
គ. ខ្ញុំគិតថាប្រហែលស្អែករួចហើយ។ (ជឿ)
ឃ. ខ្ញុំជឿថាប្រហែលស្អែករួចហើយ។ (ឮ)
ង. ខ្ញុំឮថាប្រហែលស្អែករួចហើយ។ (យល់)
ច. ខ្ញុំយល់ថាប្រហែលស្អែករួចហើយ។

DRILL EIGHT: Transformation

MODEL: T: ខ្ញុំមកធ្វើការ។
S: ខ្ញុំបែបមកធ្វើការ។
T: I'm coming to work.
S: Perhaps I'm coming to work.

ក. ខ្ញុំខ្ចីលុយលោក។ ខ្ញុំបែបខ្ចីលុយលោក។
ខ. ខ្ញុំត្រូវទៅសាលារៀនស្អែក។ ខ្ញុំបែបត្រូវទៅសាលារៀនស្អែក។
គ. ខ្ញុំបង្រៀនលោកថ្ងៃនេះ។ ខ្ញុំបែបបង្រៀនលោកថ្ងៃនេះ។
ឃ. លោកមិនទៅរៀនទេ។ លោកបែបមិនទៅរៀនទេ។
ង. ខ្ញុំមិនចង់ទៅលេងគាត់សោះ។ ខ្ញុំបែបមិនចង់ទៅលេងគាត់សោះ។
ច. ខ្ញុំមិនស្រួលខ្លួនទេ។ ខ្ញុំបែបមិនស្រួលខ្លួនទេ។

DRILL NINE: Transformation

MODEL: T: ខ្ញុំគ្មានលុយ។ (ខ្ញុំជំពាក់គេ)
S: ណាមួយខ្ញុំគ្មានលុយ ណាមួយខ្ញុំជំពាក់គេ។
T: I don't have money. (I'm in debt)
S: On the hand I don't have money, and on the other I'm in debt.

ក. ខ្ញុំធ្វើការ។ (ខ្ញុំទៅរៀន)
ណាមួយខ្ញុំធ្វើការ ណាមួយខ្ញុំទៅរៀន។
ខ. ឡាននោះថ្លៃ។ (ខ្ញុំគ្មានលុយ)
ណាមួយឡាននោះថ្លៃ ណាមួយខ្ញុំគ្មានលុយ។
គ. ខ្ញុំរវល់។ (ខ្ញុំទៅទទួលប្រពន្ធខ្ញុំ)
ណាមួយខ្ញុំរវល់ ណាមួយខ្ញុំទៅទទួលប្រពន្ធខ្ញុំ។
ឃ. ខ្ញុំដេកមិនបាន។ (ខ្ញុំឈឺ)
ណាមួយខ្ញុំដេកមិនបាន ណាមួយខ្ញុំឈឺ។
ង. ប្អូនមិនរៀនមេរៀន។ (ប្អូនខ្ជិល)
ណាមួយប្អូនមិនរៀនមេរៀន ណាមួយប្អូនខ្ជិល។
ច. សៅឯងមិនស្តាប់ខ្ញុំ។ (សៅឯងនិយាយក្នុងថ្នាក់)
ណាមួយសៅឯងមិនស្តាប់ខ្ញុំ ណាមួយសៅឯងនិយាយក្នុងថ្នាក់។

DRILL TEN: Transformation

MODEL: T: ខ្ញុំធ្វើការ។ (ដើរលេងឥតប្រយោជន៍)
S: ខ្ញុំស៊ូធ្វើការជាជាងដើរលេងឥតប្រយោជន៍។
T: I work. (go out for nothing)
S: I'd rather work than go out for nothing.

ក. ខ្ញុំគ្មានលុយ។ (ខ្ចីលុយគេ)
ខ្ញុំស៊ូគ្មានលុយជាជាងខ្ចីលុយគេ។
ខ. ខ្ញុំពិបាក។ (ទៅឱ្យគេសម្លាប់)
ខ្ញុំស៊ូពិបាកជាជាងទៅឱ្យគេសម្លាប់។
គ. ខ្ញុំស្លាប់។ (ទៅជួបគាត់)
ខ្ញុំស៊ូស្លាប់ជាជាងទៅជួបគាត់។
ឃ. ខ្ញុំដើរទៅសាលា។ (ជិះជាមួយគាត់)
ខ្ញុំស៊ូដើរទៅសាលាជាជាងជិះជាមួយគាត់។
ង. ខ្ញុំស្លាប់។ (ទៅពេទ្យ)
ខ្ញុំស៊ូស្លាប់ជាជាងទៅពេទ្យ។

Reading Passage

ការ

ប្រុសៗនៅស្រុកខ្មែរមិនអាចការប្រពន្ធតាមតែខ្លួនស្រឡាញ់នោះទេ។ កាលណាគេចង់បានប្រពន្ធ គេប្រាប់ឪពុកម្តាយគេហើយឪពុកម្តាយគេនឹងរកប្រពន្ធឱ្យ។ របៀបរកប្រពន្ធមិនមែនជាការស្រួលទេ។ ឪពុកម្តាយត្រូវសួរគេសួរឯងអំពីគ្រួសារខាងស្រីដូចជាកូនស្រីនោះកើតនៅថ្ងៃណា ខែណា ឆ្នាំណា ហើយគេនឹងយកទៅឱ្យគ្រូទាយ។ ចំណែកឯគ្រួសារខាងស្រីក៏ធ្វើដូចគ្នាដែរ ហើយត្រូវគិតមើលតើប្រុសនេះមានការធ្វើ

ទេ  តើជាអ្នកធ្វើការរដ្ឋការ ឬអ្នកលក់ដូរ ឬជាអ្នកស្រែចំការ  តើប្រុសបានរៀនដល់ណាជាដើម។ ការមានប្តីប្រពន្ធរបៀបនេះមិនមែនជាការល្អប៉ុន្មានទេ ដូនកាលធ្វើឲ្យកូនៗមិនសប្បាយចិត្ត តែភាគច្រើនគេក៏ចេះរៀនស្រឡាញ់គ្នា រស់នៅជាមួយគ្នាជាធម្មតា។ បើគេមិនត្រូវគ្នាវិញ គេក៏លែងគ្នាហើយប្តីភាគច្រើនទៅយកប្រពន្ធមួយទៀត តែប្រពន្ធភាគច្រើនស៊ូនៅមេម៉ាយជាជាងទៅយកប្តីមួយទៀត។ ប៉ុន្តែតាមទំនៀមទម្លាប់ គេមិនសូវលែងលះគ្នាទេ ពីព្រោះស្រីភាគច្រើនជាអ្នកមិនចេះអក្សរ ដើម្បីធ្វើការបានស្រួលដូច្នេះប្រពន្ធត្រូវតែនៅជាមួយប្តីរបស់ខ្លួន ទោះជាគេមានរឿងយ៉ាងណាក៏ដោយ។ យ៉ាងនេះហើយបានជាឪពុកម្តាយខាងស្រីត្រូវរកប្តីណាដែលជាអ្នកមានប្រាក់ខែ ឲ្យកូន។ ព្រោះដឹងថាប្រពន្ធមិនអាចលែងប្តីបានយ៉ាងស្រួល ប្តីក៏បានចិត្ត ធ្វើអ្វីៗតាមតែខ្លួនចង់ ដូចជាដើរលេងយប់ពាក់យប់ មានស្រីឯទៀត លេងបៀជាដើម។ ដូនកាលគេក៏លួចទៅមានប្រពន្ធមួយទៀត។

តែឥឡូវនេះប្រុសៗខ្មែរអាចបង្គាប់ឲ្យឪពុកម្តាយគេឲ្យទៅរកស្រីដែលគេស្រឡាញ់ ហើយឯស្រីៗខ្មែរវិញក៏គេធ្វើយ៉ាងនេះដែរ គឺថាគេមិនព្រមយកប្តីដែលឪពុកម្តាយគេបង្ខំឲ្យគេទទួលយក។

## VOCABULARY

| | | |
|---|---|---|
| គួរ | kuo | should |
| គ្រូទាយ | kruu tiey | astrologer, soothsayer (R) |
| ចុង | coŋ | end |
| ចុងអាទិត្យ | coŋ aatɨt | weekend |
| ជឿ | cɨə | to believe |
| ដំណាំ | tənam | plant, something planted (L) |
| ដុះ | doh | to grow |
| ណាមួយ ... ណាមួយ | naa muoy...naa muoy | on the one hand...on the other hand..., both...and..., not only...but... |
| ទាយ | tiey | to predict, to soothsay, to tell fortunes (R) |
| ទំនៀមទម្លាប់ | təniem təlóp | custom (R) |
| ធ្វើម៉េចឥឡូវ! | thee mɛc aaləw! | What can I do! |
| បានចិត្ត | baan cət | to be spoiled, to have a swollen head (R) |
| បែប | baɛp | perhaps, maybe; kind |
| ម្ណាច់នឹង | mnaac niŋ | since |
| បង្ខំ | pəkhɔm | to rush, to force |
| បញ្ចូល | pəcoul | to introduce, to put in (L) |
| ផល | phəl | product (L) |
| ... ផង ... ផង | ...phɔɔŋ...phɔɔŋ | both...and... |
| ភ្ជួរ | phcuo | to plow (L) |
| មេម៉ាយ | meemaay | widow, widower; divorcé(e) (R) |
| ម៉េចបានតែ | mɛc baan tə | why |

| | | |
|---|---|---|
| រាស់ | róh | to rake, to harrow (L) |
| លែង | lɛɛŋ | to divorce (R) |
| លែងលះ | lɛɛŋ lɛh | to divorce (R) |
| សង្ឃឹម | səkhim | to hope |
| សត្វ | sat | animal (L) |
| សឹងតែ | səŋ taɛ | almost |
| សឹងតែ... មិន | səŋ taɛ...mɨn | hardly, almost...not |
| សូ ... ជាជាង | suu...cia ciaŋ | rather...than..., to prefer |
| ស្រាប់តែ | srap taɛ | suddenly |
| ឥតប្រយោជន៍ | ət pəyaoc | useless |



Residential street scene, Phnom Penh

PASSAGE B

# សេចក្ដីឆោតល្ងង់

មានអ្នកឆោតល្ងង់ម្នាក់ បានសង្កេតឃើញអ្នកជិតខាងពាក់វ៉ែនតាមើលអក្សរ ដោយស្មានថា វ៉ែនតានោះពាក់ទៅអាចឲ្យមើលអក្សរបាន ក៏ទៅផ្សាររកទិញវ៉ែនតាមួយ ។

លុះទៅដល់ផ្ទះលក់វ៉ែនតា អ្នកនោះ ក៏រើសយកវ៉ែនតាមួយមកពាក់ ហើយបើកសៀវភៅក្បួនមើល មើលឃើញអក្សរហើយតែថាមិនកើត ក៏ចេះតែរើករកវ៉ែនតាផ្សេងៗទៀត ទើបនិយាយទៅកាន់អ្នកលក់ថា វ៉ែនតាអ្នកមិនល្អទេ ពីព្រោះខ្ញុំមើលអក្សរមិនដាច់ ។ អ្នកលក់ក៏ឆ្ងល់ ហើយសួរថា អ្នកចេះអក្សរឬទេ? អ្នកនោះឆ្លើយថា បើខ្ញុំចេះអក្សរហើយ ខ្ញុំមិនចាំបាច់មករកទិញវ៉ែនតាទេ ។ អ្នកលក់អស់សំណើច ហើយថាខ្ញុំគ្មានវ៉ែនតាលក់ឲ្យតាមបំណងអ្នកទេ អ្នកត្រូវទៅរៀនអក្សរឲ្យចេះសិន ហើយបើកាលណាមើលអក្សរមិនច្បាស់ សឹមត្រឡប់មករកខ្ញុំវិញ ។



| | | |
|---|---|---|
| សេចក្ដីឆោតល្ងង់ | sec kdɛy chaot ləŋúŋ | stupidity |
| សេចក្ដី | sec kdɛy | matter, story, contents; makes nouns from verbs |
| ឆោត | chaot | naive, gullible |
| ឆោតល្ងង់ | chaot ləŋúŋ | stupid |
| សង្កេត | səkeet | to observe |
| វ៉ែនតា | vaɛn taa | glasses, spectacles |
| លុះ | luh | when |
| ល្បង | lbɔɔŋ | to try |
| រើ | rəə | to move, to remove |
| ទើប | təəp | then, = /baan/ 'not... until' |
| ទៅកាន់ = ទៅ (literary) | | to, towards |
| អ្នក | néʔ | you |
| ឆ្ងល់ | chŋɔl | to wonder |
| អស់សំណើច | ɔh sənaəc | to find something ridiculous |
| សំណើច | sənaəc | laughter |
| សើច | saəc | to laugh |
| បំណង | mnɔɔŋ | intention |



Roadside vegetable market just outside Phnom Penh

## LESSON FORTY-ONE

## DIALOGUE

| | | | |
|---|---|---|---|
| | | បំរើ | to serve |
| | | អ្នកបំរើ | servant, maid, houseboy |
| ១. | ស៊ុម | លោកអាចជួយរកអ្នកបំរើម្នាក់ឲ្យខ្ញុំបានទេ? | Can you help me look for a servant? |
| | | យូរមកហើយ | a long time ago |
| | | ពីមួយថ្ងៃនោះ | the other day |
| | | ឈ្នួល | something rented, someone hired |
| | | ក្មេងឈ្នួល | servant, houseboy, maid |
| ២. | សុខ | យូរមកហើយមិនប្រាប់ខ្ញុំ? ពីមួយថ្ងៃនោះមានគេសួរខ្ញុំថាតើខ្ញុំចង់បានក្មេងឈ្នួលម្នាក់ទេ? | Why didn't you tell me a long time ago? The other day someone asked me whether I needed a servant or not. |
| | | ចំពោះ | as for, for, towards |
| | | ប៉ុន្តែ | but |
| ៣. | ស៊ុម | បាទចំពោះលោក ស្រួលស្រួលរកទេ ប៉ុន្តែខ្ញុំ ខ្ញុំត្រូវរកមនុស្សដែលចេះនិយាយអង់គ្លេសដែរ។ | Yes, it is easy for you, but me, I have to find people who know how to speak English too. |
| | | ...ស្រាប់ | already, ready |
| ៤. | សុខ | ហេតុអី? លោកចេះនិយាយខ្មែរស្រាប់ ព្រួយធ្វើអី? | Why? You know how to speak Cambodian already. Why worry? |
| ៥. | ស៊ុម | ចុះតើគេនិយាយជាមួយប្រពន្ធកូនខ្ញុំយ៉ាងម៉េច? | And how can they speak with my wife and children? |
| ៦. | សុខ | ចុះមុនៗលោកធ្វើម៉េច? | And before, what did you do? |
| ៧. | ស៊ុម | បាទ ខ្ញុំដូរអ្នកបំរើអស់ប្រាំនាក់ហើយ។ | Well, I've changed servants five times already. |
| | | ...ចុះណាស់ | a lot (in the sense of waste) |
| | | ហេតុតែ | just because |
| ៨. | សុខ | យី លោកប្រើអ្នកបំរើចុះណាស់ ហេតុតែលោកមានលុយច្រើនហើយ។ | Gee! you sure do use a lot of servants, just because you're rich. |
| | | ឆ្លៀត | to take the opportunity, take the time, go out of one's way |
| ៩. | ស៊ុម | ម៉េចលោកឆ្លៀតជួយរកឲ្យខ្ញុំបានទេ? | Well, can you take the time to help find me someone? |
| | | ប្រទះ | to meet (by accident), to run into |
| ១០. | សុខ | ចាំមើលខ្ញុំរកមើលក្រែងប្រទះម្នាក់។ | We'll see. I'll try to look for one, and maybe I'll run into someone. |

DIALOGUE:

1. tom - look aac cuoy róo né? pəmraə məné? aoy khñom baan eh?

2. sok - yuu móo həh mɨn prap khñom? pii məŋay noh mian kee suo khñom taə khñom coŋ baan kmeeŋ chnuol məné? eh?

3. tom - baat cəpuoh look, chnuol sruol róo tee, pəntaɛ khñom, khñom trəw róo mənuh daɛl cɛh niyiey oŋglee daɛ.

4. sok - haɛt ɛy? look cɛh niyiey khmaɛ srap, pruoy thəə ɛy?

5. tom - coh taə kee niyiey cia muoy pəpún koun khñom yaaŋ mɛc?

6. sok - coh mun mun look thəə mɛc?

7. tom - baat, khñom dou né? pəmraə ɔh pram né? həh.

8. sok - yii, look praə né? pəmraə coh nah, haɛt taɛ look mian luy craən həh.

9. tom - mɛc look chliet cuoy róo aoy khñom baan eh?

10. sok - cam məə khñom róo məə kraɛŋ pətéh məné?.

NOTES

DIALOGUE

SENTENCE NO.

2. Note that the context supplies 'why?' in the first part of this sentence, so ហេតុអ្វី /haɛt ɛy/ 'why' can be omitted.

2. ណោះ /noh/ is a spoken form of នោះ /nuh/ 'that' (cf. N.2 in the grammatical sketch).

2. មាន /mian/ + clause means 'it is a fact that...,' e.g.,

មានគេលក់ថ្នាំនៅហាងនឹង?
mian kee lú? thnam nɨw haaŋ nɨŋ?
(Is it a fact that) they sell drugs in that store?

4. The word ស្រាប់ /srap/ means 'already' at the end of a sentence, as in sentence 4. With certain nouns it forms a compound meaning 'ready-made,' e.g. ខោអាវស្រាប់ /khao aav srap/ 'ready-to-wear clothing.' In both cases, the connotation of ស្រាប់ /srap/ is that further preparation is unnecessary.

4. Another way of saying 'why?' is ធ្វើអ្វី(អី) /thəə ɛy?/, literally 'to do what?, for what purpose?'

8. Adverbial ចុះ /coh/ in this sentence means 'a lot' in the sense of waste or extravagance.

## DRILLS

DRILL NO.

3. Note the use of the resultative verb បាន /baan/ 'to get' with a quantity. The formula is verb + noun + បាន /baan/ + quantity, e.g.,

   គេចាប់ក្ដាមបានមួយឡូ។

   kee cap kdam baan mə lou

   They caught a dozen crabs.

6., 7. ឆាប់ /chap/ + verb means 'quick to..., easily...,' e.g.,

   ឡាននោះឆាប់ខូចណាស់។

   laan nuh chap khouc nah

   That breaks down very easily (is very quick to break down).

The opposite of ឆាប់ /chap/ + verb is ក្រ /krɔɔ/ + verb 'seldom, slow to, doesn't...easily,' e.g.,

   ឡាននោះក្រខូចណាស់។

   laan nuh krɔɔ khouc nah

   That car seldom breaks down.

## DRILLS

DRILL ONE: Substitution

MODEL: T: យូរមកហើយមិនប្រាប់ខ្ញុំ? (ទៅទិញ)
S: យូរមកហើយមិនទៅទិញ?
T: Why didn't you tell me a long time ago? (go to buy)
S: Why didn't you go to buy (it) a long time ago?

ក. យូរមកហើយមិនទៅទិញ? (រៀនបើកឡាន)
ខ. យូរមកហើយមិនរៀនបើកឡាន? (បង្រៀនកូនខ្ញុំ)
គ. យូរមកហើយមិនបង្រៀនកូនខ្ញុំ? (សួរប្រពន្ធលោក)
ឃ. យូរមកហើយមិនសួរប្រពន្ធលោក? (ជួលឈ្នួល)
ង. យូរមកហើយមិនជួលឈ្នួល? (ប្រាប់ខ្ញុំ)
ច. យូរមកហើយមិនប្រាប់ខ្ញុំ?

DRILL TWO: Transformation

MODEL: T: ខ្ញុំចង់ជួលអ្នកបំរើម្នាក់។ (ម្នាក់)
S: ខ្ញុំចង់ជួលអ្នកបំរើប៉ុន្មាននាក់?
T: I want to hire a servant. (one)
S: How many servants do I want to hire?

ក. ខ្ញុំត្រូវការឡានដើម្បីទៅរៀន។ (ឡាន)
ខ្ញុំត្រូវការអ្វីដើម្បីទៅរៀន?
ខ. ថ្ងៃនេះកូនខ្ញុំឈឺ វាមិនមករៀនទេ។ (កូនខ្ញុំឈឺ)
ថ្ងៃនេះ ហេតុអ្វីបានជាកូនខ្ញុំមិនមករៀន?
គ. លោកបង្រៀនមេរៀនតាមគេប្រាប់លោក។ (តាមគេប្រាប់លោក)
លោកបង្រៀនមេរៀនយ៉ាងម៉េច?
ឃ. ខ្ញុំបង្រៀនសៀវភៅលឿងមុន។ (លឿង)
ខ្ញុំបង្រៀនសៀវភៅអ្វីមុន?
ង. ខ្ញុំបង្រៀននៅទីក្រុងវ៉ាស៊ីនតោន។ (ទីក្រុងវ៉ាស៊ីនតោន)
ខ្ញុំបង្រៀននៅឯណា?
ច. លោកកុមត្រូវការក្មេងឈ្នួលម្នាក់។ (លោកកុម)
អ្នកណាត្រូវការក្មេងឈ្នួលម្នាក់?

DRILL THREE: Transformation

MODEL: T: ខ្ញុំជួលឈ្នួលម្នាក់។
S: ពីមួយថ្ងៃនោះខ្ញុំជួលឈ្នួលបានម្នាក់។
T: I hired a servant.
S: The other day I hired a servant.

ក. លោកទិញសៀវភៅអង់គ្លេសពីរ។
ពីមួយថ្ងៃនោះលោកទិញសៀវភៅអង់គ្លេសបានពីរ។
ខ. ខ្ញុំទៅបាញ់សត្វ។
ពីមួយថ្ងៃនោះខ្ញុំទៅបាញ់សត្វបានមួយ។
គ. ខ្ញុំដូរលុយមួយរយដុល្លា។
ពីមួយថ្ងៃនោះខ្ញុំដូរលុយបានមួយរយដុល្លា។
ឃ. កូនសិស្សខ្ញុំលួចសៀវភៅមួយ។
ពីមួយថ្ងៃនោះកូនសិស្សខ្ញុំលួចសៀវភៅបានមួយ។
ង. ខ្ញុំបន្លំចិនហាសិបរៀល។
ពីមួយថ្ងៃនោះខ្ញុំបន្លំចិនបានហាសិបរៀល។
ច. ខ្ញុំចាប់ចោរម្នាក់។
ពីមួយថ្ងៃនោះខ្ញុំចាប់ចោរបានម្នាក់។

DRILL FOUR: Transformation

MODEL: T: លោកចេះនិយាយខ្មែរស្រាប់។ (ត្រូវការអ្នកបកប្រែ)
S: បើលោកចេះខ្មែរអញ្ចឹងស្រួលហើយ ខ្ញុំមិនបាច់ត្រូវការអ្នកបកប្រែ។
T: You already speak Cambodian. (need a translator)
S: If you know Cambodian that's fine, I don't need a translator.

ក. លោកចេះធ្វើឡានស្រាប់។ (យកឱ្យគេធ្វើ)
បើលោកចេះធ្វើឡានអញ្ចឹងស្រួលហើយ ខ្ញុំមិនបាច់យកឱ្យគេធ្វើ។
ខ. លោកចេះចាក់ថ្នាំស្រាប់។ (ទៅជួបគ្រូពេទ្យ)
បើលោកចេះចាក់ថ្នាំអញ្ចឹងស្រួលហើយ ខ្ញុំមិនបាច់ទៅជួបគ្រូពេទ្យ។
គ. លោកចេះបើកឡានស្រាប់។ (ជួលអ្នកបើកឡាន)
បើលោកចេះបើកឡានអញ្ចឹងស្រួលហើយ ខ្ញុំមិនបាច់ជួលអ្នកបើកឡាន។
ឃ. លោកចេះហែលទឹកស្រាប់។ (ត្រូវការពោង)
បើលោកចេះហែលទឹកអញ្ចឹងស្រួលហើយ ខ្ញុំមិនបាច់ត្រូវការពោង។
ង. លោកចេះបាញ់ស្រាប់។ (ទៅរៀនបាញ់)
បើលោកចេះបាញ់អញ្ចឹងស្រួលហើយ ខ្ញុំមិនបាច់ទៅរៀនបាញ់។
ច. លោកចេះបង្រៀនស្រាប់។ (រៀនបង្រៀន)
បើលោកចេះបង្រៀនអញ្ចឹងស្រួលហើយ ខ្ញុំមិនបាច់រៀនបង្រៀន។

DRILL FIVE: Response

MODEL: T: ខ្ញុំប្រើអ្នកបំរើអស់ប្រាំនាក់ហើយ។
S: លោកប្រើអ្នកបំរើចុះណាស់។
T: I've already used five servants.
S: You do use a lot of servants.

ក. ឡានខ្ញុំប្រើសាំងដប់ប្រាំលីត្រមួយថ្ងៃ។ ឡានលោកប្រើសាំងចុះណាស់។
ខ. ផ្ទះខ្ញុំប្រើភ្លើងអស់ប្រាំរយរៀលមួយខែ។ ផ្ទះលោកប្រើភ្លើងចុះណាស់។
គ. ខ្ញុំពាក់ស្បែកជើងច្រើនគូណាស់។ លោកប្រើស្បែកជើងចុះណាស់។
ឃ. កូនខ្ញុំប្រើខោអាវឆាប់ខូចណាស់។ កូនខ្ញុំប្រើខោអាវចុះណាស់។
ង. ខ្ញុំសរសេរខ្មៅដៃអស់ច្រើនណាស់។ ខ្ញុំសរសេរខ្មៅដៃចុះណាស់។
ច. ប្រពន្ធខ្ញុំប្រើស្លាបប៉ាកកាឆាប់ខូចណាស់។ ប្រពន្ធខ្ញុំប្រើស្លាបប៉ាកកាចុះណាស់។

DRILL SIX: Substitution

MODEL: T: កូនខ្ញុំប្រើខោអាវឆាប់ខូចណាស់។ (រហែក)
S: កូនខ្ញុំប្រើខោអាវឆាប់រហែកណាស់។
T: My children wear out clothes very fast. (tear)
S: My children tear clothes very fast.

ក. កូនខ្ញុំប្រើខោអាវឆាប់រហែកណាស់។ (សៀវភៅ)
ខ. កូនខ្ញុំប្រើសៀវភៅឆាប់រហែកណាស់។ (មើល)
គ. កូនខ្ញុំមើលសៀវភៅឆាប់រហែកណាស់។ (ក្រខ្វក់)
ឃ. កូនខ្ញុំមើលសៀវភៅឆាប់ក្រខ្វក់ណាស់។ (កូនសិស្ស)
ង. កូនសិស្សខ្ញុំមើលសៀវភៅឆាប់ក្រខ្វក់ណាស់។ (ប្រើ)
ច. កូនសិស្សខ្ញុំប្រើសៀវភៅឆាប់ក្រខ្វក់ណាស់។ (ឡាន)

ឆ. កូនសិស្សខ្ញុំប្រើឡានឆាប់ក្រខ្វក់ណាស់។ (ខូច)
ជ. កូនសិស្សខ្ញុំប្រើឡានឆាប់ខូចណាស់។ (ខ្ញុំ)
ឈ. ខ្ញុំប្រើឡានឆាប់ខូចណាស់។

DRILL SEVEN: Transformation

MODEL: T: ខ្ញុំប្រើឡានឆាប់ខូចណាស់។
S: ខ្ញុំប្រើឡានក្រខូចណាស់។
T: I wear out a car very fast.
S: I use a car for a long time.

ក. កូនខ្ញុំមើលសៀវភៅឆាប់រហែកណាស់។ — កូនខ្ញុំមើលសៀវភៅក្ររហែកណាស់។
ខ. ខ្ញុំដើរឆាប់អស់កម្លាំងណាស់។ — ខ្ញុំដើរក្រអស់កម្លាំងណាស់។
គ. ខ្ញុំប្រើអាវសឆាប់ក្រខ្វក់ណាស់។ — ខ្ញុំប្រើអាវសក្រក្រខ្វក់ណាស់។
ឃ. ខ្ញុំមើលសៀវភៅនេះឆាប់ចប់ណាស់។ — ខ្ញុំមើលសៀវភៅនេះក្រចប់ណាស់។
ង. សំបុត្រខ្ញុំឆាប់មកដល់ណាស់។ — សំបុត្រខ្ញុំក្រមកដល់ណាស់។
ច. ខ្ញុំរៀនអង់គ្លេសឆាប់ចេះណាស់។ — ខ្ញុំរៀនអង់គ្លេសក្រចេះណាស់។

DRILL EIGHT: Response

MODEL: T: ខ្ញុំមិនចង់ទៅធ្វើការទេ។ (មានលុយច្រើនហើយ)
S: ហេតុតែលោកមានលុយច្រើនហើយបានជាលោកមិនចង់ទៅធ្វើការ។
T: I don't want to go to work. (have a lot of money already)
S: You don't want to go to work just because you have a lot of money.

ក. ខ្ញុំធ្វើអ្វីទាំងអស់ឲ្យគាត់។ (ស្រឡាញ់គាត់ហើយ)
ហេតុតែលោកស្រឡាញ់គាត់ហើយបានជាលោកធ្វើអ្វីទាំងអស់ឲ្យគាត់។
ខ. ខ្ញុំទិញឡានពីរបី។ (ចូលចិត្តឡានហើយ)
ហេតុតែលោកចូលចិត្តឡានហើយបានជាលោកទិញឡានពីរបី។
គ. ខ្ញុំមានប្រដាប់ភ្លេងច្រើន។ (ចូលចិត្តភ្លេងហើយ)
ហេតុតែលោកចូលចិត្តភ្លេងហើយបានជាលោកមានប្រដាប់ភ្លេងច្រើន។
ឃ. គាត់មិនមកលេងខ្ញុំ។ (មិនចូលចិត្តគាត់ហើយ)
ហេតុតែលោកមិនចូលចិត្តគាត់ហើយបានជាគាត់មិនមកលេងលោក។
ង. ខ្ញុំមើលសៀវភៅរាល់ថ្ងៃ។ (ចូលចិត្តសៀវភៅហើយ)
ហេតុតែលោកចូលចិត្តសៀវភៅហើយបានជាលោកមើលសៀវភៅរាល់ថ្ងៃ។
ច. ខ្ញុំមានចំណេះច្រើន។ (ចូលចិត្តសាលាហើយ)
ហេតុតែលោកចូលចិត្តសាលាហើយបានជាលោកមានចំណេះច្រើន។

DRILL NINE: Transformation

MODEL: T: ខ្ញុំរកឲ្យលោក។
S: លោកឆ្លៀតរកឲ្យខ្ញុំបានទេ?
T: I will look for you.
S: Can you take the time to look for me?

ក. ខ្ញុំជួលបន្ទប់មួយឲ្យលោក។ — លោកឆ្លៀតជួលបន្ទប់មួយឲ្យខ្ញុំបានទេ?
ខ. ខ្ញុំទៅដូរលុយឲ្យលោក។ — លោកឆ្លៀតទៅដូរលុយឲ្យខ្ញុំបានទេ?
គ. ខ្ញុំផ្ញើសំបុត្រនោះឲ្យលោក។ — លោកឆ្លៀតផ្ញើសំបុត្រនោះឲ្យខ្ញុំបានទេ?
ឃ. ខ្ញុំបើកឡានជូនលោកទៅសាលា។ — លោកឆ្លៀតបើកឡានជូនខ្ញុំទៅសាលាបានទេ?
ង. ខ្ញុំសុំច្បាប់លោកគ្រូឲ្យលោក។ — លោកឆ្លៀតសុំច្បាប់លោកគ្រូឲ្យខ្ញុំបានទេ?
ច. ខ្ញុំបង្រៀនកូនលោកមួយម៉ោង។ — លោកឆ្លៀតបង្រៀនកូនខ្ញុំមួយម៉ោងបានទេ?

DRILL TEN: Transformation

MODEL: T: ខ្ញុំត្រូវការឡានមួយដើម្បីជូនប្រពន្ធខ្ញុំទៅធ្វើការនៅវ៉ាស៊ីនតោន។
T: I need a car in order to take my wife to work in Washington.

ក. (ឡានមួយ)
ខ្ញុំត្រូវការអីដើម្បីជូនប្រពន្ធខ្ញុំទៅធ្វើការនៅវ៉ាស៊ីនតោន?

ខ. (ប្រពន្ធខ្ញុំ)
ខ្ញុំត្រូវការឡានមួយដើម្បីជូនអ្នកណាទៅធ្វើការនៅវ៉ាស៊ីនតោន?

គ. (ខ្ញុំ)
អ្នកណាត្រូវការឡានមួយដើម្បីជូនប្រពន្ធខ្ញុំទៅធ្វើការនៅវ៉ាស៊ីនតោន?

ឃ. (វ៉ាស៊ីនតោន)
ខ្ញុំត្រូវការឡានមួយដើម្បីជូនប្រពន្ធខ្ញុំទៅធ្វើការនៅឯណា?

ង. (ធ្វើការ)
ខ្ញុំត្រូវការឡានមួយដើម្បីជូនប្រពន្ធខ្ញុំទៅធ្វើអីនៅវ៉ាស៊ីនតោន?

ច. (ដើម្បីជូនប្រពន្ធខ្ញុំទៅធ្វើការនៅវ៉ាស៊ីនតោន)
ហេតុអីបានជាខ្ញុំត្រូវការឡានមួយ?

## Reading Passage

### ក្មេងឈ្នួល

ធម្មតាអ្នកនៅក្រុងខុសគ្នាពីអ្នកស្រែចំការ។ អ្នកស្រែចំការធ្វើការអ្វីទាំងអស់ខ្លួនគេ ទោះជាអ្នកស្រែចំការនេះជាអ្នកមានក៏ដោយ។ ចំពោះអ្នកទីក្រុង គេច្រើនជាអ្នកធ្វើការរដ្ឋការ ហើយប្រពន្ធគេច្រើនជាអ្នកធ្លាប់សប្បាយឬជាអ្នកធ្លាប់តែស្រួល គេមិនសូវចង់ធ្វើការអ្វីទេ។ ដូច្នេះហើយបានជាសឹងតែគ្រប់ផ្ទះទាំងអស់នៅទីក្រុង គេមានអ្នកបំរើ មានក្មេង មានចាស់ មានប្រុស មានស្រី។ អ្នកបំរើទាំងនេះសុទ្ធតែមកពីស្រុកស្រែ

ចំការ ជាអ្នកមិនសូវចេះអក្សរប៉ុន្មានទេ។

របៀបគេជួលអ្នកបំរើមានច្រើនយ៉ាង ហើយគេឲ្យឈ្នួលតាមអាយុនឹងតាមភេទរបស់អ្នកបំរើ តែជួនកាលគេឲ្យឈ្នួលតាមមុខងាររបស់អ្នកបំរើដែរ។

ក្មេងឈ្នួលដែលមានអាយុតិចៗ ច្រើនតែមកបំរើគេពីព្រោះឪពុកម្ដាយខ្លួនត្រូវការលុយដើម្បីធ្វើស្រែចំការ ឬដើម្បីធ្វើការផ្សេងៗទៀត ឬជួនកាលឪពុកម្ដាយខ្លួនមិនអាចចិញ្ចឹមកូនព្រោះគេមានកូនច្រើនពេក។ បើគេយកកូនគេមកឲ្យស៊ីឈ្នួលនៅទីក្រុង គេមិនគ្រាន់តែបានលុយទេ គេមិនចាំបាច់ចិញ្ចឹមកូនគេទៀត។

ចំពោះអ្នកបំរើចាស់ៗឯទៀត គេមកស៊ីឈ្នួលនៅទីក្រុងព្រោះគេមិនចូលចិត្តធ្វើការនៅក្នុងស្រែចំការដែលជាការពិបាកជាងធ្វើការនៅក្នុងផ្ទះ។ អ្នកបំរើទាំងនេះមានផ្ទះនៅស្រាប់ មានបាយស៊ីស្រាប់ ហើយជួនកាលគេមានខោអាវស្លៀកពាក់ស្រាប់ទៀតផងព្រោះម្ចាស់ផ្ទះគេឲ្យ។ គេមិនគ្រាន់តែបានផ្ទះនៅ បានបាយស៊ី បានខោអាវស្លៀកពាក់ទេ គេបានលុយទៀត។ លុយនេះគេផ្ញើទៅឲ្យគ្រួសារ ប្ដីប្រពន្ធកូនគេ។

អ្នកបំរើទាំងនេះមកស៊ីឈ្នួលប្រហែលមួយឆ្នាំឬពីរ គេត្រឡប់ទៅផ្ទះគេវិញដើម្បីធ្វើស្រែចំការបន្តិចបន្តួច ហើយកាលណាគេអស់លុយ គេត្រឡប់មកស៊ីឈ្នួលទៀត។

VOCABULARY

| | | |
|---|---|---|
| ក្រ | krɔɔ + adj. (or verb) | seldom, slow to |
| ក្មេងឈ្នួល | kmeeŋ chnuol | servant, maid, houseboy |
| ខ្មៅដៃ | khmaw day | pencil |
| ចិញ្ចឹម | cəñcəm | to raise, to nourish, to bring up (R) |
| ចោរ | cao | thief, crook, criminal |
| ចំនួន | cənuon | quantity, number |
| ចំណេះ | cənɛh | education, knowledge |
| ចំពោះ | cəpuoh | as for, for, about, toward |
| ...ចុះណាស់ | ...coh nah | a lot (with the sense of waste) |
| ឆាប់ | chap + verb | quick to + verb |
| ឆ្លៀត | chliet | to take an opportunity, to take the time to... |
| ឈ្នួល | chnuol | servant, maid; something or someone hired or rented; wage, fee, rent (R) |
| បន្លំ | pəlɔm | to cheat, fool |
| ប៉ុន្តែ | pəntaɛ | but |
| ប្រដាប់ | pədap | equipment, tool |
| ប្រដាប់ភ្លេង | pədap phleeŋ | musical instrument |
| ប្រទះ | pətéh | to meet |
| ពីម្ងៃនោះ | pii məŋay noh | the other day |
| ពោង | pouŋ | buoy |
| ភេទ | pheet | sex, gender (R) |
| ម្ចាស់ | məcah | master, owner, boss |

| | | |
|---|---|---|
| យូរមកហើយ | yuu móo həh | a long time ago, a long time now |
| រហែក | ləhaɛk | torn, to tear |
| សត្វ | sat | animal |
| ស្លាបប៉ាកា | slaappəkaa | pen |
| ស៊ីឈ្នួល | sii chnuol | to go into domestic service, to take a job, usually a menial one (R) |
| ស្មៅ | smaw | grass (L) |
| ...ស្រាប់ | ...srap | ready, already, ready-made |
| ហែលទឹក | haɛl tɨk | to swim |
| អ្នកបកប្រែ | né? bɔɔ? praɛ | interpreter |
| អ្នកបំរើ | né? pəmraə | servant, maid, houseboy |
| អ្វី | əvɛy | what (reading pronunciation) |



Streetcleaner, Phnom Penh

## LESSON FORTY-TWO

### DIALOGUE

| | | | |
|---|---|---|---|
| | | បុក | to collide |
| ១. | កុម | ពីមួយថ្ងៃនោះខ្ញុំបើកឡានបុកឡានគេមួយ។ | The other day, I had a collision with another car. |
| ២. | សុខ | អ្នកណាខុស? អ្នកណាត្រូវ? អ្នកណាបុកអ្នកណា? | Who was wrong? Who was right? Who hit whom? |
| | | អាលប័រភែក | busy with, occupied with |
| ៣. | កុម | ខ្ញុំខុស ខ្ញុំបុកឡាននោះព្រោះខ្ញុំអាលប័រភែកមើលមនុស្សដើរ។ | I was in the wrong. I hit the other car because I was busy looking at people walking. |
| | | ជាន់ | to step on |
| ៤. | សុខ | រួចម៉េចមិនជាន់ហ្វ្រាំង? ជាន់មិនទាន់ឬ? | Then why didn't you step on the brake? Couldn't you step on it in time? |
| | | ប្រឹង | to try; to strive |
| | | សំណាង | luck |
| | | យឺតៗ | slowly |
| ៥. | កុម | ខ្ញុំប្រឹងជាន់ដែរ តែវាមិនទាន់។ សំណាងល្អខ្ញុំបើកឡានយឺតៗ។ | I tried to step on it, but it was too late. Luckily I was driving slowly. |
| | | ពិនិត្យ | to look, to inspect |
| ៦. | សុខ | មានប៉ូលីសមកពិនិត្យគ្រោះថ្នាក់ទេ? | Were there any policemen who came to see the accident? |
| | | ក្រ | to take time doing something |
| | | ម្ចាស់ឡាន | owner, master |
| ៧. | កុម | ខ្ញុំហៅប៉ូលីសដែរ តែគេក្រមកដល់ពេក ខ្ញុំក៏ឲ្យលុយទៅម្ចាស់ឡាននោះទៅ។ | I called them, but they hadn't made it there yet, so I gave some money to the owner of the other car. |
| | | សុខចិត្ត | to agree, to be satisfied, to be willing |
| ៨. | សុខ | គេសុខចិត្តយកលុយនោះទេ? | Did he agree to take the money? |
| | | មុនដំបូង | at first, originally |
| | | ធ្វើជា | to pretend |
| ៩. | កុម | បាទ មុនដំបូងគេធ្វើជាមិនព្រម តែក្រោយមកគេក៏សុខចិត្តយកលុយ។ | Yes. At first he pretended not to be willing, but later on he agreed to take the money. |

DIALOGUE:

1. tom - pii məŋay noh khñom baək laan bok laan kee muoy.

2. sok - néʔnaa khoh? néʔnaa trəw? néʔnaa bok néʔnaa?

3. tom - khñom khoh, khñom bok laan nuh prúh khñom aalay tə məəl mənuh daə.

4. sok - ruoc mɛc mɨn cón fraŋ? cón mɨn tón rəh?

5. tom - khñom prəŋ cón daɛ, taɛ via mɨn tón. sənaaŋ lʔɔɔ khñom baək laan yɨɨt yɨɨt.

6. sok - mian pəlih móo pənɨt krúh thnaʔ eh?

7. tom - khñom haw pəlih daɛ, taɛ kee krɔɔ móo dɔl peek, khñom kɔɔ aoy luy tɨw məcah laan nuh təh.

8. sok - kee sok cət yóo luy nuh eh?

9. tom - baat mun təbouŋ kee thəə cia mɨn próom, taɛ kraoy móo kee kɔɔ sok cət yóo luy.

NOTES

DIALOGUE

SENTENCE NO.

1. There are two ways in this lesson of referring to 'other car.' In sentence 1, ឡានគេ /laan kee/ is indefinite: 'someone else's car.' គេ /kee/ is often used this way; for instance

   វាជំពាក់គេ។

   via cəpéʔ kee

   He's in debt.

   means more literally 'He owes to other (indefinite) people.'

   On the other hand, in sentence 7, ឡានគេនោះ /laan nuh/ means 'the other car;' it is definite, referring to a car the existence of which has already been established. Here នោះ /nuh/ means 'the one which is not mine, the other one.'

3. អាល័យនឹង /aalay tə/ is a preverbal adverb meaning 'busy with, busy at, occupied with.'

5. The words ប្រឹង /prəŋ/ and ខំ /khɔm/ are synonymous; both mean 'to try, to make an effort.'

5. The word ហួស /huoh/ means 'to pass, to exceed.' In the expression ហួស (ទេះ) ហើយ /huoh (təh) həh/ 'it's too late' it conveys the meaning that the opportunity for an action has passed by already.

   Note that in Drill 2 ហួស /huoh/ is attributive to the main verb (បើក/baək/ 'to drive' in the model): literally the model sentence is 'I drive the car

and pass the school.' In this sentence ហួស /huoh/ is translated 'beyond.' In Drill 3, however, ហួសទៅ /huoh tɨw/ means that you extend what you are doing or go a little further than some previously indicated point (the underlying object of ហួស /huoh/) to reach another point (the object of ទៅ /tɨw/). For instance, the model sentence of Drill 3 might represent a deletion transform of ខ្ញុំបើកឡានហួស (ផ្ទះលោក) ទៅសាលារៀន។

khñom baək laan huoh (phtéh look) tɨw saalaa rien.

I drove the car beyond (your house) to the school.

The deleted material is parenthesized.

Note that 'to pass (a car)' (when driving) is not ហួស /huoh/ but វ៉ា /vaa/ (borrowed from French va (aller)), e.g.,

ខ្ញុំមានគ្រោះថ្នាក់ព្រោះខ្ញុំវ៉ាឡានគេមិនទាន់។

khñom mian krúh thnaˀ prúh khñom vaa laan kee mɨn tón

I had an accident because I didn't pass the other car in time.

DRILLS

DRILL ONE: Response

MODEL: T: ហេតុអីបានជាលោកបុកឡាននោះ? (មើលមនុស្សដើរ)

S: ខ្ញុំបុកឡាននោះព្រោះខ្ញុំអាលប័រតែមើលមនុស្សដើរ។

T: Why did you collide with that car? (looking at people walking)

S: I collided with that car because I was looking at people walking.

ក. ហេតុអីបានជាលោកមិនមកលេងខ្ញុំ? (រៀនមេរៀន)
ខ្ញុំមិនមកលេងលោកព្រោះខ្ញុំអាលប័រតែរៀនមេរៀន។

ខ. ហេតុអីបានជាលោកមិនចេះមេរៀន? (ដើរលេង)
ខ្ញុំមិនចេះមេរៀនព្រោះខ្ញុំអាលប័រតែដើរលេង។

គ. ហេតុអីបានជាលោកភ្លេចសៀវភៅលោក? (រកកូនសោឡាន)
ខ្ញុំភ្លេចសៀវភៅព្រោះខ្ញុំអាលប័រតែរកកូនសោឡាន។

ឃ. ហេតុអីបានជាលោកមករៀនមិនទាន់ម៉ោង? (មើលហាងលក់ឥវ៉ាន់)
ខ្ញុំមករៀនមិនទាន់ម៉ោងព្រោះខ្ញុំអាលប័រតែមើលហាងលក់ឥវ៉ាន់។

ង. ហេតុអីបានជាលោកមិនទៅមើលកុននោះ? (ជួបពួកម៉ាកស្រី)
ខ្ញុំមិនទៅមើលកុននោះព្រោះខ្ញុំអាលប័រតែជួបពួកម៉ាកស្រី។

ច. ហេតុអីបានជាលោកមិនទិញសំបុត្រឡាន? (ទៅបើកលុយ)
ខ្ញុំមិនទិញសំបុត្រឡានព្រោះខ្ញុំអាលប័រតែទៅបើកលុយ។

DRILL TWO: Transformation

MODEL: T: ខ្ញុំបើកឡានទៅសាលារៀន។
S: ខ្ញុំបើកឡានហួសសាលារៀន។
T: I drove to school.
S: I drove beyond the school.

ក ខ្ញុំជិះកប៉ាល់ហោះទៅញូវយ៉ក។ ខ្ញុំជិះកប៉ាល់ហោះហួសញូវយ៉ក។
ខ. ខ្ញុំជិះឡានឈ្នួលទៅទីក្រុងភ្នំពេញ។ ខ្ញុំជិះឡានឈ្នួលហួសទីក្រុងភ្នំពេញ។
គ ខ្ញុំដើរទៅគុ៏លោកយ៉ាន។ ខ្ញុំដើរហួសគុ៏លោកយ៉ាន។
ឃ. ខ្ញុំជិះកង់ទៅប៉ុស្តិ៍។ ខ្ញុំជិះកង់ហួសប៉ុស្តិ៍។
ង. ខ្ញុំបើកឡានទៅផ្ទះខ្ញុំ។ ខ្ញុំបើកឡានហួសផ្ទះខ្ញុំ។
ច. ខ្ញុំរត់ទៅបន្ទប់ទឹក។ ខ្ញុំរត់ហួសបន្ទប់ទឹក។

DRILL THREE: Transformation

MODEL: T: ខ្ញុំបើកឡានទៅសាលារៀន។
S: ខ្ញុំបើកឡានហួសទៅសាលារៀន។
T: I drive to school.
S: I drive over to school.

ក. ខ្ញុំជិះកប៉ាល់ហោះទៅញូវយ៉ក។ ខ្ញុំជិះកប៉ាល់ហោះហួសទៅញូវយ៉ក។
ខ. ខ្ញុំជិះឡានឈ្នួលទៅទីក្រុងភ្នំពេញ។ ខ្ញុំជិះឡានឈ្នួលហួសទៅទីក្រុងភ្នំពេញ។
គ. ខ្ញុំដើរទៅគុ៏លោកថៃសុខ។ ខ្ញុំដើរហួសទៅគុ៏លោកថៃសុខ។
ឃ. ខ្ញុំជិះកង់ទៅប៉ុស្តិ៍។ ខ្ញុំជិះកង់ហួសទៅប៉ុស្តិ៍។
ង. ខ្ញុំរត់ទៅបន្ទប់ទឹក។ ខ្ញុំរត់ហួសទៅបន្ទប់ទឹក។
ច. ខ្ញុំបើកឡានទៅផ្ទះខ្ញុំ។ ខ្ញុំបើកឡានហួសទៅផ្ទះខ្ញុំ។

DRILL FOUR: Response

MODEL: T: លោកហៅប៉ូលិសទេ? (មកដល់)
S: ខ្ញុំហៅប៉ូលិសដែរ តែប៉ូលិសក្រមកដល់ពេក។
T: Did you call the police? (arrive)
S: I did, but the police took too much time to get there.

ក. លោកអញ្ជើញគាត់ទេ? (ឆ្លើយសំបុត្រខ្ញុំ)
ខ្ញុំអញ្ជើញគាត់ដែរ តែគាត់ក្រឆ្លើយសំបុត្រខ្ញុំពេក។
ខ. លោកចង់ទៅជាមួយគាត់ទេ? (ទៅ)
ខ្ញុំចង់ទៅជាមួយគាត់ដែរ តែគាត់ក្រទៅពេក។
គ. លោកចង់ឲ្យគាត់ធ្វើឡានលោកទេ? (មកធ្វើ)
ខ្ញុំចង់ឲ្យគាត់ធ្វើឡានខ្ញុំដែរ តែគាត់ក្រមកធ្វើពេក។
ឃ. លោកចង់បង្រៀនគាត់ទេ? (ឲ្យតំណែងខ្ញុំ)
ខ្ញុំចង់បង្រៀនគាត់ដែរ តែគាត់ក្រឲ្យតំណែងខ្ញុំពេក។

ង. លោកចង់មកលេងខ្ញុំទេ? (ប្រាប់ខ្ញុំ)
ខ្ញុំចង់មកលេងលោកដែរ តែលោកត្រូវប្រាប់ខ្ញុំពាក។
ច. លោកចាំគាត់ទេ? (មកដល់)
ខ្ញុំចាំគាត់ដែរ តែគាត់ត្រូវមកដល់ពាក។

DRILL FIVE: Response

MODEL: T: គេយកលុយនោះទេ?
S: គេមិនសុខចិត្តយកលុយនោះទេ។
T: Did they take the money?
S: They didn't agree to take the money.

ក. លោកធ្វើការឲ្យគាត់ទេ? ខ្ញុំមិនសុខចិត្តធ្វើការឲ្យគាត់ទេ។
ខ. កូនលោកប្រាប់លោកទេ? កូនខ្ញុំមិនសុខចិត្តប្រាប់ខ្ញុំទេ។
គ. កូនលោកទៅរៀនទេ? កូនខ្ញុំមិនសុខចិត្តទៅរៀនទេ។
ឃ. លោកយ៉ាន់ទិញឡានលោកទេ? លោកយ៉ាន់មិនសុខចិត្តទិញឡានខ្ញុំទេ។
ង. វាឆ្លើយសំនួរលោកទេ? វាមិនសុខចិត្តឆ្លើយសំនួរខ្ញុំទេ។
ច. លោកចង់បង្រៀនល្ងាចទេ? ខ្ញុំមិនសុខចិត្តបង្រៀនល្ងាចទេ។

DRILL SIX: Substitution

MODEL: T: បើប៉ូលិសសួរលោក លោកធ្វើជាមិនយល់អង់គ្លេស។ (មិនដឹង)
S: បើប៉ូលិសសួរលោក លោកធ្វើជាមិនដឹង។
T: If the police ask you, pretend that you don't understand English.
S: If the police ask you, pretend that you don't know.

ក. បើប៉ូលិសសួរលោក លោកធ្វើជាមិនដឹង។ (ឃើញ)
ខ. បើប៉ូលិសឃើញលោក លោកធ្វើជាមិនដឹង។ (មិនឃើញ)
គ. បើប៉ូលិសឃើញលោក លោកធ្វើជាមិនឃើញ។ (សត្រូវ)
ឃ បើសត្រូវឃើញលោក លោកធ្វើជាមិនឃើញ។ (ស្លាប់)
ង. បើសត្រូវឃើញលោក លោកធ្វើជាស្លាប់។ (បាញ់)
ច. បើសត្រូវបាញ់លោក លោកធ្វើជាស្លាប់។

DRILL SEVEN: Substitution

MODEL: T: កាលណាលោកមានគ្រោះថ្នាក់ឡាន លោកត្រូវបង្ហាញកាតទៅប៉ូលិស។
(ប័រមីបើកឡាន)
S. កាលណាលោកមានគ្រោះថ្នាក់ឡាន លោកត្រូវបង្ហាញប័រមីបើកឡានទៅប៉ូលិស។

T: When you have a car accident, you must show the police your identification card. (driver's license)

S: When you have a car accident, you must show the police your driver's license.

ក. កាលណាលោកមានគ្រោះថ្នាក់ឡាន    លោកត្រូវបង្ហាញប័ណ្ណបើកឡានទៅប៉ូលិស។
(សំបុត្រអាសូរ៉ង់)

ខ. កាលណាលោកមានគ្រោះថ្នាក់ឡាន    លោកត្រូវបង្ហាញសំបុត្រអាសូរ៉ង់ទៅប៉ូលិស។
(សំបុត្រម្ចាស់ឡាន)

គ. កាលណាលោកមានគ្រោះថ្នាក់ឡាន    លោកត្រូវបង្ហាញសំបុត្រម្ចាស់ឡានទៅប៉ូលិស។
(ប៉ូលិសចាប់លោក)

ឃ. កាលណាប៉ូលិសចាប់លោក    លោកត្រូវបង្ហាញសំបុត្រអាសូរ៉ង់ទៅប៉ូលិស។
(សំបុត្រឆ្លងដែន)

ង. កាលណាប៉ូលិសចាប់លោក    លោកត្រូវបង្ហាញសំបុត្រឆ្លងដែនទៅប៉ូលិស។
(លោកធ្វើដំណើរទៅបរទេស)

ច. កាលណាលោកធ្វើដំណើរទៅបរទេស    លោកត្រូវបង្ហាញសំបុត្រឆ្លងដែនទៅប៉ូលិស។

DRILL EIGHT: Transformation

MODEL: T: ពីមួយថ្ងៃនោះខ្ញុំបើកឡានបុកឡានគេមួយ។ (ពីមួយថ្ងៃនោះ)
S: ខ្ញុំបើកឡានបុកឡានគេមួយពីអង្កាល់?
T: The other day I collided with another car. (the other day)
S: When did I collide with another car?

ក. ពីមួយថ្ងៃនោះខ្ញុំបើកឡានបុកឡានគេមួយ។ (ខ្ញុំ)
ពីមួយថ្ងៃនោះអ្នកណាបើកឡានបុកឡានគេមួយ?

ខ. ខ្ញុំបុកឡាននោះព្រោះខ្ញុំមិនឈប់នៅភ្លើងក្រហម។ (ព្រោះខ្ញុំមិនឈប់នៅភ្លើងក្រហម)
ហេតុអ្វីបានជាខ្ញុំបុកឡាននោះ?

គ. តែប៉ូលិសក្រមកពេក ខ្ញុំក៏ឲ្យលុយទៅម្ចាស់ឡាននោះទៅ។ (ឲ្យលុយទៅម្ចាស់ឡាននោះ)
តែប៉ូលិសក្រមកពេក ខ្ញុំក៏ធ្វើម៉េចទៅ?

ឃ. លោកមានគ្រោះថ្នាក់ ព្រោះលោកបើកឡានលឿនពេក។ (លឿនពេក)
លោកមានគ្រោះថ្នាក់ព្រោះលោកបើកឡានយ៉ាងម៉េច?

ង. លោកត្រូវធ្វើការរាយការណ៍អំពីគ្រោះថ្នាក់លោកក្នុងប្រាំថ្ងៃ។ (ប្រាំ)
លោកត្រូវធ្វើការរាយការណ៍អំពីគ្រោះថ្នាក់លោកក្នុងប៉ុន្មានថ្ងៃ?

ច. តែក្រោយមកគេក៏សុខចិត្តយកលុយ។ (លុយ)
តែក្រោយមកគេក៏សុខចិត្តយកអី?

DRILL NINE: Transformation

MODEL: T: ខ្ញុំមានគ្រោះថ្នាក់ឡានមួយ។
S: ខ្ញុំមិនដែលមានគ្រោះថ្នាក់ឡានទេ។
T: I had a car accident.
S: I never have any car accidents.

ក. ប៉ូលីសដាក់ខ្ញុំមួយដង។ ប៉ូលីសមិនដែលដាក់ខ្ញុំទេ។
ខ. ខ្ញុំបើកឡានបុកគេមួយដង។ ខ្ញុំមិនដែលបើកឡានបុកគេទេ។
គ. ខ្ញុំភ្លេចយកប៉ែរមីបើកឡាន។ ខ្ញុំមិនដែលភ្លេចយកប៉ែរមីបើកឡានទេ។
ឃ. ប៉ូលីសបញ្ឈប់ឡានខ្ញុំ។ ប៉ូលីសមិនដែលបញ្ឈប់ឡានខ្ញុំទេ។
ង. ខ្ញុំប្រើស៊ីហ្វ្លេឡានយូរៗម្តង។ ខ្ញុំមិនដែលប្រើស៊ីហ្វ្លេឡានទេ។
ច. ខ្ញុំបើកឡានបញ្ច្រាសផ្លូវ។ ខ្ញុំមិនដែលបើកឡានបញ្ច្រាសផ្លូវទេ។

DRILL TEN: Transformation

MODEL: T: ខ្ញុំមិនដែលមានគ្រោះថ្នាក់ឡានទេ។
S: លោកដែលមានគ្រោះថ្នាក់ឡានទេ?
T: I have never had a car accident.
S: Have you ever had a car accident?

ក. ប៉ូលីសមិនដែលដាក់ខ្ញុំទេ។ ប៉ូលីសដែលដាក់លោកទេ?
ខ. ខ្ញុំមិនដែលបើកឡានបុកគេទេ។ លោកដែលបើកឡានបុកគេទេ?
គ. ខ្ញុំមិនដែលភ្លេចយកប៉ែរមីបើកឡានទេ។ លោកដែលភ្លេចយកប៉ែរមីបើកឡានទេ?
ឃ. ប៉ូលីសមិនដែលបញ្ឈប់ឡានខ្ញុំទេ។ ប៉ូលីសដែលបញ្ឈប់ឡានលោកទេ?
ង. ខ្ញុំមិនដែលបើកឡានបញ្ច្រាសផ្លូវទេ។ លោកដែលបើកឡានបញ្ច្រាសផ្លូវទេ?
ច. ខ្ញុំមិនដែលប្រើស៊ីហ្វ្លេឡានទេ។ លោកដែលប្រើស៊ីហ្វ្លេឡានទេ?

DRILL ELEVEN: Substitution

MODEL: T: ម្សិលមិញ ខ្ញុំបើកឡានបុកកង់មួយ។ (រទេះគោ)
S: ម្សិលមិញ ខ្ញុំបើកឡានបុករទេះគោមួយ។
T: Yesterday while I was driving I hit a bicycle. (an ox cart)
S: Yesterday while I was driving I hit an ox cart.

ក. ម្សិលមិញ ខ្ញុំបើកឡានបុករទេះគោមួយ។ (ស៊ីក្លូ)
ខ. ម្សិលមិញ ខ្ញុំបើកឡានបុកស៊ីក្លូមួយ។ (រ៉ឺម៉ក)
គ. ម្សិលមិញ ខ្ញុំបើកឡានបុករ៉ឺម៉កមួយ។ (ឡានឈ្នួល)
ឃ. ម្សិលមិញ ខ្ញុំបើកឡានបុកឡានឈ្នួលមួយ។ (ម៉ូតូ)
ង. ម្សិលមិញ ខ្ញុំបើកឡានបុកម៉ូតូមួយ។ (ឡានកាមីញ៉ុង)
ច. ម្សិលមិញ ខ្ញុំបើកឡានបុកឡានកាមីញ៉ុងមួយ។

## Reading Passage

### ខ្ញុំឈឺ

តាំងពីពេលខ្ញុំចេញពីឡានទៅដល់ពេលខ្ញុំចូលក្នុងឡានប៉ូលីស ប្រហែលជាម៉ោង ខ្ញុំមិនដឹងជារងារទេ ពិតតែមិនតែមានទឹកកកច្រើនយ៉ាងណាក៏ដោយ។ ក្រោយពេលខ្ញុំបាន

មកដល់ផ្ទះវិញបានបន្តិច ខ្ញុំងូតទឹក រួចស្លៀកពាក់ដើម្បីទៅធ្វើការ។ ដល់ខ្ញុំដើរចេញពីផ្ទះ ខ្ញុំដូចជាស្រៀវស្រាញហើយផ្ដាសាយបន្តិចៗ។ ខ្ញុំដឹងខ្លួនខ្ញុំយ៉ាងនោះ ខ្ញុំក៏សម្រេចចិត្តមិនទៅធ្វើការថ្ងៃនោះ។ ខ្ញុំហៅកន្លែងធ្វើការប្រាប់ថាខ្ញុំមិនបានទៅធ្វើការហើយ ខ្ញុំក៏ទៅសម្រាកនៅលើគ្រែខ្ញុំទៅ។

ប្រហែលពីរបីម៉ោងក្រោយមក ខ្ញុំក្រោកពីគ្រែ កខ្ញុំដូចជាឈឺបន្តិចៗ។ ព្រោះខ្ញុំគិតពីរឿងគ្រោះថ្នាក់ឡាននោះខ្លាំងពេក ខ្ញុំមិនរវល់ពីរឿងឈឺនោះទេ ខ្ញុំក៏តេឡេហ្វូនទៅអាស៊ឺរ៉ង់ខ្ញុំ។ ខ្ញុំប្រាប់គេអំពីរឿងទាំងអស់ ហើយគេសួរខ្ញុំ "មានត្រូវអីទេ? ចុះប្រពន្ធលោកត្រូវអីទេ?" ។ "មិនអីទេ តែខ្ញុំឈឺកបន្តិចៗ" ខ្ញុំប្រាប់ទៅវិញ។ "ត្រូវតែទៅឲ្យពេទ្យមើលឲ្យឆាប់ ឈឺកនេះអាចទៅជាខ្លាំងបាន ត្រូវប្រយ័ត្នលោក" អាស៊ឺរ៉ង់ប្រាប់ខ្ញុំ។

មួយថ្ងៃក្រោយមក ខ្ញុំងាកក្បាលមិនរួច។ ខ្ញុំដូចជាភ័យបន្តិច។ តាមពិតមិនគ្រាន់តែឈឺកនោះទេ ខ្ញុំផ្ដាសាយហើយក្អកថែមទៀតផង។ ដូច្នេះអាទិត្យមុនដំបូង ខ្ញុំទៅពេទ្យពីរដង តែអាទិត្យក្រោយៗខ្ញុំទៅតែម្ដងទេ។ ខ្ញុំទៅពេទ្យអស់ជាងមួយខែ។ នៅអាទិត្យទីពីរ ខ្ញុំបាត់ផ្ដាសាយ ហើយកខ្ញុំបានគ្រាន់បើបន្តិចហើយ ដល់អាទិត្យក្រោយបង្អស់ក៏បាត់ឈឺទៅ។

VOCABULARY

| | | |
|---|---|---|
| កាមីយ៉ុង | kamməyoŋ | truck |
| ការរាយការណ៍ | kaa riey kaa | a report |
| កូនសោ | koun sao | key |
| ក្រពិត | kəpɨt | a dent (L) |
| ក្រោក | kraok | to arise, to get up (R) |
| ឆ្ងល់ | chŋɔl | to wonder (L) |
| ជាន់ | cɔ́n | to step on |
| តេឡេហ្វូន | teeləfoun | telephone· to telephone (L) |
| ត្រូវ | trəw | to be injured (R) |
| ទ្វា | tvia | door (L) |
| ធ្វើជា | thee cia | to pretend |
| បរទេស | booreteeh | foreign |
| បាត់ | bat | to lose (R) |
| បុក | bok | to collide, to pound |
| ប៉ែរមីបើកឡាន | pɛɛmii baɛk laan | driver's license |
| បង្ហាញ | pəhaañ | to show |
| បង្អែក | pəˀaɛk | a support, chair back (L) |
| បញ្ឈប់ | pechup | to stop (someone or something) |
| បញ្ច្រាសផ្លូវ | pəcrah phləw | to go the wrong way (on a street) |
| ប្រឹង | prəŋ | to strive |

| | | |
|---|---|---|
| ផាក | phaaʔ | to fine |
| ភ័យ | phey | to be afraid, to be frightened (R) |
| មុនដំបូង | mun dəbouŋ | at first, originally |
| ម្ចាស់ឡាន | məcah laan | car owner |
| យឺតៗ | yɨɨt yɨɨt | slowly |
| រទេះគោ | ətéh koo | oxcart |
| រាយការណ៍ | riay kaa | to report |
| ឡឺម៉ក | ləmɔɔʔ | small trailer |
| វាហួសទៅហើយ | via huoh təh həh | it's too late |
| ស៊ីផ្លេឡាន | səflee laan | horn (car) |
| សុខចិត្ត | sok cət | to agree, to be willing, to be satisfied |
| សំណាង | sənaaŋ | luck |
| សំបុត្រឆ្លងដែន | səbot chlɔɔŋ daɛn | passport |
| សំបុត្រម្ចាស់ឡាន | səbot məcah laan | car owner certificate |
| សំបុត្រអាស៊ូរ៉ង់ | səbot aasəraŋ | insurance certificate |
| សំបុត្រឡាន | səbot laan | car registration |
| សត្រូវ | sətrəw | enemy |
| ស្រែក | sraɛk | to shout (L) |
| ហួស | huoh | to pass, to exceed |
| អាល័យតែ | aalay tə | busy with |
| អូស | ouh | to tow, to drag (L) |
| អំពី | ɔmpii | about, concerning; from |



## LESSON FORTY-THREE

### DIALOGUE

| | | | |
|---|---|---|---|
| | | ស្ព័រត៍ | sport |
| ១. | កុម | ស្រុកខ្មែរគេចូលចិត្តស្ព័រត៍ទេ? | In Cambodia, do they like sports? |
| | | ចាស់ៗ | older people |
| ២. | សុខ | ចាស់ៗមិនសូវចូលចិត្តប៉ុន្មានទេ។ | Older people really don't like them. |
| ៣. | កុម | ចុះក្មេងៗ? | And how about young people? |
| | | ទាត់ | to kick |
| | | បាល់ទាត់ | soccer |
| | | បាល់បោះ | basketball |
| | | ។ល។ | etc. |
| ៤. | សុខ | បាទ គេចូលចិត្តបាល់ទាត់ បាល់បោះ ។ល។ | They like soccer, basketball, etc. |
| | | កីឡា | sport |
| ៥. | កុម | កីឡាអីជាកីឡាជាតិ? | What is the national sport? |
| | | និយម | to be used to, to like to, to be accustomed to |
| ៦. | សុខ | បាល់ទាត់ដែលគេនិយមហៅហ្វូតបុល។ | Soccer, which they call football. |
| ៧. | កុម | ហ្វូតបុល? ដូចហ្វូតបុលអាមេរិកាំងទេ? | Football? Is it the same as American football? |
| | | ខុសគ្នា | different |
| | | អ្នកលេង | player |
| ៨. | សុខ | ខុសគ្នាឆ្ងាយណាស់ តែគេមានអ្នកលេងដប់មួយនាក់ដូចគ្នា។ | They are very different, but there are eleven players in both. |
| | | ប្រកួត (ប្រជែង) | to compete |
| ៩. | កុម | ប្រទេសខ្មែរមានដែលទៅប្រកួតប្រជែងនឹងប្រទេសឯទៀតទេ? | Has Cambodia been in competition with other countries? |
| | | ទ្វីប | continent |
| | | អាស៊ី | Asia |
| ១០. | សុខ | បាទ តែនៅតែទ្វីបអាស៊ីទេ។ | Yes, but only on the Asian continent. |

DIALOGUE:

1. tom - srok khmaɛ kee coul cət spóa eh?

2. sok - cah cah mɨn səw coul cət pəmaan eh

3. tom - coh kmeeŋ kmeeŋ?

4. sok - baat kee coul cət bal tót, bal bɔh, la?

5. tom - kɛylaa ɛy cia kɛylaa ciat?

6. sok - bal tót daɛl kee niyúm haw futbal

7. tom - futbal? douc futbal aameerɨkaŋ eh?

8. sok - khoh knia chŋaay nah, taɛ kee mian néʔ leeŋ dɔp muoy néʔ douc knia

9. tom - pəteeh khmaɛ mian daɛl tɨw pəkuot pəcɛɛŋ nɨŋ pəteh aɛtiet eh?

10. sok - baat, taɛ nɨw taɛ tviip aasii eh

NOTES

DIALOGUE

SENTENCE NO.

2., 3. Reduplicative compound nouns like ចាស់ៗ /cah cah/ 'older people' and ក្មេងៗ /kmeeŋ kmeeŋ/ 'young people, children' have plural referents. Other such compounds are ស្រីៗ /srɛy srɛy/ 'women' and ខ្មែរៗ /khmaɛ khmaɛ/ 'Cambodians.'

9. Note that នឹង /nɨŋ/ means 'with.' It is very frequently used in speech with this meaning.

9. ប្រទេស /pəteeh/ 'country' is a more formal version of ស្រុក /srok/ 'country.'

DRILLS

DRILL NO.

8. There are several ways to compare: to say two objects are equivalent, you can say ដូចគ្នា /douc knia/ or ស្មើគ្នា /smaə knia/, e.g.,

ប្អូនខ្ញុំនិងប្អូនវាធំស្មើគ្នា។ (see also Drill 9)

pʔoun khñom nɨŋ pʔoun via thom smaə knia

My younger brother and his are equally big.

or ប្អូនខ្ញុំធំស្មើគ្នានឹងប្អូនវា។

pʔoun khñom thom smaə knia nɨŋ pʔoun via

My younger brother is as big as his.

or ប្អូនខ្ញុំធំដូចគ្នានឹងប្អូនវា។

pʔoun khñom thom douc knia nɨŋ pʔoun via

My younger brother is as big as his.

etc.

Another way to say 'as...as...' is adjective + មិនចាញ់ /mɨn cañ/ + noun, as in

ប្អូនខ្ញុំធំមិនចាញ់ប្អូនវា។
p?oun khñom thom mɨn cañ p?oun via
My younger brother is as big as his.

Literally this is 'my younger brother is big, not losing out to his younger brother.'

The opposite of this, 'not as...as...' is adjective + ចាញ់ + noun (cf. Lesson 24 above and Drill 10 in this lesson) or adjective + ចាញ់ /cañ/ + noun, e.g.,

នៅស្រុកខ្ញុំត្រជាក់ចាញ់ស្រុកលោក។
nɨw srok khñom təcé? cañ srok look
It's not as cold in my country as it is in yours.

Two nouns can be contrasted by the word ចាញ់ /cañ/, e.g.,

ទាហានគេចាញ់ទាហានយើងឆ្ងាយណាស់។
təhian kee cañ təhian yəəŋ chŋaay nah
Their soldiers are far inferior to ours.

## DRILLS

DRILL ONE: Substitution

MODEL: T: ចាស់ៗមិនសូវចូលចិត្តស្ព័រប៉ុន្មានទេ។ (ក្មេងៗ)
S: ក្មេងៗមិនសូវចូលចិត្តស្ព័រប៉ុន្មានទេ។
T: The older generation doesn't really like sports very much. (younger generation)
S: The younger generation doesn't really like sports very much.

ក. ក្មេងៗមិនសូវចូលចិត្តស្ព័រប៉ុន្មានទេ។ (ក្រមុំៗ)
ខ. ក្រមុំៗមិនសូវចូលចិត្តស្ព័រប៉ុន្មានទេ។ (កំលោះៗ)
គ. កំលោះៗមិនសូវចូលចិត្តស្ព័រប៉ុន្មានទេ។ (ដើរលេង)
ឃ. កំលោះៗមិនសូវចូលចិត្តដើរលេងប៉ុន្មានទេ។ (ក្រមុំៗ)
ង. ក្រមុំៗមិនសូវចូលចិត្តដើរលេងប៉ុន្មានទេ។ (មើលស្ព័រ)
ច. ក្រមុំៗមិនសូវចូលចិត្តមើលស្ព័រប៉ុន្មានទេ។

DRILL TWO: Substitution

MODEL: T: បាល់ទាត់មានអ្នកលេងដប់មួយនាក់។ (បាល់បោះ)
S: បាល់បោះមានអ្នកលេងប្រាំនាក់។
T: Soccer has eleven players. (basketball)
S: Basketball has five players.

ក. បាល់បោះមានអ្នកលេងប្រាំនាក់។ (វ៉ូឡីបូល)
ខ. វ៉ូឡីបូលមានអ្នកលេងប្រាំមួយនាក់។ (រ៉ាកប៊ី)
គ. រ៉ាកប៊ីមានអ្នកលេងដប់មួយនាក់។ (ពីងប៉ុង)
ឃ. ពីងប៉ុងមានអ្នកលេងមួយបុពីរនាក់។ (តេននីស)
ង. តេននីសមានអ្នកលេងមួយបុពីរនាក់។ (ហ្វូតបុលអាមេរិកាំង)
ច. ហ្វូតបុលអាមេរិកាំងមានអ្នកលេងដប់មួយនាក់។

DRILL THREE: Transformation

MODEL:
T: គ្រួសារខ្ញុំទៅមើលបាល់ទាត់រាល់អាទិត្យ។
S: គ្រួសារខ្ញុំនិយមទៅមើលបាល់ទាត់រាល់អាទិត្យ។
T: My family goes to see soccer every week.
S: My family is accustomed to go see soccer every week.

ក. ចេញពីធ្វើការខ្ញុំបើកឡានដើរលេងរាល់ល្ងាច។
ចេញពីធ្វើការខ្ញុំនិយមបើកឡានដើរលេងរាល់ល្ងាច។
ខ. លោកសនទៅញ៉ាំបាយចិនរាល់ថ្ងៃ។
លោកសននិយមទៅញ៉ាំបាយចិនរាល់ថ្ងៃ។
គ. លោកម៉ៃល្អួចមើលសៀវភៅរាល់ពេលប្រឡង។
លោកម៉ៃនិយមលួចមើលសៀវភៅរាល់ពេលប្រឡង។
ឃ. ខ្ញុំទៅទាត់បាល់រាល់ថ្ងៃសៅរ៍។
ខ្ញុំនិយមទៅទាត់បាល់រាល់ថ្ងៃសៅរ៍។
ង. អាមេរិកាំងញ៉ាំកាហ្វេរាល់ព្រឹក។
អាមេរិកាំងនិយមញ៉ាំកាហ្វេរាល់ព្រឹក។
ច. ខ្ញុំភ្លេចកូនសោឡានរាល់ព្រឹក។
ខ្ញុំនិយមភ្លេចកូនសោឡានរាល់ព្រឹក។

DRILL FOUR: Response

MODEL:
T: ហ្វូតបុលខ្មែរនឹងហ្វូតបុលអាមេរិកាំងដូចគ្នាទេ?
S: ហ្វូតបុលខ្មែរនឹងហ្វូតបុលអាមេរិកាំងខុសគ្នា។
T: Are Cambodian football and American football alike?
S: Cambodian football and American football are different.

ក. សៀវភៅលឿងនឹងសៀវភៅខៀវដូចគ្នាទេ?
សៀវភៅលឿងនឹងសៀវភៅខៀវខុសគ្នា។
ខ. ឡានក្រហមនឹងឡានខៀវដូចគ្នាទេ?
ឡានក្រហមនឹងឡានខៀវខុសគ្នា។
គ. បាល់ពីរនេះដូចគ្នាទេ?
បាល់ពីរនេះខុសគ្នា។

ឃ. អាវលោកពីរនេះដូចគ្នាទេ?
អាវខ្ញុំពីរនេះខុសគ្នា។
ង. កាហ្វេទាំងអស់ដូចគ្នាទេ?
កាហ្វេទាំងអស់ខុសគ្នា។
ច. កូនលោកនិងកូនខ្ញុំដូចគ្នាទេ?
កូនលោកនិងកូនខ្ញុំខុសគ្នា។

DRILL FIVE: Transformation

NOTE: Do this drill twice, the first time the student should give the sentence with គ្នា /knia/; the second time give the sentence without គ្នា /knia/.

MODEL: T: ហ្វូតបុលខ្មែរនិងហ្វូតបុលអាមេរិកាំងខុសគ្នា។
S: ហ្វូតបុលខ្មែរខុស (គ្នា) ពីហ្វូតបុលអាមេរិកាំង។
T: Cambodian football and American football are different.
S: Cambodian football is different from American football.

ក. សៀវភៅលឿងនិងសៀវភៅខៀវខុសគ្នា។
សៀវភៅលឿងខុស (គ្នា) ពីសៀវភៅខៀវ។
ខ. ឡានក្រហមនិងឡានខ្មៅខុសគ្នា។
ឡានក្រហមខុស (គ្នា) ពីឡានខ្មៅ។
គ. កាហ្វេខ្ញុំញ៉ាំនិងកាហ្វេលោកញ៉ាំខុសគ្នា។
កាហ្វេខ្ញុំញ៉ាំខុស (គ្នា) ពីកាហ្វេលោកញ៉ាំ។
ឃ. កូនខ្ញុំនិងកូនលោកខុសគ្នា។
កូនខ្ញុំខុស (គ្នា) ពីកូនលោក។
ង. នាឡិកាខ្ញុំនិងនាឡិកាលោកខុសគ្នា។
នាឡិកាខ្ញុំខុស (គ្នា) ពីនាឡិកាលោក។
ច. ភាសាលោកនិងភាសាខ្ញុំខុសគ្នា។
ភាសាលោកខុស (គ្នា) ពីភាសាខ្ញុំ។

DRILL SIX: Transformation

MODEL: T: ឡានលោកល្អ។ (ខ្ញុំ)
S: ឡានខ្ញុំល្អជាងឆ្ងាយណាស់។
T: Your car is beautiful. (my)
S: My car is far more beautiful.

ក. ភាសាលោកស្រួលរៀន។ (ខ្ញុំ) ភាសាខ្ញុំស្រួលរៀនជាងឆ្ងាយណាស់។
ខ. ហ្វូតបុលខ្មែរស្រួលលេង។ (អាមេរិកាំង) ហ្វូតបុលអាមេរិកាំងស្រួលលេងជាងឆ្ងាយណាស់។

គ. ភាសាខ្មែរពិបាក។ (អង់គ្លេស) ភាសាអង់គ្លេសពិបាកជាងឆ្ងាយណាស់។
ឃ. ខ្ញុំមើលភាសាអង់គ្លេសលឿន។ (លោក) លោកមើលភាសាអង់គ្លេសលឿនជាងឆ្ងាយណាស់។
ង. ខ្ញុំបើកឡានប្រយ័ត្ន។ (នាង) នាងបើកឡានប្រយ័ត្នជាងឆ្ងាយណាស់។
ច. លោកអ៊ិមសរសេរអក្សរស្អាត។ (លោកសុមេត) លោកសុមេតសរសេរអក្សរស្អាតជាងឆ្ងាយណាស់។

DRILL SEVEN: Transformation

MODEL:
T: ហ្វុតបុលខ្មែរស្រួលលេងជាងហ្វុតបុលអាមេរិកាំង។
S: ហ្វុតបុលខ្មែរស្រួលលេងជាងហ្វុតបុលអាមេរិកាំងឆ្ងាយណាស់។
T: Cambodian football is easier to play than American football.
S: Cambodian football is far easier to play than American football.

ក. ឡានខ្ញុំល្អជាងឡានលោក។ ឡានខ្ញុំល្អជាងឡានលោកឆ្ងាយណាស់។
ខ. ភាសាខ្មែរស្រួលរៀនជាងភាសាអង់គ្លេស។ ភាសាខ្មែរស្រួលរៀនជាងភាសាអង់គ្លេសឆ្ងាយណាស់។
គ. ខ្ញុំមើលអក្សរលឿនជាងលោក។ ខ្ញុំមើលអក្សរលឿនជាងលោកឆ្ងាយណាស់។
ឃ. លោកស្មិសខ្ជិលជាងលោកអ៊ឹម។ លោកស្មិសខ្ជិលជាងលោកអ៊ឹមឆ្ងាយណាស់។
ង. កញ្ញាបើកឡានប្រយ័ត្នជាងខ្ញុំ។ កញ្ញាបើកឡានប្រយ័ត្នជាងខ្ញុំឆ្ងាយណាស់។
ច. អាមេរិកាំងចូលចិត្តស្ព័រត៍ជាងខ្មែរ។ អាមេរិកាំងចូលចិត្តស្ព័រត៍ជាងខ្មែរឆ្ងាយណាស់។

DRILL EIGHT: Response

MODEL:
T: ក្រុមបាល់ទាត់លោកល្អណាស់។ (ក្រុមបាល់ទាត់លោក)
S: បាទ ល្អមិនចាញ់ក្រុមបាល់ទាត់លោកទេ។
T: Your soccer team is very good. (your soccer team)
S: Yes, it's as good as your soccer team.

ក. ឡាននេះលឿនណាស់។ (ឡានលោក) បាទ លឿនមិនចាញ់ឡានលោកទេ។
ខ. ក្រុមបាល់បោះយើងពូកែណាស់។ (ក្រុមបាល់បោះចិន) បាទ ពូកែមិនចាញ់ក្រុមបាល់បោះចិនទេ។
គ. ឪពុកម្ដាយខ្ញុំមានណាស់។ (ឪពុកម្ដាយលោក) បាទ មានមិនចាញ់ឪពុកម្ដាយលោកទេ។
ឃ. កូនសិស្សខ្ញុំពូកែណាស់។ (កូនសិស្សលោក) បាទ ពូកែមិនចាញ់កូនសិស្សលោកទេ។
ង. កូនលោកឧស្សាហ៍រៀនណាស់។ (កូនខ្ញុំ) បាទ ឧស្សាហ៍មិនចាញ់កូនខ្ញុំទេ។
ច. ថ្នាក់យើងខ្ជិលណាស់។ (ថ្នាក់លោកសុខ) បាទ ខ្ជិលមិនចាញ់ថ្នាក់លោកសុខទេ។

DRILL NINE: Transformation

MODEL: T: ក្រុមបាល់ទាត់លោកល្អមិនចាញ់ក្រុមបាល់ទាត់ខ្ញុំទេ។

S: ក្រុមបាល់ទាត់យើងល្អស្មើគ្នា។

T: Your soccer team is as good as my soccer team.

S: Our soccer teams are equally good.

ក. ឡានលោកលឿនមិនចាញ់ឡានខ្ញុំទេ។ ឡានយើងលឿនស្មើគ្នា។
ខ. ក្រុមបាល់បោះលោកពូកែមិនចាញ់ក្រុមបាល់បោះខ្ញុំទេ។ ក្រុមបាល់បោះយើងពូកែស្មើគ្នា។
គ. ឪពុកម្ដាយលោកមានមិនចាញ់ឪពុកម្ដាយខ្ញុំទេ។ ឪពុកម្ដាយយើងមានស្មើគ្នា។
ឃ. កូនលោកឧស្សាហ៍រៀនមិនចាញ់កូនខ្ញុំទេ។ កូនយើងឧស្សាហ៍រៀនស្មើគ្នា។
ង. ថ្នាក់លោកខ្ពស់មិនចាញ់ថ្នាក់ខ្ញុំទេ។ ថ្នាក់យើងខ្ពស់ស្មើគ្នា។
ច. ភាសាលោកពិបាករៀនមិនចាញ់ភាសាខ្ញុំទេ។ ភាសាយើងពិបាករៀនស្មើគ្នា។

DRILL TEN: Transformation

MODEL: T: ក្រុមបាល់ទាត់យើងល្អស្មើគ្នា។

S: ក្រុមបាល់ទាត់លោកល្អមិនដល់ក្រុមបាល់ទាត់ខ្ញុំទេ។

T: Our soccer teams are equally good.

S: Your soccer team is not as good as my soccer team.

ក. ឡានយើងលឿនស្មើគ្នា។
ឡានលោកលឿនមិនដល់ឡានខ្ញុំទេ។
ខ. ក្រុមបាល់បោះយើងពូកែស្មើគ្នា។
ក្រុមបាល់បោះលោកពូកែមិនដល់ក្រុមបាល់បោះខ្ញុំទេ។
គ. ឪពុកយើងមានស្មើគ្នា។
ឪពុកលោកមានមិនដល់ឪពុកម្ដាយខ្ញុំទេ។
ឃ. កូនយើងឧស្សាហ៍រៀនស្មើគ្នា។
កូនលោកឧស្សាហ៍រៀនមិនដល់កូនខ្ញុំទេ។
ង. ថ្នាក់យើងខ្ពស់ស្មើគ្នា។
ថ្នាក់លោកខ្ពស់មិនដល់ថ្នាក់ខ្ញុំទេ។
ច. ភាសាយើងពិបាកស្មើគ្នា។
ភាសាលោកពិបាករៀនមិនដល់ភាសាខ្ញុំទេ។

## Reading Passage

### ប្រយោជន៍នៃកីឡា

ដែលហៅថាកីឡានោះ៖ គឺការធ្វើអ្វីទាំងអស់ដោយយកកម្លាំងសាច់ដុំ ដើម្បីនឹងជួយខ្លួនយើងឲ្យមានកម្លាំងខ្លាំងនិងឲ្យបានសុខសប្បាយទៅថ្ងៃក្រោយទៀត។ ការលេង

កីឡា មិនគ្រាន់តែជាការប្រកួតប្រជែងដើម្បីនឹងយកជ័យជំនះលើមនុស្សឯទៀតទេ គឺជាការប្រកួតប្រជែងសម្រាប់ខ្លួនយើង ដើម្បីនឹងយកជ័យជំនះលើសត្រូវដែលនៅក្នុងខ្លួនយើង។

ដែលហៅថាជ័យជំនះខាងកីឡាលើខ្លួនយើង គឺការសុខសប្បាយដែលសំខាន់ណាស់ក្នុងជីវិតមនុស្ស។ ការប្រើខួរក្បាលដើម្បីធ្វើការឯទៀតក្នុងមួយថ្ងៃយ៉ាងតិច៨ម៉ោង ធ្វើឲ្យមនុស្សឆាប់ចាស់អស់កម្លាំង។ កាលណាគេត្រឡប់មកដល់ផ្ទះ គេមិនសប្បាយចិត្ត ហើយមិនយូរប៉ុន្មានអស់កម្លាំង ។ ការមិនសប្បាយចិត្តនឹងធ្វើឲ្យគេឈឺ។

នេះជាសត្រូវរបស់យើង។ ដើម្បីនឹងឈ្នះលើសត្រូវនេះ យើងត្រូវការពេលប្រហែលតែមួយម៉ោង ឬតិចជាងផងក្នុងមួយថ្ងៃ ។ ការប្រើកម្លាំងសាច់ដុំតែមួយម៉ោងប៉ុណ្ណោះ អាចការពារខ្លួនយើងប្រឆាំងនឹងការប្រើកម្លាំងខួរក្បាល៨ម៉ោងក្នុងមួយថ្ងៃ ។ តាមពិតទៅ យើងមិនចាំបាច់ហាត់កីឡារាល់ថ្ងៃទេ គឺគ្រាន់តែពីរឬបីថ្ងៃក្នុងមួយអាទិត្យ វាគ្រប់គ្រាន់ណាស់ទៅហើយ ។ ដូច្នេះយើងអាចយល់យ៉ាងច្បាស់ថា តើការហាត់ កីឡាសម្រាប់ខ្លួនយើង មានប្រយោជន៍យ៉ាងណាដល់ខ្លួនយើង ។

## VOCABULARY

| | | |
|---|---|---|
| កំលោះៗ | kəlɔh kəlɔh | young male adult, bachelor |
| កីឡា | kɛylaa | sport |
| ក្មេងៗ | kmeeŋ kmeeŋ | youth, young generation |
| ក្រមុំៗ | kəmom kəmom | young female adult, young woman |
| ខុសគ្នា | khoh knia | different |
| ខួរក្បាល | khuo kbaal | brains (R) |
| ចាស់ៗ | cah cah | old generation |
| ជីវិត | cəvit | life (R) |
| ជ័យជំនះ | cɛy cənéh | victory (R) |
| ឈ្លោះគ្នា | chlúh knia | to quarrel (L) |
| តេននីស | təənih | tennis |
| ទាត់ | tót | to kick |
| ទ្វីប | tviip | continent |
| និយម | niyúm + verb | to be accustomed to, like to |
| បាល់ទាត់ | bal tót | soccer |
| បាល់ទះ | bal téh | volleyball (L) |
| បាល់បោះ | bal bɔh | basketball |
| ប្រកួត (ប្រជែង) | pəkuot (pəcɛɛŋ) | to compete |
| ប្រទេស | pəteeh | country |
| ប្រឡង | pəlɔɔŋ | take a test |
| ពីងប៉ុង | piiŋpoŋ | ping pong |
| ពូកែ | pəkaɛ | skillful, smart, effective |

| | | |
|---|---|---|
| មិនចាញ់ | min cañ | as...as, equally... |
| រាប់ | róp + number | (hundred)s, (thousand)s (L) |
| ។ល។ | la? | etc. |
| វិទ្យុ | vityu? | radio (L) |
| វិទ្យុទូរទស្សន៍ | vityu? tuorətuoh | television |
| សាច់ដុំ | sac dom | muscle (L) |
| ស្ព័រ | spóa | sport |
| ស្មើ | smaə | equal |
| ស្មើគ្នា | smaə knia | even, equal |
| ហាត់ | hat | to practise (R) |
| ហ្វុតបល | futbal | football |
| អាស៊ី | aasii | Asia |
| អ្នកលេង | né? leeŋ | player |



Classical ballet rehearsal at the royal palace in Phnom Penh

## LESSON FORTY-FOUR

### DIALOGUE

| | | | |
|---|---|---|---|
| | | សត្វ | animal |
| ១. | កុម | នៅស្រុកខ្មែរមានសត្វច្រើនណាស់ មើលទៅ? | In Cambodia, there are many animals, I think. |
| | | បាញ់សត្វ | to hunt |
| ២. | សុខ | បាទ ម៉េចលោកចង់ទៅបាញ់សត្វទេ? | Yes, why? Do you want to go hunting? |
| | | ប្រដាប់ប្រដា | equipment |
| ៣. | កុម | បាទចង់ដែរ តែខ្ញុំគ្មានប្រដាប់ប្រដា ទេ។ | Yes I do. But I don't have the equipment. |
| | | នឹង | with, by means of |
| ៤. | សុខ | ស្រុកអាមេរិកគេបាញ់សត្វនឹងអ្វីខ្លះ? | In the United States what do they go hunting with? |
| | | កាំភ្លើង | gun, rifle, firearm |
| | | ធ្នូ | bow |
| | | ព្រួញ | arrow |
| ៥. | កុម | គេប្រើកាំភ្លើង ធ្នូ នឹងព្រួញ។ ចុះនៅស្រុកខ្មែរវិញ? | They use rifles, bow and arrows. How about in Cambodia? |
| | | ស្នា | crossbow |
| | | កៅស៊ូ | rubber, elastic |
| | | ជំពាមកៅស៊ូ | slingshot |
| | | ស្លាប | wing, feather |
| | | សត្វស្លាប | bird |
| ៦. | សុខ | យើងមានស្នានឹងព្រួញ ជំពាមកៅស៊ូសម្រាប់បាញ់សត្វស្លាបតូចៗ | We have crossbows and arrows, and slingshots for shooting small birds. |
| | | នៅឯនេះ | over here |
| ៧. | កុម | នៅឯនេះមានសត្វអ្វីខ្លះដែលគេអាចបាញ់? | Over here, what are the animals we are allowed to hunt? |
| | | ពាយ | to be extinct |
| ៨. | សុខ | មានច្រើនគួរសមដែរ តែមានសត្វខ្លះលោកមិនអាចបាញ់ ព្រោះវាជិតពាយអស់ហើយ។ | Fairly many, but there are some animals that we can't hunt because they are almost extinct. |
| | | ឧទាហរណ៍ | for example |
| | | ដូចជា | such as |
| ៩. | កុម | ឧទាហរណ៍ដូចជាសត្វអ្វីខ្លះ? | For example, what are they? |

| | |
|---|---|
| ព្រៃ | forest, jungle |
| គោព្រៃ | wild bull |
| ខ្លា | tiger |
| ដំរី | elephant |
| ១០. សុខ ដូចជាគោព្រៃ ខ្លា ដំរី ។ | Like wild bulls, tigers, and elephants. |

DIALOGUE:

1. tom - nɨw srok khmaɛ mian sat craən ah məə tɨw.

2. sok - baat, mɛc look cɔŋ tɨw bañ sat eh?

3. tom - baat cɔŋ daɛ, taɛ khñom kmian pədap pədaa eh.

4. sok - srok aameerɨk kee bañ sat nɨŋ ɛy khlah?

5. tom - kee praə kəmphləəŋ, thnuu nɨŋ pruoñ. coh nɨw srok khmaɛ?

6. sok - yəəŋ mian snaa nɨŋ pruoñ, cəpiam kawsuu səmrap bañ sat slaap touc touc.

7. tom - nɨw aɛnih mian sat ɛy khlah daɛl kee aac bañ?

8. sok - mian craən kuo sɔm daɛ, taɛ mian sat khlah look mɨn aac bañ, prúh via cit piey ɔh əh.

9. tom - ottiahɔɔ douc cia sat ɛy khlah?

10. sok - douc cia kóo prey, khlaa, təmrɛy.

NOTES

DIALOGUE

SENTENCE NO.

4. Note that នឹង /nɨŋ/ means 'by means of,' as in

ស្រុកអាមេរិកគេបាញ់សត្វនឹងអ្វីខ្លះ?

srok aameerɨk kee bañ sat nɨŋ ɛy khlah?

In the U.S. what do they use to hunt with?

You can also say យកមក /yóo móo/ + verb to indicate an instrument, e.g.

ស្រុកអាមេរិកគេយកអ្វីខ្លះមកបាញ់សត្វ?

srok aameerɨk kee yóo ɛy khlah móo bañ sat?

In the U.S. what do they use to hunt with?

DRILLS

DRILL NO.

5. អត់ /ɔt/ or អិត /ət/ means 'to be without;' it is also a synonym for មិន /mɨn/ and គ្មាន /kmian/ 'there isn't, hasn't' (Lesson 35). អត់បាយ /ɔt baay/ is literally 'to be without rice' but actually means 'to starve.'

5. To say 'prefer to, would rather' there are several ways. The preferred action is marked by preverbal ស៊ូ /suu/ or សុខចិត្ត /sok cət/; the rejected action may either be negated, as in Drill 5, or introduced by ជាជាង /cia ciaŋ/ 'than' (see also Drill 6). Some examples:

ខ្ញុំស៊ូជាប់គុក ខ្ញុំមិនចូលទាហានទេ។
khñom suu cóp kuk khñom mɨn coul təhian eh
I'd rather go to jail than go into the army.

ខ្ញុំសុខចិត្តជាប់គុក ខ្ញុំមិនចូលទាហានទេ។
khñom sok cət cóp kuk khñom mɨn coul təhian eh
I'd rather go to jail than go into the army.

ខ្ញុំស៊ូជាប់គុកជាជាងចូលទាហាន។
khñom suu cóp kuk cia ciaŋ coul təhian
I'd rather go to jail than go into the army.

ខ្ញុំសុខចិត្តជាប់គុកជាជាងចូលទាហាន។
khñom sok cət cóp kuk cia ciaŋ coul təhian
I'd rather go to jail than go into the army.

The word ស៊ូ /suu/ is an adjective meaning 'determined and persistent.'

9. Note that 'to forbid to' is ហាមមិនឲ្យ /haam mɨn aoy/ + clause, e.g.,

ពេទ្យហាមមិនឲ្យខ្ញុំធ្វើការពីរថ្ងៃ។
pɛɛt haam mɨn aoy khñom thəə kaa pii ŋay
The doctor forbade me to work for two days.

Note that the subject of the following clause can come between ហាម /haam/ and មិនឲ្យ /mɨn aoy/, e.g.,

ពេទ្យហាមខ្ញុំមិនឲ្យធ្វើការពីរថ្ងៃ។
pɛɛt haam khñom mɨn aoy thəə kaa pii ŋay
The doctor forbade me to work for two days.

## DRILLS

DRILL ONE: Substitution

MODEL: T: នៅស្រុកខ្មែរមានសត្វច្រើនណាស់មើលទៅ។ (ត្រី)
S: នៅស្រុកខ្មែរមានត្រីច្រើនណាស់មើលទៅ។
T: _n Cambodia there must be a lot of animals. (fish)
S: In Cambodia there must be a ʔot of fish.

ក. នៅស្រុកខ្មែរមានត្រីច្រើនណាស់មើលទៅ។ (ឆ្កែ)
ខ. នៅស្រុកខ្មែរមានឆ្កែច្រើនណាស់មើលទៅ។ (អ្នកនេសាទត្រី)
គ. នៅស្រុកខ្មែរមានអ្នកនេសាទត្រីច្រើនណាស់មើលទៅ។ (បឹង)
ឃ. នៅស្រុកខ្មែរមានបឹងច្រើនណាស់មើលទៅ។ (ព្រៃ)

ង. នៅស្រុកខ្មែរមានផ្កាច្រើនណាស់មើលទៅ។ (សត្វស្លាប)
ច. នៅស្រុកខ្មែរមានសត្វស្លាបច្រើនណាស់មើលទៅ។

DRILL TWO: Substitution

MODEL: T: ម៉េចថ្ងៃណាមួយលោកចង់ទៅបាញ់សត្វទេ? (ស្ទូចត្រី)
S: ម៉េចថ្ងៃណាមួយលោកចង់ទៅស្ទូចត្រីទេ?
T: Well, would you like to go hunting someday? (fishing)
S: Well, would you like to go fishing someday?

ក. ម៉េចថ្ងៃណាមួយលោកចង់ទៅស្ទូចត្រីទេ? (មើលគេប្រណាំងសេះ)
ខ. ម៉េចថ្ងៃណាមួយលោកចង់ទៅមើលគេប្រណាំងសេះទេ? (មើលគេប្រជល់មាន់)
គ. ម៉េចថ្ងៃណាមួយលោកចង់ទៅមើលគេប្រជល់មាន់ទេ? (ជិះទូកលេង)
ឃ. ម៉េចថ្ងៃណាមួយលោកចង់ទៅជិះទូកលេងទេ? (លេងពីងប៉ុង)
ង. ម៉េចថ្ងៃណាមួយលោកចង់ទៅលេងពីងប៉ុងទេ? (បាញ់ព្រួស)
ច. ម៉េចថ្ងៃណាមួយលោកចង់ទៅបាញ់ព្រួសទេ?

DRILL THREE: Transformation

MODEL: T: ខ្ញុំចង់ទៅបាញ់សត្វ។
S: លោកចង់ទៅបាញ់សត្វទេ?
T: I want to go hunting.
S: Do you want to go hunting?

ក. ខ្ញុំចូលចិត្តញ៉ាំត្រី។ លោកចូលចិត្តញ៉ាំត្រីទេ?
ខ. ថ្ងៃអាទិត្យក្រោយខ្ញុំទៅស្ទូចត្រី។ ថ្ងៃអាទិត្យក្រោយលោកទៅស្ទូចត្រីទេ?
គ. ខ្ញុំខ្លាចពស់ណាស់។ លោកខ្លាចពស់ទេ?
ឃ. ល្ងាចនេះខ្ញុំទៅទិញដងសន្ទូច។ ល្ងាចនេះលោកទៅទិញដងសន្ទូចទេ?
ង. ខ្ញុំត្រូវការផ្លែសន្ទូចខ្លះ។ លោកត្រូវការផ្លែសន្ទូចខ្លះទេ?
ច. ខ្ញុំចូលចិត្តបាញ់សត្វធំៗណាស់។ លោកចូលចិត្តបាញ់សត្វធំៗទេ?

DRILL FOUR: Transformation

MODEL: T: ម្សិលមិញខ្ញុំទៅបាញ់សត្វ។
S: ម្សិលមិញខ្ញុំទៅបាញ់សត្វគ្មានបានសត្វសោះ។
T: Yesterday I went hunting.
S: Yesterday I went hunting and got nothing at all.

ក. អាទិត្យមុនខ្ញុំទៅស្ទូចត្រី។
អាទិត្យមុនខ្ញុំទៅស្ទូចត្រីគ្មានបានត្រីសោះ។

ខ. ព្រឹកមិញខ្ញុំទៅទិញដងសន្ទូច ។
ព្រឹកមិញខ្ញុំទៅទិញដងសន្ទូចគ្មានបានដងសន្ទូចសោះ ។
គ. ថ្ងៃមុនខ្ញុំទៅខ្ចីលុយបង ។
ថ្ងៃមុនខ្ញុំទៅខ្ចីលុយបងគ្មានបានលុយសោះ ។
ឃ. ម្សិលមិញខ្ញុំទៅជួលឡាន ។
ម្សិលមិញខ្ញុំទៅជួលឡានគ្មានបានឡានសោះ ។
ង. ល្ងាចមិញខ្ញុំទៅសុំលុយម្ដាយខ្ញុំ ។
ល្ងាចមិញខ្ញុំទៅសុំលុយម្ដាយខ្ញុំគ្មានបានលុយសោះ ។
ច. ល្ងាចមិញខ្ញុំទៅទិញខ្សែសន្ទូច ។
ល្ងាចមិញខ្ញុំទៅទិញខ្សែសន្ទូចគ្មានបានខ្សែសន្ទូចសោះ ។

DRILL FIVE: Transformation

MODEL: T: ខ្ញុំសម្លាប់មាន់មួយល្ងាចនេះ ។ (អត់បាយ)
S: ខ្ញុំស៊ូអត់បាយ ខ្ញុំមិនសម្លាប់មាន់ទេ ។
T: I will slaughter a chicken this evening. (starve)
S: I would rather starve than slaughter a chicken.

ក. ខ្ញុំទៅបាញ់ព្រើស ។ (គ្មានម្ហូប) ខ្ញុំស៊ូគ្មានម្ហូប ខ្ញុំមិនទៅបាញ់ព្រើសទេ ។
ខ. ខ្ញុំទៅលួចបង់ ។ (គ្មានលុយ) ខ្ញុំស៊ូគ្មានលុយ ខ្ញុំមិនទៅលួចបង់ទេ ។
គ. ខ្ញុំប្រាប់លោក ។ (ស្លាប់) ខ្ញុំស៊ូស្លាប់ ខ្ញុំមិនប្រាប់លោកទេ ។
ឃ. ខ្ញុំទៅធ្វើថំបាំង ។ (ជាប់គុក) ខ្ញុំស៊ូជាប់គុក ខ្ញុំមិនទៅធ្វើថំបាំងទេ ។
ង. ខ្ញុំទៅខ្ចីលុយប្អូនខ្ញុំ ។ (គ្មានលុយ) ខ្ញុំស៊ូគ្មានលុយ ខ្ញុំមិនទៅខ្ចីលុយប្អូនខ្ញុំទេ ។
ច. ខ្ញុំជួយលោក ។ (សម្លាប់ខ្លួនខ្ញុំ) ខ្ញុំស៊ូសម្លាប់ខ្លួនខ្ញុំ ខ្ញុំមិនជួយលោកទេ ។

DRILL SIX: Transformation

MODEL: T: ខ្ញុំសម្លាប់មាន់មួយល្ងាចនេះ ។ (អត់បាយ)
S: ខ្ញុំស៊ូអត់បាយជាជាងសម្លាប់មាន់ ។
T: I will slaughter a chicken tonight. (starve)
S: I would rather starve than kill a chicken.

ក. វាខ្ចីលុយគាត់ ។ (ខ្ចីអ្នកឯទៀត) វាស៊ូខ្ចីអ្នកឯទៀតជាជាងខ្ចីលុយគាត់ ។
ខ. ខ្ញុំញ៉ាំបាយ ។ (ដើរលេង) ខ្ញុំស៊ូដើរលេងជាជាងញ៉ាំបាយ ។
គ. វាឱ្យគេចាប់ ។ (ស្លាប់) វាស៊ូស្លាប់ជាជាងឱ្យគេចាប់ ។
ឃ. គាត់នៅរស់ ។ (ស្លាប់) គាត់ស៊ូស្លាប់ជាជាងនៅរស់ ។
ង. ពូហាក់ពិសាបាយ ។ (ពិសាស្រា) ពូហាក់ស៊ូពិសាស្រាជាជាងពិសាបាយ ។
ច. ពូហាក់ទៅរៀន ។ (ដើរលេងជាមួយស្រី) ពូហាក់ស៊ូដើរលេងជាមួយស្រីជាជាងទៅរៀន ។

DRILL SEVEN: Response

MODEL: T: ខ្ញុំចេះបាញ់ស្នា ។ (ធ្នូ)
S: លោកបាញ់ធ្នូកើតទេ?
T: I know how to shoot a crossbow. (a bow)
S: Can you shoot a bow?

ក. ខ្ញុំចេះបាញ់កាំភ្លើងដៃ ។ (កាំភ្លើងបាញ់គ្រាប់ប្រៃ) លោកបាញ់កាំភ្លើងបាញ់គ្រាប់ប្រៃកើតទេ?
ខ. ខ្ញុំចេះបើកឡាន ។ (ម៉ូតូ) លោកបើកម៉ូតូកើតទេ?
គ. ខ្ញុំចេះបង្ហាត់ឆ្កែ ។ (ឆ្មា) លោកបង្ហាត់ឆ្មាកើតទេ?
ឃ. ខ្ញុំចេះធ្វើខ្សែសន្ទូច ។ (ដងសន្ទូច) លោកធ្វើដងសន្ទូចកើតទេ?
ង. ខ្ញុំចេះអុំទូក ។ (ចែវទូក) លោកចែវទូកកើតទេ?
ច. ខ្ញុំចេះផ្លុំដំរីព្រៃ ។ (ខ្លុយ) លោកផ្លុំខ្លុយកើតទេ?

DRILL EIGHT: Substitution

MODEL: T: ខ្ញុំបាញ់រមាសដែលកំពុងរត់ ។ (ទន្សាយ)
S: ខ្ញុំបាញ់ទន្សាយដែលកំពុងរត់ ។
T: I shot a rhinoceros that was running. (rabbit)
S: I shot a rabbit that was running.

ក. ខ្ញុំបាញ់ទន្សាយដែលកំពុងរត់ ។ (ដើរ)
ខ. ខ្ញុំបាញ់ទន្សាយដែលកំពុងដើរ ។ (ក្ងោក)
គ. ខ្ញុំបាញ់ក្ងោកដែលកំពុងដើរ ។ (ហើរ)
ឃ. ខ្ញុំបាញ់ក្ងោកដែលកំពុងហើរ ។ (ទាព្រៃ)
ង. ខ្ញុំបាញ់ទាព្រៃដែលកំពុងហើរ ។ (ហែលទឹក)
ច. ខ្ញុំបាញ់ទាព្រៃដែលកំពុងហែលទឹក ។ (ខ្លាឃ្មុំ)
ឆ. ខ្ញុំបាញ់ខ្លាឃ្មុំដែលកំពុងហែលទឹក ។ (ឡើងដើមឈើ)
ជ. ខ្ញុំបាញ់ខ្លាឃ្មុំដែលកំពុងឡើងដើមឈើ ។

DRILL NINE: Transformation

NOTE: Make the sentence below into a question according to the cue.

MODEL: T: នៅស្រុកខ្មែររាជការហាមអ្នកស្រុកមិនឱ្យបាញ់សត្វ ព្រោះវាជិតពាយអស់ហើយ ។

T: In Cambodia the government forbids the people to shoot animals because they are almost extinct.

ក. (អ្នកស្រុក)
នៅស្រុកខ្មែររាជការហាមអ្នកណាមិនឱ្យបាញ់សត្វព្រោះវាជិតពាយអស់ហើយ?

ខ. (ជិតពាយអស់ហើយ)
នៅស្រុកខ្មែររាជការហាមអ្នកស្រុកមិនឱ្យបាញ់សត្វព្រោះវាយ៉ាងម៉េច?

គ. (ព្រោះវាជិតពាយវស្សហើយ)
ហេតុអីបានជានៅស្រុកខ្មែររាជការ ហាមអ្នកស្រុកមិនឲ្យបាញ់សត្វ?
ឃ. (រាជការ)
នៅស្រុកខ្មែរអ្នកណា ហាមអ្នកស្រុកមិនឲ្យបាញ់សត្វ?
ង. (នៅស្រុកខ្មែរ)
នៅឯណារាជការហាមអ្នកស្រុកមិនឲ្យបាញ់សត្វព្រោះវាជិតពាយវស្សហើយ?

DRILL TEN: Substitution

MODEL: T: រៀបចំប្រដាប់ប្រដា ឲ្យហើយទៅ និងអាលទៅបាញ់សត្វ។ (ទិញ)
S: ទិញប្រដាប់ប្រដា ឲ្យហើយទៅ និងអាលទៅបាញ់សត្វ។
T: Let's arrange the equipment first, then go hunting. (buy)
S: Let's buy the equipment first, then go hunting.

ក. ទិញប្រដាប់ប្រដា ឲ្យហើយទៅ និងអាលទៅបាញ់សត្វ។ (ស្ទូចត្រី)
ខ. ទិញប្រដាប់ប្រដា ឲ្យហើយទៅ និងអាលទៅស្ទូចត្រី។ (ជួល)
គ. ជួលប្រដាប់ប្រដា ឲ្យហើយទៅ និងអាលទៅស្ទូចត្រី។ (ទូក)
ឃ. ជួលទូកឲ្យហើយទៅ និងអាលទៅស្ទូចត្រី។ (បាញ់ទាព្រៃ)
ង. ជួលទូកឲ្យហើយទៅ និងអាលទៅបាញ់ទាព្រៃ។ (ឡាន)
ច. ជួលឡានឲ្យហើយទៅ និងអាលទៅបាញ់ទាព្រៃ។ (សត្វ)
ឆ. ជួលឡានឲ្យហើយទៅ និងអាលទៅបាញ់សត្វ។

DRILL ELEVEN: Response

MODEL: T: ជួលឡានឲ្យហើយទៅ និងអាលទៅបាញ់សត្វ។
S: កុំអាលជួលឡានអីព្រោះយើងមិនទាន់ទៅបាញ់សត្វឥឡូវទេ។
T: Let's rent a car first, then go hunting.
S: Don't rent the car yet, we're not going hunting now.

ក. ទិញប្រដាប់ប្រដា ឲ្យហើយទៅ និងអាលទៅស្ទូចត្រី។
កុំអាលទិញប្រដាប់ប្រដា អីព្រោះយើងមិនទាន់ទៅស្ទូចត្រីឥឡូវទេ។
ខ. រៀបចំទូកឲ្យហើយទៅ និងអាលទៅបាញ់ទាព្រៃ។
កុំអាលរៀបចំទូកអី ព្រោះយើងមិនទាន់ទៅបាញ់ទាព្រៃឥឡូវទេ។
គ. ស្លៀកពាក់ខោអាវឲ្យហើយទៅ និងអាលទៅមើលកុន។
កុំអាលស្លៀកពាក់ខោអាវអីព្រោះយើងមិនទាន់ទៅមើលកុនឥឡូវទេ។
ឃ. ញ៉ាំបាយឲ្យហើយទៅ និងអាលទៅដើរលេង។
កុំអាលញ៉ាំបាយអីព្រោះយើងមិនទាន់ទៅដើរលេងឥឡូវទេ។
ង. ចូលទូកឲ្យហើយទៅ និងអាលទៅទិញខ្សែសន្ទូច។
កុំអាលចូលទូកអីព្រោះយើងមិនទាន់ទៅទិញខ្សែសន្ទូចឥឡូវទេ។

ច. ខ្ចីដងសន្ទូចគាត់ឲ្យហើយទៅ និងអាលទៅស្ទូចត្រី។
កុំអាលខ្ចីដងសន្ទូចគាត់អី ព្រោះយើងមិនទាន់ទៅស្ទូចត្រីឥឡូវទេ។

## Reading Passage

### សត្វនៅស្រុកខ្មែរ

ប្រហែលជាង៣០ឆ្នាំហើយ នៅស្រុកខ្មែរ សត្វព្រៃនៅសឹងតែពាសពេញគ្រប់កន្លែង។ ពីកន្លែងមួយទៅកន្លែងមួយ គេតែងតែឃើញសត្វទាំងនោះបើមិនច្រើនក៏តិចដែរ។ ដំរី ខ្លា ខ្លាឃ្មុំ គោព្រៃ និងរមាសច្រើននៅឆ្ងាយពីភូមិ ឯឈ្លូស ជ្រូស និងទន្សាយវិញ យើងច្រើនឃើញនៅជាមួយគ្នា នៅមិនឆ្ងាយទេ។ យើងមិនសូវហ៊ានដើរចូលព្រៃម្នាក់ឯងទេ យើងត្រូវមានគ្នា ឬត្រូវមានរបស់ការពារខ្លួនជានិច្ច។ បើនិយាយពីនៅពេលយប់វិញ មនុស្សនៅស្រុកស្រែចំការមិនសូវហ៊ានដេកតាមចិត្តទេ។ គេប្រយ័ត្នណាស់ ព្រោះគេខ្លាចមកអូសគោគេ ឬមកស៊ីគេ។

អំពីសត្វព្រៃនេះ អ្នកស្រុកស្រែចំការទទួលផលអាក្រក់ច្រើនណាស់ គឺមានស្លាប់ច្រើននាក់ក្នុងមួយឆ្នាំៗ និងដំណាំរបស់គេក៏ខូចខាតខ្លាំងណាស់ដែរ។

កាលនោះ អ្នកស្រែចំការមានការពិបាកនឹងសត្វព្រៃនោះមែន តែគេសប្បាយម្យ៉ាង គឺគេសប្បាយខាងរឿងម្ហូបសម្រាប់ចិញ្ចឹមគ្រួសារគេ។ គេមិនដែលព្រួយពីរឿងនេះទេ ហើយគេមិនសូវបាច់រកទុកដង។ បើគេដឹងថាគេគ្មានអ្វីសម្រាប់បរិភោគល្ងាចនេះ គេទៅរកមុនពេលនោះបន្តិច។ បើគេមិនចង់ទៅរកសត្វព្រៃឬសត្វស្លាប គេទៅរកត្រី។ និយាយពីត្រីអញ្ចឹង ពេលនោះស្រួលចាប់ណាស់ យើងចាប់នឹងដៃទទេក៏បានដែរ។

តែឥឡូវនេះ សត្វព្រៃទាំងនោះពាយជិតអស់ហើយ។ ហើយការហាមមិនឲ្យបាញ់សត្វព្រៃនោះ ពិតមែនតែមានមែន ក៏មិនទាន់សូវបង្ខំមនុស្សឲ្យធ្វើតាមប៉ុន្មានដែរ។

## VOCABULARY

| | | |
|---|---|---|
| កៅស៊ូ | kawsuu | rubber, elastic |
| កាំភ្លើង | kəmphləəŋ | gun, rifle, firearm |
| កាំភ្លើងដៃ | kəmphləəŋ day | pistol |
| ខ្លា | khlaa | tiger |
| ខ្លាឃ្មុំ | khlaa khmum | bear |
| គោព្រៃ | kɔɔ prey | wild bull |
| គ្រាប់ប្រាយ | krɔ́p pray | buckshot |
| ឃ្មុំ | khmum | bee |
| ចែវទូក | caɛv tuuk | to row |
| ចំបាំង | cəbaŋ | war, fighting |
| ចំពាមកៅស៊ូ | cəpiam kawsuu | slingshot |

| | | |
|---|---|---|
| ឆ្មា | chmaa | cat |
| ឆ្កែ | chkaɛ | dog |
| ឈើ | chəə | wood |
| ឈ្លូស | chluuh | deer (R) |
| ដងសន្ទូច | dɔɔŋ sətuuc | fishing pole |
| ដើមឈើ | daəm chəə | tree |
| ដេញ | deñ | to chase, to pursue (L) |
| ដំរី | təmrey | elephant |
| ត្រពាំង | təpéŋ | pond (L) |
| ទទេ | tətee | free, unadorned, simple (R) |
| ទន្សាយ | nsaay | rabbit |
| ទាព្រៃ | tia prey | wild duck |
| ទូក | tuuk | boat |
| ធ្នូ | thnuu | bow |
| នឹង | nɨŋ | with, by means of |
| នេសាទ (ត្រី) | nəsaat (trey) | to fish |
| នៅឯនេះ | niw aɛnih | over here |
| បាញ់សត្វ | bañ sat | to hunt |
| បឹង | bəŋ | lake |
| ប្រជល់មាន់ | pəcúl mɔ́n | to hold a cock fight |
| ប្រដាប់ប្រដា | pədap pədaa | equipment |
| ប្រណាំងសេះ | pənaŋ sɛh | horse racing |
| ប្រើស | prəh | deer |
| ផ្លែសន្ទូច | phlaɛ sətouc | hook |
| ផ្សាំង | phsaŋ | to tame |
| ពស់ | púh | snake |
| ពាសពេញ | piah piñ | completely, all over (R) |
| ពាយ | piey | to be extinct |
| ព្រាប | priap | pigeon |
| ព្រួញ | pruoñ | arrow |
| ព្រៃ | prey | forest, jungle |
| រមាស | lmiah | rhinoceros |
| សត្វ | sat | animal |
| សត្វស្លាប | sat slaap | bird |
| សម្លាប់ខ្លួនឯង | səlap khluon aɛŋ | to commit suicide |
| ស៊ូ | suu | determined and persistent |
| ស៊ូ + verb | suu + verb | to prefer to, would rather |
| សេះ | sɛh | horse |
| ស្នា | snaa | crossbow |

| | | |
|---|---|---|
| ស្លាប | slaap | wing, feather |
| ស្ទូចត្រី | stuuc trey | to fish |
| ហាមមិនឲ្យ | haam mɨn aoy | to forbid |
| ហើរ | haə | to fly (bird) |
| អត់បាយ | ɔt baay | to starve, to go hungry |
| អុំ (ទូក) | om (tuuk) | to row |
| អ្នកនេសាទត្រី | néʔ nəsaat trɛy | fisherman |
| ឧទាហរណ៍ | ottiahɔɔ | example, for example |



Mango tree

## LESSON FORTY-FIVE

### DIALOGUE

| | | | |
|---|---|---|---|
| ១. | សុខ | លោកថុម ចុងអាទិត្យនេះ លោកចង់ទៅណា ឬធ្វើអីទេ? | Tom, do you want to go anywhere, or do anything this weekend? |
| ២. | ថុម | អត់ធ្វើអីទេ តែខ្ញុំមិនដឹងទៅឯណាសោះ។ មានកន្លែងណាគ្រាន់តែនឹងដើរលេងទេ? | I'm not doing anything, but I don't know where to go at all. Are there any places where you can just stroll around? |
| | | មិនខ្វះទេ | plenty, no lack |
| ៣. | សុខ | អូ! មិនខ្វះទេលោក។ | Oh! Plenty. |
| | | យកខ្យល់អាកាស | to take the fresh air |
| ៤. | ថុម | មានកន្លែងអង្គុយយកខ្យល់អាកាសទេ? | Are there any places to get fresh air? |
| | | វាំង | palace |
| ៥. | សុខ | បើលោកចង់យកខ្យល់អាកាស លោកអាចទៅអង្គុយលេងមុខវាំង។ | If you want to get fresh air you can go and sit down in front of the palace. |
| ៦. | ថុម | ចុះបើខ្ញុំចង់ញ៉ាំអីបន្តិចបន្តួច? | And if I want to have a little snack? |
| | | គុយទាវ | Chinese noodle soup |
| | | ក្រសួង | ministry, department, bureau |
| | | ឃោសនាការ | information, propaganda |
| | | ក្រសួងឃោសនាការ | information bureau |
| | | នំបុ័ងដាក់សាច់ | sandwich |
| ៧. | សុខ | លោកទៅផ្សារចាស់ លោកញ៉ាំគុយទាវមើលស្រីៗ ឬលោកទៅមុខក្រសួងឃោសនាការ គេមានលក់នំបុ័ងដាក់សាច់។ | If you go to the Old Market, you can eat noodle soup and watch the girls, or you can go in front of the Information Bureau where they sell sandwiches. |
| ៨. | ថុម | ចុះយប់ៗ លោកអាចទៅកន្លែងណាខ្លះ? | And at night, where can you go? |
| | | ល្ខោន | play |
| ៩. | សុខ | លោកអាចទៅកន្លែងដែលខ្ញុំបានប្រាប់លោក ឬលោកអាចទៅមើលកុន ឬល្ខោន។ | You can go to the places that I told you about, or you can go see a movie or a play. |

DIALOGUE:

1. sok - look tom, coŋ aatɨt nih look coŋ tɨw naa rɨɨ thəə ɛy eh?

2. tom - ɔt thəə ɛy eh. taɛ khñom mɨn dəŋ tɨw aɛnaa soh. mian kəlaɛŋ naa krón taɛ nɨŋ daə leeŋ eh.

3. sok - oh! mɨn khvah eh look.

4. tom - mian kəlaɛŋ ŋkuy yóo khyɔl aakah eh?

5. sok - baə look coŋ yóo khyɔl aakah look aac tɨw ŋkuy leeŋ muk véŋ.

6. tom - coh baə khñom coŋ ñam ɛy ntɛc-ntuoc?

7. sok - look tɨw phsaa cah, look ñam kətiav məəl srɛy srɛy rɨɨ look tɨw muk kəsuoŋ khohsnaa kaa, kee mian lúʔ numpaŋ daʔ sac.

8. tom - coh yup yup look aac tɨw kəlaɛŋ naa khlah?

9. sok - look aac tɨw kəlaɛŋ daɛl khñom baan prap look, rɨɨ look aac tɨw məəl kon rɨɨ lkhaon.

NOTES

DIALOGUE

SENTENCE NO.

7. Note that the first two clauses of this sentence are an example of a pair of clauses juxtaposed without a relator; their relation to each other is defined by the context, not by an explicit word like បើ /baə/ 'if,' កាលណា /kaalnaa/ 'when,' or ហើយ /haəy/ 'and.' Cf. S.4.1.1 and S.4.1.2 in the grammatical sketch also.

DRILLS

DRILL NO.

1. In this drill is introduced a new idiom: មិនថាតែ /mɨn thaa taɛ/ + noun$_1$ + noun$_2$ + ក៏ /kɔɔ/ + verb phrase + ដែរ /daɛ/ means 'not only noun$_1$ but noun$_2$ also,' e.g. មិនថាតែខ្ញុំទេ បងខ្ញុំក៏មិនសូវចូលចិត្តរៀនដែរ។

mɨn thaa taɛ khñom tee, bɔɔŋ khñom kɔɔ mɨn səw coul cət rien daɛ

Not only I but my older brother doesn't like to study either.

1. Sentence The word ខ្ជិល /khcɨl/ 'lazy' is used before a verb to mean 'to not feel like (do)ing,' e.g.

ខ្ញុំខ្ជិលក្រោកពីគេងព្រឹកនេះ។

khñom khcɨl kraok pii keeŋ prɨk nih

I don't feel like getting up this morning.

2. ស្រាប់តែ /srap taɛ/ 'suddenly' is normally another preverbal adverb like ច្រើនតែ /craən taɛ/ 'mostly' etc. However, in this drill occurs a new pattern, in which what have been introduced so far as preverbals are used at

the beginning of the clause, before the subject, as well (cf. in the grammatical sketch sections A.3, A.3.1, and A.3.2).

7. The word ងាប់ /ŋóp/ 'die' is very non-formal. It is used to refer to animals and plants and only informally for people. The usual word for 'die' when referring to people is ស្លាប់ /slap/.

Notes on the places mentioned in this lesson:

1. មុខវាំង /muk vèŋ/ This is a small park in front of the royal palace. One edge of this park is on the river front, which makes it a popular place for the Phnompenhois to go for a cool breeze. The palace itself has been turned into a national museum since the abolition of the monarchy in 1970.

2. ផ្សារចាស់ /phsaa cah/ 'the old market.' This is one of several covered markets in Phnom Penh. It occupies a large city block and is composed of permanent kiosks surrounding a central informal restaurant area where snacks and soft drinks are available. All the markets sell vegetables and fruits, and most have cloth, but the Old Market specializes in an especially wide selection of fruits and fabrics. In addition it is the only market with a large number of kiosks selling books of all sorts, almost all of them in Cambodian. Otherwise books must be bought in bookstores, which are scattered throughout the city.

3. វត្តភ្នំ /vót phnum/ This is the hill for which Phnom Penh is named. ភ្នំពេញ /phnum pɨñ/ means 'Penh's Hill,' and, according to legend, the hill and the temple on it were built by a pious woman named Penh to accommodate images of the Buddha which she found floating in the river. To this day there is a វត្ត /vót/ 'wat, pagoda' on the hill, and the វត្តភ្នំ /vót phnum/ is a popular spot for both Cambodian and foreign tourists.

4. កំពង់សោម/kəpúŋ saom/ is the country's only deepwater port. It was built under Prince Sihanouk and originally called ក្រុងព្រះសីហនុ/kroŋ préh sihaanuʔ/ 'Sihanoukville.' Since 1970 it has been known as កំពង់សោម/kəpúŋ saom/ 'Kompong Som.' The only oil refinery in the country is located in this town.

5. ភ្នំបូកគោ /phnum bóokoo/ 'Bokor' is one of the resort areas in the country. It is popular because of its cool and pleasant climate, which are a result of its altitude.

## DRILLS

DRILL ONE: Response

MODEL: T: ខ្ញុំមិនដឹងទៅលេងឯណាទេ។

S: មិនចាំតែលោកទេ ខ្ញុំក៏មិនដឹងទៅលេងឯណាដែរ។

T: I don't know where to go out.

S: Not only you, but I don't know where to go either.

ក. ខ្ញុំត្រូវការលុយរាល់ថ្ងៃ។
មិនចាំតែលោកទេ ខ្ញុំក៏ត្រូវការលុយរាល់ថ្ងៃដែរ។

ខ. ខ្ញុំមិនចូលចិត្តនំបុ័ងដាក់សាច់ទេ។
មិនចាំតែលោកទេ ខ្ញុំក៏មិនចូលចិត្តនំបុ័ងដាក់សាច់ដែរ។

គ. ខ្ញុំដើរលេងយប់ច្រើនពេក។
មិនចាំតែលោកទេ ខ្ញុំក៏ដើរលេងយប់ច្រើនដែរ។

ឃ. ខ្ញុំទាល់គំនិតមិនដឹងធ្វើអីទៅទៀត។
មិនចាំតែលោកទេ ខ្ញុំក៏ទាល់គំនិតមិនដឹងធ្វើអីដែរ។

ង. ខ្ញុំខ្ជិលរៀនណាស់ប៉ុន្មានថ្ងៃនេះ។
មិនចាំតែលោកទេ ខ្ញុំក៏ខ្ជិលរៀនដែរប៉ុន្មានថ្ងៃនេះ។

ច. ខ្ញុំត្រូវការសំរាកមួយថ្ងៃ។
មិនចាំតែលោកទេ ខ្ញុំក៏ត្រូវការសំរាកមួយថ្ងៃដែរ។

DRILL TWO:

MODEL: T: ខ្ញុំកំពុងតែអង្គុយយកខ្យល់អាកាស។ (គ្រាប់បែកមួយផ្ទុះ)

S: ខ្ញុំកំពុងតែអង្គុយយកខ្យល់អាកាសស្រាប់តែគ្រាប់បែកមួយផ្ទុះ។

T: I was siting there getting some fresh air. (a bomb exploded)

S: I was sitting there getting some fresh air when suddenly a bomb exploded.

ក. ខ្ញុំកំពុងតែមើលសៀវភៅ។ (ចង្កៀងរលត់)
ខ្ញុំកំពុងតែមើលសៀវភៅស្រាប់តែចង្កៀងរលត់។

ខ. ខ្ញុំកំពុងតែបើកឡាន។ (កង់ផ្ទុះបែក)
ខ្ញុំកំពុងតែបើកឡានស្រាប់តែកង់ផ្ទុះបែក។

គ. ខ្ញុំកំពុងតែញ៉ាំគុយទាវជាមួយពួកម៉ាកស្រីខ្ញុំ។ (ប្រពន្ធខ្ញុំមកដល់)
ខ្ញុំកំពុងតែញ៉ាំគុយទាវជាមួយពួកម៉ាកស្រីខ្ញុំស្រាប់តែប្រពន្ធខ្ញុំមកដល់។

ឃ. ខ្ញុំកំពុងតែដេកក្នុងថ្នាក់។ (លោកគ្រូចូលមកដល់)
ខ្ញុំកំពុងតែដេកក្នុងថ្នាក់ស្រាប់តែលោកគ្រូចូលមកដល់។

ង. ខ្ញុំកំពុងតែញ៉ាំបាយ។ (រុយមួយធ្លាក់ក្នុងចាន)
ខ្ញុំកំពុងតែញ៉ាំបាយស្រាប់តែរុយមួយធ្លាក់ក្នុងចាន។

ច. ខ្ញុំកំពុងតែអង្គុយរៀន។ (ខ្ញុំដួលសន្លប់)
ខ្ញុំកំពុងតែអង្គុយរៀនស្រាប់តែខ្ញុំដួលសន្លប់។

DRILL THREE: Substitution

MODEL: T: លោកមានស្គាល់កន្លែងណាគ្រាន់តែនឹងអង្គុយលេងទេ? (សួនច្បារ)

S: លោកមានស្គាល់សួនច្បារណាគ្រាន់តែនឹងអង្គុយលេងទេ?

T: Do you know any place where you can just sit around? (garden)

S: Do you know any garden where you can just sit around?

ក. លោកមានស្គាល់សួនច្បារណាគ្រាន់តែនឹងអង្គុយលេងទេ? (ដកខ្យល់អាកាស)
ខ. លោកមានស្គាល់សួនច្បារណាគ្រាន់តែនឹងដកខ្យល់អាកាសទេ? (ញ៉ាំបាយ)
គ. លោកមានស្គាល់សួនច្បារណាគ្រាន់តែនឹងញ៉ាំបាយទេ? (ហាងបាយ)
ឃ. លោកមានស្គាល់ហាងបាយណាគ្រាន់តែនឹងញ៉ាំបាយទេ? (ញ៉ាំស្រា)
ង. លោកមានស្គាល់ហាងបាយណាគ្រាន់តែនឹងញ៉ាំស្រាទេ? (មើលស្រីរាំ)
ច. លោកមានស្គាល់ហាងបាយណាគ្រាន់តែនឹងមើលស្រីរាំទេ?

DRILL FOUR: Response

MODEL: T: លោកស្គាល់កន្លែងញ៉ាំស្រាថោកទេ?

S: មិនខ្វះកន្លែងញ៉ាំស្រាថោកទេលោក។

T: Do you know any place that sells cheap drinks?

S: Plenty of places sell cheap drinks.

ក. លោកមានលុយឲ្យខ្ញុំខ្ចីទេ? មិនខ្វះ:លុយឲ្យលោកខ្ចីទេលោក។
ខ. លោកស្គាល់ហាងបាយល្អៗទេ? មិនខ្វះ:ហាងបាយល្អៗទេលោក។
គ. លោកមានបន្ទប់ដេកទេ? មិនខ្វះ:បន្ទប់ដេកទេលោក។
ឃ. លោកមានស្គាល់កន្លែងជួសឡានណាទេ? មិនខ្វះ:កន្លែងជួសឡានទេលោក។
ង. លោកទិញសំបុត្រកុនទុកទេ? មិនខ្វះ:សំបុត្រកុនទេលោក។
ច. លោកមានស្រាញ៉ាំទេ? មិនខ្វះ:ស្រាញ៉ាំទេលោក។

DRILL FIVE: Choice

MODEL: T: អាមេរិកាំងញ៉ាំ .... នៅពេលបាយព្រឹក។ (កាហ្វេ, ស្រា)

S: អាមេរិកាំងញ៉ាំកាហ្វេនៅពេលបាយព្រឹក។

T: Americans drink...at breakfast. (coffee, liquor)

S: Americans drink coffee at breakfast.

ក. អង់គ្លេសញ៉ាំ .... នៅពេលបាយព្រឹក។ (កាហ្វេ, តែ)
អង់គ្លេសញ៉ាំតែនៅពេលបាយព្រឹក។
ខ. នៅស្រុកខ្មែរគេមិនចូលចិត្ត .... ទេ។ (សាច់ជ្រូក, សាច់ចៀម)
នៅស្រុកខ្មែរគេមិនចូលចិត្តសាច់ចៀមទេ។
គ. មុនចេញពីផ្ទះខ្ញុំ .... រ៉ាដ្យូ។ (បើក, បិទ)
មុនចេញពីផ្ទះខ្ញុំ បិទរ៉ាដ្យូស្តាប់ដំណឹង។

ឃ. មុនខ្ញុំដេក ខ្ញុំ .... រាំងយោ។ (បើក, បិទ)
មុនខ្ញុំដេក ខ្ញុំបិទរាំងយោ។
ង. យើងទៅអង្គុយនៅ.... ដើម្បីយកខ្យល់អាកាស។ (មុខវាំង, រោងកុន)
យើងទៅអង្គុយនៅមុខវាំងដើម្បីយកខ្យល់អាកាស។
ច. ខ្ញុំមិនដែលញ៉ាំកាហ្វេនិង .... ទេ។ (ពែង, កែវ)
ខ្ញុំមិនដែលញ៉ាំកាហ្វេនិងកែវទេ។

DRILL SIX: Response

MODEL: T: ខ្ញុំចង់យកខ្យល់អាកាស។ (អង្គុយលេងមុខវាំង)
S: បើលោកចង់យកខ្យល់អាកាស លោកទៅអង្គុយលេងមុខវាំង។
T: I want to get some fresh air. (sit in front of the palace)
S: If you want to get some fresh air, go sit in front of the palace.

ក. ខ្ញុំចង់ទិញសាច់ប៉ាតេល្អបំផុត។ (ហាងបាយឡាប៉ៃយុត)
បើលោកចង់ទិញសាច់ប៉ាតេល្អបំផុត លោកទៅហាងបាយឡាប៉ៃយុត។
ខ. ខ្ញុំចង់ទិញខោអាវល្អហើយថោក។ (ហាងអង្គឌួង)
បើលោកចង់ទិញខោអាវល្អហើយថោក លោកទៅហាងអង្គឌួង។
គ. ខ្ញុំចង់ទៅរាំ។ (បារអូឡាំពិកមានស្រីស្អាតៗ)
បើលោកចង់ទៅរាំ លោកទៅបារអូឡាំពិកមានស្រីស្អាតៗ។
ឃ. ខ្ញុំចង់ទៅមើលកុនបារាំង។ (រោងកាស៊ីណូ)
បើលោកចង់ទៅមើលកុនបារាំង លោកទៅរោងកាស៊ីណូ។
ង. ខ្ញុំចង់ទៅមុជទឹកសមុទ្រ។ (កំពង់សោម)
បើលោកចង់ទៅមុជទឹកសមុទ្រ លោកទៅកំពង់សោម។
ច. ខ្ញុំចង់ទិញផ្លែឈើបរទេស។ (ផ្សារចាស់)
បើលោកចង់ទិញផ្លែឈើបរទេស លោកទៅផ្សារចាស់។
ឆ. ខ្ញុំចង់ជួបនិងទេសចរច្រើន។ (ហាងលក់ប្រាក់)
បើលោកចង់ជួបនិងទេសចរច្រើន លោកទៅហាងលក់ប្រាក់។

DRILL SEVEN: Response

MODEL: T: មាន់អាំងឆ្អិនហើយឬនៅ?
S: ទេ មាន់អាំងមិនទាន់ឆ្អិននៅឡើយទេ។
T: Is the broiled chicken cooked?
S: No, the broiled chicken is not cooked yet.

ក. ចេកនោះទុំហើយឬនៅ?
ទេ ចេកនោះមិនទាន់ទុំនៅឡើយទេ។
ខ. ហាងកាហ្វេនោះបើកហើយឬនៅ?
ទេ ហាងកាហ្វេនោះមិនទាន់បើកនៅឡើយទេ។

គ. ដើមផ្កាកុឡាបលោកងាប់ហើយឬនៅ?
ទេ ដើមផ្កាកុឡាបខ្ញុំមិនទាន់ងាប់នៅឡើយទេ។
ឃ. ដើមផ្កាលោកធំហើយឬនៅ?
ទេ ដើមផ្កាខ្ញុំមិនទាន់ធំនៅឡើយទេ។
ង. លោកសងលុយខ្ញុំហើយឬនៅ?
ទេ ខ្ញុំមិនទាន់សងលុយលោកនៅឡើយទេ។
ច. បន្ទប់លោកស្អាតហើយឬនៅ?
ទេ បន្ទប់ខ្ញុំមិនទាន់ស្អាតនៅឡើយទេ។

DRILL EIGHT: Response

MODEL: T: មាន់អាំងឆ្អិនហើយឬនៅ? (ឆៅ)
S: ទេ មាន់អាំងនៅឆៅនៅឡើយទេ។
T: Is the broiled chicken cooked? (raw)
S: No, the broiled chicken is still raw.

ក. ចេកនេះទុំហើយឬនៅ? (ខ្ចី)
ទេ ចេកនេះនៅខ្ចីនៅឡើយទេ។
ខ. ហាងកាហ្វេនោះបើកហើយឬនៅ? (បិទ)
ទេ ហាងកាហ្វេនោះនៅបិទនៅឡើយទេ។
គ. ដើមផ្កាកុឡាបលោកស្លាប់ហើយឬនៅ? (រស់)
ទេ ដើមផ្កាកុឡាបខ្ញុំនៅរស់នៅឡើយទេ។
ឃ. ដើមផ្កាលោកធំហើយឬនៅ? (តូច)
ទេ ដើមផ្កាខ្ញុំនៅតូចនៅឡើយទេ។
ង. លោកសងលុយខ្ញុំហើយឬនៅ? (ជំពាក់លោក)
ទេ ខ្ញុំនៅជំពាក់លោកនៅឡើយទេ។
ច. បន្ទប់លោកស្អាតហើយឬនៅ? (ក្រខ្វក់)
ទេ បន្ទប់ខ្ញុំនៅក្រខ្វក់នៅឡើយទេ។

DRILL NINE: Transformation

MODEL: T: បើលោកចង់ញ៉ាំគុយទាវមើលស្រីៗ លោកទៅផ្សារចាស់។ (ផ្សារចាស់)
S: បើខ្ញុំចង់ញ៉ាំគុយទាវមើលស្រីៗ ខ្ញុំទៅផ្សារណា?
T: If you want to eat noodle soup and watch girls, go to Phsaa Cah. (Phsaa Cah)
S: If I want to eat noodle soup and watch girls, which market should I go to?

ក. បើលោកចង់ទៅផ្សារចាស់ លោកជិះឡានឈ្នួលលេខដប់។ (លេខដប់)
បើខ្ញុំចង់ទៅផ្សារចាស់ ខ្ញុំជិះឡានឈ្នួលណា?

ខ. បើលោកចង់រៀនភាសាខ្មែរ លោកទៅសាលាយើង។ (សាលាយើង)
បើខ្ញុំចង់រៀនភាសាខ្មែរ ខ្ញុំទៅសាលាណា?
គ. បើលោកចង់មើលកុនចិន លោកទៅរោងហៃហ្វាង។ (រោងហៃហ្វាង)
បើខ្ញុំចង់មើលកុនចិន ខ្ញុំទៅរោងណា?
ឃ. បើលោកចង់យកខ្យល់អាកាសល្អ លោកទៅភ្នំបូកគោ។ (ភ្នំបូកគោ)
បើខ្ញុំចង់យកខ្យល់អាកាសល្អ ខ្ញុំទៅភ្នំណា?
ង. បើលោកចង់ខ្ចីលុយបរបោក លោកទៅបង់ជាតិ។ (បង់ជាតិ)
បើខ្ញុំចង់ខ្ចីលុយបរបោក ខ្ញុំទៅបង់ណា?
ច បើលោកចង់ទៅលេងសមុទ្រ លោកទៅថ្ងៃសៅរ៍។ (ថ្ងៃសៅរ៍)
បើលោកចង់ទៅលេងសមុទ្រ លោកទៅថ្ងៃណា?
ឆ. បើលោកចង់ទៅវត្តភ្នំ លោកទៅតាមផ្លូវនេះ។ (ផ្លូវនេះ)
បើខ្ញុំចង់ទៅវត្តភ្នំ ខ្ញុំទៅតាមផ្លូវណា?

DRILL TEN: Transformation

MODEL: T: ខ្ញុំញុំាំបាយព្រឹកនៅហាងនោះ។ (ប្រាប់លោក)
S: លោកញុំាំបាយព្រឹកនៅហាងដែលខ្ញុំប្រាប់លោក។
T: I eat my breakfast in that restaurant. (I told you about)
S: You eat your breakfast in the restaurant I told you about.

ក. ខ្ញុំខ្ចីលុយនៅបង់ជាតិ។ (ប្រពន្ធខ្ញុំធ្វើការ)
លោកខ្ចីលុយនៅបង់ដែលប្រពន្ធខ្ញុំធ្វើការ។
ខ. ខ្ញុំស្រឡាញ់ឆ្មានោះ។ (ខ្ញុំឱ្យលោក)
លោកស្រឡាញ់ឆ្មាដែលខ្ញុំឱ្យលោក។
គ. ខ្ញុំលក់ឡាន។ (ខ្ញុំឱ្យលោកខ្ចី)
លោកលក់ឡានដែលខ្ញុំឱ្យលោកខ្ចី។
ឃ. ខ្ញុំទិញស្រា។ (ខ្ញុំមិនចូលចិត្ត)
លោកទិញស្រាដែលខ្ញុំមិនចូលចិត្ត។
ង. ខ្ញុំមើលកុន។ (គ្មានមនុស្សមើល)
លោកមើលកុនដែលគ្មានមនុស្សមើល។
ច. ខ្ញុំទុកអាវនេះ។ (គេបោះចោល)
លោកទុកអាវដែលគេបោះចោល។

Reading Passage

កូនសិស្សក្រៅសាលា

ដែលហៅជាកូនសិស្សក្នុងសាលាឬក្រៅសាលានោះ មិនមែនមានន័យជាកូនសិស្សក្នុងសាលា គេត្រូវរៀនក្នុងសាលា ហើយកូនសិស្សក្រៅ គេត្រូវរៀនក្រៅសាលានោះ

ទេ។ កូនសិស្សក្នុងសាលាមានន័យថា គេនៅក្នុងផ្ទះមួយក្នុងសាលា តែគេមិនចាំបាច់បង់លុយ ញ៉ាំក៏មិនបង់លុយដែរ។ កូនសិស្សក្រៅសាលាត្រូវនៅផ្ទះរបស់គេ ឬជួលផ្ទះនៅ។

កូនសិស្សក្រៅសាលាមានការពិបាកបន្តិច បើគេមកពីខេត្តក្រៅ ព្រោះគេត្រូវជួលផ្ទះនៅ ហើយធ្វើបាយញ៉ាំខ្លួនឯង។ ចំពោះកូនសិស្សដែលមានផ្ទះឪពុកម្ដាយនៅក្នុងទីក្រុង គេមិនសូវពិបាកប៉ុន្មានទេ ព្រោះគេមានផ្ទះនៅស្រាប់ គេមានបាយញ៉ាំស្រាប់។ កូនសិស្សក្រៅសាលាក៏ជាកូនសិស្សល្អដូចកូនសិស្សក្នុងសាលាដែរ ជួនកាលល្អជាងផង។ តែកូនសិស្សក្រៅធ្វើអ្វីទាំងអស់គ្មានពេលគ្មានម៉ោងដូចកូនសិស្សក្នុងសាលាទេ។ គេសប្បាយជាងកូនសិស្សក្នុងសាលា។ ជួនកាលគេយកពេលដែលគេត្រូវរៀន ដើម្បីនឹងដើរលេង ទៅមើលកុន ទៅរាំ ឬជិះកង់មើលស្រីៗនៅតាមសួនច្បារ។ គេអាចដើរលេងរាល់យប់បាន ហើយគ្មានអ្នកណាស្តីឲ្យគេទេ សូម្បីតែឪពុកម្ដាយគេក៏គាត់មិនហ៊ានស្តីឲ្យផង។ ហេតុនេះហើយបានជាកូនសិស្សក្រៅសាលា ខ្លះរៀនមិនសូវពូកែ ប្រឡងច្រើនតែធ្លាក់ ខ្លះទៀតពូកែជាងកូនសិស្សក្នុងសាលា ព្រោះគេមិនសូវដើរលេង។

សរុបសេចក្ដីទៅ កូនសិស្សក្រៅសាលាមិនមែនជាកូនសិស្សអាក្រក់ទេ តែការខុសគ្នារវាងកូនសិស្សទាំងពីរផ្នែកនេះ គឺការសប្បាយ ការមានលុយ ការមានពេលមានម៉ោងត្រឹមត្រូវ។

## VOCABULARY

| | | |
|---|---|---|
| កុឡាប | kəlaap | rose |
| ក្រសួងឃោសនាការ | kəsuoŋ khohsnaa kaa | information department |
| ខេត្តក្រៅ | khaɛt kraw | the provinces, the provinces outside of Phnom Penh (R) |
| ខ្ចី | khcɛy | green (fruit), unripe, young (plant) |
| ខ្យល់ | khyɔl | wind, breeze |
| ឆៅ | chaw | raw |
| ឆ្អិន | chʔən | cooked |
| ដួល | duol | to fall down |
| ដើមផ្កា | daəm phkaa | flower plant |
| ដើមផ្កាកុឡាប | daəm phkaa kəlaap | rose plant |
| តែ | taɛ | tea (leaves) |
| ត្រឹមត្រូវ | trəm trəw | proper, correct (R) |
| ទាល់គំនិត | tóɔl kənit | to be speechless, to be lost |
| ទឹកតែ | tɨk taɛ | tea (liquid) |
| ទេសចរ | teehsəcɔɔ | tourist |
| ទុំ | túm | ripe |
| ន័យ | nɛy | meaning (R) |
| នៅ... នៅឡើយទេ | nɨw...nɨw laəy eh | still |
| នំបុ័ងដាក់សាច់ | numpaŋ daʔ sac | sandwich |
| ប៉ាតេ | pattee | paté, liverwurst |

| | | |
|---|---|---|
| បោះចោល | bɔh caol | to throw away |
| ប្រឡងធ្លាក់ | pəlɔɔŋ thlé? | to fail a test (R) |
| ប្រាក់ | pra? | silver |
| ផ្កា | phkaa | flower |
| ផ្ទុះ | phtuh | to explode |
| ពែង | pɛɛŋ | cup |
| ភ្នំបូកគោ | phnum bookkoo | Phnom Bokor |
| មិនថាតែ...ដែរ | mɨn thaa tə...daɛ | not only...but |
| យកខ្យល់អាកាស | yóo khyɔl aakah | to take the fresh air |
| យ៉ាងនេះហើយបានជា | yaaŋ nih haəy baan cia | this is why (L) |
| រលត់ | əlút | to be extinguished |
| រុយ | ruy | a fly |
| ល្ខោន | lkhaon | play |
| វត្ត | vót | pagoda, wat (Buddhist temple) |
| វត្តភ្នំ | vót phnum | Wat Phnom |
| វាំង | véŋ | palace |
| សន្លប់ | səlɔp | to faint |
| សរុបទៅ | sərop tɨw | in short, in brief (R) |
| សួនច្បារ | suon cbaa | garden |
| សំអាត | sə?aat | to clean (L) |
| ស្ដីឱ្យ | sdɛy aoy | to blame, to scold, to reprimand |



Wat Phnom

PASSAGE C

# អ្នកនិយាយបំផ្លើស

មានមួយថ្ងៃចៅនោះនឹងចៅនួនដើរទៅប្រទះនឹងចម្ការល្ពៅមួយ ។ ចៅនោះក្រឡេកទៅឃើញផ្លែល្ពៅ ហើយនិយាយទៅចៅនួនថា ចូរឯងមើលផ្លែល្ពៅនេះធំសំបើមអីម្ល៉េះ អញមិនដែលឃើញល្ពៅណាធំប៉ុណ្ណោះទេ ។ ចៅនួនដែលជាអ្នកតែងនិយាយបំផ្លើសក៏សើចហើយឆ្លើយតបទៅវិញថា ផ្លែល្ពៅប៉ុណ្ណោះហៅធំអ្វី មានម្ដងអញឃើញផ្លែល្ពៅមួយធំប៉ុនផ្ទះដែលយើងមើលទៅឃើញនៅឯណោះ ។



ចៅនោះញញឹមហើយនិយាយថា ពីថ្ងៃមុនអញបានឃើញថ្នាំងមួយ ថ្នាំងនោះធំប៉ុនសាលាឃុំនៅភូមិយើង ។ ចៅនួនក៏សួរទៅថាចុះថ្នាំងធំសំបើមយ៉ាងនេះគេសម្រាប់ប្រើធ្វើអ្វី ។ ចៅនោះឆ្លើយថា គេទុកសំរាប់ស្ងោរល្ពៅដែលឯងទើបនិយាយអំបាញ់មិញនេះ ។ ចៅនួនដឹងខ្លួនថាខ្លួននិយាយផ្ដាញ់ផ្ដាលឡើយ ក៏ប្រែជានិយាយពីអ្វីផ្សេងៗទៅវិញ ។

យើងត្រូវទំលាប់និយាយឲ្យទៀងទាត់ជាដរាប កាលណាយើងរ៉ាប់រៀប
អំពីការអ្វីមួយ ត្រូវកុំយកពាក្យកុហកមកបន្ថែមលើសេចក្តីពិត ។

| | | |
|---|---|---|
| បំផ្លើស | pəphləəh | to exaggerate |
| លើស | ləəh | to exceed |
| ប្រទះ(នឹង) | pətéh (nɨŋ) | to meet(unintentionally) |
| ល្ពៅ | lpɨw | pumpkin, squash |
| ក្រឡេក | kəleek | to look at |
| វិតង : វិតងវិតា | | |
| តប | tɔɔp | in return, back again |
| ប៉ុណ្ណេះ | pənnεh | this big |
| ប៉ុន | pɔn, pən | like, equivalent |
| ឯណោះ | aεnɔh | there |
| ញញឹម | ñəñɨm | to smile |
| ថ្លាង | thlaaŋ | a large, deep pot |
| សម្រាប់ប្រើធ្វើស្ល : ប្រើសម្រាប់ធ្វើស្ល | | |
| អំបាញ់មិញ | mbañ mɨñ | a moment ago, just then |
| ដឹងខ្លួន | dəŋ khluon | to be aware, to be conscious, to feel |
| គូកន | kuu kɔɔn | friend |
| ផ្ចាញ់ផ្ចាល់ | phcañ phcaal | to win an argument |
| ប្រែជា | praε cia | to change into, to change one s ways |
| ទំលាប់ | təlóp | to become accustomed to |
| ទៀងទាត់ | tieŋ tót | exact, precise, certain |
| ទៀង | tieŋ | exact, accurate |
| រ៉ាប់រៀប | róp riep | to recount, to tell in detail |
| កុហក | kəhɔɔʔ | a lie, to lie |
| បន្ថែម | pəthaεm | to add, to add something |

## LESSON FORTY-SIX

### DIALOGUE

| | | | |
|---|---|---|---|
| | | ធ្វើទាហាន | to serve in the armed forces |
| ១. | សុខ | លោកធ្វើទាហានប៉ុន្មានឆ្នាំហើយ? | How long have you been in the service? |
| ២. | កុម | បាទ ប្រហែលពីរឆ្នាំហើយ។ | About two years. |
| ៣. | សុខ | នៅសល់ប៉ុន្មានឆ្នាំទៀតបាន លោកចេញ? | How many more years before you leave it? |
| ៤. | កុម | ប្រហែលពីរឆ្នាំទៀត។ | Probably two more years. |
| ៥. | សុខ | មុនលោកចូលធ្វើទាហាន លោកធ្វើអី? | Before you were in the service, what did you do? |
| | | និស្សិត | university student |
| | | មហាវិទ្យាល័យ | university |
| ៦. | កុម | ខ្ញុំជានិស្សិតនៅមហាវិទ្យាល័យតាកែវ។ | I was a student at the University of Takeo. |
| ៧. | សុខ | លោកចូលចិត្តធ្វើទាហានទេ? | Do you like the service? |
| ៨. | កុម | បាទ | Yes. |
| | | រហូត | indefinitely, for good, all the way |
| ៩. | សុខ | អញ្ចឹងលោកនឹងធ្វើទាហានរហូត។ | So you'll be in the armed forces for good. |
| | | ពិតមែនតែ | (while) it is true that |
| ១០. | កុម | ពិតមែនតែខ្ញុំចូលចិត្តទាហាន (តែ) ខ្ញុំមិនធ្វើទាហានរហូតទេ។ | It is true that I like the service, but I won't serve in it forever. |
| ១១. | សុខ | ចេញទៅ លោកទៅធ្វើអី? | After the service, what are you going to do? |
| ១២. | កុម | ខ្ញុំទៅរៀនវិញ។ | I plan to go back to school. |

DIALOGUE:

1. sok - look thəə təhian pəmaan chnam əh?

2. tom - baat, pəhaɛl pii chnam əh

3. sok - nɨw sɔl pəmaan chnam tiet baan look cɛñ?

4. tom - pəhaɛl pii chnam tiet

5. sok - mun look coul thəə təhian, look thəə ɛy?

6. tom - khñom cia nihsət nɨw məhaavithialay takaɛv

7. sok - look coul cət thəə təhian tee?

8. tom - baat

9. sok - əñcəŋ look nɨŋ thəə təhian ləhout

10. tom - pɨt mɛɛn taɛ khñom coul cət təhian, (taɛ) khñom mɨn thəə təhian ləhout tee

11. sok - cɛñ tɨw, look tɨw thəə ɛy?

12. tom - khñom tɨw rien viñ

NOTES

DIALOGUE

SENTENCE NO.

9. រហូត /ləhout/ usually means 'all the way to the end' of a task or a given period. However, here it means 'indefinitely, forever.'

DRILLS

DRILL ONE. Substitution

MODEL. T. ខ្ញុំធ្វើទាហានជើងគោក។ (ជើងទឹក)
S. ខ្ញុំធ្វើទាហានជើងទឹក។

T. I'm in the army. (marines)
S. I'm in the marines.

ក. ខ្ញុំធ្វើទាហានជើងទឹក។ (នាវា)
ខ. ខ្ញុំធ្វើទាហាននាវា។ (អាកាស)
គ. ខ្ញុំធ្វើទាហានអាកាស។ (ថ្មើរជើង)
ឃ. ខ្ញុំធ្វើទាហានថ្មើរជើង។ (សេះ)
ង. ខ្ញុំធ្វើទាហានសេះ។ (ជើងគោក)
ច. ខ្ញុំធ្វើទាហានជើងគោក។

DRILL TWO: Substitution

MODEL: T: មុនខ្ញុំធ្វើទាហានខ្ញុំជាកូនសិស្ស។ (ប៉ូលិស)
S: មុនខ្ញុំធ្វើទាហានខ្ញុំជាប៉ូលិស។
T: Before I served in the service, I was a student. (police)
S: Before I served in the service, I was a policeman.

ក. មុនខ្ញុំធ្វើទាហានខ្ញុំជាប៉ូលិស។ (អ្នកបើកឡាន)
ខ. មុនខ្ញុំធ្វើទាហានខ្ញុំជាអ្នកបើកឡាន។ (ជាងឡាន)
គ. មុនខ្ញុំធ្វើទាហានខ្ញុំជាជាងឡាន។ (គ្រូបង្រៀន)
ឃ. មុនខ្ញុំធ្វើទាហានខ្ញុំជាគ្រូបង្រៀន។ (គ្រូពេទ្យ)
ង. មុនខ្ញុំធ្វើទាហានខ្ញុំជាគ្រូពេទ្យ។ (កូនសិស្ស)
ច. មុនខ្ញុំធ្វើទាហានខ្ញុំជាកូនសិស្ស។

DRILL THREE: Response

MODEL: T: លោកធ្វើទាហានប៉ុន្មានឆ្នាំហើយ? (បីឆ្នាំ)
S: ខ្ញុំធ្វើទាហានជិតបីឆ្នាំហើយ។
T: How long have you been in the service? (three years)
S: I've been in the service almost three years.

ក. លោកធ្វើអ្នកបើកឡានប៉ុន្មានឆ្នាំហើយ? (ពីរ)
ខ្ញុំធ្វើអ្នកបើកឡានជិតពីរឆ្នាំហើយ។
ខ. លោកធ្វើជាងឡានប៉ុន្មានឆ្នាំហើយ? (ប្រាំ)
ខ្ញុំធ្វើជាងឡានជិតប្រាំឆ្នាំហើយ។
គ. លោកធ្វើគ្រូពេទ្យប៉ុន្មានឆ្នាំហើយ? (ដប់)
ខ្ញុំធ្វើគ្រូពេទ្យជិតដប់ឆ្នាំហើយ។
ឃ. លោកធ្វើគ្រូបង្រៀនប៉ុន្មានឆ្នាំហើយ? (បួន)
ខ្ញុំធ្វើគ្រូបង្រៀនជិតបួនឆ្នាំហើយ។
ង. លោកធ្វើប៉ូលិសប៉ុន្មានឆ្នាំហើយ? (កន្លះឆ្នាំ)
ខ្ញុំធ្វើប៉ូលិសជិតកន្លះឆ្នាំហើយ។
ច. លោកធ្វើអ្នកបើកកប៉ាល់ហោះប៉ុន្មានឆ្នាំហើយ? (ប្រាំពីរ)
ខ្ញុំធ្វើអ្នកបើកកប៉ាល់ហោះជិតប្រាំពីរឆ្នាំហើយ។

DRILL FOUR: Response

MODEL: T: មុនធ្វើទាហានលោកដែលរៀនភាសាទេ?
S: មុនធ្វើទាហានខ្ញុំមិនដែលរៀនភាសាណាសោះ។
T: Before you were in the service, had you ever studied any language?
S: Before I was in the service, I had never studied any language at all.

ក. មុនធ្វើអ្នកបើកឡានលោកដែលធ្វើឡានទេ?
មុនធ្វើអ្នកបើកឡានខ្ញុំមិនដែលធ្វើឡាននោះ។
ខ. មុនធ្វើជាងឡានលោកដែលបើកឡានទេ?
មុនធ្វើជាងឡានខ្ញុំមិនដែលបើកឡាននោះ។
គ. មុនធ្វើគ្រូពេទ្យលោកដែលចាក់ថ្នាំទេ?
មុនធ្វើគ្រូពេទ្យខ្ញុំមិនដែលចាក់ថ្នាំនោះ។
ឃ. មុនធ្វើគ្រូបង្រៀនលោកដែលបង្រៀនទេ?
មុនធ្វើគ្រូបង្រៀនខ្ញុំមិនដែលបង្រៀននោះ។
ង. មុនធ្វើអ្នកបើកកប៉ាល់ហោះលោកដែលជិះកប៉ាល់ហោះទេ?
មុនធ្វើអ្នកបើកកប៉ាល់ហោះខ្ញុំមិនដែលជិះកប៉ាល់ហោះនោះ។
ច. មុនធ្វើប៉ូលិសលោកដែលបាញ់កាំភ្លើងទេ?
មុនធ្វើប៉ូលិសខ្ញុំមិនដែលបាញ់កាំភ្លើងនោះ។

DRILL FIVE: Response

MODEL: T: នៅសល់ប៉ុន្មានឆ្នាំទៀតលោកឈប់ធ្វើទាហាន? (បី)
S: នៅសល់បីឆ្នាំទៀត។
T: How many more years before you quit the service? (three)
S: Three more years.

ក. នៅសល់ប៉ុន្មានម៉ោងទៀតយើងចេញទៅផ្ទះ? (កន្លះ)
នៅសល់កន្លះម៉ោងទៀត។
ខ. នៅសល់ប៉ុន្មានថ្ងៃទៀតយើងចូលរៀន? (ដប់)
នៅសល់ដប់ថ្ងៃទៀត។
គ. នៅសល់ប៉ុន្មានខែទៀតទៅផ្ទះ? (បី)
នៅសល់បីខែទៀត។
ឃ. នៅសល់ប៉ុន្មានអាទិត្យទៀតលោកចាប់បង្រៀន? (បួន)
នៅសល់បួនអាទិត្យទៀត។
ង. នៅសល់ប៉ុន្មានឆ្នាំទៀតលោករៀនចប់? (មួយ)
នៅសល់មួយឆ្នាំទៀត។
ច. នៅសល់ប៉ុន្មានថ្ងៃទៀតលោកឈប់ធ្វើការ? (ដប់)
នៅសល់ដប់ថ្ងៃទៀត។

DRILL SIX: Response

MODEL: T: អញ្ចឹងលោកធ្វើទាហានរហូត?
S: ទេ ខ្ញុំមិនធ្វើទាហានរហូតទេ។
T: So, you'll be in the service forever?
S: No, I won't be in the service forever.

ក. អញ្ចឹងលោកធ្វើប៉ូលិសរហូត? ទេ ខ្ញុំមិនធ្វើប៉ូលិសរហូតទេ។
ខ. អញ្ចឹងលោកធ្វើអ្នកបើកឡានរហូត? ទេ ខ្ញុំមិនធ្វើអ្នកបើកឡានរហូតទេ។
គ. អញ្ចឹងលោកធ្វើកូនសិស្សរហូត? ទេ ខ្ញុំមិនធ្វើកូនសិស្សរហូតទេ។
ឃ. អញ្ចឹងលោកធ្វើជាងឡានរហូត? ទេ ខ្ញុំមិនធ្វើជាងឡានរហូតទេ។
ង. អញ្ចឹងលោកធ្វើអ្នកបើកកប៉ាល់ហោះរហូត? ទេ ខ្ញុំមិនធ្វើអ្នកបើកកប៉ាល់ហោះរហូតទេ។
ច. អញ្ចឹងលោកធ្វើគ្រូបង្រៀនរហូត? ទេ ខ្ញុំមិនធ្វើគ្រូបង្រៀនរហូតទេ។

DRILL SEVEN: Response

MODEL: T: អញ្ចឹងលោកចូលចិត្តប៉ូលិស។
S: ពិតមែនតែខ្ញុំចូលចិត្តប៉ូលិស ខ្ញុំមិនធ្វើប៉ូលិសរហូតទេ។
T: So, you like the police.
S: It is true that I like the police, but I won't be in the police forever.

ក. អញ្ចឹងលោកចូលចិត្តទាហាន។
ពិតមែនតែខ្ញុំចូលចិត្តទាហាន ខ្ញុំមិនធ្វើទាហានរហូតទេ។
ខ. អញ្ចឹងលោកចូលចិត្តបង្រៀន។
ពិតមែនតែខ្ញុំចូលចិត្តបង្រៀន ខ្ញុំមិនបង្រៀនរហូតទេ។
គ. អញ្ចឹងលោកចូលចិត្តធ្វើកូនសិស្ស។
ពិតមែនតែខ្ញុំចូលចិត្តធ្វើកូនសិស្ស ខ្ញុំមិនធ្វើកូនសិស្សរហូតទេ។
ឃ. អញ្ចឹងលោកចូលចិត្តបើកឡាន។
ពិតមែនតែខ្ញុំចូលចិត្តបើកឡាន ខ្ញុំមិនបើកឡានរហូតទេ។
ង. អញ្ចឹងលោកចូលចិត្តធ្វើគ្រូពេទ្យ។
ពិតមែនតែខ្ញុំចូលចិត្តធ្វើគ្រូពេទ្យ ខ្ញុំមិនធ្វើគ្រូពេទ្យរហូតទេ។
ច. អញ្ចឹងលោកចូលចិត្តធ្វើឡាន។
ពិតមែនតែខ្ញុំចូលចិត្តធ្វើឡាន ខ្ញុំមិនធ្វើឡានរហូតទេ។

DRILL EIGHT: Response

MODEL: T: ចេញពីកូនសិស្ស លោកទៅធ្វើអី? (ទាហាន)
S: ចេញពីកូនសិស្ស ខ្ញុំទៅធ្វើទាហាន។
T: After school, what are you going to do? (service)
S: After school, I'll go into the service.

ក. ចេញពីទាហាន លោកទៅធ្វើអី? (គ្រូពេទ្យ)
ចេញពីទាហានខ្ញុំទៅធ្វើគ្រូពេទ្យ។
ខ. ចេញពីគ្រូពេទ្យ លោកទៅធ្វើអី? (អ្នកបើកឡាន)
ចេញពីគ្រូពេទ្យខ្ញុំទៅធ្វើអ្នកបើកឡាន។
គ. ចេញពីអ្នកបើកឡាន លោកទៅធ្វើអី? (គ្រូបង្រៀន)
ចេញពីអ្នកបើកឡានខ្ញុំទៅធ្វើគ្រូបង្រៀន។

ឃ. ចេញពីគ្រូបង្រៀន លោកទៅធ្វើអី? (ប៉ូលិស)
ចេញពីគ្រូបង្រៀនខ្ញុំទៅធ្វើប៉ូលិស។
ង. ចេញពីប៉ូលិសលោកទៅធ្វើអី? (រៀន)
ចេញពីប៉ូលិសខ្ញុំទៅរៀន។
ច. ចេញពីរៀន លោកទៅធ្វើអី? (ទាហាន)
ចេញពីរៀនខ្ញុំទៅធ្វើទាហាន។

DRILL NINE: Response

MODEL: T: លោកនឹងធ្វើទាហានប៉ុន្មានឆ្នាំ? (មួយឆ្នាំ)
S: ខ្ញុំនឹងធ្វើទាហានតែមួយឆ្នាំទេ។
T: How long will you be in the service? (one year)
S: I'll be in the service for only one year.

ក. លោកនឹងធ្វើអ្នកបើកឡានប៉ុន្មានឆ្នាំ? (ប្រាំ)
ខ្ញុំនឹងធ្វើអ្នកបើកឡានតែប្រាំឆ្នាំទេ។
ខ. លោកនឹងធ្វើគ្រូបង្រៀនប៉ុន្មានឆ្នាំ? (ពីរ)
ខ្ញុំនឹងធ្វើគ្រូបង្រៀនតែពីរឆ្នាំទេ។
គ. លោកនឹងធ្វើគ្រូពេទ្យប៉ុន្មានឆ្នាំ? (ដប់)
ខ្ញុំនឹងធ្វើគ្រូពេទ្យតែដប់ឆ្នាំទេ។
ឃ. លោកនឹងធ្វើប៉ូលិសប៉ុន្មានឆ្នាំ? (បី)
ខ្ញុំនឹងធ្វើប៉ូលិសតែបីឆ្នាំទេ។
ង. លោកនឹងធ្វើជាងឡានប៉ុន្មានឆ្នាំ? (បួន)
ខ្ញុំនឹងធ្វើជាងឡានតែបួនឆ្នាំទេ។
ច. លោកនឹងធ្វើកូនសិស្សប៉ុន្មានឆ្នាំ? (ពីរ)
ខ្ញុំនឹងធ្វើកូនសិស្សតែពីរឆ្នាំទេ។

DRILL TEN: Substitution

MODEL: T: ខ្ញុំគ្មានឱកាសរៀនពេទ្យទេ។ (ទាហាន)
S: ខ្ញុំគ្មានឱកាសរៀនទាហានទេ។
T: I don't have time (the opportunity) to study medicine. (military matters)
S: I don't have time to study military matters.

ក. ខ្ញុំគ្មានឱកាសរៀនទាហានទេ។ (បើកឡាន)
ខ. ខ្ញុំគ្មានឱកាសរៀនបើកឡានទេ។ (បើកកប៉ាល់ហោះ)
គ. ខ្ញុំគ្មានឱកាសរៀនបើកកប៉ាល់ហោះទេ។ (ចាក់ថ្នាំ)
ឃ. ខ្ញុំគ្មានឱកាសរៀនចាក់ថ្នាំទេ។ (ធ្វើឡាន)
ង. ខ្ញុំគ្មានឱកាសរៀនធ្វើឡានទេ។ (ភាសាខ្មែរ)
ច. ខ្ញុំគ្មានឱកាសរៀនភាសាខ្មែរទេ។

DRILL ELEVEN: Substitution

MODEL: T: ប្រទេសខ្មែរចែកជាខេត្ត។ (ស្រុក)

S: ខេត្តចែកជាស្រុក។

T: Cambodia is divided into provinces. (districts)

S: A province is divided into districts.

ក. ប្រទេសខ្មែរចែកជាខេត្ត។ (ស្រុក)

ខ. ខេត្តចែកជាស្រុក។ (ឃុំ)

គ. ស្រុកចែកជាឃុំ។ (ភូមិ)

ឃ. ឃុំចែកជាភូមិ។

DRILL TWELVE: Substitution

MODEL: T: រាជការអនុញ្ញាតឱ្យយើងប្រើកន្លែងនេះ។ (ផ្លូវ)

S: រាជការអនុញ្ញាតឱ្យយើងប្រើផ្លូវនេះ។

T: The government permits us to use this place. (road)

S: The government permits us to use this road.

ក. រាជការអនុញ្ញាតឱ្យយើងប្រើផ្លូវនេះ។ (ម្ចាស់ភូមិ)

ខ. ម្ចាស់ភូមិអនុញ្ញាតឱ្យយើងប្រើផ្លូវនេះ។ (ហាមមិនឱ្យ)

គ. ម្ចាស់ភូមិហាមមិនឱ្យយើងប្រើផ្លូវនេះ។ (មេបញ្ជាក្រុម)

ឃ. មេបញ្ជាក្រុមហាមមិនឱ្យយើងប្រើផ្លូវនេះ។ (ជក់បារីនៅពេលយប់)

ង. មេបញ្ជាក្រុមហាមមិនឱ្យយើងជក់បារីនៅពេលយប់។ (ដើរ)

ច. មេបញ្ជាក្រុមហាមមិនឱ្យយើងដើរនៅពេលយប់។

## Reading Passage

### ទាហានខ្មែរ

ឥឡូវនេះ នៅស្រុកណាក៏ដូចស្រុកណាដែរ ការត្រូវការទាហានជាការចាំបាច់។ ហើយនៅស្រុកខ្លះ មនុស្សទាំងអស់ ទាំងស្រីទាំងប្រុស និងនៅស្រុកខ្លះទៀត តែ តែប្រុសៗទេ ត្រូវចូលធ្វើទាហានកាលណាគេដល់អាយុ។

ឯនៅស្រុកយើងវិញ លើកលែងតែឥឡូវនេះ ការចូលទាហានមិនជាការចាំបាច់ទេគឺអ្នកណាចង់ចូលក៏ចូលទៅនិងអ្នកណាមិនចង់ចូលក៏មិនចូលទៅ។ ពិតមែនតែគ្មានការបង្ខំក្នុងការចូលទាហានយ៉ាងនេះក៏ដោយ ទាហានយើងមិនដែលខ្វះមនុស្សទេ។ ជួនកាលយើងមានមនុស្សចង់ចូលច្រើនជាងយើងត្រូវការផង។ តែអ្នកដែលចូលទាហានមានហេតុខុសៗគ្នា។ អ្នកខ្លះធ្វើទាហានព្រោះគេចូលចិត្ត អ្នកខ្លះ ព្រោះគេមិនអាចរកការឯទៀតធ្វើបាននិងអ្នកខ្លះព្រោះគេមានរឿងផ្ទាល់ខ្លួន។ ឯអ្នកដែលមិនចូលទាហានវិញក៏មានហេតុខុសគ្នាដែរ។ អ្នកខ្លះមិនចូលទាហានព្រោះគេជឿថាទាហានមានគ្រោះថ្នាក់ណាស់ ហើយគេខ្លាចស្លាប់ អ្នកខ្លះ ព្រោះប្រាក់ខែមិន

ល្មម និងអ្នកខ្លះព្រោះគេគិតថាច្បាប់ទាហានពិបាកពេក។ តាមពិតរឿងចូលឬមិនចូលទាហានមានហេតុច្រើនទៀត តែហេតុទាំងប៉ុន្មានដែលបាននិយាយមកនេះគ្រាន់តែទូទៅជាងគេ។

យើងបានដឹងហើយថាការចូលទាហាននៅស្រុកយើងមិនជាការចាំបាច់ទេ ដូច្នេះការចេញពីទាហានក៏អាចធ្វើបានដែរ។ តែភាគច្រើន ច្រើនតែចូលហើយមិនចេញទេ គេធ្វើរហូត។

## VOCABULARY

| | | |
|---|---|---|
| កូនទាហាន | koun təhian | enlisted man (L) |
| ក្រៅពី | kraw pii | aside from (L) |
| ជក់ | cuoʔ | to suck, to smoke |
| ដល់អាយុ | dɔl aayuʔ | to come of age (R) |
| ថ្មើរ | thməə | (derivative of ដើរ /daə/ 'to walk' used only in a few idioms) |
| ទាហាន | təhian | soldier, military, armed forces |
| ទាហានជើងគោក | təhian cəəŋ kook | army |
| ទាហានថ្មើរជើង | təhian thməə cəəŋ | infantry |
| ទាហានជើងទឹក | təhian cəəŋ tɨk | marines |
| ទាហាននាវា | təhian niavia | navy |
| ទាហានសេះ | təhian sɛh | cavalry [1] |
| ទាហានអាកាស | təhian aakah | air force |
| ធ្វើទាហាន | thəə təhian | to serve in the armed services |
| នាយទាហាន | niey təhian | military officer (R) |
| នាយទាហានបំរុង | niey təhian bɔmrouŋ | reserve officer (L) |
| នាវា | niavia | ship |
| និស្សិត | nihsət | university student |
| ប្រាក់ខែ | praʔ khaɛ | salary, wage (R) |
| ពិតមែនតែ | pɨt mɛɛn taɛ | (while) it's true that |
| មហាវិទ្យាល័យ | məhaavithialay | university |
| មានឱកាស | mian əkah | to have the opportunity, to have time, to have occasion |
| រហូត | ləhout | indefinitely, all the way |
| សេះ | sɛh | horse |
| អាកាស | aakah | air |
| ឱកាស | əkah | occasion, opportunity |

1. The nearest equivalent in Cambodia to cavalry are ទាហានរថក្រោះ /təhian rút kruh/ 'armored vehicle forces.'

## LESSON FORTY-SEVEN

### DIALOGUE

| | | | |
|---|---|---|---|
| ១. | សុខ | លោកធ្វើទាហានមែនទេ? | You're in the service, aren't you? |
| ២. | តុម | បាទ ខ្ញុំជាទាហានជើងគោក។ | Yes, I'm in the army. |
| ៣. | សុខ | លោកចូលធ្វើទាហាននៅកន្លែងនេះតែម្ដងឬអី? | Did you join the service right here? |
| | | បញ្ជូន | to send (a person), to pass on |
| | | បន្ទាយ | barracks, fort, post |
| ៤. | តុម | ទេ គេបញ្ជូនខ្ញុំមកបន្ទាយនេះជិតពីរឆ្នាំហើយ។ | No, they sent me to this post about two years ago. |
| ៥. | សុខ | មុនលោកនៅឯណា? | Where were you before? |
| | | ប្រទេស | country (more formal than ស្រុក /srok/) |
| ៦. | តុម | បាទ នៅប្រទេសអាល្លឺម៉ង់។ | I was in Germany. |
| | | ពាក់សក្តិ | to have a rank |
| | | សក្តិ | rank, stripe; tatoo |
| ៧. | សុខ | លោកពាក់សក្តិប៉ុន្មាន? | What is your rank? |
| ៨. | តុម | បាទ សក្តិមួយ។ | Second lieutenant. |
| ៩. | សុខ | លោកចូលចិត្តទាហានទេ? | Do you like the army? |
| | | ស្អប់ | to hate, to dislike a lot |
| | | ច្បាប់ទំលាប់ | regulation, rule |
| ១០. | តុម | ខ្ញុំស្អប់ទាហានណាស់ ព្រោះគេមានច្បាប់ទំលាប់ច្រើនណាស់។ | I hate it, because there're a lot of regulations. |

DIALOGUE:

1. sok - look thəə təhian, mɛɛn tee?
2. tom - baat, khñom cia təhian cəəŋ kook
3. sok - look coul thəə təhian nɨw kəlaɛŋ nih taɛ mə dɔɔŋ rɨɨ ɛy?
4. tom - tee, kee pəcuun khñom móo pətiay nih cɨt pii chnam əh
5. sok - mun look nɨw aɛnaa?
6. tom - baat, nɨw pəteeh aallemɔŋ
7. sok - look pé? sa? pəmaan?
8. tom - baat, sa? muoy
9. sok - look coul cət təhian tee?
10. tom - khñom s?ɔp təhian nah, pruh kee mian cbap təlóp craən nah

## NOTES

## DIALOGUE

SENTENCE NO.

4. Note that the word ជូន /cuun/ 'to take a person somewhere' and បញ្ជូន /pəcuun/ 'to send someone somewhere' may be used with people with whom you are on formal and informal terms. Unlike ជូន /cuun/ 'to give; for, to,' these words may also be used with ខ្ញុំ /khñom/ 'I,' as in sentence 4.

7. The word ស័ក្តិ /saʔ/ literally means 'stripe,' so the question លោកពាក់ស័ក្តិប៉ុន្មាន/look péʔ saʔ pəmaan?/ means 'how many stripes do you wear?' It indicates that you are talking to an officer, since the ranks of officers lower than general are marked by the number of stripes they wear. The ranks are informally referred to by the number of stripes associated with them also, e.g.,

ខ្ញុំនិយាយជាមួយស័ក្តិបីម្នាក់នៅបន្ទាយ។
khñom niyiey ciamuoy saʔ bɛy mənéʔ nɨw pətiay
I spoke with a captain at the barracks.

The ranks and the number of stripes associated with them are:

| | | |
|---|---|---|
| Second Lieutenant | ស័ក្តិមួយ | /saʔ muoy/ |
| First Lieutenant | ស័ក្តិពីរ | /saʔ pii/ |
| Captain | ស័ក្តិបី | /saʔ bɛy/ |
| Major | ស័ក្តិបួន | /saʔ buon/ |
| Lieutenant Colonel | ស័ក្តិបួនកន្លះ | /saʔ buon kəlah/ |
| Colonel | ស័ក្តិប្រាំ | /saʔ pram/ |

Generals wear stars as badges of rank. Informally a general is referred to by the number of stars (ផ្កាយ /phkaay/) he wears:

| | | |
|---|---|---|
| Brigadier General | ផ្កាយមួយ | /phkaay muoy/ |
| Major General | ផ្កាយពីរ | /phkaay pii/ |
| Lieutenant General | ផ្កាយបី | /phkaay bɛy/ |
| General | ផ្កាយបួន | /phkaay buon/ |
| Marshal | ផ្កាយប្រាំ | /phkaay pram/ |

When you ask an enlisted man his rank, or if you do not know whether the soldier you are asking is an officer or an enlisted man, you ask

លោកពាក់អ្វី?
look péʔ ɛy?
What rank are you?

## DRILLS

DRILL NO.

1. ម្នាក់ៗ /mənéʔ mənéʔ/ 'each' is used with people. With things you say មួយៗ /muoy muoy/, as in Drill 3, or else ម៉ /mə/ + classifier repeated once, e.g. កាំភ្លើងមួយដើមៗត្រូវការសាមសិបគ្រាប់។

   kamphləəŋ mədaəm mədaəm trəw kaa saamsəp krop

   Each gun needs thirty bullets.

   (ដើម /daəm/ is the classifier for guns, sticks, trees, and other long, thin, sticklike objects.)

## DRILLS

DRILL ONE: Substitution

MODEL: T: យើងម្នាក់ៗរៀនបាញ់កាំភ្លើងដៃ។ (កាកាប៊ីន)

S: យើងម្នាក់ៗរៀនបាញ់កាំភ្លើងកាកាប៊ីន។

T: Each (one) of us practices shooting pistols. (carbines)

S: Each (one) of us practices shooting carbines.

ក. យើងម្នាក់ៗរៀនបាញ់កាំភ្លើងយន្ត។ (កាំភ្លើងយន្ត)

ខ. យើងម្នាក់ៗរៀនបាញ់កាំភ្លើងយន្ត។ (កាំភ្លើងស្វ័យប្រវត្តិ)

គ. យើងម្នាក់ៗរៀនបាញ់កាំភ្លើងស្វ័យប្រវត្តិ។ (កាណុង)

ឃ. យើងម្នាក់ៗរៀនបាញ់កាណុង។ (បាហ្ស៊ូកា)

ង. យើងម្នាក់ៗរៀនបាញ់បាហ្ស៊ូកា។ (កាំភ្លើងដៃ)

ច. យើងម្នាក់ៗរៀនបាញ់កាំភ្លើងដៃ។

DRILL TWO: Transformation

MODEL: T: លោកចេះបាញ់កាំភ្លើងដៃទេ?

S: ទាហានម្នាក់ៗរៀនបាញ់កាំភ្លើងដៃដប់ម៉ោង។

T: You know how to shoot a pistol?

S: Each soldier practices shooting a pistol for ten hours.

ក. លោកចេះបាញ់កាណុងទេ?
ទាហានម្នាក់រៀនបាញ់កាណុងដប់ម៉ោង។

ខ. លោកចេះបាញ់កាំភ្លើងកាកាប៊ីនទេ?
ទាហានម្នាក់ៗរៀនបាញ់កាំភ្លើងកាកាប៊ីនដប់ម៉ោង។

គ. លោកចេះបាញ់កាំភ្លើងយន្តទេ?
ទាហានម្នាក់ៗរៀនបាញ់កាំភ្លើងយន្តដប់ម៉ោង។

ឃ. លោកចេះបាញ់កាំភ្លើងបាញ់គ្រាប់បែកទេ?
ទាហានម្នាក់ៗរៀនបាញ់កាំភ្លើងបាញ់គ្រាប់បែកដប់ម៉ោង។

ង. លោកចេះបាញ់បាហ្ស៊ូកាទេ?
ទាហានម្នាក់ៗ រៀនបាញ់បាហ្ស៊ូកាដប់ម៉ោង។
ច. លោកចេះបាញ់កាំភ្លើងស្វ័យប្រវត្តិទេ?
ទាហានម្នាក់ៗរៀនបាញ់កាំភ្លើងស្វ័យប្រវត្តិដប់ម៉ោង។

DRILL THREE: Transformation

MODEL: T: ខ្ញុំរៀនបាញ់កាំភ្លើងដៃ។ (ដប់ពីរ)
S: កាំភ្លើងដៃមួយៗ មានដប់ពីរគ្រាប់។
T: I practiced shooting a pistol. (twelve)
S: Each pistol has twelve rounds.

ក. ខ្ញុំរៀនបាញ់កាណុង។ (មួយ) កាណុងមួយៗ មានមួយគ្រាប់។
ខ. ខ្ញុំរៀនបាញ់កាំភ្លើងយន្ត។ (សែសិប) កាំភ្លើងយន្តមួយៗ មានសែសិបគ្រាប់។
គ. ខ្ញុំរៀនកាំភ្លើងបាញ់គ្រាប់បែក។ (មួយ) កាំភ្លើងបាញ់គ្រាប់បែកមួយៗ មានមួយគ្រាប់។
ឃ. ខ្ញុំរៀនបាញ់កាកាប៊ីន។ (ម្ភៃ) កាកាប៊ីនមួយៗ មានម្ភៃគ្រាប់។
ង. ខ្ញុំរៀនបាញ់កាំភ្លើងស្វ័យប្រវត្តិ។ (សាមសិប) កាំភ្លើងស្វ័យប្រវត្តិមួយៗ មានសាមសិបគ្រាប់។
ច. ខ្ញុំរៀនបាញ់កាំភ្លើងដៃ។ (ដប់) កាំភ្លើងដៃមួយៗ មានដប់គ្រាប់។

DRILL FOUR: Transformation

MODEL: T: ខ្ញុំធ្វើទាហាននៅប្រទេសអាល្លឺម៉ង់។ (មួយឆ្នាំ)
S: គេបញ្ជូនខ្ញុំទៅប្រទេសអាល្លឺម៉ង់មួយឆ្នាំ។
T: I was in the service in Germany. (one year)
S: They sent me to Germany for one year.

ក. ខ្ញុំធ្វើទាហាននៅប្រទេសយួន។ (ដប់បួនខែ)
គេបញ្ជូនខ្ញុំទៅប្រទេសយួនដប់បួនខែ។
ខ. ខ្ញុំធ្វើទាហាននៅប្រទេសសៀម។ (ប្រាំឆ្នាំ)
គេបញ្ជូនខ្ញុំទៅប្រទេសសៀមប្រាំឆ្នាំ។
គ. ខ្ញុំធ្វើទាហាននៅប្រទេសបារាំង។ (ពីរឆ្នាំ)
គេបញ្ជូនខ្ញុំទៅប្រទេសបារាំងពីរឆ្នាំ។
ឃ. ខ្ញុំធ្វើទាហាននៅខេត្តកំពត។ (បីឆ្នាំ)
គេបញ្ជូនខ្ញុំទៅខេត្តកំពតបីឆ្នាំ។
ង. ខ្ញុំធ្វើទាហាននៅកន្លែងនេះ។ (ពីរខែ)
គេបញ្ជូនខ្ញុំទៅកន្លែងនេះពីរខែ។
ច. ខ្ញុំធ្វើទាហាននៅប្រទេសអាមេរិក។ (បួនឆ្នាំ)
គេបញ្ជូនខ្ញុំទៅប្រទេសអាមេរិកបួនឆ្នាំ។

DRILL FIVE: Response

MODEL: T: លោកនៅក្នុងបន្ទាយឬនៅក្រៅបន្ទាយ? (នៅលីវ)

S: ខ្ញុំនៅក្នុងបន្ទាយព្រោះខ្ញុំនៅលីវ។

T: Are you living on post or off post? (still single)

S: I'm living on post because I'm still single.

ក. លោកនៅក្នុងបន្ទាយឬនៅក្រៅបន្ទាយ? (កូនទាហាន)
ខ្ញុំនៅក្នុងបន្ទាយព្រោះខ្ញុំជាកូនទាហាន។

ខ. លោកនៅក្រៅបន្ទាយឬនៅក្នុងបន្ទាយ? (មានប្រពន្ធ)
ខ្ញុំនៅក្រៅបន្ទាយព្រោះខ្ញុំមានប្រពន្ធ។

គ. លោកនៅក្នុងបន្ទាយឬនៅក្រៅបន្ទាយ? (គ្មានលុយ)
ខ្ញុំនៅក្នុងបន្ទាយព្រោះខ្ញុំគ្មានលុយ។

ឃ. លោកនៅក្រៅបន្ទាយឬនៅក្នុងបន្ទាយ? (ទើបនឹងមកដល់)
ខ្ញុំនៅក្រៅបន្ទាយព្រោះខ្ញុំទើបនឹងមកដល់។

ង. លោកនៅក្រៅបន្ទាយឬក្នុងបន្ទាយ? (នៅតែបីខែ)
ខ្ញុំនៅក្រៅបន្ទាយព្រោះខ្ញុំនៅតែបីខែ។

ច. លោកនៅក្នុងបន្ទាយឬនៅក្រៅបន្ទាយ? (ជិតទៅស្រុកយួន)
ខ្ញុំនៅក្នុងបន្ទាយព្រោះខ្ញុំជិតទៅស្រុកយួន។

DRILL SIX: Response

MODEL: T: លោកពាក់សក្តិប៉ុន្មាន? (មួយ - ទាហានជើងគោក)

S: ខ្ញុំពាក់សក្តិមួយខាងទាហានជើងគោក។

T: What is your rank? (one - army)

S: I'm a 2nd lieutenant in the army.

ក. លោកពាក់សក្តិប៉ុន្មាន? (ពីរ - ទាហានអាកាស)
ខ្ញុំពាក់សក្តិពីរខាងទាហានអាកាស។

ខ. លោកពាក់អី? (កូនទាហាន - ទាហានជើងទឹក)
ខ្ញុំជាកូនទាហានខាងទាហានជើងទឹក។

គ. លោកពាក់អី? (កាប៉ូរ៉ាល់ - ទាហាននាវា)
ខ្ញុំពាក់កាប៉ូរ៉ាល់ខាងទាហាននាវា។

ឃ. លោកពាក់សក្តិប៉ុន្មាន? (បី - ទាហានសេះ)
ខ្ញុំពាក់សក្តិបីខាងទាហានសេះ។

ង. លោកពាក់សក្តិប៉ុន្មាន? (បួន - ទាហានថ្មើរជើង)
ខ្ញុំពាក់សក្តិបួនខាងទាហានថ្មើរជើង។

ច. លោកពាក់សក្តិប៉ុន្មាន? (ប្រាំ - ជើងគោក)
ខ្ញុំពាក់សក្តិប្រាំខាងទាហានជើងគោក។

DRILL SEVEN: Response

MODEL: T: លោកធ្វើអីនៅក្នុងក្រុមទាហានលោក? (កូនទាហាន)
S: ខ្ញុំជាកូនទាហាននៅក្នុងក្រុមទាហានខ្ញុំ។
T: What are you in your platoon? (enlisted man)
S: I'm an enlisted man in my platoon.

ក. លោកធ្វើអីនៅក្នុងក្រុមទាហានលោក? (មេដឹកនាំ)
ខ្ញុំជាមេដឹកនាំនៅក្នុងក្រុមទាហានខ្ញុំ។
ខ. លោកធ្វើអីនៅក្នុងក្រុមទាហានលោក? (អ្នកបាញ់កាំភ្លើង)
ខ្ញុំជាអ្នកបាញ់កាំភ្លើងនៅក្នុងក្រុមទាហានខ្ញុំ។
គ. លោកធ្វើអីនៅក្នុងក្រុមទាហានលោក? (នាយទាហាន)
ខ្ញុំជានាយទាហាននៅក្នុងក្រុមទាហានខ្ញុំ។
ឃ. លោកធ្វើអីនៅក្នុងក្រុមទាហានលោក? (មេបញ្ជាការ)
ខ្ញុំជាមេបញ្ជាការនៅក្នុងក្រុមទាហានខ្ញុំ។
ង. លោកធ្វើអីនៅក្នុងក្រុមទាហានលោក? (អ្នកបើកឡាន)
ខ្ញុំជាអ្នកបើកឡាននៅក្នុងក្រុមទាហានខ្ញុំ។
ច. លោកធ្វើអីនៅក្នុងក្រុមទាហានលោក? (ជួសឡាន)
ខ្ញុំជាអ្នកជួសឡាននៅក្នុងក្រុមទាហានខ្ញុំ។

DRILL EIGHT: Response

MODEL: T: លោកពាក់សក្តិមួយប៉ុន្មានឆ្នាំហើយ?
S: ខ្ញុំពាក់សក្តិមួយពីរឆ្នាំហើយ។
T: How long have you been a 2nd lieutenant? (two)
S: I've been a 2nd lieutenant two years.

ក. លោកជាកូនទាហានប៉ុន្មានឆ្នាំហើយ? (កន្លះឆ្នាំ)
ខ្ញុំជាកូនទាហានកន្លះឆ្នាំហើយ។
ខ. លោកជាមេបញ្ជាការប៉ុន្មានឆ្នាំហើយ? (បី)
ខ្ញុំជាមេបញ្ជាការបីឆ្នាំហើយ។
គ. លោកបើកឡានទាហានប៉ុន្មានឆ្នាំហើយ? (មួយឆ្នាំ)
ខ្ញុំបើកឡានទាហានមួយឆ្នាំហើយ។
ឃ. លោកផ្លាស់ទៅស្រុកអាល្លឺម៉ង់ប៉ុន្មានឆ្នាំហើយ? (ពីរ)
ខ្ញុំផ្លាស់ទៅស្រុកអាល្លឺម៉ង់ពីរឆ្នាំហើយ។
ង. លោកពាក់សក្តិបីប៉ុន្មានឆ្នាំហើយ? (ប្រាំ)
ខ្ញុំពាក់សក្តិបីប្រាំឆ្នាំហើយ។
ច. លោកជាមេទាហានប៉ុន្មានឆ្នាំហើយ? (ម្ភៃ)
ខ្ញុំជាមេទាហានម្ភៃឆ្នាំហើយ។

DRILL NINE: Response

MODEL: T: លោកចូលចិត្តកន្លែងនេះទេ? (បន្ទាយខ្ញុំ)
S: ទេ ព្រោះខ្ញុំស្អប់បន្ទាយខ្ញុំ។
T: Do you like this place? (my post)
S: No, because I hate my post.

ក. លោកចូលចិត្តបន្ទាយលោកទេ? (ទាហាន)
ទេ ព្រោះខ្ញុំស្អប់ទាហាន។
ខ. លោកចូលចិត្តទាហានទេ? (ក្រុមទាហានខ្ញុំ)
ទេ ព្រោះខ្ញុំស្អប់ក្រុមទាហានខ្ញុំ។
គ. លោកចូលចិត្តក្រុមទាហានលោកទេ? (ច្បាប់ទម្លាប់ទាហាន)
ទេ ព្រោះខ្ញុំស្អប់ច្បាប់ទម្លាប់ទាហាន។
ឃ. លោកចូលចិត្តច្បាប់ទម្លាប់ទាហានទេ? (មេដឹកនាំខ្ញុំ)
ទេ ព្រោះខ្ញុំស្អប់មេដឹកនាំខ្ញុំ។
ង. លោកចូលចិត្តមេដឹកនាំលោកទេ? (នាយទាហាន)
ទេ ព្រោះខ្ញុំស្អប់នាយទាហាន។
ច. លោកចូលចិត្តនាយទាហានលោកទេ? (ខោអាវនាយទាហាន)
ទេ ព្រោះខ្ញុំស្អប់ខោអាវនាយទាហាន។

DRILL TEN: Transformation

MODEL: T: យើងត្រូវរៀនបាញ់កាំភ្លើង។ (ពីរម៉ោងមួយថ្ងៃ)
S: យើងត្រូវរៀនបាញ់កាំភ្លើងពីរម៉ោងមួយថ្ងៃ។
T: We have to practice shooting rifles. (two hours a day)
S: We have to practice shooting rifles two hours a day.

ក. យើងត្រូវរៀនលាងកាំភ្លើង។ (មួយដងមួយអាទិត្យ)
យើងត្រូវរៀនលាងកាំភ្លើងមួយដងមួយអាទិត្យ។
ខ. យើងត្រូវរៀនដើរ។ (ប្រាំដងមួយអាទិត្យ)
យើងត្រូវរៀនដើរប្រាំដងមួយអាទិត្យ។
គ. យើងត្រូវរៀនបាញ់កាំភ្លើងបាញ់គ្រាប់បែក។ (មួយដងមួយអាទិត្យ)
យើងត្រូវរៀនបាញ់កាំភ្លើងបាញ់គ្រាប់បែកមួយដងមួយអាទិត្យ។
ឃ. យើងត្រូវរៀនជើកាំភ្លើង។ (មួយដងមួយខែ)
យើងត្រូវរៀនជើកាំភ្លើងមួយដងមួយខែ។
ង. យើងត្រូវរៀនបាញ់កាំភ្លើងយន្ត។ (មួយដងមួយថ្ងៃ)
យើងត្រូវរៀនបាញ់កាំភ្លើងយន្តមួយដងមួយថ្ងៃ។
ច. យើងត្រូវរៀនរត់។ (ពីរម៉ោងមួយថ្ងៃ)
យើងត្រូវរៀនរត់ពីរម៉ោងមួយថ្ងៃ។

DRILL ELEVEN: Transformation

MODEL: T: អ្នកភៀសខ្លួនចង់ទៅនៅកន្លែងឯទៀត។
S: ដល់ថ្នាក់ "ហ្នឹងហើយអ្នកភៀសខ្លួនចង់ទៅនៅកន្លែងឯទៀតហើយ។
T: The refugees want to live in another place.
S: At this stage the refugees want to live in another place.

ក. ខ្ញុំចង់បង្រៀនខ្មែរទៀត។
ដល់ថ្នាក់ហ្នឹងហើយខ្ញុំចង់បង្រៀនខ្មែរទៀតហើយ។
ខ. ខ្ញុំចង់ត្រឡប់ទៅភូមិនោះវិញ។
ដល់ថ្នាក់ហ្នឹងហើយខ្ញុំចង់ត្រឡប់ទៅភូមិនោះវិញហើយ។
គ. ខ្ញុំចង់ធ្វើការនៅក្នុងពេទ្យ។
ដល់ថ្នាក់ហ្នឹងហើយខ្ញុំចង់ធ្វើការនៅក្នុងពេទ្យហើយ។
ឃ. ខ្ញុំចង់ជក់បារី។
ដល់ថ្នាក់ហ្នឹងហើយខ្ញុំចង់ជក់បារីហើយ។
ង. ខ្ញុំចង់ធ្វើការឲ្យរាជការទៀត។
ដល់ថ្នាក់ហ្នឹងហើយខ្ញុំចង់ធ្វើការឲ្យរាជការទៀតហើយ។
ច. ខ្ញុំចង់ជួបគាត់ទៀត។
ដល់ថ្នាក់ហ្នឹងហើយខ្ញុំចង់ជួបគាត់ទៀតហើយ។

DRILL TWELVE: Transformation

MODEL: T: នេះជាបញ្ហារបស់លោក។ (លោក)
S: នេះជាបញ្ហារបស់អ្នកណា?
T: This is your problem. (your)
S: This is whose problem?

ក. អ្នកភៀសខ្លួនត្រូវជួយមើលអ្នកជម្ងឺ។ (អ្នកភៀសខ្លួន)
អ្នកណាត្រូវជួយមើលអ្នកជម្ងឺ?
ខ. លោកជិមភៀសខ្លួនពីប្រទេសគាត់។ (លោកជិម)
អ្នកណាភៀសខ្លួនពីប្រទេសគាត់?
គ. លោកមិនត្រូវទុកចិត្តអ្នកស្រុកទេ។ (អ្នកស្រុក)
លោកមិនត្រូវទុកចិត្តអ្នកណា?
ឃ. លោកមេបញ្ជាការពេញចិត្តនឹងកូនទាហានគាត់ណាស់។ (កូនទាហានគាត់)
លោកមេបញ្ជាការពេញចិត្តនឹងអ្នកណា?
ង. នាយទាហានហាមកូនទាហានមិនឲ្យដើរចោលកាំភ្លើង។ (នាយទាហាន)
អ្នកណាហាមកូនទាហានមិនឲ្យដើរចោលកាំភ្លើង?
ច. គ្រូពេទ្យមិនឲ្យអ្នកជម្ងឺដើរឆ្ងាយពីគ្រែទេ។ (អ្នកជម្ងឺ)
គ្រូពេទ្យមិនឲ្យអ្នកណាដើរឆ្ងាយពីគ្រែ?

DRILL THIRTEEN: Substitution

MODEL: T: ខ្ញុំបញ្ជា ឲ្យក្រុមកាំភ្លើងធំបាញ់ទៅលើទីរបស់ខ្មាំង ។ (ឡាន)
S: ខ្ញុំបញ្ជា ឲ្យក្រុមកាំភ្លើងធំបាញ់ទៅលើឡានខ្មាំង ។
T: I order the Artillery to shoot at the enemy location. (vehicles)
S: I order the Artillery to shoot at the enemy vehicles.

ក. ខ្ញុំបញ្ជាឲ្យក្រុមកាំភ្លើងធំបាញ់ទៅលើឡានខ្មាំង ។ (កាណុត)
ខ. ខ្ញុំបញ្ជាឲ្យក្រុមកាំភ្លើងធំបាញ់ទៅលើកាណុតខ្មាំង ។ (មេបញ្ជាការ)
គ. មេបញ្ជាការបញ្ជាឲ្យក្រុមកាំភ្លើងធំបាញ់ទៅលើកាណុតខ្មាំង ។ (ពលបាលជួន)
ឃ. មេបញ្ជាការបញ្ជាឲ្យពលបាលជួនបាញ់ទៅលើកាណុតខ្មាំង ។ (យក)
ង. មេបញ្ជាការបញ្ជាឲ្យពលបាលជួនយកកាណុតខ្មាំង ។ (ដុត)
ច. មេបញ្ជាការបញ្ជាឲ្យពលបាលជួនដុតកាណុតខ្មាំង ។

## Reading Passage

### ខ្ញុំចូលធ្វើទាហានបំរុង

នៅពេលដែលខ្ញុំរៀនចប់នៅវិទ្យាល័យបារាំងមួយនៅទីក្រុងភ្នំពេញ ខ្ញុំត្រូវរកការងារធ្វើដូចមនុស្សឯទៀត ឬកូនសិស្សឯទៀតដែរ ។ ព្រោះខ្ញុំមិនចង់ចូលធ្វើទាហានដូចពួកម៉ាកខ្ញុំខ្លះទៀតដែលចូលធ្វើទាហាន ដូចជាទាហានអាកាស ទាហានជើងទឹក ដែលបានទៅរៀនវិជ្ជាទាហាននៅស្រុកបារាំង ហើយម្យ៉ាងទៀតដោយខ្ញុំមិនសូវមានលុយដើម្បីទៅរៀនថែមទៀតនៅស្រុកបារាំង ខ្ញុំក៏ប្រឡងចូលធ្វើការនៅក្រសួងគយ ។ ខ្ញុំធ្វើការនៅក្រសួងនេះបានប្រហែលជាងមួយឆ្នាំ ខ្ញុំក៏បានទទួលសំបុត្រពីរដ្ឋាភិបាលមួយប្រាប់ឲ្យខ្ញុំទៅបង្ហាញខ្លួននៅមន្ទីរបញ្ជាការទាហាននៅទីក្រុងភ្នំពេញ ដើម្បីនិយាយអំពីការចូលធ្វើទាហានបំរុង ។ នៅពេលមើលសំបុត្រនោះចប់ ខ្ញុំមិនសប្បាយចិត្តសោះ ព្រោះខ្ញុំដឹងថាការរៀនវិជ្ជាទាហានក្នុងពេលមួយយ៉ាងខ្លីនេះវាពិបាកណាស់ ហើយម្យ៉ាងទៀតខ្ញុំមិនចង់ចេញពីកន្លែងធ្វើការខ្ញុំផង ។

នៅថ្ងៃដែលគេប្រាប់ខ្ញុំឲ្យទៅជួប ខ្ញុំក៏ទៅជួបគេ ។ យើងនិយាយគ្នាអំពីមុខងារទាហានទូទៅ អំពីប្រទេសយើង អំពីការងារចាស់របស់ខ្ញុំ អស់ប្រហែលជាងពីរម៉ោង ។ ក្នុងចិត្តខ្ញុំ ខ្ញុំដឹងថាខ្ញុំគ្មានផ្លូវទេ គឺខ្ញុំត្រូវតែចូលធ្វើទាហាន ចូលចិត្តក៏ដោយ មិនចូលចិត្តក៏ដោយ ។ នៅពេលយើងនិយាយគ្នាចប់ គេក៏ប្រាប់ខ្ញុំថាខ្ញុំត្រូវចូលធ្វើទាហានបំរុង ពីព្រោះខ្ញុំត្រូវធ្វើតែមួយឆ្នាំកន្លះទេ ហើយនៅពេលខ្ញុំចេញពីទាហាន ខ្ញុំអាចត្រឡប់ទៅធ្វើការនៅកន្លែងដដែលវិញ ប៉ុន្តែមានដំណឹងអាក្រក់មួយ គឺកាលណាប្រទេសយើងមានចម្បាំង រដ្ឋាភិបាលនឹងហៅទាហានបំរុងឲ្យចូលធ្វើទាហានវិញមុនគេ ។

ខ្ញុំក៏ចុះឈ្មោះចូលធ្វើទាហានបំរុងមួយឆ្នាំកន្លះ ហើយគេក៏ប្រាប់ខ្ញុំនូវថ្ងៃខែ ដែលខ្ញុំត្រូវចូលទៅបង្ហាញខ្លួនជាលើកក្រោយ ដើម្បីនឹងចូលសាលារៀនវិជ្ជាទាហាននៅទីក្រុងភ្នំពេញ ។

VOCABULARY

| | | |
|---|---|---|
| ... ក៏ដោយ ... ក៏ដោយ | ...kɔɔ daoy...kɔɔ daoy | whether...or... (R) |
| កូនទាហាន | koun təhian | enlisted man |
| ក្រុមទាហាន | krom təhian | platoon |
| ក្រៅ | kraw | outside, out |
| គយ | kóoy | customs (R) |
| គោរព | kərup | to respect, to honor (L) |
| គ្មានផ្លូវ | kmian phləw | there is no way, no chance (R) |
| គ្រាប់ | króp | round (pertaining to ammunition) |
| ចោល | caol | to throw away, to abandon |
| ច្បាប់ទម្លាប់ | cbap təlóp | regulation |
| ជំនាន់ | cənón | generation, age-group; period; era (L) |
| ញញឹម | ñəñɨm | to smile (L) |
| ដល់ថ្នាក់នឹងហើយ | dɔl thnaʔ nɨŋ haɛy | at that stage, at that point |
| ដើម | daəm | stem, classifier for guns, pencils, cigarettes, trees and other long, thin objects |
| តឹង | təŋ | tight, strict (L) |
| ទី | tii | a place |
| ទុកចិត្ត(លើ) | tuk cət (ləə) | to trust |
| ធ្វើ(ជា) | thəə (cia) | to pretend (L) |
| នាយទាហាន | niey təhian | officer |
| នូវ | nəw | a particle that can precede the object of a verb (literary) (R) |
| បន្ទាយ | pətiay | barracks |
| បញ្ជូន | pəcuun | to send (a person) |
| បោក | baok | to beat; to wash clothing (L) |
| ផ្កាយ | phkaay | star |
| ផ្លាស់ | phlah | to transfer, to change |
| ពាក់សក្តិ | péʔ saʔ | to have a rank |
| មន្ទីរចាត់ការ | məntii cat kaa | headquarters (R) |
| មួយៗ | muoy muoy | each one (object) |
| មេដឹកនាំ | mee dək nóm | leader |
| មេបញ្ជាការ | mee bañcia kaa | commander |
| ម្នាក់ៗ | məné̀ʔ məné̀ʔ | each one (person) |
| លើក | ləək | time, instance (R) |
| វិជ្ជា | viccia | knowledge, subject of, science of, -ology (R) |
| សក្តិ | saʔ | rank |
| ស្វ័យប្រវត្តិ | svaay pəvót | automatic |
| ស្អប់ | sʔɔp | to hate, to dislike |
| អ្នកភៀសខ្លួន | néʔ phieh khluon | refugee |

## LIST OF RANKS: OFFICERS
## (ARMY, AIR FORCE, MARINES)

| | | |
|---|---|---|
| 2nd Lt. | អនុសេនីយត្រី | a'nu'seenεy trεy |
| 1st Lt. | អនុសេនីយទោ | a'nu'seenεy too |
| Captain | អនុសេនីយឯក | a'nu'seenεy aεk |
| Major | វរសេនីយត្រី | vóora'seenεy trεy |
| Lt. Colonel | វរសេនីយទោ | vóora'seenεy too |
| Colonel | វរសេនីយឯក | vóora'seenεy aεk |
| Br. General | ឧត្តមសេនីយត្រី | útdomseenεy trεy |
| Maj. General | ឧត្តមសេនីយទោ | útdomseenεy too |
| Lt. General | ឧត្តមសេនីយឯក | útdomseenεy aεk |
| General | ឧត្តមសេនីយ | útdomseenεy |
| Marshall | សេនាប្រមុខ | seenaa prɔmuk |

## FIREARMS

| | | |
|---|---|---|
| rifle, firearm, gun | កាំភ្លើង | kamphləəŋ |
| pistol | កាំភ្លើងដៃ | kamphləəŋ day |
| carbine | ការាប៊ីន | kaaraabiin |
| bazooka | បាហ្ស៊ូកា | baazuukaa |
| machine gun | កាំភ្លើងយន្ត | kamphləəŋ yɔn |
| automatic gun | កាំភ្លើងស្វ័យប្រវត្តិ | kamphləəŋ svaay pəvót |
| cannon | កាណុង | kaanoŋ |
| grenade launcher | កាំភ្លើងបាញ់គ្រាប់បែក | kamphləəŋ bañ króp baεk |

# LESSON FORTY-EIGHT

## DIALOGUE

| | | | |
|---|---|---|---|
| | | ក្រុម | group, squad |
| ១. | សុខ | លោកធ្វើអីនៅក្នុងក្រុមលោក? | What is your job in your squad? |
| | | ជញ្ជូន | to transport |
| | | ទ័ព | troops |
| | | កង | military unit |
| | | កងអនុសេនាតូច | platoon |
| ២. | កុម | ខ្ញុំជាអ្នកបើកឡានជញ្ជូនទ័ព ក្នុងកងអនុសេនាតូចលេខពីរ ។ | I drive trucks to transport troops in the squad no 2. |
| | | ដឹក | to transport |
| ៣. | សុខ | លោកដឹកទាហានពីកន្លែងណាទៅកន្លែងណា? | You transport troops from where to where? |
| | | ហាត់ | to practice, to drill |
| ៤. | កុម | ពីបន្ទាយទៅកន្លែងហាត់បាញ់ ។ | From the post to the place where they practice shooting. |
| ៥. | សុខ | ធម្មតាគេប្រើឡានអី? | What kind of trucks do they usually use? |
| | | ឡានកង់ដប់ | 10-wheel truck |
| ៦. | កុម | ឡានកង់ដប់ ។ | The 10-wheel ones. |
| | | មួយជើង | one trip |
| ៧. | សុខ | មួយជើងៗ លោកជញ្ជូនបានប៉ុន្មាននាក់? | Each trip, how many men can you transport? |
| | | ទៀង | to be accurate |
| | | មិនទៀងទេ | it depends; uncertain |
| ៨. | កុម | មិនទៀងទេ ។ | It depends. |
| | | ចំបាំង | war, fighting |
| ៩. | សុខ | លោកដែលដឹកទ័ពទៅធ្វើចំបាំងទេ? | Had you ever transported troops to war? |
| | | ជាពិសេស | especially |
| ១០. | កុម | ទេលោក ជាពិសេសខ្ញុំមិនចង់សោះ ។ | No sir, especially (since) I don't want to at all. |

DIALOGUE:

1. sok - look thəə ɛy nɨw knoŋ krom look?
2. tom - khñom cia néʔ baək laan əñcuun tóp knoŋ kooŋ aʔnuʔseenaa touc leek pii
3. sok - look dək təhian pii kəlaɛŋ naa tɨw kəlaɛŋ naa?
4. tom - pii pətiay tɨw kəlaɛŋ hat bañ
5. sok - thómmədaa kee praə laan ɛy?
6. tom - laan kɔŋ dɔp
7. sok - mə cəəŋ mə cəəŋ, look əñcuun baan pəmaan néʔ?
8. tom - mɨn tieŋ eh
9. sok - look daɛl dək tóp tɨw thəə cəbaŋ tee?
10. tom - tee look, cia pəsɛh khñom mɨn cɔŋ sɔh

NOTES

DIALOGUE

SENTENCE NO.

7. មួយជើងៗ /mə cəəŋ mə cəəŋ/ 'each trip' is another example of the
ម្នាក់ៗ /mənéʔ mənéʔ/ structure described in the preceding lesson.

7. You have already seen that បាន /baan/ can be used before expressions of time and distance to indicate extent, e.g.,

យើងទៅភ្នំពេញបានបួនអាទិត្យ

yəəŋ tɨw mpɨñ baan buon aatɨt

We went to Phnom Penh for four weeks.

Here you see that បាន /baan/ can be used in the same way with objects, e.g.,

យើងដឹកឥវ៉ាន់បានមួយម៉ឺនគីឡូ

yəəŋ dək ɛyvan baan mə məən kəlou

We transported ten thousand kilos of things.

DRILLS

DRILL NO.

4. Sentence d As you already know, with ឲ្យ /aoy/ and other verbs that can have an indirect object, the direct object precedes the indirect object. However, when there is a quantity also present, the expression of quantity follows the indirect object. For example:

គេឲ្យលុយយើងប៉ុន្មានរៀល?

kee aoy luy yəəŋ pəmaan riel?

How many riels did they give us?

In this example ប៉ុន្មានរៀល /pəmaan riel/ is the expression of quantity, which follows both the direct object លុយ /luy/ 'money' and the indirect object យើង /yəəŋ/ 'us.'

## DRILLS

DRILL ONE: Response

MODEL: T: លោកជាអ្នកបើកឡាន មែនទេ?
S: បាទ ខ្ញុំជាអ្នកបើកឡានមែន។
T: You are a driver, aren't you?
S: Yes, it's true, I am indeed a driver.

ក. ប្អូនលោកជាទាហានជើងគោក មែនទេ?
បាទ ប្អូនខ្ញុំជាទាហានជើងគោកមែន។
ខ. ឪពុកលោកជាមេបញ្ជាការ មែនទេ?
បាទ ឪពុកខ្ញុំជាមេបញ្ជាការមែន។
គ. គាត់ជាលោកសក្តិប្រាំ មែនទេ?
បាទ គាត់ជាលោកសក្តិប្រាំមែន។
ឃ. លោកនៅក្នុងកងអនុសេនាតូចលេខពីរ មែនទេ?
បាទ ខ្ញុំនៅក្នុងកងអនុសេនាតូចលេខពីរមែន។
ង. ឪពុកលោកជាលោកផ្កាយមួយ មែនទេ?
បាទ ឪពុកខ្ញុំជាលោកផ្កាយមួយមែន។
ច. លោកជាទាហានជើងទឹក មែនទេ?
បាទ ខ្ញុំជាទាហានជើងទឹកមែន។

DRILL TWO: Substitution

MODEL: T: ក្រុមខ្ញុំឈ្មោះកងអនុសេនាតូចលេខពីរ។ (លេខដប់)
S: ក្រុមខ្ញុំឈ្មោះកងអនុសេនាតូចលេខដប់។
T: My unit is the squad no 2. (number ten)
S: My unit is the squad no 10.

ក. ក្រុមខ្ញុំឈ្មោះកងអនុសេនាតូចលេខដប់។ (កងយកការសម្ងាត់)
ខ. ក្រុមខ្ញុំឈ្មោះកងយកការសម្ងាត់។ (កងអនុសេនាធំលេខដប់)
គ. ក្រុមខ្ញុំឈ្មោះកងអនុសេនាធំលេខដប់។ (យើង)
ឃ. ក្រុមយើងឈ្មោះកងអនុសេនាធំលេខដប់។ (កងវរសេនាតូច)
ង. ក្រុមយើងឈ្មោះកងវរសេនាតូចលេខដប់។ (ធំ)
ច. ក្រុមយើងឈ្មោះកងវរសេនាធំលេខដប់។

DRILL THREE: Response

MODEL: T: លោកដឹកទាហានពីកន្លែងណាទៅកន្លែងណា? (បន្ទាយ - សាលា)
S: បាទ ដឹកពីបន្ទាយទៅសាលា។

T: From where to where do you transport troops? (barracks - school)

S: From the barracks to school.

ក. លោកជញ្ជូនទាហានពីណាទៅណា? (បន្ទាយ - កន្លែងហាត់បាញ់)
បាទ ជញ្ជូនពីបន្ទាយទៅកន្លែងហាត់បាញ់។

ខ. លោកបើកឡានពីណាទៅណា? (បន្ទាយ - ជំរុំកងអនុសេនាតូចលេខពីរ)
បាទ បើកពីបន្ទាយទៅជំរុំកងអនុសេនាតូចលេខពីរ។

គ. យើងត្រូវដើរពីកន្លែងណាទៅណា? (បន្ទាយ - ភ្នំលេខ ១៦៤)
បាទ ត្រូវដើរពីបន្ទាយទៅភ្នំលេខ ១៦៤។

ឃ. លោកដើរពីកន្លែងណាទៅកន្លែងណា? (បន្ទាយ - ផ្លូវកែងលេខបី)
បាទ ដើរពីបន្ទាយទៅផ្លូវកែងលេខបី។

ង. ខ្មាំងដឹកទ័ពពីកន្លែងណាទៅកន្លែងណា? (ព្រំដែន - ភ្នំលេខ ១៦៤)
បាទ ដឹកទ័ពពីព្រំដែនទៅភ្នំលេខ ១៦៤។

ច. លោកដើរពីកន្លែងណាទៅកន្លែងណា? (បន្ទាយ - សាលា)
បាទ ដើរពីបន្ទាយទៅសាលា។

DRILL FOUR: Response

MODEL: T: មួយជើងលោកជញ្ជូនបានប៉ុន្មាននាក់? (ដប់)
S: មួយជើងខ្ញុំជញ្ជូនបានដប់នាក់។

T: Each trip how many men can you transport? (ten)

S: Each trip I can transport ten men.

ក. មួយជើងលោកយកកា៉លីសបានប៉ុន្មាន? (បី)
មួយជើងខ្ញុំយកបានកា៉លីសបី។

ខ. មួយជើងលោករកលុយបានប៉ុន្មាន? (បីពាន់)
មួយជើងខ្ញុំរកលុយបានបីពាន់។

គ. មួយជើងលោកទិញកាំភ្លើងបានប៉ុន្មាន? (ពីរ)
មួយជើងខ្ញុំលួចកាំភ្លើងបានពីរ។

ឃ. មួយជើងលោកឱយកូនលោកប៉ុន្មាន? (ដប់ដុល្លា)
មួយជើងខ្ញុំឱយកូនខ្ញុំដប់ដុល្លា។

ង. មួយជើងលោកសម្លាប់ខ្មាំងបានប៉ុន្មាននាក់? (ប្រាំ)
មួយជើងខ្ញុំសម្លាប់ខ្មាំងបានប្រាំនាក់។

ច. មួយជើងលោកចង់យកប៉ុន្មាននាក់ទៅ? (ដប់ប្រាំ)
មួយជើងខ្ញុំចង់យកដប់ប្រាំនាក់ទៅ។

DRILL FIVE: Response

MODEL: T: លោកចង់ធ្វើទាហានប៉ុន្មានឆ្នាំ? (បី)
S: មិនទៀងទេ ខ្ញុំចង់ធ្វើទាហានប្រហែលបីឆ្នាំ។

T: How many years do you want to be in the service? (three)

S: It depends; I want to be in the service for about three years.

ក. លោកទៅលេងញូវយ៉កប៉ុន្មានថ្ងៃ? (ប្រាំ)
មិនទៀងទេ ខ្ញុំទៅលេងញូវយ៉កប្រហែលប្រាំថ្ងៃ។

ខ. លោកដេកប៉ុន្មានម៉ោង? (ប្រាំមួយ)
មិនទៀងទេ ខ្ញុំដេកប្រហែលប្រាំមួយម៉ោង។

គ. លោករៀនខ្មែរប៉ុន្មានអាទិត្យទៀត? (បួន)
មិនទៀងទេ ខ្ញុំរៀនខ្មែរប្រហែលបួនអាទិត្យទៀត។

ឃ. អង្កាល់លោកឈប់ធ្វើទាហាន? (ពីរឆ្នាំទៀត)
មិនទៀងទេ ខ្ញុំឈប់ធ្វើទាហានប្រហែលពីរឆ្នាំទៀត។

ង. លោកទៅញ៉ាំបាយម៉ោងប៉ុន្មាន? (ដប់ពីរ)
មិនទៀងទេ ខ្ញុំទៅញ៉ាំបាយប្រហែលម៉ោងដប់ពីរ។

ច. លោកចេញពីធ្វើការម៉ោងប៉ុន្មាន? (ប្រាំ)
មិនទៀងទេ ខ្ញុំចេញពីធ្វើការប្រហែលម៉ោងប្រាំ។

DRILL SIX: Substitution

MODEL: T: ធម្មតាគេប្រើឡានកង់ដប់។ (ឡានហ្ស៊ីប)
S: ធម្មតាគេប្រើឡានហ្ស៊ីប។

T: Usually, they use the 10-wheel trucks. (Jeep)

S: Usually, they use Jeeps.

ក. ធម្មតាគេប្រើឡានហ្ស៊ីប។ (ម៉ូតូ)

ខ. ធម្មតាគេប្រើម៉ូតូ។ (កង់)

គ. ធម្មតាគេប្រើកង់។ (រទេះកង់)

ឃ. ធម្មតាគេប្រើរទេះកង់។ (កប៉ាល់ហោះ)

ង. ធម្មតាគេប្រើកប៉ាល់ហោះ។ (ឡានឈ្នួល)

ច. ធម្មតាគេប្រើឡានឈ្នួល។

DRILL SEVEN: Transformation

MODEL: T: ខ្ញុំចង់ធ្វើទាហាន។ (ទាហានជើងគោក)
S: ខ្ញុំចង់ធ្វើទាហាន ជាពិសេសទាហានជើងគោក។

T: I want to be in the service. (army)

S: I want to be in the service, especially in the army.

ក. ខ្ញុំចង់រៀនភាសា ។ (ខ្មែរ)
ខ្ញុំចង់រៀនភាសា ជាពិសេសភាសាខ្មែរ ។
ខ. ខ្ញុំចង់ទៅដើរលេងនៅតាកែវ ។ (ផ្លូវមាត់ទន្លេ)
ខ្ញុំចង់ទៅដើរលេងនៅតាកែវ ជាពិសេសផ្លូវមាត់ទន្លេ ។
គ. លោកត្រូវទៅប្រទេសក្រៅ ។ (បារាំង)
លោកត្រូវទៅប្រទេសក្រៅ ជាពិសេសប្រទេសបារាំង ។
ឃ. លោកត្រូវទៅជួបគាត់ ។ (ថ្ងៃនេះ)
លោកត្រូវទៅជួបគាត់ ជាពិសេសថ្ងៃនេះ ។
ង. លោកគួរញ៉ាំស្រា ។ (ស្រានេះ)
លោកគួរញ៉ាំស្រា ជាពិសេសស្រានេះ ។
ច. លោកមិនគួរទៅធ្វើការទេ ។ (ថ្ងៃអាទិត្យ)
លោកមិនគួរទៅធ្វើការទេ ជាពិសេសថ្ងៃអាទិត្យ ។

DRILL EIGHT: Transformation

MODEL: T: ខ្ញុំរៀនភាសាខ្មែរ ។
S: ជាពិសេសខ្ញុំចង់រៀនភាសាខ្មែរ ។

T: I'm studying the Cambodian language.
S: I especially want to study the Cambodian language.

ក. ខ្ញុំចូលធ្វើទាហានកប៉ាល់ហោះ ។ — ជាពិសេសខ្ញុំចង់ធ្វើទាហានកប៉ាល់ហោះ ។
ខ. ខ្ញុំបង្រៀនទាហានឲ្យរៀនបាញ់ ។ — ជាពិសេសខ្ញុំចង់បង្រៀនទាហានឲ្យរៀនបាញ់ ។
គ. ខ្ញុំបាញ់កាំភ្លើងយន្ត អេម-៦០ ។ — ជាពិសេសខ្ញុំចង់បាញ់កាំភ្លើងយន្ត អេម-៦០ ។
ឃ. ខ្ញុំចេះបើកតង់ក៍ ។ — ជាពិសេសខ្ញុំចង់ចេះបើកតង់ក៍ ។
ង. ខ្ញុំឈប់រៀនថ្ងៃនេះ ។ — ជាពិសេសខ្ញុំចង់ឈប់រៀនថ្ងៃនេះ ។
ច. ខ្ញុំបង្រៀនតែយប់ទេ ។ — ជាពិសេសខ្ញុំចង់បង្រៀនតែយប់ទេ ។

DRILL NINE: Substitution

MODEL: T: ទាហានត្រូវហាត់បាញ់មួយដងមួយថ្ងៃ ។ (ដើរ)
S: ទាហានត្រូវហាត់ដើរមួយដងមួយថ្ងៃ ។
T: Soldiers have to practice shooting once a day. (marching)
S: Soldiers have to practice marching once a day.

ក. ទាហានត្រូវហាត់ដើរមួយដងមួយថ្ងៃ ។ (លោក)
ខ. លោកត្រូវហាត់ដើរមួយដងមួយថ្ងៃ ។ (និយាយខ្មែរ)
គ. លោកត្រូវហាត់និយាយខ្មែរមួយដងមួយថ្ងៃ ។ (សរសេរ)
ឃ. លោកត្រូវហាត់សរសេរខ្មែរមួយដងមួយថ្ងៃ ។ (យើង)
ង. យើងត្រូវហាត់សរសេរខ្មែរមួយដងមួយថ្ងៃ ។ (បាញ់កាំភ្លើងស្វ័យប្រវត្តិ)
ច. យើងត្រូវហាត់បាញ់កាំភ្លើងស្វ័យប្រវត្តិមួយដងមួយថ្ងៃ ។

DRILL TEN: Substitution

MODEL: T: អ្នកណាបង្ហាត់លោកបាញ់កាំភ្លើង? (និយាយខ្មែរ)

S: អ្នកណាបង្ហាត់លោកនិយាយខ្មែរ?

T: Who drills you to shoot a rifle? (to speak Cambodian)

S: Who drills you to speak Cambodian?

ក. អ្នកណាបង្ហាត់លោកនិយាយខ្មែរ? (ធ្វើឡាន)

ខ. អ្នកណាបង្ហាត់លោកធ្វើឡាន? (ចាក់ថ្នាំ)

គ. អ្នកណាបង្ហាត់លោកចាក់ថ្នាំ? (សរសេរអង់គ្លេស)

ឃ. អ្នកណាបង្ហាត់លោកសរសេរអង់គ្លេស? (បើកឡាន)

ង. អ្នកណាបង្ហាត់លោកបើកឡាន? (ជិះកង់)

ច. អ្នកណាបង្ហាត់លោកជិះកង់?

## Reading Passage

### វិន័យនិងច្បាប់ទម្លាប់ទាហាន

ទាហាននៅគ្រប់ប្រទេសត្រូវមានវិន័យនិងច្បាប់ទម្លាប់ទៅតាមប្រទេសរបស់ខ្លួន ដូច្នេះពីប្រទេសមួយទៅប្រទេសមួយ វិន័យនិងច្បាប់ទម្លាប់ខុសៗគ្នា តែមុខងារទាហានគឺមានតែមួយគឺការការពារទឹកដីរបស់គេ។

ជាទាហានសាធារណរដ្ឋខ្មែរ ម្នាក់ៗត្រូវតែគោរពវិន័យនិងច្បាប់ទម្លាប់ទាហានខ្មែរ។

ក្រសួងនិមួយៗ គេមិនយកមនុស្សទៅឲ្យធ្វើការនៅក្នុងក្រសួងនេះហើយទុកឲ្យមនុស្សធ្វើអ្វីតាមចិត្តរបស់ខ្លួនទេ ព្រោះថាក្រសួងទាំងអស់សុទ្ធតែមានវត្ថុបំណងមួយជាដរាប ដូច្នេះក្រសួងនេះតែងតែធ្វើច្បាប់និងវិន័យឲ្យអ្នកធ្វើការគោរពតាម យ៉ាងណាមិញក្រសួងទាហានក៏មានច្បាប់និងវិន័យសម្រាប់ទាហានគេដែរ។

វត្ថុបំណងទាហានគឺការការពារទឹកដី ដូច្នេះត្រូវតែមានវិន័យសម្រាប់ប្រដៅគេ ដើម្បីឲ្យវត្ថុបំណងនោះបានសម្រេច។ វិន័យនេះហើយដែលជាកម្លាំងរបស់ទាហាន។ ទាហានដែលមានវិន័យល្អតែងតែធ្វើការបានល្អ។ ការស្លៀកពាក់ ការគោរពគ្នាតាមថ្នាក់ ការស្តាប់បញ្ជា និងការទាក់ទងគ្នា ទាំងអស់នេះជាវិន័យរបស់ទាហានដែលទាហានម្នាក់ៗត្រូវធ្វើតាមយ៉ាងប្រយ័ត្ន។

ខោអាវមិនមែនគ្រាន់តែយកមកស្លៀកពាក់ដើម្បីកុំឲ្យគេមើលខ្លួនឃើញទេ គឺជារបស់មួយដែលធ្វើឲ្យទាហានខុសពីមនុស្សឯទៀត។ ទោះជាគេឃើញខោអាវទាហានពីចំងាយក៏ដោយ បើទាហានស្លៀកពាក់តាមរបៀបហើយខោអាវនោះស្អាតជានិច្ច ក៏គ្មានអ្នកណាហ៊ាននិយាយអ្វីទេ។ ដូច្នេះខោអាវមានប្រយោជន៍ណាស់ចំពោះវិន័យទាហាន។

ការគោរពគ្នាទៅតាមថ្នាក់ មិនមែនសម្រាប់ធ្វើឲ្យទាហានធំទេ គឺសម្រាប់បង្រៀនប្រដៅទាហានឲ្យចេះស្តាប់បញ្ជានាយទាហាន។ បើខ្វះការគោរពគ្នា

តាមធំតាមតូច មុខងារទាំងអស់ធ្វើមិនបានប្រយោជន៍ទេ។

ការទាក់ទងគ្នាក្នុងក្រសួងនីមួយៗ មិនមែនគ្រាន់តែជាការនិយាយរកគ្នាប៉ុណ្ណោះទេ គឺពឹងទៅលើការធ្វើការទូទៅ និងចិត្តមនុស្សម្នាក់ៗទៀត។ នៅក្នុងទាហាន ការទាក់ទងមានរបៀបគ្រប់គ្រាន់សម្រាប់ប្រើហើយ គឺយើងនៅតែយកមកប្រើដោយប្រយ័ត្នដោយមិនប្រើពាក្យធំៗ។ មិនមែនគ្រាន់តែប្រើទៅលើទាហានឯទៀតទេ គឺទៅលើមនុស្សឯទៀតៗក៏មិនត្រូវប្រើដែរ។

បញ្ជាពីមន្ទីរបាក់ការទាហានទៅនាយទាហានឬទាហានទាំងអស់ត្រូវធ្វើតាមតែមានសួរថាហេតុអ្វី។ ព្រោះថាបញ្ជានេះជាបញ្ជាមានសារៈសំខាន់ចំពោះការងារនិងការការពារប្រយោជន៍ជាតិ។ អ្នកដែលទទួលបញ្ជានីមួយៗត្រូវតែមើលឱ្យបានច្បាស់ ឬស្តាប់ឱ្យបានយ៉ាងល្អ មុននឹងយកបញ្ជានេះទៅប្រតិបត្តិ។ ម្យ៉ាងទៀតការសម្ងាត់ត្រូវតែទុកនៅក្នុងខ្លួន មិនត្រូវយកទៅនិយាយប្រាប់អ្នកឯទៀត សូម្បីតែឪពុកម្តាយឬប្រពន្ធក៏មិនត្រូវនិយាយប្រាប់ដែរ។

នាយទាហាននិងកូនទាហានសុទ្ធតែមានការទទួលខុសត្រូវនិងមុខងារខុសគ្នាទាំងអស់។ កូនទាហានទទួលបញ្ជាពីមេដឹកនាំក្រុមរបស់ខ្លួន មេដឹកនាំក្រុមទទួលបញ្ជាពីនាយទាហាន អនុសេនីយ៍ត្រីឬអនុសេនីយ៍ទោ ដែលទទួលបញ្ជាពីអនុសេនីយ៍ឯក ដែលទទួលបញ្ជាពីវរសេនីយ៍ត្រី។ល។ ពិតមែនតែនាយទាហានមួយឱ្យបញ្ជាទៅនាយទាហានមួយហើយទៅមួយទៀត ហើយទៅកូនទាហាន ទាហានទាំងអស់គ្នានេះមានមុខងារតែមួយគត់ គឺការពារនិងបំរើប្រទេសជាតិ។

VOCABULARY

| | | |
|---|---|---|
| ការពិសោធន៍ | kaa pisaot | experience (L) |
| ការសម្ងាត់ | kaa səŋat | a secret |
| ក្រុម | krom | group; platoon |
| ខ្មាំង | khmaŋ | enemy |
| ជញ្ជូន | əñcuun | to transport (a task requiring more than one trip), to move things |
| ជាពិសេស | cia pəseh | especially |
| ជំរុំ | cərum | camp |
| ដឹក | dək | to transport |
| តង់ក៍ | toŋ | tank |
| ទទួលខុសត្រូវ | tətuol khoh trəw | to take responsibility (R) |
| ទ័ព | tóp | troops |
| ទន្លេ | tunlee | river |
| ទាក់ទង | téʔ tóoŋ | to make contact with, to have relations with (R) |
| និយាយរក | niyiey róo | to seek out, to talk with (R) |
| បង្ក្រាប | pəkraap | to flatten, to defeat completely (L) |
| បង្ហាត់ | pəhat | to drill, to teach, to train |
| ប៊ីរ៉ូ | pərou | office, bureau (L) |

| | | |
|---|---|---|
| ប្រតិបត្តិ | protəbat | to put into effect, to execute (R) |
| ផ្លូវខ្វែង | phləw khvaeŋ | crossroad, intersection |
| ព្រំដែន | prum daen | border, frontier |
| ភ្នំ | phnom | hill, mountain |
| មាត់ទន្លេ | mót tunlee | mouth of the river |
| មិនទៀងទេ | mɨn tieŋ eh | it depends |
| ម៉ូតូ | moutou | motorcycle |
| មួយជើង | mə cəəŋ | one trip |
| យកការសម្ងាត់ | yóo kaa səŋat | to spy |
| យ៉ាងណាមិញ | yaaŋ naa mɨñ | likewise (R) |
| រទេះ | aatɛh | vehicle, cart |
| រទេះកង់ | aatɛh tɔŋ | tank |
| វត្ថុបំណង | votto? mnoŋ | intention, objective, purpose (R) |
| វិន័យ | vinɛy | discipline (R) |
| សម្ងាត់ | səŋat | secret |
| សម្រេច | səmrac | to decide; to be successful (R) |
| សារៈសំខាន់ | saaré? səmkhan | essence (R) |
| ហាត់ | hat | to train, to drill, to exercise |
| ឡានកង់ដប់ | laan kɔŋ dop | 10-wheel truck |

| | | |
|---|---|---|
| ក្រុម | krom | squad |
| ផ្នែក or កងអនុសេនាតូច | | platoon |
| កងអនុសេនាធំ | kɔɔŋ a?nu?seenaa | company |
| កងវរសេនាតូច | kɔɔŋ | battalion |
| កងពលតូច | kɔɔŋ | brigade |
| កងពលធំ | kɔɔŋ | division |
| អង្គ | ɔŋ | corps |
| ទ័ព | tóp | army |
| កងយកការសម្ងាត់ | kɔɔŋ yóo kaa səŋat | reconnaissance platoon, intelligence unit |

## LESSON FORTY-NINE

## DIALOGUE

| | | | |
|---|---|---|---|
| ១. | សុខ | មានការសម្ងាត់ច្រើនទេនៅក្នុងទាហាន? | Are there many secrets in the service? |
| | | កិច្ចការ | work, matter |
| ២. | ភុម | បាទ ច្រើនណាស់ ខ្ញុំមិនសូវដឹងកិច្ចការអីទេ។ | Yes, a lot. I don't really know anything. |
| | | កងទ័ព | troops |
| | | មួយៗ | each |
| ៣. | សុខ | ពេលគេបញ្ជូនកងទ័ពមួយៗ គេប្រាប់ទាហានទាំងអស់ឲ្យដឹងទេ? | Whenever they send each group of troops out, don't they let all the men know? |
| | | ទោះតែ...ក៏ | even |
| | | ពល | troop |
| ៤. | ភុម | បាទទេ ទោះតែពលតូចមួយក៏គេមិនប្រាប់យើងឲ្យដឹងផង។ | No, even (if they send) a small troop, they don't let us know, either. |
| | | ដូច្នេះ | so, thus, therefore |
| ៥. | សុខ | ដូច្នេះអ្នកណាប្រាប់លោក? | So who tells you? |
| | | ធ្វើដំណើរ | to make a trip, to travel |
| ៦. | ភុម | មេដឹកនាំក្រុម ហើយមួយថ្ងៃមុនយើងត្រូវធ្វើដំណើរ។ | The platoon leader, and (only) one day before we must go. |
| ៧. | សុខ | រួចលោករៀបចំឥវ៉ាន់ទាន់ទេ? | Then do you arrange things on time? |
| ៨. | ភុម | ក្នុងទាហានលោកត្រូវតែមានពេល។ | In the service, you have to have time. |
| ៩. | សុខ | ចុះបើមិនទាន់? | And if you're not on time? |
| | | ម្យ៉ាងទៀត | furthermore, on the other hand |
| | | ឯកសណ្ឋាន | uniform |
| | | សំរាប់ | suit, outfit |
| | | ....ប៉ុណ្ណឹង | to that extent; only |
| ១០. | ភុម | លោកត្រូវតែទាន់ ហើយម្យ៉ាងទៀតកូនទាហានគ្មានឥវ៉ាន់ច្រើនទេ មានឯកសណ្ឋានមួយសំរាប់ពីរប៉ុណ្ណឹង។ | You have to be on time, and furthermore a private doesn't have a lot of things. He only has one or two uniforms (that's all). |

DIALOGUE:

1. sok - mian kaa səŋat craən tee nɨw knoŋ təhian?

2. tom - baat, craən ah. khñom mɨn səw dəŋ kɛckaa ɛy tee

3. sok - peel kee pəcuun kooŋ tóp muoy muoy kee prap təhian téŋ ɔh aoy dəŋ tee?

4. tom - baat tee, krón tə púl touc muoy kɔɔ kee mɨn prap yəəŋ aoy dəŋ phɔɔŋ

5. sok - douc chnɛh né?naa prap look?

6. tom - mee dək nóm krom, haəy mə ŋay mun yəəŋ trəw thəə tənaə

7. sok - ruoc, look riep cɔm ɛyvan tón tee?

8. tom - knoŋ təhian look trəw tə mian peel

9. sok - coh baə mɨn tón?

10. tom - look trəw taɛ tón, haəy məyaaŋ tiet koun təhian kmian ɛyvan craən tee mian aɛksəthaan mə səraap pii pənəŋ

NOTES

DRILLS

DRILL NO.

7. ប៉ុណ្ណឹង /pənəŋ/ means 'just, only, just that much' when it follows an expression of quantity.

12. You have already learned that ទេ /tee/ at the end of a statement which is not negative indicates that it contradicts something else. ទេតើ /tee taə/ is a stronger, more emphatic form of this meaning of ទេ /tee/.

13. ទាំង /téŋ/ means 'including.' When it occurs twice, before two words or phrases, it means 'both...and...' or 'including...and...'

DRILLS

DRILL ONE: Transformation

MODEL: T: ផ្នែកខ្ញុំមានសាមសិបពីរនាក់។ (កងអនុសេនាធំ)

S: កងអនុសេនាធំ មួយៗមានសាមសិបពីរនាក់។

T: My group has 32 men. (company)

S: Each company has 32 men.

ក. ខ្ញុំដឹកទ័ពបានម្ភៃនាក់។ (ឡានកង់ដប់)
ឡានកង់ដប់មួយៗដឹកទ័ពបានម្ភៃនាក់។

ខ. ខ្ញុំលក់ថ្លៃបួនដុល្លា។ (សៀវភៅ)
សៀវភៅមួយៗលក់ថ្លៃបួនដុល្លា។

គ. ខ្ញុំបង្រៀនភាសាអង់គ្លេស។ (សាលា)
សាលាមួយៗបង្រៀនភាសាអង់គ្លេស។
ឃ. ខ្ញុំមានកៅអីពីរ។ (តុ)
តុមួយៗមានកៅអីពីរ។
ង. ខ្ញុំសួរបីដង។ (សំណួរ)
សំណួរមួយៗសួរបីដង។
ច. សំបុត្រនេះមកពីមេបញ្ជាការ។ (លិខិត)
លិខិតមួយៗមកពីមេបញ្ជាការ។

DRILL TWO: Substitution

MODEL: T: លោកគ្រាន់តែយាមបន្ទាយទេ។ (រៀនបាញ់កាំភ្លើង)
S: លោកគ្រាន់តែរៀនបាញ់កាំភ្លើងទេ។
T: You just guard the post. (practice shooting)
S: You just practice shooting.

ក. លោកគ្រាន់តែរៀនបាញ់កាំភ្លើងទេ។ (យកការសម្ងាត់)
ខ. លោកគ្រាន់តែយកការសម្ងាត់ទេ។ (រៀនធ្វើការរាយការណ៍)
គ. លោកគ្រាន់តែរៀនធ្វើការរាយការណ៍ទេ។ (មើលផែនទី)
ឃ. លោកគ្រាន់តែមើលផែនទីទេ។ (រៀននិយាយ)
ង. លោកគ្រាន់តែរៀននិយាយទេ។ (ស៊ីញ៉េ)
ច. លោកគ្រាន់តែស៊ីញ៉េទេ។

DRILL THREE: Response

MODEL: T: គេមិនប្រាប់ខ្ញុំទេ។
S: ដូច្នេះអ្នកណាប្រាប់លោក?
T: They didn't tell me.
S: Then who did tell you?

ក. ខ្ញុំមិនទៅយាមបន្ទាយនោះទេ។ ដូច្នេះអ្នកណាទៅយាមបន្ទាយនោះ?
ខ. ខ្ញុំមិនបានធ្វើការរាយការណ៍នេះទេ។ ដូច្នេះអ្នកណាបានធ្វើការរាយការណ៍នេះ?
គ. ខ្ញុំមិនបង្រៀនមេរៀននេះទេ។ ដូច្នេះអ្នកណាបង្រៀនមេរៀននេះ?
ឃ. ខ្ញុំមិនបង្គាប់ឲ្យលោកបាញ់ទេ។ ដូច្នេះអ្នកណាបង្គាប់ឲ្យលោកបាញ់?
ង. ខ្ញុំមិនបើកឡាននោះទេ។ ដូច្នេះអ្នកណាបើកឡាននោះ?
ច. ខ្ញុំមិនទទួលខុសត្រូវទេ។ ដូច្នេះអ្នកណាទទួលខុសត្រូវ?

DRILL FOUR: Response

MODEL: T: អ្នកណាទទួលខុសត្រូវក្នុងក្រុមលោក? (លោកសក្តិបី)

S: លោកសក្តិបីទទួលខុសត្រូវក្នុងក្រុមខ្ញុំ។

T: Who's in charge of your group? (the captain)

S: The captain is in charge of my group.

ក. អ្នកណាទទួលខុសត្រូវក្នុងថ្នាក់នេះ? (លោកសាន)
លោកសានទទួលខុសត្រូវក្នុងថ្នាក់នេះ។

ខ. អ្នកណាទទួលខុសត្រូវក្នុងបន្ទាយនោះ? (លោកសក្តិប្រាំសុស)
លោកសក្តិប្រាំសុសទទួលខុសត្រូវក្នុងបន្ទាយនោះ។

គ. អ្នកណាទទួលខុសត្រូវលើការរាយការណ៍នេះ? (លោកសន)
លោកសនទទួលខុសត្រូវលើការរាយការណ៍នេះ។

ឃ. អ្នកណាទទួលខុសត្រូវក្នុងជំរំលោក? (មេដឹកនាំក្រុម)
មេដឹកនាំក្រុមទទួលខុសត្រូវក្នុងជំរំខ្ញុំ។

ង. អ្នកណាទទួលខុសត្រូវក្នុងបន្ទប់នេះ? (កញ្ញាអ៊ីវី)
កញ្ញាអ៊ីវីទទួលខុសត្រូវក្នុងបន្ទប់នេះ។

ច. អ្នកណាទទួលខុសត្រូវដើម្បីនិងឲ្យលោកទៅរៀន? (ឪពុកម្តាយខ្ញុំ)
ឪពុកម្តាយខ្ញុំទទួលខុសត្រូវដើម្បីនិងឲ្យខ្ញុំទៅរៀន។

DRILL FIVE: Response

MODEL: T: ខ្ញុំចង់ធ្វើទាហានក្រោយខ្ញុំរៀនចប់។

S: ចំណែកឯខ្ញុំវិញ ខ្ញុំចង់ធ្វើទាហានមុនខ្ញុំរៀនចប់។

T: I want to serve in the armed forces after I finish studying.

S: As for me, I want to be a soldier before I finish studying.

ក. ខ្ញុំត្រូវទៅផ្ទះក្រោយម៉ោងបី។
ចំណែកឯខ្ញុំវិញ ខ្ញុំត្រូវទៅផ្ទះមុនម៉ោងបី។

ខ. ខ្ញុំសួរលោកសក្តិពីរមុនមេដឹកនាំយើង។
ចំណែកឯខ្ញុំវិញ ខ្ញុំសួរលោកសក្តិពីរក្រោយមេដឹកនាំយើង។

គ. ខ្ញុំផឹកទឹកក្រោយខ្ញុំញ៉ាំបាយ។
ចំណែកឯខ្ញុំវិញ ខ្ញុំផឹកទឹកមុនខ្ញុំញ៉ាំបាយ។

ឃ. ខ្ញុំទៅមើលកុនមុនខ្ញុំរៀនមេរៀននេះ។
ចំណែកឯខ្ញុំវិញ ខ្ញុំទៅមើលកុនក្រោយខ្ញុំរៀនមេរៀននេះ។

ង. ខ្ញុំទៅបន្ទាយក្រោយខ្ញុំទៅសាលា។
ចំណែកឯខ្ញុំវិញ ខ្ញុំទៅបន្ទាយមុនខ្ញុំទៅសាលា។

ច. ខ្ញុំនិយាយមុនខ្ញុំគិត។
ចំណែកឯខ្ញុំវិញ ខ្ញុំនិយាយក្រោយខ្ញុំគិត។

DRILL SIX: Transformation

MODEL: T: ទាហានគ្មានអីវ៉ាន់ច្រើនទេ។
S: ម្យ៉ាងទៀតទាហានគ្មានអីវ៉ាន់ច្រើនទេ។
T: Soldiers don't have a lot of things.
S: Furthermore, soldiers don't have a lot of things.

ក. ខ្ញុំត្រូវទៅយាមបន្ទាយល្ងាចនេះ។
ម្យ៉ាងទៀតខ្ញុំត្រូវទៅយាមបន្ទាយល្ងាចនេះ។
ខ. ខ្ញុំត្រូវសរសេរការរាយការណ៍ឲ្យលោកសក្តិបួន។
ម្យ៉ាងទៀតខ្ញុំត្រូវសរសេរការរាយការណ៍ឲ្យលោកសក្តិបួន។
គ. លោកមិនត្រូវទទួលខុសត្រូវក្នុងថ្នាក់នេះទេ។
ម្យ៉ាងទៀតលោកមិនត្រូវទទួលខុសត្រូវក្នុងថ្នាក់នេះទេ។
ឃ. លោកត្រូវរៀនបាញ់។
ម្យ៉ាងទៀតលោកត្រូវរៀនបាញ់។
ង. យើងត្រូវរៀនសរសេរទៀត។
ម្យ៉ាងទៀតយើងត្រូវរៀនសរសេរទៀត។
ច. ខ្ញុំគ្មានលុយទេ។
ម្យ៉ាងទៀតខ្ញុំគ្មានលុយទេ។

DRILL SEVEN: Response

MODEL: T: លោកមានឯកសណ្ឋានច្រើនសំរាប់ទេ? (ពីរបី)
S: បាទ ខ្ញុំមានឯកសណ្ឋានពីរបីសំរាប់ប៉ុណ្ណឹង។
T: Do you have many uniforms? (two or three)
S: I have a couple of uniforms only.

ក. សៀវភៅនេះថ្លៃទេ? (ប្រាំ ប្រាំមួយដុល្លា)
បាទ សៀវភៅនេះថ្លៃប្រាំប្រាំមួយដុល្លាប៉ុណ្ណឹង។
ខ. សាលាលោកនៅឆ្ងាយទេ? (ប្រាំមួយ ប្រាំពីរគីឡូ)
បាទ សាលាខ្ញុំនៅប្រាំមួយប្រាំពីរគីឡូប៉ុណ្ណឹង។
គ. គេឲ្យលោកឈប់ប៉ុន្មានថ្ងៃ? (បួនប្រាំ)
បាទ គេឲ្យខ្ញុំឈប់បួនប្រាំថ្ងៃប៉ុណ្ណឹង។
ឃ. លោកនៅប៉ុន្មានម៉ោង? (ពីរបី)
បាទ ខ្ញុំនៅពីរបីម៉ោងប៉ុណ្ណឹង។
ង. លោកចង់ខ្ចីលុយប៉ុន្មានរយដុល្លា? (មួយពីរ)
បាទ ខ្ញុំចង់ខ្ចីលុយមួយរយពីររយប៉ុណ្ណឹង។
ច. លោកមានពេលទេ? (មួយម៉ោងពីរ)
បាទ ខ្ញុំមានមួយម៉ោងពីរប៉ុណ្ណឹង។

DRILL EIGHT: Response

MODEL: T: ក្នុងទាហាន លោកហាត់ធ្វើអីខ្លះ? (យកការសម្ងាត់)
S: ក្នុងទាហាន គេបង្ហាត់ខ្ញុំឲ្យរៀនយកការសម្ងាត់។
T: In the service, what do you practice doing? (spying)
S: In the service, they train me how to spy.

ក. ក្នុងទាហាន លោកហាត់ធ្វើអីខ្លះ? (ធ្វើការរាយការណ៍)
ក្នុងទាហាន គេបង្ហាត់ខ្ញុំឲ្យរៀនធ្វើការរាយការណ៍។
ខ. ក្នុងទាហាន លោកហាត់ធ្វើអីខ្លះ? (មើលផែនទី)
ក្នុងទាហាន គេបង្ហាត់ខ្ញុំឲ្យរៀនមើលផែនទី។
គ. ក្នុងទាហាន លោកហាត់ធ្វើអីខ្លះ? (សួរខ្មាំង)
ក្នុងទាហាន គេបង្ហាត់ខ្ញុំឲ្យរៀនសួរខ្មាំង។
ឃ. ក្នុងទាហាន លោកហាត់ធ្វើអីខ្លះ? (បាញ់កាំភ្លើងស្វ័យប្រវត្ត)
ក្នុងទាហាន គេបង្ហាត់ខ្ញុំឲ្យរៀនបាញ់កាំភ្លើងស្វ័យប្រវត្ត។
ង. ក្នុងទាហាន លោកហាត់ធ្វើអីខ្លះ? (លាងកាំភ្លើង)
ក្នុងទាហាន គេបង្ហាត់ខ្ញុំឲ្យរៀនលាងកាំភ្លើង។
ច. ក្នុងទាហាន លោកហាត់ធ្វើអីខ្លះ? (ចាប់លិខិតខ្មាំង)
ក្នុងទាហាន គេបង្ហាត់ខ្ញុំឲ្យរៀនចាប់លិខិតខ្មាំង។

DRILL NINE: Response

MODEL: T: ខ្ញុំត្រូវហាត់ធ្វើអីខ្លះ? (បាញ់កាំភ្លើង)
S: លោកគ្រាន់តែហាត់បាញ់កាំភ្លើងទេ។
T: What do I have to practice doing? (shooting a rifle)
S: You just practice shooting a rifle.

ក. ខ្ញុំត្រូវមើលអីខ្លះ? (មេរៀនទីមួយ)
លោកគ្រាន់តែមើលមេរៀនទីមួយទេ។
ខ. ខ្ញុំត្រូវដឹកអីខ្លះ? (ទាហានទៅកន្លែងហាត់បាញ់)
លោកគ្រាន់តែដឹកទាហានទៅកន្លែងហាត់បាញ់។
គ. ខ្ញុំត្រូវបង្រៀនអីខ្លះ? (សរសេរ)
លោកគ្រាន់តែបង្រៀនសរសេរទេ។
ឃ. ខ្ញុំត្រូវរៀនអីខ្លះ? (មើលផែនទី)
លោកគ្រាន់តែរៀនមើលផែនទីទេ។
ង. ខ្ញុំត្រូវសួរសំណួរអ្នកណាខ្លះ? (ខ្មាំង)
លោកគ្រាន់តែសួរសំណួរខ្មាំងទេ។
ច. ខ្ញុំត្រូវធ្វើអីខ្លះ? (ការរាយការណ៍)
លោកគ្រាន់តែធ្វើការរាយការណ៍ទេ។

DRILL TEN: Response

MODEL: T: ខ្ញុំមិនចង់ធ្វើទាហានទេ។
S: លោកត្រូវតែធ្វើទាហាន។
T: I don't want to serve in the armed forces.
S: You have to serve in the armed forces.

ក. ខ្ញុំមិនចង់ធ្វើការរាយការណ៍ពីលោកទេ។
លោកត្រូវតែធ្វើការរាយការណ៍ពីខ្ញុំ។
ខ. ខ្ញុំមិនចង់រៀនភាសានេះទេ។
លោកត្រូវតែរៀនភាសានេះ។
គ. ខ្ញុំមិនជួយលោកទេ។
លោកត្រូវតែជួយខ្ញុំ។
ឃ. ខ្ញុំមិនចង់បង្រៀនកូនទាហានទេ។
លោកត្រូវតែបង្រៀនកូនទាហាន។
ង. ខ្ញុំមិនចង់រៀនយកការសម្ងាត់ទេ។
លោកត្រូវតែរៀនយកការសម្ងាត់។
ច. ខ្ញុំមិនចង់យាមបន្ទាយទេយប់នេះ។
លោកត្រូវតែយាមបន្ទាយយប់នេះ។

DRILL ELEVEN: Substitution

MODEL: T: ឯកសណ្ឋានទាហានជើងគោកពណ៌អី? (ទាហានជើងទឹក)
S: ឯកសណ្ឋានទាហានជើងទឹកពណ៌អី។
T: What is the color of the Army uniform? (Marine)
S: What is the color of the Marine uniform?

ក. ឯកសណ្ឋានទាហានជើងទឹកពណ៌អី? (ទាហានអាកាស)
ខ. ឯកសណ្ឋានទាហានអាកាសពណ៌អី? (ទាហាននារី)
គ. ឯកសណ្ឋានទាហាននារីពណ៌អី? (ទាហានថ្មើរជើង)
ឃ. ឯកសណ្ឋានទាហានថ្មើរជើងពណ៌អី? (ទាហានសេះ)
ង. ឯកសណ្ឋានទាហានសេះពណ៌អី? (ទាហានពិសេស)
ច. ឯកសណ្ឋានទាហានពិសេសពណ៌អី?

DRILL TWELVE: Response

MODEL: T: ខ្ញុំចាំថាលោកជាទាហានឆ័ត្រយោង។ (ទាហានអាកាស)
S: មិនមែនទេ ខ្ញុំជាទាហានអាកាសទេតើ។
T: I remember that you are a paratrooper. (airman)
S: That is not right, I am an airman.

ក. ខ្ញុំស្គាល់ថាលោកជាកងទ័ពថ្មើរ ។ (កងទ័ពពិសេស)
មិនមែនទេ ខ្ញុំជាកងទ័ពពិសេសទេតើ ។
ខ. ខ្ញុំជឿថាលោកជាទាហាននៅក្នុងកងកាំភ្លើងធំ ។ (កងរថក្រោះ)
មិនមែនទេ ខ្ញុំជាទាហាននៅក្នុងកងរថក្រោះទេតើ ។
គ. ខ្ញុំឮថាលោកជាទាហានខាងគមនាគមន៍ ។ (ពេទ្យ)
មិនមែនទេ ខ្ញុំជាទាហានខាងពេទ្យទេតើ ។
ឃ. ខ្ញុំស្មានថាលោកជាទាហាននៅក្នុងកងវិស្វករ ។ (កងយកការសម្ងាត់)
មិនមែនទេ ខ្ញុំជាទាហាននៅក្នុងកងយកការសម្ងាត់ទេតើ ។
ង. ខ្ញុំភ្លេចថាលោកជាប៉ូលិសទាហាន ។ (ទាហានធម្មតា)
មិនមែនទេ ខ្ញុំជាទាហានធម្មតាទេតើ ។
ច. ខ្ញុំដឹងថាលោកជាទាហាន ។ (ស៊ីវិល)
មិនមែនទេ ខ្ញុំជាស៊ីវិលទេតើ ។

DRILL THIRTEEN: Transformation

MODEL: T: ក្នុងភូមិនេះមានមនុស្សពីររយនាក់ ។ (ប្រុស, ស្រី)
S: ក្នុងភូមិនេះមានមនុស្សពីររយនាក់ទាំងប្រុសទាំងស្រី ។
T: In this hamlet there are 200 persons. (male, female)
S: In this hamlet there are 200 persons including male and female.

ក. ឪពុកម្ដាយខ្ញុំមានកូនប្រាំបីនាក់ ។ (ធំ, តូច)
ឪពុកម្ដាយខ្ញុំមានកូនប្រាំបីនាក់ទាំងធំទាំងតូច ។
ខ. យើងចាប់បានខ្មាំងម្ភៃនាក់ ។ (វៀតកុង, យួនខាងជើង)
យើងចាប់បានខ្មាំងម្ភៃនាក់ទាំងវៀតកុងទាំងយួនខាងជើង ។
គ. យើងរឹបអូសអាវុធជាច្រើន ។ (កាំភ្លើង, គ្រាប់)
យើងរឹបអូសអាវុធជាច្រើនទាំងកាំភ្លើងទាំងគ្រាប់ ។
ឃ. កងអនុសេនាធំខ្ញុំមានមនុស្ស ១២០ នាក់ ។ (នាយទាហាន, កូនទាហាន)
កងអនុសេនាធំខ្ញុំមានមនុស្ស ១២០ នាក់ទាំងនាយទាហានទាំងកូនទាហាន ។
ង. ថ្នាក់យើងមានកៅអីទាំងអស់ដប់ ។ (ថ្មី, ចាស់)
ថ្នាក់យើងមានកៅអីទាំងអស់ដប់ទាំងថ្មីទាំងចាស់ ។
ច. មនុស្សទាំងអស់ត្រូវវេទនា ។ (អ្នកមាន, អ្នកក្រ)
មនុស្សទាំងអស់ត្រូវវេទនាទាំងអ្នកមានទាំងអ្នកក្រ ។

## Reading Passage

### ខ្ញុំយកការសម្ងាត់លើកទីមួយ

នៅពេលក្រោយខ្ញុំរៀនវិជ្ជាយកការសម្ងាត់នៅក្នុងសាលាទាហានចប់ ខ្ញុំត្រូវគេបញ្ជូនឱ្យទៅធ្វើការនៅក្នុងភូមិមួយ តែខ្ញុំសុំបញ្ជាក់ថាខ្ញុំមិនមែនជាទាហានទេ

ខ្ញុំជាស៊ីវិលដែរ។ ខ្ញុំតែងតែពូកែនិយាយថា ទាហានមិនចេះខ្លាចអ្នកណាទេ គេមិនខ្លាចស្លាប់ទេ ហើយឯស៊ីវិលវិញ គេជាមនុស្សកំសាកញី ខ្លាចស្លាប់។ ខ្ញុំដូចជាជឿពាក្យនេះបន្តិច ដូចជាមិនជឿបន្តិច ព្រោះនៅថ្ងៃមួយដែលខ្ញុំទៅដល់ភូមិនោះ ខ្ញុំឃើញអ្នកស្រុកច្រើនដែលមានកាំភ្លើងគ្រប់គ្នា ហើយខ្ញុំគ្មានកាំភ្លើងទេ។ នៅថ្ងៃនោះខ្ញុំធ្វើជាមិនខ្លាច តែតាមពិតខ្ញុំខ្លាចជិតស្លាប់ ព្រោះខ្ញុំមិនដឹងអ្នកណាជាអ្នកណា។ ខ្ញុំមិនដឹងថាគេទុកចិត្តលើខ្ញុំឬមិនទុកចិត្ត។ ខ្ញុំប្រាប់គេថាខ្ញុំជាគ្រូបង្រៀនថ្មីដែលរដ្ឋាភិបាលបញ្ជូនមកភូមិនេះដើម្បីនឹងបង្រៀនកូនសិស្សនៅពេលថ្ងៃ ហើយនៅពេលខ្លះទៀតដើម្បីនឹងអប់រំអ្នកស្រុក។

ខ្ញុំបានបង្រៀនកូនសិស្សមែន ខ្ញុំបានអប់រំអ្នកស្រុកមែន តែល្អមិនល្អខ្ញុំមិនដឹងទេ ព្រោះខ្ញុំមិនមែនជាគ្រូបង្រៀន។ ខ្ញុំចូលចិត្តស្តាប់មនុស្សឯទៀតនិយាយគ្នាណាស់ ជាពិសេសកូនសិស្សខ្ញុំ។ នៅពេលចេញលេង ខ្ញុំតែងតែនិយាយជាមួយនឹងកូនសិស្ស សួរគេពីនេះពីនោះ ដូនកាលខ្ញុំសួរគេអំពីឪពុកម្តាយគេ តែខ្ញុំខ្លាចកូនសិស្សនោះទៅប្រាប់ឪពុកម្តាយវា។ ពេលចេញពីធ្វើការ ខ្ញុំទៅញ៉ាំកាហ្វេនៅកន្លែងណាដែលមានមនុស្សច្រើន។ ធម្មតាខ្ញុំមិនចូលចិត្តកាហ្វេទេ ព្រោះកាលណាខ្ញុំញ៉ាំខ្ញុំដេកមិនលក់ តែកាហ្វេវាថោកជាងគេ។ ខ្ញុំមិនហ៊ានញ៉ាំស្រា ពីព្រោះខ្ញុំខ្លាចស្រវឹងយកការសម្ងាត់មិនបាន។ ដូនកាលមនុស្សឯទៀតគេឈប់និយាយគ្នា នៅពេលដែលខ្ញុំទៅអង្គុយជិតគេ។ នេះប្រហែលជាគេមិនទាន់ទុកចិត្តខ្ញុំទេមើលទៅ ហើយខ្ញុំៗក៏មិនទុកចិត្តគេ។

ប៉ុន្តែនេះជាកិច្ចការខ្ញុំ ខ្ញុំត្រូវយកការសម្ងាត់ដែលមាននៅក្នុងភូមិនេះ ដូច្នេះខ្ញុំត្រូវរកពួកម៉ាក តែឲ្យខ្ញុំរកយ៉ាងម៉េច បើគេមិនចូលចិត្តខ្ញុំ។

VOCABULARY

| | | |
|---|---|---|
| កងទ័ព | kɔɔŋ tóp | troop |
| កងទ័ពពិសេស | kɔɔŋ tóp pəsɛh | special forces |
| កងទ័ពព្រៃ | kɔɔŋ tóp prey | guerrilla forces |
| កងវិស្វករ | kɔɔŋ vihsəvəkɔɔ | engineer corps |
| កិច្ចការ | kɛckaa | job, work |
| កំសាកញី | kəsaaʔ ñii | coward (R) |
| គមនាគមន៍ | kummənïakum | communications |
| ចាញ់បោក | cañ baok | to be cheated (L) |
| ដូច្នេះ | douc chnɛh | so, thus, therefore |
| ទទួលខុសត្រូវ | tətuol khoh trəw | to be in charge, take responsibility |
| ទារ | tia | to demand, to dun (for money) (L) |
| ទាហានឆ័ត្រយោង | təhian chat youŋ | paratroops |
| ទាហានពិសេស | təhian pəsɛh | special forces |
| ទាំង ..., ទាំង ... | téŋ...téŋ... | both...and..., including...and... |
| ធ្វើដំណើរ | thəə tənaə | to travel |
| នាំឲ្យស្គាល់ | nóm aoy skól | to introduce (L) |
| បង្គាប់ | pəkóp | to order |

| | | |
|---|---|---|
| ប៉ុណ្ណឹង | pənəŋ | only, that's all, that much |
| បោក | baok | to cheat (colloquial) (L) |
| ផែនទី | phaɛn tii | map |
| ពល | púl | troop |
| មួយៗ | muoy muoy | each |
| ម្យ៉ាងទៀត | məyaaŋ tiet | on the other hand, furthermore |
| យាម | yiam | to guard |
| រថក្រោះ | rút krúh | tank· |
| រឹបយក | rəp yóo | to seize, to confiscate |
| រួចពីមាត់ | ruoc pii mót | to say just for the heck of it, to make up a story (L) |
| លិខិត | ləkhət | message, paper |
| វិស្វករ | vihsəvaʔkɔɔ | engineer |
| វេទនា | veetənia | misery, suffering |
| សំណួរ | sənuo | question |
| សំរាប់ | sərap | a set; a suit of clothing |
| អប់រំ | ɔprum | to bring up, to educate, to guide (R) |
| ឯកសណ្ឋាន | aɛksəthaan | uniform |



Wedding Party

## LESSON FIFTY

### DIALOGUE

| | | | |
|---|---|---|---|
| | | ផ្លាស់មក(ទៅ) | to transfer, to change |
| ១. | សុខ | លោកសក្តិបី ហេតុអ្វីបាន ជាលោកផ្លាស់មកកន្លែង នេះ? | Captain, why did you transfer to this place? |
| | | បញ្ជា | to order |
| | | មេបញ្ជាការ | |
| ២. | ភុម | ខ្ញុំមិនចង់មកទេ តែមេ បញ្ជាការខ្ញុំបញ្ជាឲយខ្ញុំមក។ | I didn't want to come here, but the commander ordered me to. |
| ៣. | សុខ | កន្លែងនេះមានគ្រោះថ្នាក់ ច្រើនណាស់។ លោកយក កូនទាហានប៉ុន្មាននាក់មក ជាមួយ? | This place is very dangerous; how many men did you bring with you? |
| | | កាលពីប៉ុន្មានថ្ងៃនេះ | in the last few days |
| ៤. | ភុម | សាមសិបពីរនាក់។ កាលពីប៉ុន្មានថ្ងៃនេះ យើង ធ្វើការម្ភៃបួនម៉ោង។ | Thirty-two men. In the last few days, we've worked around the clock. |
| ៥. | សុខ | ដូចជា? | Doing what? |
| | | សង្ស័យ | to suspect |
| ៦. | ភុម | ដូចយាមជំរំយើងព្រោះ យើងសង្ស័យថាមានខ្មាំង នៅពេលយប់។ | Like guarding our camp because we suspected that there were enemy at night. |
| | | ការពារ | to defend, protect |
| ៧. | សុខ | លោកធ្វើអីទៀតដើម្បីនឹង ការពារជំរំលោក? | What else did you do to defend your camp? |
| | | ត្រង់សេ | trench |
| ៨. | ភុម | យើងជីកត្រង់សេជុំវិញ។ | We dug trenches all around. |
| ៩. | សុខ | លោកនៅកន្លែងនេះ ប៉ុន្មានខែ? | How long will you stay here? |
| ១០. | ភុម | ខ្ញុំមិនអាចប្រាប់លោកបាន ទេ ព្រោះជាការសម្ងាត់។ | I can't tell you, because it's a secret. |

DIALOGUE:

1. sok - look saʔ bɛy, haɛt ɛy baan cia look phlah móo kəlaɛŋ nih?
2. tom - khñom mɨn cɔŋ móo tee, taɛ mee bɔñcia kaa khñom bɔñcia aoy khñom móo
3. sok - kəlaɛŋ nih mian krúh thnaʔ craən nah. look yóo koun təhian pəmaan néʔ móo cia muoy?
4. tom - saam səp pii néʔ. kaal pii pəmaan ŋay nih, yəəŋ thəə kaa məphɛy buon maoŋ
5. sok - douc cia?
6. tom - douc yiam cərúm yəəŋ prúh yəəŋ sɔŋsay thaa mian khmaŋ nɨw peel yup
7. sok - look thəə ɛy tiet daəmbɛy nɨŋ kaapia cərúm look?
8. tom - yəəŋ ciik trɔŋsee cum viñ
9. sok - look nɨw kəlaɛŋ nih pəmaan khaɛ?
10. tom - khñom mɨn aac prap look baan tee, prúh cia kaa səŋat

NOTES

DRILLS

DRILL NO.

4. Note that ប៉ុន្មាន /pəmaan/ here is an indefinite meaning 'a few, several,' not a question word meaning 'how many.'

DRILLS

DRILL ONE: Substitution

MODEL: T: តែផ្លូកខ្ញុំទេផ្លាស់មកកន្លែងនេះ។ (កងអនុសេនាធំ)

S: តែកងអនុសេនាធំ ទេផ្លាស់មកកន្លែងនេះ។

T: It's only my platoon that transferred to this place. (the company)

S: It's only the company that transferred to this place.

ក. តែកងអនុសេនាតូចទេផ្លាស់មកកន្លែងនេះ។ (លោកសក្តិបួន)
ខ. តែលោកសក្តិបួនទេផ្លាស់មកកន្លែងនេះ។ (លោកមហាយុ)
គ. តែលោកមហាយុទេផ្លាស់មកកន្លែងនេះ។ (កងវរសេនាធំទីបី)
ឃ. តែកងវរសេនាធំទីបីទេផ្លាស់មកកន្លែងនេះ។ (កូនខ្ញុំ)
ង. តែកូនខ្ញុំទេផ្លាស់មកកន្លែងនេះ។ (ក្រុមលោកចែម)
ច. តែក្រុមលោកចែមទេផ្លាស់មកកន្លែងនេះ។

DRILL TWO: Extension

MODEL: T: មេបញ្ជាការខ្ញុំបញ្ជាឲ្យខ្ញុំមកកន្លែងនេះ។
S: ខ្ញុំមិនចង់មកកន្លែងនេះទេ។
T: My commander ordered me to come to this place.
S: I didn't want to come here.

ក. លោកគ្រូខ្ញុំបញ្ជាឲ្យខ្ញុំរៀនមេរៀននេះ។ ខ្ញុំមិនចង់រៀនមេរៀននេះទេ។
ខ. ឪពុកលោកបញ្ជាឲ្យលោកចូលធ្វើទាហាន។ ខ្ញុំមិនចង់ចូលធ្វើទាហានទេ។
គ. ប៉ូលិសបញ្ជាឲ្យលោកឈប់។ លោកមិនចង់ឈប់ទេ។
ឃ. នាយទាហានបញ្ជាឲ្យយើងធ្វើការច្រើន។ យើងមិនចង់ធ្វើការច្រើនទេ។
ង. គេបញ្ជាឲ្យខ្ញុំរៀនភាសានេះ។ ខ្ញុំមិនចង់រៀនភាសានេះទេ។
ច. មេបញ្ជាការខ្ញុំបញ្ជាឲ្យខ្ញុំធ្វើការរាយការណ៍មួយ។
ខ្ញុំមិនចង់ធ្វើការរាយការណ៍មួយទេ។

DRILL THREE: Transformation

MODEL: T: កន្លែងនេះមានគ្រោះថ្នាក់ច្រើនណាស់។
S: ធម្មតាកន្លែងនេះមិនដែលមានគ្រោះថ្នាក់ទេ។
T: This place has a lot of accidents (is very dangerous).
S: Usually this place never has any accidents (is never dangerous).

ក. ខ្ញុំរៀនភាសានេះ។ ធម្មតាខ្ញុំមិនដែលរៀនភាសានេះទេ។
ខ. ខ្ញុំសួរមេបញ្ជាការខ្ញុំ។ ធម្មតាខ្ញុំមិនដែលសួរមេបញ្ជាការខ្ញុំទេ។
គ. ខ្ញុំយកការសម្ងាត់ឲ្យខ្មាំង។ ធម្មតាខ្ញុំមិនដែលយកការសម្ងាត់ឲ្យខ្មាំងទេ។
ឃ. ខ្ញុំសង្ស័យលោកជាខ្មាំង។ ធម្មតាខ្ញុំមិនដែលសង្ស័យលោកជាខ្មាំងទេ។
ង. ខ្ញុំត្រូវជីកត្រង់សេជុំវិញបន្ទាយ។ ធម្មតាខ្ញុំមិនដែលជីកត្រង់សេជុំវិញបន្ទាយទេ។
ច. ខ្ញុំមានគ្រោះថ្នាក់ឡានមួយ។ ធម្មតាខ្ញុំមិនដែលមានគ្រោះថ្នាក់ឡានទេ។

DRILL FOUR: Transformation

MODEL: T: មានគ្រោះថ្នាក់មួយនៅក្នុងបន្ទាយនេះ។
S: កាលពីប៉ុន្មានថ្ងៃនេះមានគ្រោះថ្នាក់មួយនៅក្នុងបន្ទាយនេះ។
T: There was an accident in this post.
S: In the last few days there was an accident in this post.

ក. ខ្ញុំទទួលសំបុត្រមួយ។
កាលពីប៉ុន្មានថ្ងៃនេះខ្ញុំទទួលសំបុត្រមួយ។
ខ. យើងធ្វើការថែមបួនម៉ោង។
កាលពីប៉ុន្មានថ្ងៃនេះយើងធ្វើការថែមបួនម៉ោង។
គ. ខ្ញុំមិនបានទៅរៀនទេ។
កាលពីប៉ុន្មានថ្ងៃនេះខ្ញុំមិនបានទៅរៀនទេ។

ឃ. គេមិនឲ្យខ្ញុំធ្វើការទេ។
កាលពីប៉ុន្មានថ្ងៃនេះគេមិនឲ្យខ្ញុំធ្វើការទេ។
ង. ខ្ញុំគ្មានលុយទេ។
កាលពីប៉ុន្មានថ្ងៃនេះខ្ញុំគ្មានលុយទេ។
ច. លោកមិនរៀនខ្មែរទេ។
កាលពីប៉ុន្មានថ្ងៃនេះលោកមិនរៀនខ្មែរទេ។

DRILL FIVE: Substitution

MODEL: T: យើងធ្វើការម្ភៃបួនម៉ោង។ (លក់ថ្នាំ)
S: យើងលក់ថ្នាំម្ភៃបួនម៉ោង។
T: We work around the clock. (sell medicine)
S: We sell medicine around the clock.

ក. យើងលក់ថ្នាំម្ភៃបួនម៉ោង។ (ហាងថ្នាំ)
ខ. ហាងថ្នាំលក់ថ្នាំម្ភៃបួនម៉ោង។ (បើក)
គ. ហាងថ្នាំបើកម្ភៃបួនម៉ោង។ (ប៉ុស្តិ៍)
ឃ. ប៉ុស្តិ៍បើកម្ភៃបួនម៉ោង។ (ខ្ញុំ)
ង. ខ្ញុំបើកម្ភៃបួនម៉ោង។ (យាម)
ច. ខ្ញុំយាមម្ភៃបួនម៉ោង។

DRILL SIX: Substitution

MODEL: T: ខ្ញុំសង្ស័យថាលោកជាខ្មាំង។ (ទាហានយកការសម្ងាត់)
S: ខ្ញុំសង្ស័យថាលោកជាទាហានយកការសម្ងាត់។
T: I suspect that you're an enemy. (in military intelligence)
S: I suspect that you're in military intelligence.

ក. ខ្ញុំសង្ស័យថាលោកជាទាហានយកការសម្ងាត់។ (គ្រូបង្រៀន)
ខ. ខ្ញុំសង្ស័យថាលោកជាគ្រូបង្រៀន។ (ប៉ូលិស)
គ. ខ្ញុំសង្ស័យថាលោកជាប៉ូលិស។ (អ្នកបើកឡាន)
ឃ. ខ្ញុំសង្ស័យថាលោកជាអ្នកបើកឡាន។ (កូនសិស្ស)
ង. ខ្ញុំសង្ស័យថាលោកជាកូនសិស្ស។ (អ្នកឲ្យការសម្ងាត់)
ច. ខ្ញុំសង្ស័យថាលោកជាអ្នកឲ្យការសម្ងាត់។

DRILL SEVEN: Transformation

MODEL: T: ជាការសម្ងាត់។
S: ខ្ញុំមិនអាចប្រាប់លោកទេ ព្រោះជាការសម្ងាត់។
T: It's a secret.
S: I can't tell you because it's a secret.

ក. ខ្ញុំមិនដឹង។ ខ្ញុំមិនអាចប្រាប់លោកទេព្រោះខ្ញុំមិនដឹង។
ខ. ខ្ញុំមិនដែលឃើញ។ ខ្ញុំមិនអាចប្រាប់លោកទេព្រោះខ្ញុំមិនដែលឃើញ។
គ. ជាការផ្ទាល់ខ្លួន។ ខ្ញុំមិនអាចប្រាប់លោកទេព្រោះជាការផ្ទាល់ខ្លួន។
ឃ. ជារឿងសន្តិសុខជាតិ។ ខ្ញុំមិនអាចប្រាប់លោកទេព្រោះជារឿងសន្តិសុខជាតិ។
ង. មានមនុស្សច្រើនពេក។ ខ្ញុំមិនអាចប្រាប់លោកទេព្រោះមានមនុស្សច្រើនពេក។
ច. ខ្ញុំភ្លេចទៅហើយ។ ខ្ញុំមិនអាចប្រាប់លោកទេព្រោះខ្ញុំភ្លេចទៅហើយ។

DRILL EIGHT: Substitution

MODEL: T: កាលពីប៉ុន្មានថ្ងៃនេះមានខ្មាំងច្រើនណាស់។ (អាទិត្យ)
S: កាលពីប៉ុន្មានអាទិត្យនេះមានខ្មាំងច្រើនណាស់។
T: In the last few days there have been a lot of enemy. (weeks)
S: In the last few weeks there have been a lot of enemy.

ក. កាលពីប៉ុន្មានអាទិត្យនេះមានខ្មាំងច្រើនណាស់។ (ខែ)
ខ. កាលពីប៉ុន្មានខែនេះមានខ្មាំងច្រើនណាស់។ (ឆ្នាំ)
គ. កាលពីប៉ុន្មានឆ្នាំនេះមានខ្មាំងច្រើនណាស់។ (ម៉ោង)
ឃ. កាលពីប៉ុន្មានម៉ោងនេះមានខ្មាំងច្រើនណាស់។ (មិនុត)
ង. កាលពីប៉ុន្មានមិនុតនេះមានខ្មាំងច្រើនណាស់។ (ថ្ងៃ)
ច. កាលពីប៉ុន្មានថ្ងៃនេះមានខ្មាំងច្រើនណាស់។

DRILL NINE: Substitution

MODEL: T: នេះជាចំណោទរបស់សន្តិសុខជាតិ។ (ទាហាន)
S: នេះជាចំណោទរបស់ទាហាន។
T: This is a problem of national security. (military)
S: This is a military problem.

ក. នេះជាចំណោទរបស់ទាហាន។ (ជាតិ)
ខ. នេះជាចំណោទរបស់ជាតិ។ (ប៉ូលិស)
គ. នេះជាចំណោទរបស់ប៉ូលិស។ (កូនសិស្ស)
ឃ. នេះជាចំណោទរបស់កូនសិស្ស។ (លោកស័ក្តិបី)
ង. នេះជាចំណោទរបស់លោកស័ក្តិបី។ (លោក)
ច. នេះជាចំណោទរបស់លោក។

DRILL TEN: Response

MODEL: T: គេឱ្យលោកដឹងមុនទេ មុនគេផ្លាស់លោក
S: មុនគេផ្លាស់ខ្ញុំគេមិនឱ្យខ្ញុំដឹងទេ។
T: Did they let you know ahead of time, before they transferred you?
S: Before they transferred me they didn't let me know.

ក. គេប្រាប់លោកមុនទេ មុនគេឲ្យលោកទៅ?
មុនគេឲ្យខ្ញុំទៅ គេមិនប្រាប់ខ្ញុំទេ។
ខ. លោកគ្រូពន្យល់លោកមុនទេ មុនគាត់ឲ្យចំណោទនេះ?
មុនគាត់ឲ្យចំណោទនេះ គាត់មិនពន្យល់ខ្ញុំទេ។
គ. លោករៀនមេរៀននេះមុនទេ មុនលោកមកសាលា?
មុនខ្ញុំមកសាលា ខ្ញុំមិនរៀនមេរៀននេះទេ។
ឃ. លោកលាងដៃមុនទេ មុនលោកញ៉ាំបាយ?
មុនខ្ញុំញ៉ាំបាយ ខ្ញុំមិនលាងដៃទេ។
ង. លោកមើលកាំភ្លើងលោកមុនទេ មុនលោកទៅកន្លែងហាត់បាញ់?
មុនខ្ញុំទៅកន្លែងហាត់បាញ់ ខ្ញុំមិនមើលកាំភ្លើងខ្ញុំទេ។
ច. គេសួរលោកមុនទេ មុនគេឲ្យលោកចូល?
មុនគេឲ្យខ្ញុំចូល គេមិនសួរខ្ញុំទេ។

DRILL ELEVEN: Transformation

MODEL:
T: ពលបាលបញ្ជាក្រុមទាហាន។ (ពលបាល)
S: អ្នកណាបញ្ជាក្រុមទាហាន?
T: The sergeant commands the troop. (sergeant)
S: Who commands the troop?

ក. លោកសក្តិបីបញ្ជាកងអនុសេនាតូច។ (លោកសក្តិបី)
អ្នកណាបញ្ជាកងអនុសេនាតូច?
ខ. ក្នុងកងអនុសេនាធំ ខ្ញុំមានទាហានដប់ក្រុម។ (ដប់)
ក្នុងកងអនុសេនាធំ ខ្ញុំមានទាហានប៉ុន្មានក្រុម?
គ. កាលណាអ្នកដឹកនាំក្រុមមិននៅ អ្នកបាញ់កាំភ្លើងអាចបញ្ជាក្រុម។
(កាលណាអ្នកដឹកនាំក្រុមមិននៅ)
ពេលណាអ្នកបាញ់កាំភ្លើងអាចបញ្ជាក្រុម?
ឃ. គេបង្ហាត់អ្នកបាញ់រ៉ុកកែតដើម្បីឲ្យបាញ់កាំភ្លើងបាញ់គ្រាប់បែក។
(ឲ្យបាញ់កាំភ្លើងបាញ់គ្រាប់បែក)
គេបង្ហាត់អ្នកបាញ់រ៉ុកកែតដើម្បីធ្វើអី?
ង. មិនចាំបាច់មានទាហានយាមនៅក្នុងបន្ទាយទេ។ (ក្នុងបន្ទាយ)
មិនចាំបាច់មានទាហានយាមនៅឯណា?
ច. លោកត្រូវពាក់ឯកសណ្ឋានទាហានរាល់ថ្ងៃ។ (រាល់ថ្ងៃ)
លោកត្រូវពាក់ឯកសណ្ឋានទាហានថ្ងៃណាខ្លះ?

DRILL TWELVE: Substitution

MODEL: T: អ្នកណាស្ម័គ្រចិត្តទៅជួបមេខ្មាំង? (និយាយជាមួយ)
S: អ្នកណាស្ម័គ្រចិត្តទៅនិយាយជាមួយមេខ្មាំង?
T: Who will volunteer to go and meet the enemy leader? (talk with)
S: Who will volunteer to go and talk with the enemy leader?

ក. អ្នកណាស្ម័គ្រចិត្តទៅនិយាយជាមួយមេខ្មាំង? (អ្នកតំណាងកាសែត)
ខ. អ្នកណាស្ម័គ្រចិត្តទៅនិយាយជាមួយអ្នកតំណាងកាសែត? (អ្នកជំងឺ)
គ. អ្នកណាស្ម័គ្រចិត្តទៅនិយាយជាមួយអ្នកជំងឺ? (ផ្ដល់ឈាមឲ្យ)
ឃ. អ្នកណាស្ម័គ្រចិត្តទៅផ្ដល់ឈាមឲ្យអ្នកជំងឺ? (ពេទ្យ)
ង. អ្នកណាស្ម័គ្រចិត្តទៅផ្ដល់ឈាមឲ្យពេទ្យ? (ជួយ)
ច. អ្នកណាស្ម័គ្រចិត្តទៅជួយពេទ្យ ?

DRILL THIRTEEN: Transformation

MODEL: T: អ្នករបួសស្លាប់។ (លោកយកឈាមមកដល់)
S: ល្មមតែលោកយកឈាមមកដល់អ្នករបួសស្លាប់ទៅហើយ។
T: The wounded died. (you arrived with the blood)
S: By the time you arrived with the blood the wounded died.

ក. ផ្ទះនោះឆេះអស់។ (ឡានទឹកមកដល់)
ល្មមតែឡានទឹកមកដល់ផ្ទះនោះឆេះអស់ទៅហើយ។
ខ. ខ្ញុំចាយលុយអស់។ (លោកចង់លក់ឡានឲ្យខ្ញុំ)
ល្មមតែលោកចង់លក់ឡានឲ្យខ្ញុំៗចាយលុយអស់ទៅហើយ។
គ. ខ្ញុំរត់ចេញពីភូមិ។ (ឡានទាហានទៅដល់)
ល្មមតែឡានទាហានទៅដល់ខ្ញុំរត់ចេញពីភូមិទៅហើយ។
ឃ. ខ្ញុំឈប់ឃ្លានបាយ។ (យើងរកហាងបាយឃើញ)
ល្មមតែយើងរកហាងបាយឃើញខ្ញុំឈប់ឃ្លានបាយទៅហើយ។
ង. កុនលេងជិតចប់។ (ខ្ញុំទិញសំបុត្របាន)
ល្មមតែខ្ញុំទិញសំបុត្របានកុនលេងជិតចប់ទៅហើយ។
ច. ប្រពន្ធខ្ញុំឆ្លងទន្លេ។ (ខ្ញុំទៅដល់ពេទ្យ)
ល្មមតែខ្ញុំទៅដល់ពេទ្យប្រពន្ធខ្ញុំឆ្លងទន្លេទៅហើយ។

DRILL FOURTEEN: Choice

MODEL: T: លោកឆ្លងទន្លេតាម ... វាឆាប់ជាងតាម ... (ទូក , កាណូត)
S: លោកឆ្លងទន្លេតាមកាណូតវាឆាប់ជាងតាមទូក។
T: Crossing a river by...is faster than by ... (rowboat, a motor canoe)
S: Crossing a river by a motor canoe is faster than by rowboat.

ក. ....អាចនាំទំនិញបានច្រើនតែយឺតជាង... (រទេះភ្លើង, កប៉ាល់ហោះដឹកទំនិញ)
រទេះភ្លើងអាចនាំទំនិញបានច្រើនតែយឺតជាងកប៉ាល់ហោះដឹកទំនិញ។
ខ. ....អាចចម្លងមនុស្សនិងឡានតែ... អាចចម្លងបានតែមនុស្សទេ។
(កាណូត, សាឡាង)
សាឡាងអាចចម្លងមនុស្សនិងឡានតែកាណូតអាចចម្លងបានតែមនុស្សទេ។
គ. នៅក្នុងចំបាំងគេមិនសូវប្រើ.. ទេព្រោះវាយឺតជាង...
(ឡានពេទ្យ, អេលីកុបទ័រ)
នៅក្នុងចំបាំងគេមិនសូវប្រើឡានពេទ្យទេព្រោះវាយឺតជាងអេលីកុបទ័រ។
ឃ. គេប្រើ ... ដើម្បីធ្វើចំបាំង ... ដើម្បីដឹកទាហាន។ (រថក្រោះ, ឡានពេទ្យ)
គេប្រើរថក្រោះដើម្បីធ្វើចំបាំង ឡានទាហានដើម្បីដឹកទាហាន។
ង. ខ្ញុំចូលចិត្ត ... ព្រោះវាថោកជាង ... (ឡានឈ្នួល, តាក់ស៊ី)
ខ្ញុំចូលចិត្តឡានឈ្នួលព្រោះវាថោកជាងតាក់ស៊ី។

## Reading Passage

### អ្នកតំណាងកាសែត

ធម្មតាកិច្ចការអ្នកតំណាងកាសែតជាកិច្ចការពិបាកណាស់ជាពិសេសនៅកន្លែងណាឬស្រុកណាដែលមានការបាញ់គ្នា។ ហើយធម្មតាអ្នកតំណាងកាសែតច្រើនតែស្ម័គ្រចិត្តទៅធ្វើការរាយការណ៍នៅកន្លែងណាដែលមានគ្រោះថ្នាក់ច្រើន។ គ្មានអ្នកណាបញ្ជាអ្នកតំណាងកាសែតឱ្យទៅរាយការណ៍ពីកន្លែងណាទេ តែការរាយការណ៍អំពីកន្លែងនោះជាការងាររបស់គេ។ គេត្រូវមានដំណឹងដាក់ក្នុងកាសែតរបស់គេ ត្រូវមានរូបថត មិនមែនរូបថតនៅក្រោយពេលដែលព្រឹត្តិការណ៍កើតឡើងនោះទេ គឺពេលដែលព្រឹត្តិការណ៍កំពុងតែកើតឡើង។ នេះហើយជាការពិបាកនោះ។

នៅក្នុងសង្គ្រាម អ្នកតំណាងកាសែតត្រូវតែដើរតាមកងទ័ព។ គេស្លៀកពាក់ឯកសណ្ឋានទាហានតែគេប្រើប្រដាប់ថតរូប ប្រដាប់ថតសម្លេង ខ្មៅដៃ ក្រដាសជំនួសកាំភ្លើងនិងគ្រាប់។ ការណ៍ដែលគ្មានកាំភ្លើងតែស្លៀកជាទាហាននេះហើយដែលអាចធ្វើឱ្យអ្នកតំណាងកាសែតមានគ្រោះថ្នាក់ ហើយជួនកាលគេមានគ្រោះថ្នាក់ដល់ជីវិតផង។ ជួនកាលគេត្រូវជួលឡានហើយបើកទៅកន្លែងដែលមានព្រឹត្តិការណ៍កើតឡើង ហើយដល់ពេលបើកឡានទៅដល់គេគ្មានឃើញអ្វីទេ។ បើគេគ្រាន់តែទៅដល់កន្លែងនោះ គេមានសំណាងហើយព្រោះជួនកាលពួកខ្មាំងឬកងទ័ពព្រៃបាញ់ទៅលើគេឬចាប់គេយកទៅជាមួយ។ បើកងទ័ពព្រៃចាប់គេយកទៅជាមួយ គេមិនដឹងជាថ្ងៃណាខែណាគេនឹងត្រឡប់ទៅជួបពួកម៉ាកឬគ្រួសារគេទេ ឬគេមិនដឹងជាកងទ័ពព្រៃនឹងសម្លាប់គេ ឬឱ្យគេរួចខ្លួនទេ។

នៅក្នុងស្រុកមានចំបាំងយ៉ាងនេះ អ្នកតំណាងកាសែតធ្វើការគ្មានពេលគ្មានម៉ោងទេ តែគេបានផ្តល់ប្រយោជន៍យ៉ាងសំខាន់ដល់មនុស្សទូទៅ។

## VOCABULARY

| | | |
|---|---|---|
| ការផ្ទាល់ខ្លួន | kaa phtól khluon | personal affair |
| ការពារ | kaapia | to protect, to defend |
| កាលពីប៉ុន្មានថ្ងៃនេះ | kaal pii pəmaan ŋay nih | in the last few days |
| កើតឡើង | kaat laəŋ | to arise, to come about (R) |
| គ្រួស | kruoh | gravel (L) |
| គ្រោះថ្នាក់ | krúh thnaʔ | accident, danger |
| ចម្លង | cəlɔɔŋ | to take across; to copy |
| ច្បាស់ | cbah | clear |
| ឆ្លងទន្លេ | chlɔɔŋ təlee | to give birth |
| ជាតិ | ciat | nation |
| ជំនួស | cənuoh | instead of (R) |
| ឈាម | chiam | blood |
| តំណាង | tənaaŋ | to represent |
| ត្រង់សេ | trɔŋsəə | trench |
| ទំនិញ | təniñ | merchandise, goods |
| នាំ | nóm | to transport, to lead, to take a person somewhere |
| បញ្ជា | bɔñcia | to order |
| ផ្ទុក | phtuk | to load |
| ព្រឹត្តិការណ៍ | prətəkaa | event (R) |
| មេ | mee | leader, head |
| របួស | ləbuoh | to be wounded |
| រ៉ុក្កែត | rokkɛt | rocket |
| រឿង | rɨəŋ | story, matter, problem |
| ល្មមតែ | ləmóom taɛ | by the time that |
| វិបត្តិ | vəbat | crisis, destructive event (L) |
| សង្ស័យ | sɔŋsay | to suspect |
| សន្តិសុខជាតិ | sɔntəsok ciat | national security |
| សាឡាង | səlaaŋ | ferry boat |
| ស្ម័គ្រចិត្ត | smaʔ cət | to volunteer |
| ឡានទឹក | laan tɨk | fire truck |
| អ្នកតំណាងកាសែត | néʔ tənaaŋ kəsaɛt | press representative |

PASSAGE D

# ឪពុកនិងកូនប្រុសបួននាក់

មានអ្នកស្រែម្នាក់មានកូនប្រុសបួននាក់ ។ មានមួយថ្ងៃអ្នកស្រែនោះ ហៅកូនទាំងបួននាក់មកប្រជុំគ្នានៅមុខតុមួយ នៅលើតុនោះមានចង្កឹះមួយ



បាច់ និងប្រាក់មួយថង់ ឪពុកនិយាយទៅនឹងកូនទាំងបួននាក់ថា អញនឹងឲ្យប្រាក់មួយថង់នេះទៅកូនណា ដែលកាច់ចង្កឹះមួយបាច់នេះបាក់ ។ កូនទាំងអស់គ្នា ក៏ល្បងកាច់បាច់ចង្កឹះនោះម្នាក់ម្តង ៗ ប៉ុន្តែគ្មានកូនណាមួយកាច់បាច់ចង្កឹះនោះបាក់ឡើយ ។ ឪពុកក៏ស្រាយបាច់ចង្កឹះយកមកកាច់មួយម្តង ៗ ចង្កឹះបាក់បានដោយងាយ ។ កូនទាំងបួននាក់និយាយព្រមគ្នាថា បើកាច់ដូច្នេះ មិនពិបាកទេ ។ ឪពុកនិយាយថា ហៃកូនទាំងឡាយ! ឪពុកចង់បង្ហាញឯងរាល់គ្នាឲ្យដឹងថា នៅជួបជុំគ្នានាំឲ្យមានកំលាំង ៗ កាល

ណាអញស្លាប់ទៅ ចូរឯងរាល់គ្នានឹកគិតដល់រឿងបាច់ចង្កឹះនេះ ប្រយោជន៍ការពារសត្រូវពីក្រៅ ។ ចូរឯងស្រឡាញ់គ្នា ជួយគ្នាទៅវិញទៅមក ត្រូវនៅរួបរួមគ្នា ដូចបាច់ចង្កឹះនេះ ។

| | | |
|---|---|---|
| បាច់ | bac | bundle |
| ថង់ | thɔŋ | (small) bag |
| កាច់ | kac | to break by snapping off, e.g., a twig |
| ស្រាយ | sraay | to untie |
| ដោយងាយ | daoy ŋiay | easily |
| ងាយ | ŋiay | easy |
| ទាំងបួន | téŋ buon | all four |
| ព្រម | próom | to agree |
| ហៃ | hay | particle for calling attention of listener (familiar) |
| ទាំងឡាយ | téŋ laay | marks, plural |
| ឪពុក | əwpuk | I(father) |
| រាល់គ្នា | ról knia | all (together) |
| នឹក | nɨk | to think, to visualize, to recall |
| ប្រយោជន៍ | pəyaoc | with the purpose of... |
| ការពារ | kaa pia | to protect from, to defend |
| ស្រឡាញ់ | səlañ | to love, to like |
| រួបរួម | ruop ruom | to unite, to be united |

# LESSON FIFTY-ONE

## DIALOGUE

| | | | |
|---|---|---|---|
| | | ឃ្លាំង | depot, cache, warehouse |
| | | លាក់ | to hide something |
| | | អាវុធ | weapons, arms |
| | | សត្រូវ | enemy |
| ១. | ឃុម | ប៉ុន្មានអាទិត្យមុន យើងរកឃើញឃ្លាំងលាក់អាវុធរបស់សត្រូវមួយ ។ | In the last few weeks, we found an enemy weapons cache. |
| ២. | សុខ | លោកឃើញនៅឯណា? | Where did you find it? |
| | | ក្បែរ | next to |
| | | ខាងជើង | north |
| | | ព្រំដែនខ្មែរ-យួន | Cambodian-Vietnamese border |
| ៣. | ឃុម | នៅខាងជើងទីក្រុងតាយនិញ ក្បែរព្រំដែនខ្មែរ-យួន ។ | North of the (Vietnamese) city Tay Ninh, next to the Cambodian-Vietnamese border. |
| | | ឲ្យការ | to tip off (with information) |
| ៤. | សុខ | អ្នកណាឲ្យការលោក? | Who tipped you off? |
| ៥. | ឃុម | គ្មានអ្នកណាឲ្យការទេ តែយើងសង្ស័យកន្លែងហ្នឹង ។ | Nobody did, but we suspected that place. |
| ៦. | សុខ | មានអីខ្លះក្នុងឃ្លាំងហ្នឹង? | What was there in that depot? |
| | | ដើម | stem (classifier for rifles) |
| | | ជាច្រើន | many |
| ៧. | ឃុម | មានកាំភ្លើងសាម-សែសិបដើម នឹងគ្រាប់ជាច្រើន ។ | There were some thirty or forty rifles, and lots of ammunition. |
| | | ស្បៀងអាហារ | food supply, provisions |
| ៨. | សុខ | ចុះ មានស្បៀងអាហារទេ? | And were there any provisions? |
| | | បាវ | bale, sack |
| | | ត្រីងៀត | dried fish |
| | | ត្រីឆ្អើរ | smoked fish |
| ៩. | ឃុម | បាទ មានអង្ករបួនប្រាំបាវ នឹងត្រីងៀតត្រីឆ្អើរខ្លះ ។ | Yes, four or five sacks of rice, and some dried and smoked fish. |

DIALOGUE:

1. tom - pəmaan aatɨt mun, yəəŋ róo khəəñ khléŋ léʔ əvút ləbɔh sətrəw muoy

2. sok - look khəəñ nɨw aεnaa?

3. tom - nɨw khaaŋ cəəŋ tii krɔŋ taay niñ kbaε prúm daεn khmaε-yuon

4. sok - néʔnaa aoy kaa look?

5. tom - kmian néʔnaa aoy kaa tee, tə yəəŋ sɔŋsay kəlaεŋ nɨŋ

6. sok - mian εy khlah knɔŋ khléŋ nɨŋ?

7. tom - mian kəmphləəŋ saam saε səp daəm, nɨŋ krɔ́p cia craən

8. sok - coh, mian sbieŋ əhaa tee?

9. tom - baat, mian ŋkɔɔ buon pram baav, nɨŋ trεy ŋiet, trεy chʔaə khlah

NOTES

DIALOGUE

SENTENCE NO.

3. The cardinal directions are

ខាងជើង /khaaŋ cəəŋ/ 'north'
ខាងកើត /khaaŋ kaət/ 'east'
ខាងត្បូង /khaaŋ tbouŋ/ 'south'
ខាងលិច /khaaŋ lεc/ 'west'

The words for 'north' and 'south' come from an ancient Cambodian custom in which people slept with their heads to the south: ត្បូង /tbouŋ/ an old word for 'head;' and their feet to the north: ជើង /cəəŋ/ 'foot, leg.' កើត /kaət/ 'east; to be born' refers to the rising of the sun in the east; លិច /lεc/ 'west' on the other hand means 'to sink, to set' and refers to the setting of the sun in the west.

Intermediate directions are named by putting the word ឆៀង /chieŋ/ between the names of the two primary directions, e.g.,

ខាងត្បូងឆៀងខាងកើត។
khaaŋ tbouŋ chieŋ khaaŋ kaət
southeast

The word ជ្រុង /cruŋ/ 'corner' may be used instead of ឆៀង /chieŋ/, e.g.

ខាងត្បូងជ្រុងខាងកើត។
khaaŋ tbouŋ cruŋ khaaŋ kaət
southeast

7. Note the quick way to say approximate numbers like 'fifty or sixty' when the two numbers concerned end in សិប /səp/: for the first number the first part of the number is given, then the entire second number, e.g., ហាហុកសិប /haa hok səp/ 'fifty or sixty.' This is equivalent to ហាសិបឬហុកសិប /haasəp rɨɨ hoksəp/ 'fifty or sixty.'

DRILLS

DRILL NO.

2. Note that the Cambodian name for Saigon is ព្រៃនគរ /prɛy nokóo/. Saigon and the Mekong Delta were formerly part of the Khmer Empire before the Vietnamese came down from the north. The Delta area still has many ethnic Cambodians living in it and is known to Cambodians as កម្ពុជាក្រោម /kampucia kraom/ 'Kampuchea Krom' or 'Lower Cambodia.' The ethnic Cambodians there are called ខ្មែរកម្ពុជាក្រោម /khmaɛ kampucia kraom/ or ខ្មែរក្រោម /khmaɛ kraom/ 'Khmer Krom.' (See also the grammatical sketch Chapter I.)

DRILLS

DRILL ONE: Substitution

MODEL: T: យើងរកឃើញឃ្លាំងលាក់អាវុធរបស់សត្រូវមួយ។ (កាំភ្លើង)

S: យើងរកឃើញឃ្លាំងលាក់កាំភ្លើងរបស់សត្រូវមួយ។

T: We found a weapons cache of the enemy. (rifles)

S: We found a rifle cache of the enemy.

ក. យើងរកឃើញឃ្លាំងលាក់កាំភ្លើងរបស់សត្រូវមួយ។ (ហ៊ាំង)
ខ. យើងរកឃើញឃ្លាំងលាក់កាំភ្លើងរបស់ហ៊ាំងមួយ។ (បំផ្លាញ)
គ. យើងបំផ្លាញឃ្លាំងលាក់អាវុធរបស់ហ៊ាំងមួយ។ (ស្បៀងអាហារ)
ឃ. យើងបំផ្លាញឃ្លាំងលាក់ស្បៀងអាហាររបស់ហ៊ាំងមួយ។ (ដុត)
ង. យើងដុតឃ្លាំងលាក់ស្បៀងអាហាររបស់ហ៊ាំងមួយ។ (កន្លែង)
ច. យើងដុតកន្លែងលាក់ស្បៀងអាហាររបស់ហ៊ាំងមួយ។

DRILL TWO: Substitution

MODEL: T: នៅខាងជើងទីក្រុងតាយនិញក្បែរព្រំដែនខ្មែរ-យួន។ (ខាងត្បូង)

S: នៅខាងត្បូងទីក្រុងតាយនិញក្បែរព្រំដែនខ្មែរ-យួន។

T: It's north of the city Tay Ninh, near the Cambodian-Vietnamese border. (south)

S: It's south of the city Tay Ninh, near the Cambodian-Vietnamese border.

ក. នៅខាងត្បូងទីក្រុងតាយនិញក្បែរព្រំដែនខ្មែរ-យួន។ (ព្រៃនគរ)
ខ. នៅខាងត្បូងទីក្រុងព្រៃនគរក្បែរព្រំដែនខ្មែរ-យួន។ (យួន-លាវ)

ក. នៅខាងត្បូងទីក្រុងព្រៃនគរ ក្បែរព្រំដែនយួន-លាវ។ (ខាងកើត)
ឃ. នៅខាងកើតទីក្រុងព្រៃនគរ ក្បែរព្រំដែនយួន-លាវ។ (ក្រចេះ)
ង. នៅខាងកើតទីក្រុងក្រចេះ ក្បែរព្រំដែនយួន-លាវ។ (ខាងលិច)
ច. នៅខាងលិចទីក្រុងក្រចេះ ក្បែរព្រំដែនយួន-លាវ។

DRILL THREE: Transformation

MODEL: T: យើងរកឃើញកន្លែងលាក់ស្បៀងអាហារមួយនៅជិតទីក្រុងនគរ។ (ជើង-កើត)

S: យើងរកឃើញកន្លែងលាក់ស្បៀងអាហារមួយនៅខាងជើងឆៀងខាងកើតទីក្រុងព្រៃនគរ។

T: We found a food cache near the city of Saigon. (northeast)

S: We found a food cache northeast of the city of Saigon.

ក. ផ្ទះខ្ញុំនៅជិតសាលារៀន។ (កើត-ត្បូង)
ផ្ទះខ្ញុំនៅខាងកើតឆៀងខាងត្បូងសាលារៀន។
ខ. ខ្ញុំឃើញគ្រោះថ្នាក់មួយក្បែរវ៉ាស៊ីនតោន។ (ជើង-លិច)
ខ្ញុំឃើញគ្រោះថ្នាក់មួយនៅខាងជើងឆៀងខាងលិចវ៉ាស៊ីនតោន។
គ. ខ្ញុំកើតនៅជិតទីក្រុងភ្នំពេញ។ (ត្បូង-លិច)
ខ្ញុំកើតនៅខាងត្បូងឆៀងខាងលិចទីក្រុងភ្នំពេញ។
ឃ. ខ្ញុំឈប់ឡានខ្ញុំនៅជិតសាលា។ (កើត-ជើង)
ខ្ញុំឈប់ឡានខ្ញុំនៅខាងកើតឆៀងខាងជើងសាលា។
ង. គេធ្វើជំបាំងនៅជិតស្រុកយួន។ (ជើង-កើត)
គេធ្វើជំបាំងនៅខាងជើងឆៀងខាងកើតស្រុកយួន។
ច. ទាហានចាប់ខ្មាំងម្នាក់បាននៅជិតប៉ុស្តិ៍។ (ត្បូង-កើត)
ទាហានចាប់ខ្មាំងម្នាក់បាននៅខាងត្បូងឆៀងខាងកើតប៉ុស្តិ៍។

DRILL FOUR: Transformation

MODEL: T: មានឃ្លាំងលាក់អាវុធខ្មាំងមួយ។ (លោកសៅ)

S: លោកសៅឲ្យការណ៍ខ្ញុំថាមានឃ្លាំងលាក់អាវុធខ្មាំងមួយ។

T: There was a weapons cache of the enemy. (Mr. Saw)

S: Mr. Saw tipped me off that there was a weapons cache of the enemy.

ក. ខ្ញុំមិនទៅរៀន។ (នាងស៊ីហា)
នាងស៊ីហាឲ្យការណ៍ថាលោកមិនទៅរៀន។
ខ. ខ្ញុំចង់ឈប់ធ្វើការនៅកន្លែងនេះ។ (លោកម៉ម)
លោកម៉មឲ្យការខ្ញុំថាលោកចង់ឈប់ធ្វើការនៅកន្លែងនេះ។

គ. លោកសក្តិពីរផ្លាស់ទៅស្រុកប្អូន។ (ឪពុកគាត់)
ឪពុកគាត់ឲ្យការណ៍ខ្ញុំថាលោកសក្តិពីរផ្លាស់ទៅស្រុកប្អូន។
ឃ. ខ្ញុំមានកាំភ្លើងមួយ។ (ប៉ុលិស)
ប៉ុលិសឲ្យការណ៍ខ្ញុំថាលោកមានកាំភ្លើងមួយ។
ង. លោកលួចឡាននេះ។ (គេ)
គេឲ្យការណ៍ខ្ញុំថាលោកលួចឡាននេះ។
ច. ខ្ញុំទៅជួបអាមេរិកាំងម្នាក់។ (ប៉ុលិស)
ប៉ុលិសឲ្យការណ៍ខ្ញុំថាលោកទៅជួបអាមេរិកាំងម្នាក់។

DRILL FIVE: Substitution

MODEL: T: យើងយកកាំភ្លើងពីខ្មាំងបានសែសិបដើម។ (ដប់)
S: យើងយកកាំភ្លើងពីខ្មាំងបានដប់ដើម។
T: We captured 40 rifles from the enemy. (ten)
S: We captured 10 rifles from the enemy.

ក. យើងយកកាំភ្លើងពីខ្មាំងបានដប់ដើម។ (ទិញ)
ខ. យើងទិញកាំភ្លើងពីខ្មាំងបានដប់ដើម។ (លួច)
គ. យើងលួចកាំភ្លើងពីខ្មាំងបានដប់ដើម។ (ប្រាំ)
ឃ. យើងលួចកាំភ្លើងពីខ្មាំងបានប្រាំដើម។ (ខ្ញុំ)
ង. ខ្ញុំលួចកាំភ្លើងពីខ្មាំងបានប្រាំដើម។ (កងអនុសេនាតូច)
ច. ខ្ញុំលួចកាំភ្លើងពីកងអនុសេនាតូចបានប្រាំដើម។

DRILL SIX: Substitution

MODEL: T: ខ្ញុំត្រូវរបួសក្បាល។ (ជើងស្តាំ)
S: ខ្ញុំត្រូវរបួសជើងស្តាំ។
T: I was wounded in the head. (right leg)
S: I was wounded in the right leg.

ក. ខ្ញុំត្រូវរបួសជើងស្តាំ។ (ចង្កេះ)
ខ. ខ្ញុំត្រូវរបួសចង្កេះ។ (ស្មា)
គ. ខ្ញុំត្រូវរបួសស្មា។ (ក)
ឃ. ខ្ញុំត្រូវរបួសក។ (ដៃឆ្វេង)
ង. ខ្ញុំត្រូវរបួសដៃឆ្វេង។ (ពោះ)
ច. ខ្ញុំត្រូវរបួសពោះ។ (ទ្រូង)
ឆ. ខ្ញុំត្រូវរបួសទ្រូង។

DRILL SEVEN: Response

MODEL: T: ខ្ញុំត្រូវរបួសក្បាល។ (មុខ)
S: លោកមានសំណាងណាស់ លោកមិនត្រូវរបួសមុខទៀត។

T: I was wounded in the head. (face)

S: You were very lucky that you were not wounded in the face again.

ក. ខ្ញុំត្រូវរបួសជើងស្តាំ។ (ជើងឆ្វេង)
លោកមានសំណាងណាស់ លោកមិនត្រូវរបួសជើងឆ្វេងទៀត។

ខ. ខ្ញុំត្រូវរបួសចង្កេះ។ (ពោះ)
លោកមានសំណាងណាស់ លោកមិនត្រូវរបួសពោះទៀត។

គ. ខ្ញុំត្រូវរបួសស្មា។ (ទ្រូង)
លោកមានសំណាងណាស់ លោកមិនត្រូវរបួសទ្រូងទៀត។

ឃ. ខ្ញុំត្រូវរបួសភ្លៅ។ (ចង្កេះ)
លោកមានសំណាងណាស់ លោកមិនត្រូវរបួសចង្កេះទៀត។

ង. ខ្ញុំត្រូវរបួសដៃឆ្វេង។ (ដៃស្តាំ)
លោកមានសំណាងណាស់ លោកមិនត្រូវរបួសដៃស្តាំទៀត។

ច. ខ្ញុំត្រូវរបួសទ្រូង។ (ក្បាល)
លោកមានសំណាងណាស់ លោកមិនត្រូវរបួសក្បាលទៀត។

DRILL EIGHT: Response

MODEL: T: លោកបំរុងធ្វើទាហានប៉ុន្មានឆ្នាំ? (តែបីឆ្នាំទេ)
S: ខ្ញុំបំរុងធ្វើទាហានតែបីឆ្នាំទេ។

T: How long do you intend to serve in the armed forces? (only three years)

S: I intend to serve only 3 years.

ក. លោកបំរុងទៅស្រុកយួនអង្កាល់? (ឆ្នាំក្រោយ)
ខ្ញុំបំរុងទៅស្រុកយួនឆ្នាំក្រោយ។

ខ. លោកបំរុងចេញពីទាហានអង្កាល់? (ពីរឆ្នាំទៀត)
ខ្ញុំបំរុងចេញពីទាហានពីរឆ្នាំទៀត។

គ. លោកបំរុងបំផ្លាញជំរំនោះអង្កាល់? (បីថ្ងៃទៀត)
ខ្ញុំបំរុងបំផ្លាញជំរំនោះបីថ្ងៃទៀត។

ឃ. លោកបំរុងប្រាប់លោកសក្តិបីអង្កាល់? (ស្អែក)
ខ្ញុំបំរុងប្រាប់លោកសក្តិបីស្អែក។

ង. លោកបំរុងរៀនយួនអង្កាល់? (កាលណាខ្ញុំរៀនខ្មែរចប់)
ខ្ញុំបំរុងរៀនយួនកាលណាខ្ញុំរៀនខ្មែរចប់។

ច. លោកបំរុងនៅស្រុកនេះប៉ុន្មានឆ្នាំ? (ដប់)
ខ្ញុំបំរុងនៅស្រុកនេះដប់ឆ្នាំ។

DRILL NINE: Response

MODEL: T: លោកចង់ធ្វើអីកាលណាលោករៀនចប់? (ធ្វើទាហាន)
S: ខ្ញុំចង់ធ្វើទាហានកាលណាខ្ញុំរៀនចប់។
T: What do you intend to do when you finish studying? (join the service)
S: I intend to join the service when I finish studying.

ក. លោកចង់ធ្វើអីកាលណាលោកឈប់ធ្វើទាហាន? (ធ្វើប៉ូលិស)
ខ្ញុំចង់ធ្វើប៉ូលិសកាលណាខ្ញុំឈប់ធ្វើទាហាន។
ខ. លោកចង់ធ្វើអីកាលណាលោកឈប់ធ្វើប៉ូលិស? (ទៅរៀនពេទ្យ)
ខ្ញុំចង់ទៅរៀនពេទ្យកាលណាខ្ញុំឈប់ធ្វើប៉ូលិស។
គ. លោកចង់ធ្វើអីកាលណាលោករៀនពេទ្យចប់? (ទៅស្រុកយួន)
ខ្ញុំចង់ទៅស្រុកយួនកាលណាខ្ញុំរៀនពេទ្យចប់។
ឃ. លោកចង់ធ្វើអីកាលណាលោកមកពីស្រុកយួនវិញ? (គ្រូបង្រៀន)
ខ្ញុំចង់ធ្វើគ្រូបង្រៀនកាលណាខ្ញុំមកពីស្រុកយួនវិញ។
ង. លោកចង់ធ្វើអីកាលណាលោកឈប់ធ្វើគ្រូបង្រៀន? (ទៅរៀន)
ខ្ញុំចង់ទៅរៀនកាលណាខ្ញុំឈប់ធ្វើគ្រូបង្រៀន។
ច. លោកចង់ធ្វើអីកាលណាលោករៀនចប់? (ធ្វើទាហាន)
ខ្ញុំចង់ធ្វើទាហានកាលណាខ្ញុំរៀនចប់។

DRILL TEN: Substitution

MODEL: T: ខ្ញុំចង់លួចចេញពីទាហាន។ (គុក)
S: ខ្ញុំចង់លួចចេញពីគុក។
T: I intend to escape from military service. (prison)
S: I intend to escape from prison.

ក. ខ្ញុំចង់លួចចេញពីគុក។ (សាលា)
ខ. ខ្ញុំចង់លួចចេញពីសាលា។ (ស្រុកខ្មែរ)
គ. ខ្ញុំចង់លួចចេញពីស្រុកខ្មែរ។ (ប៉ូលិស)
ឃ. ខ្ញុំចង់លួចចេញពីប៉ូលិស។ (ផ្ទះ)
ង. ខ្ញុំចង់លួចចេញពីផ្ទះ។ (ទាហានជើងគោក)
ច. ខ្ញុំចង់លួចចេញពីទាហានជើងគោក។

DRILL ELEVEN: Transformation

MODEL: T: មានសាមសិបនាក់ទៀត។
S: តាមការរាយការណ៍ចុងក្រោយបំផុត មានសាមសិបនាក់ទៀត។
T: There are thirty more persons.
S: According to the latest report, there are thirty more persons.

ក. យើងបំផ្លាញរថក្រោះខ្មាំងអស់ប្រាំទៀត។
តាមការរាយការណ៍ចុងក្រោយបំផុត យើងបំផ្លាញរថក្រោះខ្មាំងអស់ប្រាំទៀត។
ខ. កងទ័ពយើងបានវាយយកបន្ទាយនោះវិញហើយ។
តាមការរាយការណ៍ចុងក្រោយបំផុត កងទ័ពយើងបានវាយយកបន្ទាយនោះវិញហើយ។
គ. កងទ័ពខ្មាំងនិងកងទ័ពយើងមានកម្លាំងស្មើគ្នា។
តាមការរាយការណ៍ចុងក្រោយបំផុត កងទ័ពខ្មាំងនិងកងទ័ពយើងមានកម្លាំងស្មើគ្នា។
ឃ. យើងមិនអាចទប់ទល់និងខ្មាំងបានទេ។
តាមការរាយការណ៍ចុងក្រោយបំផុត យើងមិនអាចទប់ទល់និងខ្មាំងបានទេ។
ង. កងទ័ពខ្មាំងពីរក្រុមទៀតមកបន្ថែមកម្លាំងកងទ័ពព្រៃ។
តាមការរាយការណ៍ចុងក្រោយបំផុត កងទ័ពខ្មាំងពីរក្រុមទៀតមកបន្ថែមកម្លាំងកងទ័ពព្រៃ។
ច. យើងត្រូវដកទ័ពថយពីតំបន់ហាមមិនឲ្យដាក់កងទ័ព។
តាមការរាយការណ៍ចុងក្រោយបំផុត យើងត្រូវដកទ័ពថយពីតំបន់ហាមមិនឲ្យដាក់កងទ័ព។

DRILL TWELVE: Transformation

MODEL:
T: ខ្មាំងកាប់ដើមឈើបាំងផ្លូវទៅព្រៃនគរ។ (ផ្លូវជាតិលេខប្រាំ)
S: ខ្មាំងកាប់ដើមឈើបាំងផ្លូវទៅព្រៃនគរទាំងអស់លើកលែងតែផ្លូវជាតិលេខប្រាំ។
T: The enemy blocks the roads to Saigon. (national route 5)
S: The enemy blocks all the roads to Saigon except national route 5.

ក. រាល់ល្ងាចអ្នកស្រុកស្តាប់រ៉ាដ៍យោ។ (រ៉ាដ៍យោប៉េកាំង)
រាល់ល្ងាចអ្នកស្រុកស្តាប់រ៉ាដ៍យោទាំងអស់លើកលែងតែរ៉ាដ៍យោប៉េកាំង។
ខ. ខ្ញុំឆ្លើយសំនួរទាំងអស់។ (សំនួរផ្ទាល់ខ្លួន)
ខ្ញុំឆ្លើយសំនួរទាំងអស់ លើកលែងតែសំនួរផ្ទាល់ខ្លួន។
គ. ខ្មាំងប្រថុយវាយជាមួយកងទ័ពទាំងអស់។ (ទាហានអាមេរិកាំង)
ខ្មាំងប្រថុយវាយជាមួយកងទ័ពទាំងអស់លើកលែងតែទាហានអាមេរិកាំង។
ឃ. អ្នកស្រុកមើលត្រាក់ទាំងអស់។ (ត្រាក់កុម្មុយនិស្ត)
អ្នកស្រុកមើលត្រាក់ទាំងអស់លើកលែងតែត្រាក់កុម្មុយនិស្ត។
ង. ឃ្លាំងស្បៀងអាហារទាំងអស់ត្រូវកងទ័ពព្រៃបំផ្លាញ។ (ឃ្លាំងនៅជិតបន្ទាយ)
ឃ្លាំងស្បៀងអាហារទាំងអស់ត្រូវកងទ័ពព្រៃបំផ្លាញលើកលែងតែឃ្លាំងនៅជិតបន្ទាយ។

DRILL THIRTEEN: Substitution

MODEL: T: ថ្ងៃនេះធាតុអាកាសមិនល្អទេ។ (មានភ្លៀងធំច្រើននៅផ្នែកខាងជើង)
S: ថ្ងៃនេះមានភ្លៀងធំច្រើននៅផ្នែកខាងជើង។
T: Today the weather is not good. (heavy rain in the Northern region)
S: Today, there is heavy rain in the Northern region.

ក. ថ្ងៃនេះមានភ្លៀងធំច្រើននៅផ្នែកខាងជើង។ (ពពកងងឹតហើយនិងមានខ្យល់ព្យុះ)
ខ. ថ្ងៃនេះពពកងងឹតហើយនិងមានខ្យល់ព្យុះ។ (មានចុះអ័ព្ទនៅពេលព្រឹក)
គ. ថ្ងៃនេះមានចុះអ័ព្ទនៅពេលព្រឹក។ (មានភ្លៀងនិងរន្ទះនៅប្រហែលម៉ោងប្រាំពីរ)
ឃ. ថ្ងៃនេះមានភ្លៀងនិងរន្ទះនៅប្រហែលម៉ោងប្រាំពីរ។ (ខ្យល់កួចមានល្បឿនមួយរយគីឡូមួយម៉ោង)
ង. ថ្ងៃនេះខ្យល់កួចមានល្បឿនមួយរយគីឡូមួយម៉ោង។ (មានធ្លាក់ទឹកកកនៅតំបន់ភ្នំ)
ច. ថ្ងៃនេះមានធ្លាក់ទឹកកកនៅតំបន់ភ្នំ។

DRILL FOURTEEN: Response

MODEL: T: ទីក្រុងនោះនៅតែនៅក្រោមអំណាចរបស់ខ្មាំង។ (ខ្លាំងជាងកងទ័ពរដ្ឋការ)
S: នេះបញ្ជាក់ឲ្យឃើញថាខ្មាំងនៅតែខ្លាំងជាងទ័ពរដ្ឋការ។
T: That city is still under enemy control. (stronger than the government troops)
S: This shows that the enemy is still stronger than the government troops.

ក. កងទ័ពរដ្ឋការមិនអាចវាយយកទីក្រុងនោះទេ។ (ខ្សោយជាងកងទ័ពខ្មាំង)
នេះបញ្ជាក់ឲ្យឃើញថាកងទ័ពរដ្ឋការនៅតែខ្សោយជាងកងទ័ពខ្មាំង។
ខ. ខ្មាំងបានពង្រឹងកងទ័ពនៅតាមព្រំដែន។ (នាំទ័ពចូលតាមផ្លូវដដែល)
នេះបញ្ជាក់ឲ្យឃើញថាខ្មាំងនៅតែនាំទ័ពចូលតាមផ្លូវដដែល។
គ. កប៉ាល់ហោះអាមេរិកាំងទម្លាក់គ្រាប់បែកនៅក្នុងព្រំដែនខ្មែរ។ (ទម្លាក់គ្រាប់បែកលើទឹកដីខ្មែរ)
នេះបញ្ជាក់ឲ្យឃើញថាកប៉ាល់ហោះអាមេរិកាំងនៅតែទម្លាក់គ្រាប់បែកលើទឹកដីខ្មែរ។
ឃ. ខ្មាំងបានបំផ្លាញផ្លូវច្រើន។ (ខ្លាំងជាងកងទ័ពយើង)
នេះបញ្ជាក់ឲ្យឃើញថាខ្មាំងនៅតែខ្លាំងជាងកងទ័ពយើង។
ង. ពួកវៀតកុងនាំទ័ពចូលស្រុកខ្មែររាល់ថ្ងៃ។ (មិនគោរពទឹកដីខ្មែរ)
នេះបញ្ជាក់ឲ្យឃើញថាពួកវៀតកុងនៅតែមិនគោរពទឹកដីខ្មែរ។

## Reading Passage

### មិត្តសម្លាប់មិត្ត
### (រឿងកើតនៅប្រទេសអឺរ៉ុបក្នុងឆ្នាំ១៩៤៥)

ការប្រតិបត្តិការទាំងកងទ័ពនៃមិត្តយើងប្រកបដោយជោគជ័យជានិច្ច តែសកម្មភាពនៃសត្រូវនៅក្នុងស្រុកយើងនៅតែដដែល និងជួនកាលខ្លាំងជាងមុនៗផង។

តាមការរាយការណ៍នៃអ្នកឱ្យការណ៍របស់យើង ហេតុដែលធ្វើឱ្យខ្មាំងមានសកម្មភាពយ៉ាងនោះមកពីមិត្តនោះ។ រឿងនេះធ្វើឱ្យយើងព្រួយខ្លាំងណាស់។ យើងត្រូវតែសុំឱ្យទាហានមិត្តយើងចេញពីស្រុកយើងក្នុងពេលយ៉ាងខ្លី។ បើយើងមិនធ្វើយ៉ាងនេះទេ ស្រុកយើងមុខជាទទួលគ្រោះថ្នាក់យ៉ាងធំ។

មិត្តយើងមកស្រុកយើងនេះ គឺគេមកដើម្បីជួយយើង។ តែឥឡូវគេសម្លាប់អ្នកស្រុកយើងរួចយកស្បៀងអាហារដូចជាអង្ករនិងត្រីងៀត ត្រីឆ្អើរ រាប់ជ៉ារ។ អ្នកស្រុកដែលគេសម្លាប់ គេរាប់ជាសត្រូវយើង និងរបស់និងស្បៀងអាហារទាំងប៉ុន្មានដែលគេយកពីអ្នកស្រុក គេថាជារបស់ខ្មាំងដែរ។

ពេលមិត្តយើងសម្លាប់អ្នកស្រុកយើងហើយ គេយកអាវុធគេទៅដាក់ជិតអ្នកស្លាប់នោះរួចគេរាយការណ៍ថាអាវុធទាំងនោះជាអាវុធរបស់ខ្មាំង។ ក្នុងការរាយការណ៍នោះ អាវុធភាគច្រើនធ្វើនៅស្រុកអាមេរិក និងខ្លះធ្វើនៅស្រុកចិន ឬនៅស្រុករុស្ស៊ី។ អាវុធពីស្រុកអាមេរិកគឺដូចជាការ៉ាប៊ីន កាំភ្លើងស្វ័យប្រវត្តិ ភាគច្រើន និងបាហ្សូកាជាដើម។

មិត្តយើងនិងសត្រូវយើងត្រូវគ្នា។ មិត្តយើងធ្វើការប្រតិបត្តិការនៅស្រុកយើងកន្លែងណាក៏ដោយ សត្រូវដឹងមុនជានិច្ច។ គេមិនសូវបាញ់គ្នាទេ។ តែជួនកាលដើម្បីធ្វើឱ្យយើងជឿថាគេជួយយើងដើម្បីដេញសត្រូវឱ្យចេញពីស្រុកយើង មិត្តយើងនិងសត្រូវយើងធ្វើជាបាញ់គ្នាម្តង។ ពួកខាងសត្រូវបាញ់មិត្តយើងជានិច្ច។ មុនពេលចេញពីកន្លែងបាញ់គ្នានោះ ពួកសត្រូវតែងតែចោលឬកប់អាវុធនៅកន្លែងនោះ។ ដល់ពេលមិត្តយើងទៅដល់ គេឃើញ រួចគេធ្វើការរាយការណ៍អំពីអាវុធដែលចោលឬកប់នោះ។ ពួកសត្រូវធ្វើយ៉ាងនោះដើម្បីជួយមិត្តយើងឱ្យបាននៅស្រុកយើងបានយូរទៅទៀត។ ឯមិត្តយើងវិញ ដើម្បីឱ្យសត្រូវមានអាវុធយកទៅធ្វើយ៉ាងនោះទៀត និងសម្លាប់យើងផង មិនដែលយកអាវុធដែលរកឃើញនោះទៅទុកទេ គេកប់ទុកឱ្យសត្រូវនៅកន្លែងដដែលទៀត។ រួចគេមិនគ្រាន់តែទុករបស់ទាំងអស់នោះឱ្យវិញទេ ជួនកាលគេឬអាវុធខ្លះដែលប្រើមិនកើតនិងរបស់គេថ្មីៗ ល្អៗ ឬគេឱ្យរបស់គេថែមទៀតផង។

ដូច្នេះមិត្តយើងក៏ដូចជាសត្រូវយើងដែរ គេគិតតែមួយយ៉ាង គឺសម្លាប់យើងដើម្បីយកទឹកដីយើង។

## VOCABULARY

| | | |
|---|---|---|
| កុម្មុយនិស្ត | kummənih | Communist |
| ខាងកើត | khaaŋ kaət | east |
| ខាងជើង | khaaŋ cəən | north |
| ខាងជើងឆៀងខាងកើត | khaaŋ cəən chieŋ kaaaŋ kaət | northeast |
| ខាងត្បូង | khaaŋ tbouŋ | south |
| ខាងលិច | khaaŋ lɛc | west |
| ខ្យល់កួច | khyɔl kuoc | tornado |
| ខ្យល់ព្យុះ | khyɔl pyuh | storm, typhoon, hurricane |
| ខ្មែរក្រោម | khmaɛ kraom | Khmer Krom (ethnic Cambodian in South Vietnam) |
| គុក | kuk | prison |
| គោរព | kərup | to respect, to honor, to obey |
| ខាំង | khéŋ | to block, to obstruct |
| ឃ្លាំង | khléŋ | depot |
| ងងឹត | ləŋɨt | dark |
| ចុងក្រោយបំផុត | coŋ kraoy mphot | last of all |
| ចុះ | coh | to descend |
| ឆៀង | chieŋ | forms compound directions, e.g. southeast, etc. |
| ជាច្រើន | cia craən | many |
| ជោគជ័យ | cook cɛy | victory, success (R) |
| ជ្រុង | cruŋ | corners; forms compound directions |
| តំបន់ | təbɔn | region, area |
| តំបន់ហាមមិនឲ្យដាក់កងទ័ព | təbɔn haam mɨn aoy daʔ kɔɔŋ tóp | demilitarized zone |
| ត្រាក់ | traʔ | tract, leaflet |
| ត្រីងៀត | trɛy ŋiet | dry fish |
| ត្រីឆ្អើរ | trɛy chʔaə | smoked fish |
| ត្រូវរបួស | trəw ləbuoh | to be wounded |
| ទទួលទាន | tətuol tien | to eat, drink (formal, impersonal)(L) |
| ទប់ទល់ | tɔɔ túl | to resist, to go against |
| ទឹកដី | tɨk dɛy | territory |
| ទ្វារកំពត | tvia kampot | Kampot's Gate (place name) |
| បន្ថែម | pəthaɛm | to increase (transitive) |
| បាវ | baav | bale |
| ប៉េកាំង | peekaŋ | Peking |
| បំផ្លាញ | pəphlaañ | to destroy |

| | | |
|---|---|---|
| បំរុង | mmoŋ | to intend |
| ប្រកបដោយ | pəkɔɔp daoy | to have, having, possessed of (literary) (R) |
| ប្រថុយ | pəthuy | to take a chance |
| ពពក | pəphook | cloud |
| ពង្រឹង | pərɨŋ | to strengthen, to stiffen, to harden |
| ព្រៃនគរ | prɛy ŋkóo | Saigon |
| ព្រំដែនខ្មែរ-យួន | prúm daɛn khmaɛ-yuon | Cambodian-Vietnamese border |
| ភ្ជង់ | phcúŋ | to point a weapon closely (L) |
| មានសំណាង | mian sənaaŋ | to be lucky |
| យ៉ុន | yón | a person's name (L) |
| រន្ទះ | ntɛh | lightning |
| របួស | ləbuoh | wound, to be wounded |
| រសៀល | əsiel | early afternoon (L) |
| លាក់ | lé? | to hide |
| សកម្មភាព | sakəməphiep | activity (R) |
| សត្រូវ | sətrəw | enemy |
| សំណាង | sənaaŋ | luck |
| ស្បៀងអាហារ | sbieŋ əhaa | food supply |
| អ័ព្ទ | ap | fog |
| អាវុធ | əvút | weapons, arms |
| អួន | uon | a person's name (L) |
| ឥស្សរៈ | ɛsəra? | free (literary); Isserak (name of Cambodian partisans who fought the French for independence) (L) |
| ឲ្យការណ៍ | aoy kaa | to tip off |

BODY PARTS

| | | |
|---|---|---|
| កែងដៃ | kaɛŋ day | elbow |
| កំភួនជើង | kəphuon cəəŋ | calf |
| ក្បាល | kbaal | head |
| ក្បាលជង្គង់ | kbaal cəkúŋ | kneecap |
| ខ្នង | knɔɔŋ | back |
| គូទ | kuut | one's behind, buttocks |
| ចង្កេះ | cəkɛh | waist |
| ច្រមុះ | cəmoh | nose |
| ត្រចៀក | təcie? | ear |
| ទ្រូង | truuŋ | chest |
| ពោះ | púh | stomach |
| ភ្លៅ | kəphləw | thigh |
| ម្រាមដៃ | məriam day | finger |
| ស្មា | smaa | shoulder |

## LESSON FIFTY-TWO

## DIALOGUE

ចូលដៃ — to sympathize with, to collaborate with

ពួកយៀកកុង — Viet Cong

១. តុម កាលពីមុនលោកចូលដៃពួកយៀកកុង មែនទេ? — Before you collaborated with the Viet Cong, didn't you?

២. សុខ បាទ ខ្ញុំនៅជាមួយគេជាង មួយឆ្នាំដែរ ។ — Yes, I stayed with them for more than a year.

រត់ចេញ — to desert

៣. តុម ម៉េចបានជាលោករត់ចេញមកវិញ? — Why did you desert?

ដេញ — to pursue, to chase, to expel, to kick out

គ្រាប់បែក — bomb

ទម្លាក់ — to drop

៤. សុខ ព្រោះកងទ័ពនឹងកប៉ាល់ហោះអាមេរិកាំងដេញបាញ់នឹងទម្លាក់គ្រាប់បែកលើយើងច្រើនពេក ។ — Because the American troops and airplanes chased us and dropped bombs on us too much.

ត្រូវគ្រាប់ — to be wounded (by a bullet)

៥. តុម លោកមានដែលត្រូវគ្រាប់ទេ? — Were you ever wounded?

ឡោមព័ទ្ធ — to ambush

៦. សុខ បាទ ត្រូវម្តងពេលទាហានអាមេរិកាំងឡោមព័ទ្ធយើង ។ — Yes, once, when the American troops ambushed us.

ធ្ងន់ — heavy; serious

៧. តុម គេបាញ់លោកត្រូវធ្ងន់ទេ? — Was it serious?

គ្រាន់បើ

វះតែ — almost

ងាប់ — to die

៨. សុខ ធ្ងន់គ្រាន់បើដែរ ព្រោះខ្ញុំវះតែងាប់ ។ — Fairly serious, because I almost died.

DIALOGUE:

1. tom - kaal pii mun look coul day puoˀ yieˀ koŋ, mɛɛn tee?

2. sok - baat, khñom nɨw cia muoy kee ciaŋ mə chnam daɛ

3. tom - mɛc baan cia look rut cəñ móo viñ?

4. sok - prúh kɔɔŋ tóp nɨŋ kəpal hɔh aameerɨkaŋ dəñ bañ nɨŋ təléˀ króp baɛk ləə yəəŋ craən peek

5. tom - look mian daɛl trəw króp eh?

6. sok - baat, trəw mə dɔɔŋ, peel təhian aameerɨkaŋ laom pót yəəŋ

7. tom - kee bañ look trəw thŋun eh?

8. sok - thŋun krón baə daɛ, prúh khñom vih taɛ ŋóp

NOTES

DIALOGUE

SENTENCE NO.

5. Here is an example of ត្រូវ /trəw/ 'to undergo, to experience' followed by a noun គ្រាប់ /króp/ 'bullet' as described in Lesson 36.

7. In this sentence ត្រូវ /trəw/ is a resultative verb meaning 'to be on target': បាញ់ត្រូវ /bañ trəw/ 'to shoot and hit on target' បាញ់មិនត្រូវ /bañ mɨn trəw/ 'to shoot and miss.'

8. The usual word for 'to die' is ស្លាប់ /slap/, which is used ordinarily for people. The word ងាប់ /ŋóp/ is usually used of animals and plants. When it refers to people it is very informal.

DRILLS

DRILL NO.

1. The ខ្មែរសេរី /khmaɛ seerɛy/ are a group of anti-Sihanouk Cambodians who operated out of South Vietnam before Sihanouk's overthrow in 1970.

5. Note that ដែរ /daɛ/ here means 'rather, somewhat,' not 'also.' That is, it serves to weaken the force of what precedes it, e.g.,

   ខ្ញុំចូលចិត្តម្ហូបចិនដែរ។
   khñom coul/cət məhoup cən daɛ.
   I like Chinese food (pretty well).

13. Note that certain verbs are intransitive and can be made transitive, with causative meaning, by affixation:

   a. Prefix ប៉ំ, បំ /pə-, bə-/ ផ្លាស់ /phlah/ 'to change' (intrans.) បំផ្លាស់ /pəphlah/ 'to cause to change' (transitive).

b. Prefix អំ(ដំ)/tə-/ ឡើង /laəŋ/ 'to rise' ដំឡើង /təlaəŋ/ 'to raise.'

c. Infix អំ, អុំ /-ɔm-, -um-/ (in fast speech /-ə-/) ស្លាប់ /slap/ 'to die' សម្លាប់ /səlap/ 'to kill.'

This relationship holds only for some verbs, so that if you try to make causative verbs from intransitive verbs that you know, sometimes you will be correct and sometimes you will not, especially since you will have to select the right prefix or infix as well.

## DRILLS

DRILL ONE: Transformation

MODEL: T: ខ្ញុំនៅជាមួយវៀតកុង។
S: កាលពីមុនខ្ញុំចូលដៃជាមួយវៀតកុង។
T: I stayed with the Viet Cong.
S: Before, I collaborated with the Viet Cong.

ក. ខ្ញុំធ្វើការឱ្យពួកស៊ី-អាយ-អេ។
កាលពីមុនខ្ញុំចូលដៃជាមួយពួកស៊ី-អាយ-អេ។

ខ. ខ្ញុំជួយទាហានអាមេរិកាំង។
កាលពីមុនខ្ញុំចូលដៃជាមួយទាហានអាមេរិកាំង។

គ. ខ្ញុំនៅជាមួយពួកខ្មែរសេរី។
កាលពីមុនខ្ញុំចូលដៃជាមួយពួកខ្មែរសេរី។

ឃ. ខ្ញុំធ្វើការឱ្យទាហានអាមេរិកាំង-យួនខាងត្បូង។
កាលពីមុនខ្ញុំចូលដៃជាមួយទាហានអាមេរិកាំង-យួនខាងត្បូង។

ង. ខ្ញុំជួយពួកកុម្មុយនិស្ត។
កាលពីមុនខ្ញុំចូលដៃជាមួយពួកកុម្មុយនិស្ត។

ច ខ្ញុំឱ្យកាំភ្លើងទៅវៀតកុង។
កាលពីមុនខ្ញុំចូលដៃជាមួយវៀតកុង។

DRILL TWO: Extension

MODEL: T: ក្រោយខ្ញុំរត់ចេញពីទាហានយួនខាងត្បូង (ពួកវៀតកុង)
S: ខ្ញុំចូលដៃជាមួយពួកវៀតកុង។
T: After I deserted from the South Vietnamese troops, (the Viet Cong)
S: I collaborated with the Viet Cong.

ក. ក្រោយខ្ញុំរត់ចេញពីកុម្មុយនិស្ត (ស៊ី-អាយ-អេ)
ខ្ញុំចូលដៃជាមួយពួកស៊ី-អាយ-អេ។

ខ. ក្រោយខ្ញុំរត់ចេញពីរាជការខ្មែរ (ពួកខ្មែរសេរី)
ខ្ញុំចូលដៃជាមួយពួកខ្មែរសេរី។

គ. ក្រោយខ្ញុំរត់ចេញពីទាហានខ្មែរ (ខ្មែរសេរី)
ខ្ញុំចូលដៃជាមួយខ្មែរសេរី។
ឃ. ក្រោយខ្ញុំរត់ចេញពីប៉ូលិស (ចោរ)
ខ្ញុំចូលដៃជាមួយចោរ។
ង. ក្រោយខ្ញុំរត់ចេញពីស្រុកអាមេរិក (ពួកកុម្មុយនិស្ត)
ខ្ញុំចូលដៃជាមួយពួកកុម្មុយនិស្ត។
ច. ក្រោយខ្ញុំរត់ចេញពីពួកយើង (ពួកខ្មាំង)
ខ្ញុំចូលដៃជាមួយពួកខ្មាំង។

DRILL THREE: Transformation

MODEL: T: កប៉ាល់ហោះអាមេរិកាំងទម្លាក់គ្រាប់បែកលើយើង។
S: កប៉ាល់ហោះអាមេរិកាំងដេញទម្លាក់គ្រាប់បែកលើយើង។
T: The American airplanes dropped bombs on us.
S: The American airplanes chased us and dropped bombs on us.

ក. ប៉ូលិសបាញ់ចោរក្នុងទីក្រុង។ — ប៉ូលិសដេញបាញ់ចោរក្នុងទីក្រុង។
ខ. ក្រុមយើងតាមពួកខ្មាំង។ — ក្រុមយើងដេញតាមពួកខ្មាំង។
គ. កប៉ាល់ហោះអាមេរិកាំងបាញ់កប៉ាល់ហោះយួនខាងជើង។ — កប៉ាល់ហោះអាមេរិកាំងដេញបាញ់កប៉ាល់ហោះយួនខាងជើង។
ឃ. ខ្ញុំចាប់ចោរម្នាក់។ — ខ្ញុំដេញចាប់ចោរម្នាក់។
ង. យើងសម្លាប់ពួកខ្មាំង។ — យើងដេញសម្លាប់ពួកខ្មាំង។
ច. លោកតាមឡានខ្ញុំ។ — លោកដេញតាមឡានខ្ញុំ។

DRILL FOUR: Transformation

MODEL: T: ខ្ញុំត្រូវគ្រាប់មួយដង។
S: លោកមានដែលត្រូវគ្រាប់ទេ?
T: I was shot once.
S: Have you ever been shot?

ក. ខ្ញុំរៀនភាសាខ្មែរ។ — លោកដែលរៀនភាសាខ្មែរទេ?
ខ. ខ្ញុំរៀនបើកកប៉ាល់ហោះ។ — លោកដែលរៀនបើកកប៉ាល់ហោះទេ?
គ. ខ្ញុំបាញ់កាំភ្លើង។ — លោកដែលបាញ់កាំភ្លើងទេ?
ឃ. ខ្ញុំទៅលេងទីក្រុងម៉ៃយ៉ាមី។ — លោកដែលទៅលេងទីក្រុងម៉ៃយ៉ាមីទេ?
ង. ខ្ញុំមានគ្រោះថ្នាក់មួយដង។ — លោកដែលមានគ្រោះថ្នាក់ទេ?
ច. ខ្ញុំជិះកប៉ាល់ហោះទៅគុយបា។ — លោកដែលជិះកប៉ាល់ទៅគុយបាទេ?

DRILL FIVE: Response

MODEL: T: លោកត្រូវគ្រាប់ខ្លាំងទេ?
S: បាទ ខ្ញុំត្រូវគ្រាប់ខ្លាំងគ្រាន់បើដែរ។
T: Were you seriously wounded?
S: Yes, I was pretty seriously wounded.

ក. លោកមានគ្រោះថ្នាក់ធ្ងន់ទេ?
បាទ ខ្ញុំមានគ្រោះថ្នាក់ធ្ងន់គ្រាន់បើដែរ។
ខ. ខ្មាំងមានការខូចខាតច្រើនទេ?
បាទ ខ្មាំងមានការខូចខាតច្រើនគ្រាន់បើដែរ។
គ. ឡានលោកខូចច្រើនទេ?
បាទ ឡានខ្ញុំខូចច្រើនគ្រាន់បើដែរ។
ឃ. ឡានលោកស្រួលទេ?
បាទ ឡានខ្ញុំស្រួលគ្រាន់បើដែរ។
ង. កប៉ាល់ហោះរុស្ស៊ីលឿនទេ?
បាទ កប៉ាល់ហោះរុស្ស៊ីលឿនគ្រាន់បើដែរ។
ច. ខ្មាំងមានកាំភ្លើងច្រើនទេ?
បាទ ខ្មាំងមានកាំភ្លើងច្រើនគ្រាន់បើដែរ។

DRILL SIX: Substitution

MODEL: T: ខ្ញុំរ៉ះតែមានគ្រោះថ្នាក់ម្សិលមិញ។ (ទៅរៀន)
S: ខ្ញុំរ៉ះតែទៅរៀនម្សិលមិញ។
T: Yesterday I almost had an accident. (go to school)
S: Yesterday I almost went to school.

ក. ខ្ញុំរ៉ះតែទៅរៀនម្សិលមិញ។ (មកលេងលោក)
ខ. ខ្ញុំរ៉ះតែមកលេងលោកម្សិលមិញ។ (មិនបានទៅញូវយ៉ក)
គ. ខ្ញុំរ៉ះតែមិនបានទៅញូវយ៉កម្សិលមិញ។ (ត្រឡប់មកពី)
ឃ. ខ្ញុំរ៉ះតែមិនបានត្រឡប់មកពីញូវយ៉កម្សិលមិញ។ (ត្រឡប់ទៅ)
ង. ខ្ញុំរ៉ះតែត្រឡប់ទៅញូវយ៉កម្សិលមិញ។ (មិនមកធ្វើការ)
ច. ខ្ញុំរ៉ះតែមិនមកធ្វើការម្សិលមិញ។

DRILL SEVEN: Transformation

MODEL: T: ខ្ញុំរ៉ះតែមិនបានមកលេងលោក។ (ឡានខូច)
S: ខ្ញុំមិនបានមកលេងលោកព្រោះឡានខ្ញុំខូច។
T: I almost couldn't come to visit you. (car broke down)
S: I couldn't come to visit you because my car broke down.

ក. ខ្ញុំ៖ តែមិនបានមករៀន ។ (ឈឺ)
ខ្ញុំមិនបានមករៀនព្រោះខ្ញុំឈឺ ។
ខ. ខ្ញុំ៖ តែមិនបានមើលកុននោះ ។ (គ្មានលុយ)
ខ្ញុំមិនបានមើលកុននោះព្រោះខ្ញុំគ្មានលុយ ។
គ. ខ្ញុំ៖ តែមិនបានទៅញូវយ៉ក ។ (ភ្លេចទិញសំបុត្រកប៉ាល់ហោះ)
ខ្ញុំមិនបានទៅញូវយ៉កព្រោះខ្ញុំភ្លេចទិញសំបុត្រកប៉ាល់ហោះ ។
ឃ. ខ្ញុំ៖ តែមិនបានចូលរៀនខ្មែរ ។ (ចុះឈ្មោះមិនទាន់)
ខ្ញុំមិនបានចូលរៀនខ្មែរព្រោះខ្ញុំចុះឈ្មោះមិនទាន់ ។
ង. ខ្ញុំ៖ តែមិនបានចេញពីទាហាន ។ (ត្រូវដេកពេទ្យ)
ខ្ញុំមិនបានចេញពីទាហានព្រោះខ្ញុំដេកពេទ្យ ។
ច. ខ្ញុំ៖ តែមិនបានឡើងសក្តិ ។ (ជាប់គុក)
ខ្ញុំមិនបានឡើងសក្តិព្រោះខ្ញុំជាប់គុក ។

DRILL EIGHT: Transformation

MODEL: T: ខ្ញុំមានទាហានម្ភៃនាក់ ។
S: ពេលវៀតកុងឡោមព័ទ្ធយើង ខ្ញុំមានទាហានម្ភៃនាក់ ។
T: I have twenty soldiers.
S: When the Viet Cong ambushed us, I had twenty soldiers.

ក. ទាហានខ្ញុំស្លាប់ប្រាំនាក់ ។
ពេលវៀតកុងឡោមព័ទ្ធយើង ទាហានខ្ញុំស្លាប់ប្រាំនាក់ ។
ខ. ក្រុមខ្ញុំខូចហាតឡានបី ។
ពេលវៀតកុងឡោមព័ទ្ធយើង ក្រុមខ្ញុំខូចហាតឡានបី ។
គ. កូនទាហានខ្ញុំត្រូវគ្រាប់ដប់នាក់ ។
ពេលវៀតកុងឡោមព័ទ្ធយើង កូនទាហានខ្ញុំត្រូវគ្រាប់ដប់នាក់ ។
ឃ. ឪពុកម្ដាយខ្ញុំស្លាប់ទាំងអស់ ។
ពេលវៀតកុងឡោមព័ទ្ធយើង ឪពុកម្ដាយខ្ញុំស្លាប់ទាំងអស់ ។
ង. យើងដុតផ្ទះយើង ។
ពេលវៀតកុងឡោមព័ទ្ធយើង យើងដុតផ្ទះយើង ។
ច. យើងកំពុងញ៉ាំបាយ ។
ពេលវៀតកុងឡោមព័ទ្ធយើង យើងកំពុងញ៉ាំបាយ ។

DRILL NINE: Response

MODEL: T: គេប្រើកាំភ្លើងអីនៅស្រុកយួន? (ធុន អឹម-១៦)
S: យើងប្រើសុទ្ធតែកាំភ្លើងធុនអឹម-១៦ ។
T: What rifles do they use in South Viet Nam? (M-16)
S: We use only the M-16.

ក. គេប្រើឡានអ្វីក្នុងកងទាហានខ្មែរ? (ជេប.អិម.សេ)
យើងប្រើសុទ្ធតែឡានជេប.អិម.សេ។
ខ. រាជការលោកទិញឡានអ្វី? (អាមេរិក)
រាជការយើងទិញសុទ្ធតែឡានអាមេរិក។
គ. លោកប្រើសាំងអ្វី? (ល្អ)
ខ្ញុំប្រើសុទ្ធតែសាំងល្អ។
ឃ. អ្នកណាខ្លះទៅមើលកុននោះ? (ខ្មែរ)
សុទ្ធតែខ្មែរទៅមើលកុននោះ។
ង. លោកប្រើជាភាសាអ្វីខ្លះ? (អង់គ្លេស)
ខ្ញុំប្រើសុទ្ធតែជាភាសាអង់គ្លេស។
ច. លោកឃើញអ្នកណាខ្លះ? (យៀកកុង)
ខ្ញុំឃើញសុទ្ធតែយៀកកុង។

DRILL TEN: Transformation

MODEL: T: ទាហានយើងប្រើកាំភ្លើងធុនអិម-១៦។
S: កាំភ្លើងដែលទាហានយើងប្រើសុទ្ធតែកាំភ្លើងធុនអិម-១៦។
T: Our soldiers use M-16 rifles.
S: The rifles that our soldiers use are all M-16.

ក. ខ្ញុំមើលកុនអាមេរិកាំង។
កុនដែលខ្ញុំមើលសុទ្ធតែកុនអាមេរិកាំង។
ខ. យើងទិញឡានបារាំង។
ឡានដែលយើងទិញសុទ្ធតែឡានបារាំង។
គ. យើងដេញបាញ់យួនខាងជើង។
យួនដែលយើងដេញបាញ់សុទ្ធតែយួនខាងជើង។
ឃ. ខ្ញុំញាំស្រាអង់គ្លេស។
ស្រាដែលខ្ញុំញាំសុទ្ធតែស្រាអង់គ្លេស។
ង. ខ្ញុំចូលចិត្តស្បែកជើងខ្មៅ។
ស្បែកជើងដែលខ្ញុំចូលចិត្តសុទ្ធតែស្បែកជើងខ្មៅ។
ច. សាលាខ្ញុំបង្រៀនភាសាខ្មែរ។
ភាសាដែលសាលាខ្ញុំបង្រៀនសុទ្ធតែភាសាខ្មែរ។

DRILL ELEVEN: Transformation

MODEL: T: ខ្ញុំបានឡើងសក្តិពីអាទិត្យមុន។ (កាប៉ូរ៉ាល់)
S: ខ្ញុំបានឡើងសក្តិជាកាប៉ូរ៉ាល់ពីអាទិត្យមុន។
T: I got a promotion last week. (corporal)
S: I got promoted to corporal last week.

ក. ខ្ញុំបានឡើងស័ក្តិពីរអាទិត្យមុន ។ (ពលបាលឯក)
ខ្ញុំបានឡើងស័ក្តិជាពលបាលឯកពីរអាទិត្យមុន ។
ខ. គេឱ្យខ្ញុំឡើងស័ក្តិពីមួយថ្ងៃនោះ ។ (អនុសេនីយទោ)
គេឱ្យខ្ញុំឡើងស័ក្តិជាអនុសេនីយទោពីមួយថ្ងៃនោះ ។
គ. លោកសានបានឡើងស័ក្តិបីថ្ងៃហើយ ។ (វរសេនីយត្រី)
លោកសានបានឡើងស័ក្តិជាវរសេនីយត្រីបីថ្ងៃហើយ ។
ឃ. គេឱ្យលោកថាច់-ជាឡើងស័ក្តិ ។ (ស័ក្តិមួយ)
គេឱ្យលោកថាច់-ជាឡើងស័ក្តិជាស័ក្តិមួយ ។
ង. ស្មៀនលោកស៊ីមបានឡើងស័ក្តិ ។ (ពលបាលត្រី)
ស្មៀនលោកស៊ីមបានឡើងស័ក្តិជាពលបាលត្រី ។
ច. លោកស្រីហែមបានឡើងស័ក្តិប្រហែលមួយអាទិត្យហើយ ។ (ស័ក្តិពីរ)
លោកស្រីហែមបានឡើងស័ក្តិជាស័ក្តិពីរប្រហែលមួយអាទិត្យហើយ ។

DRILL TWELVE: Transformation

MODEL: T: ខ្ញុំធ្លាក់ស័ក្តិ ។ (កាប៉ូរ៉ាល់)
S: គេទម្លាក់ស័ក្តិខ្ញុំទៅកាប៉ូរ៉ាល់វិញ ។
T: I was demoted. (corporal)
S: They demoted me to corporal.

ក. លោកសានធ្លាក់ស័ក្តិ ។ (កូនទាហាន)
គេទម្លាក់ស័ក្តិលោកសានទៅកូនទាហានវិញ ។
ខ. កញ្ញាហែមធ្លាក់ស័ក្តិ ។ (ស័ក្តិមួយ)
គេទម្លាក់ស័ក្តិកញ្ញាហែមទៅស័ក្តិមួយវិញ ។
គ. លោកស៊ីមធ្លាក់ស័ក្តិ ។ (ពលបាលត្រី)
គេទម្លាក់ស័ក្តិលោកស៊ីមទៅពលបាលត្រីវិញ ។
ឃ. កូនលោកស័ក្តិប្រាំធ្លាក់ស័ក្តិ ។ (អនុសេនីយត្រី)
គេទម្លាក់ស័ក្តិកូនលោកស័ក្តិប្រាំទៅអនុសេនីយត្រីវិញ ។
ង. អ្នកបើកឡានលោកមេបញ្ជាការធ្លាក់ស័ក្តិ ។ (កាប៉ូរ៉ាល់)
គេទម្លាក់ស័ក្តិអ្នកបើកឡានលោកមេបញ្ជាការទៅកាប៉ូរ៉ាល់វិញ ។
ច. ប៉ូលីសទាហានធ្លាក់ស័ក្តិ ។ (ពលបាលទោ)
គេទម្លាក់ស័ក្តិប៉ូលីសទាហានទៅពលបាលទោវិញ ។

DRILL THIRTEEN: Transformation

MODEL: T: គេបំផ្លាស់លោកថាច់-ជាទៅក្រុមមួយទៀត ។
S: លោកថាច់-ជាផ្លាស់ទៅក្រុមមួយទៀត ។
T: They transfer Mr. Thach-Cia to another squad.
S: Mr. Thach-Cia is transferred to another squad.

ក. ប៉ូលិសទាហានបណ្ដើរអ្នកទោសទៅគុក។
អ្នកទោសដើរទៅគុក។
ខ. ខ្ញុំបំបែកកង់ឡាន។
កង់ឡានបែក។
គ. ទាហានសម្លាប់ខ្មែរក្រហមដប់នាក់ពីអាទិត្យមុន។
ខ្មែរក្រហមដប់នាក់ស្លាប់ពីអាទិត្យមុន។
ឃ. គេទម្លាក់សក្តិខ្ញុំទៅកាប៉ូរ៉ាល់វិញ។
ខ្ញុំធ្លាក់សក្តិទៅកាប៉ូរ៉ាល់វិញ។
ង. ខ្ញុំបញ្ចេញចោរពីគុក។
ចោរចេញពីគុក។
ច. គេដំឡើងសក្តិលោកសៅរ៍ជាអនុសេនីយត្រី។
លោកសៅរ៍ឡើងសក្តិជាអនុសេនីយត្រី។

DRILL FOURTEEN:

MODEL: T: គេចោទលោកជាមនុស្សក្បត់ជាតិ។ (សង្ស័យ)
S: គេសង្ស័យលោកជាមនុស្សក្បត់ជាតិ។
T: They accuse you of being a traitor. (suspect)
S: They suspect you of being a traitor.

ក. គេសង្ស័យលោកជាមនុស្សក្បត់ជាតិ។ (ប្រាប់ខ្ញុំ)
ខ. គេប្រាប់ខ្ញុំលោកជាមនុស្សក្បត់ជាតិ។ (អ្នកភៀសខ្លួន)
គ. គេប្រាប់ខ្ញុំលោកជាអ្នកភៀសខ្លួន។ (គ្រូពេទ្យ)
ឃ. គេប្រាប់ខ្ញុំលោកជាគ្រូពេទ្យ។ (អ្នកបំបះបំបោរកូនសិស្ស)
ង. គេប្រាប់ខ្ញុំលោកជាអ្នកបំបះបំបោរកូនសិស្ស។ (សន្មតថា)
ច. គេសន្មតថាលោកជាអ្នកបំបះបំបោរកូនសិស្ស។

Reading Passage

## ចម្បាំងនៅស្រុកខ្មែរ

ចម្បាំងនៅស្រុកខ្មែរផ្ទុះឡើងនៅកណ្ដាលឆ្នាំ១៩៧០។ កងទ័ពខ្មែរមិនបានរៀបចំបានស្រួល ដូច្នេះការធ្វើចម្បាំងជាមួយនឹងពួកបះបោរកុម្មុយនិស្តមានការពិបាកយ៉ាងខ្លាំង។ តាមពួកនេះគេបាននិយាយថាគេនឹងវាយទម្លាក់រដ្ឋាភិបាលថ្មីបានក្នុងពេលតែបីខែប៉ុណ្ណោះ។ គេនិយាយយ៉ាងនេះព្រោះគេសន្មតថាកងទ័ពខ្មែរនៅក្មេងណាស់ហើយគ្មានប្រដាប់ប្រដាល្មមដើម្បីនឹងធ្វើចម្បាំងទេ ហើយកងទ័ពរបស់សត្រូវមានច្រើនជាងឆ្ងាយណាស់។

ជាការពិត ពួកវៀតកុងនិងពួកខ្មែរខ្លះដែលចូលដៃជាមួយគ្នានេះ

បានធ្វើឲ្យកងទ័ពខ្មែរមានការខូចខាតយ៉ាងធ្ងន់ ។ តែយ៉ាងណាក៏ដោយ កងទ័ពសត្រូវនេះ មិនអាចយកជ័យជំនះលើពួកទាហានខ្មែរបានទេ ។ កងទ័ពខ្មែរបានវាយប្រឆាំងយ៉ាងខ្លាំង ។ តាំងពីដំបូងកងទ័ពខ្មែរមានប្រហែល៣ម៉ឺននាក់ មកដល់ពេលនេះ គឺប្រហែល២០ម៉ឺននាក់ មានការកើនឡើងយ៉ាងលឿន ។ កងទ័ពខ្មែរបានវាយដេញ ឡោមព័ទ្ធ ទម្លាក់គ្រាប់បែកលើកងទ័ពសត្រូវ ធ្វើឲ្យគេស្លាប់ ត្រូវគ្រាប់ ខូចខាតយ៉ាងធ្ងន់ ។ កងទ័ពសត្រូវត្រូវរត់ចេញពីកន្លែងមួយទៅកន្លែងមួយ ដែលធ្វើឲ្យគេគ្មានពេលល្មម ដើម្បីនឹងរៀបចំធ្វើការវាយជាថ្មី ។ ប៉ុន្តែពួកនេះបានបែកជាពួកតូចៗ ដើម្បីនឹងលួចវាយបំផ្លាញផ្លូវ ប្រដាប់ប្រដាទាហាន កន្លែងស្តុកស្បៀង ។ល។ ការលួចធ្វើចម្បាំងនៅពេលនេះ ធ្វើឲ្យមានការពិបាកចំពោះកងទ័ពខ្មែរក្នុងការបង្ក្រាបសត្រូវឲ្យបានឈ្នះ ដោយមានការខូចខាតយ៉ាងតិចបំផុត ។

តែយើងជឿថា មិនយូរប៉ុន្មានទេ យើងនឹងមានជ័យជំនះលើពួកសត្រូវមិនខាន ។

## VOCABULARY

| | | |
|---|---|---|
| ការខូចខាត | kaa khouc khaat | casualty, damage |
| ការពារ... កុំឲ្យ | kaapia...kom aoy | to prevent...from (do)ing (L) |
| កុម្មុយនិស្ត | kumménih | Communist |
| ក្បត់ជាតិ | kbɔt ciat | to betray one's country |
| ខូចខាត | khouc khaat | to suffer casualties, to be damaged |
| ខ្មែរសេរី | khmaɛ seerɛy | Khmer Serei (Free Cambodian) |
| គ្រាប់បែក | krɔ́p baɛk | bomb |
| ងាប់ | ŋɔ́p | to die |
| ចូលដៃ (នឹង) | coul day (nɨŋ) | to collaborate (with) |
| ជាប់គុក | cɔ́p kuk | go to prison, to be in prison or in jail |
| ដេកពេទ្យ | deek pɛɛt | stay in the hospital |
| ដេញ | dɛñ | to chase, to be after |
| ដំឡើង | təlaəŋ | to raise, to mount |
| ដំឡើងសក្ក | təlaəŋ saʔ | to promote |
| តាម | taam | to follow |
| ត្រូវគ្រាប់ | trəw krɔ́p | to be wounded (by a bullet) |
| ទម្លាក់ | təléʔ | to drop, to cause to fall |
| ទម្លាក់សក្ក | təléʔ saʔ | to demote |
| ធុន | thun | type, caliber |
| ធ្ងន់ | thŋún | serious, heavy |
| ធ្លាក់សក្ក | thléʔ saʔ | to be demoted |

| | | |
|---|---|---|
| បណ្ដើរ | pədaə | to escort, to march (transitive) to cause to walk |
| បញ្ចេញ | pəceñ | to cause to leave, to remove |
| បំបែក | pəbaek | to break (transitive) |
| បំបះបំបោរ | pəmbah pəmbao | to rabble-rouse, to incite |
| បំផ្លាស់ | pəmphlah | to transfer (transitive) |
| ពួក | puoʔ | group |
| ពួកយៀកកុង | puoʔ yieʔ koŋ | Viet Cong |
| រត់ចេញ | rut ceñ | to desert, to flee |
| វិះតែ | vih tae | almost |
| សន្មត | sɔnnəmɔt | to assume |
| ស្គរ | skɔ́ɔ | a drum (L) |
| ស្រាល | sraal | light, not serious |
| ឡើងសក្តិ | laəŋ saʔ | to get a promotion |
| ឡោមព័ទ្ធ | laom pɔ́t | to ambush |



Sidewalk food vendors, Phnom Penh

## LESSON FIFTY-THREE

### DIALOGUE

លុកលុយ — to invade

១. ថុម ពួកយៀកកុងឧស្សាហ៍ចូល មកលុកលុយក្នុងភូមិនេះ ទេ? — Did the Viet Cong often come to invade this village?

បាប — sin

ធ្វើបាប — to torture, to mistreat, to give a hard time to

២. សុខ បាទ គេចូលចិត្តធ្វើបាប អ្នកស្រុកភូមិនេះណាស់។ — Yes, they liked to mistreat the villagers.

៣. ថុម មកពីហេតុអ្វី លោកដឹង ទេ? — For what reason? Do you know?

៤. សុខ បាទ អ្នកស្រុកភូមិនេះ ស្អប់ពួកយៀកកុងណាស់។ — Yes, (because) these villagers dislike the Viet Cong very much.

៥. ថុម ពួកនេះធ្វើបាបអ្នកស្រុក យ៉ាងម៉េចខ្លះ? — How did they mistreat the villagers?

កំញើញ — to intimidate, extort

ប្លន់ — to rob

៦. សុខ គេកំញើញយកលុយ ប្លន់យកឥវ៉ាន់ ដុតផ្ទះ។ — They extorted money, robbed things, and burned houses.

នៅពេលដែល — at the time

៧. ថុម អ្នកស្រុកធ្វើម៉េចទៅនៅ ពេលដែលពួកនេះចូល មកម្ដងៗ ? — What did the villagers do every time they came?

ពួន — to hide oneself

៨. សុខ គេរត់ពួន នឹងរាយការណ៍ ទៅទាហានរាជការ ។ — They hid and reported to the government troops.

DIALOGUE:

1. tom - puo? yie? koŋ əhsaa coul mə luk luy knoŋ phum nih eh?
2. sok - baat, kee coul cət thəə baap né? srok phum nih nah
3. tom - móo pii haɛt ɛy, look dəŋ eh?
4. sok - baat, né? srok phum nih s?ɔp puo? yie? koŋ nah
5. tom - puo? nih thəə baap né? srok yaaŋ mɛc khlah?
6. sok - kee kəñaəñ yóo luy, phlɔn yóo ɛyvan, dot phtéh
7. tom - né? srok thəə mɛc tɨw nɨw peel daɛl puo? nih coul móo mə dɔɔŋ mə dɔɔŋ?
8. sok - kee rut pún, nɨŋ riay kaa tɨw təhian riaccəkaa

## NOTES

## DRILLS

DRILL NO.

4. In the sentences of this drill the phrase មកពី /móo pii/ is a fixed clause relator meaning 'because,' e.g.,

ចោរចូលប្លន់ផ្ទះមកពីយើងមិនបិទទ្វារ។

cao coul phlón phtéh móo pii yəəŋ mɨn bət tvia

A thief got in and robbed our house because we didn't shut the door.

8. Sentence e The word មាន់ទា /món tia/ 'poultry' is a type of uncentered compound in which two members of a class are given to stand for all the members of the class. Thus មាន់ទា /món tia/ is literally 'chickens-ducks,' but as a compound noun it means 'poultry.' Other such compounds are ខោអាវ /khao aav/ 'clothing' and តុទូកៅអី /toˀ tuu kawˀɛy/ 'furniture.' Cf. also N.3.2 and N.3.2.1.2.

## DRILLS

DRILL ONE: Substitution

MODEL: T: ពួកវៀតកុងញឹកញាប់ចូលមកលុកលុយភូមិនេះទេ? (អាមេរិកាំង)

S: ពួកអាមេរិកាំងញឹកញាប់ចូលមកលុកលុយភូមិនេះទេ?

T: Did the Viet Cong often come to invade this village? (Americans)

S: Did the Americans often come to invade this village?

ក. ពួកអាមេរិកាំងញឹកញាប់ចូលមកលុកលុយភូមិនេះទេ? (បាញ់)

ខ. ពួកអាមេរិកាំងញឹកញាប់ចូលមកបាញ់ភូមិនេះទេ? (លេង)

គ. ពួកអាមេរិកាំងញឹកញាប់ចូលមកលេងភូមិនេះទេ? (រាជការ)

ឃ. ពួករាជការញឹកញាប់ចូលមកលេងភូមិនេះទេ? (យកពន្ធ)

ង. ពួករាជការញឹកញាប់ចូលមកយកពន្ធភូមិនេះទេ? (វៀតកុង)

ច. ពួកវៀតកុងញឹកញាប់ចូលមកយកពន្ធភូមិនេះទេ?

DRILL TWO: Transformation

MODEL: T: ប៉ុន្មានខែមុនវៀតកុងចូលមកភូមិនេះច្រើនដងណាស់។

S: ប៉ុន្មានខែមុនវៀតកុងញឹកញាប់ចូលមកភូមិនេះណាស់។

T: In the last few months, the Viet Cong have come into this village many times.

S: In the last few months, the Viet Cong have often come into this village.

ក. ខ្ញុំសរសេរសំបុត្រទៅឪពុកម្ដាយខ្ញុំរាល់ថ្ងៃ។
ខ្ញុំញឹកញាប់សរសេរសំបុត្រទៅឪពុកម្ដាយខ្ញុំណាស់។

ខ. កូនសិស្សខ្ញុំមកលេងរាល់អាទិត្យ។
កូនសិស្សខ្ញុំញឹកញាប់មកលេងខ្ញុំណាស់។

គ. ខ្ញុំទៅលេងញារប៉ាករាល់ខែ ។
ខ្ញុំឧស្សាហ៍ទៅលេងញារប៉ាកណាស់ ។
ឃ. យើងលេងល្បៀរាល់ចុងអាទិត្យ ។
យើងឧស្សាហ៍លេងល្បៀណាស់ ។
ង. ពួកម៉ាកខ្ញុំនិងខ្ញុំទៅមើលកុនរាល់ល្ងាច ។
ពួកម៉ាកខ្ញុំនិងខ្ញុំឧស្សាហ៍ទៅមើលកុនណាស់ ។
ច. ខ្ញុំទៅញ៉ាំបាយចិនរាល់អាទិត្យ ។
ខ្ញុំឧស្សាហ៍ទៅញ៉ាំបាយចិនណាស់ ។

DRILL THREE: Response

MODEL: T: ពួកវៀតកុងចូលមកធ្វើអីក្នុងភូមិនេះ? (ធ្វើបាបអ្នកស្រុក)
S: ពួកវៀតកុងចូលមកធ្វើបាបអ្នកស្រុកក្នុងភូមិនេះ ។
T: What did the Viet Cong come to this village to do? (mistreat the villagers)
S: The Viet Cong came to this village to mistreat the villagers.

ក. គាត់ចូលមកធ្វើអីក្នុងថ្នាក់នេះ? (ពន្យល់ខ្ញុំ)
គាត់ចូលមកពន្យល់ខ្ញុំក្នុងថ្នាក់នេះ ។
ខ. ប៉ូលីសចូលមកធ្វើអីក្នុងផ្ទះលោក? (ទារពន្ធ)
ប៉ូលីសចូលមកទារពន្ធក្នុងផ្ទះខ្ញុំ ។
គ. ទាហានចូលមកធ្វើអីក្នុងកន្លែងនេះ? (ដេញវៀតកុង)
ទាហានចូលមកដេញវៀតកុងក្នុងកន្លែងនេះ ។
ឃ. ចោរចូលមកធ្វើអីក្នុងផ្ទះលោក? (លួចលុយ)
ចោរចូលមកលួចលុយក្នុងផ្ទះខ្ញុំ ។
ង. ពួកអាមេរិកាំងចូលមកធ្វើអីក្នុងភូមិនេះ? (រកពួកវៀតកុង)
ពួកអាមេរិកាំងចូលមករកពួកវៀតកុងក្នុងភូមិនេះ ។
ច. លោកចូលមកធ្វើអីក្នុងថ្នាក់នេះ? (សួរលោក)
ខ្ញុំចូលមកសួរលោកក្នុងថ្នាក់នេះ ។

DRILL FOUR: Response

MODEL: T: មកពីហេតុអីបានជាវៀតកុងដុតផ្ទះយើង? (យើងស្អប់វៀតកុងណាស់)
S: វៀតកុងដុតផ្ទះយើងមកពីយើងស្អប់វៀតកុងណាស់ ។
T: Why did the Viet Cong burn our houses? (we hate the Viet Cong a lot)
S: They burned our houses because we hate the Viet Cong a lot.

ក. មកពីហេតុអីបានជាខ្ញុំមិនឱ្យលោកទៅជាមួយ? (លោកគ្មានលុយ)
ខ្ញុំមិនឱ្យលោកទៅជាមួយមកពីលោកគ្មានលុយ ។

ខ. មកពីហេតុអីបានជាលោកមិនរៀនមេរៀនខ្ញុំ? (ខ្ញុំមិនពន្យល់លោក)
លោកមិនរៀនមេរៀនខ្ញុំ មកពីខ្ញុំមិនពន្យល់លោក។
គ. មកពីហេតុអីបានជាខ្ញុំដើរទៅធ្វើការ? (ខ្ញុំគ្មានលុយ)
ខ្ញុំដើរទៅធ្វើការ មកពីខ្ញុំគ្មានលុយ។
ឃ. មកពីហេតុអីបានជាខ្ញុំមិនធ្វើអាហារ? (ខ្ញុំត្រូវរៀនឲ្យចប់)
ខ្ញុំមិនធ្វើអាហារ មកពីខ្ញុំត្រូវរៀនឲ្យចប់។
ង. មកពីហេតុអីបានជាចោរចូលផ្ទះយើង។ (យើងមិនបិទទ្វារ)
ចោរចូលផ្ទះយើង មកពីយើងមិនបិទទ្វារ។
ច. មកពីហេតុអីបានជាលោកមានគ្រោះថ្នាក់។ (លោកភ្លេចឈប់ភ្លើងក្រហម)
លោកមានគ្រោះថ្នាក់ មកពីលោកភ្លេចឈប់ភ្លើងក្រហម។

DRILL FIVE: Substitution

MODEL: T: គេចូលចិត្តធ្វើបាបអ្នកស្រុកណាស់។ (ប្លន់)
S: គេចូលចិត្តប្លន់អ្នកស្រុកណាស់។
T: They like to mistreat the villagers very much.
S: They like to rob the villagers very much.

ក. គេចូលចិត្តប្លន់អ្នកស្រុកណាស់។ (លួចបាញ់)
ខ. គេចូលចិត្តលួចបាញ់អ្នកស្រុកណាស់។ (កំញៀញ)
គ. គេចូលចិត្តកំញៀញអ្នកស្រុកណាស់។ (ពួកវៀតកុង)
ឃ. ពួកវៀតកុងចូលចិត្តកំញៀញអ្នកស្រុកណាស់។ (ឡោមព័ទ្ធ)
ង. ពួកវៀតកុងចូលចិត្តឡោមព័ទ្ធអ្នកស្រុកណាស់។ (ធ្វើបាប)
ច. ពួកវៀតកុងចូលចិត្តធ្វើបាបអ្នកស្រុកណាស់។

DRILL SIX: Response

MODEL: T: វៀតកុងមកធ្វើអីខ្លះ? (ដុតផ្ទះយើង)
S: នៅពេលដែលវៀតកុងមក គេដុតផ្ទះយើង។
T: What did the Viet Cong come to do? (burn our houses)
S: At the time they came, they burned our houses.

ក. ប៉ូលីសចូលធ្វើអីខ្លះក្នុងផ្ទះលោក? (ឆែកឥវ៉ាន់ខ្ញុំ)
នៅពេលដែលប៉ូលីសចូល គេឆែកឥវ៉ាន់ខ្ញុំ។
ខ. លោកទៅស្រុកយួនធ្វើអីខ្លះ? (បង្រៀនអង់គ្លេស)
នៅពេលដែលខ្ញុំទៅស្រុកយួន ខ្ញុំបង្រៀនអង់គ្លេស។
គ. គេមកធ្វើអីខ្លះក្នុងបន្ទប់យើង? (យកកៅអីចេញ)
នៅពេលដែលគេមកក្នុងបន្ទប់យើង គេយកកៅអីចេញ។
ឃ. លោកទៅផ្ទះលោកហ៊ុនធ្វើអីខ្លះ? (គ្រាន់តែញុំាស្រា)
នៅពេលដែលខ្ញុំទៅផ្ទះលោកហ៊ុន ខ្ញុំគ្រាន់តែញុំាស្រា។

ង. កញ្ញាចូលក្នុងហាងនោះធ្វើអ្វី? (ទិញសៀវភៅពីរ)
នៅពេលដែលខ្ញុំចូលក្នុងហាងនោះ ខ្ញុំទិញសៀវភៅពីរ។
ច. អាមេរិកាំងចូលមកព្រំដែនយើងធ្វើអ្វី? (ដេញវៀតកុង)
នៅពេលដែលអាមេរិកាំងចូលមកព្រំដែនយើង គេដេញវៀតកុង។

DRILL SEVEN: Transformation

MODEL: T: យើងញ៉ាំបាយ។ (វៀតកុងចូលក្នុងភូមិយើង)
S: វៀតកុងចូលក្នុងភូមិយើងនៅពេលដែលយើងកំពុងញ៉ាំបាយ។
T: We were eating. (the Viet Cong entered our village)
S: The Viet Cong came in our village while we were eating.

ក. ខ្ញុំដេក។ (ប៉ូលិសចូលលុកលុយផ្ទះខ្ញុំ)
ប៉ូលិសចូលលុកលុយផ្ទះខ្ញុំនៅពេលដែលខ្ញុំកំពុងដេក។
ខ. គាត់មើលសៀវភៅបារាំងមួយ។ (ខ្ញុំនិយាយទៅគាត់)
ខ្ញុំនិយាយទៅគាត់នៅពេលដែលគាត់កំពុងមើលសៀវភៅបារាំងមួយ។
គ. ខ្ញុំញ៉ាំបាយ។ (ពួកម៉ាកស្រីខ្ញុំមកដល់)
ពួកម៉ាកស្រីខ្ញុំមកដល់នៅពេលដែលខ្ញុំកំពុងញ៉ាំបាយ។
ឃ. កូនសិស្សលេងបៀ។ (ខ្ញុំចូលក្នុងថ្នាក់)
ខ្ញុំចូលក្នុងថ្នាក់នៅពេលដែលកូនសិស្សកំពុងលេងបៀ។
ង. ចោរបើកទ្វារផ្ទះខ្ញុំ។ (ខ្ញុំទៅដល់ផ្ទះ)
ខ្ញុំទៅដល់ផ្ទះនៅពេលដែលចោរកំពុងបើកទ្វារផ្ទះខ្ញុំ។
ច. ខ្ញុំដេក។ (លោកគ្រូចូលក្នុងថ្នាក់)
លោកគ្រូចូលក្នុងថ្នាក់នៅពេលដែលខ្ញុំកំពុងដេក។

DRILL EIGHT: Transformation

MODEL: T: ពួកវៀតកុងចូលមកក្នុងភូមិនេះ។
S: ម្សិលមិញពួកវៀតកុងភូមិនេះម្តងទៀត។
T: The Viet Cong came into this village.
S: Yesterday the Viet Cong came into this village once more.

ក. អាមេរិកាំងនិងយួនខាងជើងវាយគ្នាជិតនេះ។
ម្សិលមិញអាមេរិកាំងនិងយួនខាងជើងវាយគ្នានៅជិតនេះម្តងទៀត។
ខ. ទាហានយើងទៅកប់មីន។
ម្សិលមិញទាហានយើងទៅកប់មីនម្តងទៀត។
គ. កប៉ាល់ហោះអាមេរិកាំងទម្លាក់គ្រាប់បែក។
ម្សិលមិញកប៉ាល់ហោះអាមេរិកាំងទម្លាក់គ្រាប់បែកម្តងទៀត។
ឃ. លោកសក្តិបួនត្រូវរបួស។
ម្សិលមិញលោកសក្តិបួនត្រូវរបួសម្តងទៀត។

ង. វៀតកុងចាប់មាន់ទាក្នុងភូមិយើង។
ម្សិលមិញវៀតកុងចាប់មាន់ទាក្នុងភូមិយើងម្តងទៀត។
ច. ទាហានអាមេរិកាំង-យួនខាងត្បូងឈ្លានពានព្រំដែនខ្មែរ។
ម្សិលមិញទាហានអាមេរិកាំង-យួនខាងត្បូងឈ្លានពានព្រំដែនខ្មែរម្តងទៀត។

DRILL NINE: Response

MODEL: T: វៀតកុងមកម្តងៗ គេធ្វើអ្វីខ្លះ? (រៃលុយពីយើង)
S: វៀតកុងមកម្តងៗ គេរៃលុយពីយើង។
T: Every time the Viet Cong come, what do they do? (collect money from us)
S: Every time the Viet Cong come, they collect money from us.

ក. កាលណាអាមេរិកាំងឈ្លានពានព្រំដែនម្តងៗ គេធ្វើអ្វីខ្លះ? (គ្រាន់តែដេញវៀតកុងទេ)
កាលណាអាមេរិកាំងឈ្លានពានព្រំដែនម្តងៗ គេគ្រាន់តែដេញវៀតកុងទេ។
១. លោកទៅស្រុកបារាំងម្តងៗ លោកធ្វើអ្វីខ្លះ? (ដើរលេង)
ខ្ញុំទៅស្រុកបារាំងម្តងៗ ខ្ញុំដើរលេង។
គ. លោកចូលមកក្នុងស្រុកខ្មែរម្តងៗ លោកធ្វើអ្វីខ្លះ? (បំផ្លាញស្ពាន)
ខ្ញុំចូលមកក្នុងស្រុកខ្មែរម្តងៗ ខ្ញុំបំផ្លាញស្ពាន។
ឃ. វៀតកុងចូលស្រុកម្តងៗ លោកធ្វើអី? (រាយការណ៍ទៅរាជការ)
វៀតកុងចូលស្រុកម្តងៗ ខ្ញុំរាយការណ៍ទៅរាជការ។
ង. ទាហានរាជការមកកន្លែងនេះម្តងៗ គេធ្វើអ្វីខ្លះ? (ឃ្លាំមើលវៀតកុង)
ទាហានរាជការមកកន្លែងនេះម្តងៗ គេឃ្លាំមើលវៀតកុង។
ច. លោកទៅផ្សារម្តងៗ លោកធ្វើអ្វីខ្លះ? (គ្រាន់តែមើលកុនទេ)
ខ្ញុំទៅផ្សារម្តងៗ ខ្ញុំគ្រាន់តែមើលកុនទេ។

DRILL TEN: Transformation

MODEL: T: វៀតកុងចូលស្រុក (រាយការណ៍ទៅទាហានរាជការ)
S: បើវៀតកុងចូលស្រុក លោកត្រូវរាយការណ៍ទៅទាហានរាជការ។
T: The Viet Cong come to the village.
S: If the Viet Cong come to the village you have to report (it) to the government troops.

ក. វៀតកុងចូលស្រុក។ (យកឥវ៉ាន់ទៅលាក់)
បើវៀតកុងចូលស្រុក យើងត្រូវយកឥវ៉ាន់ទៅលាក់។
ខ. វៀតកុងចូលស្រុក។ (ទៅពួនក្នុងព្រៃ)
បើវៀតកុងចូលស្រុក យើងត្រូវទៅពួនក្នុងព្រៃ។
គ. វៀតកុងចូលស្រុក។ (នៅក្នុងផ្ទះ)
បើវៀតកុងចូលស្រុក យើងត្រូវនៅក្នុងផ្ទះ។

ឃ. បៀកកុងចូលស្រុក។ (ការពារផ្ទះលោក)
បើបៀកកុងចូលស្រុក លោកត្រូវការពារផ្ទះលោក។
ង. បៀកកុងចូលស្រុក។ (ដុតផ្ទះលោក)
បើបៀកកុងចូលស្រុក លោកត្រូវដុតផ្ទះលោក។
ច. បៀកកុងចូលស្រុក។ (ចូលដៃជាមួយគេ)
បើបៀកកុងចូលស្រុក លោកត្រូវចូលដៃជាមួយគេ។

DRILL ELEVEN: Transformation

MODEL: T: កងអនុសេនាតូចខំការពារកោះនិងផែសមុទ្រ។ (កោះនិងផែសមុទ្រ)
S: កងអនុសេនាតូចខំការពារអ្វីខ្លះ?
T: The company tries to defend the island and the pier. (what)
S: What does the company try to defend?

ក. កងអនុសេនាតូចបាញ់ទៅលើកោះនិងផែសមុទ្រ។ (លើកោះនិងផែសមុទ្រ)
កងអនុសេនាតូចបាញ់ទៅឯណាខ្លះ?
ខ. ខ្មាំងវាយវត្តឫស្សីពីសាលារៀន។ (ខ្មាំង)
អ្នកណាវាយវត្តឫស្សីពីសាលារៀន?
គ. ខ្មាំងវាយយកវត្តឫស្សីបានពីអាទិត្យមុន។ (ពីអាទិត្យមុន)
ខ្មាំងវាយយកវត្តឫស្សីបានពីអង្កាល់?
ឃ. ពលរបស់សៅកប់មីននៅក្បែរផ្លូវវៀង។ (កប់មីន)
ពលរបស់សៅធ្វើអីនៅក្បែរផ្លូវវៀង?
ង. ពលរបស់សារុនកប់មីននៅក្បែរផ្លូវវៀង។ (ក្បែរផ្លូវវៀង, មីន)
ពលរបស់សារុនកប់អីនៅឯណា?
ច. កាលណាទាហានរដ្ឋការមកដល់ ខ្មាំងរត់ទៅពួនក្នុងរូងដី។ (ក្នុងរូងដី)
កាលណាទាហានរដ្ឋការមកដល់ ខ្មាំងរត់ទៅពួនឯណា?

DRILL TWELVE: Transformation

MODEL: T: ខ្មាំងវាយភូមិនេះរាល់យប់។
S: ខ្មាំងច្រើនវាយភូមិនេះតែយប់ទេ។
T: The enemy attacked this hamlet every night.
S: The enemy mostly attacked this hamlet at night time.

ក. កងទ័ពព្រៃប្លន់ឡានឈ្នួល។
កងទ័ពព្រៃច្រើនប្លន់តែឡានឈ្នួលទេ។
ខ. សង្គ្រាមសម្លាប់អ្នកស្រុកស្លូតត្រង់។
សង្គ្រាមច្រើនសម្លាប់តែអ្នកស្រុកស្លូតត្រង់ទេ។
គ. រាល់ល្ងាចអ្នកស្រុកស្ដាប់រ៉ាដ្យូរដ្ឋការ។
រាល់ល្ងាចអ្នកស្រុកច្រើនស្ដាប់តែរ៉ាដ្យូរដ្ឋការទេ។

ឃ. ខ្មាំងធ្វើបាបអ្នកស្រុក។
ខ្មាំងច្រើនធ្វើបាបតែអ្នកស្រុកទេ។
ង. យើងធ្វើបាបឈ្លើយសង្គ្រាមដែលមិនព្រមឆ្លើយសំនួរ។
យើងច្រើនធ្វើបាបតែឈ្លើយសង្គ្រាមដែលមិនព្រមឆ្លើយសំនួរទេ។

DRILL THIRTEEN: Transformation

MODEL: T: ខ្មាំងនឹងវាយភូមិយើងយប់នេះ។ (អ្នកស្រុក)
S: អ្នកស្រុកឱ្យការណ៍យើងថាខ្មាំងនឹងវាយភូមិយើងយប់នេះ។
T: The enemy will attack our hamlet tonight. (the villagers)
S: The villagers tipped us off that the enemy will attack our hamlet tonight.

ក. មួយអាទិត្យទៀតក្រុមនាយទាហានមួយក្រុមនឹងធ្វើរដ្ឋប្រហារ។ (ប៉ូលិសសម្ងាត់)
ប៉ូលិសសម្ងាត់ឱ្យការណ៍យើងថាមួយអាទិត្យទៀតក្រុមនាយទាហានមួយក្រុមនឹងធ្វើរដ្ឋប្រហារ។
ខ. ខ្មាំងចង់បំផ្លាញស្ពានទៅទីក្រុងភ្នំពេញ។ (លោកឌុក)
លោកឌុកឱ្យការណ៍យើងថាខ្មាំងចង់បំផ្លាញស្ពានទៅទីក្រុងភ្នំពេញ។
គ. អ្នកស្រុកចូលដៃជាមួយពួកខ្មាំង។ (មេឃុំ)
មេឃុំឱ្យការណ៍យើងថាអ្នកស្រុកចូលដៃជាមួយពួកខ្មាំង។
ឃ. ស្អែកខ្មាំងនឹងបង់ក្បាលឈ្លួសទៅទីក្រុងនោះ។ (ក្មេងម្នាក់)
ក្មេងម្នាក់ឱ្យការណ៍ថាស្អែកខ្មាំងនឹងបង់ក្បាលឈ្លួសទៅទីក្រុងនោះ។
ង. កងទ័ពព្រៃចង់ចាប់អ្នកតំណាងការសឹក។ (អ្នកស្រុក)
អ្នកស្រុកឱ្យការណ៍យើងថាកងទ័ពព្រៃចង់ចាប់អ្នកតំណាងការសឹក។

Reading Passage

## ឥស្សរៈ

នៅស្រុកយួនមានវៀតមិញ នៅស្រុកខ្មែរមានឥស្សរៈ។ ពួកទាំងពីរនេះមានសកម្មភាពមិនខុសគ្នាទេ គ្រាន់តែនៅកន្លែងផ្សេងពីគ្នាប៉ុណ្ណោះ។ ហើយសកម្មភាពនោះក៏មិនខុសពីសកម្មភាពរបស់វៀតកុងនៅសម័យនេះប៉ុន្មានដែរ គ្រាន់តែកាលនោះគេធ្វើដើម្បីប្រឆាំងនឹងអំណាចបារាំង និងឥឡូវនេះគេធ្វើប្រឆាំងនឹងអាមេរិកាំង ព្រោះតាមគេយល់ថា នៅសម័យនោះនិងសម័យនេះ បារាំងនិងអាមេរិកាំងឈ្លានពានទឹកដីរបស់គេ។

ឯឥស្សរៈវិញ ខ្ញុំយល់សកម្មភាពនោះយ៉ាងច្បាស់ព្រោះកាលនោះខ្ញុំជាឥស្សរៈម្នាក់ដែរ ពួកគេប្រឆាំងនឹងអំណាចបារាំងតែមិនធ្វើបាបខ្មែរណាដែលគ្រាន់តែធ្វើការនៅក្រោមបង្គាប់បារាំងហើយមិនចូលដៃនឹងបារាំងនោះ។ តាំងពីគ្រូបង្រៀនទៅដល់ទាហាន អ្នកណាក៏ដោយ អាចធ្វើដំណើរទៅណាក៏បានដែរ ឱ្យតែស្លៀកពាក់ជាស៊ីវិលនិងគ្មានអាវុធជាមួយ។ ពីភូមិទៅភូមិមួយ អ្នកស្រុក

មានការសប្បាយដូចធម្មតា លើកលែងតែគេដឹងថាទាហានបារាំងនឹងមកលុកលុយភូមិគេ។ នៅពេលយប់គេមិនសូវព្រួយពីរឿងចោរមកលួចប្លន់យកអីវ៉ាន់ ឬគោ មាន់ទា អ្វីដូចកាលមុនទៀតទេ។ ធម្មតាគេដេកលក់ស្រួលណាស់ ព្រោះពួកឥស្សរៈដើរពីផ្ទះមួយទៅផ្ទះមួយ ឃ្លាំមើលដោយប្រុងប្រយ័ត្ន ដើម្បីឲ្យមានសន្តិសុខដល់អ្នកស្រុកនោះ។ នៅពេលព្រឹកអ្នកស្រុកទាំងនោះទៅធ្វើការនៅស្រែចំការដូចធម្មតា ពិតមែនតែមានភ័យខ្លាចពីទ័ពបារាំងបន្តិចបន្តួចក៏ដោយ។ ឯផលដំណាំវិញក៏នៅតែបានដូចធម្មតាដែរ។

ដើម្បីនឹងឲ្យមានសកម្មភាព ខ្មែរឥស្សរៈដើររៃលុយនិងស្បៀងអាហារពីអ្នកស្រុក។ គេគ្មានអ្នកណាជួយគេក្រៅពីចំណុះក្នុងស្រុកដែលគេនៅនោះទេ។ ដូច្នេះគេនិងអ្នកស្រុកត្រូវគ្នា ហើយគេមិនដែលធ្វើបាបគ្នាផង។ កាំភ្លើងនិងគ្រាប់ធម្មតា គេទិញពីទាហាន ជួនកាលគេយកបានពីបារាំងនៅពេលបាញ់គ្នា។

ធម្មតាបារាំងរកឥស្សរៈមិនឃើញទេ ព្រោះគេដើររកនៅពេលថ្ងៃដែលជាពេលឥស្សរៈធ្វើអ្នកស្រុកធម្មតា។ តែពួកឥស្សរៈវិញ ទៅរកអ្នកស្រុកស្រួលណាស់ ព្រោះគេទៅរកនៅពេលយប់ជ្រៅដែលជាពេលបារាំងកំពុងដេកលក់ស្រួល។

ដូច្នេះសកម្មភាពខ្មែរឥស្សរៈជាសកម្មភាពមួយសំខាន់ជាងគេបង្អស់នៅពេលនោះក្នុងការជួយជាតិឲ្យរួចពីអំណាចបារាំង។

VOCABULARY

| | | |
|---|---|---|
| កប់ | kɔp | to bury |
| កប់មីន | kɔp miin | to set mines |
| កំញើញ | kəñaəñ | to intimidate, extort |
| កោះ | kɔh | island |
| ឃ្លាំមើល | khlóm məəl | to watch secretly |
| ជ្រៅ | crɨw | deep (R) |
| ឈ្លានពាន | chlian pian | to violate, aggress |
| ឈ្លើយសង្គ្រាម | chləəy səkriam | prisoner of war |
| ទារពន្ធ | tia pún | to demand tax |
| ទ្វារ | tvia | door |
| ធ្វើបាប | thəə baap | to torture, to punish, mistreat |
| នៅពេលដែល | nɨw peel daɛl | at the time |
| បាប | baap | sin |
| ប៉ូលិសសម្ងាត់ | pəlih səŋat | secret police |
| ប្លន់ | phlɔn | to rob |
| ពន្ធ | pún | tax |
| ពួន | puon | to hide |
| មាន់-ទា | món-tia | poultry |

| | | |
|---|---|---|
| មីន | miin | (land) mine |
| យកពន្ធ | yóo pún | to collect tax |
| រកស៊ី | róo sii | to make a living, to earn money (L) |
| រដ្ឋប្រហារ | rót pəhaa | coup d'etat |
| រូងដី | ruuŋ dɛy | tunnel, hole, cave |
| រៃលុយ | rey luy | to collect money |
| លុកលុយ | luk luy | to invade |
| វាយគ្នា | vay knia | to fight |
| សម័យ | səmay | era, age, period of time (R) |
| ស្ពាន | spian | bridge |
| ស្លូតត្រង់ | slout troŋ | honest, decent, nice |



Farmhouse (traditional style)

## LESSON FIFTY-FOUR

### DIALOGUE

| | |
|---|---|
| អន្ទាក់ | trap |
| ដោះ | to release, take off (clothing) |
| ដោះចេញ | to undo, to dismantle |
| ១. សុខ នៅពេលដែលលោកឃើញអន្ទាក់នោះ លោកឲ្យកូនទាហានលោកដោះវាចេញទេ? | At the time you saw that trap, did you order your men to dismantle it? |
| ទទួលបន្ទុក | to be responsible, be in charge of |
| ២. ភុម ទេ តែខ្ញុំបានហៅក្រុមមួយទៀតដែលទទួលបន្ទុកខាងដោះគ្រាប់មីន។ | No, but I called another squad that is responsible for mines. |
| ឬណា | (indicating some disbelief) |
| ៣. សុខ ហេតុអី? អន្ទាក់មិនមែនជាគ្រាប់មីនឬណា។ | Why? Traps are not mines? |
| ៤. ភុម បាទ ខ្ញុំដឹងហើយ តែនៅក្បែរនោះយើងសង្ស័យជាមានមីន។ | Yes, I know, but we suspected that there were mines nearby. |
| រយៈ | period, interval |
| ក្នុងរយៈ | during |
| ៥. សុខ ក្នុងរយៈពេលនោះលោកចាំយូរទេ? | During that time did you (have to) wait long? |
| ភ្លាម | immediately, right away |
| ៦. ភុម ទេ ក្រុមខាងដោះគ្រាប់មកដល់ភ្លាម។ | No, the mine squad arrived right away. |
| ទុកចិត្ត(លើ) | to trust, to have confidence |
| ៧. សុខ លោកទុកចិត្តលើក្រុមនេះទេ? | Do you trust this squad? |
| យកចិត្តទុកដាក់ | (to do) with care, to pay attention |
| មុខងារ | job, work |
| ៨. ភុម បាទ ព្រោះគេធ្វើការយកចិត្តទុកដាក់ណាស់។ គេដឹងមុខងាររបស់គេ។ | Yes, because they do their job with care. They know their job. |

DIALOGUE:

1. sok - nɨw peel daεl look khəəñ əté? nuh, look aoy koun təhian look dɔh via
   cεñ eh?

2. tom - tee, taε khñom baan haw krom muoy tiet daεl tətuol pətuk khaaŋ dɔh
   króp miin

3. sok - haεt εy? əté? mɨn mεεn cə króp miin aεnaa?

4. tom - baat, khñom dəŋ haəy, taε nɨw kbaε nuh yəəŋ sɔŋsay thaa mian miin

5. sok - knoŋ rəyé? peel nuh look cam yuu eh?

6. tom - tee, krom khaaŋ dɔh króp móo dɔl phliam

7. sok - look tuk cət ləə krom nih tee?

8. tom - baat, prúh kee thəə kaa yóo cət tuk da? nah. kee dəŋ muk ŋia ləbɔh kee

NOTES

DIALOGUE

SENTENCE NO.

3. ឯណា /aεnaa/ at the end of a statement or proposition usually means 'what do you mean...?!' It conveys incredulity and surprise. In a sentence like sentence 3 of the dialogue, it indicates disbelief, skepticism, and a bit of derision. In Drill 10 ឯណា /aεnaa/ indicates that the speaker thinks that the proposition preceding the word ឯណា /aεnaa/ is invalid, absurd, or impossible. In this case ឯណា /aεnaa/ is translated 'what do you mean...?!' or 'how can I...?!'

5. The word រយៈ /rəyé?/ 'interval' refers only to time, not space.

DRILLS

DRILL NO.

8. The word ចំណោម /cənaom/ refers to a set, usually one from which members are singled out in the sentence in which ចំណោម /cənaom/ is used. ចំណោម /cənaom/ + noun can be followed by ទាំងអស់ /téŋ ɔh/ 'all' or not, e.g. sentence b of Drill 8 can also be

   ក្នុងចំណោមឡាននោះខ្ញុំចូលចិត្តអាមួយនេះ។
   knoŋ cənaom laan nuh khñom coul cət aa muoy nih
   Among those (that set of) cars I like this one best.

## DRILLS

DRILL ONE: Transformation

MODEL: T: ពួកវៀតកុងមិនចូលចិត្តអ្នកស្រុកទេ។

S: យើងមិនត្រូវទុកចិត្តពួកវៀតកុងទេព្រោះពួកវៀតកុងមិនចូលចិត្តអ្នកស្រុក។

T: The Viet Cong don't like the villagers.

S: We mustn't trust the Viet Cong because the Viet Cong don't like the villagers.

ក. ខ្មាំងយើងឧស្សាហ៍ខូចណាស់។
យើងមិនត្រូវទុកចិត្តខ្មាំងយើងទេព្រោះខ្មាំងយើងឧស្សាហ៍ខូចណាស់។

ខ. ស្ពាននេះចាស់ណាស់។
យើងមិនត្រូវទុកចិត្តស្ពាននេះទេព្រោះស្ពាននេះចាស់ណាស់។

គ. ផ្លូវនេះមានគ្រោះថ្នាក់ច្រើនណាស់។
យើងមិនត្រូវទុកចិត្តផ្លូវនេះទេព្រោះផ្លូវនេះមានគ្រោះថ្នាក់ច្រើនណាស់។

ឃ. ពួកម៉ាកលោកកែមភូតច្រើនណាស់។
យើងមិនត្រូវទុកចិត្តពួកម៉ាកលោកកែមទេព្រោះពួកម៉ាកលោកកែមភូតច្រើនណាស់។

ង. គាត់មិនដឹងរឿងនេះទេ។
យើងមិនត្រូវទុកចិត្តគាត់ទេព្រោះគាត់មិនដឹងរឿងនេះទេ។

ច. កាំភ្លើងនេះមិនល្អទេ។
យើងមិនត្រូវទុកចិត្តកាំភ្លើងនេះទេព្រោះកាំភ្លើងនេះមិនល្អទេ។

DRILL TWO: Transformation

MODEL: T: កូនទាហានដោះអន្ទាក់ចេញ។

S: កូនទាហានត្រូវទទួលបន្ទុកដោះអន្ទាក់ចេញ។

T: The soldiers dismantle traps.

S: The soldiers must be responsible for dismantling traps.

ក. កងទ័ពលោកដេញពួកខ្មាំង។
កងទ័ពលោកត្រូវទទួលបន្ទុកខាងដេញពួកខ្មាំង។

ខ. លោកសក្ដិពីរផ្ដល់គ្រាប់ទៅទាហាន។
លោកសក្ដិពីរត្រូវទទួលបន្ទុកខាងផ្ដល់គ្រាប់ទៅទាហាន។

គ. ខ្ញុំលើកទឹកចិត្តកូនទាហាន។
ខ្ញុំត្រូវទទួលបន្ទុកខាងលើកទឹកចិត្តកូនទាហាន។

ឃ. កូនទាហានម្នាក់យាមបន្ទាយ។
កូនទាហានម្នាក់ត្រូវទទួលបន្ទុកខាងយាមបន្ទាយ។

ង. លោកសក្ដិពីរទៅទិញអាហារ។
លោកសក្ដិពីរត្រូវទទួលបន្ទុកខាងទិញអាហារ។

ច. ខ្ញុំជញ្ជូនបាវដីខ្សាច់។
ខ្ញុំត្រូវទទួលបន្ទុកខាងជញ្ជូនបាវដីខ្សាច់។

DRILL THREE: Transformation

MODEL: T: វៀតកុងត្រូវចេញពីស្រុកខ្មែរ។ (បីខែ)
S: វៀតកុងត្រូវចេញពីស្រុកខ្មែរក្នុងរយៈបីខែ។
T: The Viet Cong must leave Cambodia.
S: The Viet Cong must leave Cambodia within 3 months.

ក. ខ្ញុំត្រូវចេញពីទាហាន។ (ប្រាំខែ)
ខ្ញុំត្រូវចេញពីទាហានក្នុងរយៈប្រាំខែ។
ខ. ខ្ញុំត្រឡប់ទៅស្រុកខ្មែរ។ (មួយអាទិត្យ)
ខ្ញុំត្រឡប់ទៅស្រុកខ្មែរក្នុងរយៈមួយអាទិត្យ។
គ. ខ្ញុំសរសេរសំបុត្រចប់។ (ពីរម៉ោង)
ខ្ញុំសរសេរសំបុត្រចប់ក្នុងរយៈពីរម៉ោង។
ឃ. កូនទាហានដោះមីនរួច។ (កន្លះម៉ោង)
កូនទាហានដោះមីនរួចក្នុងរយៈកន្លះម៉ោង។
ង. ក្រុមខាងដោះគ្រាប់មីនមកដល់។ (ដប់មីនុត)
ក្រុមខាងដោះគ្រាប់មីនមកដល់ក្នុងរយៈដប់មីនុត។
ច. ពួកវៀតកុងដកទ័ពថយពីព្រំដែន។ (ពីរអាទិត្យ)
ពួកវៀតកុងដកទ័ពថយពីព្រំដែនក្នុងរយៈពីរអាទិត្យ។

DRILL FOUR: Transformation

MODEL: T: លោកសក្តិប្រាំមកដល់។ (លោកហៅខ្ញុំ)
S: កាលណាលោកសក្តិប្រាំមកដល់ លោកហៅខ្ញុំភ្លាម។
T: The Colonel arrives.
S: When (ever) the Colonel arrives, call me right away.

ក. ខ្ញុំមកដល់ក្នុងថ្នាក់។ (លោកឈប់ជក់បារី)
កាលណាខ្ញុំមកដល់ក្នុងថ្នាក់ លោកឈប់ជក់បារីភ្លាម។
ខ. ប៉ូលិសចូលក្នុងផ្ទះ។ (លោករត់ចេញ)
កាលណាប៉ូលិសចូលក្នុងផ្ទះ លោករត់ចេញភ្លាម។
គ. លោកជួបលោកស្មៀន។ (លោកសួរគាត់)
កាលណាលោកជួបលោកស្មៀន លោកសួរគាត់ភ្លាម។
ឃ. ខ្ញុំទទួលដំណឹងល្អ។ (ខ្ញុំប្រាប់លោក)
កាលណាខ្ញុំទទួលដំណឹងល្អ ខ្ញុំប្រាប់លោកភ្លាម។
ង. មានពាក្យចចាមអារាម។ (លោករាយការណ៍មកខ្ញុំ)
កាលណាមានពាក្យចចាមអារាម លោករាយការណ៍មកខ្ញុំភ្លាម។
ច. ខ្ញុំទទួលគ្រាប់កាំភ្លើង។ (ខ្ញុំផ្តល់ឲ្យលោក)
កាលណាខ្ញុំទទួលគ្រាប់កាំភ្លើង ខ្ញុំផ្តល់ឲ្យលោកភ្លាម។

DRILL FIVE: Transformation

MODEL: T: សត្រូវចូលភូមិនេះម្ដងទៀត។
S: ខ្ញុំឮពាក្យចចាមអារ៉ាមថា សត្រូវចូលភូមិនេះម្ដងទៀត។
T: The enemy have entered this village once more.
S: I've heard a rumor that the enemy have entered this village once more.

ក. គេដាក់មីននៅក្រោមស្ពាន។
ខ្ញុំឮពាក្យចចាមអារ៉ាមថាគេដាក់មីននៅក្រោមស្ពាន។
ខ. លោកចង់ទៅស្រុកយួន។
ខ្ញុំឮពាក្យចចាមអារ៉ាមថាលោកចង់ទៅស្រុកយួន។
គ. អ្នកស្រុកផ្ដល់កាំភ្លើងឱ្យយៀកកុង។
ខ្ញុំឮពាក្យចចាមអារ៉ាមថាអ្នកស្រុកផ្ដល់កាំភ្លើងឱ្យយៀកកុង។
ឃ. យៀកកុងបញ្ឆះបញ្ឆូលអ្នកស្រុក។
ខ្ញុំឮពាក្យចចាមអារ៉ាមថាយៀកកុងបញ្ឆះបញ្ឆូលអ្នកស្រុក។
ង. លោកឱ្យយៀកកុងនៅផ្ទះលោក។
ខ្ញុំឮពាក្យចចាមអារ៉ាមថាលោកឱ្យយៀកកុងនៅផ្ទះលោក។
ច. អាមេរិកាំងដកកងទ័ពចេញឆ្នាំក្រោយ។
ខ្ញុំឮពាក្យចចាមអារ៉ាមថាអាមេរិកាំងដកកងទ័ពចេញឆ្នាំក្រោយ។

DRILL SIX: Transformation

MODEL: T: ពួកសត្រូវចូលមកបាញ់អ្នកស្រុករាល់ថ្ងៃ។ (អ្នកស្រុក)
S: អ្នកស្រុកមិនទុកចិត្តពួកសត្រូវ។
T: The enemy come to fire at the villagers every day.
S: The villagers don't trust the enemy.

ក. ឡានខ្ញុំធ្វើឱ្យខ្ញុំព្រួយរាល់ថ្ងៃ។ (ខ្ញុំ)
ខ្ញុំមិនទុកចិត្តឡានខ្ញុំទេ។
ខ. ប្រពន្ធលោកភូតលោករាល់ដង។ (លោក)
លោកមិនទុកចិត្តប្រពន្ធលោកទេ។
គ. ព្រៃហ្នឹងធំណាស់។ (ពួកយើង)
ពួកយើងមិនទុកចិត្តព្រៃហ្នឹងទេ។
ឃ. ខ្ញុំមិនសូវចេះបង្រៀនទេ។ (លោក)
លោកមិនទុកចិត្តខ្ញុំទេ។
ង. ចិនលក់ឥវ៉ាន់ថ្លៃណាស់។ (ខ្ញុំ)
ខ្ញុំមិនទុកចិត្តចិនទេ។
ច. ស្ពាននេះចាស់ណាស់។ (ខ្ញុំ)
ខ្ញុំមិនទុកចិត្តស្ពាននេះទេ។

DRILL SEVEN: Transformation

MODEL: T: លោកគ្រូបង្រៀនកូនសិស្សល្អណាស់។

S: លោកគ្រូយកចិត្តទុកដាក់នឹងបង្រៀនកូនសិស្សណាស់។

T: The teacher teaches the students very well.

S: The teacher teaches the students with care.

ក. លោកបើកឡានប្រយ័ត្នណាស់។
លោកយកចិត្តទុកនឹងបើកឡានណាស់។

ខ. កូនទាហានខ្ញុំធ្វើការល្អណាស់។
កូនទាហានខ្ញុំយកចិត្តទុកដាក់នឹងធ្វើការណាស់។

គ. កញ្ញារៀនខ្មែរស្មៀនណាស់។
កញ្ញាយកចិត្តទុកដាក់នឹងរៀនខ្មែរណាស់។

ឃ. យៀកកុងបញ្ចុះបញ្ចូលអ្នកស្រុករាល់ថ្ងៃ។
យៀកកុងយកចិត្តទុកដាក់នឹងបញ្ចុះបញ្ចូលអ្នកស្រុកណាស់។

ង. យើងការពារបន្ទាយនេះរាល់យប់។
យើងយកចិត្តទុកដាក់នឹងការពារបន្ទាយនេះណាស់។

ច. រាជការយកពន្ធពីអ្នកស្រុករាល់ឆ្នាំ។
រាជការយកចិត្តទុកដាក់នឹងយកពន្ធពីអ្នកស្រុកណាស់។

DRILL EIGHT: Transformation

MODEL: T: លោកដារាជាទាហានល្អជាងគេ។ (ទាហានទាំងអស់)

S: ក្នុងចំណោមទាហានទាំងអស់ លោកដារាជាទាហានល្អជាងគេ។

T: Mr. Dara is the best soldier of all.

S: Among all the soldiers, Mr. Dara is the best one.

ក. កញ្ញាខំរៀនណាស់។ (កូនសិស្សទាំងអស់)
ក្នុងចំណោមកូនសិស្សទាំងអស់ កញ្ញាខំរៀនណាស់។

ខ. ខ្ញុំចូលចិត្តអាមួយនេះ។ (ឡានទាំងអស់)
ក្នុងចំណោមឡានទាំងអស់ ខ្ញុំចូលចិត្តអាមួយនេះ។

គ. ខ្ញុំចង់បាញ់កាំភ្លើងធុនអឹម-១៦។ (កាំភ្លើងទាំងអស់)
ក្នុងចំណោមកាំភ្លើងទាំងអស់ ខ្ញុំចង់បាញ់កាំភ្លើងធុនអឹម-១៦។

ឃ. ខ្ញុំបានមើលសៀវភៅប្រាំ។ (សៀវភៅទាំងអស់)
ក្នុងចំណោមសៀវភៅទាំងអស់ ខ្ញុំបានមើលសៀវភៅប្រាំ។

ង. កាំភ្លើងនេះថ្លៃណាស់។ (កាំភ្លើងទាំងអស់)
ក្នុងចំណោមកាំភ្លើងទាំងអស់ កាំភ្លើងនេះថ្លៃណាស់។

ច. កូនស្រីលោកល្អណាស់។ (កូនលោកទាំងអស់)
ក្នុងចំណោមកូនលោកទាំងអស់ កូនស្រីលោកល្អណាស់។

DRILL NINE: Substitution

MODEL: T: លោកខំធ្វើការណាស់ប៉ុន្មានថ្ងៃនេះ។ (យើង)
S: យើងខំធ្វើការណាស់ប៉ុន្មានថ្ងៃនេះ។
T: You have worked very hard in the last few days.
S: We have worked very hard in the last few days.

ក. យើងខំធ្វើការណាស់ប៉ុន្មានថ្ងៃនេះ។ (រៀន)
ខ. យើងខំរៀនណាស់ប៉ុន្មានថ្ងៃនេះ។ (លោកគ្រូ)
គ. លោកគ្រូខំរៀនណាស់ប៉ុន្មានថ្ងៃនេះ។ (បង្រៀន)
ឃ. លោកគ្រូខំបង្រៀនណាស់ប៉ុន្មានថ្ងៃនេះ។ (យកចិត្តទុកដាក់)
ង. លោកគ្រូខំយកចិត្តទុកដាក់ណាស់ប៉ុន្មានថ្ងៃនេះ។ (ទាហានយើង)
ច. ទាហានខំ យើងយកចិត្តទុកដាក់ណាស់ប៉ុន្មានថ្ងៃនេះ។

DRILL TEN: Response

MODEL: T: នៅពេលលោកឃើញអន្ទាក់ លោកដោះវាចេញទេ? (កំពុងដេញខ្មាំង)
S: ដោះវាចេញឯណា បើខ្ញុំកំពុងដេញខ្មាំង។
T: At the time you saw the trap, did you dismantle it? (chasing the enemy)
S: What do you mean dismantle it, when I was chasing the enemy?

ក. នៅពេលឃើញគ្រោះថ្នាក់ លោករាយការណ៍ទៅប៉ូលីសទេ? (មិនចេះនិយាយភាសាខ្មែរ)
រាយការណ៍ទៅប៉ូលីសឯណា បើខ្ញុំមិនចេះនិយាយភាសាខ្មែរ។
ខ. នៅពេលដែលលោកលួចឡាន លោកមើលប៉ូលីសទេ? (រវល់បើកទ្វារឡាន)
មើលប៉ូលីសឯណា បើខ្ញុំរវល់បើកទ្វារឡាន។
គ. នៅពេលដែលលោកបាត់កូន លោកដើររកវាទេ? (កំពុងបង្រៀនកូនសិស្សខ្ញុំ)
ដើររកឯណា បើខ្ញុំកំពុងបង្រៀនកូនសិស្សខ្ញុំ។
ឃ. នៅពេលដែលលោកទៅដល់ស្រុកបូស្តុន លោកទៅជួបលោកសក្តិថិភ្លាមទេ? (មិនដឹងគាត់នៅឯណាផង)
ទៅជួបលោកសក្តិថិឯណា បើខ្ញុំមិនដឹងគាត់នៅឯណាផង។
ង. នៅពេលដែលលោកបាញ់កាំភ្លើង លោកឃើញខ្មាំងទេ? (មើលអីក៏មិនឃើញផង)
ឃើញខ្មាំងឯណា បើខ្ញុំមើលអីក៏មិនឃើញផង។
ច. នៅពេលដែលលោកនៅក្នុងថ្នាក់ លោកឃើញខ្ញុំចូលទេ? (កំពុងបង្រៀន)
ឃើញលោកចូលឯណា បើខ្ញុំកំពុងបង្រៀន។

DRILL ELEVEN: Response

MODEL: T: លោកចាំតែបាញ់ទេ។ (ប្រកគ្រាប់ឲ្យខ្ញុំ)
S: បាទ ឲ្យតែលោកប្រកគ្រាប់ឲ្យខ្ញុំ។
T: Just wait and shoot. (load for me)
S: Yes, provided you load for me.

ក. លោកចាំតែបើកទ្វារទេ។ (បាញ់ការពារឲ្យខ្ញុំ)
បាទ ឲ្យតែលោកបាញ់ការពារឲ្យខ្ញុំ។
ខ. លោកចាំតែកាប់ក្បាលពួកឈ្លើយសង្គ្រាមទេ។ (មានកន្លែងឲ្យគេនៅ)
បាទ ឲ្យតែលោកមានកន្លែងឲ្យគេនៅ។
គ. លោកចាំតែបោសគ្រាប់បែកដៃទេ។ (មានគ្រប់គ្រាន់)
បាទ ឲ្យតែលោកមានគ្រប់គ្រាន់។
ឃ. លោកចាំតែបង្អត់កូនទាហានទេ។ (ជួយខ្ញុំ)
បាទ ឲ្យតែលោកជួយខ្ញុំ។
ង. លោកចាំតែនិយាយជាមួយមេដឹកនាំទេ។ (ជូនខ្ញុំទៅ)
បាទ ឲ្យតែលោកជូនខ្ញុំទៅ។
ច. លោកចាំតែបោះជំរំទេ។ (រកកន្លែងឲ្យខ្ញុំ)
បាទ ឲ្យតែលោករកកន្លែងឲ្យខ្ញុំ។

DRILL TWELVE: Response

MODEL: T: ជាឈ្លើយសង្គ្រាមលោកត្រូវប្រាប់គេអ្វីខ្លះ? (លេខសំគាល់ខ្លួន)
S: ជាឈ្លើយសង្គ្រាមខ្ញុំត្រូវប្រាប់គេតែលេខសំគាល់ខ្លួនទេ។
T: As a prisoner of war what must you state? (my serial number)
S: As a prisoner of war I only have to state my serial number.

ក. ជាអ្នកយកការណ៍លោកត្រូវប្រាប់គេអ្វីខ្លះ? (ឈ្មោះខ្ញុំ)
ជាអ្នកយកការណ៍ខ្ញុំត្រូវប្រាប់គេតែឈ្មោះខ្ញុំទេ។
ខ. ជាពេទ្យទាហានលោកត្រូវឲ្យថ្នាំទៅអ្នកណាខ្លះ? (ពួកឈ្លោះប្រឆាំងនឹងរដ្ឋការ)
ជាពេទ្យទាហានខ្ញុំត្រូវឲ្យថ្នាំទៅតែពួកឈ្លោះប្រឆាំងនឹងរដ្ឋការទេ។
គ. ជាអ្នករាយការណ៍លោកត្រូវនិយាយអំពីអ្វីខ្លះ? (រឿងពិត)
ជាអ្នករាយការណ៍ខ្ញុំត្រូវនិយាយតែអំពីរឿងពិតទេ។
ឃ. ជាទាហានលោកត្រូវធ្វើអ្វីខ្លះ? (អ្វីដែលគេប្រាប់ខ្ញុំ)
ជាទាហានខ្ញុំត្រូវធ្វើអ្វីដែលគេប្រាប់ខ្ញុំ។
ង. ជាអ្នកការទូតលោកត្រូវធ្វើអ្វីខ្លះ? (អ្វីដែលរដ្ឋការប្រាប់ខ្ញុំឲ្យធ្វើ)
ជាអ្នកការទូតខ្ញុំត្រូវធ្វើអ្វីដែលរដ្ឋការប្រាប់ខ្ញុំឲ្យធ្វើ។

DRILL THIRTEEN: Substitution

MODEL: T: ពួកខ្មាំងចាប់អ្នកការទូតបរទេសម្នាក់។ (ឯកអគ្គរដ្ឋទូត)
S: ពួកខ្មាំងចាប់ឯកអគ្គរដ្ឋទូតម្នាក់។
T: The enemy captured a foreign diplomat. (ambassador)
S: The enemy captured an ambassador.

ក. ពួកខ្មាំងចាប់ឯកអគ្គរដ្ឋទូតម្នាក់។ (អ្នករាយការណ៍កាសែត)
ខ. ពួកខ្មាំងចាប់អ្នករាយការណ៍កាសែតម្នាក់។ (អ្នកជំនួញបួននាក់)

គ. ពួកទាំងចាប់អ្នកជំនួញបួននាក់។ ( ប៉ូលីស)
ឃ. ប៉ូលីសចាប់អ្នកជំនួញបួននាក់។ (សួរចម្លើយ)
ង. ប៉ូលីសសួរចម្លើយអ្នកជំនួញបួននាក់។ (ដោះលែង)
ច. ប៉ូលីសដោះលែងអ្នកជំនួញបួននាក់។ (អ្នករត់គេច)
ឆ. ប៉ូលីសដោះលែងអ្នករត់គេចបួននាក់។

Reading Passage

ខ្ញុំរត់ចេញពីកងទ័ពព្រៃ

តាំងពីមានចម្បាំងមក អ្នកស្រុកទាំងប្រុសទាំងស្រី ទាំងចាស់ទាំងក្មេង រត់ចោលផ្ទះ ចោលស្រុក ហើយគេរត់ទៅនៅកន្លែងណាដែលគេអាចរកសេចក្ដីសុខបាន។

គេរត់ព្រោះគេខ្លាចស្លាប់ គេខ្លាចកងទ័ពព្រៃកងទ័ពស្រុកដុតផ្ទះ យកឥវ៉ាន់គេ។ គេមិនដឹងទុកចិត្តលើកងទ័ពណា ហើយខ្ញុំវិញ ដោយភូមិខ្ញុំនៅឆ្ងាយពីទីក្រុងធំៗ គ្មានការទាក់ទងជាមួយអ្នករដ្ឋការ ខ្ញុំគ្មានដឹងនយោបាយក្នុងស្រុក។ ធម្មតាទាំងគេទាំងខ្ញុំ យើងរកតែសុខទេ យើងរកស៊ីសម្រាប់ចិញ្ចឹមគ្រួសារយើង។ តែត្រូវជាពេលចម្បាំង កងទ័ពព្រៃចូលមកភូមិមុនកងទ័ពរដ្ឋការ ដូច្នេះកងទ័ពព្រៃបានបញ្ចុះបញ្ចូលអ្នកភូមិឲ្យចូលដៃជាមួយគេ ដើម្បីវាយប្រឆាំងកងទ័ពរដ្ឋការ។ ខ្ញុំក៏ចូលដៃនឹងគេ តែខ្ញុំគ្មានគោលបំណងអ្វីក្រៅពីរកសន្តិសុខសម្រាប់ខ្លួនខ្ញុំទេ។

ពេលនោះគេឲ្យខ្ញុំទទួលបន្ទុកខាងវាយបំផ្លាញស្ពាន ផ្លូវថ្នល់។ ខ្ញុំមានមនុស្សធ្វើការក្រោមខ្ញុំ៥នាក់ដែរដែលធ្លាប់នៅភូមិជាមួយគ្នា ហើយយើងទាំងអស់មានគំនិតប្រហែលៗគ្នា។ មុនដំបូង យើងយកចិត្តទុកដាក់ណាស់ក្នុងការបំផ្លាញស្ពានធំតូច តែថ្ងៃមួយពួកម៉ាកយើងធ្លាក់ស្លាប់នៅពេលដែលយើងកំពុងនិងរៀបចំបំផ្លាញស្ពានមួយ យើងទាំង៥នាក់ក៏រត់ដកថយទៅកន្លែងមួយ ហើយយើងបានប្រជុំនិយាយរកខុសរកត្រូវ។ បើយើងចង់បានសន្តិសុខ មិនចង់ស្លាប់ ចុះហេតុអ្វីបានជាយើងទៅបំផ្លាញស្ពាន ហើយជួនកាល មានមនុស្សស្លាប់ដោយសារតែយើង ហើយយើងទៀតក៏គ្មានពេលសប្បាយ ដេកមិនបានស្រួល យប់នេះនៅកន្លែងនេះ យប់ស្អែកយើងទៅដេកនៅកន្លែងនោះ បាយស៊ីទាំងឆៅ។ យ៉ាងនេះហើយបានជាយើងសម្រេចថា យើងត្រូវរត់ចេញពីកងទ័ពព្រៃ ដើម្បីនឹងរកសន្តិសុខពិតជាមួយជាតិយើង។

នៅថ្ងៃមួយ ក្រោយពីបានទទួលបញ្ជារបស់អ្នកដឹកនាំ យើងបានសុំឲ្យមានប្រដាប់ប្រដារច្រើន ហើយមនុស្ស៥នាក់ទៀត ពីព្រោះមុខងារម្ដងនេះពិបាកជាងមុន។ អ្នកដឹកនាំក៏ព្រមតាម ហើយយើងក៏ចេញទៅ។ ពេលនេះហើយជាពេលក្រោយបង្អស់ដែលយើងនិយាយជាមួយពួកកងទ័ពព្រៃ និងជាពេលក្រោយបង្អស់ដែលយើងញ៉ាំបាយឆៅ ដេកនៅក្នុងព្រៃ រត់ពីកន្លែងមួយទៅកន្លែងមួយ។

នៅថ្ងៃដដែល ខ្ញុំក៏នាំមនុស្ស៩នាក់និងប្រដាប់ប្រដារជាច្រើនទៅចូលជាមួយទាហានរដ្ឋការទៅ។

## VOCABULARY

| | | |
|---|---|---|
| ក្នុងចំណោម | knoŋ cənaom | among |
| ក្នុងរយៈ | knoŋ rəyéʔ | during, within, (see note) |
| ខំ | khom | to try, to make an effort |
| គោលបំណង | kool mnɔɔŋ | purpose, aim, goal (R) |
| គ្រប់គ្រាន់ | krup krɔ́n | enough, sufficient, adequate |
| គ្រាប់បែកដៃ | krɔ́p baɛk day | hand grenade |
| ចង | cɔɔŋ | to tie (L) |
| ចងភ្នែក | cɔɔŋ phnɛɛk | to blindfold (L) |
| ចាំតែ | cam taɛ | wait and... |
| ច្រក | crɔɔʔ | to stuff, to feed, to push in |
| ជំនួញ | cənuoñ | business, buying and selling |
| ដក | dɔɔʔ | to withdraw |
| ដកថយ | dɔɔʔ thɔɔy | to retreat, to pull back |
| ដោះចេញ | doh cɛñ | to dismantle, to undo |
| ដោះលែង | doh lɛɛŋ | to release |
| ថយ | thɔɔy | to go back |
| ទទួលបន្ទុក | tətuol pətuk | to be in charge |
| បញ្ចុះបញ្ចូល | pəcoh pəcoul | to influence, to persuade |
| បាត់ | bat | to lose (something) |
| បោះជំរំ | boh cərum | to pitch camp |
| ពាក្យចចាមអារាម | piaʔ cəcaam əraam | rumor |
| ពិត | pɨt | true |
| ភូត | phuut | to lie |
| មុខងារ | muk ŋia | job, work |
| យកការណ៍ | yóo kaa | to spy |
| យកចិត្តទុកដាក់ | yóo cət tuk daʔ | to do with care, to pay attention to |
| រត់គយ | rut kóoy | to smuggle |
| រយៈ | rəyéʔ | interval |
| រាប់ | rɔ́p | to count |
| លេខសំគាល់ខ្លួន | leek səkól khluon | serial number |
| លើកទឹកចិត្ត | leek tɨk cət | to encourage |
| សួរចម្លើយ | suo cəlaəy | to interrogate |
| សំគាល់ | səkól | to recognize |
| ស្នូរ | snou | sound, noise (L) |
| ស្មោះត្រង់ | smɔh trɔŋ | honest, straightforward |

| | | |
|---|---|---|
| អន្ទាក់ | əté? | trap |
| (អ្នក) អង្គទូត | (né?) ɔŋtuut | diplomat |
| ឯណា | aɛnaa | what do you mean? |



Buddhist wat, Phnom Penh

# LESSON FIFTY-FIVE

## DIALOGUE

| | | | |
|---|---|---|---|
| ១. | សុខ | ពួកអាមេរិកាំងប្រើកប៉ាល់ហោះធុនបេហាសិបពីរសម្រាប់ធ្វើអី? | What do the Americans use the B-52 plane for? |
| | | ពឹងលើ | to depend on |
| ២. | គុម | ទាហានអាមេរិកាំងពឹងលើកប៉ាល់ហោះហ្នឹងដើម្បីនឹងទំលាក់គ្រាប់បែកលើពួកសត្រូវ។ | American soldiers depend on those planes to drop bombs on the enemy. |
| | | ប្រតិកម្ម | reaction |
| | | កប៉ាល់ហោះប្រតិកម្ម | jet plane |
| ៣. | សុខ | ចុះពុំក្រែងគេប្រើកប៉ាល់ហោះប្រតិកម្មធុនតូចៗទេឬ? | Well! Don't they use the small jet bombers? |
| | | កាំជ្រួច | missile, rocket |
| ៤. | គុម | បាទ កប៉ាល់ហោះនេះច្រើនប្រើសម្រាប់ដេញបាញ់កប៉ាល់ខ្មាំងនឹងសម្រាប់បាញ់កាំជ្រួច។ | Those planes are mostly used to chase enemy planes and to fire rockets. |
| | | សមុទ្រ | sea, ocean |
| | | ផ្ទុក | to load |
| | | នាវាផ្ទុកកប៉ាល់ហោះ | aircraft carrier |
| ៥. | សុខ | ខ្ញុំឮថានៅក្នុងសមុទ្រស្រុកចិនមាននាវាផ្ទុកកប៉ាល់ហោះដែរមែនទេ? | I've heard that in the China Sea there are aircraft carriers too, aren't there? |
| | | ហោះ | to fly |
| ៦. | គុម | បាទ មានពីរបីដែរហើយ កប៉ាល់ហោះប្រតិកម្មតូចៗច្រើនហោះចេញពីនាវានោះ។ | Yes, there are a couple of them. Most of the small jet bombers fly from those carriers. |
| | | ដឹក | to carry, to transport |
| ៧. | សុខ | គេប្រើកប៉ាល់ហោះអីដើម្បីដឹកទ័ព? | What type of airplane do they use for transporting troops? |
| | | អេលីកុបទ័រ | helicopter |
| | | កប៉ាល់ហោះដឹក | transport plane |
| ៨. | គុម | មានអេលីកុបទ័រនឹងកប៉ាល់ហោះដឹកធំៗ។ | There are helicopters and big transport airplanes. |

DIALOGUE:

1. sok - puoʔ aameerɨkaŋ praə kəpal hɔh thun bee haasəp pii səmrap thəə ɛy?

2. tom - təhian aameerɨkaŋ əmpɨŋ ləə kəpal hɔh nɨŋ haəy daəmbɛy nɨŋ təléʔ krɔ́p baɛk lɨə puoʔ sətrəw

3. sok - coh kraɛŋ kee praə kəpal hɔh proteʔkam thun touc touc tee eh?

4. tom - baat, kəpal hɔh nih craən praə səmrap dɛñ bañ kəpal khmaŋ nɨŋ səmrap bañ kəcruoc

5. sok - khñom lɨɨ thaa nɨw knoŋ səmut srok cən, mian niavia phtuk kəpal hɔh daɛ, mɛɛn tee?

6. tom - baat, mian pii bɛy daɛ haəy haəy kəpal hɔh proteʔkam touc touc craən hɔh cɛñ pii niavia nuh

7. sok - kee praɛ kəpal hɔh ɛy daəmbɛy dək tɔ́p?

8. tom - mian eeliikoptɛr nɨŋ kəpal hɔh phtuk thom thom

NOTES

DIALOGUE

SENTENCE NO.

2. In this sentence, ហើយ /haəy/ focusses attention on the preceding noun phrase. Sentence two is thus something like 'It is those planes that the American soldiers depend on to drop bombs on the enemy.' See also Drill 3.

3. In this sentence the last two words are ទេ /tee/ and ឬ /rɨɨ/. ទេ /tee/ has a connotation of contradiction of what comes before; ឬ is interrogative. See also Drill 4.

6. There are two words in Cambodian that mean 'fly.' The word ហើរ /haə/ means 'to fly by flapping wings.' However, ហោះ /hɔh/ refers to flying that is done without flapping wings.

DRILLS

DRILL NO.

5. ច្រើន /craən/ or ច្រើនតែ /craən taɛ/ is a preverbal adverb like ចេះតែ /cəh taɛ/ 'always.'

7. Note that here is a new construction for indicating causation. In this construction a limited number of transitive verbs may be followed by a second, attributive verb, which describes the action caused by the first verb. The noun that follows both verbs is the object of the first verb and the subject of the second verb. For instance, in

គេបាញ់សម្លាប់ទាហានយើងម្នាក់

kee bañ slap təhian yəəŋ mənéʔ

They shot and killed one of our soldiers.

The verb ស្លាប់ /slap/ 'to die' is attributive to បាញ់ /bañ/ 'to shoot' and is a consequence of this action. ទាហាន /təhian/, 'soldier' is both object of បាញ់ /bañ/ 'to shoot' and subject of ស្លាប់ /slap/ 'to die.'

8. មុនដំបូង /mun təbouŋ/ means 'first of all, originally.' Its opposite is ក្រោយបង្អស់ /kraoy (bɔŋʔɔh)/ 'last of all, finally.'

13. ទើប /təəp/ is used like បាន /baan/ (Lesson 17) between clauses to mean 'not...until.' Normally the condition comes first, then ទើប, then the contingent clause. In Drill 13 the condition clause is introduced by ទាល់តែ /tóol tae/, but ទាល់តែ /tóol tae/ can also be omitted, e.g.,

លោកសួរអ្នកស្រុកទើបលោករកកន្លែងខ្មាំងឃើញ។

look suo néʔ srok təəp look róo kəlaeŋ khmaŋ khəəñ

You won't find the enemy until you ask the people who live there.

## DRILLS

DRILL ONE: Substitution

MODEL: T: ពួកអាមេរិកាំងប្រើកប៉ាល់ហោះប៊ី-៥២ សម្រាប់ធ្វើអី? (អេលីកុបទ័រ)

S: ពួកអាមេរិកាំងប្រើអេលីកុបទ័រសម្រាប់ធ្វើអី?

T: What do Americans use the B-52 plane for?

S: What do Americans use the helicopter for?

ក. ពួកអាមេរិកាំងប្រើអេលីកុបទ័រសម្រាប់ធ្វើអី? (នាវាផ្ទុកកប៉ាល់ហោះ)
ខ. ពួកអាមេរិកាំងប្រើនាវាផ្ទុកកប៉ាល់ហោះសម្រាប់ធ្វើអី? (ឡានហ្ស៊ីប)
គ. ពួកអាមេរិកាំងប្រើឡានហ្ស៊ីបសម្រាប់ធ្វើអី? (ស្ពាននោះ)
ឃ. ពួកអាមេរិកាំងប្រើស្ពាននោះសម្រាប់ធ្វើអី? (គ្រាប់បែកផ្សែង)
ង. ពួកអាមេរិកាំងប្រើគ្រាប់បែកផ្សែងសម្រាប់ធ្វើអី? (កន្លែងនោះ)
ច. ពួកអាមេរិកាំងប្រើកន្លែងនោះសម្រាប់ធ្វើអី?

DRILL TWO: Transformation

MODEL: T: គេប្រើកប៉ាល់ហោះអីខ្លះនៅស្រុកយួន? (ទាហានអាមេរិកាំង)

S: ទាហានអាមេរិកាំងប្រើកប៉ាល់ហោះច្រើនមុខណាស់។

T: What airplanes do they use in South Viet Nam?

S: American soldiers use many kinds of airplane.

ក. ពួកវៀតកុងប្រើកាំភ្លើងអីខ្លះ? (ខ្មាំង)
ខ្មាំងប្រើកាំភ្លើងច្រើនមុខណាស់។
ខ. គេប្រើគ្រាប់បែកអីខ្លះក្នុងចំបាំង? (អាមេរិកាំង)
អាមេរិកាំងប្រើគ្រាប់បែកច្រើនមុខណាស់។

គ. គេលក់ឡានអីខ្លះ ? (ខ្ញុំ)
ខ្ញុំលក់ឡានច្រើនធុនណាស់ ។
ឃ. ទាហានមានស្បែកជើងអីខ្លះ ? (យើង)
យើងមានស្បែកជើងច្រើនធុនណាស់ ។
ង. លោកទទួលសំបុត្រអីខ្លះ ? (ខ្ញុំ)
ខ្ញុំទទួលសំបុត្រច្រើនធុនណាស់ ។
ច. ឡានលោកប្រើសាំងអីខ្លះ ? (ខ្ញុំ)
ខ្ញុំប្រើសាំងច្រើនធុនណាស់ ។

DRILL THREE: Transformation

MODEL: T: អាមេរិកាំងប្រើកប៉ាល់ហោះបេ-៥២ សម្រាប់ធ្វើអី ?
S: អាមេរិកាំងរំពឹងលើកប៉ាល់ហោះហ្នឹងហើយ ។
T: What do Americans use the planes (type) B-52 for?
S: Americans depend on those planes.

ក. ពួកយៀកកុងប្រើរូងដីសម្រាប់ធ្វើអី ?
យៀកកុងរំពឹងលើរូងដីហ្នឹងហើយ ។
ខ. លោកយកលុយនោះធ្វើអី ?
លោករំពឹងលើលុយហ្នឹងហើយ ។
គ. គេចង់បានឡាននេះធ្វើអី ?
គេរំពឹងលើឡាននេះហើយ ។
ឃ. លោកត្រូវការសំបុត្រខ្ញុំធ្វើអី ?
លោករំពឹងលើសំបុត្រហ្នឹងហើយ ។
ង. លោកសក្ដិការចង់ជួបខ្ញុំធ្វើអី ?
លោកសក្ដិការរំពឹងលើខ្ញុំហ្នឹងហើយ ។
ច. ខ្ញុំទិញឡាននោះធ្វើអី ?
ខ្ញុំរំពឹងលើឡានហ្នឹងហើយ ។

DRILL FOUR: Response

MODEL: T: គេប្រើកប៉ាល់ហោះប្រតិកម្មធុនតូចៗ ។ (កប៉ាល់ហោះបេ-៥២)
S: ក្រែងគេប្រើកប៉ាល់បេ-៥២ទេឬ ?
T: They use small jet bombers.
S: They probably use the B-52 (type) don't they?

ក. គាត់ជិះឡានឈ្នួលទៅញូវយ៉ក ។ (ឡានរបស់គាត់)
ក្រែងគាត់ជិះឡានរបស់គាត់ទៅញូវយ៉កទេឬ ?
ខ. លោកចង់ទៅផ្ទះថ្ងៃនេះ ។ (ថ្ងៃស្អែក)
ក្រែងលោកចង់ទៅផ្ទះថ្ងៃស្អែកទេឬ ?

គ. ចោរចូលមកដេកក្នុងផ្ទះខ្ញុំ។ (លួច)
ពុំគង់ចោរចូលមកលួចផ្ទះលោកទេឬ?
ឃ. លោកចង់មកជួបខ្ញុំ។ (ប្រពន្ធខ្ញុំ)
ពុំគង់លោកចង់មកជួបប្រពន្ធខ្ញុំទេឬ?
ង. លោកចង់ដើរលេងជាមួយខ្ញុំ។ (ពួកម៉ាកស្រីខ្ញុំ)
ពុំគង់លោកចង់ដើរលេងជាមួយពួកម៉ាកស្រីខ្ញុំទេឬ?
ច. ខ្ញុំត្រូវទៅរៀន។ (នៅផ្ទះ)
ពុំគង់លោកត្រូវនៅផ្ទះទេឬ?

DRILL FIVE: Transformation

MODEL: T: គេប្រើកប៉ាល់ហោះនេះសម្រាប់បាញ់កាំជ្រួច។
S: គេច្រើនប្រើកប៉ាល់ហោះនេះសម្រាប់បាញ់កាំជ្រួច។
T: They use these planes to fire rockets.
S: Mostly they use these planes to fire rockets.

ក. ខ្ញុំទៅលេងពួកម៉ាកស្រីខ្ញុំនៅចុងអាទិត្យ។
ខ្ញុំច្រើនទៅលេងពួកម៉ាកស្រីខ្ញុំនៅចុងអាទិត្យ។
ខ. ពួកវៀតកុងចូលមកភូមិនេះ។
ពួកវៀតកុងច្រើនចូលមកភូមិនេះ។
គ. អាមេរិកាំងដោះលែងពួកខ្មាំង។
អាមេរិកាំងច្រើនដោះលែងពួកខ្មាំង។
ឃ. ពួកវៀតកុងសម្លាប់អាមេរិកាំង។
ពួកវៀតកុងច្រើនសម្លាប់អាមេរិកាំង។
ង. វៀតកុងធ្វើចំបាំងតែយប់។
វៀតកុងច្រើនធ្វើចំបាំងតែយប់។
ច. អាមេរិកាំងប្រើកាំភ្លើងយន្ត។
អាមេរិកាំងច្រើនប្រើកាំភ្លើងយន្ត។

DRILL SIX: Substitution

MODEL: T: កប៉ាល់ហោះប្រតិកម្មមួយធ្លាក់ក្នុងសមុទ្រស្រុកចិន។ (គ្រាប់បែក)
S: គ្រាប់បែកមួយធ្លាក់ក្នុងសមុទ្រស្រុកចិន។
T: A jet bomber fell into the China Sea. (bomb)
S: A bomb fell into the China Sea.

ក. គ្រាប់បែកមួយធ្លាក់ក្នុងសមុទ្រស្រុកចិន។ (លើនាវាផ្ទុកកប៉ាល់ហោះ)
ខ. គ្រាប់បែកមួយធ្លាក់លើនាវាផ្ទុកកប៉ាល់ហោះ។ (ផ្ទុះ)
គ. គ្រាប់បែកមួយផ្ទុះលើនាវាផ្ទុកកប៉ាល់ហោះ។ (ក្នុងមន្ទីរចាត់ការ)

ឃ. គ្រាប់បែកមួយផ្ទុះក្នុងមន្ទីរចាត់ការ។ (ក្រៅ)
ង. គ្រាប់បែកមួយផ្ទុះក្រៅមន្ទីរចាត់ការ។ (ឡាន)
ច. ឡានមួយផ្ទុះក្រៅមន្ទីរចាត់ការ។

DRILL SEVEN: Transformation

MODEL: T: កប៉ាល់ហោះអាមេរិកាំងមួយធ្លាក់។ (សត្រូវបាញ់)
S: សត្រូវបាញ់ធ្លាក់កប៉ាល់ហោះអាមេរិកាំងមួយ។
T: One American airplane was downed. (the enemy shot)
S: The enemy shot down an American airplane.

ក. វៀតកុងដប់នាក់ស្លាប់។ (ខ្ញុំបាញ់)
ខ្ញុំបាញ់សម្លាប់វៀតកុងដប់នាក់។
ខ. កែវប្រាំបែក។ (ខ្ញុំធ្វើ)
ខ្ញុំធ្វើបែកកែវប្រាំ។
គ. ផ្ទះមួយឆេះ។ (ញុំងដុត)
ញុំងដុតផ្ទះមួយឆេះ។
ឃ. ទាហានប្រាំនាក់របួស។ (វៀតកុងបាញ់)
វៀតកុងបាញ់របួសទាហានប្រាំនាក់។
ង. សៀវភៅខ្ញុំបាត់។ (ប្អូនខ្ញុំធ្វើ)
ប្អូនខ្ញុំធ្វើបាត់សៀវភៅខ្ញុំ។
ច. កប៉ាល់ហោះមួយធ្លាក់។ (គេបាញ់)
គេបាញ់ធ្លាក់កប៉ាល់ហោះមួយ។

DRILL EIGHT: Transformation

MODEL: T: គេប្រើកប៉ាល់ហោះបេ-៥២ទម្លាក់គ្រាប់បែក។
S: មុនដំបូងគេត្រូវប្រើកប៉ាល់ហោះបេ-៥២ទម្លាក់គ្រាប់បែក។
T: They use the B-52 to drop bombs.
S: First of all, they have to use the B-52 to drop bombs.

ក. យើងរៀនបាញ់កាំភ្លើង។
មុនដំបូងយើងត្រូវរៀនបាញ់កាំភ្លើង។
ខ. លោកទៅជួបមេបញ្ជាការ។
មុនដំបូងលោកត្រូវទៅជួបមេបញ្ជាការ។
គ. អាមេរិកាំងដកកងទ័ពចេញពីស្រុកយួន។
មុនដំបូងអាមេរិកាំងត្រូវដកកងទ័ពចេញពីស្រុកយួន។
ឃ. យើងប្រើគ្រាប់បែកផ្សែង។
មុនដំបូងយើងត្រូវប្រើគ្រាប់បែកផ្សែង។

ង. គេដុតមន្ទីរចាត់ការ ។
មុនដំបូងគេត្រូវដុតមន្ទីរចាត់ការ ។
ច. យៀកកុងបញ្ចុះបញ្ចូលអ្នកស្រុក ។
មុនដំបូងយៀកកុងត្រូវបញ្ចុះបញ្ចូលអ្នកស្រុក ។

DRILL NINE: Transformation

MODEL: T: មុនដំបូងគេត្រូវទម្លាក់គ្រាប់បែក ។
S: ក្រែងមុនដំបូងគេមិនត្រូវទម្លាក់គ្រាប់បែកទេឬ?
T: First of all, they have to drop bombs.
S: First of all, don't they have to drop bombs, perhaps?

ក. មុនដំបូងយើងរៀនបាញ់កាំភ្លើង ។
ក្រែងមុនដំបូងយើងមិនរៀនបាញ់កាំភ្លើងទេឬ?
ខ. មុនដំបូងលោកទៅជួបលោកសក្តិប្រាំ ។
ក្រែងមុនដំបូងលោកមិនទៅជួបលោកសក្តិប្រាំទេឬ?
គ. មុនដំបូងអាមេរិកាំងត្រូវធ្វើជំបាំងនៅស្រុកប្អូន ។
ក្រែងមុនដំបូងអាមេរិកាំងមិនត្រូវធ្វើជំបាំងនៅស្រុកប្អូនទេឬ?
ឃ. មុនដំបូងគេប្រើគ្រាប់បែកផ្សែង ។
ក្រែងមុនដំបូងគេមិនប្រើគ្រាប់បែកផ្សែងទេឬ?
ង. មុនដំបូងគេដុតមន្ទីរចាត់ការ ។
ក្រែងមុនដំបូងគេមិនដុតមន្ទីរចាត់ការទេឬ?
ច. មុនដំបូងយើងត្រូវបញ្ចុះបញ្ចូលអ្នកស្រុក ។
ក្រែងមុនដំបូងយើងមិនត្រូវបញ្ចុះបញ្ចូលអ្នកស្រុកទេឬ?

DRILL TEN: Extension

MODEL: T: លោកត្រូវទៅជួបមេបញ្ជាការ ។ (លោកសក្តិបី)
S: ហើយក្រោយបង្អស់លោកត្រូវទៅជួបលោកសក្តិបី ។
T: You have to go see the commander. (the captain)
S: And finally you have to go see the captain.

ក. គេប្រើកប៉ាល់ហោះធុនបេ-៥២ ។ (អេលីកុបទ័រ)
ហើយក្រោយបង្អស់លោកប្រើ (កប៉ាល់ហោះ) អេលីកុបទ័រ ។
ខ. យើងត្រូវរៀននិយាយ ។ (សរសេរ)
ហើយក្រោយបង្អស់យើងត្រូវរៀនសរសេរ ។
គ. យៀកកុងដុតផ្ទះអ្នកស្រុក ។ (មន្ទីរចាត់ការ)
ហើយក្រោយបង្អស់យៀកកុងដុតមន្ទីរចាត់ការ ។

ឃ. រាជការត្រូវបញ្ចុះបញ្ចូលយៀកកុង ។ (អ្នកស្រុក)
ហើយក្រោយបង្អស់រាជការត្រូវបញ្ចុះបញ្ចូលអ្នកស្រុក ។
ង. លោកហ្វូនត្រូវទទួលបន្ទុក ។ (លោកស្មៀន)
ហើយក្រោយបង្អស់លោកស្មៀនទទួលបន្ទុក ។
ច. ពួកយៀកកុងត្រូវដកទ័ពថយ ។ (អាមេរិកាំង)
ហើយក្រោយបង្អស់អាមេរិកាំងត្រូវដកទ័ពថយ ។

DRILL ELEVEN: Substitution

MODEL: T: កងអនុសេនាធំខ្ញុំត្រូវការកាំភ្លើងយន្តធុនធ្ងន់ដប់ដើម ។ (កាំភ្លើងស្វ័យប្រវត្តិ)
S: កងអនុសេនាធំខ្ញុំត្រូវការកាំភ្លើងស្វ័យប្រវត្តិដប់ដើម ។
T: My company needs 10 heavy guns. (automatic guns)
S: My company needs 10 automatic guns.

ក. កងអនុសេនាធំខ្ញុំត្រូវការកាំភ្លើងស្វ័យប្រវត្តិដប់ដើម ។ (ម័រទេ)
ខ. កងអនុសេនាធំខ្ញុំត្រូវការម័រទេដប់ដើម ។ (កាំភ្លើងដែលមិនធាក់)
គ. កងអនុសេនាធំខ្ញុំត្រូវការកាំភ្លើងដែលមិនធាក់ដប់ដើម ។ (កាំភ្លើងយន្តធុនស្រាល)
ឃ. កងអនុសេនាធំខ្ញុំត្រូវការកាំភ្លើងយន្តធុនស្រាលដប់ដើម ។ (កាំភ្លើងស្វ័យប្រវត្តិធុនមធ្យម)
ង. កងអនុសេនាធំខ្ញុំត្រូវការកាំភ្លើងស្វ័យប្រវត្តិធុនមធ្យមដប់ដើម ។ (កាកាប៊ីន)
ច. កងអនុសេនាធំខ្ញុំត្រូវការកាកាប៊ីនដប់ដើម ។

DRILL TWELVE: Response

MODEL: T: លោកចូលចិត្តទាហានទេ? (មានច្បាប់ទម្លាប់ច្រើន)
S: ថ្វីបើទាហានមានច្បាប់ទម្លាប់ច្រើន ខ្ញុំនៅតែចូលចិត្តទាហានជានិច្ច ។
T: Do you like the military service? (has a lot of regulations)
S: Although the military service has a lot of regulations, I still like it.

ក. លោកចូលចិត្តឯកសណ្ឋានទាហានជើងគោកទេ? (អាក្រក់)
ថ្វីបើឯកសណ្ឋានទាហានជើងគោកអាក្រក់ ខ្ញុំនៅតែចូលចិត្តជានិច្ច ។
ខ. លោកចូលចិត្តអ្នកធ្វើបាយក្នុងបន្ទាយលោកទេ? (មិនចេះធ្វើបាយ)
ថ្វីបើអ្នកធ្វើបាយក្នុងបន្ទាយខ្ញុំមិនចេះធ្វើបាយ ខ្ញុំនៅតែចូលចិត្តជានិច្ច ។
គ. លោកចូលចិត្តប៉ូលីសទាហានក្នុងបន្ទាយលោកទេ? (កាចណាស់)
ថ្វីបើប៉ូលីសទាហានក្នុងបន្ទាយខ្ញុំកាចណាស់ ខ្ញុំនៅតែចូលចិត្តជានិច្ច ។
ឃ. លោកចូលចិត្តកាំភ្លើងធុនអិម-១៤ទេ? (ឆាប់គាំង)
ថ្វីបើកាំភ្លើងធុនអិម-១៤ឆាប់គាំង ខ្ញុំនៅតែចូលចិត្តជានិច្ច ។
ង. លោកចូលចិត្តហាត់ទាហានទេ? (ពិបាក)
ថ្វីបើហាត់ទាហានពិបាក ខ្ញុំនៅតែចូលចិត្តជានិច្ច ។
ច. លោកចូលចិត្តធ្វើអ្នកនាំសារទេ? (នឿយហត់ណាស់)
ថ្វីបើធ្វើអ្នកនាំសារនឿយហត់ណាស់ ខ្ញុំនៅតែចូលចិត្តជានិច្ច ។

DRILL THIRTEEN: Transformation

MODEL: T: យើងមិនអាចវាយយកភូមិនោះបានវិញទេ។ (ឈ្នះ)
S: ទាល់តែយើងវាយយកភូមិនោះបានវិញ ទើបយើងនឹងឈ្នះ។
T: We cannot retake that hamlet.
S: Unless we retake that hamlet, we won't win.

ក. កងទ័ពយើងគ្មានកាំភ្លើងទេ។ (ធ្វើចំបាំងកើត)
ទាល់តែកងទ័ពយើងមានកាំភ្លើង ទើបកងទ័ពយើងធ្វើចំបាំងកើត។

ខ. លោកមិនអាចសួរអ្នកស្រុកទេ។ (រកកន្លែងញុំងឃើញ)
ទាល់តែលោកសួរអ្នកស្រុក ទើបលោករកកន្លែងញុំងឃើញ។

គ. យើងមិនអាចបោះគ្រឿងអាវុធនេះចោលទេ។ (ហែលឆ្លងទន្លេកើត)
ទាល់តែយើងបោះគ្រឿងអាវុធនេះចោល ទើបយើងហែលឆ្លងទន្លេកើត។

ឃ. ខ្ញុំមិនយកកាំបិតនេះទៅជាមួយទេ។ (ឆ្ការផ្លូវបាន)
ទាល់តែយកកាំបិតនេះទៅជាមួយ ទើបលោកឆ្ការផ្លូវបាន។

ង. កងទ័ពយើងមិនបោះគ្រាប់បែកផ្សែងទៅក្នុងរូងនោះទេ។ (កងទ័ពព្រៃចេញ)
ទាល់តែកងទ័ពយើងបោះគ្រាប់បែកផ្សែងទៅក្នុងរូងនោះ ទើបកងទ័ពព្រៃចេញ។

DRILL FOURTEEN: Response

MODEL: T: លោកកំពុងធ្វើអី? (កប់គ្រាប់មីន)
S: ខ្ញុំកំពុងកប់គ្រាប់មីន។
T: What are you doing? (bury a mine)
S: I'm burying a mine.

ក. ពលរបស់កឹមកំពុងធ្វើអី? (ដាក់របងលួសបន្លា)
ពលរបស់កឹមកំពុងដាក់របងលួសបន្លា។

ខ. កូនទាហានលោកកំពុងធ្វើអី? (ដំឡើងកាំភ្លើងមរ័ចេ)
កូនទាហានខ្ញុំកំពុងដំឡើងកាំភ្លើងមរ័ចេ។

គ. លោកសុខកំពុងធ្វើអី? (និយាយទូរស័ព្ទទៅមេបញ្ជាការ)
លោកសុខកំពុងនិយាយទូរស័ព្ទទៅមេបញ្ជាការ។

ឃ. រាជការកំពុងធ្វើអី? (បញ្ជូនទ័ពទៅព្រំដែន)
រាជការកំពុងបញ្ជូនទ័ពទៅព្រំដែន។

ង. ញុំងកំពុងធ្វើអី? (ផ្តុំទ័ព)
ញុំងកំពុងផ្តុំទ័ព។

ច. លោកកំពុងធ្វើអី? (ដោះគ្រាប់មីន)
ខ្ញុំកំពុងដោះគ្រាប់មីន។

DRILL FIFTEEN: Substitution

MODEL: T: លោកមានយោបល់យ៉ាងម៉េចអំពីសង្គ្រាមនៅស្រុកយួន? (នយោបាយ)
S: លោកមានយោបល់យ៉ាងម៉េចអំពីនយោបាយនៅស្រុកយួន។

T: What is your opinion about the war in Viet Nam? (politics)

S: What is your opinion about the politics (or policy) in Viet Nam?

ក. លោកមានយោបល់យ៉ាងម៉េចអំពីនយោបាយនៅស្រុកយួន? (ស្រុកខ្មែរ)
ខ. លោកមានយោបល់យ៉ាងម៉េចអំពីនយោបាយនៅស្រុកខ្មែរ? (រដ្ឋប្រហារ)
គ. លោកមានយោបល់យ៉ាងម៉េចអំពីរដ្ឋប្រហារនៅស្រុកខ្មែរ? (រដ្ឋាភិបាល)
ឃ. លោកមានយោបល់យ៉ាងម៉េចអំពីរដ្ឋាភិបាលនៅស្រុកខ្មែរ? (ប្រមុខរដ្ឋចាស់)
ង. លោកមានយោបល់យ៉ាងម៉េចអំពីប្រមុខរដ្ឋចាស់នៅស្រុកខ្មែរ? (ការលុកលុយរបស់បារាំង)
ច. លោកមានយោបល់យ៉ាងម៉េចអំពីការលុកលុយរបស់បារាំងនៅស្រុកខ្មែរ?

## Reading Passage

### ការសួរឈ្លើយសង្គ្រាម

ធម្មតាការធ្វើសង្គ្រាមតែងតែមានមនុស្សស្លាប់ របួស ខូចខាតអីវ៉ាន់ មានផ្ទះសំណាក់ជាដើម ហើយជាពិសេសកងទ័ពយើងឬកងទ័ពសត្រូវតែងតែមានចាប់ទាហានសត្រូវឬទាហានយើងធ្វើជាឈ្លើយសង្គ្រាម។ យើងដឹងថានៅពេលកងទ័ពយើងចាប់ឈ្លើយសង្គ្រាមបាន យើងយកគេទៅឲ្យនៅជំរំមួយដើម្បីពន្យល់គេពីអ្វីដែលល្អនិងអ្វីដែលអាក្រក់។ នៅពេលណាឈ្លើយសង្គ្រាមនេះប្ដូរគំនិតគេ ហើយយល់តាមទាហានយើង តាមនយោបាយយើង យើងអាចដោះលែងគេឲ្យត្រឡប់ទៅផ្ទះគេវិញ តែជួនកាលឈ្លើយសង្គ្រាមនេះមិនចង់ត្រឡប់ទៅស្រុកគេឬផ្ទះគេទេ គឺគេចូលចិត្តរស់ជាមួយយើងវិញ។ យើងមិនដែលធ្វើបាបឈ្លើយសង្គ្រាមឲ្យខុសពីច្បាប់អន្តរជាតិសម្រាប់ឈ្លើយសង្គ្រាមទេ។ ហើយធម្មតាយើងក៏មានធ្វើបាបមនុស្សខ្លះដែរ តែមនុស្សនេះមិនមែនជាឈ្លើយសង្គ្រាមទេ គេជាអ្នកស្រុកធម្មតាដែលយើងសង្ស័យថាគេចូលដៃជាមួយនឹងពួកសត្រូវ។ យើងមិនមែនចង់ធ្វើបាបគេទេ តែយើងគ្រាន់តែចង់បានការសម្ងាត់របស់គេទេតើ។

ចំពោះទាហានយើងដែលជាឈ្លើយសង្គ្រាមរបស់ពួកសត្រូវយើងវិញ ក៏មិនដឹងថាតើគេធ្វើបាបទាហានយើងយ៉ាងណាទេ តែយ៉ាងណាក៏ដោយយើងក៏អាចស្មានបានថាទាហានយើងមិនបានទទួលនូវការព្យាបាលដូចយើងបានផ្ដល់ទៅទាហានគេទេ។ យើងដឹងតាមទាហានយើងខ្លះដែលបានលួចរត់ចេញពីគុករបស់សត្រូវ ថាសត្រូវបានធ្វើបាបទាហានយើងខ្លាំងដែលធ្វើឲ្យទាហានយើងស្លាប់ក៏មាន។ ជួនកាលសត្រូវមិនបានព្យាបាលទាហានយើងនៅពេលដែលគេឈឺខ្លាំង ហើយផ្ទុយទៅវិញ គេយកឱកាសនេះដើម្បីវាយធ្វើបាបអ្នកជំងឺនេះដើម្បីសួរចម្លើយទៀត។

## VOCABULARY

| | | |
|---|---|---|
| កប៉ាល់ហោះដឹក | kəpal hɔh phtuk | transport plane |
| កប៉ាល់ហោះប្រតិកម្ម | kəpal hɔh prɔteˀkam | jet bomber, jet |
| ... ក៏មាន | ...kɔɔ mian | it sometimes happens that... (R) |
| កាច | kaac | fierce |
| កាត់សេចក្ដី | kat sec kdɛy | to render a judgment, to decide a case (L) |
| កាំជ្រួច | kəcruoc | missile, rocket |
| ក្រោយបង្អស់ (ឬ ក្រោយបំផុត) | kraoy pə-ɔh [or kraoy pəmphot] | finally, last of all |
| កាំង | kéŋ | to stick |
| គ្រាប់បែកផ្សែង | krɔ́p baɛk phsaɛŋ | smoke grenade |
| គ្រឿងអាវុធ | krɨəŋ əvút | weapons |
| ចាត់ការ | cat kaa | to administer, to plan, to command |
| (ចុះ) ក្រែង | (coh) kraɛŋ | probably |
| ឆ្ការ | chkaa | to clear (forest) |
| ដឹក | dək | to transport |
| ដោះលែង | dɔh lɛɛŋ | to release |
| ថ្វីបើ | thɛy baə | although |
| ទូរស័ព្ទ | tuorəsap | telephone |
| ធុន | thun | type |
| ធ្លាក់ | thléˀ | to fall |
| នាវា | niavia | ship |
| នាវាផ្ទុកកប៉ាល់ហោះ | niavia phtuk kəpal hɔh | aircraft carrier |
| នឿយហត់ | nɨəy hɔt | tired, exhausted |
| បំភ្លេច | pəphlɨc | to forget (deliberately) (L) |
| ប្រមុខរដ្ឋ | pəmuk rót | chief of state |
| ផ្ទុក | phtuk | to load |
| ផ្សែង | phsaɛŋ | smoke |
| ព្យាបាល | pyiabaal | to care for (R) |
| មធ្យម | məthyum | medium, average |
| មន្ទីរចាត់ការ | mɔntii cat kaa | headquarters (building) |
| ម័រជេ | morcee | mortar (gun) |
| មុនដំបូង | mun dəbouŋ | first of all |
| របង | ləbɔɔŋ | fence |
| រោង | ruuŋ | factory, plant |
| អំពឹង (លើ) | əmpɨŋ (ləə) | to depend on |
| លទ្ធិនិយម | lattiˀ niyum | ideology (formal) (L) |

| | | |
|---|---|---|
| លួសបន្លា | luoh pəlaa | barbed wire |
| សង្គម | sɔŋkum | society (L) |
| សមុទ្រ | səmut | sea, ocean |
| ហោះ | hɔh | to fly |
| អន្តរជាតិ | ɔntəraʔciat | international (R) |
| អេលីកុបទ័រ | eeliikoptɛr | helicopter |
| អ្នកនាំសារ | néʔ nóm saa | messenger |



Stung Meanchey

PASSAGE E

# មនុស្សមានឫទ្ធានុភាពជាងសត្វ

អ្នកស្រែម្នាក់វាយធ្វើបាបក្របី ៗ ក៏ខំទ្រាំនឹងការវេទនា ៗ មានខ្លាមួយដើរមកជិតក្របី ហើយនិយាយថាបងក្របី! ហេតុអ្វីបានជាបងទ្រាំឲ្យគេវាយធ្វើបាបដូច្នេះ? ខ្ញុំឃើញបងធំជាងមនុស្សដែលវាយបងឯង ៗ ក្របីឆ្លើយ




ថាមនុស្សតូចមែនពិត ប៉ុន្តែគេមានប្រាជ្ញាជាងយើងជាសត្វ ៗ ខ្លាងឿងឆ្ងល់មិនស្គាល់ប្រាជ្ញានោះយ៉ាងដូចម្តេច ក៏សួរទៅមនុស្សថា បងមនុស្ស! ឯណាប្រាជ្ញាបងឯង? បង្ហាញខ្ញុំមើលផង ៗ មនុស្សឆ្លើយថា ប្រាជ្ញាអញទុកនៅឯផ្ទះ ៗ ខ្លាថាបងឯងទៅកេយកមក ៗ មនុស្សឆ្លើយថា បើអញទៅផ្ទះឯងនឹងចាំស៊ីក្របីអញហើយ -បើឯងចង់ឲ្យអញទៅយកប្រាជ្ញាឲ្យឯងមើលត្រូវឯងឲ្យអញចងឯងសិន ៗ

ខ្លាចង់មើលប្រាជ្ញាមនុស្ស ក៏ព្រមឲ្យមនុស្សធ្វើតាមចិត្ត លុះចងខ្លារួច ហើយមនុស្សក៏យកខ្លាទឹមនឹមនង្គ័ល ហើយប្រាប់ថា ហ្នឹងហើយមនុស្សខ្សោយ មានប្រាជ្ញាត្រួតលើកំលាំងសត្វបាន ឥឡូវនេះឯងឃើញហើយឬនៅ ? ហ្នឹងហើយប្រាជ្ញាមនុស្ស ។ ឯក្របីឃើញដូច្នោះ ក៏សើចទន់ខ្លួនប្រាណដួល ទង្គិចបុកមាត់នឹងដីបាក់ធ្មេញលើអស់ ហេតុនេះហើយ បានជាក្របីគ្មានធ្មេញលើដល់មកសព្វថ្ងៃនេះ ។

| | | |
|---|---|---|
| ឫទ្ធានុភាព | rɨthianu?phiap | physical power (literary) |
| ទ្រាំ | tróm | to bear, to put up with |
| ងឿងឆ្ងល់ | ŋɨəŋ chŋɔl | to wonder, to be puzzled |
| ងៀង | ŋɨəŋ | to black out mentally |
| ខាំ | kham | to bite |
| តាមចិត្ត | taam cət | according to (his) desire |
| នឹម | nɨm | yoke |
| នង្គ័ល | nɨŋkól | plow |
| ត្រួត | truot | to govern, to control, to supervise |
| សើចទន់ខ្លួន | saəc tún khluon | to laugh uncontrollably |
| ទន់ | tún | soft |
| ប្រាណ | praan | body (formal) |
| ទង្គិច | təkɨc | to hit, to knock |
| បុក | bok | to pound, to strike |
| សព្វថ្ងៃនេះ | sɔp ŋay nih | nowadays, at present |

## LESSON FIFTY-SIX

### DIALOGUE

| | | | |
|---|---|---|---|
| | | ចាត់ | to assign, to order |
| ១. | សំ | យើងជិតអស់ម្ហូបហើយ។ លោកចាត់អ្នកណាឲ្យទៅទិញម្ហូបម្ដងនេះ? | We're almost out of food. Whom did you assign to go buy food this time? |
| | | កាន់កាប់ | to be in charge of |
| ២. | ទុំ | អ្នកណាកាន់កាប់ខាងម្ហូបឥឡូវ? | Who's in charge of food now? |
| ៣ | សំ | លោកស័ក្តិពីរសម្បត្តិដដែល។ | It's the same one. Lt. Sambat. |
| | | មុនៗ | before |
| ៤. | ទុំ | មុនៗ គាត់ធ្លាប់ទៅទិញទេ? | Before, did he go to buy? |
| | | ញឹកញាប់ | often |
| ៥. | សំ | បាទ ធ្លាប់ តែមិនសូវញឹកញាប់ប៉ុន្មានទេ។ | Yes, he did, but not very often. |
| ៦. | ទុំ | ធម្មតាលោកបញ្ជូនអ្នកណាឲ្យទៅទិញ? | Whom did you usually send? |
| | | អ្នកកាន់លុយ | the cashier (the one in charge of money) |
| ៧. | សំ | ខ្ញុំឲ្យអ្នកកាន់លុយទៅ។ | I had the cashier go. |
| ៨. | ទុំ | គេលក់ឥវ៉ាន់យ៉ាងម៉េចឥឡូវនៅផ្សារ? | How are they selling things in the market? |
| | | រាយ | retail |
| | | ដុំ | wholesale |
| ៩. | សំ | លោកចង់ទិញរាយក៏បាន ដុំក៏បាន។ | If you want to buy at retail, it's OK; wholesale is OK also. |

DIALOGUE:

1. sam - yəəŋ cɨt ɔh məhoup həh. look cat né?naa aoy tɨw tiñ məhoup mə dɔɔŋ nih?
2. tom - né?naa kan kap khaaŋ məhoup ɛyləw?
3. sam - look sa? pii səbat tədaɛl
4. tom - mun mun kót thlóp tɨw tiñ eh?
5. sam - baat, thɛy mɨn thlóp, taɛ mɨn səw ñɨk ñóp pəmaan eh
6. tom - thómmədaa look pəcuun né?naa aoy tɨw tiñ?
7. sam - khñom aoy né? kan luy tɨw
8. tom - kee lú? ɛyvan yaaŋ mɛc ɛyləw nɨw phsaa?
9. sam - look cɔŋ tiñ riay kɔɔ baan, dom kɔɔ baan

## DIALOGUE

## NOTES

SENTENCE NO.

1. Note the use of causative ឲ្យ /aoy/ with ចាត់ /cat/ 'to assign.' ឲ្យ /aoy/ can occur either before or after the subject of the following clause. Thus sentence 1 can also be

    លោកចាត់ឲ្យអ្នកណាទៅទិញម្ហូបម្ដងនេះ?

    look cat aoy né?naa tɨw tiñ məhoup mədɔɔŋ nih?

    Whom did you assign to go buy food this time?

   But note that in the case of បញ្ជូន /pəcuun/ in sentence 6 the order must be បញ្ជូន /pəcuun/ + subject + ឲ្យ /aoy/ + verb phrase, as in this sentence.

## DRILLS

DRILL NO.

8. In this drill is introduced a new pattern that includes an indefinite. In this pattern the first clause of the sentence contains the indefinite, ណា /naa/ 'whichever,' e.g. អ្នកណា /né?naa/ 'whoever;' the second clause contains a parallel noun plus demonstrative, e.g. អ្នកហ្នឹង /né? nɨŋ/ 'that person.' Drill 8 provides examples with អ្នកណា /né?naa/ 'whoever;' some other examples are:

    យើងទៅកន្លែងណាក៏ឃើញគេនៅកន្លែងហ្នឹង។

    yəəŋ tɨw kəlaɛŋ naa kɔɔ khəəñ kee nɨw kəlaɛŋ nɨŋ

    Wherever we go we see them. (We go to any place; we see them at that place.)

    ថ្ងៃណាខ្ញុំបើកលុយថ្ងៃហ្នឹងខ្ញុំទៅញ៉ាំបាយហាង។

    ŋay naa khñom baək luy ŋay nɨŋ khñom tɨw ñam baay haaŋ

    Whichever day I get paid I go to eat out.

9. The word ទើប /təəp/ is used like បាន /baan/ 'not...until, not...unless,' e.g.

    លោកឲ្យលុយខ្ញុំទើបខ្ញុំទៅ។

    look aoy luy khñom təəp khñom tɨw

    I won't go until (unless) you give me the money.

## DRILLS

DRILL ONE: Response

MODEL: T: លោកចាត់អ្នកណាឲ្យទៅទិញម្ហូប?

S: ខ្ញុំចាត់លោកង៉ុយឲ្យទៅទិញម្ហូប។

T: Whom did you assign to go buy food?

S: I assigned Mr. Ngoy to go buy food. .

ក. លោកប្រើអ្នកណាឲ្យយាមបន្ទាយ? (កូនទាហាន)
ខ្ញុំប្រើកូនទាហានឲ្យទៅយាមបន្ទាយ។
ខ. លោកប្រើអ្នកណាឲ្យទៅសួរលោកគ្រូ? (នាងស៊ីមន)
ខ្ញុំប្រើនាងស៊ីមនឲ្យទៅសួរលោកគ្រូ។
គ. លោកតាំងអ្នកណាឲ្យទៅជួបប៉ូលិស? (លោកសក្កិពែរ)
ខ្ញុំតាំងលោកសក្កិពែរឲ្យទៅជួបប៉ូលិស។
ឃ. លោកបញ្ជាអ្នកណាឲ្យទៅចាប់ចោរ? (ប៉ូលិស)
ខ្ញុំបញ្ជាប៉ូលិសឲ្យទៅចាប់ចោរ។
ង. លោកដេញអ្នកណាឲ្យទៅដេក? (កូន)
ខ្ញុំដេញកូនឲ្យទៅដេក។
ច. លោកជួលអ្នកណាឲ្យមើលកូនលោក? (នាងចន្ទ)
ខ្ញុំជួលនាងចន្ទឲ្យមើលកូនខ្ញុំ។

DRILL TWO: Response

MODEL: T: លោកចាត់អ្នកណាឲ្យទៅទិញម្ហូប?
S: ស្រេចតែលើលោកទេ ឲ្យអ្នកណាទៅទិញក៏បានដែរ។
T: Whom will you assign to go buy food?
S: It's up to you; anybody can go.

ក. លោកប្រើអ្នកណាឲ្យយាមបន្ទាយ?
ស្រេចតែលើលោកទេ ឲ្យអ្នកណាយាមក៏បានដែរ។
ខ. លោកប្រាប់អ្នកណាឲ្យទៅសួរលោកគ្រូ?
ស្រេចតែលើលោកទេ ឲ្យអ្នកណាទៅសួរក៏បានដែរ។
គ. លោកតាំងអ្នកណាឲ្យទៅជួបប៉ូលិស?
ស្រេចតែលើលោកទេ ឲ្យអ្នកណាទៅជួបក៏បានដែរ។
ឃ. លោកបញ្ជាអ្នកណាឲ្យទៅចាប់ចោរ?
ស្រេចតែលើលោកទេ ឲ្យអ្នកណាទៅចាប់ក៏បានដែរ។
ង. លោកដេញអ្នកណាឲ្យចេញពីថ្នាក់?
ស្រេចតែលើលោកទេ ឲ្យអ្នកណាចេញក៏បានដែរ។
ច. លោកជួលអ្នកណាឲ្យមើលកូនលោក?
ស្រេចតែលើលោកទេ ឲ្យអ្នកណាមើលក៏បានដែរ។

DRILL THREE: Response

MODEL: T: អ្នកណាកាន់កាប់ខាងម្ហូប? (លោកកុយ - ទិញ)
S: លោកកុយកាន់កាប់ខាងទិញម្ហូប។
T: Who is in charge of food?
S: Mr. Koy is in charge of buying food.

ក. អ្នកណាកាន់កាប់ខាងត្រាប់? (លោកសក្តិបី - ផ្តល់)
លោកសក្តិបីកាន់កាប់ខាងផ្តល់ត្រាប់។
ខ. អ្នកណាកាន់កាប់ខាងឡាន? (ខ្ញុំ - ជួសជុល)
ខ្ញុំកាន់កាប់ខាងជួសជុលឡាន។
គ. អ្នកណាកាន់កាប់ខាងសម្ភារៈ? (លោកសក្តិពីរប៉ែត - ចែក)
លោកសក្តិប៉ែតកាន់កាប់ខាងចែកសម្ភារៈ។
ឃ. អ្នកណាកាន់កាប់ខាងដំណឹង? (សុខ - ទទួល)
សុខកាន់កាប់ខាងទទួលដំណឹង។
ង. អ្នកណាកាន់កាប់ខាងភាសាខ្មែរ? (លោកសៅ - បង្រៀន)
លោកសៅកាន់កាប់ខាងបង្រៀនភាសាខ្មែរ។
ច. អ្នកណាកាន់កាប់ខាងសំបុត្រ? (កញ្ញាមសិកាន - ផ្ញើ)
កញ្ញាមសិកានកាន់កាប់ខាងផ្ញើសំបុត្រ។

DRILL FOUR: Transformation

MODEL: T: ម្តងនេះខ្ញុំទៅទិញម្ហូប។ (លោកទៅជាមួយខ្ញុំ)
S: ម្តងនេះខ្ញុំទៅទិញម្ហូបលុះត្រាតែលោកទៅជាមួយខ្ញុំ។
T: This time I'll go to buy food.
S: This time I won't go to buy food unless you go with me. (This time I'll go to buy food only if you go with me.)

ក. ខ្ញុំទៅលេងលោកយប់នេះ។ (ខ្ញុំគ្មានការ)
ខ្ញុំទៅលេងលោកយប់នេះលុះត្រាតែខ្ញុំគ្មានការ។
ខ. គេលក់ដី។ (លោកទិញច្រើន)
គេលក់ដីលុះត្រាតែលោកទិញច្រើន។
គ. ខ្ញុំទៅជាមួយលោក។ (លោកចេញលុយ)
ខ្ញុំទៅជាមួយលោកលុះត្រាតែលោកចេញលុយ។
ឃ. យើងអាចរៀនភាសាខ្មែរ។ (លោកឈប់និយាយអង់គ្លេសក្នុងថ្នាក់)
យើងអាចរៀនភាសាខ្មែរលុះត្រាតែលោកឈប់និយាយអង់គ្លេសក្នុងថ្នាក់។
ង. កូនលោកចេញពីផ្ទះ។ (លោកឱ្យវាចេញ)
កូនលោកចេញពីផ្ទះលុះត្រាតែលោកឱ្យវាចេញ។
ច. កូនសិស្សញ៉ាំបារី។ (លោកបណ្តោយឱ្យវាញ៉ាំ)
កូនសិស្សញ៉ាំបារីលុះត្រាតែលោកបណ្តោយឱ្យវាញ៉ាំ។

DRILL FIVE: Response

MODEL: T: លោកមើលសៀវភៅអី?
S: ខ្ញុំមើលសៀវភៅដដែល។
T: What book did you read?
S: I read the same book.

ក. លោករៀនសាលាណា? ខ្ញុំរៀនសាលាដដែល។
ខ. លោកទៅផ្សារណា? ខ្ញុំទៅផ្សារដដែល។
គ. លោកទៅបង្រៀនថ្នាក់ណា? ខ្ញុំទៅបង្រៀនថ្នាក់ដដែល។
ឃ. ខ្ញុំទៅអង្គុយកន្លែងណា? លោកទៅអង្គុយកន្លែងដដែល។
ង. លោកចង់ញ៉ាំស្រាអ៊ីម្តងនេះ? ខ្ញុំចង់ញ៉ាំស្រាដដែល ម្តងនេះ។
ច. លោកត្រឡប់មកវិញតាមផ្លូវណា? ខ្ញុំត្រឡប់មកវិញតាមផ្លូវដដែល។

DRILL SIX: Response

MODEL: T: លោកកំពុងមើលសៀវភៅដដែល?
S: ទេ ខ្ញុំមើលសៀវភៅដូចគ្នា។
T: Are you reading the same book?
S: No, I'm reading a similar book.

ក. លោកញ៉ាំស្រាវិស្គីដដែល? ទេ ខ្ញុំញ៉ាំស្រាវិស្គីដូចគ្នា។
ខ. លោកប្រើឡានដដែល? ទេ ខ្ញុំប្រើឡានដូចគ្នា។
គ. លោកយករបស់ដដែលមកវិញ? ទេ ខ្ញុំយករបស់ដូចគ្នាមកវិញ។
ឃ. គេឱ្យអាវដដែលមកលោកវិញ? ទេ គេឱ្យអាវដូចគ្នាមកខ្ញុំវិញ។
ង. លោកសរសេររឿងដដែល? ទេ ខ្ញុំសរសេររឿងដូចគ្នា។
ច. លោកធ្វើម្ហូបដដែល? ទេ ខ្ញុំធ្វើម្ហូបដូចគ្នា។

DRILL SEVEN: Response

MODEL: T: មុនៗគាត់ធ្លាប់ទៅទិញទេ? (ញឹក)
S: គាត់ធ្លាប់ទៅទិញតែមិនសូវញឹកប៉ុន្មានទេ។
T: Before did he go to buy (it)?
S: He used to, but not very often.

ក. មុនៗលោកធ្លាប់ញ៉ាំស្រានេះទេ? (ច្រើន)
ខ្ញុំធ្លាប់ញ៉ាំតែមិនសូវច្រើនប៉ុន្មានទេ។
ខ. មុនៗកញ្ញាធ្លាប់ធ្វើបាយទេ? (ឆ្ងាញ់)
ខ្ញុំធ្លាប់ធ្វើបាយតែមិនសូវឆ្ងាញ់ប៉ុន្មានទេ។
គ. មុនៗលោកធ្លាប់ឮគាត់និយាយទេ? (ប្រាកដ)
ខ្ញុំធ្លាប់ឮគាត់និយាយតែមិនសូវប្រាកដប៉ុន្មានទេ។
ឃ. មុនៗលោកធ្លាប់ជួសជុលឡានទេ? (ល្អ)
ខ្ញុំធ្លាប់ជួសជុលឡានតែមិនសូវល្អប៉ុន្មានទេ។
ង. មុនៗលោកធ្លាប់បាញ់កាំភ្លើងធុនអឹម-១៦ទេ? (ត្រង់)
ខ្ញុំធ្លាប់បាញ់កាំភ្លើងធុនអឹម-១៦តែមិនសូវត្រង់ប៉ុន្មានទេ។
ច. មុនៗលោកធ្លាប់ដើរលេងយប់ទេ? (ញឹកញាប់)
ខ្ញុំធ្លាប់ដើរលេងយប់តែមិនសូវញឹកញាប់ប៉ុន្មានទេ។

DRILL EIGHT: Response

MODEL: T: ធម្មតាលោកបញ្ជូនអ្នកណាឱ្យទៅទិញ?
S: ធម្មតាអ្នកណាធ្លាប់ទិញ អ្នកហ្នឹងទៅទិញ។
T: Whom do you usually send to buy?
S: Whoever usually does the buying goes.

ក. ធម្មតាលោកប្រើអ្នកណាធ្វើ?
ធម្មតាអ្នកណាធ្លាប់ធ្វើ អ្នកហ្នឹងធ្វើ។
ខ. ធម្មតាលោកឱ្យអ្នកណាទៅបង្រៀន?
ធម្មតាអ្នកណាធ្លាប់បង្រៀន អ្នកហ្នឹងទៅបង្រៀន។
គ. ធម្មតាលោកបញ្ជាអ្នកណាឱ្យទៅចាប់ចោរ?
ធម្មតាអ្នកណាធ្លាប់ចាប់ចោរ អ្នកហ្នឹងទៅចាប់។
ឃ. ធម្មតាលោកពឹងអ្នកណាធ្វើឱ្យលោក?
ធម្មតាអ្នកណាធ្លាប់ធ្វើ អ្នកហ្នឹងធ្វើឱ្យខ្ញុំ។
ង. ធម្មតាលោកជួលអ្នកណាទៅចាំផ្ទះលោក?
ធម្មតាអ្នកណាធ្លាប់ចាំ អ្នកហ្នឹងទៅចាំផ្ទះខ្ញុំ។
ច. ធម្មតាលោកបញ្ជូនអ្នកណាទៅជួបលោកសក្ដិបី?
ធម្មតាអ្នកណាធ្លាប់ជួប អ្នកហ្នឹងទៅជួបលោកសក្ដិបី។

DRILL NINE: Transformation

MODEL: T: លោកឱ្យលុយខ្ញុំ។ (ទៅ)
S: លុះត្រាតែលោកឱ្យលុយខ្ញុំ ទើបខ្ញុំទៅ។
T: (You) give me the money. (go)
S: Unless you give me the money, I won't go. (I will go only on the condition that you give me the money.)

ក. លោកពន្យល់ខ្ញុំ។ (រៀន)
លុះត្រាតែលោកពន្យល់ខ្ញុំ ទើបខ្ញុំរៀន។
ខ. លោកចេញលុយឱ្យខ្ញុំ។ (ទៅជាមួយ)
លុះត្រាតែលោកចេញលុយឱ្យខ្ញុំ ទើបខ្ញុំទៅជាមួយ។
គ. ខ្ញុំពឹងលោក។ (ធ្វើ)
លុះត្រាតែខ្ញុំពឹងលោក ទើបលោកធ្វើ។
ឃ. គេនិយាយមកយើង។ (ឆ្លើយ)
លុះត្រាតែគេនិយាយមកយើង ទើបយើងឆ្លើយ។
ង. លោកប្រាប់ខ្ញុំ។ (ធ្វើកើត)
លុះត្រាតែលោកប្រាប់ខ្ញុំ ទើបខ្ញុំធ្វើកើត។
ច. ប្រពន្ធខ្ញុំធ្វើបាយឱ្យខ្ញុំ។ (ញ៉ាំ)
លុះត្រាតែប្រពន្ធខ្ញុំធ្វើបាយឱ្យខ្ញុំ ទើបខ្ញុំញ៉ាំ។

DRILL TEN: Substitution

MODEL: T: លោកទៅទិញក៏បាន ខ្ញុំទៅទិញក៏បាន។ (មើល)
S: លោកមើលក៏បាន ខ្ញុំមើលក៏បាន។
T: If you go to buy, it's all right; if I go, it's all right. (read)
S: If you read, it's all right; if I read, it's all right.

ក. លោកមើលក៏បាន ខ្ញុំមើលក៏បាន។ (និយាយ)
ខ. លោកនិយាយក៏បាន ខ្ញុំនិយាយក៏បាន។ (បង្រៀន)
គ. លោកបង្រៀនក៏បាន ខ្ញុំបង្រៀនក៏បាន។ (ទទួលបន្ទុក)
ឃ. លោកទទួលបន្ទុកក៏បាន ខ្ញុំទទួលបន្ទុកក៏បាន។ (ទៅសួរ)
ង. លោកទៅសួរក៏បាន ខ្ញុំទៅសួរក៏បាន។ (ចេញលុយ)
ច. លោកចេញលុយក៏បាន ខ្ញុំចេញលុយក៏បាន។

DRILL ELEVEN: Response

MODEL: T: អ្នកណាកាន់កាប់យាមល្បាត? (ពលបាលកែម)
S: ពលបាលកែមកាន់កាប់ខាងយាមល្បាត។
T: Who is in charge of patrols? (Sergeant Kem)
S: Sergeant Kem is in charge of patrols.

ក. អ្នកណាកាន់កាប់ខាងផ្ទះបាយ? (សក្តិពីរម៉ាច)
សក្តិពីរម៉ាចកាន់កាប់ខាងផ្ទះបាយ។
ខ. អ្នកណាកាន់កាប់ខាងសម្ភារៈ? (លោកកុម)
លោកកុមកាន់កាប់ខាងសម្ភារៈ។
គ. អ្នកណាកាន់កាប់ខាងប្រាក់ខែ? (ពលបាលហ៊ួន)
ពលបាលហ៊ួនកាន់កាប់ខាងប្រាក់ខែ។
ឃ. អ្នកណាកាន់កាប់ខាងមន្ទីរពេទ្យ? (គ្រូពេទ្យ)
គ្រូពេទ្យកាន់កាប់ខាងមន្ទីរពេទ្យ។
ង. អ្នកណាកាន់កាប់ខាងរ៉ាដ្យោនិងទូរស័ព្ទ? (កាប៉ូរ៉ាល់សម)
កាប៉ូរ៉ាល់សមកាន់កាប់ខាងរ៉ាដ្យោនិងទូរស័ព្ទ។
ច. អ្នកណាកាន់កាប់ខាងសន្តិសុខទូទៅ? (លោកសក្តិបួន)
លោកសក្តិបួនកាន់កាប់ខាងសន្តិសុខទូទៅ។

DRILL TWELVE: Substitution

MODEL: T: ថ្ងៃនេះមានអ្នករត់ភៀសខ្លួនប៉ុន្មាននាក់? (ចោរ)
S: ថ្ងៃនេះមានចោរប៉ុន្មាននាក់?
T: How many refugees are there today? (thieves)
S: How many thieves are there today?

ក. ថ្ងៃនេះមានចោរប៉ុន្មាននាក់ ? (ចាប់)
ខ. ថ្ងៃនេះចាប់ចោរប៉ុន្មាននាក់ ? (ឈ្លើយសង្គ្រាម)
គ. ថ្ងៃនេះចាប់ឈ្លើយសង្គ្រាមប៉ុន្មាននាក់ ? (សម្លាប់)
ឃ. ថ្ងៃនេះសម្លាប់ឈ្លើយសង្គ្រាមប៉ុន្មាននាក់ ? (ខ្មាំង)
ង. ថ្ងៃនេះសម្លាប់ខ្មាំងប៉ុន្មាននាក់ ? (មាន)
ច. ថ្ងៃនេះមានខ្មាំងប៉ុន្មាននាក់ ? (អ្នករបួស)
ឆ. ថ្ងៃនេះមានអ្នករបួសប៉ុន្មាននាក់ ?

DRILL THIRTEEN: Choice

MODEL: T: ... ជាមេបញ្ជាការក្នុងកងអនុសេនាធំ ។ (សក្តិបី , ពលបាលឯក)
S: សក្តិបីជាមេបញ្ជាការក្នុងកងអនុសេនាធំ ។
T: A ...... is the commander of a company. (captain, sergeant)
S: A captain is the commander of a company.

ក. គេប្រើ ... ដើម្បីដឹកអ្នករបួសទៅពេទ្យ ។ (កប៉ាល់ហោះប្រតិកម្ម , អេលីកុបទ័រ)
គេប្រើអេលីកុបទ័រដើម្បីដឹកអ្នករបួសទៅពេទ្យ ។
ខ. ខ្ញុំនិយាយជាមួយលោកមេបញ្ជាការតាម ... ។ (កាត់សក , ទូរស័ព្ទ)
ខ្ញុំនិយាយជាមួយលោកមេបញ្ជាការតាមទូរស័ព្ទ ។
គ. ពលបាលបញ្ជា ....... ឲ្យរើសសំរាមក្នុងបន្ទាយ ។ (នាយទាហាន , កូនទាហាន)
ពលបាលបញ្ជាកូនទាហានឲ្យរើសសំរាមក្នុងបន្ទាយ ។
ឃ. ក្រោយការពិនិត្យទត ពលបាលស្រែកថា ... ។ (តម្រៀបជួរ , បំបែកជួរ)
ក្រោយការពិនិត្យទត ពលបាលស្រែកថាបំបែកជួរ ។
ង. កូនទាហានត្រូវគំនាប់ ... ។ (ពលបាល , នាយទាហាន)
កូនទាហានត្រូវគំនាប់នាយទាហាន ។
ច. ... ចំពាក់សក្តិឲ្យលោកសក្តិពីរ ។ (ពលបាល , ឧត្តមសេនីយត្រី)
ឧត្តមសេនីយត្រីចំពាក់សក្តិឲ្យលោកសក្តិពីរ ។

DRILL FOURTEEN: Transformation

MODEL: T: កន្លែងនេះសម្រាប់អ្នកជំងឺ ។ (អ្នករបួសធ្ងន់)
S: កន្លែងនេះសម្រាប់អ្នកជំងឺជាពិសេសអ្នករបួសធ្ងន់ ។
T: This place is for patients. (the seriously wounded ones)
S: This place is for patients, especially the seriously wounded ones.

ក. អ្នកស្រុកមិនគួររងទុក្ខក្នុងសង្គ្រាមនេះទេ ។ (ក្មេងៗ)
អ្នកស្រុកមិនគួររងទុក្ខក្នុងសង្គ្រាមនេះទេជាពិសេសក្មេងៗ ។
ខ. យើងត្រូវជួយអ្នកស្រុក ។ (នៅពេលមានសង្គ្រាម)
យើងត្រូវជួយអ្នកស្រុកជាពិសេសនៅពេលមានសង្គ្រាម ។

គ. លោកត្រូវការពារភូមិទាំងអស់។ (ភូមិលោក)
លោកត្រូវការពារភូមិទាំងអស់ជាពិសេសភូមិលោក។
ឃ. កុំបាញ់ច្រើនពេក។ (យើងជិតអស់គ្រាប់ហើយ)
កុំបាញ់ច្រើនពេកជាពិសេសយើងជិតអស់គ្រាប់ហើយ។
ង. លោកត្រូវប្រើថ្នាំប្រយ័ត្នបន្តិច។ (បើលោកមិនស្គាល់ថ្នាំ)
លោកត្រូវប្រើថ្នាំប្រយ័ត្នបន្តិចជាពិសេសបើលោកមិនស្គាល់ថ្នាំ។
ច. លោកមិនត្រូវទុកចិត្តអ្នកស្រុកទេ។ (មនុស្សចម្លែក)
លោកមិនត្រូវទុកចិត្តអ្នកស្រុកទេជាពិសេសមនុស្សចម្លែក។

## Reading Passage

### ឪពុកនិងម្ដាយខ្ញុំ

ឪពុកខ្ញុំក៏ដូចម្ដាយខ្ញុំដែរ គាត់ធ្វើការច្រើនណាស់។

នៅរដូវវស្សា តាំងពីព្រឹកដល់ថ្ងៃត្រង់ រួចពីពេលគាត់ពិសាបាយថ្ងៃត្រង់ហើយដល់ល្ងាច ថ្ងៃជិតលិច ឪពុកខ្ញុំនៅតែក្នុងស្រែទេ។ គាត់ធ្វើដីសម្រាប់ដាំស្រូវ គាត់កាប់ដីបង្ហូរទឹកចូលឬចេញពីស្រែ។ គាត់ដើរពីស្រែមួយទៅស្រែមួយដើម្បីនឹងមើលក្រែងមានសត្វអ្វីមកបំផ្លាញស្រូវគាត់។ ឪពុកខ្ញុំគាត់ប្រយ័ត្នណាស់ គាត់មិនបណ្ដោយការអ្វីដែលគាត់ធ្វើកើតខ្លួនគាត់ទៅជាខូចខាតទេ។ ឯម្ដាយខ្ញុំវិញ នៅពេលឪពុកខ្ញុំកំពុងរវល់ពីការរបស់គាត់នៅស្រែ គាត់ក៏រវល់ណាស់ដែរ។ បើគាត់នៅផ្ទះ គាត់រៀបចំផ្ទះ ជួសជុលខោអាវ មើលក្រែងខ្វះឬមានត្រូវការអ្វីនៅផ្ទះនិងធ្វើម្ហូបអាហារ។ បើគាត់គ្មានការរវល់ពេកនៅផ្ទះ គាត់ទៅស្រែដើម្បីជួយឪពុកខ្ញុំដែរ។ គាត់ធ្វើការធ្ងន់ដូចឪពុកខ្ញុំមិនសូវបានទេ គាត់ធ្វើបានតែការដែលមិនសូវត្រូវការកម្លាំងច្រើនពេក។

ឯនៅរដូវប្រាំងវិញ នៅស្រែមិនសូវមានការធ្វើច្រើនទេ តែឪពុកខ្ញុំនៅតែរវល់ណាស់ដែរ។ បើគាត់នៅផ្ទះ គាត់ធ្វើនេះធ្វើនោះ ដូចជាជួសជុលផ្ទះ កាប់ឧសសម្រាប់ចំអិនម្ហូបអាហារនិងធ្វើការធ្ងន់ៗឯទៀតដែលម្ដាយខ្ញុំធ្វើមិនកើត។ ហើយបើគាត់មិននៅផ្ទះទេ ក្រៅពីទៅធ្វើការនៅស្រែឬចំការ គាត់ទៅព្រៃដើម្បីកាប់ឈើយកមកប្រើ ឬទៅចាំងរកត្រីដើម្បីយកមកធ្វើម្ហូប។ ឯម្ដាយខ្ញុំវិញ នៅពេលឪពុកខ្ញុំមិននៅផ្ទះ ពិតមែនតែគាត់មិនទៅណាឆ្ងាយពីផ្ទះ គាត់នៅតែរវល់ណាស់ដែរ។ ការអ្វីៗដែលគាត់អាចធ្វើបាន គាត់ធ្វើស្ទើរតែទាំងអស់ ដូចជាដេរខោអាវសម្រាប់កូនគាត់និងឪពុកខ្ញុំ និងសំអាតផ្ទះជាដើម។

ក្រៅពីរឿងចែកមុខងារគ្នាដើម្បីធ្វើការដូចខាងលើនោះ មានរឿងខ្លះទៀតដែលនៅក្នុងនោះខ្ញុំបានឃើញឪពុកនិងម្ដាយខ្ញុំមានមុខងារដូចជាផ្សេងពីគ្នា។ រឿងទាំងនោះគឺដូចជារឿងកាន់លុយ រឿងសម្រេចទិញអ្វីមួយ។ល។

ចំពោះរឿងលុយ ឪពុកគាត់មិនដឹងអ្វីទេ បើគ្មានឬមានស្រេចតែលើម្ដាយខ្ញុំ គឺម្ដាយខ្ញុំគាត់កាន់លុយទាំងអស់។ ឯម្ដាយខ្ញុំទៀត មិនគ្រាន់តែកាន់

លុយទាំងអស់នោះទេ   គាត់ចាយលុយនោះ ដើម្បីទិញរបស់អ្វីៗ ដោយមិនបាច់ប្រាប់ឪពុកខ្ញុំទៀតផង។ បើឪពុកខ្ញុំចង់ទិញអ្វីបន្តិចបន្តួច គាត់ត្រូវសុំម្ដាយខ្ញុំ
ចំពោះរឿងសម្រេចការអ្វីវិញ   បើការនោះជាការសំខាន់ដូចជារឿងទិញដី ផ្ទះនិងគោជាដើម   ឪពុកខ្ញុំជាអ្នកសម្រេច។

តាមពិត   រឿងរបស់ឪពុកនិងម្ដាយខ្ញុំនេះជារឿងទូទៅរបស់អ្នកស្រែចំការដែលជាប្ដីប្រពន្ធ។

## VOCABULARY

| | | |
|---|---|---|
| កាន់ | kan | to hold (in the hand), to grasp |
| កាន់កាប់ | kan kap | to take care of; to be in charge |
| គំនាប់ | kənóp | to salute |
| ចាត់ | cat | to order, to appoint |
| ចែក | caɛk | to distribute, to divide |
| ចាំផ្ទះ | cam phtéh | take care of the house, keep house |
| ជួសជុល | cuoh cul | to repair |
| ញឹកញាប់ | ñik ñóp | often |
| ដដែល | tədaɛl | same |
| ដេរ | dee | to sew (R) |
| ដុំ | dom | lump, chunk; wholesale |
| តម្រៀបជួរ | təriep cuo | to form ranks |
| ថ្ងៃ | thŋay | sun (R) |
| ថ្ងៃត្រង់ | thŋay troŋ | noon (R) |
| ថ្ងៃលិច | thŋay lɨc | the sun sets (R) |
| ទើប | təəp | then; not...until |
| បណ្ដោយឱ្យ | pədaoy aoy | to let, to allow |
| បំបែកជួរ | pəbaɛk cuo | to break ranks |
| បំពាក់ | pəpéʔ | to put on, to cause to wear |
| បំពាក់សក្តិ | pəpéʔ saʔ | to award a promotion |
| ពិនិត្យ | pənit | to inspect |
| ភ្លើ | phləə | stupid (L) |
| រងទុក្ខ | róoŋ tuk | to suffer, to be victim to |
| រាយ | riay | messy, scattered; retail |
| រើស | rəəh | to pick up |
| លិច | lɨc | to sink, to set, to be inundated (R) |
| លោក | look | he (L) |
| លោកខ្ញុំ | look khñom | my boss (L) |
| លុះត្រា | luh traa taɛ | not...unless, only on the condition that |

| | | |
|---|---|---|
| ល្បាត | lbaat | to patrol, to guard |
| ល្មមៗ | ləmoom | trivial, small (R) |
| សម្ភារៈ | səphiaréʔ | supply |
| សំរាម | səmraam | garbage |
| ស្រេចតែលើ | srac tə ləə | it's up to |
| អ្នកកាន់លុយ | néʔ kan luy | cashier |
| ឧស | oh | firewood (R) |



Sidewalk cake vendor in Phnom Penh

## LESSON FIFTY-SEVEN

### DIALOGUE

| | | | |
|---|---|---|---|
| | | ប្រុងប្រៀប | to be ready |
| | | បុណ្យ | ceremony |
| | | ធ្វើបុណ្យ | to hold a ceremony, to celebrate a holiday |
| | | បំពាក់ | to decorate, put on a medal |
| | | បំពាក់សក្តិ | award a promotion |
| ១. | ភូម | គេប្រុងប្រៀបធ្វើបុណ្យបំពាក់សក្តិស្អែកនេះ។ | They are ready for the award ceremony tomorrow. |
| | | ពលបាល | sergeant |
| ២. | សុខ | អញ្ចឹងបានជាខ្ញុំឃើញពលបាលយុងបង្ហាត់កូនទាហានឲ្យរៀនដើរ។ | That was the reason I saw Sergeant Yung training his men to march. |
| | | ជាផ្លូវការ | officially |
| | | ដាច់ខែ | the end of the month |
| ៣. | ភូម | ជាផ្លូវការគេត្រូវចាំដល់ដាច់ខែនេះ។ | Officially, they must wait until the end of this month. |
| ៤. | សុខ | ហេតុអ្វីបានជាគេធ្វើស្អែក? | Why are they doing it tomorrow? |
| ៥. | ភូម | ព្រោះលោកឧត្តមសេនីយ៍ត្រូវធ្វើដំណើរទៅស្រុកបារាំង ហើយគាត់ជាអ្នកបំពាក់សក្តិឲ្យគេ។ | Because the major general must take a trip to France, and he is the one who presents the awards. |
| | | មេដាយ | medal |
| ៦. | សុខ | មានអ្នកណាបានមេដាយទេ? ហើយលោក? | Is there anybody who is getting a medal? What about you? |
| | | នៅឡើយ | not yet at all |
| ៧. | ភូម | ទេ ខ្ញុំមិនទាន់បាននៅឡើយទេ។ | I haven't gotten one yet. |
| ៨. | សុខ | ចុះមេដាយអ៊ីដែលលោកពាក់នេះ? | And what kind of medal is that that you are wearing? |
| | | កិរិយាមារយាទ | conduct |
| ៩. | ភូម | អូ! អាហ្នឹងសម្រាប់កិរិយាមារយាទទេតើ។ ទាហានទាំងអស់ត្រូវបានម្នាក់មួយ។ | Oh! That one is for good conduct. Every soldier gets one. |
| | | បញ្ជាក់ឲ្យឃើញថា | to show (that) |
| ១០. | សុខ | អញ្ចឹងនេះបញ្ជាក់ឲ្យឃើញថាលោកជាទាហានល្អ។ | So this shows that you are a good soldier? |
| | | ទឹកចិត្ត | morale |
| ១១. | ភូម | ទេ គ្រាន់តែលើកទឹកចិត្តកូនទាហានទេ។ | No, it's just to encourage the soldier. |

DIALOGUE:

1. tom - kee proŋ priep thəə bon pəmpé? sa? s?aɛk nih
2. sok - əñcəŋ baan cia khñom khəəñ púl ləbaal yuŋ pəhat koun təhian aoy rien daə
3. tom - taam phləw kaa kee trəw cam dɔl dac khaɛ nih
4. sok - haɛt ɛy baan cia kee thəə s?aɛk?
5. tom - prúh look phkaay pii trəw thəə tənaə tɨw srok pəraŋ haəy kót cia né? pəmpé? sa? aoy kee
6. sok - mian né?naa baan meeday tee? haəy look?
7. tom - tee, khñom mɨn tón baan nɨw laəy tee
8. sok - coh meeday ɛy daɛl look pé? nih?
9. tom - oh! aa nɨŋ səmrap kənɨt məyiat tee taə. təhian téŋ ɔh trəw baan məné? muoy
10. sok - əñcəŋ nih pəcé? aoy khəəñ thaa look cia təhian l?ɔɔ?
11. tom - tee, krón tə ləək tɨk cət koun təhian tee

DIALOGUE

NOTES

SENTENCE NO.

3. The beginning of a month is referred to as ដើមខែ /daəm khaɛ/, and the one or two days at the end of the month are ដាច់ខែ /dac khaɛ/. The week or so at the end of the month is known as ចុងខែ /coŋ khaɛ/.

7. ឡើយ/laəy/ is a clause-final particle that is used following a negated verb. Its meaning is similar to that of សោះ /sɔh/ '(not)...at all,' except that ឡើយ/laəy/ ordinarily refers to future time and សោះ/sɔh/ generally does not, except when it occurs in combination with ឡើយ /laəy/, as in

ខ្ញុំមិនធ្វើអញ្ចឹងទៀតសោះឡើយ។
khñom mɨn thəə əñcəŋ tiət sɔh laəy
I'll never do that again.

9. ទេតើ /tee taə/ is a more emphatic form of the particle ទេ /tee/ that indicates some sort of contradiction of what has come before. It is not used to indicate simple negation or interrogation as ទេ /tee/ is.

9. Note that ម្នាក់មួយ /məné? muoy/ means 'each one (gets) one.' This is the same pattern as មួយខែមួយដង /məkhaɛ mə dɔɔŋ/ 'once a month.' Other numbers than 'one' can be used, e.g.,

កាំភ្លើង, ទាហានត្រូវបានពីរនាក់មួយដើម។
kəphləəŋ, təhian trəw baan pii né? mə daəm
Every pair of soldiers is to get a gun.

## NOTES FOR READING PASSAGE

The word គ្រូ /kruu/ in its most general sense refers to a person with special knowledge. You have already learned គ្រូបង្រៀន /kruu pərien/ 'teacher' and គ្រូពេទ្យ /kruu pɛɛt/ 'physician.' In this passage the word គ្រូខ្មែរ /kruu khmaɛ/ refers to a practitioner of traditional rituals, which have been absorbed into the Cambodian variety of folk Buddhism.

Among these rituals is one in which people are blessed and sprinkled with water (ស្រោចទឹក /sraoc tɨk/) before going into a dangerous situation. Soldiers also provide themselves with a កសែងយន្ត /kəsaeŋ yɔn/, which is a scarf on which magic drawings are made and on which magic spells have been recited by the គ្រូ /kruu/. The soldiers wear their scarves into battle to protect themselves from harm.

## DRILLS

DRILL ONE: Transformation

MODEL: T: ទាហានកំពុងហាត់ដើរ។ (បុណ្យបំពាក់សក្តិ)

S: មុនបុណ្យបំពាក់សក្តិ ទាហានត្រូវប្រុងប្រៀបហាត់ដើរ។

T: The soldiers are practicing marching.

S: Before the decoration ceremony, the soldiers must get ready to practice marching.

ក. ខ្ញុំរៀបចំឥវ៉ាន់។ (ធ្វើដំណើរ)
មុនធ្វើដំណើរខ្ញុំត្រូវប្រុងប្រៀបរៀបចំឥវ៉ាន់។

ខ. យើងទិញសៀវភៅ។ (ចូលរៀន)
មុនចូលរៀនយើងត្រូវប្រុងប្រៀបទិញសៀវភៅ។

គ. ខ្ញុំទិញសំបុត្រកប៉ាល់ហោះ។ (ទៅស្រុកបារាំង)
មុនទៅស្រុកបារាំងខ្ញុំត្រូវប្រុងប្រៀបទិញសំបុត្រកប៉ាល់ហោះ។

ឃ. ទាហានរៀនបាញ់កាំភ្លើង។ (ច្បាំង)
មុនច្បាំងទាហានត្រូវប្រុងប្រៀបរៀនបាញ់កាំភ្លើង។

ង. យើងកំពុងញុំាបាយ។ (ដើរលេង)
មុនដើរលេងយើងត្រូវប្រុងប្រៀបញុំាបាយ។

ច. ខ្ញុំរកការធ្វើ។ (ចេញពីទាហាន)
មុនចេញពីទាហានខ្ញុំត្រូវប្រុងប្រៀបរកការធ្វើ។

DRILL TWO: Transformation

MODEL: T: ពលបាលត្រេងបង្ហាត់កូនទាហាន។
S: អញ្ចឹងបានជាខ្ញុំឃើញពលបាលត្រេងបង្ហាត់កូនទាហាន។
T: Sergeant Kreng is drilling his men.
S: That's the reason I saw Sergeant Kreng drilling his men.

ក. ខ្ញុំមកបង្រៀនពីម្សិលមិញ។
អញ្ចឹងបានជាខ្ញុំឃើញលោកមកបង្រៀនពីម្សិលមិញ។

ខ. ខ្ញុំបើកឡានមកធ្វើការ។
អញ្ចឹងបានជាខ្ញុំឃើញលោកបើកឡានមកធ្វើការ។

គ. គេដកទ័ពថយ។
អញ្ចឹងបានជាខ្ញុំឃើញគេដកទ័ពថយ។

ឃ. គេមកទទួលខ្ញុំ។
អញ្ចឹងបានខ្ញុំឃើញគេមកទទួលលោក។

ង. លោកផ្កាយពីរបំពាក់មេដាយឱ្យខ្ញុំ។
អញ្ចឹងបានជាខ្ញុំឃើញលោកផ្កាយពីរបំពាក់មេដាយឱ្យលោក។

ច. ប្រពន្ធខ្ញុំមកជាមួយ។
អញ្ចឹងបានជាខ្ញុំឃើញប្រពន្ធលោកមកជាមួយ។

DRILL THREE: Transformation

MODEL: T: លោកសុំច្បាប់មេបញ្ជាការ។
S: តាមផ្លូវការលោកត្រូវសុំច្បាប់មេបញ្ជាការ។
T: You'll ask for permission from the commander.
S: Officially, you must ask for permission from the commander.

ក. លោកត្រឡប់ទៅស្រុកខ្មែរវិញ។
តាមផ្លូវការលោកត្រូវត្រឡប់ទៅស្រុកខ្មែរវិញ។

ខ. គេបញ្ជូនលោកទៅស្រុកយួន។
តាមផ្លូវការគេត្រូវបញ្ជូនលោកទៅស្រុកយួន។

គ. លោកប្រធានាធិបតីបំពាក់សក្តិ។
តាមផ្លូវការលោកប្រធានាធិបតីបំពាក់សក្តិ។

ឃ. លោកបង្រៀនតែមួយម៉ោង។
តាមផ្លូវការលោកត្រូវបង្រៀនតែមួយម៉ោង។

ង. ខ្ញុំជួបមេបញ្ជាការ។
តាមផ្លូវការខ្ញុំត្រូវជួបមេបញ្ជាការ។

ច. លោកសក្តិពីរទទួលបន្ទុកក្នុងមន្ទីរចាត់ការនេះ។
តាមផ្លូវការលោកសក្តិពីរត្រូវទទួលបន្ទុកក្នុងមន្ទីរចាត់ការនេះ។

DRILL FOUR: Transformation

MODEL: T: តាមផ្លូវការលោកមិនត្រូវសុំច្បាប់មេបញ្ជាការទេ។
S: ក្រៅផ្លូវការលោកអាចសុំច្បាប់មេបញ្ជាការ។
T: Officially, you must not ask for permission from the commander.
S: Unofficially, you can ask for permission from the commander.

ក. តាមផ្លូវការលោកមិនត្រូវត្រឡប់ទៅស្រុកខ្មែរទេ។
ក្រៅផ្លូវការលោកអាចត្រឡប់ទៅស្រុកខ្មែរ។

ខ. តាមផ្លូវការគេមិនត្រូវបញ្ជូនលោកទៅស្រុកយួនទេ។
ក្រៅផ្លូវការគេអាចបញ្ជូនលោកទៅស្រុកយួន។

គ. តាមផ្លូវការលោកផ្កាយពីរមិនត្រូវបំពាក់ស័ក្តិទេ។
ក្រៅផ្លូវការលោកផ្កាយពីរអាចបំពាក់ស័ក្តិ។

ឃ. តាមផ្លូវការលោកមិនត្រូវជួបលោកមេបញ្ជាការទេ។
ក្រៅផ្លូវការលោកអាចជួបលោកមេបញ្ជាការ។

ង. តាមផ្លូវការលោកមិនត្រូវបង្រៀនមួយម៉ោងទេ។
ក្រៅផ្លូវការលោកអាចបង្រៀនមួយម៉ោង។

ច. តាមផ្លូវការលោកស័ក្តិពីរមិនត្រូវទទួលបន្ទុកក្នុងមន្ទីរចាត់ការនេះទេ។
ក្រៅផ្លូវការលោកស័ក្តិពីរអាចទទួលបន្ទុកក្នុងមន្ទីរចាត់ការនេះ។

DRILL FIVE: Response

MODEL: T: អង្កាលលោកត្រូវទទួលមេដាយលោក? (ដាច់ខែនេះ)
S: ខ្ញុំត្រូវទទួលមេដាយខ្ញុំដាច់ខែនេះ។
T: When will you receive your medal? (the end of this month)
S: I'm supposed to receive my medal at the end of this month.

ក. អង្កាលលោកចាប់បង្រៀននៅអង្គរ? (ដើមខែក្រោយ)
ខ្ញុំចាប់បង្រៀននៅអង្គរដើមខែក្រោយ។

ខ. អង្កាលលោកបើកប្រាក់ខែលោក? (រាល់ដាច់ខែ)
ខ្ញុំបើកប្រាក់ខែខ្ញុំរាល់ដាច់ខែ។

គ. អង្កាលលោកបានឡើងស័ក្តិ? (ដើមឆ្នាំក្រោយ)
ខ្ញុំបានឡើងស័ក្តិដើមឆ្នាំក្រោយ។

ឃ. អង្កាលសំបុត្រខ្ញុំទៅដល់ស្រុកខ្មែរ? (ដាច់ខែនេះ)
សំបុត្រលោកនឹងទៅដល់ស្រុកខ្មែរដាច់ខែនេះ។

ង. អង្កាលលោកឈប់ធ្វើការក្នុងមន្ទីរចាត់ការនោះ? (ដើមខែមិនា)
ខ្ញុំឈប់ធ្វើការក្នុងមន្ទីរចាត់ការនោះដើមខែមិនា។

ច. អង្កាលលោកត្រូវទៅស្រុកយួនម្តងទៀត? (ដាច់ខែក្រោយ)
ខ្ញុំត្រូវទៅស្រុកយួនម្តងទៀតដាច់ខែក្រោយ។

DRILL SIX: Response

MODEL: T: លោកបានទទួលមេដាយទេឆ្នាំនេះ?
S: ទេ ខ្ញុំមិនទាន់បានទទួលនៅឡើយទេ។
T: Had you received any medals this year?
S: No, I haven't received any yet.

ក. លោកញ៉ាំបាយហើយឬនៅ?
ទេ ខ្ញុំមិនទាន់ញ៉ាំបាយនៅឡើយទេ។

ខ. លោកបានឡើងសក្តិទេ?
ទេ ខ្ញុំទាន់បានឡើងសក្តិនៅឡើយទេ។

គ. លោកចូលផ្ទះបានទេ?
ទេ ខ្ញុំមិនទាន់ចូលបាននៅឡើយទេ។

ឃ. លោកធ្វើដំណើរនោះកើតទេ?
ទេ ខ្ញុំមិនទាន់ធ្វើកើតនៅឡើយទេ។

ង. លោករកសៀវភៅលោកឃើញទេ?
ទេ ខ្ញុំមិនទាន់រកឃើញនៅឡើយទេ។

ច. លោកសរសេរចប់ហើយឬនៅ?
ទេ ខ្ញុំមិនទាន់សរសេរចប់នៅឡើយទេ។

DRILL SEVEN: Substitution

MODEL: T: អាហ្នឹងសម្រាប់កិរិយាមារយាទទេតើ។ (ញ៉ាំជាមួយស្រា)
S: អាហ្នឹងសម្រាប់ញ៉ាំជាមួយស្រាទេតើ។
T: That one is only for good conduct. (eat with liquor)
S: That one is only for eating together with liquor.

ក. អាហ្នឹងសម្រាប់ញ៉ាំជាមួយស្រាទេតើ។ (សរសេរលេងសើច)
ខ. អាហ្នឹងសម្រាប់សរសេរលេងសើចទេតើ។ (ប្រពន្ធខ្ញុំ)
គ. អាហ្នឹងសម្រាប់ប្រពន្ធខ្ញុំទេតើ។ (ដាក់លើតុលោក)
ឃ. អាហ្នឹងសម្រាប់ដាក់លើតុលោកទេតើ។ (ប្រើក្នុងផ្ទះ)
ង. អាហ្នឹងសម្រាប់ប្រើក្នុងផ្ទះទេតើ។ (ក្មេងតូចៗ)
ច. អាហ្នឹងសម្រាប់ក្មេងតូចៗទេតើ។

DRILL EIGHT: Transformation

MODEL: T: លោកជាកូនទាហានល្អ។ (មេដាយ)
S: មេដាយនេះបញ្ជាក់ឲ្យឃើញថាលោកជាកូនទាហានល្អ។

T: You are a good soldier. (medal)

S: This medal shows that you are a good soldier.

ក. ខ្ញុំមិនអាចទៅស្រុកវិញ។ (សំបុត្រនេះ)
សំបុត្រនេះបញ្ជាក់ឲ្យឃើញថាលោកមិនអាចទៅស្រុកវិញ។

ខ. លោកត្រូវចូលធ្វើទាហានវិញ។ (ច្បាប់នេះ)
ច្បាប់នេះបញ្ជាក់ឲ្យឃើញថាលោកត្រូវចូលធ្វើទាហានវិញ។

គ. គេមិនចូលចិត្តអាមេរិកាំង។ (រាជការថ្មី)
រាជការថ្មីបញ្ជាក់ឲ្យឃើញថាគេមិនចូលចិត្តអាមេរិកាំង។

ឃ. ខ្ញុំត្រូវការលុយ។ (នេះ)
នេះបញ្ជាក់ឲ្យឃើញថាខ្ញុំត្រូវការលុយ។

ង. លោកជាមនុស្សល្អ។ (កំនិតមារយាទលោក)
កំនិតមារយាទលោកបញ្ជាក់ឲ្យឃើញថាលោកជាមនុស្សល្អ។

ច. កប៉ាល់ហោះនោះជាកប៉ាល់ហោះអាមេរិកាំង។ (សញ្ញានោះ)
សញ្ញានោះបញ្ជាក់ឲ្យឃើញថាកប៉ាល់នោះជាកប៉ាល់ហោះអាមេរិកាំង។

DRILL NINE: Response

MODEL: T: នេះបញ្ជាក់ឲ្យឃើញថាលោកជាកូនទាហានល្អ។
S: បាទ ខ្ញុំជាកូនទាហានល្អ។

T: This shows that you are a good soldier

S: Yes, I'm a good soldier.

ក. នេះបញ្ជាក់ឲ្យឃើញថាលោកមិនអាចទៅស្រុកវិញ។
បាទ ខ្ញុំមិនអាចទៅស្រុកវិញទេ។

ខ. នេះបញ្ជាក់ឲ្យឃើញថាលោកត្រូវចូលធ្វើទាហានវិញ។
បាទ ខ្ញុំត្រូវចូលធ្វើទាហានវិញ។

គ. នេះបញ្ជាក់ឲ្យឃើញថាគេចូលចិត្តអាមេរិកាំង។
បាទ គេចូលចិត្តអាមេរិកាំង។

ឃ. នេះបញ្ជាក់ឲ្យឃើញថាលោកត្រូវការលុយ។
បាទ ខ្ញុំត្រូវការលុយ។

ង. នេះបញ្ជាក់ឲ្យឃើញថាលោកជាមនុស្សល្អ។
បាទ ខ្ញុំជាមនុស្សល្អ។

ច. នេះបញ្ជាក់ឲ្យឃើញថាកប៉ាល់ហោះនោះជាកប៉ាល់ហោះអាមេរិកាំង។
បាទ កប៉ាល់ហោះនោះជាកប៉ាល់ហោះអាមេរិកាំង។

DRILL TEN: Substitution

MODEL: T: ទាហានទាំងអស់ត្រូវបានម្នាក់មួយៗ (យើង).
S: យើងទាំងអស់ត្រូវបានម្នាក់មួយៗ
T: All the soldiers must get one each. (us)
S: All of us must get one each.

ក. យើងទាំងអស់ត្រូវបានម្នាក់មួយៗ (ពីរ)
ខ. យើងទាំងអស់ត្រូវបានម្នាក់ពីរៗ (ញ៉ាំ)
គ. យើងទាំងអស់ត្រូវញ៉ាំម្នាក់ពីរៗ (កូនសិស្សទាំងអស់)
ឃ. កូនសិស្សទាំងអស់ត្រូវញ៉ាំម្នាក់ពីរៗ (ទិញ)
ង. កូនសិស្សទាំងអស់ត្រូវទិញម្នាក់ពីរៗ (មាន)
ច. កូនសិស្សទាំងអស់ត្រូវមានម្នាក់ពីរៗ

DRILL ELEVEN: Fill-In

Based on your knowledge of military and other terms fill the blank with the appropriate word(s). Note that the word in parentheses is just an example. There can be more than one word that you can use.

MODEL: T: ខ្ញុំទៅ ... ដើម្បីទិញបារីៗ
S: ខ្ញុំទៅហាងថ្នាំដើម្បីទិញបារីៗ
T: I go to .... in order to buy cigarettes.
S: I go to the (drug store) in order to buy cigarettes.

ក. កាលណាលោកជួបនាយទាហាន លោកត្រូវតែ...
កាលណាលោកជួបនាយទាហាន លោកត្រូវតែគំនាប់ៗ
ខ. យើងមិនអាចបាញ់បានយូរទៅទៀតទេព្រោះយើងជិតអស់... ហើយៗ
យើងមិនអាចបាញ់បានយូរទៅទៀតទេព្រោះយើងជិតអស់គ្រាប់ហើយៗ
គ. ទាហានត្រូវស្លៀកពាក់ ... ដើម្បីធ្វើការនៅក្នុងព្រៃៗ
ទាហានត្រូវស្លៀកពាក់ឯកសណ្ឋានដើម្បីធ្វើការនៅក្នុងព្រៃៗ
ឃ. លោកត្រូវឆែកមើល ... តើលោកមានសាំងគ្រប់គ្រាន់ទេៗ
លោកត្រូវឆែកមើលឡានតើលោកមានសាំងគ្រប់គ្រាន់ទេៗ
ង. មេបញ្ជាការហៅកប៉ាល់ហោះប្រតិកម្មឲ្យមក ... លើកន្លែងខ្មាំងៗ
មេបញ្ជាការហៅកប៉ាល់ហោះប្រតិកម្មឲ្យមកទម្លាក់គ្រាប់បែកលើកន្លែងខ្មាំងៗ
ច. ខ្មាំងបានឃោសនាថាគេបាញ់ ... ធ្លាក់ដប់ក្នុងមួយអាទិត្យៗ
ខ្មាំងបានឃោសនាថាគេបាញ់កប៉ាល់ហោះធ្លាក់ដប់ក្នុងមួយអាទិត្យៗ

DRILL TWELVE: Transformation

MODEL: T: អ្នកជំងឺរៀនដើរ។
S: អ្នកជំងឺរៀនដើរបន្តិចម្តងៗ។

T: The patient is learning to walk.

S: The patient is learning to walk little by little.

ក. ខ្ញុំយកអ្នករបួសក្នុងចំបាំងទៅពេទ្យ។
ខ្ញុំយកអ្នករបួសក្នុងចំបាំងទៅពេទ្យបន្តិចម្តងៗ។
ខ. ខ្ញុំយកការណ៍ពីខ្មាំង។
ខ្ញុំយកការណ៍ពីខ្មាំងបន្តិចម្តងៗ។
គ. ខ្ញុំលួចចូលទៅដីខ្មាំង។
ខ្ញុំលួចចូលទៅដីខ្មាំងបន្តិចម្តងៗ។
ឃ. ខ្ញុំញុះញង់អ្នកស្រុកឲ្យស្អប់ខ្មាំង។
ខ្ញុំញុះញង់អ្នកស្រុកឲ្យស្អប់ខ្មាំងបន្តិចម្តងៗ។
ង. ខ្មាំងបណ្តោយឲ្យអ្នករបួសស្លាប់។
ខ្មាំងបណ្តោយឲ្យអ្នករបួសស្លាប់បន្តិចម្តងៗ។

DRILL THIRTEEN: Substitution

MODEL: T: កាលណាយើងអស់គ្រាប់ យើងវាយទល់ដៃនិងដៃ។ (ដកថយ)
S: កាលណាយើងអស់គ្រាប់ យើងដកថយ។

T: When we ran out of ammunition we fought hand to hand. (retreat)

S: When we ran out of ammunition we retreated.

ក. កាលណាយើងអស់គ្រាប់ យើងដកថយ។ (ទម្លាយទ័ពខ្មាំងមិនបានទេ)
ខ. កាលណាយើងអស់គ្រាប់ យើងទម្លាយទ័ពខ្មាំងមិនបានទេ។ (ចាប់ខ្មាំងមិនបានទេ)
គ. កាលណាយើងអស់គ្រាប់ យើងចាប់ខ្មាំងមិនបានទេ។ (លបបាញ់)
ឃ. កាលណាយើងអស់គ្រាប់ យើងលបបាញ់។ (បំបែកក្រុម)
ង. កាលណាយើងអស់គ្រាប់ យើងបំបែកក្រុម។ (នឹងមានការខូចខាតធ្ងន់)
ច. កាលណាយើងអស់គ្រាប់ យើងនឹងមានការខូចខាតធ្ងន់។

DRILL FOURTEEN: Response

MODEL: T: ប្រទេសខ្មែរនៅឯណា? (ទ្វីបអាស៊ីផ្នែកអាគ្នេយ៍)
S: ប្រទេសខ្មែរនៅទ្វីបអាស៊ីផ្នែកអាគ្នេយ៍។
T: Where is Cambodia? (Southeast Asia)
S: Cambodia is in Southeast Asia.

ក. ប្រទេសលាវខាងជើងទល់និងប្រទេសអី? (ចិនក្រហម)
ប្រទេសលាវខាងជើងទល់និងប្រទេសចិនក្រហម។

ខ. ប្រទេសណានៅខាងកើតប្រទេសខ្មែរ? (យួនខាងត្បូង)
ប្រទេសយួនខាងត្បូងនៅខាងកើតប្រទេសខ្មែរ។

គ. រដ្ឋធានីប្រទេសខ្មែរឈ្មោះអី? (ភ្នំពេញ)
រដ្ឋធានីប្រទេសខ្មែរឈ្មោះភ្នំពេញ។

ឃ. ទន្លេអីហូរកាត់ប្រទេសខ្មែរ? (ទន្លេមេគង្គ)
ទន្លេមេគង្គហូរកាត់ប្រទេសខ្មែរ។

ង. ខាងលិចប្រទេសថៃឡង់ដជាប់និងប្រទេសណា? (ភូមា)
ខាងលិចប្រទេសថៃឡង់ដជាប់និងប្រទេសភូមា។

ច. ក្នុងប្រទេសឥណ្ឌូចិនប្រទេសណាគ្មានឆ្នេរសមុទ្រ? (លាវ)
ក្នុងប្រទេសឥណ្ឌូចិនប្រទេសលាវគ្មានឆ្នេរសមុទ្រ។

## Reading Passage

### ខ្ញុំត្រឡប់មកពីធ្វើសង្គ្រាមវិញ

នៅពេលមុនចេញទៅធ្វើសង្គ្រាម ទាហានទាំងអស់ ទាំងនាយទាហាន ទាំងកូនទាហាន គេបានទៅគ្រូខ្មែរដើម្បីឲ្យគាត់ស្រោចទឹក ហើយទាហានម្នាក់ៗ តែងតែមានកន្សែងយន្តដើម្បីការពារខ្លួនគេប្រឆាំងនិងសត្រូវ។ ចំណែកខ្ញុំវិញ ខ្ញុំក៏បានឲ្យគ្រូស្រោចទឹកហើយមានកន្សែងយន្តមួយដែរ ព្រោះខ្ញុំជឿដែរថា វាអាចធ្វើឲ្យខ្ញុំគ្មានគ្រោះថ្នាក់បាន។

ដោយសារកន្សែងយន្តនេះហើយ បានជាខ្ញុំនៅរស់បានត្រឡប់មកជួបឪពុកម្តាយបងប្អូនខ្ញុំ ហើយជាពិសេសរដ្ឋការនិងអ្នកស្រុកឯងបានធ្វើបុណ្យទទួលទាហានដែលទើបនឹងត្រឡប់មកពីធ្វើសង្គ្រាម។ រដ្ឋការមិនគ្រាន់តែទទួលទាហានយើងទេ គេបានធ្វើបុណ្យពិសេសមួយទៀតដើម្បីបំពាក់សក្តិ បំពាក់មេដាយដល់ទាហានច្រើនទៀត។ ខ្ញុំ ខ្ញុំមិនបានឡើងសក្តិដូចទាហានឯទៀតទេ តែខ្ញុំបានទទួលមេដាយពីរបីដែរ។

នៅថ្ងៃគេបំពាក់មេដាយឲ្យខ្ញុំ ឪពុកម្តាយខ្ញុំគាត់បានអញ្ជើញទៅដែរ។ គាត់សប្បាយចិត្តណាស់ព្រោះគាត់យល់ថាខ្ញុំបានបម្រើជាតិពេញជាកូនប្រុសមែន។ ខ្ញុំស្តាយណាស់ ខ្ញុំស្តាយពីព្រោះលោកប្រមុខរដ្ឋមិនបានមកបំពាក់មេដាយឲ្យខ្ញុំ ប៉ុន្តែត្រឡប់ទៅជាឪពុកខ្ញុំវិញដែលជាអ្នកបំពាក់មេដាយឲ្យខ្ញុំ។ ខ្ញុំយល់ថានេះជាកិត្តិយសមកដល់ខ្ញុំ ព្រោះថាឪពុកខ្ញុំជាអ្នកបង្កើតខ្ញុំ ជាកិត្តិយសដល់ឪពុកខ្ញុំព្រោះថាគាត់មានកូនប្រុសម្នាក់ដែលពេញជាកូនប្រុស ជាកិត្តិយសដល់គ្រួសារព្រោះថាជា

គ្រួសារមួយដែលគ្រួសារឯទៀតត្រូវធ្វើតាម ពីថាគេត្រូវបញ្ជូនកូនគេឲ្យទៅធ្វើចំបាំងដែរ ។

ថ្ងៃនោះខ្ញុំសប្បាយចិត្ត ខ្ញុំចង់តែត្រឡប់ទៅធ្វើសង្គ្រាមទៀតទេ តែតាមខ្ញុំយល់ ខ្ញុំបានបំរើជាតិខ្ញុំហើយ ខ្ញុំត្រូវទុកកន្លែងឲ្យប្រុសឯទៀតចូលធ្វើការខ្លះ ។

VOCABULARY

| | | |
|---|---|---|
| កសែងយន្ត | kəsaɛŋ yɔn | see note (R) |
| កិត្តិយស | kəttəyuoh | honor (R) |
| ក្រៅផ្លូវការ | kraw phləw kaa | unofficially |
| គំនិតមារយាទ | kənɨt məyiat | character, conduct |
| គ្រូ | kruu | see note (R) |
| ជាប់ | cóp | contiguous with |
| ញុះញង់ | ñuh ñuoŋ | to instigate, to incite |
| ដាច់ខែ | dac khaɛ | end of the month |
| ដើមខែ | daəm khaɛ | beginning of the month |
| តាមផ្លូវការ | taam phləw kaa | officially |
| ទល់ដៃនឹងដៃ | túl day nɨŋ day | hand-to-hand |
| នៅឡើយ | nɨw laəy | not yet at all |
| បង្កើត | pəkaət | to give birth to, to originate (R) |
| បញ្ជាក់ឲ្យឃើញថា | pəcéʔ aoy khəəñ thaa | to prove that |
| បុណ្យ | bon | ceremony |
| ប៊ុយរ៉ូ | pərou | office |
| បំពាក់ | pəmpéʔ | to decorate (to put on a medal), to put |
| ប្រាក់ខែ | praʔ khaɛ | salary, wage |
| ប្រុងប្រៀប | proŋ priep | to get ready |
| ពលបាល | púl ləbaal | sergeant |
| ពេញជាកូនប្រុស | pɨñ cia koun proh | meets all the expectations of a male child (R) |
| ភូមា | phuumia | Burma |
| មេដាយ | meeday | medal |
| រដ្ឋធានី | rót thianii | capital city (of a republic) |
| រាជធានី | riac thianii | capital city (of a monarchy) |
| សញ្ញា | saññaa | sign |
| ស្រោចទឹក | sraoc tɨk | to sprinkle water (R) |
| អាគ្នេយ៍ | aaʔkənee | southeast |
| អាស៊ីផ្នែកអាគ្នេយ៍ | aasii phnaɛk aaʔkənee | Southeast Asia |
| ឥណ្ឌូចិន | əndoucən | Indochina |

## LESSON FIFTY-EIGHT

## DIALOGUE

| | | | |
|---|---|---|---|
| | | អំពី | about |
| ១. | កុម | ខ្ញុំចង់ធ្វើការរាយការណ៍អំពីយប់មិញ ។ | I want to make a report about last night. |
| | | ពិនិត្យ | to observe, to examine, to inspect |
| | | ស្ថានការណ៍ | situation |
| ២. | សុខ | បាទ លោកបានពិនិត្យស្ថានការណ៍នោះហើយ ឃើញយ៉ាងម៉េចខ្លះ? | Yes, you observed that situation; what do you think? |
| | | ភាគច្រើន | the majority |
| | | ច្រើនតែ | mostly |
| ៣. | កុម | ខ្មាំងភាគច្រើនតែត្រឡប់ចូលទៅក្នុងព្រំដែនស្រុកខ្មែរវិញ ។ | The majority of the enemy have returned to within the Cambodian border. |
| | | រាប់ | to count |
| | | ចំនួន | number, quantity |
| ៤. | សុខ | ចុះលោកបានរាប់ចំនួនខ្មាំងទេ? | Did you count the enemy? |
| ៥. | កុម | ទេលោក ខ្ញុំរកតែធ្វើអ្វីមិនបានដែរ ព្រោះខ្ញុំនៅជិតផ្លូវពេក ។ | No sir, I couldn't do anything, because I went too close to the street. |
| | | យ៉ាងណាក៏ដោយ | anyway, nevertheless |
| | | យោបល់ | opinion, idea, thought |
| | | បញ្ហា | problem, trouble |
| ៦. | សុខ | ខ្ញុំស្តាយណាស់ តែយ៉ាងណាក៏ដោយ លោកមានយោបល់យ៉ាងម៉េចអំពីបញ្ហានេះ? | That's too bad. But anyway, what's your opinion about this problem? |
| ៧. | កុម | បាទ យើងត្រូវតែការពារកុំឲ្យខ្មាំងចូលមកវិញបាន ។ | We have to prevent the enemy from coming back. |
| | | គ្រប់គ្រាន់ | enough, sufficient |
| ៨. | សុខ | លោកមានទាហានគ្រប់គ្រាន់ទេ? | Do you have enough men? |
| ៩. | កុម | មិនខ្វះទេ លោក ។ | (I have) plenty, sir. |

DIALOGUE:

1. tom - khñom coŋ thəə kaa riey kaa əmpii yup mɛñ

2. sok - baat, look baan pənɨt səthaankaa nuh khəəñ yaaŋ mɛc khlah?

3. tom - khmaŋ phiaʔ craən craən taɛ təlóp coul tɨw knoŋ prún daɛn srok khmaɛ viñ

4. sok - coh look baan róp cənuon khmaŋ tee?

5. tom - tee look, knñom róo taɛ thəə ɛy kɔɔ mɨn baan phɔɔŋ prúh khñom tɨw cɨt phləw peek

6. sok - khñom sdaay nah taɛ yaaŋ naa kɔɔ daoy look mian yóobɔl yaaŋ mɛc əmpii paññəhaa nih?

7. tom - baat, yəəŋ trəw taɛ kaapia kom aoy khmaŋ coul móo viñ baan

8. sok - look mian təhian krup krón tee?

9. tom - mɨn khvah tee, look

DIALOGUE

NOTES

SENTENCE NO.

7. The formula verb + កុំឲ្យ /kom aoy/ + clause is translated '...so that... not...,' e.g.,

យើងពួនកុំឲ្យវាឃើញយើងលួចផ្ទះវា។

yəəŋ puon kom aoy via khəəñ yəəŋ luoc phtéh via

We hid so he wouldn't see us stealing from his house.

DRILLS

DRILL ONE: Substitution

MODEL: T: ខ្ញុំចង់ធ្វើការរាយការណ៍អំពីយប់មិញ។ (និយាយ - រឿងកុន)

S: ខ្ញុំចង់និយាយអំពីរឿងកុន។

T: I want to make a report about last night. (talk - the plot of a movie)

S: I want to talk about the plot of a movie.

ក. ខ្ញុំចង់និយាយអំពីរឿងកុន។ (សរសេរសំបុត្រ - គ្រូសាលាខ្ញុំ)
ខ. ខ្ញុំចង់សរសេរសំបុត្រអំពីគ្រូសាលាខ្ញុំ។ (សៀវភៅ)
គ. ខ្ញុំចង់សរសេរសៀវភៅអំពីគ្រូសាលាខ្ញុំ។ (មើល - គ្រូសាលាលោក)
ឃ. ខ្ញុំចង់មើលសៀវភៅអំពីគ្រូសាលាលោក។ (ស្រុកខ្មែរ)
ង. ខ្ញុំចង់មើលសៀវភៅអំពីស្រុកខ្មែរ។ (ទិញ - លោកប្រធានាធិបតី)
ច. ខ្ញុំចង់ទិញសៀវភៅអំពីលោកប្រធានាធិបតី។

DRILL TWO: Transformation

MODEL: T: ពីម្សិលមិញខ្ញុំឃើញគ្រោះថ្នាក់មួយ។ (រាយការណ៍)
S: ពីម្សិលមិញខ្ញុំរាយការណ៍អំពីគ្រោះថ្នាក់មួយ។
T: Yesterday I saw an accident. (to report)
S. Yesterday I made a report about an accident.

ក. ថ្ងៃនេះខ្ញុំទទួលសំបុត្រពីគ្រួសារមួយ។ (សរសេរសៀវភៅ)
ថ្ងៃនេះខ្ញុំសរសេរសៀវភៅអំពីគ្រួសារមួយ។
ខ. យប់មិញខ្ញុំទៅមើលកុនមួយ។ (និយាយ)
យប់មិញខ្ញុំនិយាយអំពីកុនមួយ។
គ. គ្រូពេទ្យដកធ្មេញ។ (ពន្យល់)
គ្រូពេទ្យពន្យល់អំពីធ្មេញ។
ឃ. ស្អែកខ្ញុំពន្យល់ស្ថានការណ៍ស្រុកខ្មែរ។ (និយាយ)
ស្អែកខ្ញុំនិយាយអំពីស្ថានការណ៍ស្រុកខ្មែរ។
ង. ថ្ងៃហ្នឹងយើងមើលផ្កាយ។ (រៀន)
ថ្ងៃហ្នឹងយើងរៀនអំពីផ្កាយ។
ច. ថ្ងៃនេះខ្ញុំមានគ្រោះថ្នាក់មួយ។ (សរសេរ)
ថ្ងៃនេះខ្ញុំសរសេរអំពីគ្រោះថ្នាក់មួយ។

DRILL THREE: Transformation

MODEL: T: ខ្មាំងចូលទៅក្នុងព្រំដែនខ្មែរវិញ។
S: ខ្មាំងភាគច្រើនៗតែចូលទៅក្នុងព្រំដែនខ្មែរ។
T: The enemy goes back to within the Cambodian border.
ε S: The majority of the enemy go back to within the Cambodian border.

ក. កូនសិស្សរៀនភាសាយួន។
កូនសិស្សភាគច្រើនៗតែរៀនភាសាយួន។
ខ. កូនសិស្សខ្មែរទៅរៀនស្រុកបារាំង។
កូនសិស្សខ្មែរភាគច្រើនៗតែទៅរៀនស្រុកបារាំង។
គ. ឡានធ្វើនៅស្រុកអាមេរិក។
ឡានភាគច្រើនៗតែធ្វើនៅស្រុកអាមេរិក។
ឃ. ខ្មែរមិនចូលចិត្តរៀនភាសាអង់គ្លេស។
ខ្មែរភាគច្រើនៗតែមិនចូលចិត្តរៀនភាសាអង់គ្លេស។
ង. ស្រីអាមេរិកាំងចូលចិត្តញ៉ាំស្រា។
ស្រីអាមេរិកាំងភាគច្រើនៗតែចូលចិត្តញ៉ាំស្រា។
ច. ស្រីខ្មែរមិនញ៉ាំបារីទេ។
ស្រីខ្មែរភាគច្រើនៗតែមិនញ៉ាំបារីទេ។

DRILL FOUR: Substitution

MODEL: T: ខ្ញុំរកតែធ្វើអីក៏មិនបានផង។ (ញ៉ាំអី)

S: ខ្ញុំរកតែញ៉ាំអីក៏មិនបានផង។

T: I can't do anything. (eat anything)

S: I can't eat anything.

ក. ខ្ញុំរកតែញ៉ាំអីក៏មិនបានផង។ (បោសគ្រាប់បែកដៃ)
ខ. ខ្ញុំរកតែបោសគ្រាប់បែកដៃក៏មិនបានផង។ (ដំឡើងកាំភ្លើងយន្ត)
គ. ខ្ញុំរកតែដំឡើងកាំភ្លើងយន្តក៏មិនបានផង។ (យើង)
ឃ. យើងរកតែដំឡើងកាំភ្លើងយន្តក៏មិនបានផង។ (ដងទឹក)
ង. យើងរកតែដងទឹកក៏មិនបានផង។ (បំបែក)
ច. យើងរកតែបំបែកទឹកក៏មិនបានផង។

DRILL FIVE: Transformation

MODEL: T: ខ្ញុំមិនបានធ្វើអីទេ។

S: ខ្ញុំស្តាយណាស់ ខ្ញុំរកតែធ្វើអីក៏មិនបានផង។

T: I have not been able to do anything.

S: I'm sorry, I couldn't do anything.

ក. ខ្ញុំមិនបានរៀនទេ។
ខ្ញុំស្តាយណាស់ ខ្ញុំរកតែរៀនក៏មិនបានផង។
ខ. ខ្ញុំមិនបានទៅលេងលោកទេ។
ខ្ញុំស្តាយណាស់ ខ្ញុំរកតែទៅលេងលោកក៏មិនបានផង។
គ. ខ្ញុំមិនបានមើលសៀវភៅទេ។
ខ្ញុំស្តាយណាស់ ខ្ញុំរកតែមើលសៀវភៅក៏មិនបានផង។
ឃ. ខ្ញុំមិនបានដេកថ្ងៃទេ។
ខ្ញុំស្តាយណាស់ ខ្ញុំរកតែដេកថ្ងៃក៏មិនបានផង។
ង. ខ្ញុំមិនបានសរសេរសំបុត្រទេ។
ខ្ញុំស្តាយណាស់ ខ្ញុំរកតែសរសេរសំបុត្រក៏មិនបានផង។
ច. ខ្ញុំមិនបានទៅជួបគាត់។
ខ្ញុំស្តាយណាស់ ខ្ញុំរកតែជួបគាត់ក៏មិនបានផង។

DRILL SIX: Substitution

MODEL: T: លោកមានយោបល់យ៉ាងម៉េចអំពីបញ្ហានេះ? (ស្រុកខ្មែរ)

S: លោកមានយោបល់យ៉ាងម៉េចអំពីស្រុកខ្មែរ?

T: What is your opinion about this problem? (Cambodia)

S: What is your opinion about Cambodia?

ក. លោកមានយោបល់យ៉ាងម៉េចអំពីស្រុកខ្មែរ? (កុនដែលលោកមើល)
ខ. លោកមានយោបល់យ៉ាងម៉េចអំពីកុនដែលលោកមើល? (ភាសាខ្មែរ)
គ. លោកមានយោបល់យ៉ាងម៉េចអំពីភាសាខ្មែរ? (កូនសិស្សលោក)
ឃ. លោកមានយោបល់យ៉ាងម៉េចអំពីកូនសិស្សលោក? (ថ្នាក់រៀននេះ)
ង. លោកមានយោបល់យ៉ាងម៉េចអំពីថ្នាក់រៀននេះ? (គំរោងការនេះ)
ច. លោកមានយោបល់យ៉ាងម៉េចអំពីគំរោងការនេះ?

DRILL SEVEN: Response

MODEL: T: ខ្ញុំមានទាហានប្រាំក្រុម។
S: លោកមានទាហានគ្រប់គ្រាន់ទេ?
T: I have five squads of men.
S: Do you have enough men?

| | |
|---|---|
| ក. ខ្ញុំមានលុយតែដប់ដុល្លាទេ។ | លោកមានលុយគ្រប់គ្រាន់ទេ? |
| ខ. យើងមានសាំងតែថ្ងៃស្អែកទេ។ | យើងមានសាំងគ្រប់គ្រាន់ទេ? |
| គ. គេមានកៅអីតែមួយរយទេ។ | គេមានកៅអីគ្រប់គ្រាន់ទេ? |
| ឃ. ទាហានយើងមានគ្រាប់ខ្វះ។ | ទាហានយើងមានគ្រាប់គ្រប់គ្រាន់ទេ? |
| ង. ខ្ញុំមានកន្លែងតែបីទេ។ | លោកមានកន្លែងគ្រប់គ្រាន់ទេ? |
| ច. ក្រុមខ្ញុំមានកាំភ្លើងតែសាមសិបដើមទេ។ | ក្រុមលោកមាន កាំភ្លើងគ្រប់គ្រាន់ទេ? |

DRILL EIGHT: Response

MODEL: T: ខ្ញុំមានទាហានប្រាំក្រុម។
S: ទាហានប្រាំក្រុមគ្រប់គ្រាន់ទេ?
T: I have five squads of men.
S: Are five squads of men enough?

| | |
|---|---|
| ក. ខ្ញុំមានលុយដប់ដុល្លា។ | លុយដប់ដុល្លាគ្រប់គ្រាន់ទេ? |
| ខ. យើងមានសាំងថ្ងៃស្អែក។ | សាំងថ្ងៃស្អែកគ្រប់គ្រាន់ទេ? |
| គ. គេមានកៅអីមួយរយ។ | កៅអីមួយរយគ្រប់គ្រាន់ទេ? |
| ឃ. ទាហានយើងមានគ្រាប់បីហិប។ | គ្រាប់បីហិបគ្រប់គ្រាន់ទេ? |
| ង. ក្រុមយើងមានកាំភ្លើងសាមសិបដើម។ | កាំភ្លើងសាមសិបដើមគ្រប់គ្រាន់ទេ? |
| ច. ខ្ញុំមានស្រាមួយដប។ | ស្រាមួយដបគ្រប់គ្រាន់ទេ? |

DRILL NINE: Transformation

MODEL: T: វៀតកុងប្រើដីស្រុកខ្មែរ។ (យើង)
S: យ៉ាងណាក៏ដោយយើងមិនឲ្យវៀតកុងប្រើដីស្រុកខ្មែរទេ។
T: The Viet Cong use Cambodian soil. (we)
S: In any case we do not let the Viet Cong use Cambodian soil.

ក. ខ្ញុំទៅផ្ទះម៉ោងបី។ (លោកគ្រូ)
យ៉ាងណាក៏ដោយ លោកគ្រូមិនឲ្យខ្ញុំទៅផ្ទះម៉ោងបីទេ។
ខ. ខ្ញុំខ្ចីលុយ។ (បងឯក)
យ៉ាងណាក៏ដោយ បងឯកមិនឲ្យខ្ញុំខ្ចីលុយទេ។
គ. ប្រពន្ធខ្ញុំបើកឡាន។ (ខ្ញុំ)
យ៉ាងណាក៏ដោយ ខ្ញុំមិនឲ្យប្រពន្ធខ្ញុំបើកឡានទេ។
ឃ. ខ្ញុំយកសៀវភៅទៅផ្ទះ។ (លោកគ្រូ)
យ៉ាងណាក៏ដោយ លោកគ្រូមិនឲ្យខ្ញុំយកសៀវភៅទៅផ្ទះទេ។
ង. ខ្ញុំទិញកាំភ្លើង។ (រាជការ)
យ៉ាងណាក៏ដោយ រាជការមិនឲ្យខ្ញុំទិញកាំភ្លើងទេ។
ច. លោកចេញពីស្រុកខ្មែរ។ (ប៉ូលិស)
យ៉ាងណាក៏ដោយ ប៉ូលិសមិនឲ្យលោកចេញពីស្រុកខ្មែរទេ។

DRILL TEN: Response

MODEL: T: លោកមានទាហានគ្រប់គ្រាន់ទេ? (ត្រូវការប៉ុន្មានក្រុម)
S: មិនខ្វះទេ លោកត្រូវការទាហានប៉ុន្មានក្រុម?
T: Do you have enough men? (need how many squads )
S: Plenty; how many squads do you need?

ក. លោកមានលុយទេ? (ចង់ខ្ចីប៉ុន្មាន)
មិនខ្វះទេ លោកចង់ខ្ចីលុយប៉ុន្មាន?
ខ. លោកមានគ្រាប់កាំភ្លើងទេ? (ត្រូវការប៉ុន្មានហិប)
មិនខ្វះទេ លោកត្រូវការគ្រាប់កាំភ្លើងប៉ុន្មានហិប?
គ. លោកមានកាំភ្លើងទេ? (ត្រូវការកាំភ្លើងប៉ុន្មានដើម)
មិនខ្វះទេ លោកត្រូវការកាំភ្លើងប៉ុន្មានដើម?
ឃ. លោកមានអាវដៃខ្លីទេ? (ចង់ទិញប៉ុន្មាន)
មិនខ្វះទេ លោកចង់ទិញប៉ុន្មាន?
ង. លោកមានសៀវភៅទេ? (ចង់បានប៉ុន្មាន)
មិនខ្វះទេ លោកចង់បានប៉ុន្មាន?
ច. លោកមានបារីទេ? (ចង់បានប៉ុន្មាន)
មិនខ្វះទេ លោកចង់បានប៉ុន្មាន?

DRILL ELEVEN: Choice

MODEL: T: គេយកអ្នករបួសទៅក្នុង... ។ (បន្ទាយ - មន្ទីរពេទ្យ)
S: គេយកអ្នករបួសទៅក្នុងមន្ទីរពេទ្យ។
T: They take the wounded into ....... (barracks, hospital)
S: They take the wounded into the hospital.

ក. យើងបើកឡានឆ្លង ... តម្រង់ទៅកន្លែងខ្មាំង។ (ព្រែកជីក - វាលសមរភូមិ)
យើងបើកឡានឆ្លងវាលសមរភូមិតម្រង់ទៅកន្លែងខ្មាំង។
ខ. កងអនុសេនាតូច ... ពួកខ្មាំង។ (ជួយទ្រទ្រង់ - ស្ទាក់វាយ)
កងអនុសេនាតូចស្ទាក់វាយពួកខ្មាំង។
គ. ក្រុមទាហានយើង ... កាំភ្លើងជាច្រើនដើមនៅពេលខ្មាំងបាញ់មរ័ចេមកលើបន្ទាយយើង។ (ចាប់បាន - ខូចខាត)
ក្រុមទាហានយើងខូចខាតកាំភ្លើងជាច្រើនដើមនៅពេលខ្មាំងបាញ់មរ័ចេមកលើបន្ទាយយើង។
ឃ. ក្រោយពីបេសកកម្មយកការណ៍គេ ... ដើម្បីធ្វើការវាយការណ៍អំពីផែនការថបាំង។ (ជុំគ្នា - បញ្ជា)
ក្រោយពីបេសកកម្មយកការណ៍គេជុំគ្នាដើម្បីធ្វើការវាយការណ៍អំពីផែនការថបាំង។
ង. ក្នុងការ ... ឯកព្រំដែនខ្មែរ-យួន គេបានសម្លាប់ពួកខ្មាំងជាច្រើន។ (ប្រតិបត្តិការ - លានការណ៍)
ក្នុងការប្រតិបត្តិការឯកព្រំដែនខ្មែរ-យួន គេបានសម្លាប់ពួកខ្មាំងជាច្រើន។

DRILL TWELVE: Response

MODEL:
T: មុនចេញទៅធ្វើការប្រតិបត្តិការលោកត្រូវផ្ទៀងនាឡិកានឹងខ្ញុំ។
S: ខ្ញុំបំរុងផ្ទៀងជាមួយលោកដែរបើលោកមិនប្រាប់ខ្ញុំ។

T: Before you go on the operation, you must synchronize your watch with mine.

S: I intended to synchronize my watch with yours even if you didn't tell me.

ក. មុនបើកឡានចេញទៅលោកត្រូវចាក់សាំងបំពេញ។
ខ្ញុំបំរុងចាក់សាំងបំពេញដែរបើលោកមិនប្រាប់ខ្ញុំ។
ខ. មុនយកកាំភ្លើងចេញពីឃ្លាំងលោកត្រូវសួរលោកសក្ដិពីរ។
ខ្ញុំបំរុងសួរលោកសក្ដិពីរដែរបើលោកមិនប្រាប់ខ្ញុំ។
គ. មុនវាយសម្រុកចូលលោកត្រូវហៅមន្ត្រីចាត់ការ។
ខ្ញុំបំរុងហៅមន្ត្រីចាត់ការដែរបើលោកមិនប្រាប់ខ្ញុំ។
ឃ. មុនទៅថ្ងៃហៀងភូមិនោះលោកត្រូវបញ្ជាក់ស្ទួរខ្ញុំ។
ខ្ញុំបំរុងបញ្ជាក់ស្ទួរលោកដែរបើលោកមិនប្រាប់ខ្ញុំ។
ង. មុនបាញ់កាំភ្លើងធំលោកត្រូវវាស់ចម្ងាយពីនេះទៅទីខ្មាំង។
ខ្ញុំបំរុងវាស់ចម្ងាយពីនេះទៅទីខ្មាំងដែរបើលោកមិនប្រាប់ខ្ញុំ។
ច. មុនដើរចូលក្នុងវាលស្រែនោះលោកត្រូវពិនិត្យមើលអង្គប់ខ្មាំង។
ខ្ញុំបំរុងពិនិត្យមើលអង្គប់ខ្មាំងដែរបើលោកមិនប្រាប់ខ្ញុំ។

DRILL THIRTEEN: Transformation

MODEL: T: លោកវរសេនីយត្រីនិយាយជាមួយលោកសក្តិបី។ (សក្តិបី)
S: លោកវរសេនីយត្រីនិយាយជាមួយអ្នកណា?
T: The major is talking to the captain. (captain)
S: To whom is the major talking?

ក. គេនិយាយពីស្ថានការណ៍ផ្ទៃចំបាំង។ (ស្ថានការណ៍ផ្ទៃចំបាំង)
គេនិយាយអំពីអ្វី?

ខ. លោកវរសេនីយត្រីនឹងដាក់ទ័ពនៅក្បែរជើងភ្នំ។ (ក្បែរជើងភ្នំ)
លោកវរសេនីយត្រីនឹងដាក់ទ័ពនៅឯណា?

គ. មុនដំបូងគាត់បញ្ជាឲ្យកងទ័ពកាំភ្លើងធំបាញ់ទៅលើទីតាំង។ (កាំភ្លើងធំ)
មុនដំបូងគាត់នឹងបញ្ជាឲ្យអ្នកណា (កងទ័ពណា) បាញ់ទៅលើទីតាំង?

ឃ. កងកាំភ្លើងធំត្រូវវាស់ចម្ងាយកន្លែងតាំង។ (វាស់ចម្ងាយកន្លែងតាំង)
កងកាំភ្លើងធំត្រូវធ្វើអ្វី?

ង. គេនឹងបាញ់បីគ្រាប់ក្នុងមួយមិនុត។ (បី)
គេនឹងបាញ់ប៉ុន្មានគ្រាប់ក្នុងមួយមិនុត?

Reading Passage

## ឈ្លើយសង្គ្រាមយើង

ស- ឥឡូវអ្នកឯងត្រូវនិយាយប្រាប់យើងអំពីការសម្ងាត់របស់ក្រុមអ្នកឯងទាំងអស់។ មុនដំបូងអ្នកឯងត្រូវប្រាប់ឈ្មោះអ្នកឯងសិន។

ឆ- បាទ ខ្ញុំបាទឈ្មោះចៅឃិន។

ស- ហឺ! ឈ្មោះនេះដូចជាឈ្មោះយួន។ អ្នកឯងជាយួនពួកវៀតកុង មែនទេ?

ឆ- ទេលោក! ខ្ញុំជាជាតិខ្មែរ ជាខ្មែរសុទ្ធ ហើយខ្ញុំគ្មានការទាក់ទងអ្វីនឹងពួកវៀតកុងទេ។ សូមលោកជឿខ្ញុំចុះ។

ស- អញ្ចឹង! បើមិនមែនពួកវៀតកុង អ្នកឯងជាខ្មែរក្រហមដែលចូលដៃនឹងអាពួកវៀតកុង។ នៅពេលដែលទាហានខ្មែរចាប់អ្នកឯងបាន អ្នកឯងកំពុងដើរទៅណា មានកន្ត្រកនេះនៅដៃផង?

ឆ- ខ្ញុំបានប្រាប់លោកហើយថាខ្ញុំជាខ្មែរ ខ្ញុំមិនមែនជាទាហានខ្មែរក្រហមប្រុងចូលដៃនឹងវៀតកុងទេ។

ស- ហឺ! នៅតែដដែក រឹងក្បាលទៀតហ្ន?
ចុះស្អីនេះនៅក្នុងកន្ត្រក? អ្នកឯងយកគ្រាប់បែកនេះទៅណា?

ឆ- បាទ! មិនមែនគ្រាប់បែកទេ អ្នកណាយកមកដាក់ក្នុងកន្ត្រកខ្ញុំទេ ខ្ញុំមិនដឹងទេ។

ស- ហឺ! អាឯងនេះនៅប្រកែកទៀត មើល៍ឲ្យទឹកត្រីមកខ្ញុំ ប្រហែលវាចង់ផឹកទឹកត្រីហើយមើល៍ទៅ ហើយយកទឹកឲ្យមួយប៉ោតមកផង។

ឆ- ទេលោកទេ! ចាំខ្ញុំប្រាប់ឲ្យត្រង់កុំវាយធ្វើបាបខ្ញុំទៀត។

ស- បុង! ឥឡូវស្ពានមួយណាដែលអ្នកឯងចង់ទៅបំផ្លាញ?

ឈ- បាទ គេឲ្យខ្ញុំបំផ្លាញស្ពានមុនិរង្ស...
ស- អ្នកណា 'គេ' នោះ? អ្នកឯងមានគ្នាប៉ុន្មាននាក់?
ឈ- បាទ មានគ្នាបួននាក់ តែគេបានឲ្យខ្ញុំកាន់កន្ត្រកដើរមកមុនដើម្បីកុំឲ្យគេសង្ស័យ។
ស- ឥឡូវគ្នាអ្នកឯងនៅឯណា? ហើយអាណាប្រើអ្នកឯងឲ្យមកបំផ្លាញស្ពាននេះ? អ្នកឯងមិនដឹងថាគេសង់ស្ពាននេះអស់លុយរាប់លានរៀលទេឬ?
ឈ- បាទ ខ្ញុំមិនបាច់ប្រាប់ថាអ្នកណាទេ ព្រោះលោកដឹងស្រាប់ហើយ។ ឥឡូវសូមលោកកុំធ្វើបាបខ្ញុំទៀត ខ្ញុំនឹងប្រាប់រឿងសម្ងាត់ទាំងអស់ដែលខ្ញុំដឹង។
ស- បុង! ឥឡូវយកម៉ាស៊ីនថតសម្លេងមកហើយថតសម្លេងវាទុក។

VOCABULARY

| | | |
|---|---|---|
| កន្ត្រក | kətroʔ | market basket (R) |
| ក្រុមកាំភ្លើងធំ | krom kəphləəŋ thom | artillery squad (L) |
| គំរោងការ | kərouŋkaa | plan, plot |
| គ្រប់គ្រាន់ | krup krón | enough, adequate |
| ចោល | caol | to throw, to abandon |
| ចំនួន | cənuon | number, quantity |
| ជំហៀងភ្នំ | cəhieŋ | hillside |
| ឆ្លាត | chlaat | clever, smart (L) |
| ជជែក | cəceek | to discuss (R) |
| ដំឡើង | təlaəŋ | to mount, assemble |
| ទ្រទ្រង់ | tróo tróŋ | to support |
| ធម៌ក្តៅ | thóa kdaw | toughness, strictness (restricted usage) (L) |
| បញ្ហា | paññəhaa | problem |
| បុង | boŋ | 'good' (French bon) (R) |
| បេសកកម្ម | pehsəkaʔkam | mission |
| ប៉ោត | paot | a metal container about the size of a gasoline can (R) |
| បំបែក | pəbaɛk | to break (transitive) |
| ប៉ង | mroŋ | to intend (L) |
| ប្រកែក | pəkaɛk | to refuse, to argue back (R) |
| ប្រតិបត្តិការ | prəteʔbatkaa | operation |
| ផែនការ | phaɛn kaa | plan |
| ផ្តុំ | phdom | to assemble, to gather |
| ផ្ទៀង | phtieŋ | to make certain, to synchronize |
| ពិនិត្យ | pənit | to observe, to inspect |
| ព្រែក | preek | stream, creek |

| | | |
|---|---|---|
| ព្រែកជីក | preek ciik | canal |
| ភាគច្រើនៗតែ | phiaʔ craən craən taɛ | the majority |
| មន្ទីរពេទ្យ | məntii pɛɛt | hospital |
| ម៉ាស៊ីនថតសំឡេង | məsɨn thɔɔt səmleeŋ | tape recorder (R) |
| មិនខ្វះទេ | min khvah tee | plenty |
